ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES
បណ្ណាល័យ LIBRARY BUDDHIST INSTITUTE
០៧

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយជំនឿខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកជំនឿសាសនាៈ ព្រះគ្រូសុវណ្ណញាណ សូរ-ហាយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

ទំព័រ

### ផ្នែកអក្សរសាស្ត្រ

គេកក ហេង-យ៉ាន់ ...... កំពូលស្នេហា (រឿងប្រលោមលោក) ..... ១
ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម ... ឯកសហស្សរាត្រី ........... ១៦
ឧកញ៉ាទេពពិទូរ-ក្រសេម ... ប្រវត្តិស្ដេចទឹកស្ដេចភ្លើង (តមកនឹងចប់) ... ២៣
" " " វណ្ណគតិ នារាយណ៍ ទសាវតារ (តមកនឹងចប់) ៣៨

### ផ្នែកសាសនា

ឃុនសុវត្ថិវេទី យូរ-អុន .... មិច្ឆាទិដ្ឋិកថា ............ ៤៩

ឆ្នាំទី ១៨ – លេខ ១ ខែយ៉ាំងវីយេ ១៩៤៦– ថ្លៃជាវ : ១ ឆ្នាំ ៣៥ រៀល ។

# កំពូលស្នេហា

លោក ហេង-យ៉ាន់ រៀបរៀង

## វគ្គទី ១

## បុរសកំសត់ម្នាក់

ព្រះអាទិត្យជ្រៀងជ្រេទេរទ្រេតៗ ទៅទិសបស្ចិម ទៀបហៀបនឹងធុះផុតព្រៃទៅហើយ មានខ្យល់រំភើយៗ ផាយផាត់ទឹក ទន្លេលកបក្ដាញ់សស្រាញ់តាមក្រោមស្ពានមួយ នៅចុងមាត់ញកខ្នងក្រុងព្រៃនគរ ទីនោះស្ងាត់ឈឹងស្ងួនឥតមនុស្សម្នាដើរម្នាក់ មើលទៅខាងមុខឃើញតែកលស្រែដ៏ក្រៀមក្រោះកលល្វឹង ខាងម្ខាងសុទ្ធតែព្រៃល្បោះជាទីអាស្រ័យនៅនៃបក្សីជាតិត្របែកដំពូក ដែលពោលសំឡេងស្មូរពិរោះគួរឲ្យរន្ធត់ ។

នៅលើស្ពាននោះ មានកុមារម្នាក់ស្លៀកពាក់ចុលកាពតន់ពេកណាស់ គឺខោខ្វក់កញ្ចាស់មួយនឹងអាវទ្រនាប់រៀលខ្មៀក ឈរសញ្ជប់សញ្ជឹងនៅតែមួយឯងតែខ្លួនឯងកណ្ដាលយ៉ាងស្រងូតស្រងាត់ ដៃទាំងពីរច្រត់លើបង្កាន់ដៃស្ពាន ពោលភ្នែកមើលទឹកហូរសស្រឹមទៅឆ្ងាយ កុមារនោះមានរាងកាយតូចស្ដើងសម្បុរសស្អាត ប៉ុន្តែជាទឹកមុខស្រពោនស្រពន់ពុំស្រស់ដូចម្ដេចក៏ គន់មើលលក្ខណៈឲ្យច្បាស់ទៅក៏ឃើញថាជាអ្នកមិនធ្លាប់នឿយព្រួយលំបាកពីដើមមកឡើយ មុខស្រួង ថ្ពាស ខ្លាយជាអ្នកបេះតិតគួរ ចិញ្ចើមក្រាស់កងកាច់ផ្ទុង ឯភ្នែកនោះជ្រៅ

ដូចអណ្តែតខ្លួនក្បាលទៅកង ព្រោះអត់ងងុយជាច្រើនយប់មកហើយ មាន ពេលខ្លះដែលបាញ់ទៀងលើធ្មេញយំសស់ទៀង ចេមុះនិងស្រពាប់ បប្រួរ គាត់ស្ទើងជាអ្នកជាងសំដី ដ្ឋាមធំជាលក្ខណៈអ្នកមានបុនបានសុភស្មក កនិយាក្រមាណោស្រុកាពលមស្តណាប់ បង្ហាស់ជាកូនអ្នកមានត្រកូល ខ្ពង់ខ្ពស់ ។

បន្តរ ។ លោកក៏ក្រផែកដង្ហើមធំម្តងៗ រនិងដូចជាចង់សោយទុក្ខឲ្យ ធ្លាក់ចេញពីដួមច្រើក គិតណាស់ជាណាស់ទៅមិនដាច់ស្រេចក្នុងចិត្ត កុមារនោះសំឡឹងមើលចង្កៀងឥស្សរៈណេត្រៀង ដែលគាត់ទីនដៃយ៉ាង លោកសង្ហារ ព្រោះចង់យកចង្កៀងនោះទៅលក់ដើម្បីបានជាបានត្រាំទ ពិពិធក្រុមកែតទៅមុខទៀត ឯនោះក៏ឃ្លានខ្លាំង តែទឹកស្លាបរក្លែងបាន ពេលខ្លះខ្លួនគត ។

ពេលនោះស្ងាយថ្ងៃកុមារនោះទើបនឹងទឹកភ្នែកទង់ស្ងួរលោកក្មេកលើ ប្រាំ ឲ្យកុមារនោះទឹកភ្នែកហូរព្រោះកាត់ដែលទើបនឹងធ្លាក់ដល់ ខ្លួនម្តងៗ ។

ឯកសាលាវត្តកំពង់ទៀងខ្ពស់ស្កឹមនោះគិត បើដូចជាស្រមោលនៃ គាំពារម្នា ស្រដៃមហើញកប៉ាល់មួយដែលដៃអណ្តែតកណ្តាលសមុទ្រ ក្រោមអោយជួបជង់ក្រុសពាកបន្ទុល ។ នៅលើបៀងកប៉ាល់នោះ

អ្នកដោយសារមើរជើរជាសណ្ឋានលេងកំសាន្ត ខ្លះទំរេតខ្លួនប្រាណលើកៅអីសំពត់មើលសៀវភៅ ខ្លះទំលោយភ្នែករំដួរបាក់ក្ដីតាមដើមចុះឡើង ៗ ។ នៅឯក្បាលតុបាល់ បុរសនិងស្ត្រីកណ្ដាលអាយុ ២ នាក់កំពុងប្រស្រ័យលេងជាមួយនឹងកូនកំលោះ ១ នាក់ កូនពៅអាយុប្រហែល ១៨ ឆ្នាំគឺកុមារកំសត់នោះឯង ។

“មើលទៅកូន ឯងបាត់ឈឺពោះហើយឬអី? ពាក់អាវក្រៅ ១ ជាន់ទៀតទៅ កុំឲ្យវាត្រជាក់ដើមទ្រូងពេក” ។

“កូនជាហើយម៉ាក់, សោកស្ត្រីញញឹមមកមាតា - ម៉ាក់កុំព្រួយអីអាកាសស្រស់ស្រាយណាស់ថ្ងៃនេះ ពុកដង្ហើមចេញចូលជាសុខស្រួលក្រៃលែង ម៉ាក់មើលហ្ន៎! ត្រីកាចេះហើរបោកពីនេះទៅនោះដូចជាសត្វស្លាបគេនិយាយប្រាប់ខ្ញុំ ៗ មិនជឿ ឥឡូវឃើញច្បាស់នឹងភ្នែក” ។

“ពពកស្រោតមកហើយកូន ឯងឈប់ចូលទៅក្នុងបន្ទប់ទៅក្រែងមិនស្រួលខ្លួន” ។

លោកស្រីក៏ទើបនឹងឃាត់ជើងដើរកាត់ពីរបីជំហាន ស្រាប់តែមេឃងងឹតមួយរំពេចខ្យល់កំបុតត្បូងបក់ពីសព្វទិសាទាំង ឈូរឆរចុះ ក្ដៅថ្ងៃសមុទ្រឲ្យញាប់ញ័រគក្រើកកើតជារលកធំ ៗ ប៉ុនភ្នំ គក្រែងគក្រេងខ្ពង់នាវាពេកជាផ្កាក្រែង ខ្ញុំខ្លួនវិលវល់ចុះឡើងដោយល្បឿនយ៉ាងលឿនអស្ចារ្យ វៃកតពុះគ្រាប់ឲ្យទឹកស្បើមពន់ប្រមាណ រលកបោលមកលើ

គប់ពាល់ដែលឃ្មេះឃ្មោងផ្ទុំផ្ទៃមុល ស្មើរទទឹងកប់ចាក់កន្ទុំកកស់ទឹក ទៀវទឹក មានលំអងទឹកសាបផាវៗ មកជួបគ្រាប់ភ្លៀង ទុមហាភ័យ! ផ្គលផ្គបល់គ្រប់គ្នា អ្នកដំណើរស្ទុះព្រួលបន្ទប់ខ្លួនយ៉ាងស្រួសរាក់ យ៉ាង សេចស្រេតខ្វល់ពិត ។

សំឡឹងមើលតាមផ្ទាំងកញ្ចក់បង្អួចមូលទៅ ឃើញពពកលៀនស្មៅ ប្រមូលបញ្ចូលគ្នាជាដុំធំៗ ជាលទ្ធផលបិទខ្ទាតខ្ទប់ពេញផ្ទៃមេឃ ផ្តុកបន្ទោរ កំព្រឹលៗ ឲ្យមើលឃើញសភាពគួរស្ញប់ស្ញែងនៃមហាសមុទ្រ ខ្ទះអសុរីយ៍ បោះទឹកកន្ត្រាញជុំនៗគ្នា បាញ់ទាំងៗ ខ្លួនខ្លាក្រកក្រែក វិស័យដូចលំ លោយតំកតពចក្រឡុ ។ សន្ទឹកព្យុះព្យាមាយោភកញ្ចៀងគេក្រែកតក្រែង កន្លែងកាក់ ទឹងស្អួកលក់បោល់ពេញផ្ទៃសាគរ គេតែតពិតអ្នកជិះឲ្យរំញេញខ្លួន ប្រែមដែជាទងគួជាខ្លួនក្នុងស្ទើតស្ទះង ។

ក្នុងខណៈនោះ មានភាពភ័ពភ័យរោចក្ដុស្ទុះទៅប្រែកឡបប្រុគ្រសំឡាញ់ ទាំងពីរខ្ញុំកញ្ចុលុតិចៗ ហើយចង្អុលដាក់ត្រចៀកជាប្រែចនជងថា "កូន អើយ ... បើកម្មងជា ....... ទីងវៃកត្តាត្រាតនេះឯង ..... ណ្ហើយ កុំរង្វាល ...... កុំតក់ស្លុត .............. ទីងមក្មួកជដែលតិកមជួល យកកា នៃជិតជល់រូបបើកទាំង ៤ នាក់ ចូរកុំខាំពាក្យម្តាយមួយម៉ាត់ ទីចុះបះបង់ការតោកុណាព្រះគេនក្រ័យថ្ងៃនក្ដី ។

នាពេលជាអភេទថែបនេះ អ្នកទាំងអស់គ្នាក៏ព្រួយចិត្តមិនកើត រកថ្ងៃភ្លឺត្រូវថ្ងៃនឹងទុក្ខសុខមិនបាន គ្រាន់តែរក្សាខ្លួនប្រាណណាដោយបរិញ្ញា-ជាតិបង្គាប់ប៉ុណ្ណោះ ស្រឡាំងកាំងក្នុងកាំងស្មារតី ហាក់ដូចជាប្រាសចាកវិញ្ញាណតេងតោង តាមដំណើរវេលាកអំណាចភ្លៀងខ្យល់គ្របសង្កត់សង្កិនជុំវិញ ណាស្បូរសំឡេងខ្ទរស្ទក់ត្រចៀកនៃរាំងភ្លើងធំ ដែលទ្រហឹងជាសញ្ញាថា មានគ្រោះប្លាក់ធ្លាក់លើនាវានាកណ្ដាលសមុទ្រធំធេង ទីងស្បូរកព្រៃះតូក ៗ បង្គាប់ឲ្យពួកនាវិកៈទំព្រីងព្រែងកែវ ឲ្យផុតអំពីអន្តរាយទ្រហឹងអឹង ៗ មិនដាច់អស់ ។

លោកធំបោកផ្ទប់មកជាច្រើនលើកច្រើនគ្រា ទុកជាពួកនាវិកៈប៉ិនប្រសព្វនារីដង់ទឹកយ៉ាងពូកែខ្លាំងមួយក្ដី ក៏បាល់ក៏មិនអាចនឹងទប់ទល់ផល់សេនាព្រះពាយុប្រែបាន . ក៏ដល់ខូរកាតព្រែះណាយមួយរំពេចនៅ ៗ សារ៉ែម្រកជាទុក្ខសុះចេញទៅមាត់កាប់រយ ទឹកក្លក់ហូរខាយលើមុខស្រង៉ូក-ស្រង៉ាក់ អ្នកដោយសារកើតភ័យដែលព្រលប់ពេញ បងប្អូនថែកគ្នានៅម្នាក់ម្នាក់ ចំណែកលោកក្រក៏ស្រឡាំងកាំងកាំងកាំងស្មារតី មួយសន្ទុះបានដឹងទៀត ស្រាប់តែកេឃើញកណ្ដាយចិនចេញប្រែសមិនឃើញខ្លួន ។

នៅពេលនោះ គេបានទម្លាក់សំប៉ានតូចទៅក្នុងទឹក បម្រុងអ្នកជិះជួយឲ្យផុតអំពីសេចក្ដីភ័យអន្តរាយ ចំណែកអ្នកដែលប៉ិនហែល ក៏លោត

ចុះចឹកយកកៃកន្ទុយខ្មួយ  នៅសល់គ្នាចំនួន ១០ នាក់ប៉ុណ្ណោះនៅលើកប៉ាល់ ។

ទឹកចូលតាមកន្លែងប្រាក់តែច្រើនណាស់ហើយ  សេចក្ដីសង្ឃឹមគង់មានតែមកជួយនោះកំរោលយ៉ាងតាមនាក់ទៅ  ដូចជារលកយ៉ាងធំបោកមក កប៉ាល់ក៏លិចស្រឹមសន្សឹមៗ ទៅ ។

សោភ័ក្រ្ដចាប់បានគល់ឈើ ១ កំណាត់  តោងហែលកាត់រលកបណ្ដែតខ្លួនទៅ  តែមហាសមុទ្រសន្ធឹកឆ្ងាយល្វឹងល្វើយក្រៃលែង  ក្រមើលទៅត្រើយក៏ពុំឃើញផង  ហើយសោភ័ក្រ្ដហែលរកដីកំណាត់ ១ ទៅដល់ល្បឿនទៅមុខបានប្រហែលជាពីរម៉ែត្រប៉ុណ្ណោះ  ព្រោះបានត្រៀនទៅមុខហើយរលកច្រានថយមកក្រោយវិញ  សោភ័ក្រ្ដអស់កម្លាំងខ្លាំងណាស់  ទំតោងគល់ឈើឲ្យខ្ជាប់ហើយបណ្ដោយឲ្យអណ្ដែតយោងយោលតាមទៅមុខតាមខ្យល់និងរលក  ចូនជាពេលប៉ុន្មានយប់ថ្ងៃ រលកដែលបោកមកខ្ទប់គ្នា  ក៏បង្កើតជាផ្កាភ្លើង  ភ្លឺព្រោងព្រាតសន្ធោសន្ធៅ វិស័យដូចជាតន្ទ្រព្រាយហោះ ។

សោភ័ក្រ្ដនឹកខ្លាចមហិមា  ណាទឹកភ័យខ្លាចពេកពេញណាស់ថ្មោងបក់រេង  ទើបធ្វេចភ្នែកភាវនា "អរហំ ៗ"  តាំងស្មារតីជាទិច្ច  ដល់តែ [illegible] ទៅ ។

លុះដល់អរុណរះភ្លឺច្បាស់ឯបូព៌ទិស សោភ័ក្រ្តភ្ញាក់ខ្លួនបើកភ្នែកឡើងស្រាប់តែឃើញខ្លួនថា ដេកកើយលើដុំថ្មនៅឆ្នេរសមុទ្រនាកោះតូចមួយ ក្រោកងើបឡើងអង្គុយ ដល់ក្រឡេកមើលគេឯងមិនឃើញ ទឹកដមរលកស្រោះថ្នាក់ពីថ្ងៃម្សិលបាត់ច្បាស់ណាស់ សោភ័ក្រ្តក៏ផ្ទៃមុខ ទាំងទុក្ខមួយរំពេចមានទឹកភ្នែកហូរស្រក់ចុះមក ទើបសោភ័ក្រ្តហាក់ដូចជាមានដែកដុតក្រហមកេះកលហើយហ្ន៎! ដើមទ្រូងសែនអួលណែនស្ទើរនឹងប្រេះក្លាយជាប្រែចក្រ ទើបទ្រហោយំខ្សឹកខ្សួលឡើងថា ៖

“ឱនាងមណីមេខលា ទេពធីតារក្សាមហាសមុទ្រ! ម្ដេចមកពង្រាត់យើងឲ្យប្រាសចាកឪពុកម្ដាយ បងប្អូន បើបានជាឥតមេត្តាដូច្នេះហើយដោយហេតុអ្វីក៏មិនយកខ្ញុំទៅផង? ទុកខ្ញុំឲ្យរងទុក្ខវេទនាសព្វប្រើអ្វី? ខ្ញុំទុកសង្ឃឹមហើយ ខ្ញុំមិនចង់រស់នៅតទៅទៀតទេ ពីព្រោះតាំងពីកើតមក ខ្ញុំមិនដែលឃ្លាតឆ្ងាយពីញាតិមិត្រដូច្នេះសោះ ឥឡូវតែលតោលនៅតែឯងកណ្ដាលកណ្ដាប់កណ្ដាលទឹកដូច្នេះ ឪពុកអើយ! ម្ដាយអើយ! បើមិនរកខ្ញុំមិនរស់នៅទេ! ”

តពីនោះមក សោភ័ក្រ្តក៏ចាប់ថ្ងៃនឹងទុក្ខសោកស្រណោះជាអនេកបរិយាយ ទៀតណាឃើញលែងចង់ត្រាច់ទៅទីណាទៀត ព្រមសុខចិត្តយកកោះនោះជាសាក្សីនៃពេលជាន់ក្រោយបំផុតរបស់ខ្លួន តែចួនជាក្រឡេកមើលទៅ ឃើញទឹកសមុទ្រខៀវខ្ចីល់បីដូចប្រេង ឃើញអាកាស

ត្រជាក់ស្រួលបោយកំស្រឡះផ្លូវផង ហើយលោកក្រូសូគិតគំនិតជាថ្មីទៀត ទៀតថា :

“មហាសមុទ្រដែលមានសភាពគួរស្ញែងខ្លាចពីម្សិលនោះ ព្រោះខ្លាំងព្យុះព្យាមា តែឥឡូវបែរជាមានសំរស់គួរឲ្យទស្សនាយ៉ាងណាមិញ ហ៊ឹងជីវិតរបស់មនុស្សក៏យ៉ាងនោះដែរ តែមានសុខហើយតែងមានទុក្ខផ្លាស់ប្ដូរគ្នាជានិច្ច ថ្ងៃនេះមានទុក្ខ ថ្ងៃក្រោយគង់ជួបប្រទះនឹងសេចក្ដីសុខមិនខានឡើយ បើដូច្នោះគួរតែអញចិញ្ចឹមសេចក្ដីសង្ឃឹមជានិច្ចកង់ជួនចិត្តទៅ ប្រហែលជាអ្នកដ៏មានគុណតាំងពីដើមចង់ប្រោសរបស់អញនៅរស់គង់មានជីវិតទៅឡើយទេដឹង? គួរតែរំពឹងនឹងស្ទូរតេ តែដឹងជាទៅទីណាគេះ បើសូម្បីតែទឹកដូច្នោះ” ។

ហើយលោកក្រូក្រោកចាកទីនោះ មានតែខោអាវ ១ ជាប់នឹងខ្លួនយកដៃស្ទាបហោប៉ៅក្រោយប្រទះនឹងក្របលុយ ដែលជាប់នឹងទៀតមិនបាត់បង់ទៅកន្លែង ទាញយកមកបើកមើលឃើញមានសល់ក្រដាស ២០,០០ មួយសន្លឹក ទើបស្រេចក៏ដើរលេងលើកោះតូចនោះ ៗ ថ្ងៃជិតត្រង់ដោយអស់កំឡាំងកំលាំង ណាអត់បាយ ១ ថ្ងៃ ១ យប់មក លោកក្រូញាប់ជើងដើរតទៅទៀតពុំរួចក៏ដួលចុះលើខ្សាច់ បើកភ្នែកមើលមើលអ្វីក៏ឃើញព្រិល ៗ ហើយសន្លប់បាត់មាត់ទៅ ។ ចួនជាពេលនោះ

មានអ្នកនេសាទត្រីពីរនាក់បរទូកមកដល់កោះនោះ បានឃើញកុមារកំសត់នេះនាំគ្នាជួយរកត្រូសរសៃទាល់តែបានដឹងខ្លួនឡើង ទើបគេឲ្យអាហារបន្តិចបន្តួចអាស្រ័យ មានកំឡាំងកំហែងហើយសៅភ័ក្ត្រក៏ថ្លែងរឿងខ្លួនប្រាប់អ្នកស្ទូចត្រីសព្វគ្រប់ ពានសន្ទូចនឹកអាណិតណាស់ព្រមឲ្យដោយសារនឹងទូកគេទៅ ដល់កណ្ដាលផ្លូវបានជួបកប៉ាល់ ១ ទើបហៅកប៉ាល់នោះឲ្យឈប់យកមនុស្ស កប៉ាល់នោះក៏ឈប់តាមពាក្យអង្វរ សៅភ័ក្ត្រត្រេកអរឥតគណនា និយាយលាអ្នកនេសាទត្រីឡើងជិះកប៉ាល់ ហើយបានទិញអាវខោនាប់១ ពាក់បង្ការកុំឲ្យរងាពេក ។ ចំនួន ២ ថ្ងៃក្រោយមក សៅភ័ក្ត្របានដល់ក្រុងព្រៃនគរ ចុះដើរលេងតាមភូមិប្រទេស គេឃើញមានផ្ទះធំ ៗ ផ្លូវវែងទូលាយដូច ៗ គ្នា គេស្គាល់មិនបានវង្វេងវិលមុខ សៅភ័ក្ត្រក៏ដើរទៅឈរលេងលើស្ពានទុំឯង ៚

យូរបន្តិចលោកតារ្យបារ៉ែនបើករថយន្តមកដល់ទីនោះហើយបញ្ឈប់រថយន្តហៅសៅភ័ក្ត្រឲ្យឡើងជិះ រួចបើកចេញពីទីនោះទៅមួយរំពេច ៗ ឯសៅភ័ក្ត្រមានសេចក្ដីត្រេកអរឥតឧបមា ដោយមានសង្ឃឹមមាំកួនចិត្តថាមុខជាមិនអត់បាយស្លាប់នៅស្រុកគេ ហើយមុខជានឹងបានទៅដល់មាតុភូមិជាប្រាកដ ។

*
*   *

វគ្គទី ២

# សោភ័ក្ត្រពេនធូរ ទឹងពន្ធ

ថ្ងៃយន្តបរកាត់ផ្លូវគេលកុងជាលំដាប់ជ្រមន់ ៧ហា ទៀត ឯដើម មេឃមានភ្ញៀវស្ទើរៗ ហាក់ដូចជាវិលជុំវិញឡាន នៅសងខាងមាគ៌ា មានសត្វក្របីឈ្មោលញាក់ពុងតែស៊ីស្មៅ ពួកស្វាមាស៊ុនទ្រហឹងមកជិត ក៏ស្ទុះងើកក្បាលឡើងហើយមើលៗ ប៉ុន្តែសោភ័ក្ត្រមិនបានអើពើមើលភូមិស្ថាន ទាំងក្បាលតាវល្ងៃ វរល់តែឈ្ងក់ផ្ញើនឹកដល់ជោគវាសនារបស់ខ្លួន ព្រោះនឹកឃើញថា ``ប៉ុន្តែបានភាពរៀងជួបសំរ្រែងនោះ ប្រហែលជា ដាច់ពោះកណ្ដាលស្រែកគេទៅហើយ នេះហេតុតែវាសនានៅមាន ទើប បានមកអង្គុយជាសុខលើតួកឡាននេះ ខ្លួនឲ្យប្រាក្តដល់មាតាបិតានិងបង ប្រុសអ៊ំម៉ុំហោ! តាក នាំឡូវជីវិតរស់នៅទៀយទេ ឬមួយក៏អនិច្ចធម្មបាត់ បង់ទៅហើយអេះ? ដល់ត្រង់នេះមុខសោភ័ក្ត្រក៏ស្រពោនចុះក្រោម ទឹកភ្នែក ហោរមជោគមុខមួយរំពេច ទើបគេលៃលោះខាំកុំឲ្យសាចារ្យជន ។

ខ្ញុំគ្មិនម៉ែក្នុងរបបប្រុកដែលប្រាសចាកមាតាបិតា កាលវ័យខ្លួន នៅក្មេងនៅឡើយ ព្រោះមាតាបិតាដូចជាអ្នកកាច់ចង្កៀណនាំអោយ ភ្លឺរលោ ត្រង់ទៅតាមផលបថ ធ្លាះទៅពេញចិត្ត កាលបើអស់អំពីអ្នក កាច់ចង្កៀតទៅហើយ កាលណាឡើយបានលុះទិសបើកត្រង់បាន មុខជា ទីងវិលវល់ខុកខ្វល់លែងស្គាល់ទិសតំបន់ ៗ ដោយហេតុនេះ សោភ័ក្ត្រ

ហាក់ដូចជាកណ្តាប់ឯកឯងក្នុងពិភពលោក    ដោយព្រោះអនាថាគេចពីរ
ពំនាក់គ្នា ទុកជាបានអាចារ្យជួយទំនុកបំរុងដូចម្តេចក៏  ក៏គង់តែដូចជា
កំព្រាផ្តាច់សេចក្តីអ៊ីច  ដែលជាទុក្ខហួសនៃសេចក្តីទុកចិត្តស្មោះស្ម័គ្រ
ផល់ដោយគំរូសនា    ព្រោះមាតាបិតាមិននៅជិតហើយក្មេងជំរឿតក៏ដូច
ចំណាយសាបសូន្យទៅដែរ  ។  តែសោភ័ក្ត្រនៅសង្ឃឹមថាទុកជាបកំណា
អ្នកដ៏មានគុណទាំងពីរគង់មានជាតែរស់នៅឡើយ  ព្រោះមិនសមបើមក
ឃាតឆ្ងាយលែងយល់មុខសោះ ពីរពាក្យអ្នកនោះនៅជួបជុំគ្នាទេតើ ម្តេច
ក៏ជាបាត់ សោភ័ក្ត្រមិនសុខចិត្តទេ ចុះបានអ្វីជាទីអាង? មានតែសេចក្តី
សង្ឃឹមយ៉ាងមាំមួនប៉ុណ្ណោះ ដែលនាំឲ្យ សោភ័ក្ត្រនឹកអព្រៃជួ  ចង់ឲ្យ
ដល់ដំណាក់ឆាប់ៗ នឹងអាណាព្យាបាលមួយច្បាប់ទៀតទៅឃ្មួយ ដំណើង
អ្នកទាំង ៣ ចំស្រុកឯណោះ ទើបងើបមុខទៅលើក្មេងគយគន់មើលពង្ស-
ជាតិផ្សេងៗ ។

ស្រាប់តែដឹងខ្លួនថាឡើងលើភ្នំហោះទៀតតែម្តង គាប់ជួបឃើញកាទព្វក
មនុស្សទៅសខ្លួនទទេ ពាក់មួកចបូត តែប្រសិនបើមិនបានឃើញពាហាន
ស្លាយកាំភ្លើងឈរព្រួតព្រាទេ  គេនឹកស្មានថាជាអ្នកស៊ីឈ្នួលមម្នាក
កំពុងលើតថបដៃពីរកាប់ដុំថ្មធំៗ ហូរញើសជាថ្លុង ។ សំឡឹងទៅលើ
ឃើញគេះផ្ទាគារតូចមួយ ខ្ពស់ត្រដឹមតណ្តាបដើមឈើស្រោងស្រដាក់

វិស័យដូចបុកណាដ្ឋានគេបោះបង់ចោលនៅទីនោះ ឲ្យល្វើជាតិនានាក្រកន្ទង ព្រៃឆ្មានព័ទ្ធព័ទ្ធជុំជោស នាំឲ្យអ្នកដំណើរកើតបញ្ហាកំបាំងគួរចិត្ត ងងឹត ។

លុះថេយន្តបើកដល់លើភ្នំ ក៏គ្មានឮសូរសត្វស្អំសំដែងឲ្យដឹងថា ទីនោះមានជីវិតដែកពួនបម្រុងនៅ, ក៏តែងឥដ្ឋកម្រាស់ ១ ម៉ែត្រឡើងក្រមៅ ព្រោះស្លាកស្រស់បំពង់ដោយអគ្គីផង ព្រោះប្លុកឈើត្រូវបំផ្លាញសង់ជាគ្រាន់ផ្ទាមាំសំបើមគាពោទឹកខ្ទុងព្រមទាំងអាគ្នេយ៍ធំពីរ ប្រែះដាប់កប្បាត់ទៅក្នុងដី ក្រឡេកមើលទៅក្នុង ឃើញបន្ទប់ដេកច្រើនល្វឹងលយល្វើះ ចាំទាំងលិច ដាប់តទៅដល់ទីអន្ធុមលេងកំសាន្តយកខ្យល់អាកាស, ឯខាងកើតគឺផ្ទះបាយ ទៀបឆ្ងាយនៅខាងស្តាំដៃ មានបន្ទប់ដេក ១ ល្វែងទៀតនៅបំពុំ ខាងត្បូងផ្ទៃគឺបន្ទប់សម្រាប់សំចតទូកឡាន បន្ទប់ទាំងអស់នោះសុទ្ធសឹងធ្វើអំពីឥដ្ឋ ចន្លោះកណ្ដាលពាក់លើងត្រឈឹងត្រឈៃប្រកបដោយដើមឈើធំៗ គោលម្លប់ត្រជាក់ ប៉ុន្តែស្ងាត់ជ្រៀបឥតឮសូរអ្វីក្រៅពីសូរស្លឹកឈើបក់រវិច ៗ ហាក់ដូចជានៅកណ្ដាលទីឯកា ស្រមច្សអគ្គណាមួយ ។

លុះឡានចូលដល់ខាងក្នុង ស្ទាមស៊ីនប្រកាសប្រាប់ថាមានអ្នកដំណើរមកដល់ ទើបលេចម្ចាស់គេជនានារម្នាក់មក អ្នកនោះឯងចាស់ជរាហើយ

សក់ស្កូវសសំព្រះ អាចារ្យក៏បានបក្ខិតបន្ទប់ពីរ ចុះឈ្មោះទំលំទៅ នឹង ក្រសួងធ្វើការ រួចបានបកឡានចុះដោយស្រួល ។

រួចមកអាចារ្យក៏នាំសោភ័ក្ត្រដើរទៅឈរលេងលើចំកន សំឡឹងមើលក្រោមឃើញដំណើរថ្មចុះទៅមាត់សមុទ្រ ដេរដាសទៅដោយសត្វក្អែកខ្មួនក្រហមស្អុចខ្មៅតូចអន្ទ្រង់ហើររើកដោយអន្ទើ ។ កាក្រឹងធំហើបមាត់ត្រង់ថ្មចេញពីដីមកសំឡេងឃើញថា ទីនោះជាកាតបន្ទាយពីដើមរបស់យួន ឯនាយឯណោះសមុទ្រធំធេងកន្លាញ់ដោយលោក ឯកោះទៀតស្រួ អណ្ដែតត្រសែតកណ្ដាលរលេមយទឹងមុក ។

សេចក្ដីស្ងាត់ត្រជាក់ផង សេចក្ដីម្ចាស់កាយសប្បាយចិត្ត ព្រមទាំងខ្យល់អាកាសត្រជាក់ល្អ បញ្ញាវិញ្ញាណរបស់អ្នកដំណើរឲ្យអណ្ដែតអណ្ដែតកងការស្រមៃ ឃើញឃោងតាមបាដក្ខិនៃលោកសមុទ្រ ដែលខ្យល់ផាត់ផាយនាំមកដល់ត្រចៀកលាន់ផង ក្លិនស្អាបទឹកស្រណោះកាឡោះអាល័យនៃខ ។ លុះអាចារ្យចូលទៅផ្លាស់ខោអាវស៊ើតស៊ំ-អានរាងកាយ សោភ័ក្ត្រចាប់ក្រដាសនិងដំណើរកា ហើយមុខមោលក្រែកកយកនៅមើលធម្មជាតិ ។ ក៏ចាប់សរសេរខ្សែរលេខ ១ បញ្ឈប់ក្បាល ផ្ញើក្ដិងឲ្យលោកទៅឲ្យមន្ទីរប្រៃសណីយ៍ ហើយអង្គុយចាំសេចក្ដីតបទៅទៀត ព្រោះអាចារ្យមិនទាន់ដល់កំណត់ចូលធ្វើការនៅឡើយ នៅសម្រាកខ្លួនលើកុំចំខ្លួន ១ រាត្រីទៀត ។

លុះដល់ថ្ងៃត្រង់ ។ សោភ័ក្ត្រទៅដេកមាត់ទឹក គន្ធីយល់ហើយ ខ្ទមលើគោកផ្ទៃវែងដិតកែវខ្ទះ ។ អាកាសពេលនោះត្រជាក់ស្រួលគន់ តេក ដកដង្ហើមចូលទៅបាក់ដូចជាមានកំឡាំងពិសេស ឯលោកដែល ប្រដេញតាម ហាបលើដៃខ្សាច់ ហាក់ស្រួលស្រស់លូងល្វើយ ទឹង ខ្យល់ត្រជាក់ ក៏កើយចឹងត្រចៀកសណ្តំវិញ្ញាណឲ្យទន់ចុះ នាំឲ្យកើត សេចក្តីសង្វេគ ។

គង់ខណៈនោះ ពួស្ទូរលើងមនុស្សស្គាល់ក្រោយខ្នងមក សោភ័ក្ត្រ ងើបភ្ញាក់ ឃើញគេទាំងកាន់ថ្នាស់ពពកពិសេស សណ្តាបនូវផ្ទុំហុប ឲ្យពីចម្ងាយមក សោភ័ក្ត្រស្ទុះក្រោកបាកកៅអីទៅទទួល បានសំបុត្រ កាន់នៅដៃ ហើយវិលត្រឡប់មកគន្ធីយកៅទ្បូងវៃផលវិញ លើកសំបុត្រ ទៀងដាក់លើដើមទ្រូងដោយសេចក្តីគោរព គក់ស្មុគខ្ទក់ចិត្តមរជិង ក័យខត ញាំដៃហែកសំបុត្រស្ទើរមិនចង់កើត ។

ខណៈដែលសោភ័ក្ត្រកំពុងមើលសំបុត្រ ចិញ្ចើមក៏ត្រជាញ់ជួប គ្នា ភ្នែកទាំងទន្ទីសំដៅខ្ពង់ព្រមុះ មើលសេចក្តីបានពាក់កណ្តាលក៏ ពាក់ដៃម្ខាងចុះដោយចុកសង្រៀម សំឡឹងមើលទៅឆ្ងាយហាក់ស្រងូត ស្រងាត់ ស្រាប់តែបានលើកសំបុត្រទៀតអានតទៅទៀត មុខក្រញូវ សង្រៀម ៗ រីកឡើងម្តង ៗ ទៀងវិញ ចុងបំផុតបបូរមាត់ញញឹមយ៉ាង ស្រស់ ឯសំបុត្រនោះមានសេចក្តីដូចេះ :

អ្នកស្រុក . . . . នៅថ្ងៃ ២ ខាំឲ្យ ១៩២៩

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . កាលបើយើងបានដំណឹងមកថា មានគ្រោះថ្នាក់លិចកណ្ដាលសមុទ្រ យើងតែងតែមានទុក្ខព្រួយរៀងរាល់ថ្ងៃមិនដែលដាច់ ក្នុងបណ្ដាអ្នកស្រុកយើងដែលធ្វើដំណើរទៅនោះ ពុំមាននរណាគួរលវិលមកឃើញផ្ទះសម្បែងវិញទេ តាយាយមាតាយំសោកព្រោះស្ដាយបុត្រ ញាតិមិត្រខ្សឹកខ្សួលរំជួលថ្លើមព្រោះឃ្លាតពីបុគ្គលជាទីស្រឡាញ់ពេញចិត្ត ។ ប៉ុន្តែយើងទាំងអស់គ្នាមែងតប់ប្រមល់ ព្រោះនឹកដើមដល់ឪពុកម្ដាយរបស់ចៅ ដែលមានឧបការគុណលើយើងរាល់គ្នាជាច្រើន គួរឬមកខាតអ្នកបិណ្ឌបុណ្យទៅដោយគិតស្រណោះយ៉ាងនេះ . . . . . . . . . . . . . . . . . . . .
. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .
. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .
. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . ពីព្រឹកមិញ មាននាយនាវិកម្នាក់មកលេងនៅទីផ្សារបាននិយាយប្រាប់ថា អ្នកដែលលិចកប៉ាល់នោះ មានគេជួយស្រង់ជីវិតបានទាំងអស់ ពុំមានស្លាប់ទេ អ្នកដែលព្រាត់ប្រាសទៅមុខជានឹងបានត្រឡប់វិលមកវិញ ដោយហេតុនេះ យើងនឹកសង្ឃឹមថា មាតាបិតានឹងបងប្អូនរបស់ចៅ នង់នឹងបានមកឃើញមុខយើងរាល់គ្នា បានជាបាត់ដំណឹងប្រហែលអាស្រ័យដើរស៊ើបសួររកកូនចៅជួបជុំគ្នាទេដឹង បើដូច្នោះចៅកុំព្រួយចិត្តអ្វី ចាំដើរស៊ើបសួរទៅតង់នឹងប្រទះគ្នាពុំខាន . . . . . . . . ។

អ្នកស្រុក

គបទៅចៅសោកក្រៃ

ឯកាសហាស្រែកត្រើ

មួយពាន់មួយយប់ ( ជារឿងភាគប់ )

ភាគទី ១១

# ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម

ប្រែចេញពីភាសាបារាំងសែសមកជាខេមរភាសា

## រឿងអ្នកបួសទី ៣ ជារាជបុត្រស្តេច

សូមជំរាបអ្នកស្រី, រឿងរ៉ាវដែលខ្ញុំនឹងជំណាលជូនអ្នកស្រីស្តាប់តទៅនេះជារឿងប្លែកផ្សេងគ្នាណាស់ អំពីរឿងដែលអ្នកស្រីទើបនឹងបានស្តាប់មកអម្បាញ់មិញនេះ ។ ព្រះអង្គម្ចាស់ទាំងពីរអង្គ ដែលបានជំណាលរឿងមកមុនខ្ញុំនេះ ខ្វាក់ព្រះនេត្រម្ខាងដោយព្រោះកម្មរបស់ខ្លួនឯង ឯការខ្ញុំវិញមិនមែនដូច្នោះទេ គឺខ្ញុំខ្វាក់ភ្នែកម្ខាងដោយសារតែកំហុសរបស់ខ្ញុំ ដែលខ្ញុំដក់ទៅរកគ្រោះថ្នាក់ដោយខ្លួនឯង ដូចរឿងដែលខ្ញុំនឹងជំណាលជូនអ្នកស្រីស្តាប់តទៅនេះ ។

ខ្ញុំឈ្មោះអាជីប ជាព្រះរាជបុត្ររបស់ស្តេចសោយរាជ្យព្រះនាមកាស៊ីប លុះព្រះវររាជបិតាទិវង្គតទៅ ខ្ញុំក៏បានឡើងគ្រងរាជ្យជាតំណមក ហើយខ្ញុំក៏ស្ថិតនៅក្នុងក្រុងដដែលនោះឯង ។ ឯក្រុងនេះ នៅក្បែរមាត់សមុទ្រ ទើបនៅជាកំពង់យ៉ាងស្អកស្កះ ១ សម្រាប់ចតនាវាចម្បាំងបានចំនួន ១៥០ ហើយខ្ញុំមាននាវាជំនួញដទៃផ្សេងទៀតចំនួន ៥០ គឺនាវា

ទូកតូចសម្រាប់ប្រើតាមជាយសមុទ្រ ក៏មានចំនួនប្រហែលគ្នាដែរ ។ ឯករណីខ្ញុំធ្វើដំណើរគោកវិញ ក៏មានខេត្រខណ្ឌក្រុងស្រុកស្ដុកស្ដម្ភជាច្រើន ព្រមទាំងកោះតូច-ធំនានាមានដំណើរទឹក ។

ដំបូង: ខ្ញុំចេញទៅស្រុកត្រាខេត្រខណ្ឌផ្សេងៗ តាមដំណើរគោក រួចខ្ញុំឲ្យរៀបចំនាវាចម្បាំង ហើយខ្ញុំក៏ជិះនាវាចេញទៅស្រុកកោះផ្សេងៗ តាមដំណើរទឹក ។ ក្រោយដែលបានស្រុកត្រាអស់ ២-៣ លើក ខ្ញុំក៏វិលត្រឡប់មកស្រុកវិញ ។ ប៉ុន្តែការធ្វើដំណើរតាមដំណើរទឹកគ្រានោះ នាំឲ្យខ្ញុំសប្បាយចិត្តជាច្រើន ទើបនាំឲ្យខ្ញុំគិតសម្រេចថា នឹងចេញទៅស្រុកមើលឆ្ងាយៗ ក្រៅពីកោះតូច-ធំរបស់ខ្ញុំទៅទៀត ។ ការធ្វើដំណើរជាន់នោះ ខ្ញុំបានឲ្យតាក់តែងរៀបចំនាវាចំនួន ១០ រួចស្រេចក៏បើកក្ដោងចេញដំណើរទៅ ។ នាវារបស់យើងបានបើកចេញទៅដោយសុខសប្បាយអស់វេលា ៤០ ថ្ងៃ ឥតមានគ្រោះថ្នាក់អ្វីឡើយ លុះដល់មកយប់តំរប់ ៤១ ថ្ងៃ ទើបមានខ្យល់បក់បញ្ច្រាសមកពីមុខទូក ហើយខ្លាំងក្លាជាព្យុះសង្ឃរាយ៉ាងសំបើម នឹកស្មានថា នាវាទាំងអស់មុខជាលិចលង់ក្នុងជលសាមិនខាន តែលុះដល់ជិតភ្លឺឡើង ខ្យល់ព្យុះនោះក៏សន្សឹមស្ងប់ស្ងាត់បាត់ទៅវិញ មេឃស្រឡះឥតពពក ព្រះអាទិត្យក៏រះឡើងពីទិសបូព៌ា នាវារបស់យើងក៏បានដល់ទៅកោះមួយ ហើយយើងទាំងអស់គ្នាក៏នាំគ្នាចូលចតនាវា ឈប់សម្រាកកំឡាំងនៅកោះនោះអស់វេលាពីរថ្ងៃ ។ រួចយើង

បន្តដំណើរតទៅទៀត  កាលកន្លងទៅបាន ១០ ថ្ងៃ  យើងនឹកសង្ឃឹមថា ច្បាស់ជាមិនបានឃើញត្រើយត្រាំងសមុទ្រ  នៅត្រង់ណាមួយជាមិនខាន ។ តែដោយហេតុដែលលើបទីនត្រូវខ្យល់ព្យុះមកបក់ដូច្នេះ នាំឲ្យខ្ញុំស្ទើរមិនអាចធ្វើដំណើរតទៅទៀត ទើបខ្ញុំឲ្យវិលមាត់ត្រឡប់ទៅស្រុកវិញ តែតៃកុងរបស់យើងនេះថា មិនដឹងជាខុសទៅកន្លែងណា ៗ គង់ថ្ងៃ ១០ ខាងមុខ ម្នាក់ដែលបានបាត់ឡើងជង់ក្តោងធំនោះ បានស្រែកប្រាប់ពីលើមកថា  នៅខាងស្តាំទិសខាងត្បូងមានតែពពកនឹងមេឃ ប៉ុន្តែមើលទៅមុខទៀតឃើញមានដុំខ្មៅមួយធំ ៗ

ឯតៃកុងកាលបានឮម្នាក់ឲ្យនិយាយដូច្នោះ ក៏ស្រស់ទឹកមុខមួយរំពេច ហើយការឹងទះតប់មុខមាត់របស់ខ្លួន ស្រែកឡើងថា "ឱព្រះគុណថ្លៃវិសេស  យើងទាំងអស់គ្នាមុខជាអន្តរាយជីវិតឥតសល់ដល់ម្នាក់ឡើយ ហើយបើព្រះបន្ទិចខ្ញុំក៏គ្មានទុក្ខណាមួយ  ទីងជួយព្រះអង្គឲ្យផុតពីគ្រោះថ្នាក់នេះបានឡើយ ។ កាលតៃកុងនិយាយប្រាប់ខ្ញុំដូច្នេះហើយ ក៏គាត់ស្រែកទ្រហោយំ ដូចកាលមនុស្សដែលដឹងខ្លួនថា មុខជាស្លាប់ពិតប្រាកដណាស់  ហើយពួកអ្នកជិះនាវាទាំងប៉ុន្មានក៏ស្រែកយំទ្រហឹងអឹងកងរំពងគោរគ្នា ។ ខ្ញុំក៏បានសួរអំពីហេតុដែលនាំឲ្យអស់សង្ឃឹមនោះ តៃកុងក៏បាននិយាយប្រាប់ខ្ញុំថា  ខ្យល់ព្យុះធំដែលបក់បោកមកត្រូវនាវាយើងនោះ នាំឲ្យយើងឃ្លាតឆ្ងាយពីផ្លូវរបស់យើងទៅ  ដល់ស្រួតវេលា

ថ្ងៃត្រង់ជាក់ យើងខ្ញុំបានឃើញថ្មដុះនោះនៅជិតគែមច្រាំង ឯថ្មដុះនោះ គឺជាភ្នំខ្មៅ ៗ ជាមេដែក ដែលកំពុងស្រូបយកនាវារបស់ព្រះករុណា ថ្លៃវិសេស ឲ្យកាន់តែចូលទៅជិតភ្នំនោះជាលំដាប់ ដោយអំណាចដែក គោលនិងក្រចៀនដែកដែលប្រដាប់នៅនឹងនាវាទាំងនេះ ។ លុះដល់ថ្ងៃស្អែកនេះ វេលាដែលនាវាចូលទៅជិតក្បែរភ្នំនោះ កំឡាំងមេដែកនឹងស្រូបរឹតកាន់តែខ្លាំងឡើង ទាល់តែដែកគោលទាំងអស់របើកចេញទៅជាប់ពីភ្នំ ហើយនាវាទាំងប៉ុន្មានរបស់ព្រះករុណាថ្លៃវិសេស បែកខ្ទាយលិចលង់ក្នុងសមុទ្រអស់ទៅ ។ ដោយហេតុមេដែកមានអំណាចស្រូបយកដែក ហើយមេដែកក៏មានកំឡាំងកាន់តែខ្លាំងឡើង ដោយអំណាចការស្រូបយកដែកផ្សេង ៗ មកទុកជាប់ទួនច្រើន ហេតុនេះបានជាចំហៀងភ្នំខាងទឹកសមុទ្រ មានដែកគោលច្រើនរាប់គណនាមិនបាន ដែលស្រូបយកមកអំពីនាវាទាំងឡាយ ទើបនាំឲ្យមេដែកនោះ កាន់តែមានកំឡាំងច្រើនឡើងជាអនេក ។ តែក្នុងនិយាយតទៅទៀតថា ភ្នំនោះចោតពន់ពេកណាស់ នៅលើកំពូលមានមណ្ឌបកង្ហូល (ដូម) មួយធ្វើពីសម្រិទ្ធយ៉ាងល្អ សសរក៏ធ្វើពីសម្រិទ្ធយ៉ាងល្អដែរ នៅពីខាងលើមណ្ឌបនោះមានរូបសេះសម្រិទ្ធមួយ នៅលើខ្នងសេះមានរូបអ្នកជិះសេះម្នាក់ធ្វើពីសម្រិទ្ធដែរ តែត្រង់ដើមទ្រូងបាំងខែលសំណ នៅទីនៃខែលសំណនោះមានឆ្លាក់យន្តអាគមគាថាផង ។ តែក្នុងនិយាយប្រាប់ខ្ញុំទៀតថា បពិត្រព្រះករុណា

ដ៏វិសេស តាមរឿងក៏តែប៉ុណ្ណោះមកថា រូបនេះឯងជាហេតុបណ្ដាលឲ្យ កើតទុក្ខភ័យយ៉ាងធំ ដល់ពួកនាក់ទាំងពួកមនុស្សច្រើនជាអនេកដែលមក លិចលង់ក្បែរភក្ស័យនៅកំបន់នោះ លុះកាលណាមានអ្នកណាមួយ រំលំ រូបនោះហោលចេញបាន ទើបលែងមានគ្រោះថ្នាក់អន្តរាយតទៅ" ។

លុះតៃកុងនិយាយដូច្នេះហើយ ក៏តាំងយំសោកតទៅទៀត ពួកអ្នកដំណើរទាំងប៉ុន្មាន ក៏នាំគ្នាទ្រហោយំទាំងអស់គ្នា ។ ចំណែកគោង ខ្ញុំក៏ជឿជាក់ថា មុខជានឹងស្លាប់មិនខាន ។ មនុស្សទាំងអស់គង់នាក់ ក៏បម្រុងខ្លួននឹងទទួលនូវមរណៈ ប៉ុន្តែនៅសង្ឃឹមតែក្រែងមានអ្នកខ្លះរស់ រួចជីវិតបាន ទើបចបួលគ្នាធ្វើលិខិតដាក់ដៃគ្នានៅវិញទៅមក គឺធ្វើជាបណ្ដាំប្រគល់មត៌កឲ្យដល់គ្នានឹងគ្នា បើមានអ្នកណាមួយនៅរស់រួចជីវិតនោះ ត្រូវបានទទួលទ្រព្យសម្បត្តិរបស់អ្នកដែលមរណភាព ធ្វើជាសម្បត្តិរបស់ខ្លួន ។

ដល់ព្រឹកស្អែកឡើង ក៏មើលឃើញគ្នានៅនោះទាំងអស់គ្នា ឃើញដូច្នេះហើយក៏កើតខ្វល់ខ្វាយឡើងជាថ្មី ដោយហេតុមើលទៅឃើញសេចក្ដីស្លាប់កាន់តែច្បាស់ណាស់ ។ លុះពេលថ្ងៃត្រង់ នាវាក៏កាន់តែជិតទៅថ្មនោះណាស់ មិនយូរប៉ុន្មានក៏ឃើញតាមហេតុដែលតៃកុងនិយាយប្រាប់ គឺដែកគោលទង់ដែកឯទៀតៗ ទាំងប៉ុន្មាន ក៏ហោះចេញពីកង់នាវាសំពៅ ទៅកាន់ថ្មនោះទាំងអស់ ដោយអំណាចការស្រូបខ្លាំងក្លាណាស់ ទើបនាំ

ឲ្យត្រូវប៉ះទង្គិចនឹងថ្មយ៉ាងសាមៀម ។ នាវាទាំងប៉ុន្មានក៏បែកធ្លាយចុះហើយលិចលង់ក្នុងសាគរក្នុងវេលានោះទៅ ។ សមុទ្រត្រង់ណោះក៏ជ្រៅជាពន្លឹក យកប្រដាប់មកស្ទង់ក៏ស្ទង់មិនដល់ដីផង មនុស្សក្នុងនាវាទាំងប៉ុន្មានក៏លង់ទឹកស្លាប់អស់ ។ ប៉ុន្តែជាកុសលរបស់ខ្ញុំ ព្រះលោកមិនបង្ខំឲ្យស្លាប់ លោកចង់ឲ្យរួចរស់ជីវិត ក្នុងវេលានោះ ខ្ញុំចាប់បានក្តារមួយបន្ទះមកតោង ហើយមានខ្យល់បក់បោកឲ្យរសាត់អណ្តែតទៅរកដើមភ្នំនោះ ទៅចំត្រង់កន្លែងដែលមានថ្នាក់ សម្រាប់ឡើងទៅដល់កំពូលលើបាន ។

នៅវេលាដែលបានឃើញថ្នាក់ឡើងដូច្នេះហើយ ខ្ញុំក៏តាំងពោលសរសើរគុណព្រះជាម្ចាស់ ដែលបាននាំខ្ញុំមកចំកន្លែងនោះ បើបែរទៅខាងឆ្វេងឬខាងស្តាំនោះ ទីងមិនមានថ្នាក់សម្រាប់ឡើងសោះឡើយ ហើយខ្ញុំក៏ឡើងតាមថ្នាក់នោះទៅ ។ ជណ្តើរនោះចោតហើយចង្អៀតលំបាកនឹងឡើងពន់ពេកណាស់ ប្រសិនបើមានខ្យល់យ៉ាងខ្លាំងបក់ផាត់មក ក៏អាចនឹងផាត់យកខ្លួនខ្ញុំឲ្យធ្លាក់ចុះទៅក្នុងសមុទ្រវិញបាន ប៉ុន្តែក្នុងវេលានោះ ខ្ញុំឡើងបានរហូតដល់ទៅកំពូលលើឥតមានគ្រោះថ្នាក់អ្វីឡើយ ខ្ញុំក៏ដើរចូលទៅខាងក្រោមមណ្ឌបនោះហើយ ខ្ញុំលុតជង្គង់ចុះផ្ទាល់នឹងដីធ្វើសេចក្តីគោរពដល់ព្រះជាម្ចាស់ ថ្វាយសេចក្តីសរសើរព្រះគុណដែលបានជួយស្រោចស្រង់ខ្ញុំឲ្យបានរស់រួចជីវិត ។

ក្នុងវេលារាត្រី ដែលខ្ញុំដេកក្រោមម្លប់ឈើនោះ នៅវេលាដែលខ្ញុំកំពុងដេកលក់ ខ្ញុំយល់សប្តិឃើញតាចាស់ដែលគួរគោរពម្នាក់ មកឈរពីមុខ ខ្ញុំនិយាយប្រាប់ខ្ញុំថា -- "នែអាប៊ែប, ចូរអ្នកស្តាប់យើង កាលណាអ្នកភ្ញាក់រលឹកឡើង ចូរអ្នកជីកដីក្រោមជើងអ្នកឯង នឹងបានឃើញធ្នូសំរិទ្ធ ១ នឹងព្រួញសំណ ៣ ដែលគេបានបែនាធ្វើជារូបក្អាយផ្សេង ៗ ធ្នូនឹងព្រួញនេះហើយ សំរាប់ស្រោចស្រង់មនុស្សលោក ដែលមានគ្រោះថ្នាក់ដោយសារទឹកខ្មៅនេះ ៗ ចូរអ្នកឯងយកព្រួញទាំង ៣ បាញ់រូបនេះទៅ ហើយរូបជិះសេះនឹងធ្លាក់ទៅក្នុងសមុទ្រ ហើយសេះនឹងធ្លាក់មកខាងអ្នកឯង ហើយអ្នកឯងកប់វាទៅត្រង់កន្លែងដែលអ្នកឯងកាយយកធ្នូនឹងព្រួញនុះឯង ៗ បើធ្វើដូច្នេះហើយ ទឹកសមុទ្រនឹងឡើងខ្ពស់ឡើងហូតមកដល់ជើងបណ្តូលនេះ គឺខ្ពស់ស្មើនឹងកំពូលនេះឯង ៗ វេលាទឹកឡើងដល់កំរិតនេះ អ្នកនឹងឃើញទូក ១ ចូលអែបមក ទូកនោះមានមនុស្សតែម្នាក់ដ៏ទេ កាន់ច្រវ៉ាទៅដៃទាំងសងខាង ៗ មនុស្សនោះក៏ជាសំរិទ្ធដែរ ប៉ុន្តែប្លែកផ្សេងពីមនុស្សដែលអ្នកឯងរំលំធ្លាក់មក អ្នកឯងឡើងជិះទូកជាមួយនឹងមនុស្សនោះទៅ តាមតែគេនាំទៅឯណាក៏ដោយ អ្នកឯងកុំនិយាយចេញព្រះនាមព្រះជាម្ចាស់ឡើយសោះ ៗ មនុស្សនោះនឹងនាំអ្នកឯងទៅក្នុងកំណត់ ១០ ថ្ងៃ នឹងដល់ទៅសមុទ្រ ១ ផ្សេង ហើយអ្នកឯងនឹងឯងទៅកាន់ទីលំនៅស្រុកអ្នកឯងវិញ បានដោយសុខសប្បាយ ប៉ុន្តែត្រូវ

ចាំបណ្តាំអំពីត្រណម ដែលយើងបានផ្តាំទុកនេះឲ្យជាក់ គឺថាក្នុង ១ ដំណើរនេះ ត្រូវអ្នកឯងកុំពោលអ្វីចេញព្រះនាមព្រះជាម្ចាស់ឲ្យសោះ ។

លុះដល់វេលាខ្ញុំភ្ញាក់ឡើង ខ្ញុំមានអំណរខឹងសប្តិនោះពន់ពេកណាស់ ហើយខ្ញុំក៏ធ្វើតាមបណ្តាំតាចាស់សព្វគ្រប់ គឺខ្ញុំកាយយកធ្នូនឹងព្រួញបានមកហើយ ខ្ញុំក៏បាញ់មនុស្សជិះសេះនោះ រលំធ្លាក់ទៅក្នុងសមុទ្រទៅ ហើយឯសេះរលំទកទាន់ខ្ញុំ ខ្ញុំក៏កាយដីដីកកប់ត្រង់កន្លែងដែលកប់ធ្នូនឹងព្រួញទៅវិញ នៅវេលានោះ ខ្ញុំសង្កេតឃើញទឹកសមុទ្រជោរជន់ឡើងមក រហូតដល់ជើងមណ្ឌបស្ពាន់ទីកំពូលភ្នំនោះ ហើយស្រាប់តែឃើញទូកតូច ១ ពីចម្ងាយចូលជំរំមករកខ្ញុំ ក្នុងវេលានោះ ខ្ញុំថ្លែងសេចក្តីថ្វាយពរសព្ទសាធុការដល់ព្រះជាម្ចាស់ តាមហេតុកេរ្តិ៍ដែលមានមកតាំងពុំទាន់ប្រាកដត្រូវតាមទំនងរបស់សប្តិខ្ញុំឥតគ្លៀងចន្លោះ ។

នៅទីបំផុត ទូកនោះក៏ចូលអែបមកនឹងកំពូលភ្នំ ហើយខ្ញុំក៏ឃើញមនុស្សស្រមិទ្ធិ ដូចតាចាស់និយាយប្រាប់នោះដោយច្បាស់លាស់ ៗ ខ្ញុំក៏ចុះទៅក្នុងទូកនោះទៅដោយតាំងចិត្តតមមិនពោលពាក្យចេញព្រះនាមព្រះជាម្ចាស់ឲ្យសោះតែពាក្យអ្វីដទៃក៏ខ្ញុំតមមិននិយាយដែរ ។ លុះខ្ញុំអង្គុយសំចតលើទូកហើយ មនុស្សស្រមិទ្ធិក៏តាំងអុំទូកចេញទៅៈ ចេះតែអុំទៅ ៗ តាំងយប់តាំងថ្ងៃឥតឈប់សម្រាកសោះ លុះដល់ថ្ងៃទី ៩ ខ្ញុំបានឃើញកោះជាច្រើនដែលនាំឲ្យមានសង្ឃឹមថា ខ្លួនខ្ញុំនឹងផុតពីគ្រោះភ័យជាដាច់ ។

សេចក្ដីត្រេកអររបស់ខ្ញុំ នាំឲ្យខ្ញុំភ្លេចត្រណមតាតាស់នោះស្រឡះ ហើយ ខ្ញុំក៏ពោលសរសើរគុណព្រះជាម្ចាស់ឡើងថា ខ្ញុំសូមសរសើរព្រះគុណ ថ្លៃថ្នូព្រះអង្គ ខ្ញុំសូមថ្វាយព្រះពរសព្ទសាធុការដល់ព្រះអង្គ ។

ខ្ញុំពោលសើរតែមិនទាន់ផុតពីមាត់ ស្រាប់តែទូកនោះលិចស្រឹមទៅក្នុង សមុទ្រជាមួយនឹងមនុស្សស្រមើទាំងនោះទៅ ឯខ្លួនខ្ញុំក៏អណ្ដែតនៅក្នុងទឹក ទាំងប្រឹងប្រែរប្រែកហែលក្នុងថ្ងៃនោះ ដរាបដល់យប់ងងឹតឈឹងរកមើលទិស តំបន់ពុំឃើញ ចេះតែខំហែលទៅតាមយថាកម្ម ដរាបដល់អស់កំឡាំង ខំប្រឹងហែលសើរតែមិនរួច ខ្ញុំនឹកទុកក្នុងចិត្តថា គង់លង់ទឹកស្លាប់ក្នុង សមុទ្រនោះជាប្រាកដ កំពុងតែគិតអំពីសេចក្ដីស្លាប់ដូច្នេះ ស្រាប់តែរលក យ៉ាងធំប៉ុនភ្នំបោកបក់ជូនខ្ញុំទៅដល់ឆ្នេរខ្សាច់មួយអន្លើ ហើយខ្ញុំក៏ទើរនៅ ទីនោះ ៗ វេលានោះ ខ្ញុំក៏ស្ទុះម៉្យាឡើងទៅលើគោក ដោយខ្លាចក្រែង មានរលកធំ ៗ មកទាញយកខ្ញុំទៅវិញ ។ ទៅដល់លើគោកហើយ ខ្ញុំក៏ តាំងស្រាកត្រដាងហាលខោអាវលើដីខ្សាច់ ដោយពូតទឹកចេញឲ្យធាប ស្ងួត ព្រោះក្នុងវេលានោះដីខ្សាច់នៅមានចំហាយក្ដៅនៅឡើយ ។

លុះដល់ព្រឹកស្អែកឡើង ខោអាវខ្ញុំក៏ស្ងួតទាំងអស់ ខ្ញុំយកមក ស្លៀកពាក់ជាស្រេចហើយក៏ចេញដើរទៅ ដើម្បីពិនិត្យមើលទីឋានឲ្យ ពិតជាក់ថា ខ្ញុំនៅ ៗ ទីណា ។ ខ្ញុំគ្រាន់តែចេញដើរទៅមួយស្របក់ ក៏គាប់សំគាល់បានថា ទីឋាននោះជាកោះតូច ៗ ឥតមនុស្សនៅ មាន

ដើមឈើផ្លែទំនាំព្រៃពីរក្បាលយ៉ាងស្ដុកស្ដម្ភ ខ្ញុំបានសង្កេតឃើញថាកោះនោះនៅឆ្ងាយដាច់ស្រឡៃពីត្រើយគោកពេកណាស់ នាំឲ្យសេចក្ដីត្រេកអររបស់ខ្ញុំថយចុះជាច្រើន ៗ ប៉ុន្តែក្នុងវេលានោះ ខ្ញុំបានផ្ញើសេចក្ដីសុខទុក្ខរបស់ខ្ញុំលើព្រះជាម្ចាស់ ក្រោយនោះបន្តិច ស្រាប់តែឃើញទូកក្ដោង ១ យ៉ាងតូចបើកក្ដោងសំដៅចំមកកោះដែលខ្ញុំនៅ ៗ

ដោយខ្ញុំជឿជាប្រាកដថា ទូកនោះមុខជាចូលមកចតនៅទីកោះ ហើយដោយខ្ញុំយល់ឃើញថា ពួកមនុស្សជិះទូកទាំងនោះ មិនដឹងជាមិត្រឬជាសត្រូវទេ នោះខ្ញុំពិចារណាយល់ថា គួរកុំបង្ហាញខ្លួនខ្ញុំឲ្យគេឃើញឡើយ ៗ ខ្ញុំគិតដូច្នេះហើយ ក៏តាំងប្រញាប់ឡើងដើមឈើយ៉ាងស៊ុំទ្រុម ១ ដើម លាក់ខ្លួនពួនអាត្មាចាំមើលមនុស្សទាំងនុ៎ះឲ្យច្បាស់ ៗ វេលាដែលទូកចូលមកចតនៅឆ្នេរខ្សាច់នោះ ឃើញបារ ១០ នាក់កាន់ប៉ែលនិងគ្រឿងប្រដាប់ជីកដីផ្សេង ៗ នាំគ្នាឡើងមកលើគោក ៗ មនុស្សទាំងនោះក៏ដើរដម្រង់ទៅកណ្ដាលកោះហើយឈប់នៅទីកន្លែង ១ ក៏តាំងនាំគ្នាជីកគាស់ដី មួយស្របក់ខ្ញុំមើលទៅឃើញ ហាក់ដូចជានាំគ្នាចាប់លើកគំរបអ្វី ១ ឡើង ៗ រួចពីនោះខ្ញុំឃើញពួកទាំងនុ៎ះ ត្រឡប់ទៅកាន់ទូកម្ដងទៀត តាំងនាំគ្នាដឹកញ្ជូនគ្រឿងបរិភោគនិងពូកខ្នើយ ខ្ទះលីខ្ទះសែងឡើងមកកាន់កន្លែងដែលជីកដីនោះ ដល់ហើយក៏ចុះបាត់ទៅក្នុងដីអស់ទៅ ខ្ញុំឃើញដូច្នេះក៏សំគាល់បានថា នៅក្នុងដីមានរូងអ្វីមួយ

យ៉ាងធំ ៗ រួចពីនោះខ្ញុំឃើញពួកទាំងនុះត្រឡប់ទៅកាន់ខ្ទមម្ដងទៀត ឃើញនាំតាចាស់ម្នាក់នឹងក្មេងជំទង់ម្នាក់ អាយុប្រហែល ១៤ · ១៥ ឆ្នាំ រួចក៏ស្ងាត់បាត់ឡើងទៅកាន់វាលវែល ហើយនាំគ្នាចុះបាត់ទៅ ក្រោយនោះបន្តិចក៏ឃើញចេញពីក្នុងរូងមកវិញទាំងអស់គ្នា ៗ តែវេលាដែលត្រឡប់ទៅចុះទូកវិញនោះ ខ្ញុំសំគាល់ឃើញបាត់ក្មេងជំទង់ មិនឃើញត្រឡប់ទៅនឹងគេវិញឡើយ ខ្ញុំក៏សន្និដ្ឋានថា ក្មេងនោះច្បាស់ជានៅក្នុងរូងនោះឯង នេះនាំឲ្យខ្ញុំមានសេចក្ដីងឿងឆ្ងល់ឥតគណនា ៗ

តាចាស់នឹងពួកបារាំងប៉ុន្មាន ក៏នាំគ្នាចុះទូកបើកក្ដោងត្រឡប់ទៅវិញ លុះខ្ញុំឃើញទូកនោះទៅឆ្ងាយ ល្មមពួកទាំងនោះមើលមិនឃើញខ្ញុំ ក៏តាំងផ្ដើមចុះពីលើដើមឈើ ហើយដើរសំដៅទៅកាន់ទីដែលគេជីកដីនោះ ៗ ខ្ញុំក៏តាំងកាយដីចេញបានឃើញគំរបមាត់រូងនោះ ទើបខ្ញុំលើកចេញឃើញមានជណ្ដើរមួយចុះទៅក្នុងដីជ្រៅពីរ ខ្ញុំក៏ចុះតាមជណ្ដើរនោះទៅក៏ចុះដល់ទៅបន្ទប់មួយធំ ឃើញមានកម្រាលជើងទីងត្រាប ១ មានក្រាលកម្រាលយ៉ាងល្អ មានខ្នើយកើយខ្នើយគងនឹងខ្នើយឧបត្រម ហើយឃើញក្មេងនោះអង្គុយកាន់ផ្លិតនៅលើគ្រែនោះ ៗ ខ្ញុំសំគាល់ឃើញវត្ថុទាំងអម្បាលមាន ដោយអំណាចពន្លឺទៀនពីរ ដែលអុជបំភ្លឺក្នុងទីនោះ ក្មេងនោះឃើញខ្ញុំក៏មានសេចក្ដីភិតភ័យ ប៉ុន្តែខ្ញុំស្រែកប្រាប់ទៅផងប្រញាប់ថា "ចូរអ្នកឯង កុំមានសេចក្ដីភ័យបារម្ភអ្វីឲ្យសោះ ៗ

(មានត)

# ប្រវត្តិស្ដេចទឹកស្ដេចភ្លើង

## ឧកញ៉ាទេពពិទូរ– ក្រសេមរៀបរៀង

(តពីលើចប់)

អាការនៅរបស់ស្ដេចទឹកស្ដេចភ្លើងនោះ គឺនៅតែពីរនាក់ត្រមង់ត្រមោចតែបែបយ៉ាងតាបសបួស គ្មានមនុស្សប្រុសស្រីទៅនៅលាយឡំផងទេ ខានមុខការជាអ្នករក្សាព្រះខ័នព្រះរំពាត់ នឹងគ្រប់គ្រងពួកមនុស្សព្រៃផងគ្នាឲ្យនៅជាសុខ តាមភូមិភេទរបស់ខ្លួន ៗ

ការរក្សាព្រះខ័ននិងព្រះរំពាត់ៈអាវុធទាំងពីរនេះ ជារបស់បុរាណតាមដែលគេដំណាលត ៗ មកថា ជារបស់ព្រះមហាក្សត្រខ្មែរដែលទ្រង់ប្រទានទៅស្ដេចទឹកស្ដេចភ្លើងអង្គដំបូង នៅរក្សានៅគង់ដរាបដល់សព្វថ្ងៃនេះ ៗ ព្រះខ័ននោះមានលក្ខណៈដូចម្ដេច ក្នុងសម័យនេះគ្មានអ្នកណាដឹងបាន តែគេស្មានថាមានលក្ខណៈមិនសូវជាល្អផិតផង់ណាស់ទេ តែប្រហែលគ្នានឹងព្រះខ័នស្ដេចត្រាញ់របស់ខ្មែរយើងប៉ុណ្ណោះឯង ៗ ឯព្រះរំពាត់នោះ ជាផ្ដៅក្រែកមានចង្កឹះធំវិចិត្ររចនាដូចម្ដេចខ្លះ គ្មានអ្នកណាដឹងបានជាប្រាកដ ព្រោះតាំងពីព្រះរាជទានទៅស្ដេចទឹកស្ដេចភ្លើងហើយ ក៏គ្មានអ្នកណាបានទៅឃើញ ទោះបីមានអ្នកទៅដល់ខ្លះ ក្នុងសម័យក្រោយ ៗ មក ក៏ឃើញតែទាំងវត្ថុដែលគេរុំទុក ៗ អាវុធទាំងពីរនេះទ្រង់ប្រោសព្រះរាជទានទៅឲ្យជាគ្រឿងយសសម្រាប់អង្គស្ដេចទឹក

ស្តេចភ្លើង ជាការធ្វើសញ្ញាសិទ្ធិមានអំណាចកាចកាប់សម្លាប់បាន វៃម៉
យាំងស្តេចក្រាញ់ ដោយហេតុនេះគេទើបមានសេចក្តីគោរព និងយក
ចិត្តទុកដាក់ថែរក្សាដោយអស់អញ តាមដែលកិច្ចយូរ គឺមុនៗឆ្នាំយូរ
ទៅហើយនេះត្រូវគេរំកែត (សព្វថ្ងៃនេះ ប្តូរនៅវត្តព្រៃយូរវង្ស
ឃុំលេខ៤ (ក្នុងក្រុងពេញ) ឲ្យការពារ ព្រះខ័នទឹងព្រះរំពាត់នោះ គេរុំដោយ
សំពត់ព្រែពណ៌ក្រហម ព្រះខ័នដាក់ដំកល់លើជើងពាន១ ព្រះរំពាត់ដាក់
លើជើងពាន ១ ដំកល់ទុកនៅក្នុងគុហារបស់ស្តេចទឹកស្តេចភ្លើង ហើយ
មានជើងពាន ១ ទៀតដាក់ពីខាងមុខ គេតែងបេះផ្លែឈើដែលមាននៅ
ក្នុងព្រៃនោះមកដាក់លើជើងពាននេះ តាមដែលគេនិយាយតៗមកថា
ផ្លែឈើទាំងនោះគេបេះដាក់តែម្តងក៏នៅរហូតមក មិនដែលស្អុយរលួយទៅណា ៗ
តាមដែលប្រាជ្ញក្នុងព្រះរាជក្រឹត្យថា «នេះសម្រាប់ទឹងរុំព្រះខ័នឱ្យព្រះ
រំពាត់ ឈូតព្រែក្រហម ៥ ប្រវែងហត្ថ ៩»(សំពត់ព្រែ ២ កំណាត់នេះ
គឺ ១ កំណាត់សម្រាប់រុំព្រះខ័ន ១ កំណាត់ទៀត សម្រាប់រុំព្រះរំពាត់) ។
តាមសេចក្តីកត់ហេតុរឿងស្តេចទឹកស្តេចភ្លើងរបស់លោកញ៉ូង-សឿនថា
ស្តេចភ្លើងមុខងារជាអ្នករក្សាព្រះខ័ន ស្តេចទឹកមានមុខងារជាអ្នករក្សា
ព្រះរំពាត់ នៅក្នុងវេទិកា ១ ក្នុងស្រុកជ្រាយ ។ អាការដែលស្តេចទឹក
ស្តេចភ្លើងរក្សាព្រះខ័ននិងព្រះរំពាត់នោះ ប្រហែលគ្នានឹងពួកបារគូរក្សា
ព្រះខ័នរាជ្យនៅក្នុងព្រះបរមរាជវាំងសព្វថ្ងៃនេះ ។

ការគ្រប់គ្រង៖ តាមឯកសារប្រវត្តិសាស្ត្រនានា ដែលតាំងស្ដេចទឹក ស្ដេចភ្លើងឡើង ដើម្បីឲ្យរក្សាសេចក្ដីសុខក្នុងព្រៃទឹកក្នុងរវាងជាតិអ្នកព្រៃ ទួលជាតិខ្មែរ ជាដំណាងព្រះមហាក្សត្រពិតខ្មែរ សមដូចជាសេចក្ដីក្នុងព្រះរាជក្រឹត្យមួយអះអាងថា "ព្រះចៅក្រុងជាម្ចាស់ត្រាស់លើត្បូងទឹកញ្ញាធិកពិការ ទួលចៅពញាធិកបរិយា ឲ្យនាំព្រះរាជទ្រព្យរឿងរ៉ាវបណ្ណាការផងចេញមកដល់ស្រុក អាយុន អាប៉ា[1] ប្រសិទ្ធិសំដីគនាមករបស់ម្ទេសពារក្ស ដំកល់ដំកើងឡើងសន្មតយកឲ្យហៅថា ស្ដេចទឹកស្ដេចភ្លើងស្ទួនមារក្សព្រះវ័នទៅកៀកពួលក្ដុំ ទុក្ខមព្រាកជាម្ចាស់លើអស់ស្រុករដែរព្រាយ ពួនតាមគន្ធនប្រវេណីអំពីបុរាណរៀងៗ មកនៃគងទឹងតាក់តែងរក្សាការគ្រងប្រយ័ត្នផ្លូវព្រៃស្រុករផង ឲ្យដឹងជា-ដឹងការ" ដូច្នេះយើងអាចនិយាយថា អ្នកដែលបានតាំងជាស្ដេចទឹកស្ដេចភ្លើង ទុកដូចជាកូយរបស់ព្រះមហាក្សត្រពិតៗ ទុកដូចជាមាក្លូយត្រូវធ្វើការគ្រប់គ្រងស្រុកទេសក្នុងផ្នែកនោះជំនួស ដូចយ៉ាងស្ដេចត្រាញ់ ការដែលទទួលព្រះរាជទានព្រះខ័នខ័ងព្រះរំពាត់ទៅនោះ គឺទទួលព្រះរាជអំណាចឲ្យ ចាត់ការគ្រប់គ្រងតាមតួនាទីការ ។ ការគ្រប់គ្រងរបស់ស្ដេចទឹកនឹងស្ដេចភ្លើងនោះយ៉ាងណាៗ គ្មានឯកសារច្បាស់លាស់ណាមួយទេ ប្រាកដតាមដែលចាស់ទុំតែងនិយាយដំណាលមកថា ក្នុងតំបន់នីមួយៗ ដែលមានប្រជុំជន

[1] អាយុន អាប៉ា នេះប្រហែលជាប្រែថា ស្ដេចទឹកស្ដេចភ្លើង ។

ទៅប្រើ ក៏តាំងឱ្យធ្វើជានាយកត្រួតត្រា ហៅថា "មេក្រៀញ" ឯមេកន្ទ្រាញនេះ មានមុខការត្រួតត្រារក្សាសុខទុក្ខរបស់បណ្ដារាស្ត្រ ដែលនៅក្នុងអំណាចរបស់ខ្លួនកុំឱ្យប៉ះពាល់ កុំឱ្យឈ្លោះទាស់ទែងគ្នា ពួកគ្នាឯង ឬទាំងពួកថៃ ទាំងការពារកុំឱ្យពួកថៃមកបៀតបៀន ឬចាប់យកទៅលក់ ព្រោះអំពីដើមពួកមនុស្សព្រៃនេះច្រើនតែចាប់គ្នាឯងយកទៅលក់ឱ្យខ្មែរ ១ ទទួលទិញយកទៅប្រើឱ្យធ្វើការខាងនេះសមដូចក្នុងសៀវ-ភៅកំណត់ហេតុអំពីរឿងស្រុកខ្មែរ[1] របស់លោក ជីវតាក្វាន់ថា (ខ្មែរ) គេទិញមនុស្សព្រៃមកប្រើធ្វើការ អ្នកមានធនធានច្រើនមានមនុស្សបម្រើចំនួនច្រើនជាងមួយរយនាក់ក៏មាន ពួកអ្នកដែលមានធនធានតិច ក៏គង់មានពីត្រឹម ១៥ ដល់ ២០ នាក់ក៏មាន លើកលែងតែអ្នកដែលទាល់ក្រណាស់ ទើបមិនមានខ្ញុំប្រើនឹងគេ ។ ទំនៀមតាំងមេកន្ទ្រាញមានដរាបមកដល់សព្វថ្ងៃនេះ, ការគ្រប់គ្រងរបស់ស្ដេចទឹកស្ដេចភ្លើងមានត្រឹមបន្តិចបន្តួចប៉ុណ្ណោះ ។

## ទំនៀមផ្ញើសស្ដេចទឹកស្ដេចភ្លើងឡើងស្ដេចខ្មែរ

ទំនៀមពីដើមការខ្មែរបុរាណនោះ ស្ដេចប្រទេសរាជ និងស្ដេចត្រាញ់កំណត់ឱ្យនាំផ្កាមាសផ្កាប្រាក់ និងបណ្ណាការមកថ្វាយព្រះមហាក្សត្រាធិរាជនៅក្រុងធំរៀងរាល់ឆ្នាំ គឺក្នុងមួយឆ្នាំម្ដង ចំណែកឯស្ដេចទឹកស្ដេច

---

១ រឿងនេះ ឃុនសិពន្ធមន្ត្រី ញ៉ុក - ថែម ប្រែពីភាសាបារាំងមកជាខ្មែរ មាននៅពុទ្ធសាសនបណ្ឌិត្យ លេខ ក- ៥៤ មើលត្រង់ទំព័រ ១១ ។

ភ្លើងវាបំពួកស្តេចចំណុះដែរ តែការឡើងបានកំណត់ឲ្យពេលជានិច្ច គឺក្នុង ៣ ឆ្នាំត្រូវឲ្យមកឡើងម្តង ក្នុងការមកឡើងនេះ គ្មានកំណត់ឲ្យនាំយកអ្វីមកជាកេដបណ្ណាការផងទេ ប្រហែលវាដោយទ្រង់ឃើញថា អ្នកព្រៃនោះមុខតែជាអ្នកក្រ គ្មានរបស់អម្រែអ្វីឲ្យជាឧត្តមសមគួរនឹងឲ្យយកមកថ្វាយទេ ឲ្យមកគ្រាន់តែឲ្យបានឃើញមុខគ្នា ដើម្បីសំដែងសេចក្តីមេត្រីទៅវិញទៅមក ហើយនឹងបានសួរពីសេចក្តីសុខទុក្ខក្នុងស្រុកទេសឯណោះជាដូចម្តេចខ្លះ ដែលគ្រប់គ្រងមក ហើយនឹងឲ្យទូន្មានផ្តុំបូន្មានខ្លះ ដើម្បីឲ្យមានចិត្តគ្រប់គ្រងស្រុកទេសឲ្យបានសុខស្រួលតទៅ ។ ទោះបីដូច្នោះ វេលាដែលមក, ស្តេចទឹកស្តេចភ្លើង ក៏មិនបានមកដៃទទេ តែងនាំនូវរបស់ព្រៃបន្តិចបន្តួចជាបណ្ណាការយកមកថ្វាយរៀងរាល់ដងដែលមក តាមទំលាប់មកពីព្រេង គឺក្រមួនឃ្មុំ ត្រាប់ល្អ កុយ ភ្លុក ខ្ទើង ស្បែក ស្លាប សត្វព្រៃ វល្អ ៗ ចំឡែកៗ ។ របស់ទាំងនេះនៅស្រុកព្រៃសម្បូណ៌ ហើយជារបស់សំខាន់ក្នុងស្រុកនេះផង ទើបបាននាំយកមកថ្វាយ តាមដែលមានដូច្នេះ ។ ក្រមួននោះគេរំលាញ់ជាដុំធំៗ ហើយស្តេចទឹកស្តេចភ្លើងយកត្រាមេដៃបន្តក់ចុះ ឲ្យលេចឃើញលាយលក្ខណ៍ដើម្បីសំគាល់ជំនួសចុះហត្ថលេខានឹងបោះត្រា ព្រោះពួកមិនចេះអក្សរទេ គ្មានត្រាបោះ ។

លុះដល់កាលកំណត់, ស្តេចទឹកស្តេចភ្លើងក៏យកគ្រឿងរាជបណ្ណាការ យ៉ាងដែលពោលមកហើយ ឡើងដំរីមកកាន់ស្រុកសំបុក ដែលគេកំណត់ទុកជាទ្វារព្រះនគរ ទីដែលជាទីសម្រាប់ទទួលជួបស្តេចទឹកស្តេចភ្លើង ។ មកដល់ទ្វារព្រះនគរក៏ឈប់នៅទីនោះ មិនបានចូលមកដល់ក្រុង មិនបានជួបគាល់ព្រះករុណាម្ចាស់ផែនដីទេ ។ មកឡើងក្នុងខែណា ? ថ្ងៃប៉ុន្មានកើតប៉ុន្មានកេច? គេតាំងកំណត់មកគ្នាឲ្យដឹងទៅវិញទៅមកជាស្រេចហើយ តែឥឡូវមកក្នុងវេលានេះមិនសូវមានអ្នកណា នឹងចាំបានឲ្យពិតប្រាកដ មានចាស់ទុំដោយច្រើនថា មកឡើងក្នុងខែពិសាខ តែនៅថ្ងៃប៉ុន្មានកើតប៉ុន្មានកេចនោះចាំមិនបាន ដោយប្រមាណមើលប្រហែលជាកំណត់មកក្នុងរដូវដើមឆ្នាំនៃឆ្នាំទី ៤ គឺដាច់ឆ្នាំទី ៣ ចូលមកក្នុងខែពិសាខនៃឆ្នាំទី ៤ ក្នុងថ្ងៃណាមួយ ក៏ចុះមក ដើម្បីកម្រឲ្យត្រៀមតាំងពេលឡើងអ្នកតា ព្រោះក្នុងឱកាសនោះមានពិធីឡើងអ្នកតាផង ។

ចំណែកខាងព្រះរាជាក្រុងកម្ពុជាធិបតី លុះដល់កាលកំណត់នោះហើយ ទ្រង់ចាត់ឲ្យមន្ត្រី ២ — ៣ នាក់ជារាជទូតតំណាងព្រះអង្គ ឲ្យនាំយករាជបណ្ណាការដែលសម្រាប់ព្រះរាជទានស្តេចទឹកស្តេចភ្លើង ឡើងដំរីទៅឯស្រុកសំបុក របស់ដែលសម្រាប់ព្រះរាជទានក្នុងឱកាសនេះមានចំនួនតិចជាងរបស់ដែលព្រះរាជទានក្នុងឱកាសតែងតាំងស្តេចទឹកស្តេចភ្លើង តាមទម្លាប់រៀងមក តាមដែលចាស់ទុំទាំងឡាយមានលោកគង្គុយ

(ទេសញ្ញាំយួរយ៉ៃត្រែក) ជាដើម ភ្ជាប់ដីងមកជាសំពត់ផាមួងឬសំពត់ទេស ៦៩ សំពត់ជាតិ ក្នុងមួយមុខ ២ ក្បិន (មួយក្បិន ១០ ហត្ថ) និង ល្មួតស្លាន់ (សម្រាប់ធ្វើអង់បំពេញទពាង) នូវអំបិលជាដើម របស់អំណាលនេះ ត្រូវចែកជា ២ ភាគថ្វាយទៅស្ដេចចន ១ ភាគ ទៅស្ដេចកើន ១ ភាគ ។

កាលស្ដេចចនស្ដេចកើន និងរាជទូតខ្មែរទៅជួបជុំគ្នាហើយខាងរាជទូតខ្មែរត្រូវចាត់ការធ្វើពិធីទៀងអ្នកតា និងជប់លៀងស្ដេចចនស្ដេចកើនជួបមានពេលហើយគងបចដែលនិយាយពីដៃងការងារស្ដេចចនស្ដេចកើនខាងដើម ស្រេចកិច្ចជប់លៀងគ្នាហើយ រាជទូតខ្មែរក៏ផ្ដើមនិយាយតាមផ្លូវរាជទូតទៅនឹងស្ដេចចនស្ដេចកើន តាមតួនាទីការហើយ ក៏ថ្វាយគ្រឿងរាជបណ្ណាការទៅស្ដេចចនស្ដេចកើន ឯស្ដេចចនស្ដេចកើនក៏យកគ្រឿងរាជបណ្ណាការរបស់ខ្លួនប្រគល់ឲ្យរាជទូតខ្មែរ ឲ្យនាំយកទៅថ្វាយព្រះករុណាជាម្ចាស់ជីវិតលើត្បូង ហើយក៏លាចាកគ្នាទៅ ។ លុះគ្រប់ឆ្នាំក៏មកទៀងជួបគ្នាទៀត គ្រប់ៗ ត្រីវស្សរ៍ ។

ស្ដេចចនស្ដេចកើនកាន់តំបានអំណើតទៀងជាថ្មី ដោយព្រះបាទសម្ដេចព្រះស្រីសុរិយោពណ៌ ទ្រង់ស្ដាប់តាមទៀងនោះ គេសង្កេតឃើញថា ត្រឡប់រុងរឿងដោយយសសក្ដិអំណាច និងលាភសក្ការៈ ទៀងវិញជាច្រើន ដោយព្រះមហាក្សត្រតាំងឲ្យ ទ្រង់រាជការ

ក្នុងពេលដែលតែងតាំងឡើងជាថ្មី ឬក្នុងពេលដែលឡើងតាមទេសកាលផ្សេងៗ ដោះទ្រង់ព្រះរាជទានទ្រព្យសម្បត្តិផ្សេងៗ ជាច្រើនយ៉ាង ដូចមានពោលមកខាងដើម តាំងនេះច្រើនស្តេចទឹកស្តេចភ្លើងមានសេរីភ្លាឡើងវិក្រល តាំងពួកពួងក៏មានសេចក្តីនិយមក្នុងបានជាស្តេចទឹកស្តេចភ្លើងច្រើនឡើង ក្នុងពេលដែលកើតស្ថាបនាឡើងជាថ្មីៗ ខណៈអ្នកស្ម័គ្រទទួលធ្វើដោយស្រួល មិនលំបាកកើសដូចក្នុងសម័យបច្ចុប្បន្ននេះ តាំងសេចក្តីសម្ពន្ធមេត្រីភាពខ្មែរនិងពួងក៏ជិតជិតគ្នាច្រើន រហូតដល់ទៅពួកពួងក៏ចេកកាស្រ័យនៅក្នុងចំណោមពួកខ្មែរ ហើយថែងផ្លាស់កេរស្លៀកពាក់តាមសណ្តាប់ខ្មែរ ។ ក៏មានច្រើន អ្នកខ្លះបានតាំងធ្វើជាមន្ត្រីក្នុងស្រុកនេះ ដូចយ៉ាងឈ្មោះ យ៉ត ជាដើម ដែលបានធ្វើជាចៅញ៉ាគេជា ចៅហ្វាយស្រុក សក្តិ ១០ ហ៊ូពាន់ ឈរនៅស្រុកកំពង់ស្វាយ សព្វមានប្រាកដក្នុងក្រាំងពង្សាវតារស្រាប់ ។

ចំពោះតែងតាំងស្តេចទឹកស្តេចភ្លើង និងចំពោះស្តេចទឹកស្តេចភ្លើងមកឡើងស្តេចខ្មែរនេះ មានរៀងរៀងមកដល់ទឹងរជ្ជកាលព្រះបាទសម្តេចព្រះហរិរក្ស (ព្រះអង្គដួង) ទើបដាច់ដកបមកដល់សព្វថ្ងៃនេះ ។ ក្នុងរឿងនេះលោកគិត្ត យូរ (ឧកញ៉ាយ៉ូរ ចៅហ្វាយខែត្រក្រចេះ) បានពណ៌នាថា ការលោកនៅធ្វើចៅហ្វាយខែត្រត្រូវបានឮពួកពួងដែលចុះមកក្នុងខែត្រនោះថា ស្តេចទឹកស្តេចភ្លើងដែលលើកលែងមក

ឡើងស្ដេចខ្មែរគាំទ្រពីកាលណាមក? ពួកពង្សាវតារនោះតបថា កាំងពី
រជ្ជកាលព្រះបាទសម្ដេចព្រះហរិរក្ស (ព្រះអង្គដួង) មកដោយព្រះកជា
គន្ធនេះទ្រង់បោះបង់ចោលតែម្ដង ។

## ស្ដេចទឹកស្ដេចភ្លើងក្នុងបច្ចុប្បន្ន

សម័យស្ដេចខ្មែរបោះបង់ចោលដូច្នេះហើយ ស្ដេចទឹកស្ដេចភ្លើងក៏នៅមានគេមកទៀតដកបដល់សព្វថ្ងៃនេះ ការដែលមានគេមកនោះដោយហេតុពួកពង្សមានសេចក្ដីគោរពតាមប្រពៃណីដែលធ្លាប់មកហើយ អំពីបុរាណកាលថា យ៉ាងនៃក្រពេក ដូចយ៉ាងព្រះខ័នគេសំគាល់ថា ជារបស់សក្ដិសិទ្ធិសម្រាប់អ្នកមានបុណ្យជាម្ចាស់លើគេការកតអំពីស្ដេចទឹកស្ដេចភ្លើងទៅហើយ ទីងបោះបង់ចោលទៅក៏ពុំកើត ទីងលើកឲ្យទៅអ្នកណាមួយក៏ពុំបាន ទើបគេនាំប្បត្តិកឲ្យមានអ្នកតំណាងស្ដេចទឹកស្ដេចភ្លើងតមក, តែការរើសខ្លួនជាស្ដេចក្នុងសម័យនេះ តាមដែលពួកពង្សតំណាលមកថា ជាការលំបាកយ៉ាងនៃក្រពេក ព្រោះគ្មានអ្នកណាស្ម័គ្រចិត្តទីងធ្វើសោះ វេលារើសម្ដងៗ គេនាំបង្ខំឬគេចាប់ខ្លួនមកសន្តតឲ្យធ្វើទើបបាន, តាមសេចក្ដីគត់បោត្ថុរបស់លោកញូង-សៀង ក៏ថាដូច្នេះដែរ ។ ការដែលលំបាករើសខ្លួនទាំងម្ដេះ ក៏ព្រោះការធ្វើក្នុងដំណែងនោះមានមុខការត្រង់តែជាអ្នករក្សាព្រះខ័នទីងព្រះរំពាត់ គ្មានផលប្រយោជន៍អ្វី គ្មានឬទ្ធិអំណាចរួចអំពីដើម នៅត្រង់គ្រោះថ្នាក់កណ្ដាលខ្លួននៃព្រៃ

ហាក់ដូចជាគេយកទៅប្រោសទោល ។ ន័យមួយទៀត គេជឿថាអ្នកដែលទទួលធ្វើជាស្តេចទឹកស្តេចភ្លើងក្នុងសម័យនេះ រមែងតាញ់ខ្លួន គឺងាយក្រខ្វាចង់ស្លាប់, ចំណែកឯស្តេចទឹក នោះគេថាតាញ់បុណ្យស្តេចភ្លើង មិនឃើញរស់ ៤-៥ ឆ្នាំក៏គាំងស្លាប់, ហេតុតែនេះហើយ ដែលនាំឲ្យពិបាករើសខ្លួនណាស់ តែដោយហេតុគេកាន់ខ្ជាប់ក្នុងទំនៀមទម្លាប់ដើមក្លាំងពេក ស្តេចទឹកស្តេចភ្លើងមិនបាត់អាយុកែសាវ មកដល់សព្វថ្ងៃនេះបាន ហើយមិនបានមកឡើងស្តេចខ្មែរដូចអំពីដើមទេ ។

ចំណែកឯពួកក្រស្តខ្មែរនៅតំបន់ឡាវព្រះនគរ ដែលប្លាប់ធ្វើពិធីឡើងអ្នកតាព្រះគន្ធព្រះខ័នមកអំពីដើមដូចម្តេច ក៏មិនហ៊ានបោះបង់ចោលទោះនៃធ្វើជាបន្តមកដល់សព្វឆ្នាំនេះ តាមក្នុងសេចក្តីកត់ហេតុរបស់លោកញ៉ង់-សៀង ថាមាន ធ្វើរាល់ឆ្នាំ ក្នុងមួយឆ្នាំគេធ្វើពីរដង គឺធ្វើក្នុងខែបុស្ស ឬ ខែមាឃម្តង ក្នុងខែពិសាខ ឬ ខែជេស្ឋម្តង តែការណាតាំងប៉ុណ្ណោះឆ្នាំគេធ្វើពិធីជាពិសេសម្តង ។ ពិធីដែលធ្វើជាបុណ្យគានោះជាពិធីតូច ពុំនកំណត់ដូច្នេះ តែកាលណាដល់រដូវនោះហើយ ជំទប់អ្នកតាដើរប្រមាណអ្នកស្រុកដែលចំណុះអ្នកតានោះ ឲ្យយកស្រូវ ឬជាទៅថ្វាយអ្នកតាតាមថ្ងៃដែលគេកំណត់ទុក តាមទម្លាប់ដែលគេធ្វើមក ក្នុងមួយផ្ទះត្រូវឲ្យមានបាទស្លា ៣ មាន់ការ ១ បាយដំណើប ១ ចាន ទំនួមទាំងអស់គាប្រមានស្រាអក ១ ពាង ក្រៅអំពីនេះ អ្នកដែលត្រូវការសុំពរអ្នកតា

ក៏មានអម្បោះសបទិប ៗ ម្នាក់ៗទៅផង ។ ឯរឿងបញ្ចាន់រូបសំណាក់ក្នុងសម័យនេះគ្មានទេ, កាលដល់ពេលជួបជុំគ្នាហើយ គេយកចានស្លា ១ មាន់អាំង ១ បាយដំណើប ១ ចាន យកទៅរៀបដាក់នៅមុខអ្នកតា អ្នកមានអម្បោះក៏យកអម្បោះដាក់ក្នុងជើងពានយកទៅដាក់ផង ហើយអុជទៀនធូប នាំគ្នាសែនព្រេនថ្វាយអ្នកតាទៅ ទាំងសុំពរឲ្យស្រុកទេសសុខសប្បាយ ប្រាសចាកជម្ងឺថ្កាត់សុំឲ្យមានភ្លៀងល្អជាដើម ហើយផ្ដងស្រាអាតចុះលើគ្រឿងក្រយា អ្នកខ្លះក៏យកដាវមកអុជធូបដោតទៀន ប៉ុណ្ណោះឈ្មោះថាស្រេចកិច្ចឡើងអ្នកតានេះហើយ ។ កាលសែនព្រេនរួចគេក៏ជប់លៀងគ្នាដោយអាហារដែលនាំមករៀងខ្លួន ទាំងស្រាអាកដែលសេសសល់ពីអ្នកតា រួចហើយនាំគ្នាទៅទីលំនៅវិញ យកអម្បោះទៅចងកចងដៃឲ្យកូនចៅ ដើម្បីការពារកុំឲ្យឈឺថ្កាត់ ។

វេលាដល់ពេលតំបេ ៣ ឆ្នាំ គេធ្វើពិធីជំនុំគ្រប់គ្រួសារ របៀបធ្វើនបរិប្រោបដូចមានពោលមកហើយខាងដើម ប៉ុន្តែមកក្នុងសម័យនេះគ្មានបញ្ចាន់រូបផងទេ ។ ការឡើងអ្នកតានេះ ប្រព្រឹត្តទៅតាមប្រវេណីដែលមានមកហើយពីបុរាណកាល តែមើលទៅឃើញហាក់ដូចជាដំណាងការដែលស្ដេចទឹកស្ដេចភ្លើងមកឡើងស្ដេចខ្មែរពីដើម ។

សំនៀងបកក្នុងប្រវត្តិស្ដេចទឹកស្ដេចភ្លើងចប់តែប៉ុណ្ណេះ ។

# នារាយណ៍ទសាវតារ

ឧកញ៉ាទេពពិទូរ - ក្រសេម រៀបរៀង

(តទៅនិងចប់)

អ្នកឥតគ្នាសក៏កំណត់យកព្រះពុទ្ធទៅជាព្រះអវតារទី ៩ របស់ខ្លួន ដើម្បីឲ្យមនុស្សប្រុះចូលរួមជាមួយគ្នា តែតាមសេចក្តីពិតនោះគឺព្រះពុទ្ធមិនបានជាព្រះអវតាររបស់ពួកនេះកំទេ ។

កលក្កាវតារ មិនខានមកក្នុងកលិយុគ តាមពាក្យទំនាយថា មានរូបជាបុរសជិះសេះស ដាំអ្នកកាចកម្រោលមនុស្សគ្រក់បានទូទៅទាំងលោក និងបណ្តាលឲ្យមនុស្សមានសត្យធម៌ក្នុងលោកឡើងវិញ ដូចការេក្នុងយុគ, ដាគម្ពីរសំដែងសេចក្តីសង្ឃឹមទៅក្នុងអនាគត ដូចយ៉ាងពួកពុទ្ធសាសនិកជនដែលប្រាថ្នាឲ្យជួបនឹងព្រះអរិយមេត្រីយ ។

ព្រះនាមរបស់ព្រះនារាយណ៍មានចំនួនកប់ពាន់ ហៅតាមគុណវុឌ្ឍិតែជះនឹងតាមហេតុការណ៍ដែលជាសេចក្តីប្រសារ៍មាន គេការ់ថា អ្នកណារទេញចាំបាននិងមានបុណ្យ គឺ: ១-បញ្ចាំង = ក្រុម ៥ យ៉ាង, ២-នារាយណ៍ = ការម្រឹតក្នុងទឹក, ៣-បុរស = ប្រុស, ៤-អច្យុត = មិនពេះច្យុតយថោក, ៥.អនន្ត = គ្មានទីបំផុត, ៦-ហរិ = សូនកេក្យ, ៧-គោវិន្ទ ឬគោបាល = រក្សាផែនដី, ៨-អនន្តសៃយនៈ = ដេកលើនាគអនន្ត-

នាគពជ, ៩- ចតុភុជ = ដៃបួន, ១០- ទាមោទរ = អ្នកក្រវាត់ដោយខ្សែ, ១១- បទ្មនាភ = កើតចេញមកក្នុងផ្ចិតដូចទឹកឃ្មុំ, ១២- ហ្ឫសិកេស = ជាម្ចាស់នៃរបស់ដែលធ្វើឲ្យកើតសេចក្ដីដឹងខ្លួន, ១៣- ជលសាយិន = ដេកលើទឹក, ១៤ កុម្មុទ្ធ = អ្នកដំកួច, ១៥- បទ្មនាភ = ផ្ចិតផ្កាឈូក, ១៦- បីតម្ពរ = ស្លៀកលឿង, ១៧- មធុសូទន = អ្នកសម្លាប់មធុ គឺអសុរដែលព្យាយាមប្រទូសរ៉ាយព្រះព្រហ្មដែលកើតក្នុងផ្កាឈូក សង្កត់សង្កៀនអំពីនាភីព្រះអង្គ, ១៨ គិរីតិន = អ្នកទ្រង់គ្រឿងប្រដាប់ប្រដាក្បាល, ១៩- ត្រិវិក្រម = កាន់ ៣ ជំហាន, ២០- លក្ស្មណាបតិ = ប្ដីព្រះលក្ស្មី, ២១- ជនាទ្ទន = អ្នកដែលជនរាប់អាន, ២២- នរ = មនុស្ស, ២៣- វាសុទេវ = បុត្រព្រះវសុទេព, ២៤- បុរុសោត្តម = ទេវកជ, ២៥- យជ្ញេស្វរ = ម្ចាស់នៃយញ្ញកម្ម, ២៦- វៃកុណ្ឋនាថ = ជាធំក្នុងវៃកុណ្ឋ, ២៧- ចតុរវ្យូហ = ដៃបួន, ២៨- កេសវ (កេសរ) = មានសក់ក្រាស់ឬសក់ល្អ, ២៩- ស្រីករ = ដៃមានស្រី, ៣០- ស្រីសំភារ = ដៃកាន់សំរិទ្ធិមានស្រី, ៣១- វិណ្ហុបុរិស្ន..., ៣២- គុន្ធិស = អ្នកជាធំជាងគេ ៗ ល ៗ ស្រោះព្រោះមកបាននៃតម្រុណៈ ៗ

ព្រះលក្ស្មី ( សក្តិ (sakti) ជាជាយាព្រះនារាយណ៍ មានកំណើតមកអំពីក្សីរសមុទ្រ ក្នុងកាលដែលកូរសមុទ្រទឹកដោះក្នុងរឿងកុម៌ាវតារ, ក្នុងខ្ទះពោលថា នាងជាធីតាឫសីភ្រិគុ ដែលជាសង្សារក្នុងយុគព្រះវេទនីទ ធីតាព្រះទក្ស ១, មាននាមហៅផ្សេងៗ គឺលោកមេ = មេរបស់លោក

លោកមាតា = មាតារបស់លោក, ជាអ្នកទ្រង់នូវសិរីរូបដ៏ល្អ ជាស្នេហ៍ ជាទេវី នៃសេចក្តីស្រឡាញ់គឺជាកាមទេព ដូចកាលព្រះនាងផុះឡើងអំពីពពុះក្សីរសមុទ្រ ពួកទេវតាទាំងអសុរឃើញក៏កើតសេចក្តីស្នេហាខ្លាំងក្រៃ ១ខ ពួកអសុរពោញកះដោយរូបតោមនាង ទើបមិនបានទឹកអម្រឹត ។ ព្រះព្រហ្ម ជាពាក្យប្រែ នាងជាពាក្យនិយាយ, ព្រះវិស្ណុជាអ្នកកាត់សេចក្តី នាងជាអ្នកអង្វរសុំ, នាងជាផែនដី ព្រះនារាយណ៍ជាអ្នកឧបត្ថម្ភផែនដី, នាងជាទេពនារីអំណោយពរ មានព្រះហឫទ័យប្រកបដោយមេត្តាករុណាជានិច្ច ភាពហាជាស្នេហ៍គួរឲ្យក្រេបផឹក នាងឧត្តមដោយគុណសម្បត្តិ ដូច្នេះ ទើបបាននាមថាគគតី ជាអ្នកឧបត្ថម្ភស្រីគ្រប់ជាន់ ។ រូបភាពនេ ច្រើនធ្វើជារូបស្រីសម្បុរមាស ដៃបួនក៏មាន ដៃពីរក៏មាន ចំណាំតែឈរលើផ្កាឈូករីក នៅចន្លោះរូបដំរីពីរ ដំរីនោះស្រោចទឹកលើសិរនាង ឬមិនដូច្នោះ ក៏លោស់ផ្កាឈូក, បើជារូបម្នាក់ឯង តែងខ្លួនពេញយស សិរប្រដាប់ដោយឧនពគេទ៌ ដៃកាន់ផ្កាបទុម មានអន្ទាក់សម្រាប់ចាក់ មានអំបោកគ្រំសម្រាប់វាះ ។ នៅស្រុកជ្វា នាងក្លាយទៅជាព្រះស្រីស្រពណ៍ ជាអ្នកឲ្យកំណើតស្រូវដល់ពួកកស្ត ដៃឆ្វេងកាន់កួរស្រូវ ដៃស្តាំធ្វើគ្រឿងសំគាល់នៃសេចក្តីមេត្តាករុណា ។

ព្រះលក្ស្មីជាគូនឹងព្រះនារាយណ៍ មិនសូវដែលឃ្លាត បានតាមស្តេចអវតារមកកើតច្រើនគ្រាគឺ ក្នុងកុមារីការ នាងកើតក្នុងក្សីរសមុទ្រ

ទើបបាននាមថា ក្សីរព្ធិតនយា កូនស្រីរបស់ក្សីរសមុទ្រ ឬជលធិជា កើតអំពីទឹក, ក្នុងកំមនាវតារ នាងចុះមកកើតក្នុងផ្កាឈូក ទើបមាននាមថា បទ្មា ឬកមលា; ក្នុងបរសុរាមាវតារ នាងជានាងធរណី, ក្នុងរាមចន្ទ្រាវតារ នាងជានាងសីតា, ក្នុងក្រឹស្នាវតារ នាងជានាងរុក្មិណី; ហេតុនេះគេអាចនឹងឃើញបានថា គ្រប់គ្រាដែលមកកើតរមែងជាទេវីស្រឡាញ់របស់ព្រះអវតារទាំងអស់, ក្រៅអំពីនេះនៅមាននាមថា ឥន្ទិរា, កញ្ចក់ឬរណាជាដើម ។

ក្នុងទីខ្លះពោលថា ព្រះវិស្ណុមានមហេសី ៣ អង្គ គឺព្រះសរស្វតី, ព្រះគង្គា ព្រះស្រី (លក្ស្មី); នាងទាំង ៣ នេះមានសក្តិស្មើគ្នា ជាធំរៀងខ្លួនមិនបេះញមអ្នកណាឡើយ, ចំណាំតែតាមរឿងឲ្យក្តៅក្រហាយដល់ព្រះវិស្ណុញយៗ ទើបទ្រង់ត្រាស់លះព្រះសរស្វតីឲ្យទៅព្រះព្រហ្ម ព្រះគង្គាឲ្យទៅព្រះសិវៈ ព្រះអង្គឯងនៅសល់តែព្រះលក្ស្មីមួយ, តម្រាខ្លះពោលថា ព្រះធរណី (ភូមិទេវី) គឺជាជាយារបស់ព្រះអង្គដែរ ។

អាវុធ = ព្រះនារាយណ៍ទ្រង់អាវុធ ៥ យ៉ាងគឺ ១ ស័ង្ខឈ្មោះបញ្ចជណ្យ, ២ - ចក្រឈ្មោះសុទស្សនៈ ឬវជ្រនាភៈ, ៣ - គទា (ដំបង) ឈ្មោះកោមោទកី, ៤ - ធនូឈ្មោះសារង្គៈ, ៥ - ដាវឈ្មោះនន្ទកៈ ។

រូបព្រះវិស្ណុដែលគេសាងឡើងច្រើនធ្វើដៃ ៤ ហើយកាន់ស័ង្ខ, ចក្រ, គទានិងផ្កាឈូក នៅទ្រូងមានរោម គេហៅថាយន្តស្រីវត្សៈ មានស្នាប់ទ្រូងឈ្មោះកៅស្តុភ មានវល័យ (កង) ប្រដាប់ដោយត្បូង សយមន្តកៈ ។

វៃកុណ្ឋ = ឋានសួគ៌ដែលព្រះវិស្ណុទ្រង់សណ្ឋិតនៅឈ្មោះ វៃកុណ្ឋ, គង់នូវមហាសាគរតែពោលថាផែនដីនោះជាមាសទាំងផែន, មានបរិមណ្ឌល ជាប់ប្រាយជុំវិញ ៨០ ម៉ឺនយោជន៍ វិមានប្រដាប់ដោយកែវមណី សសរ ទឹក ក្បៀនប្រដាប់វិមានធ្វើដោយកែវរត្ន ទាំងព្រះគង្គាទេបានចាប់ ផ្តើមពីឋានសួគ៌ជាន់ខ្ពស់បង្អស់មកពីសិរ្សព្រះ (ផ្កាយតួរ) ហូរចេញអំពីនេះ ធ្លាក់មកត្រង់កណ្ដាលមណ្ឌលព្រៃព្រាហ្ម (គឺផ្កាយទាំង ៧ ដែលហៅថា ផ្កាយក្រពើ) ហើយហូរចុះមកដល់លោកនេះ; ឋានសួគ៌ដ៏ស្ងប់ស្ងាត់នេះ នៅជា នោះលើកំពូលភ្នំព្រះសុមេរុ ដែលតាំងនៅកណ្ដាលកោះជម្ពូទ្វីបជាកណ្ដាល ផ្កាឈូក ដែលត្រកងជាលោក, មើលពីកំពូលភ្នំព្រះសុមេរុ គឺទើបឃើញ ផ្កាដ៏ ៩ ក្នុង បញ្ចូលស្មើព្រៃព្រាតទៅជុំវិញ, សត្វទាំងអស់ក្បែរដើមកំពូល វិញ ព្រះសុមេរុនេះដែលជាដែនកើតទេវតាលើឋានសួគ៌ មានស្រះ ប្រពន្ធពេញទៅដោយទឹកសម្បូរថ្ងៃមេឃ ក្របាម, ស, លើបណ្ដុំផ្កាដែល អាចគង់នៅ ទ្រង់ព្រះជន្មព្រះនាងទិព្វគន្ធពេញ (ថ្ងៃត្រង់) ព្រះ វិស្ណុគង់លើអាសនៈឈូកស មានព្រះលក្ខ្មីគង់ខាងស្ដាំ សីហាសនៈ ក្បែរកាក់ជូនដោយអ្នកដ៏រុងរឿង ទទឹមានរុំចេញ ពាក់គន្ធព្រះទេវី ព្រះនាងទាំងនោះហេតុពីរយោជន៍ ។

ស្តេចក្រុង ត្រូវជាតាហាណៈរបស់ព្រះវិស្ណុ ជាទាសព្រះកស្យបៈ ព្រះនាងវិនតា ដោយហេតុនាងវិនតា ភរិយាទទឹងនាងកទ្រូជា

មហេសីស្ដាំរបស់ព្រះកស្សបៈ ហៅថាមាតានៃនាគទាំងឡាយ, នាងកទ្រូយកឈ្មោះជាឧបាយ ពួកនាគដែលជាសត្វនៅក្នុងមហាសមុទ្រចង់ផឹកទឹកអម្រឹតនឹងគេដែរ ទើបគិតរកជាងវៃឡូវខ្លួននាងវិនតា ដែលបាក់ស្ដេចគ្រុឌមកដំគាំងដណ្ដើមយកទឹកអម្រឹតទៅ ។

ព្រះកស្សបៈ មានមហេសី ២ អង្គ គឺនាងកទ្រូនឹងនាងវិនតា, មុនដែលព្រះព្រហ្មនឹងសាងលោក បានប្រទានបុត្រតាមដែលនាងទាំងពីរត្រូវការ ដែនាងកទ្រូលោភលន់ខ្លាំងណាស់ បានសុំបុត្រដល់ទៅពាន់នាក់ នាងវិនតាសុំត្រឹម ២ នាក់ប៉ុណ្ណោះ តែនាងបានសុំឲ្យបុត្រទាំងពីរមានបុណ្យជាងបុត្រនាងកទ្រូ, កាលនាងទាំងពីរប្រសូតទារកមក ក៏មានលក្ខណៈខុសពីសាមញ្ញជន គឺជាពង ដូចនាងសិការបស់ក្រិក, កន្ទងផងជាច្រើនបែតវេ្យ (បកៈណៈរបស់ពួកហាក្ខភពជាវេលារយៈឆ្នាំ) ពងរបស់កទ្រូក៏ញាស់ចេញមកជាប្រុសៗ ចំនួនមួយពាន់ តែពងរបស់នាងវិនតាមិនឃើញហេតុថានឹងញាស់ឡើយ នាងព្រួយថានឹងប្រកួតដោយបុត្ររបស់ត្រូវដោយឆាប់ៗ ទើបដោះពងមួយឲ្យបែក ក៏ឃើញជាសត្វដែលមិនសម្បូណ៌ជាអលក្ខណៈ ពោលគឺមានតែត្រឹមពាក់កណ្ដាលខ្លួនហៅថាអរុណ ។ មានសេចក្ដីអៀនខ្មាស់នឹងនាងកាយរបស់ខ្លួន

១ ក្នុងទំព័រគោលថានាងទិតិមាតានៃអសុរៈប្រសូតិជាពង ដែលញាស់ចេញមកជាស្ដេចគ្រុឌ ។

ធ្វើដាក់បណ្ដាសាមាតា នាងកទ្រុបានបង្ខំនាងវិនតាជាទាសី, លុះ
កាលក្រោយខ្លួនមកប្រមាណ ៥ ជួរអាយុ ស្ដេចគ្រុឌក៏ញាស់អំពីពងទីពីរ ដើម្បី
ស្រុយកក្ដីយុត្តិមាតាឡើងវិញ ។ បានតស៊ូនឹងបុត្រនាងកទ្រុទាល់តែ
មានជ័យ, សាហេតុនេះឯងហើយ ដែលបណ្ដាលឲ្យគ្រុឌនឹងនាគមិនចុះ
ត្រូវគ្នា ។

គម្ពីរខ្លះពោលថា សាហេតុដែលគ្រុឌនឹងនាគទាំងឡាយអរិទឹង
គ្នា ព្រោះនាងវិនតានឹងកទ្រុភ្នាល់គ្នាដោយប្រឡងទាយសម្បុរសេះ ដែល
ទ័ពរថព្រះអាទិត្យ នាងកទ្រុថាសម្បុរខ្មៅ នាងវិនតាថាសម្បុរក្រហម
ទើបកើតភ្នាល់គ្នាថា បើអ្នកណាចាញ់ត្រូវធ្លាក់ខ្លួនជាខ្ញុំរបស់អ្នកឈ្នះ
នាងកទ្រុធ្វើកលឧបាយប្រើញាតិនាគដែលជាបុត្ររបស់ខ្លួន ឲ្យទៅព្រួសឲ្យ
សេះព្រះអាទិត្យមានពណ៌ខ្មៅ នាងក៏ចាប់ឈ្នះជ័យជំនះក្នុងការភ្នាល់
នាងវិនតាក៏ធ្លាក់ទៅជាខ្ញុំរបស់នាងកទ្រុ ពួកនាគបុត្រនាងកទ្រុនាំ
គ្នាចាំរក្សាអម្រឹតជាជំនួយខ្លួន តែស្ដេចគ្រុឌដណ្ដើមយកទៅមុន ព្រះឥន្ទ្រ
ហោះតាមមកដណ្ដើមបានច្បាំងគ្នានឹងគ្រុឌក៏ដ តែក៏ចាញ់វជ្រៈធ្លាក់បែក
ចេញពីក្ដៅដល់ព្រះវិស្ណុចុះមកក្រាបក៏មិនសម្រេច ក្នុងចុងក្រោយក៏ព្រមធ្វើ
សម្ពន្ធមិត្រនឹងគ្នា មានខសន្យាថា វេលាអង្គុយព្រះវិស្ណុសុខចិត្តឲ្យគ្រុឌ
នៅខ្ពស់ជាង តែវេលាទៅណាមកណាត្រូវជិះគ្រុឌ, គ្រុឌកដនេះមាន
លក្ខណៈដូចគេ ខ្លួនដូចមនុស្សសម្បុរមាស ចាប់ស្លាប ៥ សំពុះក្រហម

មានក្របកដូចសត្វឥន្ទ្រីយ៍មានប្រពន្ធឈ្មោះនន្ទកិប្បវិនាយកា  មានបុត្រឈ្មោះសម្បាតិ មានឆាយាផ្សេង ៗ ដូចយ៉ាងគស្សប, វេនតេយ, គរុឌ-មាន, បន្នគនាសន: (អ្នកកំចាត់នាគ) វិហង្គម, សុវេណ្ណដីអ, ខគេស្វរ: (ស្តេចនៃបក្សី:, សុបណ្ណ, ទ្វិជជិត  ទីនេះនៅមានឈ្មោះដទៃទៀតជាច្រើនតាមគុណសម្បត្តិនិងតាមហេតុការណ៍នោះ ៗ មានវិមាននៅជាវិមាន  ហៅថាសិម្ពលីគឺនៅជិតមាត់ឆ្នេរមហាសមុទ្រ ។

គម្ពីរខ្លះពោលថា  សុបណ្ណកាលនេះជាកូននាងវិនត, ម្ដាយនោះនាងវិនតាចាញ់គេ  ធ្លាក់ទៅជាទាសីរបស់កទ្រូសៈមិនអាចនឹងដកខ្លួនចេញបាន  ដរាបណាតែនាងជួយឲ្យទូលបាក់ទឹកអម្រឹតឲ្យខ្លាក់ចេញពីព្រះសុមេរុដែលទៀមដោយគំនរភ្លើង  ត្រូវកដុតគំនរជួយមាតា  ទើបជំរៅណាន់ខ្លួនឲ្យតូចក្លាយទៅលួចបេះគំនរភ្លើង  ទៅប្រទះនឹងស្តេចនាគពីរ ដែលក្រហមដូចភ្លើង  ត្រូវកដកំណាស់ស្លាបឲ្យធ្លាប់ចូលភ្នែកហើយសម្លាប់  ហើយទើបឆក់យកតែទឹកអម្រឹតហើររត់ទៅ  ពួកទេវតាឃើញដូច្នោះ  ក៏ដេញតាមព្រះឥន្ទ្រចាប់នបណ្ណាលឲ្យរន្ទះបាញ់  តែឥតលោកសាប់ដល់តិចទេ  ព្រោះតែមានពេទម្ចេញដេរមកប៉ុណ្ណោះ, កាលបានទឹកអម្រឹតទៅឲ្យកទ្រូស:  នាងវិនតក៏បានរួចផុតពីភាពដូចដើម,  មុនដែលអសុរនឹងទឹកអម្រឹតនេះ  ព្រះឥន្ទ្រក៏មកចាប់យកតែឆ្នាំនោះហោះទៅ ឯបានសួគ៌ ពួកនាគបានតែលិទ្ធស្មៅ នៅទីដែលត្រូវដាក់តែឆ្នាំទិព្វ

ស្ដេចក៏លះអណ្ដាតនាគជាប់ជាចំរៀក ២ ។ តមកគ្រុឌក៏បានជាពាហនៈ របស់ព្រះវិស្ណុ ហោះហើរលឿនដូចខ្យល់មានវិមានដ៏ល្អជាទីអាស្រ័យនៅ ហៅថា សិម្ពលី ឬថា ដើមរកា គឺជាស្រ័យនៅនឹងដើមរកាជាវិមាន ។

គ្រុឌនេះជាស្ដេចលើពួកបក្សីសត្វទាំងពួង នៅស្រុកខ្មែរអំពីដើម គេនិយមជឿកោតគ្រុឌ ដោយល្អិតល្អប្រសើរណាស់ណាស់ ទើបបានមានសាក់រូបគ្រុឌទុកនៅព្រះពន្លាជ័យ ខ្មែរទើងទៅតាមប្រាសាទបុរាណជាច្រើន បែបច្រើនយ៉ាងណាស់ មានរូបគ្រុឌចាប់នាគជាដើម អ្នកចង់ឃើញគួរទៅមើលឯប្រាសាទអង្គរ ។

នាគពង្ស: នាគសត្វនេះ តាមដែលធ្លាប់ប្រែមកហើយថា ប្រសើរ ថាជាសត្វមានលក្ខណៈរូបពងវែង ១ ដូចយ៉ាងពស់ តែមានសិរដូចយ៉ាងពាន់, លោកចំណែកទុកជា ៤ ពួកគឺ: ១ នាគសួគ៌មានមុខងារជាអ្នករក្សាវិមានទេវតា, ២ នាគអាកាសមានមុខងារជាអ្នកបណ្ដាលឲ្យភ្លៀងធ្លាក់មក, ៣- នាគលោកបាល មានមុខងារជាអ្នករក្សាសមុទ្រទន្លេ, ៤- នាគរក្សាកំណប់ទ្រព្យ មានមុខងារជាអ្នករក្សាទ្រព្យដែលគេកប់ទុកក្នុងដី ។ ពាក្យបារាំង: គេលថាមានច្រើនពួក ជាអ្នករក្សាកំណប់ទ្រព្យដែលមានកន្លែងកក់ក្នុងផែនដី, មានទីលំនៅ ១ តាមសមុទ្រ - ទន្លេ តែទីលំនៅពិសេស គឺបាតាល ជាលោកមួយនៅក្រោមផែនដី មាននគរជាទី

ឈ្មោះកេតុវតី ប្រែថា សុក្កសុក្ក ប្រាកដតាមក្នុងគម្ពីរបុណ្ណកៈ ទីដ ឋឆ្នុកកៈ ជាលោកគុជាតាយនោះមានប្រែនការ គ្រឿងគ្រាស់ វាលទ សេចក្តីសុខសប្បាយហាក់ដូចឋានសួគ៌ នៅមានពួកទៃត្យៈទីដមានពាវថាវ ជាតម្បូរព្រះគង្គបៈ ខភិនានិទិត ត្រង់គ្រងនៅកំព្រែងជានិច្ច ។

ក្នុងពួកនាគដទៃទាំងនេះ មានរាជាគ្រប់គ្រងហើយគេហៅយមជាជា ស្តេចលើពួកសត្វទាំងអស់ពុំយេដង នាគរាជដែលជាធំបំផុតគ្រាប់ក្រុង បំពេញគបៈ ថែមយ៉ាងហោតីតាល់តែព្រះព្រហ្មប្រាថ្នាពាក្យថា មិពីនេះ ទៅឬជាសេសនាគក៏ដូចៈ ហើយមានជីវិតរស់នៅហួតកប្ប រឺមហាក ឈ្មោះថា អនន្ត មានក្បាល ៧ ក្នុងទីខ្លះថាមានក្បាលរាប់ពាន់ ជា បល្ល័ង្កសម្រាប់ផ្ទំរបស់ព្រះវិស្ណុក្នុងវេលាកប្បវិនាស ។

រឿងព្រះស្តេចនាគពេលនោះមានប្រែខណៈ ស់នៅជៈតែប្រចាំរបនាគេវៀន ប្រែប្រួលប្រែនយោងស្មើរតែឥន្ទ្រទេពម្ខាងគោលពុំបាន ក្នុងគ្រាមក្រុងការ នាគរាជក៏ចូលជាខ្សែវាក្នុងក្រោបរបស់ព្រះបាទសត្យព្រត, ក្នុងគ្រានុមារិការ ក្លាយជាខ្សែទាញក្នុងសមុទ្រទឹកដោះ បានព្រួសពិសជាភ្លើងប្រល័យកល្ប ដែលលាងលោកក្នុងកាលកប្បវិនាស រាប់ជាខ្ទង់មួយនាគទីងនាគរាជ ឈ្មោះ ជាស្នុក បានតាមព្រះនាងយកចិត្តមកកើតក្នុងមនុស្សលោកដូច ហើយកើតជាព្រះលក្សណ៍ក្នុងអវតារគ្រាទី ៧ និងជាព្រះពលទេពក្នុង

"សតោក្រោទី ៨  ក្នុងគ្រាពុទ្ធកាលក៏មាននាគរាជមកចាក់ទងផងជាច្រើន ផង ដូចហៅថាស្ដេចមុចលិន្ទនាគរាជជាដើម ។

នាគនោះបីមានពិសកំណាចក៏ពិត  តែក្នុងទីខ្លះមានរឿងក៏ថា នាគចាំគុណចិត្តបុណ្យ ហើយផ្ដល់ផលដល់មនុស្សដែលមានសេចក្ដីករុណាប្រណី ដល់នាគ, នាគបំណាច់កែវកំណើតយសតិបញ្ញា ដែលជារបស់មិនអាចមើលឃើញបាន, ឯនាងនាគី ឬ នាគិនីក៏ដូចជានាងអប្សរ ជាសត្វគួរឲ្យស្នេហា-ចូលចិត្តសង្គមនឹងមនុស្សរហូតដល់ទៅយកមនុស្សធ្វើជាស្វាមី  ខាងមនុស្សក៏ចូលចិត្តនិយមនាងនាគណាស់ដែរ  ដូចមានប្រាកដក្នុងរឿងកំផ្សេងៗជាច្រើន សូម្បីក្នុងព្រះរាជពង្សាវតារខ្មែរយើងក៏ថា ព្រះថោងនិងព្រះនាងទេវីរាជា  ក៏មានព្រះមហេសីជានាងនាគ  រហូតដល់ទៅពង្សាវតារចិន-យួន- លាវជាដើមក៏ពោលពីរឿងដូចគ្នានេះ ។

ខ្មែរយើងក្នុងជាន់ដើម  រហូតមកដល់សម័យទំនើប គេធ្លាប់ដឹងរឿងកំណើតនាគនេះ ដោយល្អិតល្អន់ហើយ គេនិយមជាសត្វវិសេសពីដើមរៀងមក ទើបបានសាងរូបចម្លាក់នៅប្រាសាទបុរាណ មានចំនួនរាប់ពាន់រាប់សែន រឿងក្នុងគ្រាកូរសមុទ្រទឹកដោះក៏មាន ក្នុងគ្រាប្រល័យ-កប្ប ព្រះវិស្ណុផ្ទំលើសេសនាគក៏មាន  ស្ពានជានាគក្បាល ៧ ហើយជារូបស្លាក់ក៏មានជាច្រើនអនេក  អ្នកប្រាថ្នាចង់ឃើញ សូមអញ្ជើញទៅពិនិត្យមើលចុះ ។

មិច្ឆាទិដ្ឋិកថា

ឃុន សុវត្ថិវេទិបុរ - អ៊ុន រៀបរៀង

នមត្ថុ រតនត្តយស្ស

សូមនមស្ការចំពោះព្រះរតនត្រ័យ

# សេចក្ដីផ្សេងគ្នានៃការយល់ឃើញ

មនុស្សក្នុងលោកសន្និវាសនេះ មិនថាជាតិណាសាសន៍ណាទេ តែងតែមានសេចក្ដីយល់ឃើញ ដែលហៅថា ទិដ្ឋិ ផ្សេងៗគ្នាជាច្រើនប្រការ តែបណ្ដាសេចក្ដីយល់ឃើញទាំងនោះ ការយល់ឃើញខ្លះ ក៏សមហេតុសមផល, ការយល់ឃើញខ្លះ ក៏ឃ្លាតមិនត្រូវចំនងមិនសមបែបបៀបគួរយកមិនបាន. កុំថាតែមនុស្សក្នុងសម័យឥឡូវនេះ ដែលជាមនុស្សធ្លាក់នៅក្នុងជាន់ទាបអាយុថយតិចចុះ ទាំងប្រាជ្ញាសំពប់ជាតិ គឺមានស្ដួចស្ដើងនេះទៀយ សូម្បីក្នុងសម័យពុទ្ធកាល គឺសម័យដែលព្រះសម្ពុទ្ធទ្រង់គង់ធរមាននៅឡើយ ក៏មានមនុស្សច្រើនពួកដែលមានសេចក្ដីយល់ឃើញ ទីនសេចក្ដីប្រកាន់ ខុសពីលទ្ធិពុទ្ធសាសនា ដូចយ៉ាងគ្រូ ៦ នាក់[១] មានគ្រូឈ្មោះបូរណកស្សបៈជាដើម គេយល់

---

១ បូរណកស្សបៈ ១ មក្ខលិគោសាល ១ និគណ្ឋនាដបុត្ត ១ សញ្ជយវេលដ្ឋបុត្ត ១ បកុធ-កច្ចាយនៈ ១ អជិតកេសកម្ពល ។ គ្រូទាំង ៦ នេះ ជាមនុស្សមិច្ឆាទិដ្ឋិ ជាមនុស្សអន្ធពាលទេ តែប្ដេជ្ញាខ្លួនជាព្រះសម្ពុទ្ធ ។

ឃើញថា "ធ្វើអំពើអាក្រក់មានការសម្លាប់សត្វជាដើម ឈ្មោះថាមិនធ្វើបាប" ដោយយល់ឃើញសត្វដែលស្លាប់ក្តីក៏ស្លាប់ឯង ឬ សត្វដែលទើបរស់នៅក៏រស់នៅឯង មិនមែនមានហេតុនាំបច្ច័យណាមួយនាំឲ្យស្លាប់ ឬ នាំឲ្យរស់នៅឡើយ" យ៉ាងនេះជាដើម ។

ហេតុនោះ ទិដ្ឋិការយល់ឃើញនេះ បើនឹងសម្រេចពិចារណាគុណទោស ទំនុកក្ត ដោយស្មើៗ និងវាងវៃគ្រប់ផ្នែក, ក៏ឃើញថាមិនឲ្យទោសផងមិនឲ្យគុណដល់អ្នកយល់ឃើញដូច្នោះឡើយ, តែបើពិចារណាឲ្យល្អិតល្អន់ស្រាលស្រៀវហើយ ក៏នឹងឃើញថាទិដ្ឋិនេះ ជាធម៌ដែលមានកំឡាំងជាទីខ្លាំងបំផុត អាចនឹងនាំមនុស្សឲ្យមានសន្តានប្រព្រឹត្តត្រែមត្រូវតាមធម៌ក៏បាន. ឲ្យប្រព្រឹត្តធ្វើអំពើអាក្រក់ដែលមានទោសផ្សេងៗ ធ្ងន់ខ្លះក៏ក្រាន់ធាក់ជាធម៌ដែលអាចបណ្តាលពួកកុសលធម៌ ក៏នឹងអកុសល-កម្មដែលឲ្យវិបាកប្រាកដឡើងក៏នឹងសន្តានដៃគួរ យល់ឃើញនោះៗក៏បាន ដូចទិដ្ឋិរបស់បរិញ្ញាជក ៣ នាក់នេះ ។

## រឿងសញ្ជ័យ(១)

សេចក្តីថា ក្នុងក្រុងរាជគ្រឹះ មានបរិញ្ញាជក ៣ នាក់ គឺសញ្ជ័យប-រិព្វាជក ១ ឧបតិស្សបរិញ្ញាជក ១(២) កោលិតបរិញ្ញាជក ១(៣) បណ្តាប-

---

១ រឿងនេះមានសេចក្តីពិស្តារក្នុងគម្ពីរធម្មបទដ្ឋកថា ភាគ ១ ត្រង់យមកវគ្គ ។ ២ កាលព្រោះកក្រួលមកបួសក្នុងពុទ្ធសាសនា គេហៅថា "សារីបុត្ត" ព្រោះជាកូនរបស់នាងសារីព្រាហ្មណី ។
៣ គេហៅថា "មោគ្គល្លាន" ព្រោះជាកូននៃនាងមោគ្គល្លីព្រាហ្មណី ។

រិព្វាជកទាំង ៣ នាក់នេះ សញ្ជយបរិព្វាជកជាមហាគណាចារ្យ មានសិស្ស រាប់រយនាក់, ឯឧបតិស្សបរិព្វាជកនឹងកោលិតបរិព្វាជក ត្រូវជាសិស្ស របស់សញ្ជយបរិព្វាជកនោះ តែជាអ្នកមានទិដ្ឋិយល់ត្រូវ, បានលះបង់ទិដ្ឋិ គេចោល ដោយយល់ឃើញថាមិនមែនជាមោក្ខធម៌ ។ ឧបតិស្សបរិព្វាជក បានស្តាប់អរិយសច្ចកថាសង្ខេបអំពីសំណាក់អស្សជិត្ថេរ ក៏បានសម្រេច សោតាបត្តិផល ហើយនាំដំណឹងនោះមកប្រាប់ដល់កោលិតបរិព្វាជក ជាសំឡាញ់ ។ បានស្តាប់ហើយក៏បានសម្រេចសោតាបត្តិផលដូចគ្នា ទើបនាំគ្នាទៅបបួលសញ្ជយបរិព្វាជកដែលជាគ្រូខ្លួន ឲ្យចូលទៅគាល់ ព្រះសាស្តាក្នុងវត្តវេឡុវ័ន ដោយហេតុតែគាត់ជាមនុស្សមានទិដ្ឋិយល់ខុស ក៏មិនព្រមទៅ ។ បរិព្វាជកទាំង ២ នាក់បាននាំបរិវាររបស់ខ្លួនទៅសូម បព្វជ្ជាឧបសម្បទាក្នុងសំណាក់ព្រះសម្ពុទ្ធ មិនយូរប៉ុន្មានក៏បានសម្រេច អរហត្តផល ព្រមទាំងតាំងនៅក្នុងទីជាអគ្គសាវក ។ រឿងនេះបណ្ឌិត គួរជ្រាបថា ឧបតិស្សបរិព្វាជកនឹងកោលិតបរិព្វាជក ដែលបាន សម្រេចអរហត្តផល ព្រមទាំងបានដំណែងដ៏ប្រសើរក្តីក៏ព្រោះទិដ្ឋិ (១) សញ្ជយបរិព្វាជក ដែលធ្លាក់ខ្លួនក្នុងទីជាមនុស្សអន្ធពាលក៏ព្រោះទិដ្ឋិ (២) ហេតុនោះបានជាព្រះភគវាជាគ្រូនៃយើងទ្រង់ត្រាស់ថា :

---

១ សំដៅយកសម្មាទិដ្ឋិ ។ ២ សំដៅយកមិច្ឆាទិដ្ឋិ ។

អសារេ សារមតិនោ សារេ ច អសារទស្សិនោ
តេ សារំ នាធិគច្ឆន្តិ មិច្ឆាសង្កប្បគោចរា
សារញ្ច សារតោ ញត្វា អសារញ្ច អសារតោ
តេ សារំ អធិគច្ឆន្តិ សម្មាសង្កប្បគោចរា

សេចក្ដីថា ជនទាំងឡាយឯណា យល់ឃើញនូវធម៌ឥតខ្លឹម (១) ថាជាធម៌មានខ្លឹម (២) វិញ យល់ឃើញនូវធម៌មានខ្លឹមថាជាធម៌ឥតខ្លឹមវិញ ជនទាំងឡាយនោះ ឈ្មោះថាមានសេចក្ដីត្រិះរិះខុសជាអារម្មណ៍ រមែងមិនបាននូវធម៌មានខ្លឹម (៣) ជនទាំងឡាយឯណា សំគាល់នូវធម៌មានខ្លឹមថាជាធម៌មានខ្លឹមផង សំគាល់នូវធម៌មិនមានខ្លឹមថាជាធម៌មិនមានខ្លឹមផង ជនទាំងឡាយនោះ ឈ្មោះថាមានសេចក្ដីត្រិះរិះត្រូវជាអារម្មណ៍ រមែងបាននូវធម៌មានខ្លឹម ។

សេចក្ដីដែលបានពោលមកប៉ុណ្ណោះ បង្ហាញឲ្យឃើញច្បាស់ថាទិដ្ឋិនេះ ជាបហាតព្វធម៌ គឺធម៌ដែលគួរលះបង់ចេញក៏មាន ជាភាវេតព្វធម៌ គឺធម៌ដែលត្រូវសេពឲ្យកើតក្នុងសន្ដានក៏មាន ។

ទិដ្ឋិបែបណាជាបហាតព្វធម៌? ទិដ្ឋិបែបណាជាភាវេតព្វធម៌? មុននឹង

---

១ មិច្ឆាទិដ្ឋិមានវត្ថុ ១០ ធម៌ទេសនាជាហេតុឲ្យកើតមិច្ឆាទិដ្ឋិ នេះហៅថាធម៌ឥតខ្លឹម ។ ២ សម្មាទិដ្ឋិមានវត្ថុ ១០, ធម៌ទេសនាជាហេតុឲ្យកើតសម្មាទិដ្ឋិ នេះហៅថាធម៌មានខ្លឹម ។ ៣ សីល, សមាធិ បញ្ញា, វិមុត្តិ, វិមុត្តិញ្ញាណ, ទស្សន, រួមជា ៦ នេះលោកហៅថា ធម៌មានខ្លឹមនេះ ។

ដោះប្រស្នានេះ ទើបសូមពណ៌នាអំពីទិដ្ឋិសព្ទ ឲ្យឃើញគោលសេចក្ដីជាមុនសិន ។ សព្ទថា "ទិដ្ឋិ" នេះប្រែថា "សេចក្ដីយល់ឃើញ" ប្រើជាពាក្យកណ្ដាលៗ មិនសំគាល់ថាការយល់ខុស ឬជាការយល់ត្រូវយ៉ាងណាមួយនៅឡើយទេ ; ដែលទើបឲ្យដឹងច្បាស់ថាសព្ទនេះ ត្រូវប្រែថា "ការយល់ខុស" ឬ "ការយល់ត្រូវ" នោះ គប្បីអាស្រ័យសព្ទជាគ្រឿងសំគាល់ ២ យ៉ាងគឺ "មិច្ឆា" និង "សម្មា" ដែលលោកប្រកបទុកនៅខាងដើម ទិដ្ឋិសព្ទៈជាយាវធីសមាស សម្រេចរូបជា មិច្ឆាទិដ្ឋិ សម្មា-ទិដ្ឋិ ឯ មិច្ឆាទិដ្ឋិសព្ទ ប្រែថា "សេចក្ដីយល់ឃើញខុស" សម្មាទិដ្ឋិសព្ទ ប្រែថា "សេចក្ដីយល់ឃើញត្រូវ" ។ តែក្នុងបាលីភាសាច្រើនប្រើ "ទិដ្ឋិ" សព្ទនេះជាគ្រឿងសំគាល់ខាងសេចក្ដីយល់ឃើញខុសដោយមិនបាច់យកមិច្ឆាសព្ទ មកប្រកបចូលផង ដូច ទិដ្ឋិសម្បន្នោ "អ្នកដល់ព្រមដោយទិដ្ឋិ" ទិដ្ឋិវិបន្នោ "អ្នកវិបត្តិព្រោះទិដ្ឋិ" ដូច្នេះក៏មាន សព្ទទាំងពីរនេះ ក៏គង់ជាគ្រឿងសំគាល់ឲ្យដឹងថា "អ្នកដល់ព្រមដោយមិច្ឆាទិដ្ឋិ" "អ្នកវិបត្តិព្រោះមិច្ឆាទិដ្ឋិ" ។

ទិដ្ឋិនេះ បើនិយាយដោយសេចក្ដីផ្សេងគ្នានៃការយល់ខុស និងការយល់ត្រូវ ដូចពោលមកខាងលើនោះចាត់ជា ២ ប្រការគឺ មិច្ឆាទិដ្ឋិ=សេច-ក្ដីយល់ឃើញខុស ១ សម្មាទិដ្ឋិ= សេចក្ដីយល់ឃើញត្រូវ ១ ។ បណ្ដាទិដ្ឋិទាំង ២ ប្រការនេះ មិច្ឆាទិដ្ឋិ ជាបាបកធម៌ គឺជាទិដ្ឋិដែលគួរលះ

បង់បោលចេញអំពីខន្ធសន្តានៈ ព្រោះមិច្ឆាទិដ្ឋិនេះជាប្រធាននៃអកុសលធម៌ទាំងពួង ទាំងជាធម៌មានទោសធ្ងន់បំផុតក្រៃពេកជាងអកុសលឯទៀត ឯសម្មាទិដ្ឋិ ជាភាវេតព្វធម៌ គឺជាទិដ្ឋិដែលគួរអប់រំបំរុងទុកក្នុងខ្លួន ឬគួរធ្វើឲ្យបណ្ដុះក្នុងចិត្តឲ្យកើតមានឡើង ព្រោះសម្មាទិដ្ឋិនេះជាប្រធាននៃកុសលធម៌ទាំងពួង ។ កើតឡើងបានក៏អាស្រ័យតែទិដ្ឋិនេះ ។

តអំពីនេះទៅ នឹងអធិប្បាយចំពោះតែមិច្ឆាទិដ្ឋិមួយក្នុងសៀវភៅក្បាលនេះ តាមន័យដែលមានមកក្នុងគម្ពីរទាំងពីរក្បាល មានគម្ពីរមង្គលត្ថទីបនី អដ្ឋកថាមង្គលសូត្រជាដើម ។

## មិច្ឆាទិដ្ឋិ

ពាក្យថា មិច្ឆាទិដ្ឋិនេះ ប្រែថាយ៉ាងណា ? មានសេចក្ដីអធិប្បាយដូចម្ដេច ? ។

ពាក្យថា មិច្ឆា ប្រែថា "ខុស" ទិដ្ឋិ ប្រែថា "ការយល់ឃើញ" ប្រែរួមទាំងពីរពាក្យថា "ការយល់ឃើញខុស" ។ បានសេចក្ដីថា គំនិតដែលយល់ឃើញមិនត្រូវតាមទំនងនៃធម៌ ឬមិនសមតាមហេតុផលដែលពិតប្រាកដហៅថា "មិច្ឆាទិដ្ឋិ" មានបទវិគ្គហៈក្នុងដីកាវិសុទ្ធិមគ្គថា តេជាក្បួនគ្ហាណា ការនេ មិច្ឆា បស្សតីតិ មិច្ឆាទិដ្ឋិ (ប្រែថា) ធម្មជាតិឯណាឃើញខុស ព្រោះមិនកាន់យកតាមសភាពដែលពិត ធម្មជាតិនោះឈ្មោះថា មិច្ឆាទិដ្ឋិ, នេះជាសេចក្ដីប្រែតាមរូបសព្ទ មិច្ឆាទិដ្ឋិ ។

មានសេចក្តីអធិប្បាយថា ឧបាទិន្នកសង្ខារ គឺសង្ខារដែលមានវិញ្ញាណគ្រប់គ្រង សូម្បីមានកេចចៀន ៗ គ្នាយ៉ាងណាក៏ដោយ ក៏គង់ធ្លាក់ចុះក្នុងគន្លងនៃលក្ខណៈ ៣ យ៉ាងដូចគ្នា, មែនពិតណាស់សង្ខារទាំងពួងកាលបើតាំងឡើងហើយ មិនដែលគន្ធូនផុតចាកលក្ខណៈ ៣ យ៉ាងឡើយ ដែលមានលក្ខណៈ ៣ យ៉ាង គេប្រើថាធម្មតា, ឯលក្ខណៈ ៣ យ៉ាងនោះគឺ អនិច្ចលក្ខណៈ ហេតុជាគ្រឿងសំគាល់ថាមិនទៀង ១, ទុក្ខលក្ខណៈ ហេតុជាគ្រឿងសំគាល់ថាជាទុក្ខ ១, អនត្តលក្ខណៈ ហេតុជាគ្រឿងសំគាល់ថាមិនមែនជារបស់ខ្លួន ១ ។ សេចក្តីកើតឡើងក្នុងខាងដើម, សេចក្តីប្រែប្រួលទៅក្នុងកណ្តាល, សេចក្តីបែកធ្លាយទៅវិញក្នុងទីបំផុត នេះជាគ្រឿងសំគាល់ថាមិនទៀង ហៅថាអនិច្ចលក្ខណៈ ការគេគាបសង្កត់ដោយសេចក្តីលំបាកព្រោះការឈឺចាប់ផង ដើម្បីបានដោយកម្រ នេះជាគ្រឿងសំគាល់ថាជាទុក្ខ ហៅថា ទុក្ខលក្ខណៈ; ការប្រព្រឹត្តទៅផ្សេង ៗ នៃខន្ធមិនត្រូវតាមអំណាចខ្លួន ដូចសក់ស្កូវជាដើម គេមិនត្រូវការឲ្យស្កូវឲ្យបាក់ ក៏គង់តែស្កូវគង់តែបាក់ទៅបាន នេះជាគ្រឿងសំគាល់ថាមិនមែនជារបស់ខ្លួន ហៅថា អនត្តលក្ខណៈ ។ បើបុគ្គលឯណា ពិចារណាឃើញសង្ខារ ដែលមានលក្ខណៈ ៣ យ៉ាង នៅប្រចាំជាធម្មតានោះ ថាមិនមានលក្ខណៈ ៣ ប្រការដូច្នេះក្តី, ឬក៏ពិចារណាឃើញសង្ខារដែលមិនទៀង ថាទៀងវិញ ដែលជាទុក្ខ ថាជាសុខវិញ ដែលមិនមែនជារបស់ខ្លួន ថាជារបស់ខ្លួនវិញ

ដូច្នេះក្តី ការយល់ឃើញរបស់បុគ្គលនោះ ហៅថា មិច្ឆាទិដ្ឋិ ព្រោះយល់ឃើញខុសអំពីផ្លូវដែលពិតមែន ។ ម្យ៉ាងទៀត ក្នុងគម្ពីរអដ្ឋសាលិនីថា: មិច្ឆាទិដ្ឋិសហគតេន (ចិត្តេន) ខន្ទសិកខយោ សេដ្ឋាតិ គេសំ អត្ថិកំ១ នអញ្ញលិកម្មក្ខបច្ចយាវិកណ្ណា ទិន្នំ ករោតិ (សេចក្តីថា) បុគ្គលឯណាពិចារណាឃើញវិបរិតដោយចិត្តរៈគិតខុសថា "ទេវតាតាំងឡាយមានខន្ធកុមារនិងព្រះឥសូរជាដើមជាបុគ្គលប្រសើរបំផុតក្នុងលោក" ដូច្នេះហើយធ្វើនូវការបូជាមានអតិកំខនកម្មគឺអំពើដែលបង្អោនកាយថ្វាយខ្លួនលុតជង្គង់ថ្វាយបង្គំ និងអញ្ជលីកម្ម គឺអំពើដែលធ្វើនូវក្រពុំប្រាមដៃលើកឡើងប្រណម្យនមស្ការ ចំពោះទេវតាតាំងឡាយមានខន្ធកុមារ និងព្រះឥសូរជាដើមនោះឬធ្វើនូវគ្រឿងតាំងសម្រាប់បូជាដល់រូប ក្នុងខ្លោបទីនេះ ព្រោះព្រំដោយគ្រឿងសក្ការបូជាមានគោម័យជាដើម, ការចូលចិត្តខុសហើយធ្វើកិច្ចយ៉ាងនេះក៏ឈ្មោះថា មិច្ឆាទិដ្ឋិ ។ សូម្បីសេចក្តីយល់ឃើញរបស់បុគ្គលឯណាថា "សត្វដែលបានទៅកើតក្នុងសុគតិឬទុគ្គតិបានសោយសេចក្តីសុខឬទុក្ខ មិនមែនកើតមកអំពីផលនៃកម្មដែលខ្លួនធ្វើល្អនិងធ្វើអាក្រក់ទេ គឺកើតមកអំពីសំណាក់នៃទេវតាមានខន្ធកុមារនិងព្រះឥសូរជាដើម ទេវតាពួកនេះឯងជាអ្នកប្រគល់ឲ្យនូវសេចក្តីសុខ និងទុក្ខដល់ពួកសត្វ"; សេចក្តីយល់ឃើញរបស់បុគ្គលនោះ ក៏ហៅថា មិច្ឆាទិដ្ឋិ នេះជាសេចក្តីអធិប្បាយនៃពាក្យថា មិច្ឆាទិដ្ឋិ ។

(មានត)

## កែតម្រូវ

ពាក្យថា "ព្រះស្រីសុរិយោព័ណ៌" ទាំងប៉ុន្មានអន្លើ ក្នុងប្រវត្តិស្តេចចំកស្តេចកើន ដែលមានចុះផ្សាយក្នុងសៀវភៅកម្ពុជសុរិយា លេខ ១១-១២ ប្រចាំខែណូវែម្ប្រ៍-ដេសែម្ប្រ៍ ១៩៦៥ ត្រូវកែថា "ព្រះស្រីសុរិយព័ន្ធ" វិញ និងពាក្យថា "...ឲ្យជាក់ជាង" ក្នុងសៀវភៅ លេខ ១១ ខែណូវែម្ប្រ៍ ១៩៦៥ ត្រង់រឿងអធិប្បាយសុភាសិតខ្មែរ ទំព័រ ៧០០ បន្ទាត់ ១៥ ត្រូវកែថា "...ឲ្យជាក់ជើង" ដូច្នេះវិញ ។

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកដំណឹងសាសនាៈ ព្រះគ្រូសុវណ្ណញាណ ស្វរ-ហាយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកអក្សរសាស្ត្រ* — ទំព័រ

លោក ហេង-យ៉ាត់ — កំពូលស្នេហា (តមក) . . . . . . . . . . ៥៣

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម — ឯកសហស្សរាត្រី ភាគទី១០ (តទៅ) . . . . . ៦៨

" " " — ព្រះរាជក្រឹត្យក្រមចៅហ្វាយស្រុក (តមកនិងចប់) ៧៦

ព្រះគ្រូញាណសំវរ ញាណ-ណឹក — វិធីរាប់ថ្ងៃ-ខែ-ឆ្នាំ-វត្សរ៍ (ពាក្យកាព្យ) . . . . ៩៥

*ផ្នែកសាសនា*

ឃុនសុវត្ថិវេទ៍ យូរ-អ៊ុន — មិច្ឆាទិដ្ឋិកថា (តមក) . . . . . . . . . ១០១

ព្រះគ្រូមហាបវរ ម៉ាយ-ស៊ុន — ឥន្ទវគ្គបរិយាយ . . . . . . . . . . . . ១០៨

ឆ្នាំទី ១៨ – លេខ ២ ខែហ្វេវ្រីយេ ១៩៤៦ – ថ្លៃជាវៈ ១ ឆ្នាំ ៣៥ រៀល ។

# កំពូលស្នេហា

លោក ហេង — យ៉ាន់ រៀបរៀង

(តមក)

សោភ័ក្រ្តមើលសំបុត្រចប់ហើយ ក៏សប្បាយចិត្តឥតឧបមា ស្រាលខ្លួនប្រាណ ដើរស្ទើរតែមិនជាប់ទីដីហាក់ដូចជាមានអ្វីទ្រពីក្រោម ព្រោះត្រូវនឹងសេចក្តីសង្ឃឹមរបស់ខ្លួន ។ ឱ កាលណាអើយទើបបានជួបមុខគ្នា ពីជាតិមុនយើងបានធ្វើបាបកម្មអ្វីបានជាមកព្រាត់ប្រាសយូរឥតងាយកន្លងដូច្នេះ ឱទេវតាអើយ! ជួយណែនាំផ្លូវខ្ញុំឲ្យបានជួបនឹងមាតាបិតាថ្លៃរបស់ខ្ញុំព្រមទាំងបងប្រុសរបស់ខ្ញុំផង ។

វគ្គទី ៣

## ស្ពានមនោរម្យ

ថ្ងៃនោះជាថ្ងៃអាទិត្យវេលាម៉ោង ៣ រសៀល សោភ័ក្រ្តស្លៀកពាក់ជាចរិមណ្ឌលថែមជាអ្នកស្រុកបច្ចិមទិស ដើរមួយៗ លើចិញ្ចើមថ្នល់ "ជីពុកពក" កែងស្បែកជើងគោះគម្រាលថ្មលាន់រំពងកណ្តាលសេចក្តីស្ងាត់ នាំឲ្យចិនស្លៀកខោខ្លីពីរ-បីនាក់ងាកមើលមករោយដោយសេចក្តីឆ្ងល់ ហើយដើរហួសទៅ ។ នៅតាមផ្លូវក្រិចក្រយានបរចុះឡើងរវើលគ្នា ព្រោះគ្រានោះពន្លឺព្រះអាទិត្យរះកំពុងក្តៅពេញកម្លាំង ។

សោភ័ក្ត្រមានភ្នែកសជាប់ខ្ទង់ ហូរស្រោបពេញមុខស្រក់តក់ៗលើ កន្ទួលស្រៀវផាត់ហាយអត់មួយពេល តែក្ខុនោះឯង មិនបានជាស្រស់ ដល់ទណ្ឌកម្មហួសក៏តែនោះឡើយ តែបង្អួចផ្ការពើដើមម្ដើយឈូកកន្ទុំ អារម្មណ៍ផ្សេងៗ ។

លុះដល់ពេលព្រលប់ "ចាំស៊ីសស៊ូត" ក៏ដេបចូលហានចិនទៀតនោះ ដែលបានសន្មតឈ្មោះហៅថា ទីផ្សារកាក់ពិត្ត ជិតបក់វាលខ្យល់ពីលើបោល ខ្យល់តាមៗល្ហើយស្រល នៅសងខាងកៅអីវែង មានបន្ទះក្នុងស៊ីៗ ជះពីណាក៏ភ្លោនដំឡើងខ្ពស់ខ្ពង់គួរជាពីរផ្លូវ គុនបន្ទោះកណ្ដាលស្រួតបរ៉េ ។

លុះគន្ធយផ្ទះខ្ទនស្រលបួលហើយ សោភ័ក្ត្រឆាកៈមកតែចិនតួតបំរើ ចិននោះក៏ស្ទុះមកយ៉ាងរហ័សមកក្បែរក់ រួចសោភ័ក្ត្រញាក់ចិញ្ចើមហៅមុខ ពីណាខ្សឹបៗថា "គៅពីង" អ្នកបំរើស្ដាប់បែខ្សំ ស្ទុះទៅតាបយក ស្រាបុរីយេមួយផងមកឲ្យ អ្នកផឹកភ្ញាក់ខ្លួនបើកភ្នែកមួលក្រឡេងទាន់ ឆាត់ថា:

"យើអាឌេះ! ទៅយកស្រាមកឲ្យឯងវិញ គៅពីង! គៅពីងណាអាក់ៈព្រលប" ។

តែទើតកកមកដល់មុខហើយ សោភ័ក្ត្រចាប់ស្ងាបស្រាមកចូកចំណាប់ាន តែក៏ឯតាញពុំរួច ប្រែនរញចុះភ្ញាម្សៀនខ្ទើនលើន ក៏នៅ

ពែងកម៉ិនរួច ទឹកខ្មាញ់ក្នុងចិត្តថា "ផុតម៉ិនរួច អញក៏លែងស៊ីកុំឲ្យវាស្លាប់ខ្លួន ខុះនៅឲ្យណាយល់ដ៏បើបេ" ហើយក៏ផ្អកខ្លួនទៅកៅអីវិញ ដាក់ជើងស្តាំគងលើជើងឆ្វេង ងើយមុខមើលតំបូលនៅជញ្ជាំង ពួនជាទៅត្រង់នោះមានកញ្ចក់ម៉ែ១ ផ្ទាំង ទើបឆ្លុះមើលស្រមោលមុខរបស់ខ្លួនយ៉ាងជិត ផ្គង់ញញឹមញញែមញៀរផ្អងគមួយ ស្របក់ចុះខាងមុខបញ្ចេញ ។

ទឹកតែក្នុងកែវលាយអស់ត្រូវហៀរធ្លាក់ទៅលើតាខរង់ សោកក្រហួសចិត្តទើបលើកកែវឡើងហុតមិនចាំហាប់ស្ងាបត្រា ដាក់ទឹកត្រជាក់ចូលក្នុងបំពង់កត្រឡប់ទៅសណ្តែកតែម្តងឲ្យអស់ រួចដាក់កែវនោះលើតុវិញ ទឹកចង់សើចតែម្នាក់ឯង ។ ចុងពីចុកក្នុងទាញនាឡិកាពីហោប៉ៅខោខាងមុខ មើលម៉ោងជាងប់មួយរំលងកាត់ពីថ្ងៃត្រង់មក ឃើញត្រូវចិប់ដងទើបទឹងចង្កូលកន្ទុះ ទឹកខ្ញាញ់ណាស់ ញាក់គាល់កាបញ្ចុលកន្លែងដើមវិញក្រោកក្រេសល្វាយកល្មោះ ១ គាត់ចុះលើតុ ដើរចេញទៅក្រៅយ៉ាងរហ័ស ។

ពេលវេលានៅថ្ងៃពេក សោកក្រព្រំដែនដាទីងដើរឆ្ពោះទៅទិណា ទើបកាត់ទៅផ្លូវអូហ៊ីយេរ ត្រង់លំហើយខ្ទមតាមចិញ្ចើមថ្នល់ ភ្នែកក៏កមើលនេះនោះបំភ្លេចពេលឲ្យហួសទៅធាប់ៗ ដើរដល់ផ្ទះមួយមានរបោះហាអក្សរធំៗថា "ចរិតវ្យក្រុងភ្នំពេញ" ក៏ទឹកក្នុកយកដៃស្ទាបចង្កាឃើញថាត្រាតខ្វះទើបចូលទៅឲ្យជាងគេកាល់ដើងសក់កោរសក់កកមុខឲ្យ

អ្នកជាន់ទាញកុងជើងក្រួសមករុញជុំវិញគ្រវៀកន្ទក់កញ្ចឹក តាម
របៀបរបស់គេ ។ ដល់ពេលគោរ អ្នកជាន់ផ្តាតគោអោយសោកក្រួចំរេត
យ៉ាងស្រួល ហើយលើងពេមមុខខាត់ចុះខាត់ឡើង ស្វាយអន្លូលយ៉ាង
មន្ទីរយ៉ាងជួម ទាល់តែបុរសនោះទទ់គ្របកន្លុកដេកលក់ទៅ ។

កាលបើអ្នកជាន់លែងគោរ គេក៏បាញ់ទឹកសិតសត់ឲ្យ ទើបសោកក្រួ
ត្រាក់ព្រឹកដឹងខ្លួនឡើងក្រោករលាស់កំទេចសក់ ផ្សៀងផ្តងខ្ទះកញ្ចក់
ក្រោយមន្ទស់បានឡើងដ៏ត្រែវក្រយាន ដម្រង់ទៅទិសខាងត្បូង ។ ពេល
នោះត្រជាក់ស្រួលពេលម៉ោង៤កន្លះ មនុស្សម៉ាដេរដាសដើរសងខាង
ចិញ្ចើមថ្នល់ ដែលគ្នាអិនអាប់ស្ដាប់ស័ព្ទទិសកំបង់មិនបាន សមស្រួ
ស្រែកដើងបន្ទសលើងផ្ទុកកលលាន់ស្រែកក្រោកផង ។

៤ នាទីក្រោយមក សោកក្រួចុះពាក់សុំក្រដើរចូលទៅកងភូមិ ១, ទី
ភូមិនោះធំទូលាយកល់ត្រើន មានដើមប្ដាទំលាក់រោយលផ្កាក្រហមស
រយ៉ាងរយ៉ាងបោលក្លិនក្រអូបរញ្ជួយផ្សាយអស់អាកាស ពន្លឺពន្លឺដេរដាស
តាមដំណើរបង់ដែល រំលេចស៊ុកខៀវខ្ចីស្រស់បំព្រង តាមផ្លូវពួលទៅ ដើម
ផ្កាជាច្រើនដុះជាជួរគ្នាឲ្យគយគន់ កំពុងរីកផ្ទុះក្លាស់ពណ៌ ។

ចុះផ្ទាំងថ្មដាច់លេចចែងកណ្តាលភូមិ ខ្ពស់ជាងត្រែហារបាំងផ្ដិតខាង
ដំបូលប្រក់ក្បឿងពណ៌ក្រមៅស្រស់ស្អាត តាមជាយដញ្ចាំងផ្ទាំងខាង
ក្រៅ ក្បាច់ខ្ចងដើងក្អែតព័ទ្ធជុំវិញ នាំឲ្យអ្នកដំណើរនឹកស្មានក្នុងចិត្តថា

ត្រកូលនោះគេកាន់សាសនាគ្រិស្ត៍ លុះចូលតាំកណ្តាលចំស្រែខ្លះ ត្រផាក់សប្បាយក្រអូបឈ្ងប់ នក្តាលសំរែកបក្សីពិរោះល្វើនល្វើយ ចិត្តសោភ័ក្ត្រត្រីត្រេច ប្រដូចបានផញ្ញាបន្ទូរសេដ្ឋកិសេចក្ដីសុខដ៏ក្សេម-ក្សាន្ត ។

ដើមទៀប ១ ដើមគួបលំអពីមុខផ្ទះ ផែកៈពាររង់ដោយផ្លែពោន ពោនទទឹងផ្កាក្រហមប្រាលបាញ់ត្រង់ទៅលើ រកាទខ្ទង់លេងលើខ្ទង់យ៉ាងចង់ក្ដង់ ហាក់ដូចជាសំដែងការហោះហៅសកុណជាតិ ឲ្យចុះមកជាក់ជួមពិថមដោយដំពុះ សត្វតាបខ្នងខ្ពសម្បុរស្រស់ក៏នាំគ្នាត្រេកអរត្រូលមកចោមរោម វែសតាប្រៀងល្អងនោះសព្វពេកេះបក់កន្ទុយរវិច ៗ ។

សោភ័ក្ត្រដើរហួសផល់ផណ្ដើរការប្រផ្ទូរឡើងផល់ពនហាលខាងមុខ ពេលកន្ទុយភ្នែកមើលទៅឃើញស្បែកជើង ១ គួរសិតស្អើង ស្បែកជើងនោះមានព័ណ៌ស៊ីបកុមា្ម រួចកេចញសាចំលើយខាងក្រែងជើង ១ ដុំប៉ុនត្រាក់តាក់ធំ បានឃើញដូច្នោះហើយ ក៏រកើបញាប់ញ័រដោយសេចក្ដីត្រេកអរ ទើបញញឹមញញែមមាញកខ្សែមកជូតមុខ រៀបខោអាវឲ្យស្រួលបួលលើកក្រក់ចង់កឡេងតាំងឡើងបង្កិប រួចបានដើរចូលទៅឆាន់កន្លែងទទួលភ្ញៀវ៖ "ជំរាបសួរ លោកអាចារ្យ" ។ ជាហើយក៏ដាក់ខ្លួនអង្គុយចុះលើកៅអី ១ នៅក្បែរមាត់ទ្វារ ពេលភ្នែកគយគន់មើលជុំវិញខ្លួន ។

បន្ទប់នោះថែលម្អ មានគ្រឿងប្រដាប់សម្រាប់ទទួលភ្ញៀវ ឥតមានខ្វះ របស់អ្វីទេ  សាលាសក៏ត្រជាក់ស្រួល ដោយមេសាររបានទាំងម៉ោងបង្អួចពីក្រៅ ចំណាត់ថ្ងៃពីពេក លឿន ត្រជាក់ពិតទ្រែចសំពន្ធ ឲ្យស្រួលទទួលមិនចាំងក្តៅ លើក្បាលទៅចន្លោះជាប់ ៗ  ព្រមទាំងមានស្ពានខ្សែរខ្វែងគ្នាសម្រាប់តំណ ផ្តើម ៗ  ជាប្រផ្ញើយ ទូរស័ព្ទគ្រប់មុខសម្រាប់ទំនាក់ទំនងភ្ញៀវ,  ពីយ៉ាងណាក៏ មិនប្រាកដក្នុងលោកតាំងទៅក្បែរបង្អួច  នៅពីមុខជាប់ទីនេះពាក់កណ្តាល  នាឡិកា មួយគ្រឿងដើរតេក ៗ  ចង្អុលប្រាប់ម៉ោងជាទិច្ចជាទិវន្តមិនចេះហត់មិនចេះ អស់កម្លាំង  គង់ប៉ុណ្ណោះនាឡិកាដែលយោលមួយផង  ពេលវេលាក៏ចេញ ទៅបន្តិច  ពេលនេះមិនយល់ទៅហើយ  កាលណាទៀតទីនេះញញួរ ត្រឡប់វិញបាន  កាលបើមិនកាន់ហួសទម្រេចទីយ៉ាក់ឲ្យនៅទីនេះមួយ ស្របក៏បាន ។

ប្រាសកន្លិចកួលផ្តល់ហេតុនោះ  លោកគ្រូជាដើមជំរាបចិត្តថា ពេលវេលាដែលចេញហួសទៅកក់ម្ភានត្រូវតទាំងបាន  មិនខុសពីជីវិត មនុស្សលោកគ្រប់រូបដែលតែងតែទៅតាមធម្មតា  មានទុក្ខមានសុខ បាត់សំនេគទៅវិញទៅមក  ទីនេះគេត្រឡប់ហាក់គន្លងពេលវេលា ក៏ឲ្យចេញ ទៅតាមពេល  ដើម្បីទីនេះក្រុមខ្លួនមែនដែលជាទីពេញចិត្តមិនដែលបាន សម្រេចណាស់នោះទេ ។

មួយវិញទៀតគ្រប់ៗ យ៉ាង នាលិកាតែងប្រកាសដល់សត្វលោក ថា មាននាឡិកាមិត្ររបស់ខ្លួនគេចប់ចុះបាត់បង់ទៅហើយ ចុះមិនដឹងជា មរណសញ្ញានោះនឹងធ្លាក់លើរូបនរណាឡើយ នាពេលនេះ លោកគ្រូ ក៏ភ្ញាក់ខ្លួនព្រើត ហួសនឹកដល់មាតាបិតាព្រមទាំងបងប្អូន ដែលបាត់ ដំណឹងសូន្យឈឹងមិនដឹងថាយ៉ាងណាទៅហើយ ទើបយកដៃស្ទាបថ្ពាល់ ហើយច្រត់ទៅលើកៅអីជាទុក្ខ ដេកផ្ទៃគិតបណ្ដោយឲ្យអារម្មណ៍ជ្រក ជ្រែញចុះពោរពេញសន្តានចិត្តតាមសន្ទុះ ហេតុដល់ក្ដៅស្មារតីលែងគិត អ្វីឯទៀតក្រៅអំពីរូបរបស់ខ្លួន ។ លោកទាំងមូលលែងប្រាកដដល់ ចិត្តលោកគ្រូទុកជាថៅលនាលិកាយោលទៅមកដដែលៗ បក្សាបក្សី ទ្រំសំទ្រុំតែងតែង ប្រាប់ថាមានជីវិតដែលកប់តាមខ្លួនរស់នៅដីកន្លែង ក៏ លោកគ្រូមិនបានឮសំពីមិនបានដឹងមិនបានឮឡើង រវល់តែនឹងមួយ គន់សភាពខ្លួនក្នុងវេលាពេលនោះ ត្រចៀកឮស្ងប់តែមេះមួនលោកកំប៉ុ ក្នុងដើមព្រឹង យូរទៅក៏លែងឮអ្វីទាំងអស់ អត្ថភាពរបស់លោកគ្រូ ហាក់ដូចជាសាបសូន្យទៅដែរ ថែរជាប្រក់ឡូ ១ វាលក្តីងងឹតសូន្យ ឈឹងគ្មានទីត្រាណា បន្តិចមកស្រាប់តែឮសូរសព្ទគ្រូព្រៀងយ៉ាងរន្ធត់ លាន់ឮពាលាន់ពនឹងឡើងពីកណ្ដាលផ្ទះក្រៅឡើងនោះ ដូចជាឮឯងនាយឯ ណោះមិនច្បាស់ជាក្រុងណា តាមតែពន្លាន់ឮដិតៗ ឡើងបានខ្លាំ ទាំងតន្ត្រីមកដង គួពីយ៉ាងណាក៏ស្ទាវច្បាស់ដល់ត្រចៀករបស់លោកគ្រូ

ដែលបានកើតឡើងដោយមិនដឹងខ្លួនខ្ញុំតាមទស្សស្រណោះស្រណោកក៏
បានរសៀលផ្លាស់ផ្លាយទៅ គ្រាប់កាំភ្លើងបែកស្លាប់សត្វព្យ៉ាណូត
ក្រុកបាញ់ទៅកៃគ្រឹះគោះមិនបេះដែកមិនបេះដូង ញញឹមប៉ប្រិមឡើង
ជាប់បបូរមាត់ ឃើញស្លៀកសំពត់ក៏សំឡឹងមើលទៅដៃម្ដង តែពុះតែ
បង្ហាញមកខាងព្យ៉ាណូតអត់មិនបានដោយហេតុអ្វី?

ពិងហេតុដែលអស្ចារ្យនោះ ពួកកំឡោះតាពទីងដៅសេចក្ដីបាន
ស្រាប់ហើយនៅលើខ្លួនព្យ៉ាណូតស័ក្តិសិទ្ធិ មានដៃសស្គុសផ្សងគ្រប់
គ្រប់ក្តីជាដូចជាខ្ទួនស្រីស្រស់លើតុនមូលលើនគ្មានចាំង បែកបដោយ
ក្រចកកាត់ហាំងល្អធ្ងន់ពណ៌ស៊ីដម្រស់ ម្រាមដៃ ១០ ពើកពើកផេក
ខ្ទាះបោះស្រាលយ៉ាងប៉ឡើ មើលទៅហាក់ដូចជាបោះមិនជាប់នឹងខ្លួន
សោះ អង្គុកគ្រែសពត្តដីល្អយេ ខ្ទន់គួរឲ្យគគ់ពាន់ពេក នេះច្បាស់ជា
ដែនដីទេពអប្សរប្រកញ្ញា លំអដើមដៃមូលខ្ទុលខ្ទុលមានសាច់ខ្ទន់
ជាទីសំរើបចិត្តកំឡោះទ្យូទៅទេ៖ បណ្ដាលឡើងដោយសេចក្តីស្ញប
ជាងសេចក្តីប៉ុនប៉ងត្រាថា ។

សោកក្រើសខ្សឹម ៗ ដូចគេន់ ដើមទ្រូងតេញកំពុងកាចពាន់សម័យ
យ៉ាងម៉ាំ តឹកសរសៃដល់កម្ពុលដូចគេសិត ដែលទ្រនូវផ្កាទិព្វរកត្រយង
គ្រប់គ្រប់កណ្តាលសក់កន្ត្រាញ់ សាយចារលេកទៅក្រោយ បង្ក
ហើងផ្តួលកណ្ដាកតួឲ្យអន្ទែលលេង រំមបបូរមាត់ស្ដើងក្រហមព្រឿង ៗ

ស្រស់ពីព្រឹមហាក់ដូចញញឹមរក    ចេញញេញមកសស្វាចគ្រឹមធេងចុះ
ពន្លឺ    សុភិតសុខនិងមេត្រីចិត្តនៅលើខ្ទង់ច្រមុះតូចស្រួចស្អិតស្អាតចិញ្ចៀម
ខ្មៅស្ទើនដូចគេកាស    ញាក់ត្រចៀកឡើងតាមដំណើរគំនិតក្នុង
ចិត្ត    ថ្ពាល់ស្រស់ស្រឡះពណ៌កយព្រាយឈោយលោស្លិបញ្ញា    គួរឲ្យទស្សនា
មណ្ឌលមុខមើលពីចំហៀងអីម្ល៉េះទេ    មើលក្តុះមានខ្សែរលេរពីចុងច្រមុះចុះ
ដល់ផ្ចិតបបូរមាត់កើតជាខួចយ៉ាងស្រស់ដែលរត់ចុះឡើង    ពេលដែល
នាងនិយាយសើចញញឹម    ប្រជុំឈេះខ្មៅចំកណ្តាលថ្ពាល់ខាងស្តាំជាទីស្នេ-
ហាដល់ភ្នែកបុរសតាំងឡាយ ៗ    សោភ័ត្រមិនចេះទៀងណាយគយគន់
រង្វង់ត្រចៀកទ្រលុក ៗ និងព្រយុះដែលក្រញ៉ុលក្រង់នោះសោះ ៗ

លុះលេងគ្នុងចប់ ១ ខ្ទហើយ    ធារីមានទោយក៏ឆាកមកបង្ហាញមុខ
តាំងមូលឲ្យសោភ័ត្រឃើញ    រង់ក្រសិតុសយារវៃនិងមានចរិយ៉ុរងន់
ឡើងឈាមបំព្រង    ង្ស់រស្លុះដោយភ្នែកខ្មៅស្រិលដូចខ្លងចិត្ត    ដែលហុច
ប្រចះនិងភ្នែកសោភ័ត្រកាលណា ក៏ប៉ើកច៉ាឡើង    រួចនាងនោះក៏ខ្ទប់បបូរ
មាត់បញ្ចេញខួចកណ្តាលថ្ពាល់    សំដៅហ៊ូរសាចក្តីមិនរាញ្ញចិត្តនឹងបុរសនោះ
ហាកសំឡឹងមើលនាងវែបនោះ    វៃបបូរមាត់ទាងបាក់ដូចជាចង់ញញឹម
ចន្ទិប    នាំឲ្យសោភ័ត្រឃើញរាត់តែលួងគួរតិសម័យ ៗ

នៅផិតពីយ៉ាងភ្លូត    ការាព្យកិតុងមើលសៀវភៅធ្វើព្រងើយ    សត់
វែកចំហៀងមុខក្រញ៉ុពុះបះស្រស់    ទឹកមុខគ្រៀមក្រោះពុំដែលឃើញ

ញញឹមដល់មុខ ចាំញញឹមតែងតែរាល់ថ្ងៃ មានចិត្តឥតស្រស់ស្រាយញញើរ ពិបាកផ្គាប់ចិត្តស្រីចិត្តណាស់ ទ្រង់ចាប់ផ្ដើមសង្ស័យចិត្ត សំឡេងនោះ គ្នា ។ ដែលសោកស្ត្រីបានព្យាបាលណាក៏សង្ឃៀតក្រោយនៃសីធនត្តុបាន ។ ការពេបោមានសក្តិគុរុសង្ឃមុខ ។ ការប្រហទោសរស្មីមិនឈប់ទាក់ឲ្យមាន ក្តីយុទ្ធជាប់ថា "មិនមែនអំពីនេះទេ" ដោយសារក្បួនធ្នាស្រាយស្រស់ គ្រួសារដាប់ចិត្ត សំដីបួនមាត់នេះហើយ ដែលបំភាត់ផ្ចាប់គ្រួសាររបស់ សោកស្ត្រី ទ្រង់ពិនិត្យគ្រប់ក្រោយផ្ចាប់តាមគ្រប់តំបន់ទៅ ។

គាំវ៉ៈនោះមានឈ្មោះថា "ពុជនេត្រនារី" ប្រាកដជាបេត្រកូលខ្ពង់ខ្ពស់ស្អុកសម្ភ នាងប្រឹងរិះរកសញ្ញាប័ត្រប្រាកដ- ថ្ងៃបានចំ ។ តែនាងដេញប្រយោគចូលរាំទ្រក្រលេបធ្លាក់ទើបឈប់នៅផ្ទះ ។ ដោយនាងមិនចេះនៅទំនេរ ទើបចូលមកសូមរៀនរៀនពីចៅ ណូតពីសំណាក់ពាក្យដែលនៅផ្ទះជិតគ្នាហើយជាអ្នកស្និទ្ធស្នាលនឹងគ្រួសាររបស់នាងផង ពីព្រោះវិជ្ជានេះ ជាវិជ្ជាមួយដែលស្ត្រីគាពពាន់សម័យគោរពតែពេះ ដល់ពេលគ្រប់គ្រាន់ត្រូវតែលេងភ្លេងកំសាន្តទៀត បន្ទាប់ពីឲ្យគេអស់នោះ រល្បកចិត្តផ្សេងៗដែលប្រែប្រួល ទំនួលឲ្យមាននូវគ្រឿងសប្បាយប្រហែលៗ គ្នា ដើម្បីកុំនិជីវិតស្រាក់ទៀតណើរទៅយ៉ាងសប្បាយរីករីក មិនដាដែលៗ គួរឲ្យធុញទ្រាន់ដូចក្នុងវង្សត្រកូលខ្ពង់ខ្ពស់សព្វថ្ងៃនេះ ។

ម៉ាងបានចូលមករៀនចំនួន ២ ខែហើយ តែសោភ័ក្ត្រមានឱកាស សរសើរលំអរបស់នាង ប្រហែលមួយសប្តាហ៍ប៉ុណ្ណោះ ហើយអ្នកតែងមកលេងសឹងមិនលោះខានថ្ងៃណាមួយ ពេលព្រឹកមកលេងយប់ ពេលល្ងាចមកលេងថ្ងៃ តែកម្លោះគ្រាន់មិនដែលប្រស្រ័យអ្វីដល់សោភ័ក្ត្របានមួយម៉ាត់ឡើយ គ្រាន់តែហាលកន្ទុយភ្នែកមើល ៗ មើលមកម្តងៗប៉ុណ្ណោះ ៗ សោភ័ក្ត្រហាក់ដូចជាទៅកណ្តាលកំសួលហ្លួលព្រោះគាត់នេះណា គេសួរអើពើខ្លួនសោះនៅក្តីយ ក្រមុំតែម្នាក់ឯង ៗ ចុះដោយហេតុអ្វីបានជាចេះតែមក? ទានក្តីពេលដ៏គំបាំងអ្វីក៏ស្រប តាញប្ដូ? តើគេមានសេចក្តីខុសប៉ងថែបណា? ជាបញ្ហាដែលសោភ័ក្ត្របានសាកសួរទៅខ្លួនឯងជាញឹកញយមកហើយ ដឹងខ្លួនពិតជាការដកអំពើនាំឲ្យខាតពេលវេលា ប្រជាកន្ធិចក្តីជានិងលែងមកទៀត តែពុទ្ធោ! ពុទ្ធោអើយ! លុះដល់កំណត់ហើយគ្រាប់តែមានអ្វីទាញនាំឲ្យដើរមកទីនោះ ៗ

សោភ័ក្ត្រឈ្លក់ក្នុងការសង្ស័យខ្លាំង មិនបានគិតដល់អាហារពេលមកអន្ទយដត ហើយដែលបានពិនិត្យមើលកាយាខ្លួនផ្ទោះ បានសួរទៀតថា : "សោភ័ក្ត្រឯងទៅមើលក្នុងកញ្ចក់ទេ? ខ្ញុំគេសរសើរថាល្អមើលណាស់ បើទៅចូរមកហៅខ្ញុំផង ខ្ញុំទៅមើលដែរ" ៗ

(តទៅ)

ឯកសារមាស្រុកខ្មែរ

មួយពាន់មួយយប់ (ជារឿងតកប់)

ភាគទី ១០

# ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម

ប្រែចេញពីភាសាបារាំងសែសមកជាខេមរៈភាសា

## រឿងអ្នកបួសទី ៣ ជារាជបុត្រស្តេច

(តមក)

ធម្មតាជាស្តេចឬជាកជបុត្រដូចជាខ្ញុំនេះ ខ្ញុំមិនធ្វើការក្រក់ដល់ខ្លួនអ្នកឡើយ គឺខ្លួនអ្នកខុតជាមានគុណវិញទេ ដែលបានខ្ញុំមកបួសបែបនេះអ្នកកន្លងទីនេះដើម្បីជួយដោះអ្នកឲ្យបានរួចចេញអំពីទុក្ខ ដល់អោយអ្នកមកគប់ទាំងរស់ ដោយខ្ញុំមិនបានដឹងរឿងការសោះ ៗ ការនោះ ខ្ញុំមើលឃើញទាំងអស់ ដែលគេទាំងអ្នកមកចូលក្នុងទីនេះ ហើយខ្ញុំពេនសោកក្តីច្រល់ណាស់ដែលអ្នកបណ្តោយឲ្យគេធ្វើតាមចិត្ត ឥតមានប្រឆាំងប្រែះអ្វីសោះ" ៗ

វេលាដែលខ្ញុំនិយាយដូច្នេះហើយ កុមារនោះក៏អស់សោកក្តីភ័យព្រាម្ភ ហើយថែវងាញញឹមមកកាន់ខ្ញុំ ហៅខ្ញុំឲ្យអង្គុយជិតខ្លួន ៗ លុះខ្ញុំអង្គុយហើយ ក្មេងនោះក៏និយាយមកកាន់ខ្ញុំថា "ទ្រង់, ទូលបង្គំនឹងនិយាយរឿងទូលបង្គំឲ្យទ្រង់បានជ្រាប ឪពុកទូលបង្គំជាចៅកែមាសគេជ្រើយាំងធំ មានទ្រព្យសម្បត្តិច្រើនណាស់ ហើយមានខ្ញុំកំដរនឹងមនុស្សគ្នា ដែលចេញជួញតាមផ្លូវទឹកនឹងផ្លូវគោក គ្រប់តំបន់ គាត់មាន

ប្រពន្ធមកយូរណាស់ហើយតែគ្មានកូនមួយសោះ មានថ្ងៃ ១ គាត់យល់សប្តិថា គាត់នឹងបានកូនប្រុស ១ តែកូននោះមានអាយុមិនយឺនយូរទេ លុះគាត់ភ្ញាក់ឡើងវិញ ក៏មានសេចក្តីទុក្ខព្រួយចិត្តជាច្រើន ។ អំណោះ ២-៣ ថ្ងៃតមក ម្តាយខ្ញុំគាត់ប្រាប់ឪពុកខ្ញុំថា គាត់មានផ្ទៃពោះហើយ គាត់គិតស្មានថា ចាប់មានទម្ងន់តាំងអំពីថ្ងៃដែលឪពុកខ្ញុំយល់សប្តិនោះឯង ។ លុះដល់កំណត់ ៩ ខែ ម្តាយខ្ញុំក៏សម្រាលខ្ញុំមកនាំឲ្យមានសេចក្តីត្រេកអរសាទរជាច្រើនក្នុងគ្រួសារ ឯបិតាទូលបង្គំបានយកចិត្តទុកដាក់បីបាច់រក្សាទូលបង្គំយ៉ាងល្អ តាំងពីពេលទូលបង្គំកើតមក បាននៅពិគ្រោះសាកសួរគ្រូហោរា បានទាយថា "កូននេះនឹងមានសេចក្តីសុខសប្បាយ ឥតគ្រោះថ្នាក់រហូតដល់អាយុ ១៥ ឆ្នាំ ដល់គ្រប់កំណត់អាយុនេះ នឹងមានអន្តរាយដល់ជីវិតហើយពិបាកនឹងគេចបានចៀសផង ឲ្យផុតពីគ្រោះថ្នាក់នោះបានផង ។ គ្រូហោរាបានទាយតទៅទៀតថាក្នុងកាលនោះ រូបសម្រង់ដ៏ស្រស់ដែលនៅលើកំពូលភ្នំ នឹងត្រូវស្តេចអាយ៉ាវជាកដបុត្រស្តេចតាសៀប រំលំធ្លាក់ទៅក្នុងសមុទ្រ តពីនោះកន្លងទៅបាន ៥០ ថ្ងៃ កូនអ្នកឯងនឹងត្រូវស្តេចនោះពិឃាតជីវិតបង់" ។ ដោយហេតុមានទំនាយហោរា ស្របគ្នានឹងនិមិត្តសប្តិរបស់ឪពុកទូលបង្គំផងនោះ នេះការនឹងតែនាំឲ្យឪពុកទូលបង្គំកើតទុក្ខព្រួយចិត្តយ៉ាងខ្លាំង ទើបគាត់រក្សាការពារប្រយ័ត្នទូលបង្គំ រហូតមកដល់ឥឡូវនេះត្រូវជាឆ្នាំ

គ្រប់ ១៥ តាមកំណត់អាយុទូលបង្គំ ។ ដល់គាត់បានប្រាប់ដំណើរជា
រូបមនុស្សស្រីម្ពី គ្រឿងស្តេចដែលទូលបង្គំចេញព្រះនាមមកអំបាញមិញ
នេះបាត់ទៅក្នុងសមុទ្របែបមាណ ៩០ ថ្ងៃមកហើយ ។ ដំណើរនេះនាំឲ្យ
គាត់គិតភ័យខ្លាចក្រៃលែងជាខ្លាំង ព្រោះមានគ្រោះថ្នាក់អន្តរាយដល់ទូលបង្គំ
ដូចជាទំនាយរបស់ពួកហោរនោះ ទើបគាត់រកឧបាយគ្រប់យ៉ាង ដើម្បី
បង្វែរគ្រោះឆាបឲ្យបាត់ចៀសចេញទៅ ដើម្បីរក្សាជីវិតទូលបង្គំឲ្យ
បានគង់វង្សទៅ ។ ឯទីកន្លែងសម្រាប់ពួនទៅទីនេះ គាត់បានឲ្យរៀប
ចំប្រមូលទុកតាំងពីឆ្នាំមកហើយ ដើម្បីឲ្យទូលបង្គំមកពួននៅក្នុងនេះ
ឲ្យបានគ្រប់ចំណាត់ ៥០ ថ្ងៃ រាប់តាំងពីថ្ងៃដែលស្តេចបានរំលំរូបមនុស្ស
ដីសេះនោះមក ។ លុះគាត់បានដឹងថាគេរំលំរូបនោះបាន ១០ ថ្ងៃហើយ
បានជាគាត់ប្រញាប់ប្រញាល់យកទូលបង្គំមកលាក់ទុកនៅទីនេះ ហើយ
គាត់សញ្ញាថា ដល់គម្រប់ហួស ៤០ ថ្ងៃទៅគាត់នឹងមកទទួលយកទូល
បង្គំត្រឡប់ទៅវិញ ។ កុមារនោះនិយាយតទៅទៀតថា «ចំណែកខាង
ទូលបង្គំមានសង្ស័យថាមុខជាស្តេចអាយ៉ាចមករកទូលបង្គំ ដែលមក
លាក់ខ្លួនពួនទៅក្នុងទីនេះពុំឃើញឡើយ ព្រោះកោះនេះឆ្ងាយដាច់សង្វែង
ណាស់ សូមប្រធ្រាប, នេះហើយជារឿងរបស់ទូលបង្គំ ដូចទូល
បង្គំក្រាបទូលមកនេះ» ។

នៅវេលាដែលកូនអ្នកជំនួញមាសពេជ្រ ដំណាលរឿងក៏របស់គាត់ឲ្យខ្ញុំស្ដាប់នោះ ខ្ញុំខំទប់សើចចំអកផងដល់ពួកចោរទាំងនោះណាស់ ដែលបានទាយថា ខ្លួនខ្ញុំជាអ្នកពិឃាតជីវិតក្មេងនោះ ។ លុះគាត់និយាយរឿងចប់ហើយ ខ្ញុំក៏និយាយបញ្ជាក់ប្រាប់គាត់ថា "នែអ្នកកំលោះ ពួកអ្នកជឿជាក់ក្នុងចិត្តលើសេចក្ដីសប្បុរស របស់ព្រះជាម្ចាស់ចុះ កុំខ្លាចអ្វីឡើយសោះ ត្រូវអ្នកយល់ថាខ្លួនអ្នកបានសងបំណុល ដែលអ្នកជំពាក់គេនោះរួចស្រេចទៅហើយ ។ ក្នុងកាលឥឡូវនេះ អត់មានជំពាក់បំណុលអ្វីគេទៅទៀតទេ ។ ខ្ញុំមានសេចក្ដីត្រេកអរណាស់ ចំពោះការជួយដោះទុក្ខធុរៈរបស់អ្នក ឲ្យរួចផុតពីកណ្ដាប់ដៃរបស់ស្ដេច ដែលគូលមកបងពិឃាតជីវិតអ្នកក្នុងទីនេះ ។ ខ្ញុំនឹងរង់ចាំមើលនៅទីនេះឲ្យអស់វេលា ៤០ ថ្ងៃឲ្យឃើញជាក់ថា ពាក្យទំនាយរបស់ពួកចោរដែលនាំឲ្យអ្នកគិតភ័យបារម្ភនោះខុសផ្ដេសផ្ដាសទាំងអស់ ។ តែការណាដល់ទៅពេលនោះខ្ញុំនឹងជួយដោះទុក្ខធុរៈរបស់អ្នកគ្រប់យ៉ាង សុំកុំឲ្យអ្នកភ័យព្រួយអ្វីឡើយ ។ លុះអ្នកផុតពីគ្រោះថ្នាក់បានសុខសប្បាយហើយ ទើបខ្ញុំសុំអនុញ្ញាតអ្នកនឹងបិតាអ្នក ជិះទូកដោយសារត្រឡប់ទៅត្រើយខាងឆ្ងាយវិញ តែកាលណាខ្ញុំបានត្រឡប់ទៅដល់ស្រុករបស់ខ្ញុំវិញហើយ ខ្ញុំនឹងតបគុណអ្នកដើម្បីបង្ហាញឲ្យឃើញសេចក្ដីកតញ្ញូរបស់ខ្ញុំ ចំពោះខ្លួនអ្នកឲ្យអស់ពីចិត្តរបស់ខ្លួនខ្ញុំ ។

ការដែលខ្ញុំនិយាយដូច្នេះ ដើម្បីឲ្យខ្លួនឈ្មួញមាសពេជ្រនោះ ស្បើយពីទុក្ខព្រួយចិត្ត ទើបឲ្យគាត់ទុកចិត្តមកលើខ្លួនខ្ញុំផង ។ តាំងពីនោះមកខ្ញុំប្រុងប្រយ័ត្នមិនឲ្យមានគ្រោះភ័យអ្វីឡើយដល់ក្មេងនោះ ហើយខ្ញុំមិនព្រមនិយាយប្រាប់ថា ខ្លួនខ្ញុំជាស្ដេចអាយ៉ិច ក្រែងគាត់ភ័យខ្លាច ហើយខ្ញុំប្រឹងប្រយ័ត្នមិនឲ្យមានមោះមៃសង្ស័យមកលើខ្លួនខ្ញុំផង ។ តមក យើងទាំងពីរនាក់ក៏និយាយរួសរាយជាមួយគ្នា គំពីរឿងកំប្លែង ៗ រហូតដល់ឈប់ ទើបខ្ញុំដឹងច្បាស់ថា ក្មេងនោះមានគំនិតប្រាជ្ញាជាច្រើន ។ យើងទាំងពីរនាក់បរិភោគអាហារទាំងនោះជាមួយគ្នា ទុកជាមានភ្ញៀវថែមថ្មីមកម្នាក់ទៀត ក៏ស៊ីអាហារទាំងនោះមិនអស់ដែរ ហើយបើក្នុង ៦០ ថ្ងៃទៅហើយ ក៏គង់នៅមានសល់ស្បៀងជាច្រើន ។ ក្រោយបរិភោគអាហាររួចស្រេច យើងនាំគ្នានិយាយសន្ទនាបន្តិចបន្តួច រួចនាំគ្នាដេកទៅ ។

ដល់ព្រឹកឡើង កុមារនោះក្រោកពីដេក ខ្ញុំនាំគាត់ទៅកាន់ទឹកលុបមុខលាងមាត់ជូតជម្រះកាយហើយ ខ្ញុំក៏រៀបធ្វើអាហារព្រឹកឲ្យគាត់បរិភោគ រួចខ្ញុំប្រឌិតធ្វើជាល្បែងសម្រាប់លេងមួយយ៉ាង ជាគ្រឿងកំសាន្តកែអផ្សុក ក្នុងថ្ងៃនោះនិងថ្ងៃតទៅ ៗ ខ្ញុំរៀបធ្វើអាហារល្ងាច ដូចជាអាហារពីព្រឹកមិញនេះដែរ ហើយយើងក៏នាំគ្នាបរិភោគអាហារទៅដល់ពេលដេក ក៏នាំគ្នាដេកទៅដូចជាថ្ងៃមុន ៗ នេះដែរ ។ យើងទាំងពីរនាក់កាន់តែមានសេចក្ដីស្និទ្ធស្នាលនឹងគ្នាមួយថ្ងៃបន្តិច ៗ ខ្ញុំបានគន់មើលយល់ថា

កុមារនោះកាន់តែមានសេចក្ដីគោរពមកកាន់ខ្ញុំជាច្រើន ចំណែកខាងខ្ញុំវិញ ក៏មានសេចក្ដីស្រឡាញ់រាប់អានដោយស្មោះត្រង់ណាស់ ទើបនាំឲ្យខ្ញុំនឹកឃើញថែមមិនដាច់ ដែលពួកហោរាបានទាយប្រាប់ឪពុកថាកូននោះនឹងស្លាប់ ដោយដៃខ្ញុំជាប្រាកដ ដ្បិតពាក្យទំនាយនោះ កុហកណាស់ ឥតត្រូវបន្តិច ហើយតាំងខ្លួនខ្ញុំក៏យល់ច្បាស់ថា ការពិឃាតកូនក្មេងដូច្នេះ ជាអធម្មកម្មមិនសមគួរដល់ខ្លួនខ្ញុំសោះឡើយ ។ លោកស្រី! នៅទីបំផុត យើងទាំងពីរនាក់ នៅជាមួយគ្នាដោយសេចក្ដីសុខសប្បាយ ឥតមានគោះថែមបន្តិចហេតុអស់វេលា ៣៩ ថ្ងៃ ។

ដល់គ្រប់កំណត់ ៤០ ថ្ងៃ ព្រឹកឡើង កុមារដែលនិយាយនឹងខ្ញុំដោយទឹកភ្នែកអរណាស់ថា "ទ្រង់, ឥឡូវគ្រប់ ៤០ ថ្ងៃហើយ ទូលបង្គំមិនស្លាប់ទេ ទូលបង្គំសូមត្រេកអរចំពោះព្រះជាម្ចាស់ នឹងសេចក្ដីមេត្រីស្មោះត្រង់របស់ទ្រង់ ឪពុកទូលបង្គំ មុខជានឹងដឹងគុណទ្រង់យ៉ាងច្រើនមិនខាន ហើយនឹងជួយទំនុកបំរុងទ្រង់គ្រប់យ៉ាង ព្រមទាំងថ្វាយសេចក្ដីសុខសម្រាន្ត ឲ្យទ្រង់ត្រឡប់ទៅកាន់ប្រទេសរបស់ទ្រង់ដោយស្រួលផង ។ គាត់និយាយអង្វរខ្ញុំថា សូមឲ្យទ្រង់ដាំទឹកក្ដៅឲ្យទូលបង្គំបន្តិច ដ្បិតទូលបង្គំចង់ដុសខ្លួនប្រាណឲ្យបានស្អាតសព្វសព៌ាង្គកាយ ហើយនឹងផ្លាស់ស្លៀកពាក់សំពត់អាវថ្មីៗ ដើម្បីនឹងទទួលឪពុកក្នុងថ្ងៃនេះ ។ ខ្ញុំក៏តាំងដាំទឹកក្ដៅឡើងល្មមក្ដៅឧណ្ហៗ ក៏ចាក់ដាក់ទៅក្នុងធាង ១ យ៉ាងគួរសម្រាប់

ស្ទួកវិច ៗ កុមារដ៏ចង់ ក៏ចុះស្ទួកទឹកកងអាងក្តួចនោះ ផុសដប្រែះញើស ក្លែរ លុះរួចកិច្ចស្ទួកទឹកហើយ ក៏ឡើងទៅដេកលើគ្រែដែលខ្ញុំបានរៀប ទុកឲ្យខ្ញុំយកផ្លុយដណ្តាប់ឲ្យរាងដ ៗ លុះដេកសម្រាកលក់ទៅបានបន្តិច ក៏ភ្ញាក់ឡើងនិយាយប្រាប់ខ្ញុំថា "ទេវី, សូមទេវីមេត្តាប្រោសទៅយក ស្លឹកនំស្តា មកឲ្យខ្ញុំលចង្កិបរំភោគឲ្យបានត្រជាក់ចិត្តបន្តិច" ៗ

ផ្លែចន្ទីតនោះ មានសល់នៅជាច្រើន ទើបខ្ញុំរើសសម្រាំងយកតែ ផ្លែដែលល្អបំផុតដាក់លើចាន ៤ ចូនជាព្រះនោះ ខ្ញុំរកកាំបិតសម្រាប់ពុះ ផ្លែចន្ទីតពុំឃើញសោះ ទើបខ្ញុំសួរទៅក្មេងដ៏ចង់ ៗ ក្មេងនោះឆ្លើយប្រាប់មក ខ្ញុំថា កាំបិតសៀតកុកនិងដញ្ចូង លើក្បាលដំណេកឲ្យលចង្កិដារខ្ញុំ នេះឯង ៗ ខ្ញុំក្រឡេកមើលទៅឃើញកាំបិតមួយនៅទីនោះ តែដោយខ្ញុំ ប្រញាប់ប្រញាល់ពេកនៅវេលាដែលស្ទុះទៅយកកាំបិតនោះ ផល់តាប់ កាំបិតជាប់មកនឹងដៃ ហើយថយមកវិញ ស្រាប់តែជាន់ជាយសួយព័ទ្ធជើង ស្លុយច្រោបទៅលើក្មេងនោះ ឯកាំបិតដែលកាន់នៅនឹងដៃខ្ញុំ ក៏ចាក់ទៅចំ បេះដូងកំ ដោយមិនដឹងខ្លួនដោយខ្លួនខ្ញុំឥតមានចេតនាប្រហារជីវិតបន្តិច សោះ ៗ ឯកុមារដ៏ចង់ក៏ដល់នូវមរណភាពក្នុងពេលនោះមួយរំពេចទៅ ៗ

ក្នុងខណៈនោះខ្ញុំក៏កាំងស្រែកឡើងទាល់តែក្អាក់សំឡេងថា "ឱតម្ត អើយ! នៅខ្លះតែគ្រប់រំលាំងប៉ុណ្ណោះ និងទ្រង់ផុតបុត្តាគ្រោះថ្នាក់នេះ ទៅហើយ ម្តេចឡើយមិនឲ្យតនុកាសបន្តិចទេះឲ្យផងសោះ នៅវេលា

នោះគិតខ្ញុំបេះដៃតែគិតរំលេចអំពីគ្រោះថ្នាក់ដែលឥតនឹកគានោះ ហើយគិតឃើញថាខ្លួនខ្ញុំជាអ្នកពិឃាតកុមារដ៏ទន់មែនទៀតសមិនគួរទេ ទើបខ្ញុំខឹតសើបនឹងពាក្យចំនាយដ៏ពិតក្រោកផនោះណាស់ ៗ ហើយខ្ញុំដើរដើយទៅលើមេឃ លើកដៃប្រណម្យបន្ទំព្រះនិងយកម្នាក់ឯងក្នុងខណៈនោះថា

“ឱ! ព្រះម្ចាស់ថ្លៃខ្ញុំអើយ សូមឲ្យព្រះអង្គកុំបីអត់ទោសឲ្យគេអាះ ប្រសិនបើខ្លួនបន្ទំជាអ្នកកាន់ចិត្តសម្លាប់បំបាត់ជីវិតគេមែន សូមកុំឲ្យព្រះអង្គទុកជីវិតខ្លួនព្រះបន្ទំឲ្យរស់នៅបានយូរទៀតទេ” ។

ដោយហេតុខ្ញុំមានសេចក្តីរំភើបចិត្តក្តៅក្រហាយជាខ្លាំងណាស់ ទើបខ្ញុំពេញចិត្តខ្លួនយកសេចក្តីស្លាប់ក្នុងខណៈនោះ ដោយឥតញញើតសោះទៀយ ៗ ប៉ុន្តែតាមតម្កា អំពើអាក្រក់ក្តី អំពើល្អក្តី មិនដែលបោះតាមគ្នាឲ្យផលក្បាស តាមពាក្យអំពាវនាវកនោះទេ ។ កាលខ្ញុំកំពុងរះគិតជញ្ជឹងទៅ ចែកដៃក្លូកហៀរចេញមកស្រាក់ឥតឈប់ខ្វន មានចិត្តអាណិតកូនក្មេងស្ទើរក្លាចដើមទ្រូង ដែលខ្ញុំមិនអាចធ្វើឲ្យក្មេងនោះមានជីវិតរស់ទៀតវិញ ឥឡូវដល់កំណត់ ៤០ ថ្ងៃហើយ ខុះជាទឹនបានចួបនឹងការចាស់ជាថុំពុកក៏មិនមានខ្ញុំគិតដូច្នេះហើយ កំដើរចេញពាកករទននោះទៀតផណ្តើរផុតទៅកាន់លើហៅយកថា ១ ដុំធំខ្ចប់ចិត្ត ត្រង់ត្រាចូលរូបកាយដ៏ល្អបទៅ ។ (មានត)

# ព្រះរាជក្រឹត្យក្រោមចៅហ្វាយស្រុក

## ក្នុងវេលាកាលព្រះបាទសម្ដេចព្រះ•ទ័យយកជាកមាធិបតី

## ព្រះអង្គចន្ទ

(តមកទីអប់)

លស់ ១០០ ដំណាំ ហើយយកគូទ្រវែបពន្ធកូនបញ្ចូលជាមហាក ។ ឯអាណាកទូនព្ទបដ៏កំបាំងនោះ ឲ្យរាជនេះទីធ្វើតាត់ឲ្យកង់តាល ហើយយកឈ្មោះបញ្ចូលបញ្ជី ដូចេះពីរកាយុឆ្នាំ ១៦ ឡើងបញ្ចូលបញ្ជីជាលើ ។ ដើកេន្ទ្រពាលកណ្ដាលចាស់ បើពិការជាមនុស្សទ៍នីប្រើធ្វើព្រះរាជការពុំបាន នោះ កុំឲ្យយកឈ្មោះបញ្ចូលក្នុងបញ្ជីឡើយ លុះដឹងជាសួរហើយឲ្យប្ដូរដោយនាហ្មឺនមន្ត្រីសេនាបតី ដោយចាំពួកដោយគន្ធងខងស្រលីង(១) ទីដទៃ ៗ ឯអស់កះឈ្មោះសព្វព្រះអង្គ នូវកឈ្មោះព្រះវង្សរាជវង្សជំទាវនោង ផង បើប្រែទុលមទ្យមានមេឲ្យជាបម្រើស្រដៀងគ្នាឯង ឲ្យស្ដាប់បង្គាប់ ។ (បើទីន) យកកឈ្មោះដោយដំពូកទីទៃ (១) កុំមាននើសតាល់សល់នីង បម្រើយ(២) (ដែលតាង) ចាំធ្វើរាជការដោយក្នុងសីងមាន ចាំមានព្រះ

---

១ ពាក្យថា ស្រលីង ឬ ស្រឡាំង នេះភាយធម្មតាសំដៅយកចំនួនស្បូវ ៨០ សរសៃ ដែលគេបានវែកចងជាមួយកម្រែង ទល់បានចំនួន ១០ ស្រលីងគេហៅថាសូត្រ ១ ផ្ទុំ ។ តែ ពាក្យថា តន្លង់ខង ស្រលីងក្នុងទីនេះសំដៅយករបៀបធ្វើការឲ្យបានត្រឹមត្រូវហ្មត់ចត់តាមគន្លង ច្បាប់ ។ ២ នីកុំឲ្យមានទើសទាល់កោតញញើតនឹងសេចក្ដីដោះស្រាយរបស់ជននោះ ១ ឡើយ ។

បន្ទូលព្រះរាជទ័ណ្ឌ[១] ទុកដោយគួរ[២] ទីទៃៗ កុំឲ្យមានប្រើកំសឹងមាន នាអស់អម្បាលណោះឯង សឹងមានចម្លើយរបីងរំងឹតត្រូវប្រកួតអ្នកអាងកុំ ភ្ជាប់អាជ្ញា ប្រើអាជ្ញាបំណាច់[៣] ចំពាប់យកហើយក៏ចូលដោយចៅហ្វាយ ទៀតខ្លួលដោយអម្ចាស់ទីទៃៗ ។

កំណត់អំពីនេះទៅ បើចៅហ្វាយស្រុកទីងទែងអាជ្ញា ឲ្យចាប់យក ចំណុះស្រុកមកប្រើព្រះរាជការទាំងតួនឲ្យមែន ទីងច្បាប់ព្រះបាទអ្នកជា អម្ចាស់កុំឲ្យមានក្តីឡើយ ពោះក្នោះនោះទៅប្តឹងដល់ចៅហ្វាយខាងក្រុង នឹងឲ្យជាក្តី ព្រះបាទអ្នកជាអម្ចាស់កុំបើក (ឲ្យ) ទៀនក្រាបទូលឡើយ ។ បើចៅហ្វាយឯណាទំទៀនក្រាបទូលហើយ ព្រះបាទអ្នកជាអម្ចាស់ត្រាស់ នឹងឲ្យទុកទោសជាទម្ងន់ផ្ទៃក្រោមខ្ញុំចៅហ្វាយនោះហោង ។ តែចៅហ្វាយ ស្រុក ខ្ញុំដំទប់ យោកយ៉ែត ក្រឡាបញ្ជី ចៅមឿង ចៅបាន ក្រមការ ញ្ញក់ងារ ខ្ញុំមេបំណាចផង ធ្វើមេខន់ងករការ (គឺត្រូវធ្វើតាមច្បាប់រាជ- ការ) កុំឲ្យរែកគក្បាគផ្តេទុកបុតបង្កិនយកសារពើទ្រព្យរបស់គេ កុំឲ្យ ឥតស្រាសាហារផ្សពោលកំយចង់ចងប្រកយ្ហាន់មេខុសខន់ច្បាប់ ។ បើ ចំណុះស្រុកផងប្រកែកប្រកួតអ្នកអាងចៅហ្វាយខាងទីទៃៗ ដល់អម្បាល មានក្តីឲ្យយកការងឹតួងនោះឲ្យបាន កុំផ្សពោលតិះដៀលដល់ចៅអម្ចាស់

---

• ព្រះរាជទ័ណ្ឌៈ គឺកម្រិតរបស់ព្រះរាជបញ្ញត្តិ ឬ ព្រះរាជប្រកាស ។ ២ ដោយគួរទីទៃៗ គឺដោយខ្លួនទីទៃៗ ។ ៣ អាជ្ញាបំណាច់ ឬ ហៅលោកាសំដៅយកអាជ្ញាជាខេត្តណែនតែជាអ្នករៀបកេណ្ឌយកមនុស្សមកធ្វើការរាជការ ។

នូវចៅហ្វាយខាងទីនៃ ៗ នោះឡើយ ។ បើចៅហ្វាយស្រុកនូវមេបំណាវ[១] ទាំងនេះរកឃើញគ្រឿងតំរុយកុបកម្ម និងយកទ្រព្យរបស់គេដឹកស្រាសាហាវជោរ ពោលក់យកថវិកាចែកឃ្មាំងគេទុកសន្ទូរបញ្ជប់ នោះគេជៀលទៅផល់អម្ចាស់ ចៅហ្វាយគេក្តី ព្រះបាទមេរមបរពិតអ្នកជាអម្ចាស់ ទំនងឲ្យត្រូវក្តី ៧ ថ្ងៃ ហើយពិន័យអស្គិតហូសក្តិ[២] ជីង ៣[៣] តម្លឹង ១៧ តក្រុណាំឡើយ ។

នោះធ្វើជា មានព្រះបន្ទូលព្រះរាជវណ្ណតុំឲ្យប្រើក្តី នោះជាគ្រា ព្រះរាជទ្រព្យក្តី ហើយជាចាំអាជ្ញាដោយអម្ចាស់ដោយចៅហ្វាយឲ្យមក ចេកក្តី បើនឹក្អឹងបើង ពុំកោតពុំខ្លាចអាជ្ញាព្រះរាជការ ព្រះបាទអ្នកជា អម្ចាស់ហើយ ឲ្យចៅហ្វាយស្រុកចាប់យកឲ្យបាន លក់យកថវិកាចែក ឃ្មាំងក្តី (ត្រូវ) ចៅហ្វាយ (ស្រុក) នូវពាក់អាវធនធ្វើទោសឲ្យស្មុគស្មូន កុំបីគោកញរញៀតឡើយ ។ បើព្រះរាជទ្រព្យ (ដែល) គេក្បានោះបាត់ បង់ប៉ុន្មានៗ នោះកុំឲ្យចៅហ្វាយស្រុកនូវកម្មោះរក្សាសងឡើយ តែពិចារ-ណាអ្នកគេក្បានោះ បើជាពាក់អាវពិត ទើបឲ្យលៃតយកដោយនូវល្មម ហោង ។ បើចំណុះស្រុកផងនាំដើរវេះវៀនទៅឯណាៗក្តី នោះបូល ទៅដោយនូវអម្ចាស់ នូវចៅហ្វាយខាងទីនៃ ៗ បើពុំឲ្យចាប់ស្រុកនូវ

---

១ មេបំណាវចេកផែនទេតឹង ? ។ ២ ពហូស័ក្តិ ច្បាប់ដើមសរសេរក្លាយជា ពហាស័ក្តិតាមស៊ាំពីនិយាយពាក្យនេះប្រែថាស័ក្តិច្រើន, អំណាចច្រើន ។ ៣ ជីង ៣ តម្លឹង ១៧ គឺ ៣ ជញ្ជីង ១៧ តម្លឹង (១ ជញ្ជីង ៨០ បាទ ៣ ជញ្ជីងជា ២៤០ បាទ ។ ១ តម្លឹង ៤ បាទ ១៧ តម្លឹងជា ៦៨ បាទ ២៤០+៦៨= ៣០៨ បាទ) ។

ហៅមឿងហៅបានដឹងទៀយ ឲ្យយកអស់ប្រពន្ធកូនអម្បាលពោះមក ព្រោះព្រោះលុះឃើញថា យកមកពិចារណាដូចថានោះឲ្យចាលកង ហើយ ទើបលែងអស់ប្រពន្ធកូននោះទៅផ្ទះវិញហោង ។

មួយសោតបើព្រះបន្ទូលព្រះរាជប្រញ្ញុ ត្រាស់ឲ្យហៅហ្លួយស្រុក ករពល(១) ប្រជាប់ព្រះរាជការសង្គ្រាមក្តី ពោះហៅហ្លួយស្រុកបងឯង យកមកនៅក្អាប់បន្ទាយ ឲ្យជាឝយល្បាកលាភឡើកប្រយ័ត្នការផ្ទវសង្គ្រៃ ឥឡូវក្តី បាបានយកមកថ្វើព្រះរាជការហើយក្តី ពោះតាំងកពុំទាន់ដល់ ហៅហ្លួយស្រុកក្តី បើមានគាថ្វារ៉ូវកំណាចឯណាមកគណ្ដើមអំពីរាជការ ផ្ទះ ឲ្យហៅហ្លួយស្រុកចាប់កំណាចជាកវរងៀតកុំគោគញ្ញើក ទៀយ ។ បើកំណាចនោះ (ជា) ពលព្រះបាទវរមហាពិត្រអ្នកជាអម្ចាស់ ទ្រនំផ្លូវក្រោម ទូរអស់ព្រះអង្គឲ្យហៅហ្លួយស្រុកកាប់ចែកឃ្លាំងឲ្យខ្ជាប់ ហើយ ឲ្យដំទៀងជើងអណ្ដាគ បាញ់ ១០០ សណ្ដាក(២) ហើយ ដាក់មកគំពីនោះ កាប់ក្បាលឲ្យបាន ១០ រណ្ដៅ កុំឲ្យកន្លាប់កាចសាហាវ ពោះយង់យៀយ អស់គ្នាកំណាចដែលជួយយកផណ្ដើមតាំងបុំគាំ

១ កណ្ដាពល ? ។ ២ ប្រហែលជាបាញ់ ១១០ និងឬ ១០០ គ្រាប់ ដោយគ្រប់ធ្វើក ទេដឹង ? តាមច្បាប់ដើមសរសេរជាសណ្ដាកគេអាចអានបានជា ២ យ៉ាងគឺជា ស័ណ្ដោតក៏បាន ស័ណ្ដោតក៏បានឬឬយថា ស័ណ្ដិត (សណ្ដាត) វិញក៏បាន ព្រោះតាមរបៀបសរសេរអក្សរ ជាន់ដើម: បងជារបោង ។ ផងជាជោងទ្រូព្រេះដាដើម ។

ឲ្យចាប់ព្រែកឃ្នងឲ្យខ្ជាប់ ហើយឲ្យដំឡើងជើងអណ្ដាក បាញ់ឲ្យបាន២៤ សណ្ដាក ហើយឲ្យបញ្ចូលជាមហាគន្ធអស់ហោង ។

មួយសោតនោះមហាគន្ធមានញាតិដៅជាព្រៃអារ នោះ (ជា) សាច់ (ញាតិ) ទំងមហាគន្ធក្ដី សាច់ (ញាតិ) ទំងព្រែតន្ធមហាគន្ធក្ដី បើជាក់ជាព្រៃអារហើយឲ្យចៅហ្វាយស្រុកប្រើធ្វើព្រះរាជការ កុំគោត ញញើតឡើយ ។ បើ (សាច់) ញាតិជនជះណ្ដើម (យក) ញាតិដៅ អស់នេះឲ្យចៅហ្វាយស្រុកចាប់មហាគន្ធព្រែកឃ្នងឲ្យខ្ជាប់ ហើយនាំទៅ ដល់ចៅហ្វាយមហាគន្ធនូវមន្ត្រីធំឯកទ្ធិ ឲ្យឡើងក្រាបទូលព្រះបាទបរម- បពិត្រហោង ។ នាចៅហ្វាយស្រុកយកមកធ្វើរាជការផងទាំងពួងនោះ នោះចំណុះស្រុកខុសទីរាជការធ្ងន់ស្រាលដូចម្ដេចក្ដី ឲ្យពិចារណាធ្វើ ឲ្យមែនតាមច្បាប់ តាមដោយនូវទោសនោះ កុំឲ្យធ្វើតុគេដៀតតែស្រប់ ពង់យកប្រពន្ធកូនទ្រព្យរបស់គេ នូវខ្ញុំកំដរគោក្របីដំរីសេះរទេះទូក នូវ សារពើទ្រព្យធន ពុំបានដូចក្ដីបណ្ដាំឡើយ គេគល់ខុសហើយធ្វើទុក្ខ គេដូច្នេះ ។ បើគេចូលទៅដល់មន្ត្រីធំឯកទ្ធិ ឡើងក្រាបទូលដល់ល្អង ធូលីព្រះបាទហើយឲ្យជំនុំពិចារណា បើខុសមែនដូច្នោះ ព្រះបាទអ្នក ជាម្ចាស់នឹងឲ្យផ្ដុំទោសវិញ ដូចកាលធ្វើទោសគេនោះហោង ។

មួយសោតបើអស់ព្រះអង្គ នូវអស់ព្រះវង្សរាជវង្សមុខមន្ត្រីសេនាបតី នូវជំទាវនាងផង ប្រើកញ្ចាំចេញមកយកជំពូកនូវគម្ពោះទាំងទៃ១ក្ដី បើជា

នាំសារពើទំនិញចេញទៅជួញក្ដី បើគ្មានសំបុត្រ ព្រះបន្ទូលពិសេសក្ដី
ពុំមានព្រះបន្ទូលត្រាស់អំពីព្រះបាទបរមបពិត្រ អ្នកជាម្ចាស់ផែនផ្ទៃ
ក្រោម ត្រាស់លើមន្ត្រីធំឯកទង ឲ្យមកដល់ចៅហ្វាយស្រុកនោះ (១០)
កុំឲ្យចៅហ្វាយស្រុកនោះបើកឡើយ ។ បើអាជ្ញាខំបំពេសយកឯងនេះទៅ
ឯង ឲ្យចៅហ្វាយស្រុកឃាត់ជំណើមយកវិញ ហើយចាប់អាជ្ញានោះ
ចែកឃ្លាំងនាំទៅដល់មន្ត្រីធំឯកទង ជំនុំពិចារណាធ្វើដោយទោសានុទោស
នោះ ។ បើអាជ្ញាមកលួចយកកម្មោះឯង ពុំឲ្យចៅហ្វាយស្រុកដឹង
ឲ្យចាប់អាជ្ញានោះចែកឃ្លាំងនាំទៅដល់មន្ត្រីធំឯកទង បើអាជ្ញាលួចអស់
កម្មោះហួសចូលទៅ ឲ្យចៅហ្វាយស្រុកកាត់ត្រាដោយដំណើរនោះ ឲ្យ
នាំទៅដល់មន្ត្រីធំឯកទង ឲ្យក្រាបបង្គំទូលដល់លួនធូលីព្រះបាទ (ដើម្បី)
ឲ្យយកអាជ្ញានោះមកជំនុំពិចារណា ធ្វើដោយទោសានុទោសនោះឲ្យទៀន
ប៉ុនដ ។ បើអាជ្ញាខានសំបុត្រព្រះបន្ទូលអំពីព្រះបាទបរមបពិត្រ អ្នកជា
ម្ចាស់ត្រាស់លើមន្ត្រីធំឯកទង ឲ្យមកដល់ចៅហ្វាយស្រុក ជាឲ្យបើក
ប៉ុន្មាន ៗ ទើបចៅហ្វាយស្រុកឲ្យភ្នាក់ងារគេយកឲ្យបានជួបគន្ធព្រះបន្ទូល
ពិសេស កុំឲ្យអាជ្ញាដើរយកឯងឡើយ ។ បើចៅហ្វាយស្រុកយកកម្មោះ
ថាយបានជួបព្រះបន្ទូលពិសេស ហើយ (បើ) អាជ្ញាទំដើរយកលើស
ទីនព្រះបន្ទូលពិសេសនោះ ឲ្យចៅហ្វាយស្រុកមួសយកអស់កម្មោះនោះ
ទៅវិញ ហើយឲ្យចែកកោះអាជ្ញានោះនាំទៅដល់មន្ត្រីធំឯកទងហោង ។

១ លោកនាអស់ក្រុងធំទាំងពួង នៅនាក្នុងផ្ទៃក្រោមព្រះបាទអ្នកជាអម្ចាស់ កំណើតជាព្រៃផ្សារ ក៏បាននាំទៅដល់មន្ត្រីធំឯកក្នុងលោក ។

១ លោកអស់ក្រុងធំទាំងពួង នៅនាក្នុងផ្ទៃក្រោម ព្រះបាទអ្នកជាអម្ចាស់ កំណើតព្រៃផ្សារ ជាពល ជាកម្លោះសម្រាប់រៀន ។ មកក៏សុំមាន ប្តូរចិបចូលផងនៅពឹងពាក់ពំនាក់ អំពីបូកណារៀនមកពុំដែលឲ្យយកប្រើឡើយ ហើយបើបរទេស(១) ផងទាំងពួង ចូលមកនៅក្នុងផ្ទៃក្រោមព្រះបាទអ្នកជាអម្ចាស់ ហើយចូលពឹងពាក់ពំនាក់ដោយខ្លួនសព្វព្រះអង្គនោះពុំដែលឲ្យយកជាកម្លោះឡើយ បើមាន (ធ្វើ) ដូច្នេះ យល់ជាខុសទំនួលច្បាប់អំពីបូកណារៀង ។ មក កុំឲ្យអស់ព្រះអង្គយកជាកម្លោះផ្សេងអស់ទាំង (មនុស្ស) អស់នេះឯង ជាខ្ញុំជាកម្លោះផ្ទៃក្រោមសម្រាប់ពជគារលោក ។

១ លោក បើផ្ទៃក្រោមកើតក្រុលសឹកសត្រូវ នោះនឹងកាត់តែងប្រោះប៉ែចញ្ញបុកផការផងទាំងពួងក្ដី មេមន្ត្រីធំធំទុំឡើងក្រាប (បង្គំ) ទូល ព្រះបាទបរមបពិត្រអ្នកជាអម្ចាស់ ត្រាស់ឲ្យនាំព្រះបន្ទូលព្រះរាជប្រញ្ញូប្រញ្ញមកដាក់ចៅហ្វាយស្រុក ឲ្យយកពលប៉ុន្មាន ៗក្ដី ឲ្យចៅហ្វាយស្រុកយកឲ្យបានដូចកំណត់ ឲ្យមានបន្ទាស់ផ្លាស់គ្នាឲ្យស្មើ

---

១ បរទេស គឺអ្នកនៅប្រទេសដទៃផ្សេងក្រៅពីជាតិខ្មែរទៅជួបជា ចិន, យួន, ក្ដិង, ក្ដឹប, ភូមាគឺជើង ។

ឲ្យដឹងបុណ្យផុយដូចគ្នា កុំថាជំពូកអ្នកនេះ កុំថាជំពូកអ្នកនោះឡើយ ។ ឯអស់ខ្ញុំនូវក្នុងពលបៈម្រែសព្វមុខមន្ត្រី នូវនាយមហាត ខាងពលជន នោះ បើមានសំបុត្រនូវព្រះបន្ទូលឲ្យបរយកការមៅស្រែផងមៅស្រែ (១) ទើបឲ្យយកតែខ្ញុំ ឯពលពុំឲ្យយកឡើយ ។ បើឧជការនោះគ្រាន់បើ (២) ឲ្យត្រាណាអស់ខ្ញុំអ្នកដ៏មានគ្នាក់ងារ ដ្បិតសឹងនៅជាខ្ញុំធ្វើព្រះរាជការថ្វាយ នៅក្នុងរាជការ ឲ្យចៅហ្វាយស្រុកខេមរានំ (៣) ចាំងអម្បាលណោះ តែអស់ពែងារ នូវអស់កម្មោះ នូវបំពេសចាំងពួង ។ រីឯពលមានបន្ទាស់ ថាសំគ្នា ចូលទៅធ្វើព្រះរាជការនោះចេញងារមក (ហើយ) កុំឲ្យ ចៅហ្វាយស្រុកប្រើឡើយ បើមានសំនាលិកមក ទើបឲ្យចៅហ្វាយ ស្រុកបរយកនូវចំពោះតាមបន្ទាយ ហើយឲ្យចៅហ្វាយស្រុកជណ្ដឹងនន់ យល់ថាសំគៀនឲ្យចេញងារចូលងារ ឲ្យមែនខនឹងកំណត់ខែ ២ ក្ដី ខែ ៣ ក្ដី ឲ្យចៅហ្វាយស្រុកឲ្យត្រឡាបញ្ចីថាសំគៀនប្រែលលំនូវលើ (៤) ឲ្យចូល មកជូនសៀវភៅកុំឲ្យយូរឡើយ ។ បើក្នុងរាជការកម្រែ មន្ត្រីធំឯក្នុងក្រាប (បន្ដំ) ចូលឲ្យគង់ផ្ដាច់ចេញមកបរយកក្រៅងារ ប្រែលលំលើវត្ដ នោះឲ្យ

---

១ ការបម្រែ: ព្រាណសរសេរថា ការម្រៃស្រែ ប្រហែលសំដៅយកការភ្ជួរបន្តិចបន្តួចទេ? ជនម្នាស្រែនេះក៏ប្រហែលសំដៅយកមនុស្សតែបន្តិចបន្តួចដែរ ។ ឬម្យ៉ាងវិញទៀត សំដៅយកការដែលត្រូវធ្វើមួយជនមួយកាល ហើយត្រូវការភ្ជាក់ចជន! ។ ២ ប្រហែលជាចាត់ដើរទេដឹង? ព្រោះទូរថា បើរាជការនោះគ្រាន់ប្រើ ។ ៣ ប្រហែលជាឃុំទាំងទេដឹង? ។ ៤ ប្រែលលំ: អ្នកមានប្តីប្រពន្ធ? លើវៈ អ្នកឥតប្តីប្រពន្ធ ។

យកបងប្អូនកូនក្មួយ អ្នកឯណោះជាមេកន្សឹក នោះក្តីឲ្យចៅហ្វាយស្រុកទាំងទៀយ ឲ្យជួយយកឲ្យដំណើរចូលទៅជាធ្លាប់ដូចព្រះកបប្រញ្ញត្ត នោះហោង ៕

១ សោក នាព្រះបាទធម្មេបតិត្រឹបញ្ជីចៅហ្វាយស្រុក នោះទំនង បានអបតរណ៍រេធ ដោយព្រះកបមានពិសេសក្តី..... ជំនួសខេះឯងទំនង បានដូចព្រះកបការ (១) ។ នោះចៅហ្វាយស្រុកជំនុំសារពើសេចក្តី ១ បើកុំជាច់ស្រេច ឲ្យកត់ដោយដំណើរសេចក្តីនោះ ឲ្យនាំចូលទៅដល់មន្ត្រីជំឯកង ក្រាប (បង្គំ) ទូលដល់ល្អងធូលីព្រះបាទ នោះល្មមកាត់សេចក្តីអំពីក្ទន់ក្តី ល្មមនឹងប្រើការឲ្យចេញមកយកទៅជំនុំពិចារណាឯក្ទន់ក្តី តាមដោយបទប្រការសេចក្តីនោះ ៕

១ សោក បើពលរបស់ព្រះបាទអ្នកជាម្ចាស់ និងគេសព្រះអង្គ បើជាចេញទៅជាចោរលួចប្រពន្ធគេក្តី នោះកាលួចប្តូរយកទ្រព្យរបស់គេ ហើយកាយតាំងបាញ់ពាក់គាប់ម្ចាស់ទ្រព្យម្ចាស់ផ្ទះទូវ៉េនោះស្លាប់ក្តី នោះជាក្រុសក្តី នោះស្លាប់ឲ្យសម្លាប់ពំនោះជាលើស្រៀត (២) ហោង ៕ បើត្រាន់តែជាក្រុសក្តី បើកលួចប្ទទូវហើយពុំបានបាញ់ពាក់គាប់ម្ចាស់ទ្រព្យ

---

១ ប្រយោគនេះ ខ្ញុំជាមិនបានសេចក្តីច្បាស់លាស់ល្អប្រពៃណាសមាគាត់សេចក្តីខ្លះ ឬពាក្យខ្លះដោយសេចក្តីក្លាំងក្លាតំរបស់អ្នកជាវ ។ ២ សេចក្តីថា នោះស្លាប់ឲ្យសម្លាប់ពំនោះបង្ហើរ គឺថាបើពលកសម្លាប់ម្ចាស់ទ្រព្យក្តី សម្លាប់ប្តីគេក្តី នោះគេកឲ្យសម្លាប់ពលនោះចោល ទើបគប្បីយកសម្លាប់គេនោះឯង ។

នូវថ្លៃនោះទៀយ ឯណាជាមេនោះឲ្យបាញ់ ១០០ សំណាកបណ្ដើរក្រវែល ហើយឲ្យវាយ ១០ តំណំ ហើយកាត់ក្បាល ១ រណ្ដៅឲ្យគង់ជាពលផ្ដួលដែល ហើយ ( កុំ ) ឲ្យពិចារណាគិតដំរៀប្រែទ្រព្យគេនោះប៉ុន្មាន ៗ នូវថ្លៃនោះទៀយ ។ ឯណាជាមេនោះ.....មកបង្វែងកាមច្បាប់ទេបតិន័យ ១ ជា ៤ បើវាមានទ្រព្យបង់ក្រយាពិន័យ កុំឲ្យវាយផ្ដួលទៀយ ។ បើឥតទ្រព្យបង់ក្រយាពិន័យគ្រប់ នោះបានក្រយាពិន័យ ១ ជា ៣ ក្ដី ១ ជា ២ ក្ដី នោះបានគ្រប់តែទ្រព្យដើមក្ដី ខាតទ្រព្យដើមខ្វះក្ដី ឲ្យគិតទ្រព្យកម្សាលខាតនោះ នោះត្រូវប៉ុន្មាន ៗ ឲ្យផ្ដួលតាមដោយទ្រព្យដើមនោះហោង ។ នោះទ្រព្យដើមក្ដី ក្រយាពិន័យក្ដី បើខាតដល់ឡឹង ១ ក្រវែងនោះដល់តម្លឹង ៩ ក្ដី នេះឲ្យវាយ ។ បើខាតដល់តម្លឹង ១០ ក្រវែងនោះដល់តម្លឹង ១៩ នេះឲ្យវាយ ហើយបាញ់ផង បើខាតដល់ជីង ១ ក្រវែងនោះប៉ុន្មាន ៗ ឲ្យវាយហើយឲ្យកាប់ក្បាលបាញ់ផង ( ផែល ) ឲ្យវាយនោះសិនឲ្យបណ្ដើរស្រុកអាក្រោសផង ប្រាប់អស់អ្នកទាំងពួងកុំឲ្យចេញទៅជាចោរទៀយ ។ វាយម្ដងនោះជាប្រាក់បាទ ២ បាញ់ម្ដងជាប្រាក់បាទ ២ (ផែ) កាប់ក្បាលម្ដង ១ រណ្ដៅជាប្រាក់តម្លឹង ៤ ។ បើខាតបាត់បង់ទាំងទ្រព្យដើមតម្លឹង ១០ ក្ដី ច្រើនក្រវែងនោះក្ដី បើអាចោរនោះឥតទ្រព្យទិញសងឲ្យចញ្ចប់សិន កុំអាលផ្ដួលទៀយ ឲ្យធ្វើបំបុត្រកក់ដោយដំណើរនាំទៅដល់ទៅហ្លួងយាយពល នូវព្រះស្ញូរក្រាដ ឡើងក្រាប

(បន្ទី) ខ្លួនឲ្យបានទ្រង់ប្រាជ្ញបវល់ល្អផ្ដល់ព្រះបាទ ។ រីពុំឲ្យលុកក្តួពល ស្ដីបង់ក្រយាពិន័យឯងឡើយ រីឯជាមេហោរនោះ នោះបានក្រយ៉ា ពិន័យក្តី ឲ្យផ្ទុំទាំពុំលែងឡើយហើយគង់ជាពលដូចដែលហោង ។ បើព ង៉ាៈហារលួចគោក្របីគេសោត រីក្រយាពិន័យឲ្យសងដោយមានដោយ គ្មាន (ហើយ) ផ្ទុំទាំផ្ទុំដើមនោះហោង ។ រីប្រាក់ពួកពុំឲ្យយកឡើយ ឲ្យតែផ្ទុំទាំដូចកំណត់ . . . ប្រាក់ពួកនោះកុំឲ្យសោះលាត្រាប្រណីឡើយ ហោង[1] ។

ឯពលបើគេពិហារណាគេនៅយល់ថា គាពលធ្មប់[2] មែនដូចពាក្យ គេថា ឲ្យសង្វាប់បង្ហៀត កុំឲ្យលស់ (លាត្រាប្រណី) ឡើយ ហើយ ឲ្យរេយកអស់ទ្រព្យរបស់ រីប្រពន្ធកូនក៏ឲ្យគង់ជាពលដូចដែល ។

ឯពលបើខ្ចីចង្ការទ្រព្យគេក្តី នោះធ្វើឲ្យបាត់បង់ទ្រព្យគេក្តី បើ ម្ចាស់ទ្រព្យនោះនៅយកការ បើមានពាក្យបរិហារបរគេទមឥសន្ទុកនឹង

---

១ សេចក្តីក្នុងប្រយោគនេះ ហាក់ដូចជាមានកាត់សេចក្តីខាងដើមអញ្ជើ ទើបបាច់យកមិនបានជាក់ច្បាស់ ។ ពាក្យថា "ប្រាក់ពួក" ប្រហែលជាឈ្មោះមុខពន្ធអ្វីៗ ក្នុងសម័យនោះ ! ប្រយោគខាងដើមថា រីប្រាក់ពួកពុំឲ្យយកឡើយ "ឲ្យតែផ្ទុំទាំដូចកំណត់" ប្រយោគខាងចុងត្រឡប់ជាមានសេចក្តីផ្ទុយថា ប្រាក់ពួកនោះកុំឲ្យលស់លាត្រាប្រណីឡើយហោង ដូច្នេះទើបឃើញថា ប្រហែលជាអ្នកចារៈ ចម្លងខ្វះសេចក្តីបាស់របស់គេខ្លះទេដឹង ។ ២ វិជ្ជាមួយយ៉ាងដែលគាប់ទាក់ទងទៅនឹងខ្មោចបិសាច បើប្រុសហៅថា (ធ្មប់) ស្រីហៅថា (អាប) ពេលអ្នកក្នុងសម័យនោះក៏ស្អប់អាលធ្មប់ទ្រូះ ត្រាំតែនេះក៏ឲ្យយកទៅកាប់សម្លាប់ចោល ! — មិនអាចដឹងបាន ។

ឲ្យឈរនោះ បើមានទ្រព្យរបស់ទៀតសងដោយនូវពាក្យសន្មត បើទ្រព្យពិបាកឲ្យសងតែទ្រព្យដើម បើអត់ទ្រព្យសងឡើយ ឲ្យកត់ជាសំបុត្រ ហើយឲ្យនាំទៅដល់ទៅហ្វាយពល នូវព្រះស្មូគ្រាជ ឲ្យឡើងក្រាប (បង្គំ) ទូលដល់ល្អងធូលីព្រះបាទ ហើយពុំបោះទឹងព្រះទ័យ ។ បើវាមានក្ដីទេ ពុំជាចោរពុំជំពាក់ទ្រព្យគេនោះ នោះអាល្មើសនឹងព្រះបន្ទូល ទោះសេព្រះបន្ទូល ក្រលើសព្រះបន្ទូលក្ដី ប្រកួតប្រជែងព្រះបេស្កក្ដី បង្អាក់មហាគ បណ្ដាមហាគក្ដី វាយមហាគយកទ្រព្យហ្វូងនូវសហាច សហាវក្ដី នោះវាខុសមេធាវក្ដី នោះល្មើសធាហានក្ដី នោះប្រកួតអួតអាង ភ្លះភិះដៀលពុំគោរពខ្លាចប្រទេញ្ញានរាមនឹងធាហានក្ដី នូវពស្ត្រីប្រជាគ្នាវាឯងក្ដី នោះបង្អាក់បណ្ដោះរូនគេក្ដី វិសាលរតីអស់ទាំងនេះ នោះទោសវាស្លាប់ឲ្យសម្លាប់ ដើទោសវាពុំដល់ស្លាប់ នោះត្រូវក្រយាពិន័យប៉ុន្មានៗ កុំឲ្យលើកពិន័យគលឡើយ ឲ្យផ្ដន្ទាទោសតាមដោយទោសធ្ងន់ស្រាល ឲ្យវាពន្ធវាតាល កុំឲ្យវាគាបពាយនិយាយឡើយ ។ ឯទោសពលើខុសទឹងព្រះប្ដាអ្នកជាអម្ចាស់ទឹងអស់ព្រះអង្គផង បើល្មមសម្លាប់ឲ្យដោយព្រះក្រឹត្យដីកាសម្លាប់នោះ បើល្មមត្រូវក្រយាពិន័យ នោះប្រើនឲ្យបាញ់សណ្ដាកកាប់ក្បាលផង ឲ្យគន់ជាពលដូចផលហោង ។

# គោរម្យងារនឹងស័ក្តិមន្ត្រីស្រុកក្រៅ

ឧកញ៉ាតេជោ ជាចៅហ្វាយស្រុកសន្ទុកស័ក្តិ ១០ ហ៊ូពាន់ឯកជាខ្ទង់ពោះ[១] ។ ឧកញ៉ាពិស្នុលោក ចៅហ្វាយស្រុកព្រាំងស្តាំ មានចៅមឿង ៣ មឿង ។ ឧកញ៉ាអជូន ចៅហ្វាយស្រុកត្បូមបរស្តាំ មានចៅមឿង ៤ មឿង ។ ឧកញ៉ាសួគ៌ាលោក ចៅហ្វាយស្រុកពោធិ៍សាត់ឆ្វេង មានចៅមឿង ៤ មឿង ។ ឧកញ៉ាធម្មតេជោ ចៅហ្វាយស្រុកបាភ្នំ (ឆ្វេង) មានចៅមឿង ៦ មឿង ។ អស់ចៅហ្វាយស្រុកទាំង ៤ នេះ សឹងជាជើងត្រស[២] ស័ក្តិ ១០ ហ៊ូពាន់ឯក ។

ឈ្មោះឧកញ៉ានគរ[៣] ឆ្វេងខៀវ ស័ក្តិ ៩ ហ៊ូពាន់ មានចៅមឿង ៥ មឿង ។ ឧកញ៉ាឧទ័យធិរាជ ស្តាំខៀវ ស័ក្តិ ៩ ហ៊ូពាន់ ចៅហ្វាយស្រុកសំរោងទង មានចៅមឿង ៣ មឿង ។ ឧកញ៉ាសេនាធិបតីចៅហ្វាយស្រុកព្រះត្រពាំង[៤] ស័ក្តិ ៩ ហ៊ូពាន់ មានចៅមឿង ១០ មឿង ។

---

១ ខ្ទង់ពោះ៖ ក្នុងទីនេះជាពាក្យសំគាល់ដល់មន្ត្រីជាន់ខ្ពស់បំផុតសម្រាប់ខេត្តក្រៅ ។
២ ជើងត្រស៖ ប្រហែលជាក្លាយមកពីពាក្យថា ជើងត្រិះទេងឹង៖ ព្រោះពាក្យនេះប្រែថា «ជើងផ្ទះ, ជំហរផ្ទះ» ។ មន្ត្រីជាន់ខ្ពស់ទាំង ៤ នេះជាអ្នកសម្រេចរាជការខេត្តក្រៅ មានទំនងដូចជាមន្ត្រីធំៗក្នុងវាំងហៅថា «ចតុស្តម្ភ» ប្រែថាសសរ ៤ ជាជនឹងអធិបតី គឺ អគ្គមហាសេនាបតី ជាអ្នកសម្រេចរាជការទាំងពីជាមួយនឹងមហាក្សត្រទ្រង់រាជ្យ ។ ៣ ប្រហែលជាសំដៅយកខេត្តនគរវត្ត - នគរធំ នៅក្នុងភូមិខេត្តសៀមរាបសព្វថ្ងៃនេះ ។ បើមិនដូច្នោះទេ គង់សំដៅយកអង្គរបុរីនៅក្នុងខេត្តតាកែវ ។ ៤ ខេត្តព្រះត្រពាំង សព្វថ្ងៃនៅក្នុងដែនកូសាំងស៊ីន ។

ពញាធម្មាធិបតី ចៅហ្វាយស្រុកសម្បូរ ស័ក្តិ ៩ ហ៊ូពាន់ មាន
ចៅមឿង ៣ ទៀត ។
ពញាធនញ្ជ័យស្នេហ៍ ចៅហ្វាយ (ស្រុក) ចាំប៉ា ស័ក្តិ ៨ ហ៊ូពាន់
មានចៅមឿង ៤ ទៀត ។ ពញាឧទ័យតេជះ ចៅហ្វាយស្រុកស្រីសុន្ទរ
ស្នាក់ខ្មែរ ស័ក្តិ ៨ ហ៊ូពាន់ មានចៅមឿង ៤ ទៀត ។
ចៅពញាកជាសួគ៌ ចៅហ្វាយស្រុកបាភ្នំ ស័ក្តិ ៨ ហ៊ូពាន់ មាន
ចៅមឿង ២ ទៀត ។ ចៅពញាកជាកម្ម ចៅហ្វាយស្រុកគោក
សេះ មានចៅមឿង ៣ ទៀត ។ ចៅហ្វាយ តាំង ២ នេះស័ក្តិ ៨
ហ៊ូពាន់ដូចគ្នា ។
មានចៅពញាកជាស្នេហា ចៅហ្វាយស្រុកត្បូងឃ្មុំ ស័ក្តិ ៨ ហ៊ូពាន់
មានចៅមឿង ៣ ទៀត ។ ចៅពញាយោធាធិបតីកដី ចៅហ្វាយ (ស្រុក)
មង្គលបុរី ស័ក្តិ ៨ ហ៊ូពាន់ មានចៅមឿង ២ ទៀត ស្រុក
តាំង ២ នេះស័ក្តិដូចគ្នា ។
ចៅពញាអនុរក្សា ចៅហ្វាយស្រុកស្ទឹងត្រែងស្រែអំបិល
ហ៊ូពាន់ មានចៅមឿង ៣ ទៀត ។ ចៅពញាសេនាធិបតី ចៅហ្វាយ
ស្រុកត្បូងក្ឃ្មុំ ស័ក្តិ ៨ ហ៊ូពាន់ មានចៅមឿង ៤ ទៀត ។
ចៅពញាធម្មាធិរាជ ចៅហ្វាយស្រុកកំពង់ស្វាយ ស័ក្តិ ៨ ហ៊ូពាន់ មាន
ចៅមឿង ១ ទៀត ។ ព្រះសុរិន្ទធិបតី ចៅហ្វាយស្រុកព្រៃវែង

សក្តិ ៦ ហ៊ូពាន់ មានចៅមឿន ២ ឡើន ។ ព្រះសិរីសោភ័ណ ចៅហ្វាយស្រុកព្រៃវែង សក្តិ ៦ ហ៊ូពាន់ មានចៅមឿន ៣ ឡើន ។ ព្រះយសគេជោ ចៅហ្វាយស្រុករលាប្អៀរ សក្តិ ៦ ហ៊ូពាន់ មានចៅមឿន ២ ឡើន ។ ព្រះយោធាធិបតី ចៅហ្វាយស្រុកកំពង់សោម សក្តិ ៦ ហ៊ូពាន់ មានចៅមឿន ២ ឡើន ។ ព្រះកជគេជោ ចៅហ្វាយស្រុកព្រៃក្តី សក្តិ ៦ ហ៊ូពាន់ ........(១) ។ ចៅហ្វាយស្រុកទាំង ៩ នេះ ខាងស្តាំ(២) ។

ព្រះសេនាសង្គ្រាម ចៅហ្វាយស្រុកក្រគរ សក្តិ ៦ ហ៊ូពាន់ មានចៅមឿន ១ ឡើន ។ ព្រះមនោសង្គ្រាម ចៅហ្វាយស្រុកក្រង សក្តិ ៦ ហ៊ូពាន់ មានចៅមឿន ២ ឡើន ។ ព្រះយោធាសង្គ្រាម ចៅហ្វាយស្រុកទ្រាំង សក្តិ ៦ ហ៊ូពាន់ មានចៅមឿន ១ ឡើន ។ ព្រះជ័យគេជោ ចៅហ្វាយស្រុកដើនព្រៃ សក្តិ ៦ ហ៊ូពាន់ មានចៅមឿន ៤ ឡើន ។ ព្រះអធិកគេជោ ចៅហ្វាយស្រុកបាភ្នំ(៣) សក្តិ ៦ ហ៊ូពាន់ មានចៅមឿន ៣ ឡើន ។ ព្រះកមគេជោ ចៅហ្វាយ

---

១ មានចៅមឿនប៉ុន្មានទៀតមិនប្រាកដ ។ ២ មិនគ្រប់ ៩ បើរាប់រួមទាំងពីចៅពញាក្នុងសេចក្តីមកឃើញតែ ៨ បាត់ ១ តាមវិធាននោះគួរតែ ៩ ស្រុកទេ មិនខែនទ ៩ ទៀយ ព្រោះចៅហ្វាយស្រុកខាងឆ្វេងមាន ៨ ដែរ ។ ៣ ពាក្យនេះប្រហែលសរសេរដោយកពាក្យបាសាក់នៅក្នុងរូបវៃក្រុកពង់តាមសព្វថ្ងៃនេះ ។

ស្រុកស្ទឹងត្រង់ស័ក្តិ ៦ ហ៊ូពាន់ មានចៅមឿង ២ ទៀង ។ ព្រះពុក្រៃ ចៅហ្វាយស្រុករំដួល ស័ក្តិ ៦ ហ៊ូពាន់ មានចៅមឿង ១ ទៀង ។ ព្រះមនោសង្គ្រាម(១) ចៅហ្វាយស្រុកស្វាយទាប ស័ក្តិ ៦ ហ៊ូពាន់ មានចៅមឿង ១ ទៀង ។ អស់ចៅហ្វាយស្រុកទាំង ៧(២) នេះមានច្រើន ។

## ស័ក្តិមន្ត្រីក្រោមបង្គាប់ចៅហ្វាយស្រុក

ឯចៅហ្វាយស្រុកស័ក្តិ ១០ ហ៊ូពាន់នេះ ជំទប់សិនឈ្មោះអកខុន ស័ក្តិ ៤ ហ៊ូពាន់ ហៅក្សត្រ ក្រឡាបញ្ជី សុភា សិនឈ្មោះជាគតហ៊ុន ស័ក្តិ ៤ ហ៊ូពាន់ ធម្មាភិគន្ធ្រៃ... សិនឈ្មោះជាអកពាន់ស័ក្តិ ២ ហ៊ូពាន់ ។ ចៅមឿង សិនឈ្មោះជាអកហ្មឺនស័ក្តិ ៤ ហ៊ូពាន់ ជំទប់ចៅមឿង សិនឈ្មោះអកពាន់ស័ក្តិ ២ ហ៊ូពាន់ ក្រឡាបញ្ជីសម្រាប់ចៅមឿង សិនឈ្មោះអកហ្លួនស័ក្តិ ១ ហ៊ូពាន់ ។ ចៅបានស័ក្តិ ២ ហ៊ូពាន់ ជំទប់ចៅបានឈ្មោះអកហ្លួនស័ក្តិ ១ ហ៊ូពាន់ ក្រឡាបញ្ជីសម្រាប់ចៅបាន ឈ្មោះចៅហ្លួនស័ក្តិ ១ ហ៊ូពាន់ ចាស់ស្រុកឈ្មោះចៅហ្លួន (វែរ)

---

១ គោរម្យងារៈមនោសង្គ្រាមនេះដូចគ្នានឹងគោរម្យងាររបស់ចៅហ្វាយស្រុកក្នុងខាងលើនេះ ចៅហ្វាយស្រុកទាំងពីរស្រុកនេះ ប្រហែលមានគោរម្យងារផ្សេងគ្នាទេ តែអ្នកចម្លងមកខុសទេដឹង? ។ ២ តាមរៀបរាប់ពិតគួរតែ ៨ ទេ ព្រោះចំនួនចៅហ្វាយស្រុកខាងស្ដាំ ស័ក្តិ ៦ ហ៊ូពាន់ មាន ៨ នាក់ ចៅហ្វាយស្រុកខាងឆ្វេងក៏ត្រូវតែមានចំនួន ៨ នាក់ដែរ មិនមែនជា ៧ ដូចចំនួនបូករួមនោះឡើយ ។

ស័ក្តិ ៣ ហ៊ឺពាន់ ។ ចំណែកពលទេពក្តី នាយពេជ្ឈក្តី នាយសុភាក្តី នាយសន្ធិការក្តី សុស្តីក្រក្តី អស់កម្មាះសព្វលំពូកនេះក្តី អស់នាយទាំង ៥ នេះ ឈ្មោះទៅហ្លួនស័ក្តិ ១ ហ៊ឺពាន់ អស់ទាំងនេះសឹងឡើងទៅក្រោយស្រុក ។

ឯទៅហ្លួយស្រុកស័ក្តិ ៩ ហ៊ឺពាន់ក្តី ទៅក្រោយស្រុកស័ក្តិ ៨ ហ៊ឺពាន់ក្តី ជំទប់[១] សឹងឈ្មោះអកហ៊ឺនស័ក្តិ ៦ ហ៊ឺពាន់ ។ យោកក្បាត់ក្រឡាបញ្ជី សុភា[២] សឹងឈ្មោះអកពាន់ ស័ក្តិ ២ ហ៊ឺពាន់ ។ ជម្នាញកក្រឡាបញ្ជី សឹងឈ្មោះអកហ្លួន ស័ក្តិ ៤ ហ៊ឺពាន់ ។ ទៅមឿនសឹងឈ្មោះទៅមឿន ស័ក្តិ ៤ ហ៊ឺពាន់ ជំទប់ទៅមឿនឈ្មោះអកហ្លួន ស័ក្តិត្រឹង[៣] ។ ក្រឡាបញ្ជីសម្រាប់ទៅមឿនឈ្មោះទៅហ្លួន ស័ក្តិ ១ ហ៊ឺពាន់ ។ ទៅបានឈ្មោះទៅបាន ស័ក្តិ ២ ហ៊ឺពាន់ ជំទប់ទៅបានឈ្មោះទៅហ្លួនស័ក្តិត្រឹង ។

---

១ ជំទប់ៈ ក្នុងសម័យសព្វថ្ងៃមិនប្រើឈ្មោះជាជំទប់ទៀត, ចំណែកក្នុងសម័យបុរាណទៀ មានតែជំទប់ប៉ុណ្ណោះ ៣ ថ្នាក់ ជំទប់លេខ ១ ហៅថាជំទប់កណ្ដា, លេខ ២ ជំទប់លេខា, លេខ ៣ ជំទប់ភក្តី ។ ស្តាប់មើលគោរម្យងារជំទប់ ទូរតែជាអ្នកមានយសស័ក្តិខ្ពង់ខ្ពស់ត្រាន់បើដែរ តែតម្រូវការជំទប់ថ្នាស់មកជាជាឡាត់ស្រុក, ភូឈួយទៀតទៅវិញ បានជាងារស័ក្តិជំទប់ធ្លាក់មកទៅត្រឹមបំផុតពីជំទប់ឃុំ ។ ២ សុភាៈ ជាមន្ត្រីខាងក្រសួងតុលាការ ក្នុងសម័យសព្វថ្ងៃនេះត្រឡប់បានឡើងយសស័ក្តិខ្ពង់ខ្ពស់ស្មើនឹងចៅហ្វាស្រុក - ទៀតបែកខាងរដ្ឋបាល ។ ៣ ពាក្យថាៈ " ត្រឹង " ប្រហែលជាពាក្យថៃទេដែលប្រែថា " កន្ទះ, ពាក់កណ្ដាល " បានសេចក្តីថាអកហ្លួនមានស័ក្តិត្រឹមពាក់កណ្ដាលស្រដៀងឡើង ។

ចាស់ស្រុកឈ្មោះចៅហ្មឺនសក្តិ ១ ហ៊ូពាន់ បម្រើនពលទេពក្តី នាយឃោយក្តី នាយសូភាក្តី នាយសង្ឃការីក្តី ស្មស្តីក្រៅក្តី អស់ធម្មោះសព្ទដំពូកក្តី នាយតាំង ៤ នេះ ស៊ីងឈ្មោះចៅហ្មឺនសក្តិ ១ ហ៊ូពាន់ អស់តាំងនេះ ស៊ីងឡើងចៅហ្វាយស្រុក ។

ឯចៅហ្វាយស្រុកសក្តិ ៧ ហ៊ូពាន់ក្តី សក្តិ ៦ ហ៊ូពាន់ក្តី ជំទប់ស៊ីងឈ្មោះជាអគ្គពាន់ សក្តិត្រឹងចៅហ្វាយ (ស្រុក) ។ យោកក្បាត់ ក្រឡា-បញ្ជីស៊ីងឈ្មោះជាគតហ្មឺន សក្តិ ២ ហ៊ូពាន់ ។ ធម្មាពិករក្រឡាបញ្ជី ស៊ីងឈ្មោះជាចៅហ្មឺនសក្តិ ១ ហ៊ូពាន់ ។ ចៅមឿងឈ្មោះជាអគហ៊ូន សក្តិ ២ ហ៊ូពាន់ ជំទប់ចៅមឿងឈ្មោះជាចៅមឿង សក្តិត្រឹងចៅមឿង ។ ក្រឡាបញ្ជីសម្រាប់ចៅមឿងឈ្មោះជាបម្យ៉ង ស៊ីងសក្តិ ១ ហ៊ូពាន់ ។ ចៅបាឧឈ្មោះជាចៅបាឧ សក្តិ ១ ហ៊ូពាន់ ជំទប់ចៅបាឧឈ្មោះជាចៅហ្មឺនសក្តិត្រឹង ។

ចាស់ស្រុកឈ្មោះជាចៅហ្មឺនសក្តិ ១ ហ៊ូពាន់ បម្រើនពលទេពក្តី នាយឃោយក្តី នាយសុភាក្តី នាយសង្ឃការីក្តី ស្មស្តីក្រៅក្តី បម្រើនអស់ធម្មោះសព្ទដំពូកក្តី អស់នាយតាំង ៤ នេះ ស៊ីងឈ្មោះជាចៅហ្មឺនសក្តិ ១

ហ៊ុយាន់ អស់ទាំងនេះសឹងទៀងទៅហ្វាយស្រុក (១) (នេះសារស្តាបច្បាប់ក្រម ទៅហ្វាយស្រុក អ្នកកញ្ញាធិកជវៃង្ស ដើមឈ្មោះពេជ្រ (ជាប្អូន) វា: ព្រះជិត

ចប់ច្បាប់ក្រមទៅហ្វាយស្រុកពីបូរាណតែប៉ុណ្ណេះ

---

(១) តាមរឿងនេះឃើញថា ចៅហ្វាយស្រុកមានអំណាចនឹងសិទ្ធិយ៉ាងខ្ពង់ខ្ពស់បំផុត នៅក្នុងកិច្ចក្នុងស្រុករបស់ខ្លួន មិនត្រូវទទួលស្គាល់សព្វថ្ងៃនេះទេ ដែលមានការបែងចែកអំណាចនឹងមុខក្រសួងដាច់ដោយឡែកពីគ្នា ដូចជា ផ្នែកខាងតុលាការ, រដ្ឋបាល, សាសនា, ការសិក្សា ក៏មានមុខក្រសួងនឹងអំណាចដាច់ដោយឡែកៗ ពីគ្នា ។ ក្នុងសម័យនោះទុកជាមានមុខក្រសួងដាច់ដោយឡែកពីគ្នាដែរ តែត្រូវរួមឡើងទៅលើចៅហ្វាយស្រុកទាំងអស់ ។ ដូច្នេះទើបឃើញថា ចៅហ្វាយស្រុកជាន់នោះ ជាអ្នកសម្រេចកិច្ចការស្ទើរតែដាច់ស្រេចដោយខ្លួនឯងទាំងអស់ ទាំងផ្នែកខាងអាណាចក្រ ទាំងផ្នែកខាងពុទ្ធចក្រ ដែលនៅក្នុងស្រុករបស់ខ្លួន ។

វិធីរាប់ថ្ងៃ-ខែ-ឆ្នាំ-រដូវ

ព្រះគ្រូញាណសំវរ ញាណ-ឈឹម រៀបរៀងទីធំរបស់

## លេខប្ញី (ពាក្យ ៧)

លេខ ១ លោកកំណត់ទុកថា ជាថ្ងៃអាទិត្យជាក់ស្ពាន់
លេខ ២ លោកប្រាប់ឲ្យប្រកាន់ ទុកជាថ្ងៃចន្ទប្រាកដពៅ ។
លេខ ៣ លោកឲ្យស្គាល់ពាក្យពារ ជាថ្ងៃអង្គារសេទ្ធតហៅ
លេខ ៤ លោកប្រាប់កុំសៅហៅ ចំណាំទុកទៅជាថ្ងៃពុធ ។
លេខ ៥ លោកត្រាទុកឥតចាស់ ជាថ្ងៃព្រហស្បតិ៍ចាំឲ្យមុត
លេខ ៦ លោកស្ដីចំហុត ជាថ្ងៃសុក្រសុខឥតឃ្លាតឃ្លា ។
ឯលេខ ៧ លោកសំណៅ ទុកជាថ្ងៃសៅរ៍ចេះចំក
បុគ្គលទាំងអស់លោកប្រាប់ថា ជាមួយសង្គហៈគប់គ្រាន់ ។
លេខនៃឈ្មោះថ្ងៃទាំងនេះ ជាត្រូវចង់ចេះកុំធុញទ្រាន់
ដើម្បីនឹងប្រើការជំនាន់ ដែលប្រព្រឹត្តទាន់ពេលសម័យ ។
ដូចសំពុត្រហេតុរឿងណា ដែលយើងត្រូវត្រាទុកឈ្មោះថ្ងៃ
និងឈ្មោះខែឆ្នាំត្រូវតែតៃ យកលេខនោះនៃប្រើសុខសាន្ត ។
ជម្រុងសរសេរពាក្យថាថ្ងៃ បន្ទាប់ត្រូវលៃគួរសាកពាក្យ (១)

---

(១) ធ្វើនៅថ្ងៃ ● ៤/+ ១ ឆ្នាំរកាសទោស័ក ព. ស. ២៤៧៧ (ភាគខ្មែរ) ។
ធ្វើនៅថ្ងៃ ២ +/៣ ២ ឆ្នាំរកាសបួស័ក ព. ស. ២៤៧៧ (ភាគរោគ) ។

| | |
|---|---|
| ឲ្យយ៉ាងពិសេសល្អសមស្អាត | ខាងក្នុងកាកបាទចុះលេខថ្ងៃ ។ |
| លើក្រោមកាកបាទប្រាប់លេខប័ក្ស | ខ្ទង់នោះជាក់សុរសោរ |
| បើជាខាងខ្នើតលិចកៃល | ចុះលេខលើនៃកាកបាទនោះ ។ |
| បើជាចំណែករនោចវិញ | ក្រោលេះក្រោមមិញកាកបាទស្មោះ |
| ខាងស្ដាំកាកបាទឲ្យចុះបោះ | សំគាល់លេខឈ្មោះនៃគ្រប់ប្រើ ។ |
| កទៅលោតឲ្យជាក់ឈ្មោះឆ្នាំ | សកកាជប្រចាំត្រូវចុះធ្វើ |
| នៅចុងបំផុតកុំរេរើ | ដើម្បីស្រួលប្រើក្នុងសំបុត្រ ។ |
| នេះជារបៀបចោទពណា | លោកបានថែងតារយ៉ាងចំហុត |
| ទុកសម្រាប់កម្ពុជបុត្រ | ប្រើស្រួលបំផុតបំប្រួញទី ។ |

(របស់លោក អៀង-ប្អាង)

## លេខខែ

មិគសិរលេខ ១ ពុំព្រួយគិត
គឺលេខ ២ ពិតនៃបុស្ស
ខែមាឃលេខ ៣ ឥតគន្ធា
ផល្គុនមាសាត្រាលេខ ៤;
ខែចេត្របួលផ្តាំតាមកំណត់
លេខ ៥ ច្បាស់ផងនៅទំនួន
វិសាខលេខ ៦ ត្រូវសមសួន
៧ ក្នុងក្បួនជូនខែជេស្ឋ;
អាសាឍចំណូលថ្ងៃចូលវស្សា
ប្រើលេខអស្តាបាត្រូវបេះ
គឺលេខ ៨ នោះឯងណេះ
ខែស្រាពណ៍តនេះលេខ ៩;
លេខ ១០ ជាប់ដាំខែភទ្របទ
ច្បាស់ផ្ទប្រើត្រាកត់ខែតាមក្បួន
រដូវដាក់បិណ្ឌបុណ្យចាំមួន
ជុំខែរចិនយួនថៃដាច់ខែ;
អស្សុជ ១១ ចាំត្រូវបាំ
ចំណាំទុកនៅកុំភ្លេចភ្លេ
កត្តិក ១២ ជាចុងគេ
ជួបចប់ជាខែ ១២ គត់;
លេខថ្ងៃលេខខែពីរបែបនេះ
កុមារត្រូវចេះចាំឲ្យស្ទាត់.
ទំរៀនទន្ទេញឲ្យគ្មានបទ
ទុកប្រើសំបុត្រកត់បញ្ជី ។

## ខែពេញ—ខាត

ខែដប់ពីរតាមធម្មតា
សឹងមិនដូចគ្នាទេណាពៅ.
ខ្លះមានថ្ងៃចំនួនណាពៅ
សាមសិបខ្ទង់ពៅមិនខានខ្វះ ។

ខែខ្វះមានថ្ងៃម្ភៃប្រាំបួន ចំនួននោះឯងជាខែខ្វះ
ប៉ុណ្ណោះណាក៏ខែគេដាក់ឈ្មោះ ចំនួនខែខ្វះប្រាំមួយខែ ។
ទីមួយដំបូងគឺមិគសិរ ជាគម្រប់ពីរមាឃមាសា
ផល្គុនគម្រប់បីខែពេញ ពិសាខគម្រប់បួន ។
ទាល់តែខែស្រាពណ៍គ្រប់ជាប្រាំ អស្សុជផងចាំឲ្យថែរក្សា
ប្រាំមួយខែនេះថ្ងៃម្ភៃប្រាំបួន ប្រាំផ្សេងណាផ្ទួនៗជាខែខ្វះ ។
ឯណាខែគ្រប់នោះវិញណា ប្រាំមួយមាសាគឺដូចនេះ
កត្តិកជាមុខគេឯងណាស់ គជាប់ពីនេះគឺខែបុស្ស ។
ផល្គុណវិសាខអាសាឍហ ក៏ខែបន្ទាប់ក្រោយភទ្របទ
ប្រាំមួយខែទៀតគិតលើសលស់ គ្រប់ខែទាំងនោះ ៣០ ថ្ងៃ ។
ឯខែដែលខ្វះនោះឯងគូ កុមារផងត្រូវគុំសង្ស័យ
ខ្វះពាក់នោះបកល់សម័យ ខាងខ្នើតរីស័យគគមានខ្វះ ។
គូខែមួយៗមានបក្សពីរ ខាងកេសរកឲ្យជាក់ច្បាស់
បក្សមួយព្រះចន្ទគឺស្រឡះ ពោលតាមពាក្យចាស់ហៅថាខ្នើតៗ
បក្សមួយព្រះចន្ទចេះស្រូប អាប់ងងឹតស្រមិនឃើញនេត
ខុសគ្នាទីគោលទៅខាងខ្នើត ទើបបានជាកើតហៅរនោច ។
ខាំមួយមានខែដប់ពីរគត់ នៅទីកំណត់មិនខានខុប
ជួនណាលើកខែមួយឡើងជួប ប៉ុណ្ណោះស្រេចស្រោបខែអាសាឍ ។

ថ្នាំនោះមានទៃវផលផងបី
លើសថ្នាំជាប្រើដោយបង់ឃ្លាត

លោកនិយមប្រើសំដប់ជាតិ
សមតាមក្បួនខ្នាតច្បាប់លោក[១] ។

វិធីកាប់ថ្នាំ

# ឧកញ៉ាសុត្តន្តប្រីជា (ឥន្ទ)

វិធីកាប់ថ្នាំចាំឲ្យចប់
ទាំងពីរដណ្ដប់នោះណាទៅ

ថ្នាំដូតកណ្ដុរដោយដើមទៅ
ថ្នាំចូរនាមគោសកកជ ។

ថ្នាំនាលនៈមន្ទ្រាខ្ញុំងឥតមោះ
ថ្នាំដោះខ្យល់សម្ដូចលាជ

ថ្នាំកេងហោងនាមនាគពជ
ម្រាញ់ឯងកាចនាមតួសរីរ ។

មមីបានទីប្រាំពីរតក់
សន្ធកនាមសេះជាសត្វឯក

មមៃតពៃភតទានប៉ូក
ថ្នាំកែអតិរេកខាងមានខ ។

គវែកកប់មកថ្នាំនោ
សញ្ញានាមមានថៃបវ

ថ្នាំចសុនខនាមករណ៍
គឺសុនទៃក្នុដវៃគ្រា ។

ថ្នាំកុនាមផ្ដកលោកបញ្ចប់
ចាំកិច្ចដណ្ដប់ដោយគណិតា

ហៃតួកកុមារទាំងអស់គ្នា
ចូរចាំសព្វហ័ណណាកែងតែយ ។

---

១ បើលើកខែអាសាឍពីរផងប្រើយ៉ាងនេះ៖ គឺបឋមាសាឍៈថ្ងៃ + ៥០ ឆ្នាំ... ។ ទុតិយាសាឍៈ ថ្ងៃ + ៤ ឆ្នាំ... ។

# រដូវទាំង ៣

ក្នុងឆ្នាំមួយៗរដូវថ្មី ណាកុមារីកុមារា
ឯរដូវបីតែងចប់ថា មួយហេមន្តាពេលរងា ។
គ្រាក្ដៅណាស់ហៅថាគិម្ហន្ត លុះក្រៀងជារដូវវស្សានា
រដូវមួយមានខែបួនបក្ខា ទាំងបីដូចគ្នាជាដប់ពីរ ។
មួយពេលកត្តិកធ្លាក់ផល្គុន ត្រជាក់លើសលន់នៅសព្វទី
ពេលនោះហៅឈ្មោះតាមបុរាណ សរទ្ទរដូវត្រជាក់ហេមន្ត ។
រដូវទីពីរដល់ណានោះ សឹងបួនខែសោះគ្នាៗ
មួយពេលផល្គុនដល់ចេត្រា អាសាឍមាសាពេញបូណ៌មី ។
រដូវនោះឯងលោកជាន់មុន ហៅថាគិម្ហន្តព្រោះក្ដៅផង
តពីនោះទៅវិញទៀត ជារដូវចុះវស្សានា ។
បើងមានខែបួនជួនកំណត់ កត្តិកចប់ចុះបុនវស្សា
ត្រឹមថ្ងៃពេញបូណ៌មីអស់ទឹក ជួបជុំគ្នាវិញដរាប ។
ទៅមើលមេឃទៅខំចាំឲ្យចប់ ពាក្យពុំញចប់ចាកសភាព
ទំនងបែបនេះតជាប ពេញជាពាក្យកាព្យល្អប្រាជ្ញមុន ។
លេខថ្ងៃខែឆ្នាំចាំឲ្យស្ទាត់ កុំឲ្យភ្លាំងភ្លាត់ទុកជាធន
ទាំងរដូវបីនៅកុំគន្ធ ត្រូវនឹកឲ្យចាំដដែលអើយ ។

(ចប់)

## លក្ខណៈ, រស, បច្ចុបដ្ឋាន, បទដ្ឋានរបស់មិច្ឆាទិដ្ឋិ

មិច្ឆាទិដ្ឋិនេះ មានអ្វីជាលក្ខណៈ អ្វីជារស (កិច្ច) អ្វីជាបច្ចុបដ្ឋាន (សេចក្ដីប្រាកដឬផល) អ្វីជាបទដ្ឋាន (អាសន្នហេតុឬទីទ្រ)? ។

មិច្ឆាទិដ្ឋិនេះ មានការតាំងចិត្តដោយឥតឧបាយនៃប្រាជ្ញាជាលក្ខណៈ, មានកិច្ចវង្វេងតែការប្រកាន់ស្អិតតាមគំនិតដែលខ្លួនយល់ឃើញខុស ជាកិច្ច, មានការផ្ដល់ចិត្តបំពោះទៅរកខុសជាផល; ធម៌ ៣ យ៉ាងគឺ ភាពជាអ្នកមិនប្រាថ្នាឲ្យជួបប្រទះនឹងអ្នកមានសីលមានធម៌សប្បុរស ១ ភាពជាអ្នកមិនប្រាថ្នានឹងរៀនស្ដាប់ធម៌របស់សប្បុរស ១ ភាពជាអ្នកកំណាញ់ទ្រព្យមិនមានសទ្ធាជ្រះថ្លាក្នុងព្រះរតនត្រ័យ ១ ទាំង ៣ នេះហៅបទដ្ឋានគឺជាអាសន្នហេតុឬទីទ្ររបស់មិច្ឆាទិដ្ឋិ ព្រោះមិច្ឆាទិដ្ឋិនេះកាលបើមានធម៌ទាំង ៣ នេះ ទើបកើតឡើង ឬ តាំងនៅបាន បើមិនមានទេ ក៏តាំងនៅមិនបានដែរ, ប្រៀបដូចក្ដាលការល្អិតទាំងឡាយដែលតាំងនៅបានព្រោះអាស្រ័យផែនដីជាទីទ្រដូច្នោះឯង (១) ។ តែពិត មិច្ឆាទិដ្ឋិរមែងមានធម៌ទាំង ៣ ប្រការ មានភាពជាអ្នកមិនប្រាថ្នាឲ្យជួបនឹងពួកសប្បុរសជាដើមនោះឯងជាកម្លាំង ដើម្បីទប់ទល់ឲ្យវង្វេងហើយនៅជាមិច្ឆាទិដ្ឋិ

១ សេចក្ដីដែលសំដែងមកនេះ ដកយកពីគម្ពីរវិសុទ្ធិមគ្គភាគ ៣ ព្រុងព្រះធម្មគុណទេស ។

ដកចេញទៅ, ដូចសញ្ជ័យបរិព្វាជក, កាលដែលឧបតិស្សនឹងកោលិតបរិព្វាជកជាបរិស័ទខ្លួន ចូលមកបបួលឲ្យចូលទៅគាល់ព្រះសម្ពុទ្ធឯវត្តវេឡុវ័ន, មិនព្រមទៅសោះ ត្រឡប់ជាសួរថា "ក្នុងលោកនេះ មនុស្សល្ងង់និងមនុស្សជាអ្នកប្រាជ្ញណា ច្រើនជាងណា?" បរិព្វាជកទាំង ២ នាក់តបថា "មនុស្សល្ងង់ច្រើន, ឯអ្នកប្រាជ្ញតិចពេកណាស់" សញ្ជ័យបរិព្វាជកពោលថា "បើដូច្នោះខ្ញុំយកទាំងច្រើន, ជនទាំងឡាយល្ងង់ចូរមកក្នុងសំណាក់ខ្ញុំ ជនទាំងឡាយជាអ្នកប្រាជ្ញចូរទៅទៅកាន់ព្រះសម្ពុទ្ធចុះ" ។ មួយទៀតដូចកាលមិគារសេដ្ឋីដែលជាកពុកក្មេកនាងវិសាខា, សូម្បីព្រះសម្ពុទ្ធទ្រង់យាងចូលដល់ក្នុងផ្ទះខ្លួនហើយ ក៏មិនចេញមកអង្គុយជិត ស្តាប់ធម៌របស់ព្រះអង្គដោយចូលចិត្តឡើយ ។ វេលានេះនឹងសំដែងរឿងមិគារសេដ្ឋីនោះ ទុកក្នុងទីនេះដោយសង្ខេប ស្រង់យកចំពោះតែសេចក្តីដែលទាក់ទងនឹងហេតុមិនមែនបរាភវិនា ដើម្បីជាគ្រឿងប្រដាប់ប្រាជ្ញានៃសាធុជន ដូចសេចក្តីតទៅនេះ :

## រឿងមិគារសេដ្ឋី[១]

សេចក្តីដំណាលថា នាងវិសាខាជាធីតារបស់ធនញ្ជ័យសេដ្ឋី និងនាងសុមនទេវីនៅក្នុងក្រុងសាកេត ក្នុងដែនអង្គៈ បានទៅជាភរិយារបស់បុណ្ណវឌ្ឍនកុមារ ដែលជាកូននៃមិគារសេដ្ឋី ក្នុងក្រុងសាវត្ថី ។ មិគារ-

១ រឿងនេះនៅក្នុងរឿងវិសាខាក្នុងគម្ពីរធម្មបទដ្ឋកថាភាគ ៣ ត្រង់បុព្វវត្ថុ ។

សេដ្ឋីបានធ្វើអាពាហមង្គលឲ្យបុណ្ណវឌ្ឍនៈ នឹងនាងវិសាខា កូនក្រុងសាកេតរួចហើយ ក៏នាំនាងវិសាខាមកកាន់ផ្ទះរបស់ខ្លួនឯងក្រុងសាវត្ថី បាននិមន្តពួកអចេលកៈទាំង ៥ រយនាក់មកជប់លៀង ហើយផ្ញើដំណឹងទៅឲ្យនាងវិសាខាថា "ចូរនាងមកថ្វាយបង្គំព្រះអរហន្ត" ។ នាងវិសាខាស្មានថាជាព្រះអរហន្តមែន លុះមកដល់ឃើញសុទ្ធតែជាអ្នកកាក្រាតកាយ ក៏បន្ទោសសេដ្ឋីរួចចូលទៅឯលំនៅរបស់ខ្លួនវិញ ។ ពួកអចេលកៈឃើញដូច្នោះ ក៏បន្ទោសសេដ្ឋីថា "អ្នកឯងស្រីដទៃមិនបានទេឬ? បានជាទៅយកស្រីមហាកាឡកណ្ណីជាសាវិការបស់សមណគោតមមកឲ្យចូលផ្ទះនេះ សូមអ្នកបណ្ដេញវាឲ្យដើរចេញអំពីផ្ទះនេះទៅ" សេដ្ឋីមិនហ៊ានដេញ ក៏ឡប់ជាប្រាប់ទៅវិញថា "លោកម្ចាស់ទាំងអស់ ចូរនៅស្ងៀមសិនចុះ" ។ ក្រោយពីនោះមក សេដ្ឋីកំពុងតែបរិភោគក្រយាហារក្នុងពេលព្រឹក មានព្រះថេរៈ១រូបនិមន្តចូលទៅបិណ្ឌបាត សេដ្ឋីឃើញហើយតែធ្វើជាមិនឃើញ បែរអង្គុយឈ្ងោកបរិភោគតែម្យ៉ាង គួរជាវេលានោះនាងវិសាខាកំពុងតែអង្គុយបក់ឲ្យសេដ្ឋី ទ្រាំអត់នៅស្ងៀមមិនបានទើបទូលព្រះថេរៈថា "សូមលោកម្ចាស់និមន្តទៅប្រោសសត្វឯទៀតចុះ ឪពុកក្មេកខ្ញុំព្រះករុណា លោកពិសាតែអាហារចាស់[១]ទេ" ។ កាលដំណើរនេះពួកនិគ្រន្ថបានញុះសេដ្ឋីឲ្យបណ្ដេញនាងចេញអំពីផ្ទះម្ដងទៀត តែសេដ្ឋីទ្រាំអត់បាន ។ សំដីនាង

---

១ សំដៅដល់កុសលបុណ្យដែលធ្វើទុកពីជាតិមុន ។

វិសាខាដែលស្តីឲ្យឪពុកក្មេកជាន់ទី២លើកនេះ  បណ្តាលឲ្យឪពុកក្មេកទៅប្តឹងប្តល់ដល់កុដុម្ពិកៈទាំង ៨ នាក់[១] ឲ្យជំនុំជំរះ តែដាក់ទោសនាងវិសាខាមិនបានក៏ត្រឡប់ជាសុំខមាទោសនឹងនាងវិញ ព្រមទាំងឲ្យគេបើកឱកាសឲ្យនាងវិសាខានិមន្តព្រះសម្មាសម្ពុទ្ធធ្វើបុណ្យធ្វើទានតាមចិត្ត ។ នាងវិសាខាកាលបានការហើយក៏ប្រើគេឲ្យទៅនិមន្តព្រះទសពលមកគង់វេលាព្រឹកមួយ ។ ចំពោះពួកសមណៈអាក្រាតកាយ លុះពួកជាព្រះសម្ពុទ្ធនិមន្តមកផ្ទះសេដ្ឋី ក៏នាំគ្នាទៅអង្គុយចាំឡោមផ្ទះ ។ នាងវិសាខាចាត់ចែងត្រៀមសក្ការៈតាំងពួនថ្វាយព្រះទសពលរួចហើយ ជូនដំណឹងទៅអាចារ្យឪពុកក្មេកថា "សូមលោកឪពុកអញ្ជើញមកអង្គាសបច្ច័យថ្វាយព្រះសាស្តា" ។ សេដ្ឋីមានប្រាថ្នានឹងមកតាមពាក្យកូនប្រសាដែរ តែពួកអាជីវកហាមឃាត់មិនឲ្យមកទេ ផ្ញើដំណឹងទៅវិញថា "ប្រុសកូនស្រីនាងអង្គាសខ្លួនឯងចុះទៅចុះ" ។ នាងវិសាខាអង្គាសខ្លួនឯង លុះរួចស្រេចកិច្ចហើយ បានឲ្យដំណឹងទៅម្តងទៀតថា "សូមលោកឪពុកអញ្ជើញមកស្តាប់ធម៌" ។ គ្រានោះសេដ្ឋីក៏គិតដើរតាមលំទៅប្រឹងនឹងទៅស្តាប់ធម៌ ពួកអចេលកបានហាមថា "បើអញ្ជើញទៅស្តាប់ក៏អញ្ជើញចុះ ប៉ុន្តែត្រូវអង្គុយខាងក្រៅរនាំង[១] ។ វេលានោះ ព្រះសាស្តាទ្រង់តាំងផ្តើមអនុបុព្វីកថា សំដែងធម៌ឲ្យជួបជា

---

១ កាលធនញ្ជយសេដ្ឋីបញ្ជូនកូនស្រីទៅនៅផ្ទះប្តី បានផ្ញើកុដុម្ពិកៈ ៨ នេះ ជំនុំការទោសត្រីកូនស្រីជំនួសខ្លួន ។

គេបាចអង្ករនិងដើមព្រិចផង ទ្រព្យដូចជាមហាមេឃបង្អុរចុះទូរគៀងនិគមជន-ពមិជន ។ កាលព្រះសាស្ដាគង់ក្នុងសំណែងធម៌ព្រើឲ្យមានដំណើរនៅឡើង នៅខាងមុខមិនដាច់ មិគារសេដ្ឋីក៏ណោលនៃដំណល់សិបក្នុងសោតាបត្តិផល ដ៏ប្រដាប់ដោយន័យ ១ ពាន់ ជាអ្នកលែងសង្ស័យក្នុងព្រះត្រៃរតន៍ ទើបបើកជាយភ្ជិនខនមកបៅដោះនាងវិសាខា ហើយទុកនាងជាមាតា ។ តាំងដើមអំពីថ្ងៃនោះមក គេហៅនាងវិសាខាថា មិគារមាតា ។ មិគារសេដ្ឋីលុះលែងបៅដោះនាងវិសាខាហើយ ទៅក្រាបទៀបព្រះបាទាព្រះសម្ពុទ្ធ ហើយចាប់ព្រះបាទាដោយដៃផង ផ្ទាល់ព្រះបាទាដោយមាត់ផង រួចប្រកាសឈ្មោះខ្លួនថ្វាយព្រះទសពលថា "ខ្ញុំព្រះអង្គឈ្មោះមិគារសេដ្ឋី" ក៏ក្រាបទូលថា "ព្រះអង្គ! ខ្ញុំព្រះអង្គមិនដឹងថាធ្វើទានក្នុងក្រុមព្រះអង្គបានផលច្រើនប៉ុណ្ណេះទេ, ទើបតែវេលានេះបានដឹង ព្រោះតែស្រីយកូនប្រសាស្រី, ខ្ញុំជាបុគ្គលរួចចាកអបាយទុក្ខទាំងពួងហើយ, កូនប្រសាស្រីដែលមកកាន់ផ្ទះខ្ញុំនេះ ឈ្មោះថាយកទាំងសេចក្ដីចំរើន យកទាំងប្រយោជន៍ យកទាំងសេចក្ដីសុខមកឲ្យខ្ញុំផង ។

សោហំ អជ្ជ បជានាមិ យត្ថ ទិន្នំ មហប្ផលំ
អត្ថាយ វត មេ ភទ្ទា សុណិសា ឃរមាគតា

ទេយ្យទានដែលគេថ្វាយក្នុងសាសនាឯណា ជាទានមានផលច្រើន,

ខ្ញុំព្រះអង្គទើបនឹងដឹងច្បាស់នូវសាសនានោះក្នុងថ្ងៃនេះ, ក្នុងប្រការស្រី-នខ្ញុំជាស្រីពុទ្ធមាមិកា មកកាន់ផ្ទះខ្ញុំដើម្បីសេចក្ដីចំរើនដល់ខ្ញុំព្រះអង្គ ។

## លើករឿងធៀបនឹងធម៌

រឿងដែលដំណាលមកនេះ សាស្ដាជនគប្បីប្រាប់ថា ត្រង់មិគារ-សេដ្ឋីឃាត់នាងវិសាខាមិនឲ្យនិមន្តព្រះសម្មាសម្ពុទ្ធ ពួកអចេលកៈញុះសេដ្ឋីឲ្យបណ្ដេញនាងវិសាខាអំពីផ្ទះចេញក្ដី នេះត្រូវត្រង់បទដ្ឋានទី ១ គឺការពារអ្នកមិនបានជួបនឹងពួកសប្បុរស, ត្រង់ពួកអចេលកៈឃាត់មិនឲ្យសេដ្ឋីស្ដាប់ធម៌ នេះត្រូវត្រង់បទដ្ឋានទី ២ គឺការពារអ្នកមិនបានស្ដាប់ធម៌ពួកសប្បុរស, ត្រង់សេដ្ឋីមិនបានយកបាយទៅដាក់បាត្រព្រះថេរៈ ១ រូប ដែលនិមន្តចូលមកបិណ្ឌបាត នេះត្រូវត្រង់បទដ្ឋានទី ៣ គឺការពារអ្នកកំណាញ់ទ្រព្យមិនមានសទ្ធាក្នុងព្រះរតនត្រ័យ ។

## កំណើតមិច្ឆាទិដ្ឋិ

មិច្ឆាទិដ្ឋិ កើតឡើងដោយហេតុប៉ុន្មានយ៉ាង? គឺអ្វីខ្លះ? ។ មិច្ឆាទិដ្ឋិកើតឡើងដោយហេតុ ៦[១] យ៉ាង គឺ:

---

១ ស្រង់ពីគម្ពីរ អង្គុត្តរ, អ.ឧនិ.ទុកនិបាត ទ្វេមេ ភិក្ខវេ បច្ចយា មិច្ឆាទិដ្ឋិយា ឧប្បាទាយ "ម្នាលភិក្ខុទាំងឡាយបច្ច័យ ២ ប្រការនេះឯងទើបមិច្ឆាទិដ្ឋិកើតឡើងបាន" ។

១- បរតោ ឃោសោ ស្តាប់អសទ្ធម្មកថាអំពីបុគ្គលដទៃ

២- អយោនិសោមនសិការោ មិនធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា

## អធិប្បាយ

១- ស្តាប់អសទ្ធម្មកថា អំពីបុគ្គលដទៃ, ពាក្យថា អសទ្ធម្មកថា ប្រែថា "កថាជាអសទ្ធម្ម គឺពាក្យមិនមែនធម៌ជារបស់ពួកសប្បុរស, ពាក្យថា "បុគ្គលដទៃ" ក្នុងទីនេះ សំដៅយកពួកមនុស្សអសប្បុរស ដែលជាអ្នកនិយាយអសទ្ធម្មកថា ។ មែនពិត មនុស្សអសប្បុរសរមែងមិននិយាយធម៌ជាថដែលមានខ្លឹមសារដល់ខ្លួននិងបុគ្គលដទៃទេ និយាយតែពាក្យដែលនាំឲ្យខូចប្រយោជន៍ក្នុងលោកនេះ និងលោកខាងមុខ គឺ តែងនិយាយដឹកនាំពួកជនមិនឲ្យជឿកម្មនិងផលរបស់កម្ម, មិនឲ្យជឿហេតុដែលគួរជឿ, មិនឲ្យខ្លាចបាបមិនឲ្យខ្ពើមអំពើទុច្ចរិត, មិនឲ្យតក់ស្លុតខ្លាចបាប មិនឲ្យរអាចិត្តចំពោះអំពើទុច្ចរិត, មិនឲ្យខំសង្វាត់រៀនសូត្រ, មិនឲ្យមានសេចក្តីព្យាយាមក្នុងកុសលធម៌, មិនឲ្យមានស្មារតីសេចក្តីរឭកត្រូវ មិនឲ្យមានប្រាជ្ញាការពិនិត្យក្នុងកិច្ចលោកធម៌ និយាយដឹកនាំពួកជនឲ្យមានតែមានសេចក្តីប្រាជ្ញាខ្សោយ, មិនឲ្យមានសន្តោសតាមមានតាមបាន, មិនឲ្យស្ងាត់កាយស្ងាត់ចិត្ត, មិនឲ្យរក្សាសីល ជាដើម ។ (តទៅ)

## ៩ វត្តបរិយាយ

ព្រះគ្រូមហាបទុម ឆាយ · ស៊ិន ក្រុមជំនុំព្រះត្រៃបិដក

រៀបរៀង

### នមត្ថុ សុគតស្ស

មាតាបេត្តិភរំ ជន្តុំ កុលេជេដ្ឋាបចាយិនំ
សណ្ហំ សខិលសម្ភាសំ បេសុណេយ្យប្បហាយិនំ
មច្ឆេរវិនយេ យុត្តំ សច្ចំ កោធាភិភុំ នរំ
តំ វេ ទេវា តាវតឹសា អាហុ សប្បុរិសោ ឥតិ ៗ

សម្តេចព្រះភគវាព្រះអង្គជាសាស្តាឯកនៃសត្វលោក ទ្រង់ប្រកបដោយមហាករុណាចំពោះពួកវេនេយ្យសត្វ មានប្រាថ្នានឹងចម្លងប្រជានិករឲ្យបានដល់ត្រើយពោលគឺសេចក្តីសុខសម្រាន្ត តាមគួរដល់ឋានឧបនិស្ស័យដែលនឹងឧប្បត្តិប្រព្រឹត្តទៅ ដោយទេសនាបរិយាយមានប្រការជាអនេក ។ ការទេសនាប្រដៅវេនេយ្យសត្វជាកិច្ចវត្តដែលព្រះអង្គបានបំពេញគ្រប់៤៥ ព្រះវស្សា តាំងអំពីកាលត្រាស់ដឹងបរមាភិសេកសម្មាសម្ពោធិញ្ញាណហូតមកដល់អវសានកាលនៃបរិនិព្វានសម័យ ទ្រង់មានព្រះហឫទ័យធំពេញព្រៀបដោយមហាករុណា ដែលជាហេតុមិនឲ្យព្រះអង្គធុញទ្រាន់ ក្នុងការខ្នះខ្នែងប្រដៅពួកសត្វដែលកិលេសរួបរឹតឲ្យល្ងៀងវិលវល់ទៅតាមគម្ពីរមូលធម៌ដែលព្រះអង្គសំដែងចុះមកនោះមាន

១- បរតោ ឃោសោ ស្តាប់អសទ្ធម្មកថាអំពីបុគ្គលដទៃ

២- អយោនិសោមនសិការោ មិនធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា

## អធិប្បាយ

១- ស្តាប់អសទ្ធម្មកថាអំពីបុគ្គលដទៃ, ពាក្យថា អសទ្ធម្មកថា ប្រែថា "កថាជាអសទ្ធម្ម គឺពាក្យមិនមែនធម្មកថារបស់ពួកសប្បុរស. ពាក្យថា "បុគ្គលដទៃ" ក្នុងទីនេះ សំដៅយកពួកមនុស្សអសប្បុរស ដែលជាអ្នកនិយាយអសទ្ធម្មកថា ។ មែនពិត មនុស្សអសប្បុរសរមែងមិននិយាយធម្មកថាដែលមានខ្លឹមសារដល់ខ្លួននិងបុគ្គលដទៃទេ និយាយតែពាក្យដែលនាំឲ្យខូចប្រយោជន៍ក្នុងលោកនេះ និងលោកខាងមុខ គឺតែងនិយាយដឹកនាំពួកជនមិនឲ្យជឿកម្មនិងផលរបស់កម្ម, មិនឲ្យជឿហេតុដែលគួរជឿ, មិនឲ្យខ្លាចបាបមិនឲ្យខ្មាសអំពើទុច្ចរិត, មិនឲ្យតក់ស្លុតខ្លាចបាប មិនឲ្យអាចិត្តចំពោះអំពើទុច្ចរិត, មិនឲ្យខំរៀនសូត្រ, មិនឲ្យមានសេចក្តីព្យាយាមក្នុងកុសលធម៌, មិនឲ្យមានស្មារតីសេចក្តីរឭកត្រូវ មិនឲ្យមានប្រាជ្ញាការពិសោធក្នុងផ្លូវលោកផ្លូវធម៌ និយាយដឹកនាំពួកជនឲ្យគ្រាន់តែមានសេចក្តីប្រាថ្នាច្រើន, មិនឲ្យមានសន្តោសតាមមានតាមបាន, មិនឲ្យស្ងាត់កាយស្ងាត់ចិត្ត, មិនឲ្យរក្សាសីល ជាដើម ។ (តទៅ)

# សេចក្ដីបរិយាយ

ព្រះគ្រូមហាបញ្ញា មាឃ · ស៊ិន ក្រុមជំនុំព្រះត្រៃបិដក

រៀបរៀង

## ឯមគ្គ សុគតស្ស

មាតាបេត្តិភរំ ជន្តុំ  កុលេជេដ្ឋាបចាយិនំ

សណ្ហំ សខិលសម្ភាសំ  បេសុណេយ្យប្បហាយិនំ

មច្ឆេរវិនយេ យុត្តំ  សច្ចំ កោធាភិភុំ នរំ

តំ វេ ទេវា តាវតឹសា  អាហុ សប្បុរិសោ ឥតិ ។

សម្ដេចព្រះភគវាព្រះអង្គជាសាស្ដាឯកនៃសត្វលោក ទ្រង់ប្រកបដោយមហាករុណាចំពោះពួកវេនេយ្យសត្វ មានព្រះប្រាថ្នានឹងចម្លងប្រជានិករឲ្យបានដល់ត្រើយពោលគឺសេចក្ដីសុខសម្រាន្ត តាមគួរដល់ឋានៈឧបនិស្ស័យដែលនឹងនាំប្រព្រឹត្តទៅ ដោយទេសនាបរិយាយមានប្រការជាអនេក ៗ ការទេសនាប្រដៅវេនេយ្យសត្វជាកិច្ចកំដែលព្រះអង្គបានបំពេញគ្រប់៤៥ ព្រះវស្សា តាំងអំពីកាលត្រាស់ដឹងបរមាភិសម្ពោធិញ្ញាណហូតមកដល់អវសានកាលនៃបរិនិព្វានសម័យ ទ្រង់មានព្រះហឫទ័យឥតពេញទៀបដោយមហាករុណា ដែលជាហេតុមិនឲ្យព្រះអង្គធុញទ្រាន់ ក្នុងការទូន្មានប្រៀនប្រដៅពួកសត្វដែលកិលេសរួបរឹតមន្ទិលចិត្តនៅតែលំទៅតាមកម្មៈ មូលធម៌ដែលព្រះអង្គសំដែងពុកមកនោះមាន

ខំយកចិត្តទុកដាក់ប្រព្រឹត្តទៅតាមការប្ដេជ្ញារបស់ខ្លួន ទាំងកាលសម័យ ព្រះបរមទេសនាដែលព្រះអង្គទ្រង់សំដែងហើយអ្នកមានប្រាជ្ញានឹងឃើញបានថាជាស្វាក្ខាតធម៌និងជានិយ្យានិកធម៌ពិត ។ អ្នកដែលបានស្ដាប់ហើយក៏រមែងអនុវត្តទៅតាមហេតុ ដែលនាំមកនូវប្រយោជន៍ដ៏ទូលាយគោលគឺប្រយោជន៍បច្ចុប្បន្ន, ប្រយោជន៍ក្នុងបរលោកនិងប្រយោជន៍យ៉ាងឧត្ដម គឺព្រះនិព្វានដែលជាឯកន្តបរមសុខ; ក្នុងទីនេះ ខ្ញុំសូមលើកយកបរិយាយអនុសាសនីពាក្យប្រដៅនៃព្រះបរមសាស្ដាចារ្យ ដែលមាននាមថា ឥន្ទវត្ត [1] ដើម្បីជាប្រយោជន៍ដល់ពុទ្ធមាមកបុគ្គលទាំងឡាយ ក្នុងការញុំាងធម្មប្រតិបត្តិដែលនៅមិនទាន់កើតឲ្យកើតឡើងបាន និងញុំាងធម្មប្រតិបត្តិដែលកើតមានហើយឲ្យរឹងរឹតតែបរិបូណ៌ចំរើនកើនឡើងទៀត; ឥន្ទវត្តនោះមាន ៧ ប្រការ នឹងប្រែជាបទភាសាដែលរៀបរៀងជាគោលទុកសង្ខេបដោយលំដាប់ដូចតទៅនេះ :

## ១ — មាតាបេត្តិភរណៈ [2]

" ការចិញ្ចឹមមាតាបិតា ,,

សូមរៀបរាប់អំពីពាក្យថាមាតាបិតាជាមុនសិន: ស្រីអ្នកញុំាងបុត្រឲ្យកើតឈ្មោះថា ជននី, បុរសអ្នកញុំាងបុត្រឲ្យកើតឈ្មោះថា ជនកៈ;

---

១ ក្នុងច្បាប់ខ្លះលោកឲ្យឈ្មោះថា វត្តបទ ក៏មាន ។ ២ ក្នុងគាថាដែលលើកពោលទុកខាងដើម លោកសំដែងតាមបុគ្គលាធិដ្ឋាន, ប៉ុន្តែខ្ញុំខំដាក់សម្រួលទៅជាធម្មាធិដ្ឋានវិញគ្រប់មាតិកាតទៅ ដើម្បីស្រួលការអធិប្បាយ ។

ជមងឺខ្ទិចផងក: ទាំងពីរនេះហៅថាមាតាបិតា ជាអ្នកទ្រទ្រង់គុណដ៏ធំ
កូនចៅបុត្តធីតា: ព្រោះជនដែលបានអត្តភាពមកកើតក្នុងលោក ឈ្មោះថាមាន
មាតាបិតាជាដើមកើត ជាឧបការ: ជាអ្នកឲ្យកំណើតគឺជីវិត, រីឯង
បរិភោគលោហិតនៃមាតាតាំងតែអំពីកាលចុះចាប់បដិសន្ធិ តាំងអំពីអាយុ:
ដែលចំរើនឡើងក៏ត្រូវអាស្រ័យបាច់ឈាមនៃមាតា ហូតដល់វេលា
ដែលប្រសូតចេញចាកគភ៌: ការ:ដែលមាតាត្រូវបំរុងថ្នាក់ថ្នមដោយពារ
ជាលូរនោះ គឺមាតាបន្ទុំចេញនូវលោហិតដ៏សជាជាអាហារបរិភោគទាំង
យប់ទាំងថ្ងៃពុំមានស្រាកស្រាន្ត, តែងទំរំថែទាំព្យាបាលគ្រប់គ្រងយាមយប់
ទាំង ៤ ឲ្យបានប្រព្រឹត្តទៅស្រួលដោយសេចក្តីសុខក្សេមក្សាន្ត, ជពប
ទាល់តែបុត្តធីតានោះមានវ័យចំរើនធំឡើង ជួនកាលកាត់ទុកចំរុងជាខិព្ច
ការដែលមាតាទទួលភារ:ដ៏ធ្ងន់យ៉ាងនេះ ក៏ព្រោះមេត្តាចិត្តរបស់លោក
ប្រកបដោយសេចក្តីស្រឡាញ់ មិនអាចនឹងកាត់ចិត្តឲ្យដាច់ស្រឡះ ឬ
នឹងលះបង់បាន ។ ចំណែកបិតាសោត កាលមាតាធ្វើសេចក្តីបរិហារ
អស់កាលយូរថ្ងៃដូច្នេះហើយ ក៏ត្រូវតាំងចិត្តទទួលភារ:ដ៏ធ្ងន់ដូចគ្នា គឺត្រូវ
ស្វែងរកគ្រឿងបរិភោគ និងទ្រព្យសម្បត្តិមកដាក់គ្រឿងចាក់បែង ដើម្បី
ឧបត្ថម្ភបំរុងដល់មាតានឹងបុត្តធីតាឲ្យបានទទួលសេចក្តីសុខ, យកចិត្តឈើ
ដាក់រក្សាកិច្ចការផ្សេងៗ ។ រាំងសេចក្តីពប់បាចអន្តរាយទាំងពានក្នុងឯង
ខាងក្រៅមិនឲ្យមានការសអន្តរាយស្រ័យ ដើម្បីនឹងបាននូវកិច្ចបរិហារបុត្ត

ធីតាដោយល្អ តាំងនេះក៏ព្រោះសេចក្ដីស្រឡាញ់បុត្តធីតាជាចំណែកធំផុត គ្នា ហេតុនេះមាតាបិតាទើបឈ្មោះថាជាអ្នកមានឧបការៈធំ ទាំងកេរ្តិ៍ឯណាមកប្រៀបផ្ទឹមពុំបាន ព្រោះត្រូវថែរក្សាបកបីតាំងតែពីកាលនៅក្នុងគភ៌រហូតប្រសូតចេញមកក៏គង់នៅតែបំរុងរក្សាទៀតដរាបដល់តែបុត្តធី-តាបានចម្រើនវ័យធំ ដោយឥស្សរភាពក្នុងផ្ទះសម្បែងផ្សេង ៗ ក៏ខ្វល់ខ្វាយកំឡាំងទ្រព្យនឹងកំឡាំងចិត្តរបស់ខ្លួន នៅរៀបចំទុកបំរុងបានគ្រប់គ្រាន់ណាក៏ចេះតែជួយគាំទ្របុត្តធីតាឲ្យទៅបានផុតត្រឹមណោះ ៗ បើពោលចំពោះគុណធម៌ដែលជាចំណែកនាទីរបស់មាតាបិតាគប្បីទុកបំរុងដល់បុត្តធីតានោះ លោកពោលទុកដោយសង្ខេបត្រឹម ៥ ស្ថានគឺ ១- បាបា និវារេន្តិ រមែងហាមឃាត់មិនឲ្យធ្វើសេចក្ដីអាក្រក់ ឯបុត្តធីតាដែលល្អរមែងមិនធ្វើឲ្យមាតាបិតាលំបាកចិត្តព្រោះខ្លួន គឺរក្សាខ្លួននៅក្នុងឱវាទរបស់មាតាបិតា ២- កល្យាណេ និវេសេន្តិ រមែងញុំាងបុត្តធីតាឲ្យតាំងនៅក្នុងកម្មដែលបណ្ឌិតជនគប្បីកាន់ពោលគឺអំពើឯណាដែលប្រព្រឹត្តទៅ ដើម្បីសេចក្ដីល្អប្រពៃ ដែលនឹងនាំមកនូវសេចក្ដីសុខចំរើនព្រមទាំងប្រយោជន៍ដល់បុត្តធីតានិងវង្សត្រកូល, រមែងដឹកនាំប្រៀនប្រដៅបុត្តធីតាក្នុងអំពើដ៏ប្រពៃ ដែលជាផ្លូវនាំឲ្យបុត្តធីតាបាននៅជាអ្នកមានអធ្យាស្រ័យសុចរិតល្អ ជាសិរីនៃត្រកូល គឺកេរ្តិ៍ឈ្មោះពោះស្រុះស្រួលជាទីគាប់ចិត្តរបស់អ្នកដទៃ; ៣- សិប្បំ សិក្ខាបេន្តិ រមែងញុំាងបុត្តធីតាឲ្យសិក្សាសិល្បវិជ្ជា

បុត្តធីតាពេញវ័យសម្បូរនឹងស្វែងរកសេចក្តីចេះដឹងហើយ  មាតាបិតា បង្ហាត់បុត្តធីតាឲ្យស្រូតរៀនសិក្សាដោយខ្លួនឯង  ឬដោយការនាំចូលទៅកាន់សាលារៀន  ហើយផ្គត់ផ្គង់នូវគ្រូអាចារ្យដែលមានសេចក្តីចេះដឹង ដើម្បីឲ្យបង្ហាត់បុត្តធីតា ឲ្យបានទៅជាអ្នកឆ្លាតក្នុងវិទ្យាសាស្ត្រទាំងឡាយ  ដែលជាផ្លូវដើម្បីបុត្តធីតាឲ្យចិញ្ចឹមជីវិតបានដោយងាយក្នុងអនាគតកាល ៦ – បដិរូបេន ទារេន សំយោជេន្តិ រមែងប្រកបផ្សំផ្គុំបុត្តធីតាដោយភរិយា ស្វាមីដ៏សមគួរ  បុត្តធីតាពេញវ័យមានអាយុសមគួរល្មមឲ្យមានភរិយា ស្វាមីគ្រប់ខ្លួនជាស្រេចបានហើយ  ទើបជានាទីរបស់មាតាបិតាដែលនឹងបង្ហាត់បុត្តធីតារបស់ខ្លួន  ដោយការស្វែងរកភរិយា ស្វាមីជាមុខការៈដ៏សំខាន់  ចំណែកមួយសម្រាប់អ្នកនៅគ្រប់គ្រងផ្ទះ-ផ្ទះ  កិច្ចនេះជាភារៈរបស់មាតាបិតាអ្នកប្រាថ្នាសេចក្តីល្អ  រមែងតាក់តែងឲ្យតាមសមគួរដល់វ័យ,  សេចក្តីចេះដឹង, សេចក្តីអង់អាច,  សេចក្តីប្រព្រឹត្តល្អទីនាំមកនូវស្វែងរកគ្រឿងចិញ្ចឹមជីវិត ,  ដែលល្មមនឹងចិញ្ចឹមគ្នាបាន  ហើយអាចនឹងតាំងខ្លួនឲ្យរីងប៉ុងបានតទៅ: ៥– សមយេ ទាយជ្ជំ និយ្យាតេន្តិ រមែងប្រគល់ទ្រព្យមតិកឲ្យបុត្តធីតាក្នុងសម័យដ៏គួរនិវ្វរៈយកយោគមត្តា ខ្សឹងក្នុងកាលដែលបុត្តធីតាមានភរិយា ស្វាមីគ្រប់គ្រងគេហដ្ឋានដោយខ្លួនឯងហើយ  សម្រាប់ជាដើមទុនក្នុងការស្វែងរកផលប្រយោជន៍ចិញ្ចឹមជីវិតតទៅ ៗ  (ងំ១៣)

# ពាក្យសួររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរនៅក្រសួងពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ត្រូវការអ្នកបេះភ្លេងបារមី ( ព្រះបារមី ) និងទំនុកច្រៀងភ្លេងនេះដែលជាភ្លេងប្រគំក្នុងពិធីឡើងអ្នកតាស្ដេច ព្រមទាំងភ្លេងឯទៀតនិងទំនុកច្រៀងដែលសម្រាប់ប្រគំក្នុងពេលឡើងអ្នកតាទូទៅ ។

បើអស់លោក - អ្នកមើលសៀវភៅកម្ពុជសុរិយា ស្គាល់អ្នកណាបេះភ្លេងទាំងនេះយ៉ាងស្ទាត់ សូមបង្ហាញឈ្មោះនិងទីលំនៅអ្នកនោះដល់ក្រុមជំនុំ ឬក៏ឲ្យអ្នកនោះចូលទៅជួបនឹងក្រុមជំនុំ, កាលបើបញ្ជាក់ឃើញថាបានការពេញចិត្តក្រុមជំនុំហើយ, ក្រុមជំនុំនឹងជូនរង្វាន់ពុំខាន ។

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយជំណឿងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកជំណឿងសាសនាៈ ព្រះគ្រូសុវណ្ណញាណ សូរ-ហាយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកអក្សរសាស្ត្រ* ទំព័រ

លោក ហេង-ឃ៉ាន់ កំពូលស្នេហា (តមក) . . . . . . . . . . ១១៣

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម ឯកបហស្សរាត្រី ភាគទី១០ (តមក) . . . . . ១២៩

ឃុន សុន្ទរមេធី ញ៉ូង-សៀង មិត្រសំឡាញ់ខ្ញុំបាក់ភ្លា . . . . . . . . . . ១៥២

*ផ្នែកសាសនា*

ឃុនសុវត្ថិវេទី យូរ-អ៊ុន មិច្ឆាទិដ្ឋិកថា (តមក) . . . . . . . . . . ១៥៥

ព្រះមហាបទុម មាឃ-ស៊ុន ផ្លូវវត្តបរិយាយ (តមក) . . . . . . . . . . ១៦៥

ឆ្នាំទី ១៨ — លេខ ៣ ខែម៉ារ្ស ១៩៤៦ — ជំនៀងជាវៈ ១ ឆ្នាំ ៣៥ រៀល ។
1946

# កំពូលស្នេហា

## លោកហេង-យ៉ាន់ រៀបរៀង

(តមក)

លោកគ្រូមិនបានជាស្ដាប់ ព្រោះតែនឹកដួងស័ព្ទយំគ្រប់ផ្កា ឃើញ អាហារកំពុងតែហុយនៅ ក៏យល់សេចក្ដីខុសឆ្ងាយថា "បាទ! កុំព្រួយ លោកអញ្ជើញពិសាចុះ" ។

អាហារទឹកកកនិងសោបឈ្ងុយទាំងនេះ ក្រហាមមុខដល់ហៀរទឹកភ្នែក ណុជនេត្រនារីអត់មិនបានក៏ងាកមក ម៉ោមុខលោកគ្រូហើយនាងក៏ ញញឹម លោកគ្រូជាសេចក្ដីខុសក៏តបទៅថា "អូក! មិនពិសាតែទេ ម្ហូប? តែជាគេសង្ឃឹមហើយនឹងទ្រាំស្រោចស្រពធ្វើដែរ" ។

"ចា៎ះ កុំព្រួយទីនខ្ញុំអីចា៎ះ ទុកជាយ៉ាងណាក៏ខ្ញុំមិនប្រឡូងនឹងពេលយ៉ាងណូតដែរ .មិនលើកយកឲ្យព្រួយហួសប្រមាណ" ហើយនាងក៏សើចព្រម ទាំងអាចារ្យរបស់នាង ។

លោកគ្រូមិនដឹងជានាងនិយាយចំអកឲ្យ ក៏សើចជាមួយនឹងនាងដែរ រួចលើកតែងតែទៀតដក់ៗ ចុះទៅ ដល់ឃើញណុជនេត្រនារីមើលខ្លួន ដោយយកចិត្តទុកដាក់ ក៏ភ្ញាក់ខ្លួនភ្លេចគិតថាទឹកក្ដៅ លើកតែងទៀត ហុត ដល់លោកអណ្ដាតក៏ភ្ញាក់ខ្លួនព្រឺតនិងខ្លាក់ចេញមកខាងក្រៅ ម្ល៉ោះ ហើយទំរេចទាំងក្ដៅទៅ ធ្វើមុខក្រញូវត្រូវបញ្ចប់ពេញឱនចូលគ្នា យក

ដៃកែងស៊ីមទ្រង់ នាំឲ្យអ្នកតាំងពីនោះសើចការនៃគេទាំងឡាយ សោកក្រៃ ខឹងនៀនខ្លួន ស្ទើរនឹងផ្ដេកព្រះអង្គឲ្យឃ្លាតខ្លួនទៅ តែមិនដឹងធ្វើ ដូចម្ដេច ទើបតែធ្វើជាសួរអាហារថា "អាហារបានរៀបកុំសប្បាយសើច កើម្ទេះ ប្រាប់ខ្ញុំឲ្យបានដឹងត្រាន់នឹងសើចផង" ។

"ចាះ" ណាក់ផេទ្រនាភៃឆ្លើយដួសឡើង "យើងសើចពីសត្វជីងចក់ មួយនោះ វាឃើញចំណីល្អខាំដេញចាក លុះជិតដល់ហើយក៏ស្ទុះទៅ ក្រញាំកត្រាំប្រណី ខុសឯចំណីភ្លាត់ឯចំណាប់ក្រឡាប់ក្បាលដល់ដី តែម្ដង គួរឲ្យចង់សើចមែនទេហ៎! គោគក៏គោគម្ទេះ! គាណិតគ្នាពេក ស្ទើរនឹងលួមឋើមទៅហើយ" ។

"ដឹកចប្រែសាសនអ្នក ការត្រង់នេះមិនគួរឲ្យចង់សើចទេ ខ្ញុំបាទ មើលឃើញថា ល្បុតដែលអ្នកអាទប្រែសាសន៍អម្បាញ់មិញនេះ ជា ល្បុកនៃលោកធម្មតាដែលតែងលេងគ្រប់ទិសគ្រប់តំបន់ក្នុងលោកនេះ មិន ចំពោះលើរូបណាសាសន៍ណាភាសាណាឡើយ និងឡើងគួរឲ្យសង្វេគ ណាស់ពេក សត្វជីងចក់កាលបើបានប្រទះចំណីហើយ តែងទំរៃពាគាម មើលដល់ខ្លួនខ្លួន តែងគិតទឹកនាផល់រឿងទាំងពួង ចិត្តប្រាថ្នាតែលើ ចំណីនោះប៉ុណ្ណោះ ខុសជាផេកដើរឈរអង្គុយក្ដី ក៏ឃើញតែរូបចំណី នោះជាប់និងភ្នែក តាំងចិត្តប្រាថ្នាតែឲ្យបានមកជិតខ្លួន តែចំណីនោះ វាកោតគេមុខធ្វើព្រងើយ បែរជាចំអកឲ្យកឡៀយឆ្លើនឲ្យគ្នាគេគក្ខុក

គួរតែអាណិតដល់គ្នាដែលកំសត់អត់ឃ្លាន តើអ្នកយល់ឃើញដូចម្ដេច ? ខ្ញុំសង្កេតឃើញថា អ្នកមានអធ្យាស្រ័យទន់ភ្លន់ មានចិត្តអាសូរករុណាដល់ទុក្ខនៃកៀនមនុស្សផងគ្នា បើជាគិតដូច្នោះមែន សុំអ្នកមេត្តាគំនិតយោបល់យល់ដូចខ្ញុំដែរមែនទេអ្នក ? ។

ណុជនេត្រនារីត្រូវសួរចំពោះខ្លួនដូច្នោះ ក៏ឡើងមុខក្រហមព្រឿងៗ អាក់មុខបញ្ចេញពាក្យមិនឆ្លើយ មិនបានគិតឡើយថាមនុស្សប្រែបសោកក្រយល់សេចក្ដីជ្រាលជ្រៅយ៉ាងនេះ ចេះលេងសំដីលៃបងាយដល់ម្ល៉េះ តែកបង់ចិត្តទាំងគេហ៊ាននិយាយបែបនោះផង ព្រោះទើបនឹងប្រសព្វនឹងម្ដងក៏ប្រាជ្ញប្រាជ្ញាឱ្យនាងយ៉ាងហ្នឹង ផញ្ញឹងគិតមួយប្រែកតៅឃើញត្រូវតាមពាក្យគេនិយាយមែន ទើបនាងខ្ទឹបមាត់ដោយសេចក្ដីអៀន ព្រោះបានជាសើចជ្រុលទៅហើយ ដូចជាមិនអាណិតដល់គ្នាសោះ ដែលទំព្រឹត្តមកលេងមិនមានលោះថ្ងៃណា សេចក្ដីប្រាជ្ញារបស់សោកក្រក៏ប្រពៃប្រពិលដល់ចិត្តនាង ទាំងនាំឱ្យស្ងៀមនៅគួរពេបពុំដឹងដោយហេតុអ្វី គំនិតថយ៉ាងជំរែក្រុងខួរក្បាលរបស់នាង ទើបបណ្ដាលឱ្យនាងញញឹមកេតីយ៉ាងណុក ដោយមិនច្បាស់ជាមានចិត្តបែបណា ព្រមទាំងអង្គុយខ្ពង់ខ្ពស់ក្នុងយ៉ាងរវើរវាយ ដល់សោកក្រសួរសាឡើងទៀតថា “អត់ទោសអ្នក អ្នកមិនឆ្លើយបញ្ហារបស់ខ្ញុំផងទេឬ? បានជា

ខ្ញុំកាត់ចិត្តហ៊ានសួរ ព្រោះសង្ឃឹមថាអ្នកនឹងតបមកគេវិញ តើអ្នកនឹងទុកឲ្យខ្ញុំមានសេចក្ដីស្ដាយក្រោយត្រឡប់លើទៅផ្ទះវិញឬ?

នាងក៏ភ្ញាក់ព្រើតឆ្លើយយ៉ាងរហ័សថា "ចា៎ះខ្ញុំ . . ." ផល់ត្រឹមនេះ ក៏ងាកបែរមើលមុខអាចារ្យ ជាការអង្វរឲ្យជួយពៃនាងផង ។

អាចារ្យក៏បញ្ចប់សេចក្ដីឲ្យថា "លោកគ្រូឯងនៅឈ្លបសួរដល់ណាទៅទៀត ឆមតាដីនិងចក់មិនដែលនៅស្ងៀមឲ្យចំណើរតែចូលខាត់ឯងៗទេ បើគេស្រុបនោះគឺគេពេញចិត្តណាដីនិងចកគត់លាន មែនទេ?" ។

ណ្ដុំនេះត្រឹមកន្សែងលាអាចារ្យត់ទៅផ្ទះ ដំណើរនាងល្អសល្វន់ ទន់ភ្លន់ទាំងដៃជើងគួរជាទីទស្សនា នាងចុះទៅហើយលោកគ្រូនៅតែតាមមើលនាងទៀត ប៉ុន្តែត្រចៀកស្ដាប់សំឡូស្បែកជើងក្រូស ៗ បន្សូសដីទៅឆ្ងាយ ។

ស្ដាយអើយសែនស្ដាយ! មិនគួរនិយាយឲ្យនាងតែសោះ! ។

## វគ្គទី ៤

## ហៅសែនរំខាន

ព្រះបន្ទូលពេញបូណ៌មី បញ្ចេញរស្មីព្រានព្រាតលើធម្មជាតិស្រស់បំព្រង ពពកសត្បុសថ្លាស្អាតវិស័យដូចសំប៉ែក លាលាតដោយកន្ទេ ៗ ឯអាកាសវេហាស៍ផ្កូនផ្ដាផ្កុំធំ ៗ ត្រឈូលដូចកោមបៀម ដូចសោភ័សនឡើយ

ទៅឯជើងមេឃប្រផេះគ្នាជាលំដាប់លំដោយ នាំឲ្យនឹកស្មានថាខាង បុណ្យដាច់ឡើងឯកាល័យ មុខអួរឲ្យស្រវាំងឲ្យស្រណោះអាល័យ អាល័យអណ្តែតអណ្តូងលិចទន្ទឹមគ្នា ។

យប់នោះសោភ័ក្ត្រគេញចិត្ត នៅតែឯងឯការពុំប្រាថ្នាចូលសយនាសន ទីនអ្នកនិតរាន ដើរក្រឡេមៀងមើលតារាការដែលរះលន្ទឹមកន្ទឹកល ល្មើម នូវសេចក្តីសុខកាយសប្បាយចិត្ត! ។ ឱ! ទុះឱ! សោភ័ក្ត្រខុសធម្មតា ទេតើ! មានហេតុអ្វីបណ្តាលឡើងក្នុងចិត្តឬ? បានជាថ្ងៃនេះហើយមិនទាន់ចូលកាន់ដំណេក យប់ជ្រៅណាស់ទៅហើយគេដេកស្កាត់ សល់តែសត្វប្រចៀវហើរចៀលត្បាតគេក្រហារ ។

លុះនាឡិកាជ័យម៉ោង ១ ទើបសោភ័ក្ត្រពាក់ខ្លួនចូលតាំងបន្ទប់ មុនទីនេះបក្តិតនៅនោះ សោភ័ក្ត្របានសំឡឹងមើលមុងដែលជាក់ជាយកាងខ្យល់ រួចក៏ញញឹមយ៉ាងស្រស់ ព្រោះត្រៃសរៃនៃសេចក្តីសុខវង្វាក់ពេញខ្លួន ហើយនាំឲ្យដឹងតែពីសប្បាយ ពន់កាយដូចជាអណ្តែតគ្មានដឹងប៉ះពាល់លើអ្វី ហៃរះទៅវាលណា ក៏ដូចជាទន់ល្មើយ ប៉ុន្តែចុងក្រោយក៏បិទស្ងៀមនៅឯង ។

សេចក្តីសុខបានព្រួញគ្រងសោភ័ក្ត្រ ឲ្យដេកលក់ស្រួលរហូតដល់ពេលភ្ញាក់រួចក៏ឆ្ពោលទៅត្រង់បង្អួច ។ ចុះសេចក្តីសុខប្រែកេចនេះកើតឡើងដោយហេតុអ្វី? សោភ័ក្ត្រក៏មិនបានសាកសួរដល់ខ្លួនឯងដែរ រកហេតុនឹងបច្ច័យជាប្រយោជន៍អ្វីដល់គេ បើគេត្រូវការតែសេចក្តីសុខ គ្រាន់

ស្ងៀតតែសេចក្តីទុក្ខបានខ្លះ តែសោកក្រមិនបានគ្របលោកអ្នកដ៏មានគុណទាំងពីរព្រមទាំងបងប្រុសនោះទេ គឺគ្រាន់តែបានស្តាយទុក្ខថាម្តេចឡាចក៏ត្រូវមិនបានឃើញមុខគេទៀតប៉ុណ្ណោះ ។

ឯសេចក្តីសុវនោះ កំណត់ឲ្យឃើញជាក់ស្តែងថា សោកក្រៃបានអាយុ ១៨ ឆ្នាំ ហើយ ដោះត្រូវសំគាល់ឲ្យដឹងថា កុមារបានផ្លាស់ខ្លួនពេលានដើរចូលកាន់ត្រៃសរជីវិតផតក្លឹក ពេលានចូលយោធនឡើត គត្រឹមករត្រឹមដោយមានភ្លេងភ្លាត់ប្រែតំដេញផ្ទំខ្លួន ។

ព្រះអាទិត្យទើបនឹងចេញពាក់ការទិព្វ រះភ្លឺច្បាស់ស្រឡះពេញផែដោយភាសាស្រែស្រទន់លើផ្ទៃបស្ចិមមហាសមុទ្រ ដែលប៉ោសពាសពេញនៅឆ្នេះត្បូងដំនឹងជុំសិលា ដាច់ស្នេហាដៃមិត្តទឹងពួកកំឡោះ ។ អាកាសក៏ត្រជាក់ត្រាំនិងសប្បាយគួរឲ្យស្រឡះដល់ចិត្ត មានខ្យល់រំភើយរៀយៗ អប់ម្សៅផ្ការាយ យោនខ្ទន់ភ្លន់ ចំណែកផ្ទៃមេឃក៏ថ្លៃថ្លាតអស្ចារ្យគួរពិតពិតណាស់មើលមិនដាក់ភ្នែក ចំណុចឯណាមួយដែលបើងឃ្មាញពិតទឹកស្ទើរដល់ខ្សែភ្លេងការពាក់ឯកសារនេះ ? មិនចង់គ្រាប់ឆាក់មហាផលពីផាទីមនោរម្យ : មិនចង់ប្រះខ្លួនផេតលេងលើផ្ទៃទឹកដ៏ទន់ល្មើយ ! មិនចង់ហុចដៃទាំងពីរដោយស្មោះស្ម័គ្រក្រពេះស្ប្ប្រែបះត្រចង់ដែលញញឹមរបឹតព្រះនេត្រគ្គីថា សំឡឹងមើលមកដោយសេចក្តីមេត្តាដ៏លើសលើ ។

នរណាម្នាក់ដែលមានចិត្តសង្ហា ហ៊ានស្គាល់ឲ្យបានលោកគ្រូគ្រោះទៅជាន់នាក់? នាក់អស្ចារ្យដែលត្រូវនាំលោកគ្រូឆ្លងផែនទៅកាន់ស្ថានមនោរម្យរមស្មុគ? រូបអ្នកនោះឯងមិនទាន់បញ្ជាក់ដល់ចិត្តនៅឡើយ គ្រាន់តែប្រហាក់ប្រហែលប៉ុណ្ណោះ ហើយរូបនោះនឹងប្រាកដនៅថ្ងៃដែលសេចក្តីត្រូវការកើតមានឡើងលើរូបនោះ ។

ល្ងាចមួយ លោកគ្រូដើរមកលេងផ្ទះសាលារៀនតាមធម្មតា ស្រាប់តែប្រទះនឹងណុតនេត្រនារីណាម្នាក់ នាងកំពុងឡើងជិះឡានជាមួយទីទុំ ពុកម្តាយបងប្អូនរបស់នាង មានទាំងហិបកាលិសផងចំនួនដូចជាធ្វើដំណើរទៅឆ្ងាយ ។ លោកគ្រូក៏ហួសផល់សំណាក់សាលារៀនបានសេចក្តីថា នាងមិនសប្បាយក្នុងខ្លួនទៅយកខ្យល់អាកាសឯកោបាន ១ អាទិត្យ ។

លោកគ្រូអង្គុយលេងនៅទីនោះបានបន្តិច ក៏ប្រញាប់លាសាលារៀនវិលទៅលំនៅវិញ ព្រោះដូចជាបន្ទ្រើតបន្ទល់ក្នុងចិត្តពេក "ដូចម្តេចក៏ឆាប់ទៅម្ល៉េះលោកគ្រូ? ។

"បាទ! ខ្ញុំបាទមិនសូវស្រួលក្នុងខ្លួន ដូចជាគឺងម៉ុរគឺងមាត់អស់យ៉ាន់ហើយក្នុងថ្ងៃនេះ" ។

"រកផឹកថ្នាំសិន ប៉េដូប្រោះ" ។

" អ៊ុំ, អរគុណ! កុំព្រួយលោកអាចារ្យ ខ្ញុំទៅសម្រាកខ្លួនមួយសន្ទុះស្ងាត់ហើយ " ។

រូបសោភ័ក្ត្រក៏វិលត្រឡប់មកលំនៅអាត្មាវិញ កន្ទក់កន្ទេញទឹកថា " គុនាងមិនទៅផ្ទះទេតើ អាត្មាអញបានឃើញមុខនាងអស់កំណត់មួយកាលវិញ ហើយក៏ទឹកអប្សរក្ខនិចិត្តនឹកការណ៍យល់មួយពេល ក្រឡេកមើលវិញចាប់ផ្ដើមឃើញដូចជាស្នាក់ដែលមិនជាទីសប្បាយ នូវឲ្យទៀតណាយក្រៃលែងទើបដើរទៅលេងផ្ទះអ្នកជិតខាង ក៏ឮតែគេនិយាយពាក្យដដែលគ្មានខ្លឹមសារ ជាសំដីរកាយណាយឥតប្រយោជន៍ ។ សោភ័ក្ត្រគេចមកវិញរំពឹងគិតដល់រូបខ្លួន " ចុះអាត្មាអញថ្ងៃនេះ ដូចម្ដេចក៏ប្លែកខុសពីធម្មតាម៉្លេះ, មិនបេះរកាយផល់ក្ដីសោះ ត្រាន់តែឮថាណាដទេត្រូវទៅបាត់បំណាំងក៏ ?..... ។

ឈ្មោះនេះចេញមកមិនទាន់ផុតពីមាត់ សោភ័ក្ត្រក៏កើតក្ដីនិវត្តចិត្តញ័រចំប្រប់ក្ដាយ ទៅស្មៀមមួយព្រែសប់ក្ដី ស្រាប់តែរូបដាននេះលេចចំពោះទ្រូងក្រក្ដីដួងចិត្តរបស់សោភ័ក្ត្រ ការនៃតព្រាសចិត្តចម្ងល់ ត្រាតែដូចធម្មតាស្និទ្ធជាប់កក្ដីចិត្តនោះលែងលុបចុះ ។ ណាដទេព្រាហ្ម ឈ្មោះនេះពេញដួងហឫទ័យរបស់សោភ័ក្ត្រយ៉ាងខ្ជាប់ខ្ជួន ។ ថ្ងៃនោះពេលសោភ័ក្ត្រដែលរាន់ក្ដីឈ្មោះនេះចាប់ផ្ដើម ចូលកិច្ចការស្រកក្ដីខ្ពស់ ហាក់មិនដឹងខ្លួនបានតាំងព្យាយាមការនៃឈ្មោះនោះ ព្រោះហាក់ដូចជាមន្តអាថ៌កំបាំងស័ក្តិ

សិទ្ធិមួយចង់ ដែលគាប់ទាំងខ្លួនសព្វគ្រប់មកឲ្យ ។ សោភ័ក្រ្តពិតជា "ខ្ញុំអាណាព្យាបាលស្រឡាញ់ខាងវេជ្ជ ក៏រៀបរាប់ប្រាប់ថាខែមុន ទើបសំដែង ទឹកចិត្តរបស់ខ្លួនប្រុងៈ ខ្ញុំណាស់នេះត្រូវការជីវិតផងដែរ ម្ដេចក៏ចាកឃ្លាត ទៅបាត់ ឲ្យបងនៅស្ងាត់តែម្នាក់ឯង នេះព្រោះតែជាប្អូនមិនអាសូរផង ដើម្បីឲ្យឯងបងទ្រាំទ្រផងទេ ... សោភ័ក្រ្ត ! សោភ័ក្រ្ត ម្ដេចក៏បាត់ស្មារតី ក្លាយ ពាក្យថាបងទំនួញគេនឹងធ្លាយលើខ្ញុំឲ្យច្រើនណាស់ វិស័យមេឃ ទីពីរ មិនគួរយកមកប្រើសោះ ហើយខ្លួនឯងតាមស័ក្ដិដូចម្ដេចក៏ប្រាថ្នា ផល់ទៅព្រះបន្ទូលលើមេឃ "

ទុកជាពិការណាដល់ឋានៈដុតភាពរបស់ខ្លួនយ៉ាងណា សោភ័ក្រ្តក៏ នៅតែនឹករលឹកដល់នាងជានិច្ច មិនចេះហោះស្រាកស្រាន្តឡើយ ទោះ ធ្វើការក្ដី ដើរក្ដី ដេកក្ដី សោភ័ក្រ្តឃើញតែរូបនាងជាប់នឹងភ្នែក រំខាន ចិត្តអន្ទះសារជំពាំពេលនាងត្រឡប់វិលមកវិញតែម៉ែខ្ញុំថា "ចាំនៅប្អូន ថ្ងៃទៀត ! នៅបីថ្ងៃទៀត ! នៅពីរថ្ងៃទៀត ! នឹងបានជួបប្អូនកែវខ្លួន ក្អួន ..." ដល់យប់ដែលនាងត្រឡប់ចូលផ្ទះ ចួនជាពពកនោះមេឃងងឹត អ័ព្ទទិសទី ផ្គរគ្រហឹមព្រមៗ សន្ធឹកលាន់ឮគួរឲ្យភ័យខ្លាចចិត្ត តែសោភ័ក្រ្ត នៅតែទៅ ព្រុះដើរជិតដល់ផ្ទះអាចារ្យ ស្រាប់តែភ្លៀងធ្លាក់ខ្លាំងៗ មក ទទឹកទាំងអស់ នាំឲ្យសោភ័ក្រ្តមួម៉ៅក្ដៅចិត្តត្រឡប់មកផ្ទះវិញ ដោះ ខោអាវចោលហោលចូលដេកតែម្ដងប្រាថ្នានឹងឲ្យផុតព្រឹកឆាប់ៗ ។

តែបើជាដេកមិនលក់សោះ រសាប់រសល់ខ្វល់ក្នុងចិត្ត ប្រែចុះប្រែឡើង លើគ្រែទឹកដល់ណាស់ ទ្រគាន់តែភ្ញាក់ឡើងៗ ។ ដោយកំឡាំងចំណង់ចង់ជួបមុខនាងពេជ ក៏បន្សាត់ចិត្តឲ្យអណ្ដែតទៅតាមក្រសែនៃសេចក្ដីស្រមៃ គិតតែកែប្រឌិតរឿងធ្វើឲ្យបានជួបនឹងនាង ឯតួរឿងនោះផ្សេងៗ ប្លែកគ្នាតែត្រង់ទីកន្លែងពេលវេលា និងហេតុការណ៍ប៉ុណ្ណោះ ឬនតាំងផ្ទ គ្រូពេទ្យជួយសង្គ្រោះម្ដាយរបស់នាង ហើយមាតារបស់នាងក៏លើកកូនស្រីឲ្យដោយសេចក្ដីដឹងគុណ ក្នុងជាបុរសអ្នកក្លាហានជួយការពារជីវិតនាង ឬមួយជាសោកក្រុមគ្នា ដោយគំនាប់សេចក្ដីព្យាយាមនាងព្រមស្ម័គ្រជាមួយ ឬក៏ជួលគ្រៅដល់ទេវតាចុះមកបណ្ដាលចិត្តនាងឲ្យស្រឡាញ់ ហើយបានជួយជ្រោមជ្រែងឲ្យសមដូចសេចក្ដីប្រាថ្នា ៗល។

គិតណាស់ជាណាស់ទៅក៏លែងដេកលក់ ទុកជាខំធ្វើភ្នែកយ៉ាងណា ភ្នែកក៏មិនជិតស្និទ្ធគ្នា បណ្ដាលឲ្យទៅជាក្ដៅមុខធ្ងន់ក្បាលជាប្រើន តែរឿងគិតរឿងដដែលតទៅទៀតក៏មិនកើត ព្រោះខួរក្បាលបំពេញនាទីហួសកំរិតទៅហើយ មិនមានកំឡាំងនឹងធ្វើការតទៅទៀត ទោះហើយសោកក្រៀមនៅតែសៀមធ្វើភ្នែកភ្លឺៗ កណ្ដាលរាត្រីស្ងាត់ ទឹកខ្ញាញ់ណាស់ ទើបប្រែះទះរៀលចុះឡើង ចង់ពណ្ណាញស្រែភ្លែលចុះមកពីផ្ដែក មិនឲ្យដេកឲ្យជៀសរួចញ្ញាក់ ទើបប្រសិនជារូបជម៉ោះ

ប្រហែលប្រពោរដីតែបន្តិចទៅហើយ តែនេះក្មេងមើលមិនឃើញក៏មិនដឹងធ្វើដូចម្ដេច ។

លុះសន្សើមធ្លាក់ អាកាសត្រជាក់ល្អបរិវេណ សោភ័ត្រក៏បានកាន់ចុះក្បាលអស់កំឡាំងទន់ខ្លួនប្រាណ ត្របកភ្នែកបិទក្រុះមួយរំពេច ស្រមុកដៀយរហូតដល់បែកបច្ចូសម័យ តែលុះព្រឹកឡើងក៏កើតឈឺក្បាលវិលមុខ រួចស្រតទំរស់ដៃជើងខានទៅផ្ទះនាងអស់មួយថ្ងៃទៅទៀត ។

កាលបើរើសំបុត្រដាក់ក្រញ៉ាក់ស្បែកជើងរួចហើយក៏ទៅចែកតាមផ្ទះ សោភ័ត្រប្រទះសំបុត្រ ១ ច្បាប់ ការឱ្យលេខផ្ទះណុំជនេត្រនារី ទើបប្រញាប់ប្រញាល់ចោលយកសំបុត្រឯទៀតទៅដាក់សំណាក់អ្នកដទៃ ដើម្បីទុកពេលទំនេរចំអក់នៅលេងផ្ទះនាងឲ្យបានយូរបន្តិច ។ ប្រហែលជាម៉ោង ៩ សោភ័ត្របានដល់ម្ដុំផ្ទះនាងឃើញណុំជនេត្រអង្គុយលើកៅអីនៅមុខផ្ទះកំពុងចាក់ការ ទើបឈរទ្រឹងសំឡឹងមើលភាកហ្វ័យដោយសេចក្ដីលើកខ្លាំង ត្រាតែកាំងភ្ញាក់ខ្លួនមិនបានទាញកណ្ដឹងហៅម្ចាស់ផ្ទះប្អូនជានាងក្រឡេកមើលមកឃើញ នាងបានដើរចេញមកសាកសួរ “ មានការអ្វី ? អញ្ជើញចូលមក ” ។

សោភ័ត្រដើរចូលទៅទាញសំបុត្រហុចឲ្យនាង ណុំជនេត្រមិនបោយអរគុណដល់បុរសប្រៃសណីយ៍ រួចយកសំបុត្រចូលទៅក្នុងផ្ទះ មួយសន្ទុះបានចេញមកវិញ កាន់ក្រដែកមួយបន្តោមនៅដៃ រួចនាងប្រស្រ័យ

លោកក៏ក្រហាយពាក្យដូច្នេះ "យកផ្លែក្រូច ១ បន្ទោមទៅពិសាចុះ ក្រូចនេះផ្អែមល្អណាស់" ។

"ទុកជាជូរជូរម្ដេចក្ដី បើខ្ញុំបានទទួលពីដៃអ្នកក៏គង់ឆ្ងាញ់ពិសាវិញ សម្រាប់ខ្ញុំបាទ មួយវិញទៀត ផ្លែក្រូច ១ បន្ទោមនេះជារបស់មានដៃខ្សែ ខ្ញុំបាទប្រហែលជាពុំហ៊ានទទួលទានទេ មុខជាទុកគល់មើលហើយ" ។

នាងក៏ញញឹមហើយថា "អញ្ជើញពិសាតែសិនចុះ ! កុំឲ្យកែសំកំ-ខ្លាំងពេក ព្រោះតែជាគេសង្ឃៈយោងកំខ្លាំងម្យ៉ាងដែរ" ។

"អរគុណអ្នកហើយ ខ្ញុំបាទពុំហ៊ានទទួលទានតែទេ ខ្លាចក្រែងពេកកប់ធើក ខាំឲ្យស្លាប់ដោយក្រូចកម្លោចបន្ទោមនេះ" ។

នាងក៏ទឹកកក់ចិត្តថា "គាត់នេះមិនព្រមហ៊ាញ់ប្រើបគេសោះ" ចំណែកលោកគ្រូក៏ហានាងវិការត្រឡប់ទៅកន្លែងវិញ ដើរចេញតាមផ្លូវថា នឹកគិតញញឹមក៏កាន់ប្រសើរដែរ ! ថ្ងៃនេះបានសាសងជាមួយនាងគាប់ចិត្ត ! បានទទួលក្រូច ១ បន្ទោមពីដៃនាងទៀត នេះជាជ័យជំនះដ៏ធំនៃការប្រឹងប្រែងរបស់ខ្ញុំ ។ កាលបើលោកគ្រូគិតដល់រឿងនេះ រូបភាពនាងក៏កាន់តែច្បាស់ឡើងដល់ចិត្តជាប់សព្វថ្ងៃសុខុម ។

បណ្ដាពួកយុវជនកំពុងពាល កាលៈបើយុវជនណាមួយបានស្គាល់សេចក្ដីកាមារម្មណ៍ជាគ្រាដំបូង នឹងដក់ការមភាពជាទីពេញចិត្តនោះ ដើម្បីនឹងនយកទស់បំអំពីបញ្ញា ហើយនឹងនឹកសរសើរឥតព្រោះនូវរូបឆោមឈោមព័ណ៌របស់នាង ឬបន្ទូររំពៃកេទខ្លាំងៗ តែម្នាក់ឯង រហូតដល់ប្រឹងសរសេរសេចក្ដីទឹងរកាយរបស់នាង តែមិនដឹងធ្វើម្ដេចនឹងបានជិតហាក់ដូចជាមានរបងរុំមកខាំងជាប់ មិនឲ្យឈានចូលក្នុងខ្សែដ៏ក្ដុមបាន កាលបើចំណាន់ដក់ការសរសេរប្រែបដូចសេចក្ដីប្រាថ្នាហើយ នង់ទង់បានចងឲ្យស្នាស់នូវសេចក្ដីកើបរំជួលក្នុងចិត្តរបស់សោកគ្រួ ទេវវេលានោះបានដោយឥតការប្រាំ ។

ប៉ុន្តែសេចក្ដីតកយបែបនោះមិនស្ថិតស្ថេរប៉ុន្មានទេ ព្រោះសោកគ្រួមានបាំងៈរហូតតាប ហើយថែមទាំងមិនមានញាតិសន្ដានទៅជិតខាងផងផុតផ្ទះសង្សម ។ ចំណែកនាងពេលដែលកំពុងរៀន នាងមិនដែលសំដែងទឹកចិត្តរបស់ខ្លួនឲ្យឃើញថា នាងអើពើនឹងសោកគ្រួនោះឡើយគិតតែអំពីមេរៀនដោយយកចិត្តទុកដាក់ អាការៈជាកុមារីដ៏ទំប្រឹងរៀន ឡើងព្រន្ធឥមៀវស្រស់ស្រស់ប្រផុំប៉ះញើម យូរៗ នាងលើកដៃជក់សក់ដែលធ្លាក់មកលើមុខខ្លួន ។ សក់នោះជាត់ជាយតាមខ្យល់ធ្លុះពន្លឺប្រាក់នៃបង្អៀងអត្តសន្តិស្រុកវបរវេណ នាំឲ្យសោកគ្រួនឹកឃើញថានេះជាក់ជាទេពធីតាច្បាស់ចុះមកដែនដីសង្ស័យ ។

ហើយលោកស្ត្រីពិនិត្យចិត្តថា ខ្លួនជាមនុស្សព្រោកពាលមិនសមស័ក្តិ នឹងនាងនោះ នឹងចូលរួមរស់នៅនឹងនាងផងពុំបាន ទុកជាខ្លួនសន្ទុះទៅ ចំពោះក្តី ក៏ដូចជាឥតទៅដែរ ព្រោះគ្មានទោសណាដែលរស់សាកសួរអំពី រឿងក្តីនោះ ស៊ីអង្គុយព្រឺព្រួចតែម្នាក់ឯងនូវទ្រទ្រង់គតអន្ទះផល់រូបអី អ្ហ៎ះ! ចួនក៏តាំងចិត្តថា នឹងលែងមករកអ៊ីតពេញកទៀត ព្រោះគួរឲ្យអាណិតសម្ពុទពេកណាស់ ទុកជាមស្រីកា ទៅក៏គ្មានផលអ្វី បើនាងហាក់ ដូចជាវិព្រាហ្ម៍យកទ្រើងហើយ ៗ បែបនេះ កូនមានចិត្តស្ទើរនាំចន្ទិបទៅ ក្រែងលោនាងអាណិតអាសូរខ្លះ ព្រោះចិត្តអកកក្រសម្បាញ់គេ រមែង មានសេចក្តីសង្ឃឹមជាដរាប តែម្ល៉េះលោកស្ត្រីគាន់តែស្រងូតស្រងាត់ឡើង ជាលំដាប់ ។

ថ្ងៃមួយជាពេលសម្រាកខ្លួន នាងបានបោលកែ្សមើលមកលោកស្ត្រី មួងៗដែរ តែក្សែទៅតាំងតួនោះទុកជាមុតចាក់ចុះដល់ថ្លើមប្រមាត់លោកស្ត្រី ដូចម្តេចក៏ សរសៃផង ខ្ទរសេចក្តីបរិសុទ្ធចិត្តទាំងអស់ ធ្លាក់ចុះលើ លោកស្ត្រីបិទដួលចេញមកអំពីទីពលល្ហល្ហៃ ។ ឯទីយ៉ាន់នេះត្រូវតាំងតួនោះ បានស្រាចសន្ទានចិត្តឡើងអក្ខរស្លោកអម្រឹតដ៏ត្រជាក់ បានស្ទុះ ដល់ខ្សែកន្ទ្រាក់ញញាទន្ទ្រកន់ពេកញាប់ញ័រខ្ទត់ ទុយេ៉ងពល់គ្នាជាពិណាទ ដំរីសេសហ្ម៉ា! ពេលបើត្រូវខ្យល់តសៀតមកក៏ជួយរងំគោរមគ្រាម ។ ចំណែកលោកស្ត្រីក៏ពុំហានសំឡឹងនាងចំដែរ តែយប់មួយដោយការស្រវឹម

ក៏ក្រុមខ្លួនសំឡឹងមើលនាងយ៉ាងយូរ ហេតុដល់នាងឡើងមុខក្រហមគេចចេញ ព្រោះសេចក្ដីអៀនហើយនាងបែរខ្នងឲ្យ ។

នៅវេលានោះ សោភ័ក្រ្តតូចចិត្តជ្រុលខ្លួនធ្វើឲ្យធ្លាក់ធ្ងន់ទៅលើនាង ទើបយកដៃទះថ្ពាល់ជាងក្ដាក់ដល់នាងព្រមទាំងអាចារ្យ តែសោភ័ក្រ្តមិនបានជាចាប់ក្ដីព្រោះអន់ចិត្តណាស់ចង់តែយំ យកដៃទាំងពីរខ្ទប់មុខផង ទុក្ខសញ្ចប់សញ្ចឹងដោយសេចក្ដីទុក្ខសង្រែម នេះបញ្ជាក់ជាណាស់ដល់នេត្រមិនអាណិតដល់ខ្លួនសោភ័ក្រ្តសោះ បានជាបែរខ្នងធ្វើព្រងើយ ឱណ្ឌេទេត្រនារីអើយ! រូបខ្ញុំអាក្រក់ណាស់ណាទៅឬ? បានជានាងធ្វើដូច្នេះ នឹងពីថ្ងៃនេះទៅ សមខ្ញុំសោះសូន្យអស់សប្បាយរីករាយ ណាព្រាត់ប្រាសចាកទុក្ខក្ដាយបងប្អូន បានឃើញមុខណាដែលទេត្រព្រាត់បានស្បើយទុក្ខខ្លះ ឥឡូវនាងធ្វើហើយថែមទៀតគួរឲ្យសោភ័ក្រ្តឈឺចិត្តទេ ។

កាលបើឈ្មក់តក្ដីការឧកព្រឹត្តិដល់សេចក្ដីទុក្ខនាពេលនោះ សោ-ភ័ក្រ្តមិនបានឮពាក្យអាចារ្យសូត្រ ហេតុដល់អាចារ្យគោងជូនពាក្យជាំគំរប់ ៣ លើកទើបបានឮ ងើបមុខឡើងមុខនោះជោគទៅដោយទឹកភ្នែក សោភ័ក្រ្តទឹកស្មានថាខ្លួនប្រែវែម ទើបយកកន្សែងដៃជូតភ្នែកឲ្យស្អាត អាចារ្យឃើញដូច្នេះក៏សួរថា “ពុទ្ធោ អើយសោភ័ក្រ្ត ឯងកុំព្រួយអ្វី ទុកជាឯងយំសោកយ៉ាងណា ៗ ក្ដី ក៏ការណ៍នេះកន្លងហួសទៅហើយ ធ្វើមេត្តាកុសលផលបុណ្យរបស់ឯងត្រូវឲ្យកំព្រាដូច្នេះ” ។ (មានត)

ឃ្លាំងសហស្រភត្រ

ប្រជុំរឿងកំប្លែង (ជារឿងរកាប់)

ភាគទី ១០

ក្នុងទិពក្នុងត្រី ញ៉ុក-ថែម ប្រែចេញពីកាសែតភាគខាងលិចមកជាខេមរភាសា

# រឿងអ្នកប្រមាញ់ ក ឃាតករព្រៃស្ងប់

(តទៅ)

គ្រាន់តែខ្ញុំកាយដីលុបរួចស្រេច ដោយក្នុងគ្រាឡើងមើលទៅត្រើយខាងខាយ ស្រាប់តែឃើញខ្លួនគាត់ ។ ហើយ បើកសំដៅមកទៀតកោះនោះដើម្បីទិញម្ហូបយកទៅក្នុងកោះនោះ ឱ្យគេរួបទៅដាក់ផ្ទះសម្បត្តិវិញ ។ គ្រានោះ ចិត្តខ្ញុំបោះពិភពភ័យនឹងអំពើ ដែលខ្ញុំបានធ្វើមកនោះមិនដាច់ ហើយកើតគំនិតគិតឃើញថា "ប្រសិនបើចង្វាញខ្លួនខ្ញុំឱ្យគេឃើញ មុខជាគាត់បង្គាប់ឱ្យពួកគាត់ចាប់ខ្ញុំសម្លាប់ចោលមិនខាន នៅវេលាដែលគាត់យល់ថាខ្លួនខ្ញុំជាអ្នកសម្លាប់កូនគាត់ បើខ្ញុំជាខ្ញុំបេះទីយាយដោះសាយ៉ាងណា ក៏គង់តែមិនសមស្រួលរស់ ។ ដូច្នេះគួរតែខ្ញុំរកទុកឆ្ងាយទៀតសិនឱ្យផុតពីសេចក្តីអាឃាតព្យាបាទរបស់គាត់ទៅសិន ព្រោះរឿងកូនស្លាប់នោះមុខជាគាត់ផ្ទេរមកលើខ្ញុំជាមិនខាន" ។ នៅជិតកន្លែងនោះ មានដើមឈើ ១ ដើមធំ ហើយមានស្លឹកក្រាស់ក្រសាយសាខាល្មមបាំងបាំងខ្លួនខ្ញុំឱ្យជិតបាន ហើយខ្ញុំចាប់ព្រាក់ឡើងដើម

ឈើនោះ ហើយលាក់ខ្លួនពួននៅប្រគាប់ឈើ ។ ល្មមខ្ញុំមើលទៅខាងក្រោមឃើញគ្នីៗ បានច្បាស់ ខ្ញុំបានឃើញទូកនោះល្មមចតត្រង់កន្លែងដែលចតពីមុននោះឯង ។

តាចាស់និងពួកចោរ នាំគ្នាឡើងពីទូកស្រទៅមួយរំពេច ហើយដើរសំដៅទៅត្រង់កន្លែងកុនដី ខ្ញុំសង្កេតមើលទំនុះផងទាំងនោះឃើញស្រស់បស់ទាំងអស់គ្នា ដោយមានសង្ឃឹមពេញទី ប៉ុន្តែផល់ឃើញមានស្នាមកកាយឧងលុបទៅវិញថ្មីៗ ក៏ថ្លស់ទឹកមុខមួយរំពេច ទាំងតាចាស់ទាំងពួកចោរ ។ ពួកមនុស្សទាំងនោះ នាំគ្នាកាយដីទីងលើកថ្មប៉ុគំរបនោះចេញ ហើយក៏ចុះស្រទៅ រួចស្រែកហៅឈ្មោះគេងឹកឡេះនោះមិនឮស្ងូរមាត់ឆ្លើយសោះ ហើយនាំគ្នាដើរចូលទៅកុនទៅ ស្រាប់តែឃើញផតស្រទាននៅលើគ្រែហើយមានទាំងកាំបិតដោតជាប់ត្រង់កំពូលបេះដូង ព្រោះខ្ញុំមិនហ៊ានដកយកកាំបិតនោះចេញមក ។ ពួកមនុស្សទាំងនោះក៏ស្រែកទ្រហោយំកន្ទេញទ្បើង តាចាស់ក៏ថ្លស់សន្ធប់ដោយសេចក្ដីសៅសោកយ៉ាងលើសលុប ពួកចោរៗ ក៏នាំគ្នាទាញត្រកងលើកគាត់ចេញមកខាងលើកេខ្យល់អាកាសល្អ ហើយសែងគាត់មកដាក់ក្បែរគល់ឈើ ដែលខ្ញុំទំនៅពីខាងលើនោះឯង ។ ទុកជាពួកចោរទាំងខ្លះកុនហោងណា តាចាស់ក៏នៅតែសន្ធប់ដដែល មុខស្លេកស្លាំងគ្មានឈាមបង្ហាញឡើងសាណិក

គាថាសដាច់ពុកពន់ពេក    គាត់នៅតែសន្លប់ជាច្រើនម៉ោងស្ទើរតែអស់សង្ឃឹមទៅហើយ ។

លុះគាត់សន្លប់ជាយូរថ្ងៃហើយ    ក៏ត្រឡប់ដឹងខ្លួនមានស្មារតីឡើងវិញ    ទើបពួកបារាំងនាំគ្នាយកសំពត់យ៉ាងល្អ ៗ ស្រោបខ្លួននោះលើកចេញមក    ក្រោយដែលបានដកក្រណាត់រួចស្រេចហើយ    ក៏ដាក់សពក្នុងទៅក្នុងក្រណាត់នោះទៅ    ។    ឯគាថាសដាច់ពុកបានបារាំងនាក់ជួយទប់ទ្រូងគាត់    មុខគាត់មានទឹកភ្នែកហូរហោមយំខ្សឹកខ្សួល    មុខស្លេកសាំណោបគួរអាណិតណាស់    គាត់ទំរើងទប់ពោះដុំដីទៅក្នុងក្រណាត់បានបន្តិចហើយពួកបារាំងនាំគ្នាយកដីលុបក្រណាត់នោះទៅ    ។

កាលពួកបារាំងដឹកកប់សពកូនគាថាសរួចហើយ    ក៏នាំគ្នាជញ្ជូនយកគ្រឿងប្រដាប់ប្រដាចេញមកពីកងពី    ព្រមទាំងគ្រឿងស្បៀងអាហារដែលសេសសល់នៅពីប៉ុន្មាន  យកទៅដាក់ទូកទាំងអស់  ។  ឯគាថាសក៏នេះតែខ្សឹកខ្សួលហើយលោកក៏ដូចត្រូវរញ្ជាជាពន្លឹក  ខ្លួនព្រួណោមិនដាច់ដើរមិនរួច    ទើបពួកបារាំងលើកគាត់ផ្តេកលើគ្រែស្នែងរួចនាំគ្នាសែងចុះទូកហើយបើកក្តោងចេញទូកទៅ    ។  មិនយូរប៉ុន្មាន  ទូកនោះក៏ចេញឆ្ងាយពីកោះទៅ    ទាល់តែខ្ញុំក្រឡេងមើលលែងឃើញតទៅទៀត  ។

លុះគាថាសនិងពួកបារាំងចេញផុតទៅហើយ  ខ្ញុំក៏នៅលើកោះនោះតែម្នាក់ឯង    វេលាយប់ខ្ញុំចូលទៅជ្រកការស្រមោលទៅក្នុងរូងដីដែលនោះឯង

ដល់វេលាថ្ងៃ ខ្ញុំក៏ចេញទៅដើរលេងនៅជុំវិញកោះ ហើយឈប់ដើរលេង នៅក្បែរកន្លែងដែលខ្ញុំត្រូវកប៉ាល់ស្រោក ។

ខ្ញុំមានសេចក្ដីអផ្សុកណាស់ ដែលនៅលើកោះនោះតែម្នាក់ឯង អស់វេលាយូរដល់ទៅ ៣ ខែ តែតពីនោះមក ខ្ញុំបានឃើញទឹកសមុទ្រស្រកស្រកចុះទៅយ៉ាងសំខាន់ ហើយចំពោះកោះដែលខ្ញុំអាស្រ័យនៅ ក៏ទៅជាកោះយ៉ាងធំ ហើយហាក់ដូចជានៅជិតទីដីគោក តាំងមានចំនងផ្លូវដើរឆ្លងកាត់ទៅកាន់ត្រើយដីគោកបានផង ទើបខ្ញុំចេញដើរជាវេលាយូរណាស់តាមឆ្នេរសមុទ្រ ដែលដោះសទៅយោគតែទេក្រាប់ ខ្ញុំអស់កំឡាំងណាស់ ស្ទើរតែដើរទៅទៀតមិនបាន តែនៅទីបំផុត ខ្ញុំក៏ដើរទៅដល់ត្រើយដីគោកបាន នៅវេលានោះខ្ញុំបោលភ្នែកក្រឡេកមើលទៅទិសខាងពីខាងមុខខ្ញុំ នោះឃើញហាក់ដូចមានភ្លើង ១ ចំនៅឆ្ងាយលន្លឹមជាហេតុនាំឲ្យខ្ញុំមានសេចក្ដីត្រេកអរ ដោយនឹកស្មានថា "ខ្ញុំមុខជាបានជួបប្រទះនឹងអ្នកណាមួយមិនខាន ទើបមានគេដុតភ្លើងឡើងដូច្នេះ" ។ ប៉ុន្តែដល់ខ្ញុំដើរចូលទៅកាន់តែជិតទៅ ការនឹកស្មានរបស់ខ្ញុំខុសស្រឡះ គឺដែលខ្ញុំនឹកស្មានថាជាភ្លើងនោះ មិនមែនសោះ ត្រឡប់ទៅជាប្រាសាទទទន់ដែនក្រហមឆ្អៅ ដែលត្រូវទឹករន្ទះថ្ងៃបាំងមក មើលទៅពីចម្ងាយហាក់ដូចជាអណ្ដាតភ្លើង ។

ខ្ញុំក៏ដើរចូលទៅឈប់សម្រាកមួយភ្លែត ហើយអង្គុយនៅក្បែរច្រា-
ងមាត់ទោះឯងពិនិត្យមើលរបៀបការតសាង ខ្ញុំកំពុងពិចារណាមើលគេហ-
ស្ថានដ៏ស្កុតស្ដុកនោះ មិនទាន់ជាអស់ចិត្តបន្តិចផង ស្រាប់តែឃើញមនុស្ស
ជាង ១០ នាក់ រូបរាងមាំដាក់ស្នាក់ស្រាកទើបនឹងត្រឡប់មកពីដើរលេង ៗ
ប៉ុន្តែហេតុដែលនាំឲ្យខ្ញុំនឹកឆ្ងល់ណាស់នោះ គឺអ្នកទាំងនោះ សុទ្ធតែ
ម្នាក់ៗកាន់ស្ពាយមានម្នាក់ទាំងអស់គ្នា ៗ ផងទាំងនោះ ដើរមកជា
មួយនឹងការសម្លាក់ មានរូបរាងធំខ្ពស់ មានមុខមាត់គួរជាទីគោរព ៗ

ខ្ញុំរេះតែមិនចេះនឹងឆ្ងល់មិនដាច់ អំពីការប្រជុំប្រទះនឹងមនុស្សម្នាក់
ច្រើននាក់ព្រមគ្នា ហើយសុទ្ធតែខ្ពស់ៗកែកម្ចាស់ម្នាក់ដូចគ្នាទាំងអស់ ៗ
នៅវេលាដែលខ្ញុំកំពុងតែគិតនឹករកហេតុផលនោះ ស្រាប់តែផងទាំងនោះ
នាំគ្នាដើរត្រង់ចូលមករកខ្ញុំ ហើយសំដែងសេចក្ដីត្រេកអរដែលបានមក
ជួបប្រទះនឹងខ្ញុំ លុះរកគាត់នឹងខ្ញុំរួចហើយក៏សួរមកកាន់ខ្ញុំ អំពីដំណើរ
ទំនងដែលបាននាំខ្ញុំមកកាន់ទីនោះ ៗ មុននឹងដំណាលរឿងរ៉ាវរបស់ខ្ញុំ ៗ
សុំឲ្យអ្នកទាំងនោះអង្គុយសិន បានខ្ញុំដំណាលរឿងដែលជាទីពេញចិត្ត
ឲ្យស្ដាប់ ព្រោះរឿងរ៉ាវរបស់ខ្ញុំត្រូវការពេលវេលាវែងបន្តិច ទើបបាន
ថ្ងៃនឹងបស់សព្រៃប៉ុន្មាន ៗ អ្នកទាំងនោះ ក៏នាំគ្នាអង្គុយដោយស្ងប់ស្ងៀម
ហើយៈទើបខ្ញុំក៏ចាប់ផ្ដើមនិយាយរឿងរ៉ាវ តាំងអំពីខ្ញុំចេញពេលនគរហ្វូក

បានមកដល់ទីនោះ  រឿងរបស់ខ្ញុំនេះនាំឲ្យក្រុមទាំងនោះ  មានសេចក្តី ជឿនជ្រួលពន់ពេកណាស់ ។

លុះខ្ញុំនិទានរឿងរ៉ាវរបស់ខ្ញុំចប់សព្វគ្រប់ហើយ  ទើបបុរសកំ-ព្រោះទាំងនោះក៏និយាយសូមឲ្យខ្ញុំចូលទៅក្នុងប្រាសាទជាមួយនឹងគេ ។ ខ្ញុំក៏ទទួលពេញចិត្តព្រមចូលទៅ  យើងក៏នាំគ្នាដើរកាត់ថែវល្វែងទទួលភ្ញៀវ ទីរល្វែងតូច-ធំ និងបន្ទប់ដែលសុទ្ធតែមានគ្រឿងប្រដាប់ផ្ទះ ទើបបានដល់ទៅក្នុងបន្ទប់ធំ ១ ដែលមានតាំងកៅអីវែង ១០ ក្រាលព្រំពណ៌ខៀវដាក់តំរៀបជារង្វង់មូល។  ហើយនៅឃ្លាត ៗ ពីគ្នាបន្តិច  ជាកៅអីសម្រាប់អង្គុយក្នុងវេលាថ្ងៃក៏បាន  សម្រាប់ដេកក្នុងវេលាយប់ក៏បាន  នៅត្រង់កណ្តាលរង្វង់នោះមានកៅអី ១ ទៀត  ជាតំរប់ ១១ ខ្ពស់បន្តិច  ជាកន្លែងរបស់តាចាស់ដែលយើងបានពោលរួចមកហើយ  ឯបុរសកំព្រោះឯទៀតៗ ក៏អង្គុយលើកៅអីទាំង ១០ នោះ ។

ដោយហេតុកៅអីទាំងនោះ  អង្គុយបានតែម្នាក់ៗ ប៉ុណ្ណោះ  បានជាមានជនម្នោះម្នាក់  ក្នុងចំណោមជនទាំងនោះនិយាយឡើងប្រាប់ខ្ញុំថា “នែសម្លាញ់! ចូរអ្នកឯងអង្គុយត្រង់កណ្តាលព្រំនេះចុះ  យើងសុំប្រាប់អ្នកថា សូមឲ្យអ្នកគ្រាន់តែមើលយើងបានហើយ  កុំបង្ខំចង់ឲ្យហួសពីនោះទៅទៀត  អំពីហេតុដែលយើងខ្វាក់ភ្នែកស្តាំទាំងអស់គ្នា  គឺថាសុំឲ្យអ្នកសុខចិត្តត្រឹមតែមើលបានហើយ កុំបង្ខំចង់សាកសួរឲ្យហួសពីនោះទៅទៀត ។

ឯតាចាស់ក៏ស្ងៀមទៅ ១ ស្របក់ គាត់ក៏ក្រោកឡើងហើយដើរចេញទៅ ហើយត្រឡប់មកវិញមួយរំពេច នាំយកចានអាហារសម្រាប់ឧត្តមជនទាំង ១០ នាក់ ហើយគាត់ក៏ចែកអាហារ ១ ចំណែកម្នាក់ៗ គ្រប់គ្នា ៗ ឯខ្ញុំគាត់ក៏បែងឲ្យ ១ ចំណែកដែរ ហើយខ្ញុំនឹងអ្នកទាំងនោះ ក៏នាំគ្នាបរិភោគទៅ លុះបរិភោគរួចហើយ តាចាស់ដដែលនោះគាត់ បាក់ស្រាឲ្យម្នាក់ ១ ពែង ១ គ្រប់គ្នា ៗ

ដោយរឿងក៏របស់ខ្ញុំជាចំឡែកពេកណាស់ បានជាអ្នកទាំងនោះ សូមឲ្យខ្ញុំនិយាយរឿងនោះម្តងទៀត ក្រោយបរិភោគអាហារល្ងាចរួច ហើយ ខ្ញុំក៏តាំងដំណាលរឿងដដែលតាល់តែយប់ជ្រៅទៅច្រើន គឺជា មួយយប់ចំទើបចប់រឿងរបស់ខ្ញុំ ៗ ពេលនោះមានឧត្តមជនម្នាក់និយាយ ក្រោកឡើងប្រាប់ទៅតាចាស់នោះថា "តា! ឃើញទេ, ដល់ពេលដេកហើយ តានៅមិនទាន់ចែករបស់អ្វី ដែលយើងតែងធ្វើមកឲ្យយើងនៅឡើយ" ៗ លុះឮពាក្យនេះ តាចាស់ក៏ក្រោកឡើងចូលទៅក្នុងបន្ទប់ ១ ស្រាប់តែ ចេញមកវិញឃើញនាំក្តោលផើង ១០ ដាក់តម្រួតលើគ្នា សុទ្ធតែជា ផើងខៀវ គ្របដោយសំពត់ពណ៌ខៀវទាំងអស់ ហើយគាត់ដាក់ផើង ពីមួយៗ នៅពីខាងមុខឧត្តមជនទាំងនោះ ម្នាក់មួយៗ គ្រប់គ្នា ព្រមទាំង ចង្កៀងមួយៗផង ៗ

អ្នកតាំងនោះក៏តាំងបើកត្របភ្នែកឡើង ឃើញមានសុទ្ធតែផេះ ម្សៅ ធ្យូង និងល័ខ្មៅពណ៌ក្រលើប ហើយតាំងលាយច្របល់របស់តាំងនោះជាមួយគ្នា រួចតាំងយកមកផ្ទុះលាបស្រឡាបខ្លួននិងមុខមាត់ស្រមេម ស្រមាមគួរគួរមើលណាស់ ។ លុះបានប្រឡាក់ខ្មៅយ៉ាងដូច្នោះហើយ អ្នកតាំងនោះ ក៏តាំងស្រែកយំខ្សឹកខ្សួលឡើងតាំងអស់គ្នា ហើយទះកប់មុខខ្លាត់គក់ទ្រូងរបស់ខ្លួន តាំងស្រែកមិនឈប់មាត់ថា "នេះឯងហើយ ជាផលនៃការនៅទំនេរនិងការប្រព្រឹត្តខ្ជះខ្ជាយរបស់យើង" ។

ផងតាំងនោះ តាំងនាំគ្នាធ្វើការហ៊ោប៉ាំខ្សែកដូច្នេះ ស្ទើរតែអស់មួយយប់នោះ ទាល់តែអស់ចិត្តហើយទើបនាំគ្នាឈប់ រួចគាបាសក៏យកទឹកមកឲ្យអ្នកតាំងនោះលាងមុខលាងដៃចេញ តាំងសំពត់អាវក៏ប្រឡាក់ខ្ចូចអស់ គេក៏ផ្លាស់ចោលទៅ យកសំពត់ផ្សេងទៀតមកស្លៀកពាក់ ។ ការដែលសស្លាវប៉ាំខ្សែកនេះ ខ្ញុំទើបតែនឹងបានឃើញក្នុងស្រុកនេះឯងជាដំបូង តាំងពីកើតមកខ្ញុំមិនដែលឃើញមាណាប្រព្រឹត្តអំពើដូចជាឆ្កួតលលាដូច្នេះទេ ។

អ្នកស្រី, សូមឲ្យអ្នកគិតមើលចុះ ខ្លួនខ្ញុំដែលត្រូវគេយាក់ឲ្យនៅស្មៀមក្នុងទីនោះ តើខ្ញុំគឹងច្រងយ៉ាងណាទៅ! ។ ខ្ញុំស្ទើរតែហាមាត់សួរទៅតាំងយេ តាំងពាន់ផង តែព្រួកក្តុមផងតាំងនោះ បង្គាប់ឲ្យខ្ញុំនៅ

តែរបៀបតាមពាក្យប្ដេជ្ញា ខ្ញុំត្រូវត្រាំនៅដូចជារូបតុក្កតាបរទេសមួយយប់ពេញនោះ ។

ដល់ថ្ងៃស្អែកតមក យើងនាំគ្នាក្រោកឡើងដើរចេញទៅយកខ្យល់អាកាសហើយខ្ញុំបាននិយាយទៅនឹងអ្នកតាំងនោះថា "លោកម្ចាស់ថ្លៃ, ខ្ញុំសូមជំរាបអស់លោកថា ខ្ញុំសូមលើកលែងកាន់ច្បាប់ជីតីនតែង ដែលបញ្ញត្តឲ្យខ្ញុំប្រតិបត្តិតាមពីថ្ងៃល្ងាចម្សិលនោះហើយ ដ្បិតខ្ញុំមិនអាចប្រតិបត្តិតាមបានទេ ។ ខ្ញុំយល់ថាអស់លោកសុទ្ធតែជាសុភាពបុរស ហើយមានសតិបញ្ញាដ៏ទូលាយ អស់លោកក៏ល្អស្គាល់ទុកចិត្តខ្ញុំហើយ ប៉ុន្តែខ្ញុំបានឃើញអស់លោកៈធ្វើអំពើប្លែកពីអ្នកដទៃ ។ មានតែមនុស្សឆ្កួតលាណាទើបអាចធ្វើដូច្នោះបាន ទុកជាមានគ្រោះថ្នាក់ដល់ខ្លួនខ្ញុំដូចម្ដេចក៏ខ្ញុំនឹងអត់ទ្រាំនសួរអស់លោកមិនបានទេ ខ្ញុំត្រូវតែសុំសួរអស់លោកថា ហេតុអ្វីបានជាអស់លោកយកដេះមេស្រ្បូង ទីនលីតមកលាយលាបប្រឡាក់មុខមាត់ដូច្នោះ? ហើយហេតុម្ដេចបានជាអស់លោកមានតែក្នុកម្នាក់តាំងអស់គ្នា ហេតុនេះ ខ្ញុំសូមអង្វរអស់លោកឲ្យជួយបំពេញបំណង់ចង់ដឹងនេះឲ្យបាន" ។ ទុកជាខ្ញុំទទូចអង្វរសួរយ៉ាងណា អ្នកតាំងនោះនៅតែមិនឆ្លើយសោះ តាំងមិនមើលមកខ្ញុំផង ទើបត្រូវតែខ្ញុំបិទមាត់នៅស្ងៀមតទៅទៀត ។

វេលាថ្ងៃមិនទាន់អ្វីជាប់ខ្សែកខ្ទុសពីជម្ពូភាគៈ ១ ថ្ងៃគន្លងឫស្សីរៀ, ហើយតែការណាដល់វេលាបេច ព្រះ បេចរភោគអាហាររួចស្រេចហៀង ខ្លួនហើយ គាត់ក៏យកដើមពណ៌ខ្មៅទាំងនោះមកទៀត រួចពួកទុក្ខម-ផនទាំងនោះ ក៏តាំងលាបប្រឡាក់មុខខាក់តាំងស្រែកឡើងថា "នេះហើយជាផលនៃការទោទំនេររបស់យើង និងការដើរលេងឡើយជួយរបស់យើង" ។

នៅទីបំផុត ខ្ញុំមិនអាចទប់ចំណង់ចង់ដឹងរបស់ខ្ញុំតទៅទៀតបាន ទើបខ្ញុំសុំអង្វរទុក្ខមផនទាំងនោះយ៉ាងខ្លាំង ថ្វីបើពុំព្រមប្រាប់ទេ ក៏សូមឲ្យអស់លោកទាំងនោះពន្យល់ផ្លូវ ដើម្បីឲ្យខ្ញុំបានវិលត្រឡប់ទៅនគររបស់ខ្ញុំវិញ ព្រោះខ្ញុំមិនអាចទ្រាំនៅរួមជាមួយនឹងអស់លោកឲ្យបានយូរតទៅទៀតទេ ដោយខ្ញុំមិនអាចទ្រាំមើលការចំឡែកអស្ចារ្យរៀងរាល់ ៗ យប់បានតទៅទៀតដោយមិនព្រមអនុញ្ញាតឲ្យខ្ញុំបានដឹងរឿងអ្វីឡើយ ។

ខណៈនោះ ទុក្ខមផនម្នាក់ឆ្លើយតបមកខ្ញុំជំនួសអ្នកទាំងពួងថា "កុំបីអ្នកជឿនឆ្ងល់អ្វី និងសេចក្ដីប្រព្រឹត្តរបស់យើងនេះ ដែលយើងមិនព្រមទទួលអង្វរអ្នក ហេតុមកដល់វេលានេះដោយហេតុតែយើងករុ-ណាតមេត្តាចំពោះរូបអ្នក ហើយជួយអ្នកឲ្យរួចផុតពីទុក្ខសោកគ្រោះយ៉ាងដូចអ្នកបានឃើញយើងរាល់គ្នានឹងនៅតែស្រែក ៗ ប្រសិនបើអ្នកនៅតែទទូចចង់ដឹង ព្រោះជាអកុសលរបស់យើងទៀត សុំឲ្យអ្នកនិយាយតបុះ

យើងនឹងបំពេញតំណងអ្នកតាមដែលអ្នកសុំយើងឥឡូវនេះក៏បាន" ។ លើបខ្ញុំនិយាយប្រាប់ទៅវិញថា ខ្ញុំមិនមានសេចក្ដីហេតុគេខ្វះអ្វីទាំងអស់ ។ ខ្មោចផងដែលនោះនិយាយម្ដងទៀតថា " យើងនឹងប្រទានអ្នកឯងឲ្យសមនឹងការបូជាសប្បុរសរបស់អ្នក គឺត្រូវធ្វើអ្នកឲ្យធ្លាក់ក្លួតស្ដាំម្ខាងក្លួចផ្កាយើងដែរ" ។ ខ្ញុំតបទៅវិញថា មិនអ្វីទេ ខ្ញុំសុំដឹកចអស់លោកថា ប្រសិនបើត្រូវធ្លាក់នេះ ធ្លាក់មកដល់ខ្លួនខ្ញុំ មិនបន្ទោសអស់លោកទេ ហើយខ្ញុំទទួលខុសដោយខ្លួនឯង" ។ ខ្ញុំថ្លែងសេចក្ដីម្ដងទៀតថា កាលណា ខ្ញុំធ្លាក់ក្លួតម្ខាងទៅ ខ្ញុំមិនមានសង្ស័យថា ត្រូវបានទៅជាមួយនឹងអស់លោកទេ តាមដែលខ្ញុំគិតស្មាន ពីព្រោះចំនួនអស់លោកនៅពេញកន្លែងទៅហើយ ទាំងមិនអាចបន្ថែមឲ្យលើសចំនួនទៀតផង ។ ខ្ញុំប្រាប់ទៅអ្នកទាំងនោះថា ខ្ញុំសុខចិត្តតែនៅរួមជាមួយនឹងមនុស្សស្លូតត្រង់ស្លូតជាអ្នកទាំងនោះដែរ ប៉ុន្តែបើយោងតាមមិនបាន ត្រូវនៅបែកគ្នាវិញនោះត្រូវពេញចិត្តឲ្យតាមសេចក្ដីសុំរបស់ខ្ញុំវិញចុះ ។

ខ្មោចផងទាំង ១០ នាក់ លុះឃើញថាខ្ញុំដាច់ចិត្តតែកើតស្ងប់ស្ងៀមហើយ គឺចាប់យកសត្វចៀម ១ មកចាក់កសម្លាប់ ការពុះស្បែកចេញហើយក៏យកកាំបិតដែលប្រើការនោះមកជូនខ្ញុំ ហើយប្រាប់ថា " ចូរអ្នកឯងយកកាំបិតនេះទៅប្រើការ ក្នុងកាលដែលយើងនិយាយប្រាប់អ្នកក្នុងកាលឥឡូវនេះឯង ។ ត្រូវយើងខ្ចប់ខ្លួនអ្នកនឹងស្បែកនេះហើយ

យើងនៅទៀតផាប់ រួចយើងទុកអ្នកចោលនៅកន្លែងនេះ ហើយយើងនាំគ្នាថយចេញទៅ ។ មួយស្របក់ទើបមានសត្វស្លាប ១ ជាសត្វមានរូបកាយធំសំបើម ដែលគេហៅថា សត្វរុក (ឥន្ទ្រី?) ហើរមកលើអាកាស, ហើយចាបចាប់អ្នកឯងដោយសំគាល់ថាជាសត្វចៀម រួចនាំអ្នកឡើងទៅឯអាកាស, តែយើងសុំកុំឲ្យអ្នកភិតភ័យតក់ស្លុតឲ្យសោះ សត្វនោះនឹងនាំអ្នកចុះទៅឯផែនដីវិញ ហើយនឹងដាក់អ្នកនៅលើកំពូលភ្នំណាមួយ ។ តែកាលបើអ្នកដឹងថាវាដាក់ដល់ដីហើយ ចូរអ្នកយកកាំបិតវះរបៀរស្បែកចៀមហើយអ្នកចេញមកក្រៅទៅ ។ ឯសត្វឥន្ទ្រីគ្រាន់តែក្រឡេកឃើញអ្នកភ្លាម វានឹងភិតភ័យហើរចេញទៅ ទុកឲ្យអ្នកនៅទីនោះតែម្នាក់ឯង ។ អ្នកកុំឈប់នៅត្រឹមទីនោះ ចូរអ្នកដំរើរតទៅទៀតជាបន្តទៅដល់ប្រាសាទ ១ មានទំហំធំសំបើមអស្ចារ្យ មានដំបូលប្រក់សុទ្ធតែត្បូងមាសជាប្រាសាទប្រដាប់ដោយត្បូងមរកតធំៗ នឹងពេជ្រទាំងគ្រាប់ធំៗ ទៀតជាច្រើន ។ ចូរអ្នកទៅឯទ្វារ ដែលតែងតែបើកចំហជានិច្ចហើយអ្នកដើរចូលទៅ ។ ពួកយើងដែលបាននៅក្នុងប្រាសាទនេះទាំងប៉ុន្មាន សុទ្ធតែធ្លាប់បាននៅក្នុងទីនោះមកហើយគ្រប់ៗគ្នា ។ យើងមិនបាច់ទាំងនិយាយប្រាប់អ្នកថា យើងបានឃើញរបស់អ្វីខ្លះនៅទីនោះទេ គ្រាន់ឲ្យអ្នកឯងដឹងរឿងទាំងនុ៎ះដោយខ្លួនចុះ ។ រឿងក៏ដែលយើងអាចនិយាយប្រាប់អ្នកបានយ៉ាងខ្លី គឺថារឿងនឹងហើយដែលនាំឲ្យយើងខ្វាក់ភ្នែកស្ដាំទាំង

រស់គ្នា ។ ឯរឿងការរបស់យើងតែម្នាក់ៗ សឹងពេញទៅដោយហេតុភេទយ៉ាងចំឡែកអស្ចារ្យ ហើយបើនឹងតាំងពីរឿងទាំងនេះទុកត្រូវធ្វើជាសៀវភៅ ១ យ៉ាងធំបាន ប៉ុន្តែយើងត្រូវស្ងៀមត្រឹមប៉ុណ្ណេះ មិនអាចនិយាយប្រាប់អ្នកឲ្យព្រៀនលើសពីនេះតទៅទៀតទេ ។

អ្នកស្រី, ក្នុងចំណោមមនុស្សជនទាំង ១០ នាក់នោះ មានម្នាក់បាននិយាយសារសព្ទប្រាប់ខ្ញុំដូច្នេះរួចហើយ ខ្ញុំក៏រុំខ្លួនចូលស្បែកចៀម យកកាំបិតដែលគេបានប្រគល់ឲ្យនោះទៅផង លុះខ្ញុំចូលទៅក្នុងស្បែកស៊ប់ស្ងួនហើយ អ្នកទាំងនោះក៏តាំងនាំគ្នាដេរ ស្រេចហើយទុកខ្ញុំចោលទៅពីនោះផង រួចនាំគ្នាថយចូលទៅក្នុងបន្ទប់អស់ទៅ ។ មួយស្របក់ស្រាប់តែសត្វឥន្ទ្រីហើរមកឃើញ ក៏ចាប់ចុះមកសំដៅខ្ញុំ ចាប់ខ្ញុំទាំងក្រញ៉ាំក្រចកដោយស្មានថាជាសត្វចៀម ហើយក៏នាំខ្ញុំទៅលើភ្នំ ១ ដ៏ខ្ពស់ត្រដួតត្រដឹមស្កឹមស្កៃ ។

លុះកាលដែលខ្ញុំដឹងជាក់ជាដល់ដីហើយ ខ្ញុំក៏តាំងចាប់យកកាំបិតទៅវះស្បែកចៀមដោះខ្លួនខ្ញុំចេញមកហើយ បញ្ចេញខ្លួនទៅចំពោះមុខសត្វឥន្ទ្រីៗ គ្រាន់តែក្រឡេកឃើញខ្ញុំក៏ហើរទៅយ៉ាងរហ័ស ។ ឯសត្វឥន្ទ្រីនោះជាសត្វស្លាប ១ សម្បុរស មានខ្នាតទំហំធំធាត់បញ្ហើមណាស់ ។ ឯកំពូលភ្នំនោះខ្ពង់ព្រើងណាស់ កាលចាប់ផ្ដើមដំរើវង្វាយទៅក្នុងវាលបាន ហើយតាំងយកទៅដាក់លើកំពូលភ្នំធ្វើជាចំណីអាហារ ។

ខ្ញុំខំឃ្លាតដើរសំដៅទៅរកប្រាសាទនោះ មិនឲ្យខូចពេលវេលាទេ ខ្ញុំលើកជំហានដើរវែងៗដើរទៅ ត្រឹម ១ កំណាត់ថ្ងៃក៏បានដល់ទីនោះ ខ្ញុំអាចនិយាយបានថា ប្រាសាទដែលខ្ញុំឃើញនោះ មានលំអជាងសេចក្ដីដែលគេបានពោលពណ៌នាប្រាប់ខ្ញុំនោះទៅទៀត ។ ទ្វារប្រាសាទចំហរពោលគឺបិទទេ ខ្ញុំក៏ដើរចូលទៅក្នុងទីលាន ១ មានសណ្ឋាន ៤ ជ្រុង ហើយធំទូលាយណាស់ មានទ្វារព័ទ្ធជុំវិញចំនួន ៩៩ ទ្វារ ធ្វើពីឈើខ្លឹមចន្ទន៍និងឈើកន្ធុក្រពើ ហើយមានទ្វារ ១ នោះធ្វើពីមាស ទាំងនេះនៅមិនទាន់កប់ទ្វារ ដែលមានដំណើរជាច្រើនយ៉ាងល្អចំឡែក សម្រាប់ឡើងទៅជាន់ខ្ពស់ផងទេ ហើយនៅមានទ្វារដទៃទៀតដែលខ្ញុំមិនទាន់បានឃើញ ។ ទ្វារទាំង ១០០ នោះ សម្រាប់ជាផ្លូវចូលទៅក្នុងសួនច្បារឬ ឃ្លាំងដែលដាក់ពេញទៅដោយទ្រព្យសម្បត្តិឬមួយជាកន្លែងដែលដាក់វត្ថុរបស់ដែលមើលឃើញចំឡែកៗទាំងអស់ ។

ខ្ញុំបានឃើញនៅចំពីមុខនោះមានទ្វារចំហខ្ញុំក៏ឈានជើងដើរចូលទៅក្នុងបន្ទប់ធំ ១ នៅក្នុងនោះមានស្ត្រីក្រមុំចំនួន ៤០ នាក់ អង្គុយនៅត្រៀបត្រាសុទ្ធតែមានរូបឆោមល្អឯកទាំងអស់ តាមដែលខ្ញុំនឹកស្មានទៅ ដូចជាគ្មានស្រីឯណាលើសពួកនោះទៅទៀតឡើយ ។ នាងទាំងនោះសុទ្ធតែស្លៀកពាក់សំពត់យ៉ាងថ្លៃថ្លាទាំងអស់ កាលក្រឡេកមកឃើញខ្ញុំភ្លាម ស្រាប់តែនាំគ្នាក្រោកស្រែឡើងព្រមគ្នា មិនឲ្យខ្ញុំដកបស្សូរទាន់ទេ នាងទាំង

នោះនិយាយមកកាន់ខ្ញុំ ដោយសេចក្ដីត្រេកអរណាស់ថា "ម្ចាស់ថ្ងៃដ៏ក្លាហានហើយ, អ្នកអញ្ជើញមកប្រតែហើយៗ" មានស្ត្រីម្នាក់ក្នុងចំណោមនោះ និយាយជំនួសអ្នកឯទៀតៗថា "អស់កាលយូរមកហើយដែលយើងនៅរង់ចាំអ្នកជិះសេះម្នាក់ ដូចជារូបអ្នក ទ្រង់ទ្រាយរបស់អ្នកល្អមិនឲ្យយើងស្គាល់បានថា រូបអ្នកប្រៀបដោយលក្ខណៈល្អគ្រប់យ៉ាង ល្មមឲ្យយើងកប់អានបានទាំងអស់ យើងគ្រប់គ្នាមានសង្ឃឹមថាអ្នកនឹងមិនបានឃើញអ្នកណាមួយក្នុងក្រុមយើងនេះ ដែលមិនសមគួរនឹងអ្នកសោះឡើយ" ។

លុះខ្ញុំស្រឡាំងកាំងនៅយូរដូច្នោះ ទើបស្រីទាំងនោះ បង្ខំឲ្យខ្ញុំអង្គុយលើកន្លែងមួយជាអាសនៈខ្ពស់បន្តិច នៅពីមុខអាសនៈរបស់នាងទាំងនោះ ខ្ញុំបន់ចញ្ចាក់ថា កន្លែងនោះហើយ ដែលធ្វើឲ្យខ្ញុំកើតទុក្ខក្រៀមក្រំជាទម្ងន់នៅវេលាក្រោយមក ។ ស្ត្រីទាំងនោះនិយាយមកកាន់ខ្ញុំថា "កន្លែងនេះជាកន្លែងរបស់អ្នក តាំងពីឥឡូវនេះទៅ យើងត្រូវទុកអ្នកជាគ្រូត្រូវម្ចាស់ថ្ងៃនៃយើង ជាចៅហ្វាយរបស់យើង ជាចៅក្រមរបស់យើង យើងគ្រប់គ្នាជាទាសីរបស់អ្នក ប្រើខ្លួនតាមចិត្តលោចសេចក្ដីបង្គាប់អំពីអ្នកទាំងអស់គ្នា" ។

អ្នកស្រី, នាងកញ្ញានោះនេះ ខ្ញុំនឹកឆ្ងល់ចិត្តណាស់ អំពីការធ្វើកិច្ចប្រណិប័តន៍របស់ស្ត្រីប្រុសស្រស់ទាំងនោះចំពោះមកលើខ្ញុំ និយាយ

មិនបានថាមិនត្រូវ គឺនាងមួយយកទឹកក្តៅមកលាងជើងឲ្យខ្ញុំ នាងម្នាក់ទៀតយកទឹកគប់ខ្ទឹមចន្ទន៍មកបាក់លើដៃខ្ញុំ ពួកនាងខ្លះទៀតនាំគ្នាលើកយកអាហារភោជនយ៉ាងឆ្ងាញ់ពិសាមកឲ្យខ្ញុំ មានពួកនាងខ្លះទៀតយកកែវចាក់ស្រាយ៉ាងឆ្ងាញ់ពិសាហុចមកឲ្យខ្ញុំ ហើយស្រីទាំងអស់នោះ សុទ្ធតែមានរបៀបរបបឥតគួរ មានលំនាំញញែងញញឹមគួរឲ្យចាប់ចិត្តស្នេហា ។ ឯខ្ញុំក៏តាំងផឹកទឹកបរិភោគយ៉ាងស្កប់ស្កល់ លុះរួចកិច្ចបរិភោគហើយ ពួកស្ត្រីទាំងនោះក៏នាំគ្នាមកអង្គុយចោមរោមនៅជុំវិញខ្លួនខ្ញុំ សុំឲ្យខ្ញុំនិយាយអំពីរឿងដំណើររបស់ខ្ញុំ ខ្ញុំក៏តាំងចាប់និយាយរឿងថ្មើរទេសរបស់ខ្ញុំជាលំដាប់ហូរហែរហូតដល់ចូលយប់ស្ងាត់ ។

លុះខ្ញុំដំណាលរឿងការរបស់ខ្ញុំ ឲ្យស្រីទាំង ៤០ នាក់ស្តាប់ចប់ហើយនោះមានពួកស្ត្រីខ្លះដែលអង្គុយនៅជិតខ្ញុំ ក៏នៅតែនិយាយសន្ទនាជាមួយនឹងខ្ញុំ នៅវេលានោះ មានពួកស្ត្រីខ្លះទៀតឃើញថាយប់ហើយ ក៏នាំគ្នាក្រោកទៅយកទៀនមកអុជ ហើយបាននាំគ្នាលើកយកទៀន ១ ដុំយ៉ាងធំគួរឲ្យអស្ចារ្យ ដែលស្រីទាំងនោះចាក់ចែងធ្វើឡើងសម្រាប់អុជបំភ្លឺឲ្យមានរបៀបរៀបរយគួរឲ្យគេសរសើរពន់ពេក ។

មានស្ត្រី ៣ ពួកទៀត នាំគ្នារៀបតុដាក់ផ្លែឈើក្រៀម, ត្រណាប់ទំនេរគ្រឿងផឹកមានស្រាផ្សេងៗ យ៉ាងល្អជាច្រើនមុខ មាន ១ ពួកទៀតរៀបគ្រឿងភ្លេងតូរ្យតន្ត្រី ។ កាលណារៀបរួចស្រេចសព្វគ្រប់ហើយ

ហើយស្ត្រីទាំងនោះអញ្ជើញខ្ញុំទៅតុអាហារ ។ នាងទាំងនោះអង្គុយជាមួយនឹងខ្ញុំនៅទីនោះអស់មួយស្របក់ធំ ។ ហើយពួកនាងខ្លះចាប់លេងភ្លេង ហើយនាំស្រែកច្រៀងរម្យទៅជាមួយនឹងសូរភ្លេងយ៉ាងពិរោះ ។ នាងពួកនាងខ្លះទៀតលោតប៉ោងផ្អក់ជាគូៗ គ្នា ម្ដង ១ គូ ។ គួរឲ្យពិតពិលរមិលមើលណាស់ ។

លុះវេលាអធ្រាត្រទៅ ពួកក្រុមក្បួនសប្បាយទាំងឡាយក៏ផុតអស់ទៅ ។ វេលានោះ មានស្ត្រីម្នាក់បាននិយាយនឹងខ្ញុំថា "អ្នកមានសេចក្ដីនឿយហត់តាមផ្លូវមកប្រែង ពីឡូវនេះ ដល់ពេលអ្នកអញ្ជើញទៅសម្រាកខាងហើយ ទីបន្ទប់ដេករបស់អ្នកគេបានរៀបចំស្រេចហើយ ប៉ុន្តែមុននឹងអ្នកចូលទៅសម្រាកក្នុងទីនោះ សូមឲ្យអ្នកជ្រើសរើសក្នុងចំណោមពួកយើងទាំងអស់នេះចុះ បើអ្នកពេញចិត្តនឹងនាងណាច្រើនជាងគេ សុំឲ្យនាំយកនាងនោះទៅសម្រាកជាមួយនឹងអ្នកផងចុះ ។ វេលានោះខ្ញុំមិនដឹងជានឹងរើសយកណាទៅណាទេ ព្រោះនាងទាំងនោះ មានរូបឆោមលោមពណ៌ល្អស្មើគ្នាទាំងអស់ មានអធ្យាស្រ័យល្អ សុទ្ធតែសមគួរដល់ការគោរពរបស់ខ្ញុំ គួរខ្ញុំប្រណិប័តន៍បំរើទាំងអស់ ។

ស្ត្រីម្នាក់នោះដដែល បាននិយាយនឹងខ្ញុំឡើងវិញទៀតថា "យើងទាំងអស់គ្នាមានសេចក្ដីជឿជាក់ចុះចិត្ត លើសេចក្ដីទៀងត្រង់របស់អ្នក ហើយយើងយល់ឃើញថាខ្លាចក្រែងគេគមានការប្រច័ណ្ឌគ្នាក្នុងចំណោម

ពួកយើងនេះ សូមអ្នកកុំព្រួយឡើយ យើងសូមជំរាបអ្នកថា សេចក្ដីសុខរបស់ស្ត្រីណាក៏ដោយដែលអ្នកជ្រើសរើសយកទៅនោះ មិនធ្វើឲ្យយើងច្រណែនប្រច័ណ្ឌគ្នាឡើយ ពីព្រោះយើងមានទឹកចិត្តដូចគ្នា ហើយ-រាល់ៗថ្ងៃ យើងគង់តែបានទទួលកិត្តិយសដូចគ្នានេះម្ដងម្នាក់ៗ រហូតដល់គំរប់៤០ថ្ងៃ ទើបចាប់ផ្ដើមសាជាថ្មីឡើងវិញ ។ សូមឲ្យអ្នកជ្រើសរើសតាមចិត្ត កុំនាំឲ្យខូចពេលវេលាសម្រាកកាយ ដែលអ្នកកំពុងត្រូវការក្នុងវេលានេះឡើយ" ។

ទើបខ្ញុំត្រូវតែតាំងចិត្តខ្លួនឯងសម្រេចដាច់ខាត ក្នុងខណៈនោះហើយខ្ញុំក៏ហុចដៃទៅឲ្យស្ត្រីដែលនិយាយជំនួសអ្នកឯទៀតៗ នោះមុនគេនាងនោះក៏ហុចដៃនាំមកឲ្យខ្ញុំចាប់ ហើយគេនាំយើងទាំងពីរនាក់ទៅកាន់បន្ទប់១ យ៉ាងល្អផែក គេទុកឲ្យយើងនៅក្នុងបន្ទប់នោះតែពីរនាក់ រួចស្រីឯទៀតៗ ក៏ថយទៅកាន់ទីតាំងរៀងខ្លួនទៅ ។

ដល់ព្រឹកឡើង គ្រាន់តែខ្ញុំស្លៀកពាក់រួចស្រេច ស្រីទាំង ៣៩ នាក់ក៏នាំគ្នាចូលមកកាន់បន្ទប់ខ្ញុំ សុទ្ធតែពាក់តែងខ្លួនប្រណីតជាងពីថ្ងៃមុន ។ ពួកនាងទាំងនោះក៏នាំគ្នាជំរាបសួរខ្ញុំ សួរពីសុខទុក្ខរបស់ខ្ញុំរួចក៏នាំខ្ញុំទៅកន្លែងងូតទឹក ហើយតាំងដុសលាងខ្លួនប្រាណឲ្យខ្ញុំ ហើយផ្គត់ផ្គង់ប្រណិប័តន៍សព្វគ្រប់តាមដែលគេត្រូវការ រួចខ្ញុំក៏ចេញពីនោះទៅ

ហើយនាងទាំងនោះក៏នាំយកសំពត់អាវមកជូនខ្ញុំ សុទ្ធសឹងល្អប្លែក ជាងពីថ្ងៃ ១ នោះទៅទៀត ។

យើងរាល់គ្នា ស្ទើរតែទៅជាប់ចិត្តគ្នា ១ ថ្ងៃនោះ លុះដល់ពេលទៅដេក នាងទាំងនោះក៏និយាយសុំឲ្យជ្រើសរើសក្នុងនាង ដើម្បីឲ្យទៅរួមដំណេកជាមួយនឹងខ្ញុំ ។ អ្នកស្រី ខ្ញុំមិនបាច់ដកប្រាប់អ្នកស្រីអំពីរឿងពិតផ្សេង ៗ នោះទេ ខ្ញុំសុំជំរាបអ្នកស្រីថា ខ្ញុំបានទៅរួមជាមួយនឹងស្ត្រីទាំង៤០នាក់ ដោយទទួលនាងទាំងនោះម្នាក់ ៗ មករួមដំណេកជាមួយនឹងខ្ញុំ ហើយពេលសំកាលកំណត់នេះ ជីវិតខ្ញុំផុតជាប់ទៅដោយកាមគុណយ៉ាងស្កប់ស្កល់ ឥតមានផុតរលោសអ្វីបន្តិចឡើយ ។

លុះរស់នៅជាច់ឆ្នាំ (មិននាំឲ្យខ្ញុំធុញប្លែកអ្វីទេ) ក្នុងវេលាព្រឹក ១ ស្រាប់តែស្រីទាំង ៤០ នាក់ មិនបានសំដែងសេចក្ដីរីករាយស្រស់ស្រាយ ដូចធម្មតាបេតុផង មិនបានស្រស់ស្រាយសប្បាយយ៉ាងណា ៗ ទេ នាំគ្នាចូលមកលាខ្ញុំ សុទ្ធតែមានបាល់ទាំងសងខាងដោតទៅដោយទឹកភ្នែកទៅវិញ ។ នាងទាំងនោះចូលមកឱបខ្ញុំដោយស្នេហាម្នាក់ ៗ ស្រាប់តែនិយាយប្រាប់ខ្ញុំថា "លាសិនហើយ! ក្សត្រថ្លៃសំឡាញ់ សូមក្រាបលាសិនហើយ! យើងទាំងអស់គ្នា ត្រូវចេញចាកចោលព្រះអង្គហើយ" ។ ខ្ញុំក៏សួរទៅស្ត្រីទាំងនោះថា "ខ្ញុំសុំពោលអាងតាងព្រះនាមរបស់ព្រះ ឱនាងល្អរបស់ខ្ញុំអើយ! សូមឲ្យនាងនិយាយប្រាប់ខ្ញុំ

ប្រសិនបើខ្ញុំអាចជួយដោះទុក្ខរបស់នាងបាន ឬមួយបើជំនួយរបស់ខ្ញុំមិនជាឥតប្រយោជន៍សម្រាប់នាងរាល់គ្នា" ។ នាងទាំងនោះមិននិយាយប្រាប់ខ្ញុំឲ្យជាក់ច្បាស់ទេ តែបែរជានិយាយថា "យើងរាល់គ្នាលែងបានឃើញ បានស្គាល់ទ្រង់តទៅទៀតហើយ មានចំនួនអ្នកជិះសេះជាច្រើននាក់ មុនទ្រង់នេះដែលបានចូលមកចួបនឹងយើង ហើយសុទ្ធតែបានទទួលការផ្តេកផ្តិតស្នេហា អំពីយើងរាល់គ្នាដូចជាទ្រង់ដែរ ។ យើងរាល់គ្នាមិនដឹងជាធ្វើដូចម្តេច កុំឲ្យគ្រាត់ប្រាសចាកទ្រង់ទៅបានឡើយ" ។ លុះនាងទាំងនោះនិយាយដូច្នេះហើយ ក៏នាំគ្នាយំខ្សឹកខ្សួលយ៉ាងគួរណាចអាណិតទៀងទាំងអស់គ្នា ។

ខ្ញុំនិយាយសួរទៅទៀតថា "ម្នាលនាងសំឡាញ់ទាំងឡាយ សុំកុំយំសោកថ្វី នាងទាំងឡាយកុំធ្វើឲ្យខ្ញុំក្រៀមក្រំជាងនេះទៅទៀតឡើយ អាណិតប្រាប់ខ្ញុំអំពីហេតុនៃសេចក្តីទុក្ខរបស់នាងឲ្យខ្ញុំបានដឹងផង ។ ស្ត្រីទាំងនោះតបមកខ្ញុំថា អនិច្ចាអើយ! នៅមានហេតុអ្វីផ្សេងទៀត ដែលអាចធ្វើឲ្យយើងមានទុក្ខព្រួយ ដែលត្រូវតែយើងរាល់គ្នាតាំងព្រាត់ប្រាសចាកទ្រង់? ប្រហែលជាយើងលែងបានជួបនឹងទ្រង់តទៅទៀត ប្រសិនបើទ្រង់ចង់បញ្ជាក់ហេតុនោះ ប្រសិនបើហេតុនោះល្មមសមគួរដល់ទ្រង់ជួបប្រទះមែន នោះមុខជាលែងជួបប្រទះនឹងយើងរាល់គ្នា ។ ខ្ញុំឆ្លើយទៀតថា "នាងទាំងឡាយ ខ្ញុំមិនយល់សោះអំពីរឿងដែលនាង

និយាយនោះ ខ្ញុំសុំឲ្យនាងនិយាយប្រាប់ខ្ញុំឲ្យជាក់ច្បាស់ជាងនេះ ។ ទើបនាងម្នាក់និយាយឡើងថា "ប្រពៃហើយទ្រង់, ដើម្បីធ្វើឲ្យទ្រង់សព្វព្រះទ័យ យើងកល់គ្នាសូមក្រាបទូលទ្រង់ថា យើងទាំងអស់គ្នាសុទ្ធតែជាក្សត្រីជាបុត្រីរបស់ស្ដេចជាច្រើនអង្គ ។ យើងនៅក្នុងវាំងនេះជាមួយគ្នាដោយសុទ្រចិត្ត ដូចទ្រង់បានទតឃើញហើយ ប៉ុន្តែលុះដល់ចុងឆ្នាំនិមួយៗ យើងត្រូវតែចេញបាត់ទៅចាកវាំងនេះក្នុងកំណត់ ៤០ ថ្ងៃ ដើម្បីធ្វើការសំខាន់ខានពុំបានឡើយ ដែលជាការមិនបើកឲ្យយើងនិយាយការសម្ងាត់នេះទេ លុះរួចកិច្ចនោះហើយ ទើបយើងត្រឡប់មកក្នុងប្រាសាទនេះវិញបានកល់គ្នា ។ ឥឡូវដាច់ឆ្នាំពីម្សិលមិញនេះហើយ ត្រូវតែយើងចេញចោលទ្រង់ទៅឥឡូវនេះឯង គឺរឿងនេះហើយដែលយើងកល់គ្នាមានសេចក្ដីក្រៀមក្រំ ។ មុនយើងចេញទៅ យើងទុកកូនសោរបស់ទ្រព្យទាំងអស់ជូនទ្រង់ ដូចជាសោទ្វារទាំង ១០០ ទ្វារ ហើយនៅក្នុងនោះ ទ្រង់នឹងបានឃើញអ្វីៗជាទីគាប់ចិត្តនិងជាទីកំសាន្តចិត្តកែអផ្សុកក្នុងកាលដែលយើងកល់គ្នាមិននៅ ។ ប៉ុន្តែដើម្បីសេចក្ដីសុខសប្បាយរបស់ទ្រង់ និងដើម្បីជាប្រយោជន៍ដល់យើងកល់គ្នាដោយឡែកផង យើងសូមផ្ដាំទ្រង់ថា កុំបីតាក់សោបើកទ្វារមាសឡើយ ។ ប្រសិនបើទ្រង់បើក មុខជាយើងកល់គ្នាខានបានជួបនឹងទ្រង់តទៅទៀត ហើយជាហេតុនាំឲ្យយើងមានទុក្ខព្រួយកាន់តែច្រើនឡើងទៀត ។ យើងមានសង្ឃឹមថា

ទ្រង់មុខជាធ្វើតាមបណ្តាំ ដែលយើងកល់គ្នាបានក្រាបទូលមកនេះ ។ ដើម្បីឲ្យទ្រង់សម្រាកព្រះអង្គបានស្រួល និងសុខសម្រាន្តក្នុងព្រះវរកាយ សូមទ្រង់ប្រយ័ត្នកុំបីធ្វេសឡើយ ។ ប្រសិនបើទ្រង់នៅតែបោះបង់ ទ្រង់ជាបឡៀក្រៃលែងទៅទៀត មុខជាទ្រង់មានកំហុសធំមិនខាន យើងកល់គ្នាសូមអង្វរទ្រង់ កុំបីធ្វើឲ្យមានកំហុសនេះឡើយ ហើយឲ្យយើងកល់គ្នាបានជួបប្រទះនឹងទ្រង់ទៀត នៅទីនេះក្នុងកំណត់ ៤០ថ្ងៃ ។ បើយើងនឹងយកសោភាមោសផាប់ទៅជាមួយនឹងយើងទៅ ការធ្វើដូច្នេះជាការមើលងាយប្រមាថដល់ក្សត្រដូចជាទ្រង់ ហាក់ដូចជាមិនទុកចិត្តនឹងការស្ងប់ស្ងៀមនឹងធឹងរបស់ទ្រង់សោះឡើយ ។

ពាក្យសំដីរបស់ក្សត្រីរូបស្រស់ៗទាំងនោះ នាំឲ្យខ្ញុំមានសេចក្តីព្រួយចិត្តជាខ្លាំង ។ ខ្ញុំក៏បានសំដែងទឹកចិត្តឲ្យឃើញថា នៅវេលាដែលកល់គ្នាមិននៅនេះ ខ្ញុំមានសេចក្តីក្រៀមក្រំចិត្តជាច្រើន ហើយសូមអរគុណដល់បណ្តាំរបស់នាងទាំងនោះ ដែលបានផ្តាំផ្ញើដោយមេត្រីចិត្ត ខ្ញុំក៏ប្រាប់ថា ខ្ញុំតាំងចិត្តនឹងធ្វើខ្លួនខ្ញុំឲ្យបានសុខសប្បាយតាមចំនងដែលអាចរកមកបានដោយខ្លួនឯង គង់ពុំនានថ្ងៃដែលយើងត្រូវតែព្រាត់ប្រាសគ្នានៅទីបំផុត ខ្ញុំបានឱបថើបក្សត្រីទាំងនោះម្តងម្នាក់ៗ គ្រប់ៗគ្នា រួចនាងទាំងនោះក៏នាំគ្នាចេញទៅ នៅតែខ្ញុំម្នាក់ឯងនៅក្នុងប្រាសាទដ៏ហោស្ថាននោះ ។

សេចក្ដីសាមគ្គីចងភ្ជាប់គ្នា សេចក្ដីស្នេហាដ៏ស្មោះស្ម័គ្រ សេចក្ដីស្រុះស្រួលមូលចិត្តនឹងគ្នា សេចក្ដីក្សេមក្សាន្តរីករាយ នោះខ្ញុំបានទទួលសេពសោយហេតុ ១ ឆ្នាំ ខ្ញុំមិនដែលមានសេចក្ដីថ្នាំងថ្នាក់អាក់អន់ចិត្តបន្តិចឡើយ នៅក្នុងប្រាសាទដ៏សុខសម្រាន្តនោះ ។ ខ្ញុំមិនដែលបានយកភ្នែកក្រឡេកគយគន់មើលស្ត្រីទាំងឡាយសឹងល្អ ៗ ចំឡែកកប់លើលោកនាមុខ ឲ្យក្រៃលែងជាងលំអោមទើតរបស់ស្ត្រីទាំងនោះ ទីងការសប្បាយចិត្តដែលបានមើលស្ត្រីទាំងនោះ យកចិត្តទុកដាក់នឹងខ្ញុំតែម្នាក់ប៉ុណ្ណោះ ខ្ញុំមានចិត្តក្រៀមក្រំសោកស្ដាយ ដែលស្ត្រីទាំងនោះកោងចេញពេលខ្ញុំទៅ ហើយក្នុងកំណត់ ៤០ ថ្ងៃដែលស្ត្រីទាំងនោះមិននៅ ក៏ប្រាកដដល់ចិត្តគំនិតរបស់ខ្ញុំ ហាក់ដូចជាយូរណាស់ដល់ ១០០ ឆ្នាំតែម្ដង ។

ខ្ញុំមិនភ្លេចពាក្យបណ្ដាំដ៏សំខាន់ ដែលស្ត្រីទាំងនោះបាននិយាយនឹងខ្ញុំ គឺហាមប្រាមយ៉ាងដាច់ខាត កុំឲ្យខ្ញុំបើកទ្វារមាស ។ ទើបខ្ញុំយកកូនសោរបស់ទ្វារទាំង ១០០ ដែលគេដាក់រៀបរៀងមានរបៀបរៀបរយល្អ ទើបខ្ញុំយកកូនសោទី ១ ទៅបើកទ្វារដំបូង ហើយខ្ញុំដើរចូលទៅក្នុងសួនច្បារនោះ ។ ក្នុងសួននេះមានសុទ្ធតែឈើផ្លែ សឹងមានផ្លែដេរ-ដាសស្មេតស្អុះព្រៀនដាតនេក ខ្ញុំស្មានថា ក្នុងពិភពលោកនេះមិនមានកន្លែងណាយកមកប្រៀបផ្ទឹមបានឡើយ ។ សូម្បីក្នុងសាសនា

យើងដែលបាននិយាយដំណាលពីសួនស្ថានសួគ៌ ថាប្រកបដោយឈើផ្លែល្អស្អាតយ៉ាងណា គង់តែមិនវិសេសជាងទីនុះឡើយ ។ ឈើផ្លែទាំងនោះ ប្រកបដោយដើមត្រង់លំពេញមានរបៀបរៀបរយល្អ មានទំហំដើមប៉ុនៗគ្នា ខាងកំពស់ស្មើគ្នាមានផ្លែធ្ងន់ៗ ច្រើនដាសពេកណាស់ តាំងពីកើតមកខ្ញុំមិនដែលប្រទះឃើញឈើផ្លែមានសភាពដូច្នេះឡើយ កាលបើពេលដែលក្រឡេកមើលទៅ គួរឲ្យត្រជាក់ភ្នែកកើតចិត្តរីករាយជាពន់ពេកណាស់ ។ អ្នកស្រី, ខ្ញុំសូមជំរាបថា នៅទីសួននោះ មានព្រែកជីកខ្វាត់ខ្វែង មានរបៀបរៀបរយទាំងអស់ នាំបង្កើតជាផ្លូវទឹកមានចំនួនគប់គ្រាន់ ល្មមឲ្យដើមឈើទាំងនោះស្រូបជញ្ជក់យកជាតិទឹកជាល្អយកទៅជប់លៀងដើមនឹងឫស នាំបង្កើតជាផ្លែផ្កាយ៉ាងស្កុកស្គមតាមរដូវកាល ឯចំនួនផ្លែក្នុង១ដើមៗនោះមានច្រើនណាស់ មើលឃើញទុំក្រហមព្រាលជាទិច ស្ទើតែរកស្លឹកគ្មាន ហើយសុទ្ធតែផ្លែស ៗ ល្អទាំងអស់ ។ អ្នកស្រី, ខ្ញុំតាំងដើរតែយកន់ទីទៀននោះមិនចេះផ្អែតឆ្អន់សោះ ក្រូចឃ្វាយក្រូចទឹកមិនខកឃ្លានឡើយ បើកុំតែខ្ញុំជាអ្នកមានគំនិតគិតគូរស្រេចជាមុន កុំអីខ្ញុំចេញពាកទីនោះពុំរួចឡើយ លុះខ្ញុំត្រឡប់ចេញមកហើយក៏បិទទ្វារចាក់សោរទៅវិញ ទើបខ្ញុំចាក់សោរបើកទ្វារមួយបែកទៅទៀត ។ (មានត)

# មិត្រសំឡាញ់ទុច្ចរិតគ្នា

មានបុរសពីរនាក់ឈ្មោះគោត ១ ឈ្មោះផៃ ១ ជាមិត្រភក្តិរាប់អានគ្នាទៅវិញទៅមក ។ លុះថ្ងៃមួយ ផៃខ្វះប្រាក់ចាយក៏ទៅនិយាយសូមខ្ចីប្រាក់គោតចំនួន ៥០០០០ សិន; គោតក៏ព្រមឲ្យគេប្រើ ប៉ុន្តែនិយាយសូមឲ្យផៃធ្វើសំបុត្រចុះហត្ថលេខាជាគ្រឿងសំគាល់ទុកលើផៃខ្លួន ទើបប្រគល់ប្រាក់ឲ្យ ។ ផៃក៏យល់ព្រមតាមរួចហើយត្រឡប់ទៅផ្ទះវិញ, ធ្វើសំបុត្រចុះហត្ថលេខាតែម្នាក់ឯង ហើយយកមកឲ្យគោត។ បានទទួលសំបុត្រមើលឃើញសេចក្តីសព្វគ្រប់ហើយក៏សួរទៅសំឡាញ់ថា " ហេតុដូចម្តេចក៏មិនឲ្យអ្នកស្រីជាភរិយាចុះហត្ថលេខាជាមួយផង? ការនេះមិនមែនជាធុរស្រាវអ្វីប៉ុន្មានទេ ព្រោះយើងទាំងពីរនាក់ជាមិត្រសំឡាញ់នឹងគ្នា ជួនកាលសំឡាញ់តាល់ ជួនកាលខ្ញុំតាល់ តែងតែពឹងពាក់គ្នាទៅវិញទៅមក, បើគ្រាន់តែធ្វើសំបុត្រចុះហត្ថលេខាជាក់ស្តែង ក្រែងលោជួនជាអ្នកមួយក្ស័យ អ្នកមួយរលត់ ហើយទើបបានសងគ្នាដោយស្រួលប៉ុណ្ណោះទេ តើ ខ្ញុំមិនមែនគិតរឿងដោយមិនចង់ឲ្យសំឡាញ់ខ្ចីនោះទេ ដូចយើងស្គាល់គ្នាយូរឆ្នាំស្រាប់ហើយ" ។ ផៃបានស្តាប់ហើយក៏លាសំឡាញ់ប្រញាប់ប្រញាល់ត្រឡប់ទៅផ្ទះវិញ, ឲ្យប្រពន្ធចុះហត្ថលេខាក្នុងសំបុត្រសន្យានោះថែមទៀតរួចហើយយកមកឲ្យសំឡាញ់វិញ។ គោតបានទទួលសំបុត្រហើយសំឡឹងមើលមួយស្របក់ក៏និយាយថា " សំឡាញ់ធ្វើសំបុត្រនេះ

ត្រឹមត្រូវល្អពិតប្រាកដមែនហើយ ប៉ុន្តែនៅខ្វះបន្តិចទៀតមិនទាន់ពេញ
ចិត្តខ្ញុំនៅឡើយ ” ។

ថៃ - នៅខ្វះដូចម្តេចទៀត, សំឡាញ់ពេញចិត្តយ៉ាងណាវិញ ?

គោត - ចិត្តខ្ញុំចង់ឲ្យសំឡាញ់ទិញក្រដាសមួយពុម្ពធំហើយជួលជាង
ណាដែលថៃចំណាននេះគួរយ៉ាងចំណាប់មកឲ្យគូររូបឲ្យស្អាតបាតល្អ ។

ថៃ - ចុះហេតុអ្វីក៏ចាំបាច់ឲ្យជាងគូររូបនោះ, ហើយគូររូបអ្វី ?

គោត - គូររូបយើងទាំងពីរនាក់ ព្រោះខ្ញុំយល់ឃើញយ៉ាងនេះគឺ
កាលជាន់មុនៗ មានគេមកសូមខ្ចីប្រាក់ខ្ញុំហើយមានចាំគេធ្វើសំបុត្រចុះហត្ថ-
លេខាកំណត់ថ្ងៃខែឆ្នាំនឹងចំនួនទឹកប្រាក់ ដូចជាសម្លាញ់ធ្វើនេះដែរ ប៉ុន្តែ
លុះដល់កំណត់ដែលនឹងត្រូវសងវិញនោះ ប្រែនៃកើតហេតុខាសចិត្ត
អាក់អន់មិនស្រុះស្រួលនឹងគ្នាសោះ សូម្បីតែបានប្រាក់យកមកសងវិញ
ហើយ ក៏សំដែងអាការទឹកមុខមិនស្រស់បស់ដូចជាកាលដែលខ្លួនមកសូម
ខ្ចីនោះឡើយ ដោយហេតុនេះទើបខ្ញុំគិតតែរឿងនេះជាថ្មី ចង់ឲ្យសំឡាញ់
រកក្រដាសមួយពុម្ពយ៉ាងធំ ហើយជួលជាងឲ្យគូររូបយើងទុកជាគ្រឿង
សំគាល់ទៅថ្ងៃក្រោយ គឺមុនដំបូងគូររូបសំឡាញ់ដែលមកផ្ទះខ្ញុំក្នុងថ្ងៃនេះ
ហើយធ្វើទឹកមុខញញឹមញញែមរីករាយនិយាយសូមខ្ចីប្រាក់ខ្ញុំ ទាំងគូររូប
ខ្ញុំដែលយល់ព្រមឲ្យប្រាក់ទៅសំឡាញ់ដោយសេចក្តីរីករាយដែរ ហើយ
គូររូបយើងទាំងពីរនាក់ទៀតក្នុងពេលដែលគ្រប់កំណត់ថ្ងៃ-ខែ-ឆ្នាំដែលខ្ញុំ

មិនត្រូវការប្រាក់វិញនោះ គឺទារដោយធ្វើកម្មវិញញឹមតាំងសំឡាញ់ ដែលយកប្រាក់មកសងទីទៀតនោះក៏សំដែងអាការកែកាយ ដូចជាកាលដែល មកសូមខ្ចីដូច្នោះដែរ កុំឲ្យធ្វើមុខជូរក្រញូវដូចជាមុខមនុស្សកំពុងប្រឹង ញាក់ថាថ្នាំបង់ណាមកនោះឡើយ ។

## របៀបសេពក្តីជាគតិយ៉ាងនេះ

ជាតិមនុស្សក្នុងលោក បើទើបតែជួបគោគ គាត់ថាមែនហើយ កាល ខ្ចីខ្ទះប្រាក់ លុយកាក់អ្នកអើយ មកខ្ចីគេហើយ ធ្វើមុខកែកាយ ។ ពោល ពាក្យពីរោះ អង្វរស្មានស្មោះ ឲ្យគេសប្បាយ លុះគេឲ្យមក ខ្លួនយក ទៅចាយ ចិញ្ចឹមរូបកាយ ប្តីកូនប្រពន្ធ ។ រួចហើយបំភ្លេច ចួនកាល ប្រះគេច ហាក់មិនគិតគន់ ដល់គេរំលឹក ខ្លួនទឹកមុខក្រេវ ធ្វើមុខដូច ស្អួន ចូលជាន់ថ្គាម ។ ។ ពាលតែម្ចាស់ប្រាក់ ក្តៅចិត្តចាំថាក គេចាក់ដោរ ស្តី ជាផែកគក់ ឈ្មោះភាគកើតក្តី មួយទៅជាបី អប្រិយកេ្តឈ្មោះ ។ ហេតុនេះអ្នកអើយ បើខ្ចីគេហើយ ត្រូវសងដោយស្មោះ កុំរុញរ៉ាគេទារ ហំឲ្យម៉ៃមោះ ថ្នាំកើតឈ្មោះ ពីព្រោះតែខ្លួន ។ កុំបាច់ឲ្យគេ តែតិតរេរេ គួរប្រមាំមួន ដាក់ក្នុងទីកំណត់ សងគប្រមួន គួរយ៉ាងដូច ខ្លួន កោតដែរនោះឡើយ ។

វិជ្ជាពិជិតការជា

# ឃុំគសុវត្ថិទេទី ឃួរ-អ៊ុន រៀបរៀង

(តមក)

ម្យ៉ាងទៀតពួកអសប្បុរសតែងពោលពាក្យជាទំនាស់នឹងពុទ្ធសាសនា ដូចពុទ្ធសាសនាថា " សត្វទាំងឡាយកាលស្លាប់ទៅហើយតែងកើតទៀត លើកតែព្រះអរហន្តចេញ " ពាក្យអសប្បុរសថា សត្វស្លាប់កើតទៀតមែន តែកុំបូលពុំថា រូបខ្មោចនោះកើតទៀត អ្នកក្រៅពីខ្មោចនោះទើបធ្វើសត្វឱ្យកើតឡើងបាន, ឧទាហរណ៍ដូចប្តីស្លាប់ទៅជាខ្មោច នេះក៏អស់មានកំណើតត្រឹមប៉ុណ្ណោះ, ចំណែកប្រពន្ធ ឬ កូនប្រុសស្រីដែលរស់នៅ កាលបើមានគូស្រករគ្នាវេលាណា រមែងមានកូនចៅជាទៅជាប់តវង្សទៅ, នេះឯងហៅថា ស្លាប់កើតទៀត, ប្រៀបដូចដើមចេកដែលគេកាត់ផ្តាច់ពីគល់ចេញហើយ ដើមនោះក៏ត្រូវតែពុករលួយទៅ, ចំណែកគល់ដែលគេកាត់ផ្តាច់នៅក្នុងផែនដីវិញឱ្យកូនដុះផុះចេញមកបាន ។ មួយទៀត ពុទ្ធសាសនាថា "ធ្វើបុណ្យបានបុណ្យ ធ្វើបាបបានបាប" ពាក្យអសប្បុរសថា ពាក្យនោះត្រូវមែន, តែផលបុណ្យផលបាបនោះមិនមែនយើងត្រូវចាំទទួលយកក្នុងលោកឯណាទេ គឺឱ្យផលតែក្នុងពេលដែលយើងកំពុងនៅរស់ បើស្លាប់ទៅហើយក៏ហើយគ្នា, គួរយ៉ាងដូចមនុស្សធ្វើចោរកម្ម, ផលកំពើនេះជាត្រូវទៅសោយទុក្ខក្នុង នរក, ប្រេត, តិរច្ឆាន,

អសុរកាយ, អបាយភូមិទាំង ៤ នេះ មិនមែននៅក្នុងលោកឯណាទេ គឺនៅតែក្នុងលោកនេះ, ចុះនរកគឺអ្វី គឺគុក, ប្រេតគឺអ្វី គឺអ្នកទោស, តិរច្ឆានគឺអ្វី គឺអ្នកទោសដែលជាប់ការប្រើឲ្យធ្វើការមិនគិតថ្លៃឈ្នួលដូចប្រើសត្វតិរច្ឆាន, អសុរកាយគឺអ្វី គឺអ្នកទោសដែលជាប់គុកហើយបង្ខំខ្លួននៅមិនងាយនឹងបានជួបឃើញមុខឡើយ ត្រូវតែឲ្យឃើញតែថ្ងៃឃើញតែខ្មោច'' ពាក្យយ៉ាងនេះជាដើម ឈ្មោះថា អសទ្ធម្មកថា, មិនតែប៉ុណ្ណោះ សូម្បីពាក្យដែលគេជេរប្រទេច ពាក្យបញ្ចុះឲ្យលួចប្លន់ ឲ្យកាប់ចាក់ជាដើម ដែលជាពាក្យនាំឲ្យធ្ងន់សេចក្ដីក្រោធ ឬឲ្យធ្ងន់សេចក្ដីអាក្រក់ដល់អ្នកស្ដាប់ នេះក៏ហៅថា អសទ្ធម្មកថា ដែរ ។ បុគ្គលឯណាបានស្ដាប់អសទ្ធម្មកថាបែបនេះ ហើយជឿកាន់យកជាប្រមាណក្នុងពេលណា ក្នុងពេលនោះ បណ្ឌិតប្រាជ្ញថា មិច្ឆាទិដ្ឋិកើតឡើងដល់បុគ្គលនោះ ។

២ — មិនធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា នេះបានដល់ការប្រើគំនិតដែលមានសន្ទានបញ្ញាមិនស៊ើតា, ដូចជាគេមិនយោមានគំនិតមិនស៊ើតា មែនពិត ធម្មតាគំនិតរបស់មនុស្សយើងដែលគិតការអ្វីមួយហើយ កាលបើមិន ២ ប្រការ គឺសន្ទានបញ្ញាមិនមានគំនិតស៊ើតាទេ គំនិតនោះឯងក៏រមែងក្លាយទៅជាមិច្ឆាទិដ្ឋិ ។

ចុះមនុស្សពួកណាដែលប្រើកំលាំងសង្ខារច្រើនជាងបញ្ញា?

មនុស្សទន់អន់ប្រាជ្ញា ប្រើកំលាំងសង្ខារច្រើនជាងបញ្ញា គឺកាលបើឮគេនិយាយអ្វី ក៏ជឿចូលចិត្តកាន់តាមយ៉ាងងាយៗ ឥតមានគិតពីខុសត្រូវ ឬសមហេតុសមផលឡើយ, បើគិតពិនិត្យការអ្វីមួយ ដែលជាហេតុហួសកំលាំងប្រាជ្ញាខ្លួន ក៏មិនហាក់សួរគេទេ ស្រាប់តែប្រកាន់ជឿតាមយោបល់ខ្លួនតែម្តង គួយ៉ាងដូចមនុស្សពួក ១ រៀនកម្មដ្ឋានទានវិធីតាំងគូផ្សំព្យញ្ជនៈ ៣៣ តួ គឺព្យញ្ជនៈតាំងពី ក ដល់ អ ផ្សំកើតបានជាលេខ ៣២ គ្រប់ៗតួ ហើយចុះសន្និដ្ឋានថា ព្យញ្ជនៈ ៣២ តួនេះ អាចបង្កើតបានជាអាការរបស់មនុស្ស ៣២ ដូចពាក្យថា "ក កើតជាកេសា សក់សោតណា ៩ លាន ខ កើតជាលោមខាង កប់ទៅបាន ៩ កោដិ" ដូច្នេះជាដើម, ចំណែកឯព្យញ្ជនៈទី ៣៣ គឺ អំ (ο) ថាអាចបង្កើតបានជាវិញ្ញាណរបស់មនុស្ស ។ ក៏សេចក្តីយល់ឃើញបែបនេះ មិនត្រូវសោះ ព្រោះអក្សរមិនមែនធ្វើមនុស្សឲ្យកើតទេ, មនុស្សយើងតើបង្កើតអក្សរឡើង សម្រាប់ប្រើជាក់ពាក្យតាមភាសារបស់ជាតិនិមួយៗ ព្រោះហេតុនោះ បើអក្សរគ្រប់សាសន៍ក្នុងលោកមិនត្រូវគ្នាដោយសណ្ឋានខ្លះ មិនត្រូវគ្នាដោយសំនៀងដែលអានខ្លះ, មិនត្រូវគ្នាដោយចំនួនខ្លះ ដូចអក្សរសម្រាប់ភាសាខ្មែរមាន ៥៤ តួ ចែកជាស្រៈ ២១ តួ ជាព្យញ្ជនៈ ៣៣ តួ, អក្សរសម្រាប់ភាសាបារាំងមាន ២៦ តួ

បែកជាស្រៈ ៦ តួ ជាព្យញ្ជនៈ ២០ តួ; បើចូលចិត្តថា អក្សរខ្មែរដែលជាព្យញ្ជនៈ ៣៣ តួ គាថបង្កើតបានជាផ្ទួនៗ ចុះអក្សរបាលីដែលជាព្យញ្ជនៈមានតែ ២០ តួ កាលណើហ្វាំងនេះ គឺជាការរបស់ជាតិបាលីមានពុះពុំពីខ្មែរគ្រប់ណាខ្លះ? បៀបមើលតែប៉ុណ្ណេះ ក៏ឃើញថា ការយល់ឃើញរបស់មនុស្សពួកនោះមិនត្រូវ ទើបហៅថា មិច្ឆាទិដ្ឋិ ។

ចុះមនុស្សពួកណា ប្រើកម្លាំងបញ្ញាប្រែនជាឯសក្ខា?

មនុស្សបានប្រាជ្ញ ប្រើកម្លាំងបញ្ញាប្រែនជាឯសក្ខា, គឺជាអ្នកមិនស្តាប់ជឿពាក្យគេគ្នាបងទេ, បើគិតតែម្នាក់ប្រែនមិនយកពាក្យគេចូលតាមគំនិតគេឡើយ, សូម្បីវិជ្ជាដែលខ្លួនរៀនរបស់ដើមកខ្លះៗ ក៏មិនយកមកជាប្រមាណនៃផ្លូវគំនិត ស៊ូជឿតាមតែតាមៈយោបល់ឈ្វេងយល់របស់ខ្លួនវិញ មនុស្សបែបនេះ, ប្រែនប្រើគំនិតខុសធំថ្មី ដែលគួរឱ-ឲ្យថាជាមិច្ឆាទិដ្ឋិ, គួយាំងដូចមនុស្ស ២ ពួក គិតឃើញថា "បានសួគ៌មិនមាន, ទេវតាមិនមាន" មនុស្ស ១ ពួកទៀតថា "បានសួគ៌ក៏មានទេវតាក៏មានដែរ" តែមិនមែនទៅឯណាទេ, គឺនៅតែក្នុងមនុស្សលោកនេះឯង. ចុះទីណាដែលគេថាជាឋានសួគ៌? ទីក្រុងធំៗ ក្នុងនគរអ្នកៗ ក្នុងប្រទេសមួយៗ ឈ្មោះថាឋានសួគ៌ ព្រោះពាក្យថា សួគ៌ៗប្រែថា "ទីកែលសម្បូណ៌ដោយអារម្មណ៍ដ៏ប្រសើរលើសទីឯទៀតៗ" ។ ចុះអ្នកណាដែលគេថាជាទេវតា? មនុស្សដែលសម្បូណ៌ដោយកាម

គុណ ៥ ហៅថា ទេវតា ព្រោះពាក្យថា ទេវតាៗ ប្រែថា "អ្នកលេងកាមគុណ" ។ គឺមនុស្សណាយល់ឃើញបែបនេះ បណ្ឌិតគប្បីជ្រាបថា មនុស្សនោះឯង ច្រើនប្រកាន់យកត្រង់ឃើញនឹងភ្នែកជាប្រមាណ, ហេតុនោះបានជាយល់ថា ឋានសួគ៌មិនមាន ឬថាមានដែរតែមិនមែននៅក្នុងទេវលោក ។ បើប្រកាន់យកតែឃើញនឹងភ្នែក ទើបថារបស់នោះៗ មានដូច្នោះ ចុះមនុស្សយើងក្នុងលោកនេះ មានច្រើនជាតិច្រើនសាសន៍ណាស់ អ្នកនោះឯងគង់មិនទាន់ឃើញមិនទាន់ស្គាល់សព្វគ្រប់ដែរ, កាលបើយ៉ាងនេះ មានតែជាតិណាសាសន៍ណាដែលអ្នកនោះមិនទាន់ឃើញ, ជាតិនោះសាសន៍នោះនឹងមិនមានក្នុងលោកនេះឬ? ដូចយ៉ាងជាតិមនុស្សក្នុងនានាប្រទេសណាមួយ កាលដែលគេមិនទាន់ចូលមកក្នុងស្រុកយើង ៗ គ្រាន់តែឮគេថា, ប្រហែលមនុស្សដែលយល់ឃើញថា "ឋានសួគ៌មិនមានឬថាមានដែរ តែមិនមែននៅឯទេវលោក" មុខជាមិនជឿពាក្យដែលគេថានោះ, បើមិនជឿថាមានជាតិមនុស្សទាំងនោះទេ គេនឹងឲ្យឈ្មោះអ្នកនោះថាដូចម្តេច? ធៀបមើលតែប៉ុណ្ណោះ ក៏គង់ឃើញថា មនុស្សដែលចូលចិត្តថា "ឋានសួគ៌មិនមាន ឬ មានដែរតែនៅក្នុងមនុស្សលោកនេះ" នោះជាគំនិតមិច្ឆាទិដ្ឋិ ។ នេះសំដែងដោយសង្ខេបតាមទេសនា, ចំណែកក្នុងគម្ពីរបកិណ្ណកថា អយោនិសោមនសិការៈ គឺការមិនធ្វើទុក

ក្នុងចិត្តដោយមុខព្រាយប្រាជ្ញានោះ មាន ៤ យ៉ាង, ក្នុងទី នេះ ខ្ញុំគ្រាន់តែលើក មកឲ្យឃើញ ដើម្បីជាគ្រឿងប្រៀបប្រាជ្ញានៃអ្នកសិក្សាបានខ្លះគឺ

១ - អនិច្ចេ និច្ចន្តិ យល់ថាទៀងក្នុងចំណែកដែលមិនទៀង

២ - ទុក្ខេ សុខន្តិ យល់ថាសុខក្នុងចំណែកជាទុក្ខ

៣ - អនត្តនិ អត្តាតិ យល់ថាខ្លួនក្នុងចំណែកដែលមិនមែនខ្លួន

៤ - អសុភេ សុភន្តិ យល់ថាល្អក្នុងចំណែកដែលមិនល្អ ។

មិច្ឆាទិដ្ឋិ កាលបើកើតមានឡើងតែងកើតដោយហេតុ ២ ប្រការនោះ ហេតុណាមួយ ដូចអធិប្បាយមកនេះឯង ។ សាធុជនកាលទទួលពិនិត្យត្រួតមើលគំនិតរបស់ខ្លួនឲ្យដឹងថា គំនិតអាត្មាអញជាប់គន្លងមនោកម្មហើយ ឬនៅឡើយទេ នោះត្រូវបង្កើតដោយ

## អង្គមិច្ឆាទិដ្ឋិ ២ ប្រការ គឺ

១ - វត្ថុនោ តថាគតាការវិបរីតតា វត្ថុដែលពិតជាទំនាស់នឹងអាការដែលខ្លួនជឿកាន់

២ - យថា ច តំ គណ្ហាតិ តថាភាវេន តស្សូបដ្ឋានំ ខ្លួនជឿកាន់នូវវត្ថុនោះថាយ៉ាងណា វត្ថុនោះក៏មិនប្រាកដយ៉ាងនោះ ។

បណ្ដាអង្គទាំង ២ ប្រការនេះ អង្គទី ១ ជាអង្គខាងក្រៅ បានដល់វត្ថុទាំងពួងក្នុងលោកដែលជារបស់ពិត គឺបើមិនទៀងក៏មិនទៀងពិត, ដែល

ជាទុក្ខក៏ជាទុក្ខពិត, ដែលមិនមែនខ្លួនក៏មិនមែនខ្លួនពិត, ដែលមិនល្អក៏មិនល្អពិតជាដើម ។ អត្ថទី ២ ជាអត្ថខាងក្នុង បានដល់គំនិតដែលប្រកាន់ចំពោះវត្ថុដែលពិតនោះថាមិនពិតវិញ គឺគំនិតដែលយល់ឃើញខុសថាជាត្រូវ, ត្រូវថាជាខុស ។ សាធុជនកាលបើពិនិត្យទៅឃើញព្រមដោយអត្ថ ២ ប្រការនេះហើយ ត្រូវប្រាកដថា ការយល់នោះជាមិច្ឆាទិដ្ឋិ ។ កាលបើមិច្ឆាទិដ្ឋិ គឺការយល់ខុសមានក្នុងសន្តានហើយការត្រិះរិះខុស, ការពោលពាក្យខុស, ការធ្វើខុស, ការចិញ្ចឹមជីវិតខុស, ព្យាយាមខុស, ការដំកល់ស្មារតីខុស, ការស្មឹងស្មាធិខុស ក៏កើតមានឡើងជាលំដាប់គ្នា ព្រោះបណ្ដាមិច្ឆត្តធម៌គឺធម៌មានសភាពខុសទាំង ៨, មិច្ឆាទិដ្ឋិនេះឯង ជាធម៌នាំមកឲ្យមិច្ឆត្តធម៌ទាំង ៧ កើតឡើងបាន ។

## មិច្ឆាទិដ្ឋិក្លាយជាសម្មាទិដ្ឋិ

មិច្ឆាទិដ្ឋិនឹងក្លាយទៅជាសម្មាទិដ្ឋិវិញបានឬទេ? បើប្រែក្លាយបាន តើប្រែប្រួលដោយហេតុប៉ុន្មានយ៉ាង? គឺអ្វីខ្លះ? ចូរអធិប្បាយមកមើល ។

ប្រែក្លាយបាន, ប្រែប្រួលដោយហេតុ ២ យ៉ាងគឺ

១- បរតោ ឃោសោ ឧស្សាហ៍ស្ដាប់សទ្ធម្មកថាអំពីបុគ្គលដទៃ

២- យោនិសោ មនសិការោ ការធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ។

ហេតុទាំង ២ ប្រការនេះ មានសេចក្ដីអធិប្បាយផ្សេងគ្នានឹងហេតុ

កើតមិច្ឆាទិដ្ឋិដូចអធិប្បាយរួចមកហើយ; តែបើទុកជាដូច្នោះ ខ្ញុំនឹងអធិប្បាយហេតុនឹងនេះ មិនឲ្យផ្ទួនសាដដែលលើសេចក្ដីមុនទេ ដើម្បីជាគ្រឿងប្រដាប់បញ្ញានៃអ្នកបានមើល ឬ បានស្ដាប់ ដូចតទៅនេះ ៗ

១- ឧស្សាហ៍ស្ដាប់សទ្ធម្មកថាអំពីបុគ្គលដទៃ, ពាក្យថា សទ្ធម្មកថា ប្រែថា "កថាជាសទ្ធម្មគឺពាក្យជាធម៌របស់សប្បុរស" ពាក្យថា បុគ្គលដទៃ សំដៅយកសប្បុរសៗ ប្រែថា "បុរសអ្នកស្ងប់ម្ងាប់" បានដល់អ្នកប្រាជ្ញមានពត់ កាយ វាចា ចិត្ត ឲ្យស្ងប់ស្ងាត់ចាកបាបធម៌ ព្រមទាំងប្រកបដោយសប្បុរសធម៌ ៧ យ៉ាងក្នុងសន្ដាន មានភាពជាអ្នកដឹងហេតុជាដើម ហៅថា សប្បុរសៗនោះឯង តែងនិយាយដឹកនាំពួកជនឲ្យជឿកម្មនិងផលរបស់កម្ម, ឲ្យជឿហេតុដែលគួរជឿ ឲ្យខ្មាសបាបឲ្យខ្ពើមអំពើទុច្ចរិត, ឲ្យតក់ស្លុតខ្លាចបាប រអាចិត្តចំពោះអំពើទុច្ចរិត, ឲ្យខំឧស្សាហ៍រៀន, ឲ្យមានសេចក្ដីព្យាយាមក្នុងកុសលធម៌ ឲ្យមានស្មារតីសេចក្ដីរឭកត្រូវ, ឲ្យមានបញ្ញាដឹងសព្វទាំងផ្លូវលោកផ្លូវធម៌គ្មានចន្លោះ មួយទៀត លោកតែងនិយាយពាក្យដែលនាំឲ្យមានប្រាថ្នាតិច, នាំឲ្យមានសន្ដោសដោយបច្ច័យតាមមានតាមបាន, នាំឲ្យស្ងាត់កាយស្ងាត់ចិត្ត នាំមិនឲ្យច្រឡូកច្រឡំដោយបក្ខពួក នាំឲ្យមានព្យាយាមរឹងប៉ឹង នាំឲ្យតាំងនៅក្នុងសីល នាំឲ្យមានសមាធិចិត្ត នាំឲ្យកើតប្រាជ្ញាស្គាល់ការណ៍

ដ៏ជ្រាលជ្រៅ នាំឲ្យធ្វើចិត្តផុតចាកកិលេស នាំឲ្យកើតការដឹងឃើញក្នុងវិមុត្តិ ពាក្យយ៉ាងនេះជាដើម ហៅថា សទ្ធម្មកថា ។

មិច្ឆាទិដ្ឋិបុគ្គល កាលបើបានចូលទៅគប់រកនឹងពួកសប្បុរសនោះ ហើយបានតាំងចិត្តប្រុងស្តាប់ធម៌លោកដោយគោរព រមែងធ្វើទិដ្ឋិឲ្យត្រង់ទៅរកផ្លូវពិត ដែលហៅថា សម្មាទិដ្ឋិ អធិប្បាយមកនេះ ត្រូវតាមទំនងអានិសង្សស្តាប់ធម៌ទី៤ថា ទិដ្ឋឹ ឧជុំ ករោតិ "អ្នកស្តាប់ធម៌រមែងធ្វើទិដ្ឋិឲ្យត្រង់" សេចក្តីនេះបង្ហាញឲ្យឃើញថា មិច្ឆាទិដ្ឋិនឹងប្រែក្លាយទៅជាសម្មាទិដ្ឋិបានដោយវិធីស្តាប់ធម៌របស់សប្បុរស ដែលហៅថា សទ្ធម្មកថា ដូចមិគារសេដ្ឋី កាលស្តាប់ធម៌ព្រះទសពលក៏បានសម្រេចសោតាបត្តិផលដល់នូវភាពជាអរិយបុគ្គលក្នុងពុទ្ធសាសនា រឿងនេះមានសំដែងរួចមកហើយ ឬក៏ដូច

## រឿងភារទ្វាជព្រាហ្មណ៍ (១)

សេចក្តីថា នាងធនញ្ជានីព្រាហ្មណី ជាប្រពន្ធរបស់ព្រាហ្មណ៍មិច្ឆាទិដ្ឋិឈ្មោះភារទ្វាជៈ ជាស្រីបានសម្រេចដល់ថ្នាក់សោតាបត្តិផល ។ នាងកណ្តាស់ក្តី ក្អកក្តី ភ្លាត់មាត់ក្តី តែងបន្លឺវាចាថា នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។ ក្នុងថ្ងៃមួយដែលជាវេលាជួបជុំព្រាហ្មណ៍មិច្ឆាទិដ្ឋិច្រើននាក់, នាងភ្លាត់មាត់បន្លឺវាចាបែបនោះឯង ។

១ មានក្នុងគម្ពីរធម្មបទដ្ឋកថា ភាគ ៨ ត្រង់ព្រាហ្មណវគ្គ ។

ភារទ្វាជព្រាហ្មណ៍ក៏ខឹង ទើបស្តីបន្ទោសថា "មេចៅដែននេះ សរសើរស្រមណ៍កំណោរគន្ធីមិនគួរសរសើរយ៉ាងនេះ, ហេងឯងចាំមើល អញនឹងទៅដេញដោលសួរគ្រូហេងឯង ក្នុងកាលឥឡូវនេះ" ថាហើយក៏ដើរចេញទៅកាន់សំណាក់ព្រះសាស្តាតែមិនថ្វាយបង្គំទេ ឈរក្នុងទីគួរមួយទូលសួរដូច្នេះថា:

កឹសុ ឃត្វា សុខំ សេតិ កឹសុ ឃត្វា ន សោចតិ
កិស្សស្ស ឯកធម្មស្ស វធំ រោចេសិ គោតម

គេសម្លាប់អ្វីដេកជាសុខ សម្លាប់អ្វីមិនសោកស្តាយ បពិត្រព្រះគោតម! ព្រះអង្គទ្រង់ពេញព្រះរាជហឫទ័យចំពោះការសម្លាប់ធម៌ណាជាធម៌ឯក ។

ព្រះសាស្តាទ្រង់ត្រាស់ដោះប្រស្នានេះ ដោយព្រះគាថាយ៉ាងនេះថា

កោធំ ឃត្វា សុខំ សេតិ កោធំ ឃត្វា ន សោចតិ
កោធស្ស វិសមូលស្ស មធុរគ្គស្ស ព្រាហ្មណ
វធំ អរិយា បសំសន្តិ តញ្ហិ ឃត្វា ន សោចតិ

គេសម្លាប់សេចក្តីក្រោធដេកជាសុខ សម្លាប់សេចក្តីក្រោធមិនសោកស្តាយ ម្នាលព្រាហ្មណ៍ ពួកអរិយៈតែងសរសើរចំពោះការសម្លាប់សេចក្តីក្រោធថាជាធម៌ឯក ដែលមានគល់លាយដោយពិស មានចុងឆ្ងាញ់ក្រៃពេក បើជនសម្លាប់សេចក្តីក្រោធនោះបាន រមែងមិនទឹកស្តាយឡើយ ។

(មាគត)

៩ ធម្មបរិយាយ

# ព្រះគ្រូមហាបទុម អាយ–ស៊ុន ក្រុមជំនុំព្រះត្រៃបិដក

រៀបរៀង (តមក)

មាតាបិតាមានឧបការគុណដល់បុត្តធីតាយ៉ាងធំធ្លាយយ៉ាងនេះ ទើបមានពាក្យពោលជានេមិត្តកនាមទុកមកដោយពុទ្ធភាសិតថា

ព្រហ្មាតិ មាតាបិតរោ បុព្វាចរិយាតិ វុច្ចរេ

អាហុនេយ្យា ច បុត្តានំ បជាយ អនុកម្បកា

សេចក្តីថា មាតាបិតាទុកជាព្រហ្មផង ជាបុព្វាចារ្យផង ជាអាហុនេយ្យបុគ្គលផង របស់បុត្តធីតា គឺជាអ្នកអនុគ្រោះបំពោះបុត្តធីតា ។ មាតាបិតាធ្វើកិច្ចចិញ្ចឹមបំរុងបុត្តធីតា ដោយសេចក្តីនឿយលំបាកយ៉ាងនេះ ទើបឈ្មោះថាជាអ្នកទ្រង់គុណដ៏ធំ បុត្តធីតាត្រូវតែធ្វើបដិការតបគុណលោកទាំងនោះកុំបីអាក់ខាន បើបុត្តធីតាប្រព្រឹត្តខុសក្នុងមាតាបិតា ហើយរមែងទទួលទោសដ៏ធ្ងន់ សមដូចគាថាថា

ឃរំ កិច្ចាករោ ចោ សោ មាតុអបចារកោ

មាតរិ មិច្ឆា ចរិត្វាន និរយំ សោ ឧបបជ្ជតិ

ឃរំ កិច្ចាករោ ចោ សោ បិតុអបចារកោ

បិតរិ មិច្ឆា ចរិត្វាន និរយំ សោ ឧបបជ្ជតិ

សេចក្ដីថា កូនប្រុសស្រីឯណាដែលមាតាបិតាបានចិញ្ចឹមមកហើយដោយសេចក្ដីលំបាក ហើយត្រឡប់ជាមិនទំនុកបំរុងចិញ្ចឹមមាតាបិតាវិញ កូនប្រុសស្រីនោះលុះស្លាប់ទៅរមែងទៅកើតក្នុងនរក ព្រោះប្រព្រឹត្តខុសចំពោះមាតាបិតា ។ ហេតុនោះបុត្តធីតាត្រូវតែគោរពប្រតិបត្តិមាតាបិតារបស់ខ្លួន ដើម្បីលើកខ្លួនឲ្យផុតចាកអបាយមាននរកជាដើម ។ កិច្ចការទំនុកបំរុងមាតាបិតានោះ ពោលដោយប្រភេទមាន ៥ ប្រការ គឺ ១- ភតោ នេ ភរិស្សាមិ កូនត្រូវតាំងចិត្តថា លោកបានចិញ្ចឹមអាត្មាអញហើយអាត្មាអញត្រូវចិញ្ចឹមលោកវិញ; ២- កិច្ចំ នេសំ ករិស្សាមិ ត្រូវធ្វើកិច្ចការរបស់លោក, ៣- កុលវំសំ ឋបេស្សាមិ ត្រូវទ្រទ្រង់តម្កល់ត្រកូលឲ្យតាំងនៅឋិតថេរចិរកាល ៤- ទាយជ្ជំ បដិបជ្ជាមិ ត្រូវប្រតិបត្តិខ្លួនឲ្យសមគួរនឹងទទួលកេរ្តិ៍មត៌ក, ៥- ទក្ខិណំ អនុប្បទស្សាមិ កាលលោកលាខន្ធទៅកាន់បរលោកហើយ ត្រូវធ្វើទក្ខិណានុប្បទានឧទ្ទិសផលជូនទៅតាមកាលគួរ ។

ក្នុងទី ១ បានដល់ការចិញ្ចឹមលោកដោយអាហារគ្រឿងបរិភោគ និងគ្រឿងឧបភោគមានសម្លៀកបំពាក់ទីដេកទីលំនៅជាដើម, ការបម្រើទាំងអម្បាលនេះ ជាកិច្ចដែលបុត្តធីតាត្រូវធ្វើចំពោះមាតាបិតាតាមឋានៈរបស់ខ្លួន ។ ទី ២ កិច្ចការងាររបស់មាតាបិតា កូនប្រុសស្រីគប្បីធ្វើដោយខ្លួនឯង កុំឲ្យលោកមានចិត្តធុញលំបាកនឹងកិច្ចនោះៗ ។ ទី ៣ ទ្រទ្រង់

ដម្រង់វង្សត្រកូលឲ្យគង់ស្ថិតស្ថេរ គឺជួយការពារកេរមត៌ករបស់លោកកុំឲ្យវិនាស ឬក៏នោះសោត ការបុណ្យកុសលឯណាមួយដែលជាកិច្ចធ្លាប់មានមកក៏ត្រូវរក្សាទុកកុំឲ្យសាបសូន្យ ។ ទី៤ ប្រព្រឹត្តខ្លួនឲ្យជាអ្នកសមគួរនឹងទទួលកេរមត៌ក គឺគោរពប្រតិបត្តិឲ្យលោកពេញចិត្តក្នុងសេចក្តីប្រព្រឹត្តិរបស់ខ្លួនដែលជាអ្នកអាចរក្សាកេរមត៌កបាន ។ ទី១ ២-៣-៤ ជានាទីរបស់បុត្រធីតា ត្រូវធ្វើចំពោះមាតាបិតា ក្នុងពេលដែលលោកនៅមានជីវិត ។ ឯទី៥ ត្រូវធ្វើក្នុងពេលដែលលោកអស់ជីវិតទៅ ដោយការធ្វើកាយវាចាចិត្តរបស់ខ្លួនឲ្យជាកុសលហើយធ្វើទក្ខិណាទានឧទ្ទិសផលជូនទៅ ។ បុគ្គលអ្នកប្រកបការបម្រើមាតាបិតាដូចបានពោលមកនេះ ឈ្មោះថាជាអ្នកធ្វើខ្លួនមិនឲ្យមានសេចក្តីក្តៅក្រោយ ហើយបណ្ឌិតតែងសរសើរថាជាអ្នកមានកតញ្ញូកតវេទិតាធម៌ តែងមានបីតិបាមោជ្ជៈប្រព្រឹត្តទៅក្នុងចិត្ត អស់យប់នឹងថ្ងៃជានិច្ចសូម្បីសម្តេចព្រះបរមសាស្តា ក៏ទ្រង់សរសើរទុកដោយគាថា ដែលមានមកក្នុងសព្រហ្មកសូត្រថា

តាយ នំ បរិចរិយាយ មាតាបិត្តូសុ បណ្ឌិតា
ឥធេវ នំ បសំសន្តិ បេច្ច សគ្គេ បមោទតិ

សេចក្តីថា បណ្ឌិតទាំងឡាយ តែងសរសើរបុគ្គលក្នុងលោកនេះ ព្រោះការទំនុកបំរុងចិញ្ចឹមមាតាបិតា បុគ្គលនោះលុះលះ

លោកនេះទៅហើយ ក៏រមែងត្រេកអររីករាយក្នុងឋានសួគ៌ ។ ព្រោះហេតុនេះបុគ្គលគួរតបស្នងដល់ឧបការគុណរបស់មាតាបិតា ដែលមានដល់ខ្លួនហើយក្នុងកាលមុន គប្បីតាំងចិត្តធ្វើបដិការតបគុណលោកដោយស្ថាន ៤ ប្រការដូចបានពោលហើយនោះឲ្យគ្រប់បរិបូណ៌, យ៉ាងនេះឯងទើបគះបញ្ចាំងសេចក្ដីសុខ - ចំរើនទីប្រយោជន៍ឲ្យសម្រេចក្នុងលោកទាំង ២ ដោយអនេកប្រការ ។

## ២– កុលេ ជេដ្ឋាបចាយនៈ

« ការប្រព្រឹត្តិឱនលំទោនចំពោះជេដ្ឋបុគ្គលក្នុងត្រកូល »

ជេដ្ឋបុគ្គល បើ ឬ វុឌ្ឍបុគ្គលសំដែងដោយប្រភេទមាន ៣ យ៉ាងគឺ ១- ជាតិវុឌ្ឍ បុគ្គលចាស់ដោយជាតិ បានដល់លោកអ្នកខ្ពង់ខ្ពស់ដោយជាតិដែលពួកជនសំគាល់ថាជាធំក្នុងលោក មានព្រះមហាក្សត្រជាដើម ២- វយវុឌ្ឍ បុគ្គលចាស់ដោយវ័យ បានដល់លោកអ្នកខ្ពង់ខ្ពស់ដោយអាយុគឺជាព្រឹទ្ធាចារ្យមានអាយុច្រើន; ៣- គុណវុឌ្ឍ បុគ្គលចាស់ដោយគុណ បានដល់អ្នកទ្រង់គុណសម្បត្តិ គឺ សេចក្ដីល្អក្នុងសន្តានមានឧបាលគុណជាដើម ។ វុឌ្ឍបុគ្គលទាំង ៣ ប្រភេទនេះ ជាអ្នកសមគួរដល់ជនអ្នកតាំងហ៊ានដោយជាតិ វ័យអាយុនិងគុណសម្បត្តិគប្បីគោរពកប់ការ ដោយអាការគ្រឹមតែសាមីចិកម្ម គឺសេចក្ដីកោតក្រែងប៉ុណ្ណោះ ក៏អាចនឹងបន្ទោបង់នូវហេតុទុក្ខនឹងភ័យ (មានត)

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះគ្រូសុវណ្ណញាណ សូរ-ហាយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកអក្សរសាស្ត្រ* — ទំព័រ

| | | |
|---|---|---|
| លោក ហេង-យ៉ាន់ | រំពួលស្នេហា (តមក) . . . . . . . . . | ១៦៨ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម | ឯកសហស្សរាត្រី ភាគទី ១០ (តមកនិងចប់) . . | ១៨៣ |
| " " " | ព្រះរាជប្រវត្តិ ព្រះបាទសម្តេចព្រះជ័យជេស្ឋា (ព្រះអង្គសូរ) . . . . . . . . . . . . | ២០៤ |

*ផ្នែកសាសនា*

| | | |
|---|---|---|
| ឃុនសុវត្ថិវេទី យូរ-អ៊ុន | មិច្ឆាទិដ្ឋិកថា (តទៅ) . . . . . . . . . | ២០៧ |
| ព្រះគ្រូមហាបទុម មាឃ-ស៊ុន | ឥន្ទ្រវត្តបរិយាយ (តមក) . . . . . . . . | ២១៩ |

[illegible]

កំពូលស្នេហា

# លោក ហេង-យ៉ាន់ រៀបរៀង

(តមក)

"បាទ! ខ្ញុំបាទជាមនុស្សអនាថាឥតគេរាប់ បើប្រសិនណាជាមិនជឿនឹងខ្លួនក៏មិនសូវជាកើតទុក្ខប៉ុន្មានដែរ, តែនេះមេឃកបង្អាប់ខ្ញុំបាទឲ្យជឿនឹងខ្លួនថាខ្ញុំបាទជាមនុស្សទុគ៌តពិត ថាហើយលោកគ្រូក៏សំឡឹងមុខណុផ-នេត្រនារី ស្រាប់តែឃើញទឹកមុខនាងសន់មួយរំពេច ទ្រង់ដូចស្រងូតទៅដោយសេចក្ដីអាណិត បបូរមាត់ទ្រង់ចំហាបន្តិច លោកគ្រូឃើញដូច្នោះក៏កាន់កាន់ស្មារតី ពុំជឿថាគិតបែបណា ទើបញញឹមឡើងមួយរំពេចដោយមិនជឿនឹងខ្លួន ក្នុងខណៈនោះ នាងញញឹមតបមកវិញហើយងាកចេញទៅ ។ ចំណែកគាថាវ្យយកដៃស្ទាបថ្ពាល់សអន្ទ័យជញ្ជឹងមួយស្របក់ប្រញាប់ដើរមុខទៀតនិយាយទៅកាន់លោកគ្រូថា "លោកគ្រូឯងកុំគិតយ៉ាងហ្នឹងខ្ញុំទុកឯងដូចជាប្អូនរបស់ខ្ញុំបង្កើត ឯងប្រាប់ខ្ញុំឲ្យបានដឹងផង ខ្ញុំមិនហាមប្រាមឲ្យ" ។

"លោកគាថាវ្យកុំព្រួយអី គ្មាននរណាគេមើលងាយខ្ញុំទេ ដែលខ្ញុំនិយាយមានដើមនោះ គឺយល់ដោយការយាងជើងកន្ទ្រីនរបស់អ្នកនោះទេតើ ប៉ុន្តែប្រហែលជាខ្ញុំកាន់ប្រឡូវដោយខ្ញុំព្រះឲតេត· អ្នកព្រួយកំសែសរស់នៅជុំវិញខ្លួនខ្ញុំ" ។

"បើដូច្នោះកុំព្រួយអី អាឡូវពិណោណូក់ខ្ញុំទៅហើយ ក្អឹមមាន គ្គាល់ផ្ទះណា គេបោះតែថែរឬទេ? បើស្គាល់ឯងហៅមកខ្ញុំមាន" ។

"ចុះរូបគ្រែវណា ខ្ញុំបោះតែបន្តិចបន្តួចដែរ?

"បើឯងបោះស្រួលណាស់ហើយ ឯងតែលមើលគ្រែលោកដេក កុំឲ្យណាផងគ្រែផ្សារព្រោះអន់អ្វីទៀន" ។

"បាទមានគី ពីព្រោះការនេះក៏នាំប្រយោជន៍ដល់ខ្លួនខ្ញុំខ្លះដែរ កាលបើខ្ញុំបានព្រួកក្មេងកាលណា ក៏បានស្រាលខ្លួនមិនសូវព្រួយពេក" ជាហើយសោកក៏ក្រោកចូលទៅតែពិណោណូក់ ពិនិត្យមើលសព្វគ្រប់ទៅ ឃើញខ្លួនបន្តិចបន្តួចល្មមនឹងតែបាន ទើបចាប់ដោះគ្រឿងប្រដាប់ទៀបចំ ជាថ្មីឲ្យស្រួលបួលឡើងវិញ លុះតែរួចស្រេចហើយសោកក៏ក្រោយគខ្លាមួលបញ្ចូលទៅវិញ ស្រាប់តែក្រឡេតទៅឃើញម្រាមដៃនាងនៅជិតនោះ ទើបបន្លឺលខ្លាទៅបោះតែរុសព្រោះតែកមិនមើល ដល់យូរពេកណាស់នេះត្រឹមធ្លាល់សំឡេងមើលតែជីនថា សោកក៏ក្រោកលាយតែគយគន់មើលដៃនាង ទើបនាងញញឹមដកដៃចេញ សោកក៏ក្រលើបមើលនាងហើយក៏អៀនអាក់មុខចុះ មួលខ្លាតាល់តែជាប់ទៅ រួចបានសាសនៃគនាងដូច្នេះ "អត់ទោសអ្នក អ្នកអញ្ជើញអង្គុយខាងណោះមួយភ្លែតសិនចុះ ចាំខ្ញុំគោះខ្ទង់លមើល តើព្រួចដីដើមទេ?" ។

លោកគ្រូនៅមុខពីយ៉ាណូក់ហើយគោះខ្ទង់មួយម្តង ៗ ឃើញថានៅ ស្រួលដូចពីដើម ទើបនឹកព្រួយចង់លេងភ្លេង ក៏យកដៃប៉ះបង្ហាត់ទៀត មើលតាមបង្អួចទៅ ឃើញពពកសក្បុសសោកឆ្ងាយទៅៗ បន្តិច... ចុង បំផុតលោកគ្រូចុចខ្ទង់មួយ ៗ ស្រាប់តែពីយ៉ាណូក់នោះចេញសូរភ្លេង ពិរោះគាប់ចិត្ត គួរឲ្យស្រណោះ ស្រណោកសំឡេងការលំយោលពន់ពេក បញ្ជាក់ឲ្យដឹងថា លោកគ្រូមានថ្វីដៃពូកែពេកណាស់ ខាងការលេងភ្លេង កាន់ពីយ៉ាណូក់ ខុសជាអាចារ្យឯកចាញ់ដែរ នាំឲ្យណាំជនទេព្រងើប មើលមុខគ្រូហើយសួរទៀប ៗ ថា "ខ្ញុំហៅសែនគួរសមអស់យ៉ាងហើយ គាត់ហ៊ាងហានៈគ្រែមប្រសៅប្រែសទីយ៍ទេ ហើយជាមនុស្សកំព្រាផង ហេតុដូចម្តេចក៏បុកពាស់ជស់ទៅជាអ្នកថ្លៃថ្នូ ៗ មួយវិញទៀតក៏គ្មានអ្នក មានគួរសម មិនចំណានខាងការលេងពីយ៉ាណូក់ដល់ម៉្លេះទេ គាត់នេះ ច្បាស់ជាកូនអ្នកមានសក្តិសក្តមហើយ មុខគាត់ក៏ស្រស់បស់សមជាមនុស្ស មានកិត្តិសំណាង ៗ

តាមខ្ញុំ ៗ យល់ដូចប្អូនដែរ តែខ្ញុំសួរទៅគាត់ថា ខ្ញុំជាមនុស្សគ្រាំថា ធំព្រាត់តម្រឹមតែប៉ុណ្ណឹង មិនបានប្រាប់តាមត្រកូលស្រុកកំណើតឲ្យច្បាស់ លាស់សោះ ៗ

ចុះបងចេះបទហ្នឹងដែរឬអ៊ី? ខ្ញុំចង់រៀនបទហ្នឹងអស់យ៉ាងហើយ ពិ ពោះមែនទេបងថា! ៗ

"ពីរោះមែនប្អូន ហើយស្នាដៃបងមិនបានចំណេះទេ តែបងនេះសោភ័ក្ត្រ ពីកមិត្តនាំមកទេតើ តែទីតាមដំណើររឿង ដល់ប្អូនរៀនបេះស្លាក់មែនទែន ទៅក៏នឹកនឹងឃើញពេះកើតបងតាមរឿងរបស់ប្អូនដូចសោភ័ក្ត្រដែរ ប្អូនកុំភ័យខ្វល់តែទីនេះទេ ឲ្យតែខំរៀនទៅ" ។

សោភ័ក្ត្រក្រោកចាកពីយ៉ាណូ អញ្ជើញនាងឲ្យលេងវិញ "អ្នកអញ្ជើញលេងក្លួនចុះ ខ្ញុំបាទតែបានស្រួលហើយ" ។

ចាះខ្ញុំអរគុណហើយ តែថាខ្ញុំមិនប្រសប់លេងក្លួនទេ ប្រហែលជាឆ្គងព្រៃងផ្លៃងណាស់ហើយមើលទៅ" ។

ទេអ្នក ! អ្នកមានប្រសាសន៍យ៉ាងនេះ ដូចជាមិនស្គាល់ស្នាដៃរបស់អ្នក ដៃអ្នកឯកហើយខាងគោះពីយ៉ាណូ រកអ្នកណាឲ្យស្មើដូចគ្មាន" ។

"កុំបញ្ជោរខ្ញុំធ្វើអី ខ្ញុំក៏ល្ងង់ហើយបានជាមករៀន" ។

"ទេអ្នក ខ្ញុំមិនបញ្ជោរអ្នកទេ ព្រោះក្លួនមិនពីរោះដូចម្ដេច កាលណាបានឃើញម្រាមដៃយ៉ាងស្រស់បែបនេះហើយ ក៏គង់តែនឹងចាប់ចិត្តជាក់ក្លួនមិនខានព្រោះ...... ។

ឯនាងចន្ទមើលមុខហើយញញឹមដង សោភ័ក្ត្រនឹកអៀនលែងហ៊ាននិយាយអ្វីតទៅទៀត នៅទ្រឹងមាត់បំបាត់ឲ្យនាងសើចទៀត សោភ័ក្ត្រស្ទាក់ស្ទើរជាក់ខ្លួនអង្គុយចុះដោយឥតពិចារណា គិតលើធាតុនៅអស់

ស្រែកយំញាំស្ទុះលោតចុះដីភ្លាម ស្ដោកក្រៀមក្រំស្មារតីភ្ញាក់ដួលគេ ចង្រ្កាក់ នាំឲ្យនាងអាក់ខានលេងភ្លេងសើចរីក ៗ កាន់តែខ្លាំងឡើង ។

នៅពេលនោះ អាចារ្យក៏ពុំងើបមើលសៀវភៅពីរបស់ខ្លួនដែរ ក៏ងើបមុខឡើងសួរនាងថា “សើចពីរឿងអ្វីហ្នឹងប្អូន ?”

នាងមិនឆ្លើយរំពៃតែសើចខ្លាំងៗឡើង អាចារ្យលាន់មាត់ថា “ហើ” ឆ្ងល់ខ្លាំងរឹងរឹតតែថែមទៀត រឿងអ្វីទៅបានជាសើចក្អាកក្អាយម៉្លេះ ស្រីស្រស់ មិនបេះមាត់មិនបេះហើយសោះណា” ។

នាងក៏ឈប់សើចម្ដងឆ្លៀតមុខទងឆ្លើយឡើងថា “អត់មានរឿងអ្វីទេ” ។

មិនដែលមានអត់រឿងអ្វីក៏សើចដែរ មិនគិតទំនៀមទៅទេ ។

នាងក៏ឡើងមុខក្រហមសំឡក់សោភ័ក្ត្រយ៉ាងខ្ញី តែសោភ័ក្ត្រញាក់មុខយ៉ាងដូច នាំឲ្យនាងអត់ទ្រាំពុំបានសើចឡើងទៀត ។ អាចារ្យធ្វើមុខមាំគំហកឡើងយ៉ាងខ្លាំង “មើលមិនរៀនទេឬអ្វី ? ប្អូនមកទីនេះគឺមករៀន សើចឬដូចម្ដេច និយាយឲ្យបងស្ដាប់បានផងមើល” ។

សោភ័ក្ត្រដូច្នោះ ក៏ខ្ញាញ់គងចិត្តតតេះបមាទកថា មិនដែលមាន គ្រាន់តែនាងសើចដក់មិនបាន ឲ្យយំទៅឬអ្វីបានត្រូវចិត្ត អាចារ្យចំផាត់ងរ៉ូវមែន នេះនាងត្រូវបន្ទោសក៏ព្រោះតែអាក្កាអញ្ជាក់ព្រលហួសគេក ប្រហែលជានាងស្អប់ហើយ ទុកម្នេយគម!

ចំណែកកណ្ដុរនេះ ត្រនាំទុំមុខពេនកូនគេទៅទៀត ជួរបេញមកជា ហៅសេនពីបាកចិត្តស្រស់យ៉ាំងហើយ លុះដល់ពេលនាងវិលទៅផ្ទះវិញ សោកក្រក៏បេញតាមក្រោយបន្ទាប់តាមឲវ៉ែវ កណ្ដុរនេះត្រដើរក្រមផ្លូវមក ឃើញផ្កាកូឡាបលូកដៃបេះ ប្រទះនឹងបន្លាតវ៉ែសែកឈួយយ៉ះ ។

នៅពេលនោះ សេបក្ដីវាបសេបក្ដីកាសមៀនរាក់បេញចាកសន្ដានសោកក្រមួយរំពេច លុះដោយចិត្តបន្ទំឈរជិតនាង បន្តនិយាយរកនាង បន្ទំបំរើនាង សោកក្រក៏សែកឡើងថា "ឈប់សិនស្ងួត ចាំខ្ញុំបេះជូន" ហើយសោកក្រក៏ស្ទុះវ្កុតទៅបេះផ្កាកូឡាបបានពីរមែក ដោយមិនបានគិតដល់បន្លាមុតដៃ ជូនផ្កាយកមកឲ្យនាង ទើបនឹកឃើញថាឯក្រោយថា "យី! អញធ្វើនេះក្ដែលណាសំទៅហើយទេតើ! ពុំគួរបើដល់ប៉ុណ្ណោះសោះ ប្រសិនបើនាងវៃជាសំឡុក ធ្វើពុំបានក៏មិនទទួលយកផ្កាដែលគាត់អញបានបេះមកឲ្យហើយ កើតក្ដាអញនឹងយកមុខទៅទុកឯណា ។

តែកណ្ដុរនេះត្រនារី ត្រឡប់ជាញញឹមទទួលយកផ្កាពីដៃសោកក្រ ព្រោះនាងមានអធ្យាស្រ័យជាទេពធីតា នឹងប្រតិយាទរ៉ាក់ចាតទំនងនេះ ដូចម្ដេចបាន បុន្តែបំផុតនាងបានពោលពាក្យដ៏ពីរោះចាប់ចិត្តដូច្នេះថា "ខ្ញុំត្រវ៉ែកផ្កា ៣ទេ យកផ្កាមួយនេះទៅចុះថាក់តែកំឡាំងនេះឲ្យផាត់" ។

កាលយើងនាំគ្នាដើរផុតទៅ ផ្កាក៏ជ្រុះអំពីដៃសោកក្រៃ តែសោកក្រៃរើសឡើងវិញ រើសទុកជាទីរលឹកឲ្យដឹងខ្លួនថាមិនមែនជាស្រីមេទេ ច្បាស់ជាបានលះលើកនាង បាននិយាយជាមួយនឹងនាង បានបេះផ្កាឲ្យនាងផ្កានេះហើយ ដែលនាងឲ្យជាកំរៃ ដែលសោកក្រៃស្ងួនទុករហូតដល់អនាគតកាល ។

* *

## វគ្គទី៤

## សេចក្ដីស្នេហាមានកំឡាំងរឹងរឹតតែខ្លាំងឡើង

"ថ្ងៃនេះ សោកក្រៃក៏បាត់មុខក្រមកអំម្ហូរនេះ? គាបារ្យថាឡើង ណុជនេត្រទ្រង់ស្រពោនមុខបន្តិចនេចមើលទៅក្រៅ ចំណែកប្អូនប្រុសរបស់នាងញាក់ស្មានាន់ ប្រឈមមុខនិយាយឡើងថា: "គាក់កាលយ តែចូលបនការៀនហើយយ៉ាងបានជាយកយូរក្រមកដល់" ។

"ឯងកុំនិយាយហានហ៊ុន" ណុជនេត្រឃាត ដូចម្ដេចក៏ដឹងថាគាត់ជក់ការៀន ពីណាប្រាប់ឯង? ប្អូនឯងឃើញច្បាស់នឹងភ្នែក? គាត់ហ៊ុនជាមនុស្សត្រឹមត្រូវល្អណាស់ ឯងស្មរបងមើលមិនជឿ" ។

"មែនអូន សោកក្រៃគំនិតមារយាទល្អណាស់ នេះច្បាស់ជាមិនស្រួលហើយ បានជាបាត់ដល់ថ្ងៃនេះ" ។ នាឡិកាវាយម៉ោង ៤ ច្បាស់ៗ សោកក្រៃក៏មិនទាន់លេចមុខមក អ្នកទាំង ៣ អង្គុយរង់ចាំដោយសេចក្ដីអៀន ដែលប្អូនណុជនេត្រជាក្មេងរំលងនៅស្ងៀមមិនបាន

ព្រឹននាទី អត់ទ្រាំចន្ទុះបង្អាប់សោកក្រមិនកើត ក៏ព្យាយាមបញ្ចេញមកថា "បងមិនជឿខ្ញុំ គាត់ដក់ហើយ បងមើលមុខគាត់ ចាំតែជ្រងទៅៗ ឃើញតែស្បែកខ្ចីស្គួន មើលតែគន្លងប៉ុណ្ណោះទៅថាមិនជក់ការកៀន កំពុតនិយាយទៅហើយ" ។

ណុជនេត្រើយចាត់ឡើងដោយកំហឹងសំឡេង "ស្មៀម" ឯងនេះ ចាត់ការក្រក់ណាស់ បេះតែបោលទោសគេផ្តេសផ្តាសទៅ ត្រាន់តែឃើញគេស្គមថាគេជក់ដែរ អញ្ចុះត្រង់រូបឯងដូចកុកនោះ តើក៏មកពីជក់ការកៀនឬអីហ៎!?

"តាមអីខ្ញុំទើបទិញនើបពីឈឺ" ។

"ចុះគាត់ៗ មិនទើបពីឈឺដែរ" ។

"បើដូច្នោះក៏ចាំទៅ ដូចម្តេចក៏ចាត់ហាក់ឲ្យខ្ញុំធ្វើអ្វី ថ្ងៃនេះបង ចង្រៃណាស់ មិនស្រួលដូចសព្វដងសោះ" ។

"ឯងកំខូចចាំ! បានជាបងបន្ទោស កុំឲ្យមាត់ពេសថែបហ៊ានទៅថ្ងៃមុខ" ។

"ឌ! គាត់ដើរមកដល់ហើយ បងសួរគាត់មើល តើគាត់ទើបនឹងចេញពីកៀមការកៀនមែនទេ? ។

"ណុជនេត្រើមុខក្រញូវជាក់ តែបួនបេសំខាន់ធ្វើព្រងើយ ។ កាចារ្យសួរឡើងថា "មេបក៏បាត់ឈ្វើរម៉េះ មិនស្រួលខ្លួនឬអ្វី?

"បាទ! ដូចជាវិលមុខបន្តិច" ។

"ខ្ញុំចាំតែឯងមក នឹងនាំទៅលេង បើឯងមិនស្រួលដូច្នោះ ឲ្យក្មេងវាជូនថ្នាំឲ្យផឹកទៅ" ។

"ចុះលោកអាចារ្យអញ្ជើញទៅណា?" ។

"ខ្ញុំជូនប្អូនខ្លះទៅកាត់សក់ មកប្អូនទៅ; ប្អូនណារុជនេត្រដើរតាមអាចារ្យទៅ លុះដល់ជិតសោភ័ត្រក៏ខ្សឹបដាក់ត្រចៀកថា "វ៉ែត្រងមិនទាន់បាន ៣ ឆ្នាំទេ ដឹងបានជាមិនស្រួលខ្លួន មិនអីទេ ចាំខ្ញុំមកវិញខ្ញុំចាវ" ណារុជនេត្រឡើងមុខក្រហម តែសោភ័ត្របែរជាញាក់ចិញ្ចើមខ្ចូលហើយញញឹមផ្សែង ។

អាចារ្យដើរដល់មាត់ទ្វារបែរមកផ្តាំណារុជនេត្រថា "ប្អូន! ប្អូននៅលេងជាមួយនឹងសោភ័ត្រចុះ ដល់ម៉ោង៩ បងត្រឡប់មកវិញទេ" ហើយក៏ដើរចេញទៅទុកឲ្យណារុជនេត្រនៅតែម្នាក់ឯងចំពោះមុខកំលោះដែលនាងពុំស្គាល់ ទើបនាងប្រញាប់ក្រោកឡើងនឹងវិលទៅផ្ទះវិញ សោភ័ត្រឃើញដូច្នោះ ទើបនិយាយឡើងថា "ប្រញាប់អញ្ជើញទៅណាអ្នក ខ្ញុំនៅអង្គុយព្រួយតែម្នាក់ឯងកំសត់ណាស់ មេត្តានៅអង្គុយលេងត្រាន់នឹងបានជជែកគ្នាពីនេះពីនោះ ឬមួយមុខខ្ញុំសាហាវណាស់ទៅឬ? បានជាអ្នកបែរគេចចេញមិនចង់នៅ?

នាងឮសូរពាក្យអង្វរយ៉ាងទន់ភ្លន់ដូច្នោះក៏អង្គុយចុះ តែក្នុងចិត្តញាប់ញ័រដោយសេចក្ដីញញើតជាក្រៃ ចិត្តចង់តែគេចចេញទៅ តែគាស់ភ្ជាប់ខ្លួនបានយ៉ាង៖ ក៏ព្រោះនៅសល់តែពីរនាក់ក្នុងបន្ទប់ពេលល្ងាចនោះឯង ។ ទំព័រសៀវភៅនៅលើតុៈ រវើកបន្តគ្នាម្ដងម្ដងៗ ដោយខ្យល់ត្រជាក់ជួយរំភើយ ពោលគឺទៅខ្សែការយោលតិច ៗ តាមកំណត់ ផ្ទៃទ្រនាប់ក្ដាបតុំហ៊ានកំរើកជើងដៃ នៅស្ងៀមតែម្ដងនឹងមិនហ៊ានបែរប្រែល មិនហ៊ានងើបមុខមើលគេ តែក្រមុំមួយស្របក់មើលឲ្យបរិវេណបន្ទប់ហើយស្ទើរតែសម្គាល់ឃើញគ្រាន់ឲ្យជួយការពារនាង ហើយនាងស្រីតែមិនហ៊ានផុតពន្លឺផង ឯម្រាមដៃនាងបង្វិលផងចាក់ការលេងទៅមក ដូចជាគ្មានទីពឹងផល់អ្វីទាំងអស់ ។

ចំណែកលោកក្រៅកើតក្នុងចិត្តពន់ពេក ទឹកស្រកផល់រូប សំឡេង ក្លិន រស សម្ផស្ស ទើបតិចហាញថា "ការគ្នាអញមានចិត្តស្នេហានាងនេះយូរក្រែលហើយ តែនាងដូចជាព្រងើយកន្តើយពុំអើពើឲ្យជឿនចិត្តសោះ ផ្ទៃនេះជាឱកាសល្អក្នុងអញនិយាយបេលចិត្តនាងមើលម្ដង តើទឹងសមដូចបំណងឬទេ តែទឹកក្រអឺលឯកដោយមិនធ្លាប់ចុះស៊ាមការផ្សាំនារីសោះ ពិតខនិយាយដោះស្រាយដូចម្ដេចទើបគួរកើតសំរើនិយាយពុះលប់ក្រោយប់ជាញ័រជើងញ័រដៃទះទ្រើកទៅវិញ ដើមទ្រូងតក់ចេញបេះដូងលោតញាំងខុសប្រក្រតី នឹងនៅស្ងៀមមិននិយាយស្ដីទៅដូចជា

មិនគួរ គំនិតនឹងសាកសួរប្រលោមលួងលោមនាងនោះ ក៏ផុះឡើងក្នុងខួរក្បាលសោភ័ក្រមួយរំពេច ក៏ខ្សឹបនោះតាំងចិត្តថា "អ្នកណាឡើយនឹងដឹងបាន ប្រហែលជាប្រកបមើលទៅ...." ទើបរលាស់សេចក្ដីខ្មាសចេញពីសន្ដាន និយាយចេញមកបានសេចក្ដីដូច្នេះ "ជាកិត្តិយសដល់ខ្ញុំពេកណាស់ ដែលបានប្រស្រ័យជាមួយនឹងអ្នកកំលោះ... អ្នកពេញចិត្តចរចាជាមួយនឹងខ្ញុំដែរឬអ្វី? សំដីរបស់សោភ័ក្រធ្ងន់ខាំងញ័រហើយរៀបៗផង ។

"ចុះនារីម៉ី ដែលខ្ញុំស្ងួតគ្ងយនៅនេះ ព្រោះហេតុប៉ុណ្ណឹងទេតើ ដោយយកខ្ញុំឲ្យនៅអង្គុយលេងគ្រាន់បានជាដៃគូ មិនពិតឬ?

សំឡេងនាងប្រាស់ៗយ៉ាងស្រួយស្រស់ . នាំឲ្យសោភ័ក្រកាំងមួយស្របក់ដោយយល់ឃើញថា នាងនាររំភើបដល់ចិត្តបន្តិចសោះ គឺនាងមិនបានស្ម័គ្រចិត្តជាមួយផង ដែលនៅទីនេះគឺដោយបង្ខំពិត ។

"បាទ! អ្នកមានប្រសាសន៍នោះក៏ត្រូវហើយ តែថាបានជាខ្ញុំសួរ ព្រោះតែនឹងអ្នកអង្គុយនៅទីនេះដោយសេចក្ដីតាល់ មិនមែនដោយចិត្តស្ម័គ្រ បានជាខ្ញុំហ៊ានផ្ដែកលេងមុននឹងប្រាស់កូនចិត្តឲ្យហេតុនោះ បើជាអ្នកពេញចិត្តនិយាយលេងជាមួយនឹងខ្ញុំមែន នោះខ្ញុំមានសេចក្ដីត្រេកអរណាស់ ព្រោះហាក់ដូចជាអ្នកមេត្តាឲ្យទឹកត្រជាក់ដល់ខ្ញុំបាទ ដែលទើបនឹងមកពីហាលថ្ងៃថ្ងូរព្រោះឯង" ។

"ខ្ញុំនេះ មិនដែលប្រព្រឹត្តឲ្យខុសអំពីចិត្តរបស់ខ្ញុំនោះទេ" នាងថាហើយក៏សំឡឹងមើលមុខសោភ័ក្រ្ត ទើបប្រែទះក្ដកក់ក្បាលក្ដៅព្រោយនូវពន្ធុសេចក្ដីស្នេហាមកកេនាង នាំឲ្យនាងនឹកខ្មាសទុនមុខយកដៃញីក្ដួនក្ដៀងដោយសេចក្ដីខ្មាស ប្អូនជាពេលនោះ ស្ងូវដើរក្មេងៗចូលមកគ្រលួញឡើង គឺប្អូនស្រីរបស់នាងមកលេង នាំឲ្យនាងរីករាយថាទឹកចិត្ត សេចក្ដីភ័យក៏តពីគ្រោះថ្នាក់ដែលត្រូវធ្លាក់មកលើនាង អំពីពារៈនៅតែពីនោកជាមួយនឹងប្រុសក់ឡោះ ទើបនាងដោះខ្លួនរើបឡើងទៅលេងលេងទៅមាត់បន្ទប់ ក្ដុករកៃតយកន់មើលធម្មជាតិ ៗ

សោភ័ក្រ្តដើរតាមក្រោយទៅឈរត្រង់មន្ទប់នោះដែរ មានក្មេងស្រីនៅជាកណ្ដាល ទើបព្រួនាងខ្សឹបៗឡើងថា "ឱហ៎កដូចជាក្មេងដ៏ពីរោះហ្ន៎!" នៅជិតមាត់បន្ទប់នេះមានដើមផ្កាផ្គរលោលក្លិនក្រអូបឈ្មុយឈ្មួយឯអាកាស ពេលលំអង់ដេរដាសពាសពេញ គពីនោះឆ្ងាយបន្តិចទៅ មានដើមអម្ពិលទឹកដៃធុំទ្រវេយោនរយោន ដើមចំប៉ាលាត្រដាងផែតទៅសនិទាន ដើមពុទ្រាមែកស្វាងញាំងនឹងផលព្រឹក្សាដ៏ទៀតៗជាច្រើន ខាងឯនាយឯណោះ មានដើមពោធិ៍មែកសាខាស្លឹកខ្ចីល្អក់ ត្របដណ្ដប់ក្ដុកាកមួយឲ្យមានម្លប់ត្រជាក់ៗ ផ្សៀងត្រចៀកស្ដាប់ទៅក៏បានឮនូវសំឡេងក្សាបក្សីច្រៀងហ៊ឺងអឺងអាប់ ចេញពីកណ្ដាលព្រៃក្បាលនោះ សោតកាមក្រសែខ្យល់បក់មក ទឹកសំឡេងនោះក៏ស្រាលចុះដាល់ជាប់

ខ្សោយទៅៗ រូបកាយណាកលទោចបាក់ទៅឆ្ងាយ សេចក្ដីស្លាប់ក៏ចុះមក សណ្ឋិតលើផ្ទៃជាតិ នាំឲ្យសោភ័ក្ត្រភ្ញាក់ខ្លួនព្រើត មុខស្រពោនចុះមួយរំពេច ហើយបន្ទូរខ្លួនទៅគេងដោយដង្ហើមខ្លួនចេញខ្សាវៗ មកថា "ពីនេះសប្បាយអីម្ល៉េះហ្ន៎! ត្រូវរបស់គេនៅរួមគ្នាសប្បាយអឹកធឹក..." ទឹកភ្នែកក៏ហូរមកលើមុខសោភ័ក្ត្រពាសពេញ ណុដនេត្រឃើញដូច្នោះក៏នឹកអាណិតខ្លោចចិត្ត ទើបព្រឺតប្រស្រីភ្នែកសួរអំពីហេតុដែលនាំឲ្យសោភ័ក្ត្រយំ ទើបសោភ័ក្ត្រនិយាយថ្លែងរឿងរ៉ាវរបស់ខ្លួន ចាប់តាំងពីឃ្លាតជាតមាតាបិតានឹងបងប្រុស កំព្រាកំព្រូនតែម្នាក់ឯងនៅកណ្ដាលស្រុកគេ រហូតដល់បានមកនៅស្រុកភ្នំពេញឲ្យនាងស្ដាប់ដោយសព្វគ្រប់ ឃើញនាងរំភើបចិត្តអាណិតដល់ប្រក់ទឹកភ្នែក ទើបនិយាយបញ្ចប់សេចក្ដីថា "ឱអ្នក! ទុកជាជីវិតរបស់ខ្ញុំសោះសូន្យដូចម្ដេចក្ដី នៅពេលដែលខ្ញុំបានជួបប្រទះអ្នកជាគ្រាដំបូង ខ្ញុំបានទទួលនឹកក្នុងចិត្តថា បើគុណបុណ្យទេព្តាជួយបណ្ដាលឲ្យអ្នកមានចិត្តមេត្តាអាសូរដល់រូបខ្ញុំបាទ ដោយអនុញ្ញាតឲ្យរួមសហាយជាមួយគ្នា ប្រហែលជាទុក្ខទាំងប៉ុន្មាន ដែលខ្ញុំបានរៀមទុកក្នុងដើមទ្រូងជាយូរមកហើយ នោះនឹងបានរសាយចេញមិនខាន ប្រាសជានឹងបានសុខដោយសារចិត្តធម៌របស់អ្នកដោយពិតឥតសង្ស័យ មកដល់ថ្ងៃនេះឃើញថា អ្នកករុណាដល់រូបខ្ញុំបាទមែន! ខ្ញុំមានសេចក្ដីត្រេកអរណាស់ៗ! ធ្វើម្ដេចបានសេចក្ដីនេះ តាំងនៅស្ថិតស្ថេររហូតកាលទៅអេះ!

ฟ่อรตาร์ ๑๕๒ →๑๕๓

ក្រាសៅក្រដួបយ៉ាងសន្ធាប់ស្រុក, ក្រវេលកម្រាលឿង, ក្រុមព្រំផ្ទៃទីង ពួកសុគុណភជាតិឯទៀតៗ យ៉ាងល្អៗ គួរពិតពិលរមិលមើល ដែលក្នុងមួយជាតិខ្ញុំនេះមិនដែលឮគេនិយាយម្ដងសោះ ។ ផងដែលជាកំណាទីង ទឹកស្រោចសត្វបក្សាបក្សីទាំងនោះសុទ្ធតែធ្វើពីត្បូងថ្មយ៉ាងឯកដ៏មានថ្លៃមួយយ៉ាងទៀត សួនសត្វនោះជាឋានស្អាតល្អណាស់, មើលទៅទំផ្ទៃសួនទាំងមូល ខ្ញុំគាប់យល់បានថា ការសំអាតសួនសត្វនោះឯង ត្រូវប្រើមនុស្សមិនតិចជាងពីមួយរយនាក់ ។ ប៉ុន្តែគ្រប់ៗពេល ពុំឃើញមានមនុស្សនៅក្នុងនោះទេ ទាំងក្នុងសួនច្បារដែលខ្ញុំនៅនោះសោត ក៏ខ្ញុំឥតឃើញគុណជាតិដែលនាំឲ្យទាស់ដល់ភ្នែកខ្ញុំសោះ ។ កាលព្រះអាទិត្យអស្តង្គតទៅហើយ ពួកបក្សាបក្សីព្រួនមីរផើរជាសំរែកព្រៀវខ្សៀវខ្ញៀវ ហោះហើរទៅទ្រនំទំសម្រាកដេកក្នុងព្រៃ ខ្លួនខ្ញុំក៏នឹកស្រងេះស្រងោចជាប់ចិត្តនឹងសូរសំឡេងបក្សាបក្សីទាំងនោះឯងពន់ពេកណាស់ ។ ខ្ញុំដើរត្រឡប់មកក្នុងផ្ទះខ្ញុំវិញ បានសម្រេចក្នុងចិត្តថា នឹងចាប់បើកទ្វារឯទៀតក្នុងថ្ងៃជាលំដាប់ទៅ លើកលែងតែទ្វារទីមួយរយចេញ ។

លុះដល់ថ្ងៃស្អែកឡើងខ្ញុំទៅបើកទ្វារទី ៤; របស់ដែលខ្ញុំបានឃើញពីថ្ងៃមុន អាចបណ្ដាលឲ្យខ្ញុំមានសេចក្ដីអស្ចារ្យចំផ្ទៃក្នុងចិត្ត ឯរបស់ដែលខ្ញុំបានឃើញក្នុងថ្ងៃនេះអាចធ្វើឲ្យខ្ញុំកើតបីតិសប្បាយរីករាយ ។ លុះខ្ញុំបើកទ្វារនោះហើយ ខ្ញុំមើលទៅឃើញមានប្រាសាទមួយ ខ្ញុំក៏ដើរទៅ

តាមទីធ្លាធំជាប់បរិវេណនៃប្រាសាទនោះ ដែលមានរបៀបកសាងយ៉ាងឆើត ដែលខ្ញុំពុំបានពន្យល់អ្នកស្រីដោយពិស្តារឡើយ, ប្រាសាទនោះមានទ្វារ ៤០ សុទ្ធតែបើកចំហទាំងអស់ ក្នុងទ្វារមួយៗ មានផ្លូវចូលបន្តជាប់ទៅនឹងឃ្លាំងធំមួយៗ ហើយឃ្លាំងធំទាំងអស់នោះពេញទៅដោយទ្រព្យសម្បត្តិច្រើនលើសលប់សុទ្ធសឹងមានថ្លៃជាទីនគរធំៗ ថែមទៀត ។ ឃ្លាំងទី ១ ដាក់ផ្ទុកពេញសុទ្ធតែគុជនិងកែវមុក្តា មានទំហំប៉ុនៗពងព្រាបជារបស់មានថ្លៃមិនអាចនឹងគណនាបាន ; ឃ្លាំងទី ២ : ពេជ្រទាំងគ្រាប់, ពេជ្រជំហៀង នឹងត្បូងទទឹម ; ឃ្លាំងទី ៣ : ត្បូងមរកត ; ឃ្លាំងទី ៤ : មាសក្តោរ ; ឃ្លាំងទី ៥ : មាសក្រាសម្រាប់ចាយ ឃ្លាំងទី ៦ : ប្រាក់ណែន ; ឃ្លាំងពីរទៀត : ប្រាក់រៀល ។ ឃ្លាំងឯទៀតៗក្រៅពីនេះពេញណែនទៅដោយកែវមណី, កែវពិទូរ្យ, កែវប្រពាឡ កែវផ្សេងទៀតគ្រប់ត្រកូលដែលយើងធ្លាប់ស្គាល់ឯទៀតៗ ដូចយ៉ាងត្បូងថ្ម, ត្បូងប៊ុតជាដើមនោះមិនបាច់និយាយឡើយ គឺច្រើនពោរពាសមិនដឹងជានឹងយកទៅឯណាអស់ ។ ក្នុងឃ្លាំងធំនីមួយៗ នោះមានឃ្លាំងតូចមួយៗ ពេញណែនណាន់តាន់តាប់ទៅដោយផ្កាថ្មទាំងឡាយ ឯផ្កាថ្មទាំងនោះមិនមែនមានត្រឹមតែមែកទេ មានទាំងគល់ដើមទាំងមូលផង ។

លុះខ្ញុំបានឃើញទ្រព្យសម្បត្តិទាំងអស់នោះហើយ ក៏មានសេចក្តីអស្ចារ្យនឹងសេចក្តីកោតស្ញប់ស្ញែងក្នុងចិត្តពន់ពេក ទើបខ្ញុំលាន់មាត់ថា

"គ្មានអ្វីប្រៀបផ្ទឹមឲ្យស្មើទេ បើទុកណាជាប្រមូលសម្បត្តិស្ដេចក្នុងសកលពិភពលោក យកមកដាក់ដំកល់តែក្នុងថ្ងៃមួយ ក៏មិនបានស្មើនឹងទ្រព្យសម្បត្តិក្នុងឃ្លាំងទាំងនោះឡើយ ផ្ញើជួបអ្នកហ្នឹងឲ្យខ្ញុំមានបុណ្យភ័ព្វនឹងបានទ្រព្យសម្បត្តិទាំងអស់នេះព្រមទាំងពួកស្ត្រីជាទីស្រឡាញ់ទាំងនោះ! ។

អ្នកស្រី! របស់ឯទៀត ៗ ដែលក្រ ៗ ហើយមានថ្លៃ ដែលខ្ញុំបានឃើញក្នុងថ្ងៃជាលំដាប់គ្នាទៅនោះ ខ្ញុំមិនអាចនឹងអធិប្បាយសាសព្ទដំណើរដោយសព្វគ្រប់បានទេ ខ្ញុំសូមដំណាលសរុបទៅតែមួយថា ក្នុងរវាង ៣៩ ថ្ងៃខ្ញុំបើកទ្វារបាន ៩៩ បានឃើញរបស់អស្ចារ្យ ដែលខ្ញុំពិតពិលរមិលមើលក្នុងទីនោះ ៗ សព្វគ្រប់ឥតសល់បន្ទប់ឡើយ នៅសល់តែទ្វារទីមួយរយដែលគេហាមមិនឲ្យខ្ញុំបើកប៉ុណ្ណោះ ។

គិតថ្ងៃតាំងពីពួកស្ត្រីប្រិមប្រិយ៍ទាំងនោះចេញទៅ រៀងមកដល់ថ្ងៃនេះជាថ្ងៃគំរប់ ៤០ គត់ ក្នុងថ្ងៃនោះឯង ប្រសិនបើខ្ញុំអាចរក្សាបញ្ញើដែលខ្ញុំត្រូវការបាន នោះខ្ញុំនឹងបានបង្ហាញអស្ចារ្យជាងមនុស្សទាំងអស់នៅវេលាដែលខ្ញុំកំពង់តែកើតទុក្ខធុញយ៉ាងនេះ ១ ថ្ងៃស្អែកឡើង ពួកស្រីទាំងនោះនឹងត្រឡប់មកដល់វិញហើយ សេចក្ដីត្រេកអររីករាយព្រោះទទួលបានជួបនឹងនាងទាំងនោះ គួរតែអាចទប់ចំណង់របស់ខ្ញុំបាន (គឺកុំបាច់ចង់ឃើញរបស់អ្វី ៗ ទៀត) ប៉ុន្តែបែរជាមិនដូច្នោះ ហេតុតែអកុសលដែលនាំឲ្យខ្ញុំក្ដៅក្រហាយស្ដាយក្រោយ មិនចេះអស់មិនចេះហើយ

គឺមារមករំផែកល្បួងដឹកនាំឲ្យខ្ញុំលុះក្នុងតណ្ហាប៉ុន្តែ ហើយក៏មិនបើកឱកាសឲ្យខ្ញុំឈប់សម្រាកសោះ បណ្តាលឲ្យខ្ញុំពើបប្រទះតែនឹងសេចក្តីទុក្ខលំបាក ដែលខ្ញុំបានតែស៊ូប្រថុយទទួលសាកល្បងមើល ។

ខ្ញុំក៏ដើរទៅបើកទ្វារដែលមានគ្រោះថ្នាក់ ដែលខ្ញុំបានទទួលពាក្យប្រដៅថា មិនត្រូវបើកសោះនោះ ខ្ញុំមិនទាន់តាំងបានឈានជើងចូលទៅផង ស្រាប់តែផ្លុំក្លិនស្អុយសាហាយ, តែក្លិនស្អុយនោះ បែរជាទំនាស់ដល់និស្ស័យចិត្តរបស់ខ្ញុំទៅវិញ គឺធ្វើឲ្យខ្ញុំវិលមុខដួលសន្លប់បាត់ស្មារតី ។ បើទុកជាដូច្នោះ ខ្ញុំគង់ភ្ញាក់ខ្លួនមានស្មារតីឡើងវិញ, នៅវេលានោះ គួរតែខ្ញុំបិទទ្វារទៅវិញហើយកុំចង់ឃើញចង់ដឹងរបស់អ្វីទៀត, តែខ្ញុំបាបេសជំនះចូលទៅតាមតែបាន ។ លុះនៅចាំពីរ-បីខណៈ ទើបមានខ្យល់ខ្លាំងបក់មកផាត់ក្លិននោះអស់ទៅ ខ្ញុំក៏បានធូរស្រាលស្រួលខ្លួនឡើងវិញដូចដើម ។

ខ្ញុំឃើញកន្លែងមួយទូលាយ, ខាងលើមានពិតានរង្វង់កោងរាងកន្ធូប ហើយផ្ទៃក្រាលខាងក្រោមប្រស់ព្រំទៅដោយថ្មម៉ាប,ក្នុងកន្លែងនោះមានទៀនមាសគាទនឹងទៀនក្រមួនជាច្រើន ឆេះភ្លឺព្រោងព្រាតបញ្ចេញក្លិនផ្សែងសាយភាយ មានតាំងបង្គៀងមាសបង្គៀងប្រាក់ដាក់ពេញទៅដោយប្រេងជីណាយដោយក្លិនគន្ធជាតិគ្រប់យ៉ាងគ្រប់បែប, របស់ទាំងអស់នោះឯង ធ្វើឲ្យខ្ញុំកាន់តែប្រឹងប្រយ័ត្នសង្កេតមើលដោយហ្មត់ចត់ទៅទៀត,

ស្រាប់តែប្រទះឃើញសេះមួយទៅស្រិល មានលំអគួរឲ្យអស្ចារ្យផង ពិតពិលរម៉ិលមើលក្នុងពិភពលោក ។ ខ្ញុំក៏ដើរចូលទៅជិតវាដើម្បីពិនិត្យមើលឲ្យជាក់លាក់ បានឃើញសេះនោះមានតែបន្ទីងបង្ហៀរធ្វើពីមាសកាន់ ហើយទីងគ្រឿងចងការយ៉ាងខ្ជំ នៅជិតខាងសេះនោះមានស្បងដាក់ពេញសុទ្ធតែស្រូវពោតសាលីនិងល្ង មានរបៀបរៀបរយយ៉ាងស្អាត ហើយខាងម្ខាងទៀតមានស្បូកដាក់ពេញដោយទឹកផ្កាកុលាប ។ ខ្ញុំក៏ចាប់ខ្សែបង្ហៀរដឹកចេញមកខាងក្រៅដែលមានពន្លឺថ្ងៃ ដើម្បីពិនិត្យមើលឲ្យច្បាស់; រួចខ្ញុំផ្លោះជិះលើខ្នងហើយខ្ញុំបង់ធ្វើឲ្យវាដើរទៅមុខ តែវានៅទ្រឹងព្រងើយឥតកំរើកសោះ ខ្ញុំក៏វាយវាមួយរំពាត់ខ្សែ, ត្រាន់តែត្រូវមួយរំពាត់ភ្លាម ស្រាប់តែវាស្រែកកញ្ជ្រៀវយ៉ាងខ្លាំងគួរស្ញែង រួចលោតហោះត្រដាងស្លាបដែលមលមុនដំបូងឥតឃើញសោះ ហើយហោះហើរទៅកណ្តាលអាកាសនភាល័យយ៉ាងឆ្ងាយសន្ធឹម, សូម្បីខ្ញុំមានសេចក្តីភិតភ័យខ្លះ ក៏ខ្ញុំភាបចប់ខ្លួនឲ្យនៅនឹងមាំមួនបាន ហើយឥតមានគ្រោះថ្នាក់ឈឺចាប់អ្វីទេ ។ សេះនោះហោះត្រឡប់ចុះមកផែនដីវិញ ហើយវាបន្ទាបដាក់ខ្លួនលើដំបូលដ៏កបរស៊ើនិងប្រាសាទមួយ, វាដិនរនៅស្ងៀមបើកឱកាសឲ្យខ្ញុំចុះពីលើខ្នងដោយស្រួលបួលសោះ ពេះតែបម្រះកញ្ច្រោលប្រាយចុះប្រាយឡើង តាលតែខ្ញុំអិលធ្លាក់ទៅខាងក្រោយ ហើយវាវាត់រលាស់កន្ទុយវាឲ្យត្រូវភ្នែកខ្ញុំខ្វាក់

ម្នាក់ ។ រឿងកំរដូចថ្ងៃមកនេះឯង ដែលនាំបណ្តាលឲ្យខ្ញុំទៅជាអ្នកខ្វាក់ម្ខាង, ខណៈនោះទើបខ្ញុំលឺនឹកឃើញចំពោះខ្លួនឯង ដល់ពាក្យដែលឧត្តមជនទាំង ១០ នាក់ប្រាប់ខ្ញុំតាំងពីដំបូង, ឯសេះនោះក៏ហោះបាត់ទៅវិញទៅ ។ ចំណែកខាងខ្ញុំកាលក្រោកឡើង មានសេចក្តីសោកសៅក្តុកក្តៅអំពីដំណើរខុសចិត្តពេក ដែលខ្លួនទំលើសស្ទើរស្ទើរតែជាប់ខ្លួនឯង (ឥតមាននរណាបង្ខំសោះ) ខ្ញុំដើរលើផ្ទៃដំបូលរាបស្មើនោះ យកដៃខ្ទប់ភ្នែកបណ្តើរ, មានសេចក្តីឈឺចាប់យ៉ាងលើសលប់ពន់ប្រមាណហើយខ្ញុំចុះមកខាងក្រោម បានឃើញបន្ទប់មួយដែលអាចឲ្យខ្ញុំចំណាំបានត្រង់ដែលមានកៅអីវែង ១០ ដាក់តំរៀបគ្នាជារង្វង់មូល កៅអីមួយទៀតត្រង់កណ្តាលខ្ពស់ជាងគេបន្តិច គឺជាប្រាសាទដែលខ្ញុំចូលមកកាលពីមុន ហើយសត្វត្រីនាំខ្ញុំយកទៅនោះឯង ។

ឧត្តមជនកំឡោះខ្វាក់ម្ខាងទាំង ១០ នាក់ មិនបាននៅក្នុងបន្ទប់នោះទេ ខ្ញុំនៅរង់ចាំគេនៅទីនោះ ។ លុះមួយស្របក់ទើបគេមកដល់ជាមួយនឹងតាចាស់ ។ អ្នកទាំងនោះបានឃើញខ្ញុំ ក៏មិនសំដែងអាការៈប្លែកអ្វីឡើយ ។ គឺធ្វើព្រងើយ ។ ទាំងដំណើរដែលខ្ញុំខ្វាក់ភ្នែកនោះ ក៏ឥតរវល់អើពើសួរសោះ, ស្រាប់តែនិយាយនឹងខ្ញុំថា «ការដែលអ្នកវិលត្រឡប់មកដល់វិញនេះ យើងរំខានចិត្តខ្លាំងណាស់ ព្រោះយើងមិនបានទទួលបដិសណ្ឋារៈគួរសម តាមដំណើរដែលយើងប៉ុនប៉ងប្រាថ្នា,

តែពួកយើងមិនមែនជាមេនាំបណ្ដាលឲ្យអ្នកឯង បានទទួលសេចក្ដីទុក្ខទោសនេះទេ » ។ ខ្ញុំតបទៅវិញថា ខ្ញុំមិនចោទប្រកាន់ទោសតែអ្វីដល់អស់លោកឡើយ គឺខ្ញុំសុខចិត្តទទួលកំហុសដោយខ្លួនឯងទាំងអស់ ។ អ្នកទាំងនោះ និយាយមកកាន់ខ្ញុំថា «ឧទាហរណ៍របស់ពួកយើង ក៏ល្មមជាបែបឲ្យអ្នកឯងយល់ដើមចមបានហើយ គឺអំពើទាំងអស់ដែលអ្នកឯងបានជួបប្រទះនោះ ពួកយើងក៏បានជួបប្រទះដូចគ្នាដែរ, យើងបានសេពសោយបិយតែគ្រប់បែបចំនួនពេញមួយឆ្នាំ ប្រសិនបើយើងកំបើកទ្វារមាសក្នុងពេលដែលពួកម្ចាស់ក្សត្រីមិននៅនោះ យើងនឹងមានភ័ព្វសំណាងបានសប្បាយដូចគ្នាតរៀងឆ្ងាយទៅទៀត ។ អ្នកឯងមិនមែនជាមនុស្សសុចរិតឆ្លាតកាន់តែជាងយើងទេ បានជាអ្នកត្រូវទទួលទោសទណ្ឌកម្មដូចយើងដែរ ។ យើងចង់ទទួលអ្នកទុកឲ្យនៅក្នុងពួកយើងនេះ ដើម្បីឲ្យធ្វើសេចក្ដីផ្ដន្ទាទោសខ្លួនដូចជាយើង ដែលយើងមិនដឹងជាកាលណានឹងបានរួចឡើយ, ប៉ុន្តែយើងបានប្រកាសប្រាប់អ្នករួចទៅហើយ អំពីដំណើរដែលឃាត់យើងក្នុងទីនេះ ។ ព្រោះហេតុនោះឯងអ្នកត្រូវរួចខ្លួន; ចូរអ្នកទៅឯក្រុងបាគដាទចុះ, ទៅដល់ទីនោះអ្នកនឹងបានជួបប្រទះនូវមនុស្សដែលអាចវិនិច្ឆ័យ អំពីជោគជ័យផលការរបស់អ្នកឯងពុំខាន ។

ពួកកុកម្មជនទាំងនោះ ពន្យល់ប្រាប់ផ្លូវខ្ញុំសព្វគ្រប់ហើយ ខ្ញុំក៏បែកឃ្លាតចេញអំពីគេទៅ ៗ ខ្ញុំឲ្យគេកោរពុកមាត់ពុកចង្ការទាំងពោមចិញ្ចើម តាមផ្លូវហើយស្លៀកពាក់ជាភេទអ្នកបួស ៗ ខ្ញុំដើរយូរណាស់ទើបបានមកដល់ក្រុងនេះក្នុងពេលយប់នាថ្ងៃនេះឯង ៗ មកដល់ត្រង់ទ្វារ ខ្ញុំបានជួបនឹងអ្នកបួសទាំងនេះដែលមានលក្ខណ៍ដូចគ្នា ហើយជាអ្នកបរទេសដូចខ្ញុំ ៗ យើងទាំង ៣ នាក់ក៏នឹកពិភាល់ចល់ខ្លាំងណាស់ ត្រង់ដែលយើងខ្វាក់ភ្នែកម្ខាងដូច ៗ គ្នា ៗ ប៉ុន្តែយើងមិនទាន់មានពេលនឹងសន្ទនាសាកសួរគ្នា អំពីសេចក្ដីអភ័ព្វនេះនៅឡើយទេ យើងទើបតែនឹងមានពេលត្រង់ដែលសូមអង្វរសុំទីសំណាក់បាក់ពួន ដែលអ្នកស្រីបានអនុញ្ញាតយល់ព្រមឲ្យដោយមេត្តាចិត្តនេះឯង ៗ កាលអ្នកបួសទី ៣ ថ្លែងរឿងរ៉ាវរបស់ខ្លួនចប់សព្វគ្រប់យ៉ាងនេះហើយ នាងសូប៊ីតក៏ចាប់និយាយចំពោះទៅរកអ្នកបួសទី ៣ នោះ ហើយនឹងអ្នកដែលជាពួកគណៈដូចគ្នាទាំងនោះថា ទៅចុះ! អ្នកទាំង ៣ នាក់នេះបានរួចខ្លួនហើយ, ចង់ទៅណាក៏ចូរទៅតាមចិត្តចុះ ៗ ប៉ុន្តែបណ្ដាអ្នកទាំង ៣ នាក់នោះ មានអ្នកបួសម្នាក់ឆ្លើយថា អ្នកស្រី! យើងសូមអង្វរសូមឲ្យអ្នកស្រីអត់ទោសដល់យើងឲ្យទាន សូមអនុញ្ញាតឲ្យយើងនៅក្នុងទីនេះសិន ដើម្បីស្ដាប់រឿងរ៉ាវរបស់លោកទាំងនេះ ដែលមិនទាន់បានអធិប្បាយនៅឡើយ ៗ គ្រានោះនាងសូប៊ីតងាកបែរទៅរកកាលីហ្វ,

អគ្គមហាសេនា, យ៉ាហ្វ៉ារ នឹងមេស្រុក ដែលនាងមិនទាន់បានស្គាល់ថា ជាមនុស្សយ៉ាងណានៅឡើយ ហើយនិយាយថា: ដល់វេនអ្នកស្រី និយាយរឿងខ្លួនហើយ ចូរនិយាយទៅ ! ។

អគ្គមហាសេនា យ៉ាហ្វ៉ារ ដែលធ្លាប់តែទទួលពាក្យជំនួសគេជានិច្ច បានឆ្លើយតបទៅនាងស្ញូ៊ីតទៀតថា អ្នកស្រី! ដើម្បីឲ្យពួកយើង ប្រតិបត្តិតាមបង្គាប់អ្នកស្រីនោះ យើងឥតមានរឿងអ្វីដទៃថ្មីទេ មាន តែត្រូវថ្លែងរឿងដែលបានជួបមកពីមុនរួចហើយនោះបន្ថែមម្ដងទៀត ប៉ុណ្ណោះឯង ។ អ្នកស្រី ! ពួកយើងនេះជាពាណិជនៅស្រុកមូស៊ូល ហើយយើងមកកាន់ក្រុងបាគដាទនេះដើម្បីលក់ដូរទំនិញផ្សេង ៗ; ទំនិញ ទាំងនោះយើងផ្ញើទុកក្នុងឃ្លាំង ក្នុងសាលាសម្រាប់ភ្ញៀវដំណើរដែល យើងនៅការស្នាក់ ។ ក្នុងថ្ងៃនេះ មានជនម្នាក់ក្នុងក្រុងនេះ បានអញ្ជើញយើងទៅជប់លៀងបាយល្ងាចឯផ្ទះគេ ជាមួយនឹងមនុស្ស ឯទៀតជាច្រើនរូប លុះជប់លៀងដោយម្ហូបយ៉ាងឆ្ងាញ់នឹងស្រាទំពាំងបាយជូរ រួចហើយ ម្ចាស់ផ្ទះបានឲ្យហៅពួករបាំប្រុសស្រី ព្រមទាំងអ្នកច្រៀងនឹង អ្នកភ្លេងមកលេងកំសាន្តសប្បាយ ក្នុងវេលានោះជាពេលយប់ទៅហើយ សូរសន្ធឹកតឹកកងភ្លេងត្រូវត្រែនិងចម្រៀងសើចហ៊ាសប្បាយនោះ ក៏ឮ ទៅដល់ពួកអ្នកយាមល្បាត ។ ក៏ចូលទៅចាប់ខ្លួនបានខ្លះ ឯយើងទាំង ៣ នាក់មានភ័ព្វធំណាស់ បាននាំគ្នារត់រួចមក ប៉ុន្តែពេលនោះជាវេលាយប់

ជ្រៅណាស់ទៅហើយ តាំងពីសាលាសំណាក់របស់យើងក៏គេបិទអស់ទៅ យើងជាអ្នកដំណើរមិនដឹងជាទៅជ្រកកោនឯណា ទើបប្រញាប់ប្រញាល់ដើរមកតាមផ្លូវក្បែរផ្ទះអ្នកស្រី ចួនជាបានឮសំឡេងមនុស្សសើចលេងសប្បាយ ក៏ចូលមកគោះទ្វារហៅដើម្បីសុំសំណាក់ផង ។ អ្នកស្រី! រឿងរ៉ាវដូចសារស័ព្ទមកដោយសង្ខេបប៉ុណ្ណោះឯង ជាកិច្ចដែលយើងបានទទួលធ្វើតាមបង្គាប់របស់អ្នកស្រី ។ នាងសុបិតក៏បានស្តាប់រឿងរ៉ាវនោះហើយ ក៏ហាក់ដូចជាកើតពឹងនឹកពាក្យនិយាយតដូចម្តេចទៅទៀត ។ ប៉ុន្តែអ្នកបួសទាំង ៣ នាក់បានដឹងអាការដូច្នោះ ក៏អង្វរនាងសូមឲ្យមានសេចក្តីសប្បុរសចំពោះពាណិជក្រុងមូស៊ូលទាំង ៣ នាក់នោះដូចជានាងដែលមានចិត្តសប្បុរសដល់ខ្លួនដូច្នោះដែរ ។ នាងសុបិតក៏និយាយទៅកាន់ពាណិជទាំងនោះថា ណ្ហើយចុះមិនអីទេ !. ខ្ញុំយល់ព្រមជឿតាមរឿងរបស់អ្នកដែរ ខ្ញុំត្រូវការតែត្រឹមកិច្ចដែលឲ្យអ្នកទាំងឡាយទទួលស្តាប់បង្គាប់ខ្ញុំតែប៉ុណ្ណោះ ខ្ញុំអត់ទោសឲ្យអ្នកទាំងអស់គ្នា លុះត្រាតែអ្នកនាំគ្នាថយខ្លួនចេញទៅអំពីផ្ទះខ្ញុំឥឡូវនេះឯង ហើយចង់ទៅកន្លែងណាក៏ទៅតាមសេចក្តីពេញចិត្តចុះ ។ នាងសុបិតបានអនុញ្ញាតបើកឲ្យដោយស្រួសំដី ដែលល្មមឲ្យសំគាល់បានថានាងជាអ្នកទទួលយល់ព្រមស្តាប់បង្គាប់ដែរ ; កាលបើ អគ្គមហាសេនាមេស្រួរ, អ្នកបួសទាំង ៣ នាក់និងបុរសអ្នកស៊ីឈ្នួល ក៏ចេញទៅដោយខ្លួនលំទោនឥតហ៊ានហើបមាត់ ១

ម៉ាក់សោះព្រោះខ្លាចបុរសជាប្តីទាំង ៧ នាក់ ដែលមានគ្រឿងសស្ត្រាវុធកាន់នៅដៃប្រុងចាំ ក្នុងទីចំពោះមុខនោះឯង ។ កាលជនទាំងនោះចេញទៅផុតអំពីខាងក្នុងផ្ទះហើយ គេក៏បិទទ្វារក្រោយ ឯកាលីហ្វ៍ខ្ទង់មិនបង់ឲ្យអ្នកបួសទាំងនោះដឹងថាខ្ទង់ជាអ្វីឡើយ ទើបមានព្រះឱង្ការថា អស់លោកទាំងឡាយ ពួកលោកសុទ្ធតែជាអ្នកបរទេស ហើយទើបនឹងចូលមកដល់ក្រុងនេះថ្មីៗ តើឥឡូវនេះ អស់លោកគិតអញ្ជើញទៅជ្រកកោនក្នុងទីណា ព្រោះពេលនេះនៅយប់ងងឹត មិនទាន់ភ្លឺនៅឡើយផង ។ អ្នកបួសទាំងនោះតបថា ឱព្រះគុណអើយ រឿងនេះឯងហើយដែលនាំឲ្យយើងខ្វល់ខ្វាយព្រួយចិត្ត ។ កាលីហ្វ៍ខ្ទង់ឆ្លើយឡើងថា បើដូច្នោះមិនអីទេ លោកទាំងអស់ទៅតាមយើងចុះ យើងនឹងជួយធុរៈកុំឲ្យព្រួយ ។ លុះខ្ទង់មានព្រះឱង្ការយ៉ាងនេះរួចហើយ ទើបងាកទៅខ្សឹបនឹងអគ្គមហាសេនា ហើយត្រាស់បង្គាប់ថា ចូរអ្នកនាំអ្នកបួសទាំង ៣ នាក់នេះទៅឲ្យសំណាក់ឯផ្ទះអ្នកឯង ហើយដល់ថ្ងៃស្អែកពេលព្រឹក ចូរនាំយកទៅឲ្យជួបនឹងខ្ញុំ ព្រោះខ្ញុំត្រូវការឲ្យគេកត់រឿងរ៉ាវរបស់ជនទាំងនេះ ចុះទុកក្នុងពង្សាវតារសម្រាប់រាជ្យខ្ញុំ ។

លោកអគ្គមហាសេនា យ៉ាហ្វារ នាំអ្នកបួសទាំង ៣ នាក់ទៅឲ្យសំណាក់ឯផ្ទះរបស់ខ្លួន, ឯបុរសអ្នកស៊ីឈ្នួលក៏ទៅផ្ទះរបស់គាត់ទៅ ។ បំណែកខាងកាលីហ្វ៍ខ្ទង់យាងចូលទៅកាន់ព្រះរាជវាំងជាមួយនឹងមហាត-

លំគាមស្រែ ។ លុះយាងទៅដល់ហើយ ទ្រង់ចូលទៅកាន់ក្រឡាព្រះបន្ទំ, ប៉ុន្តែទ្រង់ផ្ទំព្រះនេត្រមិនជិតសោះ ព្រោះព្រះទ័យព្រះអង្គចេះតែសោកសល់ នឹកញាប់ញ័រដោយរឿងប្លែកខុសប្រក្រតីដែលទ្រង់បានទតឃើញនឹងបានឮពីមុននោះឯង ។ ទ្រង់ចេះតែគិតក្នុងព្រះទ័យដោយបង់ប្រាថ្នាទៅនឹងសួរពីគេនោះជាស្រីយ៉ាងណា , ហើយដោយមានហេតុបច្ច័យដូចម្តេចបានជាទាន់ធ្វើទុក្ខបុកម្នេញយ៉ាងមេឃ្លៀវទៅតាំងពីរ, តាំងនាងកាមិនដែលមានស្នាមក្រពិតក្រពៀក្រនុំដើមទ្រូងនោះតើដោយហេតុអ្វី ? លុះដល់ព្រះអាទិត្យរះឡើងហើយ ក៏ទ្រង់នៅតែរវល់ទឹងគំនិតដដែល ៗ នោះនៅឡើយ ។ ទ្រង់ក្រោកឡើងចាកក្រឡាព្រះបន្ទំហើយ ស្តេចចូលទៅក្នុងបន្ទប់ដែលជាទីសម្រាប់ពិភាក្សាអំពីកិច្ចការផ្សេងៗ ទីងជាទីគំនាល់ហើយ ទ្រង់គង់លើព្រះវែនទីនាំង ( បល្ល័ង្ក ) ។

លុះមួយស្របក់ទើបអគ្គមហាសេនាមកដល់ ហើយថ្វាយបង្គំកាលីហ្វដោយគោរព តាមទម្លាប់ធម្មតា ។ កាលីហ្វទ្រង់មានព្រះរាជឱង្ការថា អគ្គមហាសេនា! រឿងដែលយើងត្រូវគិតពិចារណាសម្រេច ក្នុងកាលឥឡូវនេះ នោះមិនទាន់ជាបញ្ហាប់ស្រុកទេសប៉ុន្មានទេ ; រឿងដែលសំខាន់នោះគឺរឿងស្រី ៣ នាក់ ទឹងមេឃ្លៀវទៅតាំងពីរ ។ ដំណើរនេះនាំឲ្យខ្ញុំងឿងឆ្ងល់ពេកណាស់ គំនិតខ្ញុំចេះតែសោកសល់មិនស្ងប់ស្ងៀមសោះ ។ អ្នកចូរទៅហៅស្រីទាំងនោះមក ហើយនាំទាំងអ្នកបួសទាំង ៣ នាក់នោះ

មកជាមួយគ្នាផង ៗ ចូរទៅឲ្យឆាប់ ហើយកំណត់ចាំក្នុងចិត្តថា ខ្ញុំនឹងចាំទន្ទឹងមើលផ្លូវអ្នកក្នុងទីនេះ ៗ

អគ្គមហាសេនា ក្រាប់ជីនព្រះច័យខ្លាំងផុតគេរបស់ចៅហ្វាយនាយ ក៏ប្រញាប់ប្រញាល់ទទួលតាមព្រះកដបញ្ជា ហើយដើរសំដៅទៅផ្ទះស្រីតាំងនោះឯង ៗ លុះទៅដល់ហើយ ទើបសារស័ព្ទជំពនាង់ដោយសេចក្ដីគោរពយ៉ាងអស់ពីចិត្តតាមដំណើរព្រះបញ្ជាដែលខ្លួនត្រូវនាំនាងឲ្យអញ្ជើញទៅជួបនឹងទ្រង់កាលីហ្វ៍ ឥតមាននិយាយប្រាប់អំពីរឿងដែលបានជួបគ្នា ក្នុងក្រឹះនៅផ្ទះនាងនោះហើយ ៗ ស្រីតាំងឡាយនោះយកសំពត់មកទទូរ ហើយចេញទៅជាមួយនឹងអគ្គមហាសេនា ៗ ទៀងចូលទៅផ្ទះរបស់ខ្លួន ទៅនាំយកអ្នកបួសទាំង ៣ នាក់ដែលកាលពីមុនបានជួបនឹងកាលីហ្វ៍ ទាំងបាននិយាយជាមួយផង តែមិនស្គាល់ទ្រង់ថាជាស្ដេចឡើយ; អគ្គមហាសេនានាំអ្នកទាំងអស់នោះចូលទៅក្នុងព្រះក្ខជ-វាំងដោយសេចក្ដីខ្ជាក់, កាលីហ្វ៍ បានទតហើយក៏តេកយព្រះហ្ឫទ័យយ៉ាងពន្លឹក ៗ ដើម្បីធ្វើឲ្យមានសណ្ដាប់ធ្នាប់គួរសមល្អ ចំពោះមុខពួកមេទាហានប្រចាំដំណាក់ ដែលមកនៅគ្រៀតតាតោក្បែរទ្រង់នោះ ស្ដេចកាលីហ្វ៍នេះបានរៀបចំឲ្យស្រីទាំង ៣ នាក់ អង្គុយខាងក្រោយកំរាំងននៃបន្ទប់មួយដែលមានទ្វារជាប់ទៅនឹងល្វែងបន្ទប់របស់ទ្រង់ ហើយឲ្យអ្នកបួសទាំង ៣ នាក់អង្គុយជិតព្រះអង្គ, ឯអ្នកបួសទាំងនោះសំដែងកាការ

គោរពមិនបាន តាមធ្វើឲ្យស្តេចជ្រាបបានខ្លះថា គេក៏ស្គាល់ខ្លួនថាជាស្តេចដែរ ។

កាលស្រីតាំងឡាយអង្គុយស៊ីប់ស្រួលហើយ កាលីហ្វ៍ឆាតថៃរទៅរកស្រីតាំងនោះហើយមានព្រះបន្ទូលថា ឱនាងតាំងឡាយ កាលបើខ្ញុំប្រាប់នាងឲ្យដឹងថា ខ្ញុំបានក្លែងខ្លួនជាអ្នកជំនួញចូលទៅក្នុងផ្ទះនាងពីយប់មិញនោះ នាងមុខជានឹងកិតក័យឥឡូវនេះពុំខាន ព្រោះនាងក័យខ្លាចក្រែងដែលបានធ្វើអំពើគ្គាគួនជ្រុលមកលើខ្ញុំ ហើយនាងប្រហែលជាស្មានថា ខ្ញុំបានឲ្យហៅនាងមកក្នុងនេះ ដើម្បីនឹងសងសឹកដល់នាងវិញហើយយ៉ាងមើល, ប៉ុន្តែមិនមែនដូច្នោះទេ ចូរនាងកុំកិតក័យឲ្យសោះ ចូរជឿជាក់ប្រាកដថា រឿងកាលដែលកន្លងហើយនោះ ខ្ញុំបំភ្លេចចោលបាត់ទៅហើយ ។ ខ្ញុំមានបំណងចង់ឲ្យពួកស្រី ៗ នៅក្រុងបាគដាទនេះ មានគំនិតមារយាទល្អដូចជាពួកនាង ដែលបានធ្វើឲ្យខ្ញុំឃើញដូច្នោះដែរ ។ ខ្ញុំនៅចាំជានិច្ចអំពីសេចក្តីយោគយល់អធ្យាស្រ័យល្អរបស់នាង ដែលបានអត់ទោសឲ្យយើង ក្រោយដែលយើងបានធ្វើឲ្យខុសបញ្ញត្តិនោះឯង ។ កាលនោះខ្ញុំជាអ្នកជំនួញនៅស្រុកមូស៊ូល ប៉ុន្តែឥឡូវនេះខ្ញុំជាស្តេចហារូន . អាល់ - រ៉ាជិត , គឺជាស្តេចកាលីហ្វ៍ទី ៥ នៅក្នុងផជំណាក់ អប្បាស៊ីរុងរឿង ដែលទទួលដំណែងជាមរតកហោរាអគ្គព្យាការីយ៉ាងធំ ។ ខ្ញុំសុំសួរនាងតែប៉ុណ្ណោះទេ គឺចង់ដឹងថា ពួកនាងជាអ្វី

ហើយដោយមានហេតុបច្ច័យដូចម្ដេច បានជានាងម្នាក់នោះក៏យកមកក្លែងរូប ហើយបែរទៅជាយំសោកនូវប្ដីនោះទៅវិញ, ម្យ៉ាងទៀត នាងមួយដែលមានស្នាមក្រពិតក្រពៀវត្រង់ដើមទ្រូងនោះតើដោយហេតុដូចម្ដេច ។

កាលីហ្វ សូម្បីមានបន្ទូលពាក្យខាងលើនេះយ៉ាងច្បាស់លាស់ហើយ តាំងស្រី ៣ នាក់ក៏បានស្ដាប់ជាក់លាក់សព្វគ្រប់ហើយ ទ្រង់ហាក់ដូចជានៅចង់មានបន្ទូលថែមទៀត ប៉ុន្តែអគ្គមហាសេនាយ៉ាហ្វារបានសំដែងទឹកមុខស្រស់ស្រាយគួរសម ហើយសូមកុំឲ្យទ្រង់មានបន្ទូលថែមទៀតឡើយ ។

កាលស្ដេចកាលីហ្វមានព្រះរាជានុញ្ញាឲ្យនាងសូប៊ីទុកចិត្ត បាត់ភ័យបារម្ភយ៉ាងនេះហើយ នាងក៏និយាយរឿងខ្លួនបំពេញព្រះទ័យទ្រង់ ដូចតទៅនេះ ។

ចប់ភាគទី ១០ តែប៉ុណ្ណេះ

រឿងក្នុងភាគទី ១១ ចំឡែកណាស់ទៅទៀត
សូមអញ្ជើញមើលតទៅកុំខាន ។

# អារម្ភកថា

ហេតុដែលនាំឲ្យយើងស្រង់និងរួបរួមព្រះរាជប្រវត្តិនេះឡើង ដោយយើងបានពិនិត្យមើលព្រះរាជក្រឹត្យក្រមខ្លះ ដែលគេបានរៀបរៀងឡើងក្នុងរជ្ជកាលព្រះបាទសម្ដេចព្រះជ័យចេស្ដានោះ យើងយល់ឃើញថាព្រះមហាក្សត្រអង្គនេះ ទ្រង់មានព្រះវិរិយៈឧស្សាហៈប្រកបដោយហិរិឧត្តប្បៈដ៏ប្រសើរ ទ្រង់មានព្រះប្រាជ្ញាញាណជ្រាលជ្រៅ ទ្រង់យកព្រះទ័យទុកដាក់ពិនិត្យព្រះរាជក្រឹត្យក្រមផ្សេងៗ ជាច្រើនក្រម មានចំនួនដល់ ២៤ ក្រម ទ្រង់មានឫទ្ធានុភាពប្រាបប្រាមខ្មាំងសត្រូវ ទាំងខាងក្នុងស្រុកទាំងខាងក្រៅស្រុកបានរាបទាបទូទៅ នៅសម័យដែលប្រទេសកម្ពុជាកំពុងកើតចលាចលនិងចម្បាំងរាំងដល់ផតស្រោក ត្រាតែក្រុងកម្ពុជាទាំងមូលបានសេចក្ដីស្ងប់សាន្តត្រាណ ។ ទើបបានជាប្រទេសឯករាជ្យយ៉ាងបរិបូណ៌ឡើងវិញ ។

ក្រោយសម័យមហានគរ (អង្គរធំ) មក យើងយល់ថា ព្រះបាទសម្ដេចព្រះជ័យចេស្ដា (ព្រះអង្គស្ងួរ) នេះ គួរហាក់ជាព្រះមហាក្សត្រដែលមានឫទ្ធានុភាព ១ អង្គបាន ព្រោះ (១) ទ្រង់បានរួបរួមស្រុកខ្មែរដែលបែកខ្ញែកគ្នាជាពីរបីណែកហើយនោះ ឲ្យបានមូលគ្នាតែ ១ ឡើងវិញបាន (២) ទ្រង់បានប្រមូលព្រះរាជវង្សានុវង្សទាំងអាណាប្រជាជនឲ្យបានសេចក្ដីសុខក្សេមក្សាន្តទាំងអស់គ្នា (៣) ទ្រង់ធ្វើសារឿជាប់ស្រប

បិទកន្ទះក (៤) ទ្រង់មានព្រះរាជហឫទ័យមេត្តាករុណា ដល់អាណាប្រជាជនទូទៅមិនរើសមុខ (៥) ទ្រង់ជាកល់ដ៏កើនតែមទ្រណា ដែលធ្វើការមានគុណបំណាច់ដល់ផែនដី ទីនទ្រង់ទំនុកបំរុងមកលើដីនឲ្យមានយសស័ក្តិខ្ពង់ខ្ពស់ឡើង (៦) ទ្រង់ជាអ្នកទ្រង់ទសពិធរាជធម៌យ៉ាងហ្មត់ចត់ ហើយដែលចំឡែកជាងក្សត្រគ្រងរាជ្យដទៃ ៗ នោះ គឺទ្រង់មានព្រះរាជហឫទ័យប្រកបដោយសទ្ធាជ្រះថ្លា យ៉ាងមុតមាំក្នុងព្រះពុទ្ធសាសនា ស្តេចចេញទ្រង់ព្រះផ្នួសដល់ ៣ ដង ដូចមានសេចក្តីសាស័ព្ទក្នុងព្រះរាជប្រវត្តិនេះស្រាប់ ។

មួយវិញទៀត យើងមានបំណងចង់បង្ហាញឲ្យឃើញហេតុកើតពេសស្រុកទេស ក្នុងរវាងតាំងពីពាក់កណ្តាលសតវត្សរ៍ទី ១៧ ដល់ខាងដើមសតវត្សរ៍ទី ១៨ ។ ក្នុងរវាងសម័យនោះហើយ ដែលប្រទេសកម្ពុជាកំពុងមានចម្បាំងរាំងជល់ ទាំងការចលាចលខាងក្នុងស្រុកជាច្រើនប្រការ លុះផុតរយៈពីការកោលាហលជាពន្ទុកនោះមក កម្ពុជរដ្ឋក៏បានដល់នូវសេចក្តីសុខសាន្តត្រាណទូទៅ សេដ្ឋកិច្ច ពាណិជ្ជកម្ម ក្សេត្រកម្ម ក៏កើតផលចំរើនឡើងជាអនេក ស្រុកទេសក៏មានសម្បត្តិសម្បូណ៌ ដូចមានសេចក្តីតំណាលថា ស្រូវ ៥០០ ថាំង មានថ្លៃត្រឹមតែ ១ ណែនប៉ុណ្ណោះ ។ ខាងក្បួនច្បាប់សម្រាប់ស្រុកក៏បានសើរើរៀបចំឡើងជាថ្មី

ដើម្បីផ្សាយសេចក្ដីយុត្តិធម៌ដល់ប្រជាជនគ្រប់ថ្នាក់ តាមដែលទ្រង់យល់ថាជារបៀបត្រឹមត្រូវល្អក្នុងជាន់នោះ ។ ចំណែកខាងពុទ្ធចក្រ ព្រះមហាក្សត្រអង្គនេះ ក៏ទ្រង់យកព្រះទ័យទុកដាក់ជួយទំនុកបំរុងដោយប្រពៃ ព្រះពុទ្ធសាសនាក្នុងជាន់នោះ គង់មានសេចក្ដីចំរើនរុងរឿងជាច្រើន តែព្រះរាជពង្សាវតារមិនបានពោលពណ៌នាទុក ទើបយើងមិនអាចដឹងបាន ។

ព្រះបាទសម្ដេចព្រះជ័យចេស្ដា (ព្រះអង្គស្ងួរ) នេះ មានព្រះលក្ខណៈនឹងព្រះរាជអធ្យាស្រ័យ ចំឡែកប្លែកជាងក្សត្រគ្រងរាជ្យដទៃៗ ដូចជារាជសម្បត្តិជារបស់ខ្ពង់ខ្ពស់ថ្លៃថ្លាបំផុត ជាទីប្រាថ្នារបស់ជនទូទៅ តែទ្រង់អាចលះបង់ព្រះរាជទានដល់អ្នកដទៃ ទៅបានជាច្រើនលើកច្រើនគ្រា សព្វគេឃើញព្រះរាជអធ្យាស្រ័យប្រកបដោយមេត្តាករុណា ដ៏ធំទូលាយនិងសប្បុរសល្អណាស់ ប៉ុន្តែបើគេគិតលៃលកកៀតយកប្រសាសនោបាយរបស់ស្រុកមកជាគ្រឿងពិនិត្យ ការដែលប្រគល់រាជ-សម្បត្តិទៅឲ្យអ្នកដទៃដែលទន់ខ្សោយ ទាំងកំឡាំងអានុភាព ទាំងកំឡាំងសតិបញ្ញាមិនអាចរៀបចំត្រួតត្រាស្រុកទេសទាំងមូលឲ្យបានស្រួល នោះទុកដូចជាប្រគល់គ្រោះថ្នាក់ឲ្យកើតមានឡើងដល់ស្រុកទេសទៅវិញ ។ ហេតុនេះ បានជានៅវេលាដែលទ្រង់លះបង់រាជសម្បត្តិ ព្រះរាជទានព្រះរាជបុត្រលើកក្រោយបង្អស់លែងទ្រង់ទទួលយកវិញទៀតនោះ ឡូន

អ្នកធ្លាប់តែផ្ដើមយកជាសម្បត្តិ ជាហេតុបណ្ដាលឲ្យកើតចម្បាំងនឹងការពារបក្សក្នុងស្រុកឡើងជាថ្មីទៀត សេចក្ដីសម្បូណ៌សប្បាយក្នុងស្រុក ក៏ដល់នូវសេចក្ដីវិនាសអន្តរាយ ប្រទេសកម្ពុជាទាំងមូលត្រូវរងកម្ទេចខ្លួន គ្រោះថ្នាក់ជាថ្មីម្ដងទៀត កើតមកពីការផ្ដើមយកជាសម្បត្តិផង បែកសាមគ្គីភាពក្នុងស្រុកជាបច្ច័យ ទើបជាហេតុនាំឲ្យអន្ទងស់ត្រូវខាងក្រៅ ឲ្យលើកទ័ពចូលមកញាំញីឲ្យកាន់តែខ្ទេចខ្ទីហិនហោចថែមទៀត នេះជាឧទាហរណ៍គួរតែចងចាំជាតិជាន់ក្រោយ គិតគេចវៀសវាងឲ្យផុតស្រឡះពីការតស៊ូដណ្ដើមនិងគំនិតគ្នា ដែលជាបច្ច័យនាំឲ្យកើតបែកសាមគ្គីខាងក្នុងស្រុកឡើង ។

សូមសរុបសេចក្ដីក្នុងរជ្ជកាលរបស់ព្រះបាទសម្ដេចព្រះជ័យចេស្ដា (ព្រះអង្គស្ងួន) ចំពោះខាងដើមរជ្ជកាល ស្រុកទេសបែកខ្ញែកចេញទៅជាពីរចំណែក មានកើតចលាចលនិងកើតចម្បាំងកំដល់ជាច្រើនគ្រា តែព្រះមហាក្សត្រអង្គនេះ ទ្រង់បានបង្ក្រាបត្រាតែរាបទូទៅ ប្រទេសកម្ពុជាទាំងមូលក៏បានរួបរួមមូលតែ ១ ឡើងវិញបានសម្រេច ឈ្មោះថាទ្រង់បានជួយស្រោចស្រង់ប្រទេសជាតិជាឯករាជ្យឡើងវិញយ៉ាងបរិបូណ៌ មានរដ្ឋអំណាចជាទីគោរពកោតញញើតនៃប្រទេសជិតខាងៗ - លែងហ៊ានលើកទ័ពមកបៀតបៀនញាំញីប្រទេសកម្ពុជាទៀតជាយូរឆ្នាំ ៗ ក្នុងរជ្ជកាលនេះ មានព្រះវង្សជាតិលាវនិងព្រះវង្សជាតិចាម ព្រមទាំងប្រជាជនទាំង

លើកស្រែសារ ចូលមកដែនកោនព្រះបរមពោធិសត្វរាជាប្រើនពេខក្រុ ប្រទេសកម្ពុជាត្រានោះ ចុំពេជ្ជរុនរឿងឡើង ១ គ្រា គួរជាទំព្ញានុគត់ នៃក្សត្រត្រៃនិកព្វជាតំណាតៗ មក ។

ជាទីបំផុត យើងមានសង្ឃឹមថា អស់លោក-អ្នកខេមរជាតិគង់ចូលចិត្តមើលព្រះរាជប្រវត្តិ ព្រះបាទសម្តេចព្រះជ័យជេស្តានេះខ្លះពុំខាន ហើយយើងនាំយកមកចុះផ្សាយក្នុងទស្សនាវដ្តីកម្ពុជសុរិយានេះ ដើម្បីចែកជូនដល់លោក-អ្នកបានមើលគ្រប់គ្នា ។

ហ្លួងនិពន្ធមន្ត្រី ញ៉ុក - ថែម
ថ្ងៃ ខែសីមប្រ៍ ១៩៥៥

# ព្រះរាជប្រវត្តិ

## ព្រះបាទសម្តេចព្រះជ័យជេស្ឋា (ព្រះអង្គសូរ[១])

(ក្នុងកម្ពុជសតវត្សរ៍ទី ១៧)

### ហ្លួងទិពត្ថមន្ត្រី ញ៉ុក–ថែម

ទ្រង់សម្តេច – ទ្រង់ព្រះនាមព្រះជ័យជេដ្ឋា

ព្រះបាទសម្តេចព្រះរាជឱង្ការព្រះជ័យជេស្ឋា (ព្រះអង្គសូរ) ជាព្រះរាជបុត្រព្រះបាទសម្តេចព្រះរាជឱង្ការ ព្រះបរមរាជាធិរាជរាមាធិបតី និងអគ្គមហេសី នាមជ័យប៉ែន ។ ទ្រង់ប្រសូតក្នុងឆ្នាំជូតទោស័ក[២] ពុទ្ធសករាជ ២២០៧ ចុល្លសករាជ ១០២២ (គ. ស. ១៦៦១) ។ ព្រះវររាជបិតាទ្រង់តាំងប្រទានព្រះនាមថា ព្រះអង្គសូរ[៣] ។ ទ្រង់មាន

---

១ ការរៀបរៀងព្រះរាជប្រវត្តិនេះ យើងបានស្រង់យកចេញពីព្រះរាជពង្សាវតារក្រុងកម្ពុជា ច្បាប់សរសេរដៃរបស់បណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ ព្រមទាំងបានប្រៀបធៀបនឹងច្បាប់ពារនិងស្លឹករឹត ច្បាប់ព្រះរាជពង្សាវតារក្រុងកម្ពុជាដែលប្រែបោះពុម្ពជាភាសាថៃឆ្នាំ ១៩១៧ ។ និងច្បាប់ពង្សាវតារ Cao-Men-Ky.-Luoc (ភាសាយួនប្រែជាភាសាបារាំង) ។ ២ ច្បាប់ព្រះរាជពង្សាវតារស្លឹករឹតវត្ត កោកកាក ស្រុកស្អាង ថាទ្រង់ប្រសូតក្នុងឆ្នាំជូតចត្វាស័ក ។ ច្បាប់ព្រះរាជពង្សាវតារដែលប្រែជាភាសាថៃ ថាទ្រង់ប្រសូតក្នុងឆ្នាំជូត ព. ស. ២២០៤ ចុល្លសករាជ ១០២៣ ។ ៣ តាមច្បាប់ស្លឹករឹតនិងច្បាប់ភាសាថៃថាព្រះនាមជាចៅពញាសូរ ។

ព្រះអនុជារួមព្រះជនកជននី ១ ព្រះនាមព្រះអង្គស័ក្យត្រៃ ប្រសូតក្នុងឆ្នាំជូត ត្រីស័ក ព.ស. ២២០៤ ចុល្លសករាជ ១០២៣ (គ.ស. ១៦៦២) ។

លុះដល់ ១៤ កើតខែពិសាខ ឆ្នាំចត្វាស័ក ព្រះរាជបិតាទ្រង់ព្រះមេត្តាប្រោសព្រះរាជទាននាម ព្រះអង្គជាព្រះរាជបុត្រច្បង ព្រះជន្ម ១៩ វស្សា ជាព្រះជេដ្ឋាព្រះអង្គសូរ ព្រះនាមជា សម្តេចព្រះកែវហ្វា ។ ទ្រង់ព្រះមេត្តាប្រោសព្រះអង្គសូ ព្រះជន្ម ១១ វស្សា ព្រះនាមជាព្រះជ័យជេដ្ឋា ។ ទ្រង់ព្រះមេត្តាប្រោសតាំងអ្នកម្នាងវៃ ព្រះវររាជមាតាព្រះអង្គសូរ ជាសម្តេចព្រះទាវក្សត្រ ។

ព្រះជ័យជេដ្ឋា (ព្រះអង្គសូរ) ទ្រង់មិនបានឡើងគ្រងរាជសម្បត្តិ បន្ទាប់អំពីព្រះវររាជបិតាសោយព្រះទីវង្គតទៅទេ ព្រោះទ្រង់មានព្រះជេដ្ឋា គឺសម្តេចព្រះកែវហ្វា ឡើងគ្រងរាជសម្បត្តិមុនទ្រង់ ក្នុងឆ្នាំ ព.ស. ២២១៦ (គ.ស. ១៦៧៣) ។ ក្នុងរជ្ជកាលសម្តេចព្រះកែវហ្វានេះ ក្រុងកម្ពុជាប្រកបដោយការចលាចលនឹងចម្បាំងរាំងដល់មិនស្រាក ទាំងព្រះរាជវង្សានុវង្សក៏បែកខ្ញែកទៅជាពីរពួក គឺពួកខាងសម្តេចព្រះកែវហ្វាទ្រង់រាជ្យ ១ ពួកខាងសម្តេចព្រះឧទាធិបតីមហាឧបយោរាជ (ព្រះអង្គនន់) ១ ទាំងពីរពួកនេះតាំងច្បាំងដណ្តើមរាជសម្បត្តិគ្នា ទាល់តែស្រុកខ្មែរបែកចេញជាពីរចំណែក គឺចំណែកផែនដីត្រើយខាងកើតទន្លេមេគង្គ បានទៅខាងសម្តេចព្រះមហាឧបយោរាជ ចំណែកផែនដីត្រើយខាងលិចទន្លេ

បានមកសម្ដេចព្រះកែវហ្វា ជាក្សត្រទន់ខ្សោយ (ដូចមានន័យលក្ខណៈនៅខាងមុខនេះស្រាប់) ។ ឯព្រះជ័យជេដ្ឋា (ព្រះអង្គសួរ) ទ្រង់ធ្វើសឹកសង្គ្រាមរួបរួមនឹងព្រះជេដ្ឋាដែលជាក្សត្រទន់ខ្សោយ ប្រចាំនៅក្រុងឧត្តុង្គឫជ័យ ។

គ្រាមួយ ព្រះបាទសម្ដេចព្រះកែវហ្វា (ព្រះអង្គជី) ស្ដេចចេញទៅចណ្ដុកនឹងទ័ពតាមផ្លូវខាងក្រៅ នោះទ្រង់ប្រគល់ព្រះបរមរាជ-វាំងឧត្តុង្គឫជ័យ ឲ្យព្រះជ័យជេដ្ឋាជាព្រះអនុជគ្រប់គ្រងថែរក្សាជំនួសព្រះអង្គ ។ លុះស្ដេចយាងទៅដល់ស្រុកប្រាំជម៉ឹង វៃគ្រប់ពេលទនស្ដាំ ក៏ស្រាប់តែទ្រង់ព្រះអាពាធជាទម្ងន់ ទ្រង់សោយព្រះទិវង្គតនៅស្រុកនោះទៅ [១] ។ ឯការព្រះរាជសង្គ្រាមក៏មិនទាន់បានចាញ់ឈ្នះដាច់ស្រេចទៅខាងណាទេ បញ្ហាក៏ជាភារៈយ៉ាងធ្ងន់មកលើព្រះជ័យជេដ្ឋាជាព្រះអនុជដែលត្រូវទទួលឡើងគ្រងរាជសម្បត្តិជាលំដាប់តមក ដូចមានរឿងរ៉ាវតទៅខាងមុខនេះ ។

ឯពួកមន្ត្រីខ្ញុំរាជការនាយទ័ពនាយកងទាំងពួង បាននាំគ្នារៀប

១ — តាមច្បាប់សាស្ត្រស្លឹករឹតរិត សម្ដេចព្រះកែវហ្វាច្បាំងចាញ់ទ័ពយួន-ខ្មែរ ខាងសម្ដេចព្រះរាមាធិបតីមហាចយោវរ៉ាក្ស ហើយស្ដេចរត់ទ័ពទៅសោយទិវង្គតនៅស្រុកប្រាំតម៉ឹង ខែត្រលំពេងទុកស្ដាំ ។

ដំកល់ព្រះបរមសពហើយ ក៏នាំគ្នាទៅក្រាបទូលព្រះជ័យជេដ្ឋាឲ្យទ្រង់ព្រាប ទើបទ្រង់ត្រាស់បង្គាប់ឲ្យរៀបក្បួនហែ ព្រះបរមសពសម្តេចព្រះជេដ្ឋាចូលមកក្រុងឧដុង្គមានជ័យវិញ ។

## ព្រះរាជសង្គ្រាមគ្រាទី ១

ទ័ពព្រះជ័យជេដ្ឋាឈ្នះទ័ពព្រះបទុមរាជា

មុនទៀងគ្រងរាជសម្បត្តិ ព្រះជ័យជេដ្ឋា (ព្រះអង្គស្ងួរ) ទ្រង់តាំងព្រះទ័យជាដាច់ស្រេចថា ត្រូវតែទទួលធ្វើបង្វាំងតពីព្រះជេដ្ឋាឲ្យគេឃើញថ្វីព្រះហស្តព្រះអង្គសិន ទើបបន្ទាប់តពីពេលដែលបានហែព្រះបរមសពចូលក្រុងឧដុង្គឫជ័យហើយ ស្តេចក៏ចេញទៅកេណ្ឌពលធ្វើទ័ពដោយព្រះអង្គឯង ។ នៅវេលាគ្រានោះស្តេចកេណ្ឌបានសេនាពាហនជាចំនួនប្រមាណ ៣០.០០០ រូបស្រេច ស្តេចចាត់ជាទ័ពជើងទឹក ១០.០០០ ជាទ័ពជើងគោក ២០.០០០ ព្រមដោយគ្រឿងសស្ត្រាវុធ ។

(មានត)

មញ្ញាធិដ្ឋកថា

# ឃុនសុវត្ថិវេទ យូរ-អ៊ិន រៀបរៀង

(តទៅ)

កាលទ្វាជព្រាហ្មណ៍ លុះស្តាប់ចប់ហើយ ក៏ជ្រះថ្លាបានសុំឲ្យព្រះគន្ធ៍ចបួស បួសហើយមិនយូរប៉ុន្មានក៏បានសម្រេចព្រះអរហត្តផល ។

២ - ចេតុកកន្ទ៍ចិត្តដោយ១បាអប្រាជ្ញា នោះបានដល់ការប្រើគំនិត ប្រកបដោយសទ្ធានិងប្រាជ្ញាមានកម្លាំងស្មើគ្នា, ដូចគេទឹមគោមានកម្លាំងស្មើគ្នា អធិប្បាយថា ធម្មតាជាបណ្ឌិតកាលនឹងគិតពិចារណាការអ្វីមួយមុនដែលនឹងចុះចិត្តជឿសិន លោករមែងប្រើប្រាជ្ញាការកស្រាវស្ទង់មើលហេតុផលក្នុងអតីត បច្ចុប្បន្ន អនាគត, កាលបើឃើញថា សមហេតុសមផល មិនឃ្លៀងឃ្លាតទេ ទើបលោកចុះសន្និដ្ឋានជឿថាការនោះពិតជាយ៉ាងនេះ ការនេះពិតជាយ៉ាងនោះ, ដូចមនុស្សគ្រប់ជាតិគ្រប់សាសន៍ក្នុងលោកនេះ ដែលមានដំណើរផ្សេងៗគ្នា ដោយអាយុវែងខ្លះខ្លីខ្លះជាដើម លោកពិនិត្យឃើញថាពួកសត្វដែលមានអាយុវែង ព្រោះមិនសម្លាប់សត្វ, ដែលមានអាយុខ្លីព្រោះសម្លាប់សត្វ; ដែលមិនមានរោគព្រោះមិនបៀតបៀនសត្វ ដែលមានរោគព្រោះបៀតបៀនសត្វ; ដែលមានសម្បុរល្អ ព្រោះមិនមានទោសៈ, ដែលមានសម្បុរអាក្រក់ ព្រោះមានទោសៈ, ដែលមានគេជាខ្ញុំការច្រើន ព្រោះមិនប្រណែនឈ្នានីសគេ

ដែលមិនមានគេជាខុភាព ព្រោះច្រណែនឈ្នានីសគេ; ដែលមានទ្រព្យសម្បត្តិច្រើន ព្រោះបរិច្ចាគទាន, ដែលមិនមានទ្រព្យសម្បត្តិ ព្រោះមិនបរិច្ចាគទ្រព្យធ្វើទាន, ដែលមានត្រកូលខ្ពង់ខ្ពស់ ព្រោះគោរពកោតក្រែងចំពោះចាស់ព្រឹទ្ធាចារ្យ, ដែលមិនមានត្រកូលខ្ពង់ខ្ពស់ ព្រោះមិនគោរពចាស់ព្រឹទ្ធាចារ្យ; ដែលមានប្រាជ្ញាច្រើន ព្រោះសេពគប់នឹងសប្បុរស, ដែលមិនមានប្រាជ្ញា ព្រោះមិនសេពគប់នឹងសប្បុរស ដ្បិតសត្វទាំងឡាយដែលកើតមកក្នុងវាលវដ្តសង្សារ រមែងមានកម្មគឺបុណ្យនិងបាបជាមេចំណែកចែកសត្វឲ្យមានគតិថ្លៃថោកទាបខ្ពស់ផ្សេងៗគ្នា ។ លុះលោកប្រើបញ្ញាពិចារណាស្ទាបស្ទង់មើលហេតុនិងផល ឃើញថាសមគួរស្របគ្នាហើយ លោកទើបជឿ យ៉ាងនេះឯងហៅថា ប្រើគំនិតដោយឧបាយប្រាជ្ញា ។ មួយទៀត ក្នុងគម្ពីរអង្គុត្តរនិកាយចតុក្កនិបាតថា យោនិសោមនសិការៈ គឺធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញានេះមាន ៤ យ៉ាងគឺ

១- និច្ចេ និច្ចន្តិ យល់ថាទៀងក្នុងចំណែកដែលទៀង

២- ទុក្ខេ ទុក្ខន្តិ យល់ថាទុក្ខក្នុងចំណែកដែលជាទុក្ខ

៣- អត្តនិ អត្តាតិ យល់ថាខ្លួនក្នុងចំណែកដែលជាខ្លួន

៤- សុភេ សុភន្តិ យល់ថាល្អក្នុងចំណែកដែលល្អ ៗ

មិច្ឆាទិដ្ឋិកបុគ្គល កាលបើបានប្រើគំនិតដោយឧបាយប្រាជ្ញា តាមចំនួនសេចក្តីនេះហើយ រមែងប្រែក្លាយទៅជាសម្មាទិដ្ឋិកបុគ្គលបានវិញ ៗ

មិច្ឆាទិដ្ឋិដែលទីនាំប្រែក្លាយទៅជាសម្មាទិដ្ឋិវិញ ដោយការស្រ័យហេតុទាំង ២ ប្រការនេះ ហេតុណាមួយ, កាលបើសម្មាទិដ្ឋិ គឺសេចក្ដីយល់ត្រូវកើតមានក្នុងសន្តានហើយ, ការត្រិះរិះត្រូវ, ការពោលវាចាត្រូវ, ការងារត្រូវ, ការចិញ្ចឹមជីវិតត្រូវ, ព្យាយាមត្រូវ, ការដំកល់ស្មារតីត្រូវ, ការស៊ប់ស្មាធិ៍ត្រូវ ក៏កើតមានឡើងជាលំដាប់គ្នា ព្រោះមគ្គសម្មត្តធម៌និងធម៌មានសភាពត្រូវទាំង ៨ សម្មាទិដ្ឋិគឺសេចក្ដីយល់ត្រូវនុះឯងជាធម៌នាំបណ្ដាលឲ្យសម្មត្តធម៌ទាំង ៧ កើតឡើងបាន ។

## ប្រភេទនៃមិច្ឆាទិដ្ឋិ

មិច្ឆាទិដ្ឋិ បើពោលដោយសង្ខេបមានប៉ុន្មាន? ដោយពិស្ដារមានប៉ុន្មាន? គឺអ្វីខ្លះ? ដែលចែកយ៉ាងនេះគេចែកទៅតាមអ្វី?

មិច្ឆាទិដ្ឋិនេះ បើពោលដោយសង្ខេបមាន ២ យ៉ាងក៏មាន មាន ៣ យ៉ាងក៏មាន, បើពោលដោយពិស្ដារបាន ៦២ ប្រការ, ចែកទៅតាមដំណើរនៃគំនិតដែលគេគិតឃើញផ្សេង ៗ គ្នា ។

## មិច្ឆាទិដ្ឋិ ២ យ៉ាងនោះគឺ

១- សស្សតទិដ្ឋិ សេចក្ដីយល់ឃើញថាទៀង

២- ឧច្ឆេទទិដ្ឋិ សេចក្ដីយល់ឃើញថាសោះសូន្យ

អធិប្បាយៈ សេចក្ដីយល់ឃើញថាក្នុងលោកនេះមិនមានអ្វីសោះសូន្យទេ សូម្បីមនុស្សឬសត្វដែលស្លាប់ហើយ ក៏គ្រាន់តែខ្ទេចព្រោមពុក

ផុយស្រួយ ធ្លាក់ចុះ ទៅតែកាន់តែយ៉ាប់ប៉ុណ្ណោះ ។ ចំណែកការនិយមនោះគឺចិត្ត ដែលហៅតាមភាសាសំស្ក្រឹតថា អាត្មន៍ ហៅតាមភាសាមគធៈថា អត្តាក្តី ថាជីវាត្មក្តី នោះជាធម្មជាតិតាំងនៅទៀងទាត់ឋិតថេរ មិនមែនសោះសូន្យទេ តែងកាន់យកនូវបដិសន្ធិកំណើតដដែលៗ ជាប់តទៅមិនដាច់, ការយល់ឃើញបែបនេះ ហៅថាសស្សតទិដ្ឋិ ។ មួយទៀត សេចក្តីយល់ឃើញថាមនុស្សឬសត្វក្នុងលោកនេះ មានកំណើតទៀងទាត់មិនមានប្រែប្រួល ផ្លាស់ជាតិផ្លាស់កំណើតទៅផ្សេងៗ ឡើយ ខ្លួនកើតមកជាជាតិណា សាសន៍ណា, កាលបើស្លាប់ទៅត្រឡប់កំណើតជាថ្មីទៀត ក៏កើតជាជាតិនោះ សាសន៍នោះដដែល, ធ្លាប់កើតមកជាមនុស្សក៏នៅជាមនុស្ស, ធ្លាប់កើតមកជាសត្វក៏នៅជាសត្វដូចដែល, ការយល់ឃើញបែបនេះហៅថា សស្សតទិដ្ឋិ ។

ចំណែកសេចក្តីយល់ឃើញថា មនុស្សនិងសត្វ កាលបើចុតិឃ្លាតចាកអត្តភាពនោះៗ ចេញហើយ ក៏រលត់សូន្យឈឹងឥតមានអ្វីកើតទៀតឡើយ, ប្រៀបដូចជាអណ្តាតប្រទីបដែលអស់ប្រេង រមែងរលត់ទៅសូន្យឈឹងឯង, ការយល់ឃើញបែបនេះហៅថា ឧច្ឆេទទិដ្ឋិ ។

## មិច្ឆាទិដ្ឋិ ៣ យ៉ាងនោះគឺ

១. អកិរិយទិដ្ឋិ សេចក្តីយល់ឃើញថាមិនមែនជាអំពើ

២ អហេតុកទិដ្ឋិ សេចក្ដីយល់ឃើញថាមិនមានហេតុ

៣ នត្ថិកទិដ្ឋិ សេចក្ដីយល់ឃើញថាមិនមាន ៗ

១ – អកិរិយទិដ្ឋិ សេចក្ដីយល់ឃើញរបស់មនុស្សពួកខ្លះថា បុគ្គលធ្វើនូវអំពើឯណាមួយ ដែលហៅថាអាក្រក់ បើក្នុងលោកនេះ មិនមានអ្នកណាដឹង មិនមានអ្នកណាចាប់បាន មិនមានអ្នកណាដាក់ទោសទេ អំពើនោះឯងក៏ទទេ ៗ ទៅ ពុំនាំឲ្យផលអាក្រក់ទៅក្នុងបរលោកឡើយ, បើមានគេដឹង គេចាប់បាន គេដាក់ទោស ក៏គ្រាន់តែមានទោសទុក្ខក្នុងបច្ចុប្បន្ននេះប៉ុណ្ណោះ, ទៅបរលោកមិនមានឲ្យផលជាទុក្ខយ៉ាងណាទេ; ចំណែកខាងបុគ្គលធ្វើអំពើឯណា ដែលហៅថាល្អវិញ, បើក្នុងលោកនេះមិនមានគេដឹង មិនមានគេសរសើរ មិនមានគេឲ្យអំណោយទេ, អំពើល្អនោះឯង ក៏ទទេ ៗ អសារឥតការទេ ពុំនាំមិនមានឲ្យផលជាសុខក្នុងបរលោក តែបើមានគេដឹង គេសរសើរ គេឲ្យអំណោយ, ក៏គ្រាន់តែមានកោតជយល្អក្នុងបច្ចុប្បន្ននេះឯង, ផុតទៅបរលោកមិនមានឲ្យផលជាសុខជួបម្ដងទៀតឡើយ, ការយល់ឃើញយ៉ាងនេះឈ្មោះថា អកិរិយទិដ្ឋិ ។

សេចក្ដីនេះសមនឹងពាក្យអដ្ឋកថានៃសាមញ្ញផលសូត្រថា សេចក្ដីបួល

ចិត្តរបស់គ្រូ ១ នាក់ឈ្មោះបូរណកស្សប [១] ថា "បុគ្គលធ្វើអំពើអាក្រក់ខ្លួនឯងក្តី ប្រើគេឲ្យធ្វើក្តី, កាត់អវយវៈមានដៃជាដើមរបស់បុគ្គលដទៃដោយខ្លួនឯងក្តី ប្រើគេឲ្យកាត់ក្តី, បៀតបៀនគេដោយខ្លួនឯងក្តី ប្រើគេឲ្យបៀតបៀនក្តី, សោយសោកខ្លួនឯងក្តី ធ្វើគេឲ្យសោយសោកក្តី, នឿយហត់ខ្លួនឯងក្តី ប្រើគេឲ្យនឿយហត់ក្តី, ញាប់ញ័រខ្លួនឯងក្តី ធ្វើគេឲ្យញាប់ញ័រក្តី, សម្លាប់សត្វដោយខ្លួនឯងក្តី ប្រើគេឲ្យសម្លាប់ក្តី, លួចទ្រព្យគេដោយខ្លួនឯងក្តី ប្រើគេឲ្យលួចទ្រព្យអ្នកដទៃក្តី, លួចប្រពន្ធគេក្តី, និយាយកុហកក្តី អំពើទាំងនេះមិនមែនឈ្មោះថា ធ្វើអំពើអាក្រក់ទេ" សេចក្តីចូលចិត្តរបស់គ្រូនេះហៅថា អកិរិយទិដ្ឋិ ។ ឯអកិរិយទិដ្ឋិនេះជាសេចក្តីយល់បដិសេធកម្ម គឺបដិសេធកម្លាំងការធ្វើ ប្រកាន់យកបច្ច័យខាងក្រៅ គឺបុគ្គលដទៃជាអ្នកឲ្យល្អឲ្យអាក្រក់វិញ ។ ខុសគោលពីលទ្ធិព្រះពុទ្ធសាសនារបស់យើង ដែលប្រកាន់ថាការធ្វើនោះឯងជាហេតុ

---

១ បូរណៈប្រែថា ពេញ ជាពាក្យដែលគេហៅបន្ថែម កស្សបៈជាឈ្មោះគោត្ត ។ មានសេចក្តីដំណាលថាអ្នកនេះ ១ នាក់មានខ្ញុំតែ ៩៩ នាក់មកយូរហើយ វេលាក្រោយមកបានខ្ញុំ ១ នាក់បន្ថែមជា ១០០ ទើបហៅខ្ញុំក្រោយបំផុតនោះថា "បូរណៈ" មិនយូរប៉ុន្មានបូរណកស្សបៈបានរត់លែងធ្វើខ្ញុំគេ លុះទៅដល់កណ្តាលព្រៃពួកចោរដណ្តើមយកសំពត់អស់ពីខ្លួន មានមនុស្សច្រើនរយនាក់ ឃើញបូរណកស្សបៈអាក្រាតកាយ សំគាល់ថាព្រះអរហន្ត ហើយក៏នាំគ្នាមកចុះចូលយកជាគ្រូអាចារ្យ ។ ចំណែកបូរណៈឯង ក៏កាន់យកភាពជាអ្នកអាក្រាតកាយនោះជាសាភេទអ្នកបួសដើម្បីចិញ្ចឹមជីវិតចាប់ដើមពីត្រឹមថ្ងៃនោះមក ។ គ្រូនេះជាអ្នកពោលបដិសេធកម្មថាធ្វើទុកដូចជាមិនធ្វើ ហៅថា អកិរិយវាទ ។ សាមញ្ញផលសុត្តវណ្ណនា ។

ជួបមនុស្សប្លន់យកទ្រព្យរបស់គេ សូម្បីគេចាប់យកទៅធ្វើទោសមិនបាន ក៏ដោយ ក៏គង់តែបានសេចក្ដីក្ដៅក្រហាយចិត្ត ដែលហៅថាវិប្បដិសារី មិនខាន, មនុស្សប្រព្រឹត្តទ្រព្យរបស់ខ្លួន ទៅជួយទំនុកបំរុងអ្នកដទៃ សូម្បី មិនបានផលឲ្យឃើញទាន់ហន់ជាក់ស្ដែងនឹងភ្នែកក៏ពិតមែន តែពេលដែល ឡើងរឭកហើយ ក៏គង់មានសេចក្ដីរីករាយចិត្តខ្លួនឯង, ព្រោះការធ្វើអំពើល្អ ឬអំពើអាក្រក់នោះ រមែងឲ្យផលជាសុខជាទុក្ខ ក្នុងលោកទាំង ២ គឺលោក នេះនិងលោកខាងមុខ តាមសមគួរដល់កម្លាំងកម្ម ។

២– អហេតុកទិដ្ឋិ សេចក្ដីយល់ឃើញរបស់បុគ្គលពួកខ្លះថា មនុស្សយើងបានល្អឬបានអាក្រក់ក៏បានឯងៗ ឥតមានអ្នកប្រើឲ្យបានទេ គឺថាបើដល់ពេលដែលត្រូវបានល្អ ស្រាប់តែការងារអ្វីក៏មានគេសរសើរ មានគេជួយទំនុកបម្រុងថែរក្សា ទាំងលាភយសក៏កើតមានឡើងតាម លំដាប់គ្នា បើដល់ពេលដែលត្រូវអាក្រក់ ធ្វើអ្វីមានគេតិះដៀល មាន គេបោះបង់ចោល ទាំងលាភសក្ការៈធ្លាក់យសសក្ដិតាមលំដាប់គ្នា, ការយល់ឃើញបែបនេះហៅថា អហេតុកទិដ្ឋិ ។ សេចក្ដីនេះត្រូវគ្នា នឹងពាក្យអ្នកដទៃនៃសាមញ្ញផលសូត្រថា សេចក្ដីចូលចិត្តរបស់គិរិយ

១ នាក់ឈ្មោះមក្ខលិគោសាល[១]ថា “ហេតុបច្ច័យដែលនាំឲ្យពួកសត្វសៅហ្មងមិនមាន, ពួកសត្វដែលនឹងសៅហ្មង ក៏សៅហ្មងឯងៗ មិនមែនមកអំពីហេតុបច្ច័យអ្វីទេ; ចំណែកខាងហេតុបច្ច័យដែលនឹងនាំឲ្យពួកសត្វបរិសុទ្ធក៏មិនមាន ពួកសត្វដែលបរិសុទ្ធក៏បរិសុទ្ធឯងៗ មិនមែនមកអំពីហេតុបច្ច័យអ្វីទេ” ការយល់ឃើញរបស់គ្រូនេះហៅថា អហេតុកទិដ្ឋិ ។ អហេតុកទិដ្ឋិនេះ ជាសេចក្តីយល់ឃើញបដិសេធហេតុ ប្រកាន់យកបច្ច័យខាងក្រៅ គឺពេលវេលាដែលជាគ្រោះកាចគ្រោះល្អ បណ្តាលឲ្យសុខឲ្យទុក្ខវិញ ខុសពីលទ្ធិរបស់ព្រះពុទ្ធសាសនាដែលសំដែងថា សង្ខតធម៌ទាំងពួង សុទ្ធតែកើតមកអំពីហេតុ ។ សូម្បីមិនប្រាកដថាអ្វីជាហេតុនៃធម៌ឈ្មោះនេះ ឬ ឈ្មោះនោះ ក៏គង់តែធម៌ទាំងនោះឯងកើតមកអំពីហេតុតែម្យ៉ាង ។

៣— **នត្ថិកទិដ្ឋិ** សេចក្តីយល់ឃើញរបស់មនុស្សពួកខ្លះថា សត្វ បុគ្គល មិនមាន រូបនេះគ្រាន់តែជាធាតុប្រជុំគ្នាហើយកកើតឡើង

---

១ មក្ខលិ ប្រែថា កុំភ្លាត់ ជាពាក្យដែលម្ចាស់ប្រាប់ឲ្យប្រុងស្មារតី ដែលហៅថាគោសាល ព្រោះកើតក្នុងរោងគោ ។ មានសេចក្តីដំណាលថា គ្រូនេះពីដើមជាខ្ញុំរបស់អ្នកមានម្នាក់ កាលដើរកាន់ឆ្នាំងប្រេងលើដីមានភក់ ម្ចាស់ឃើញប្រាប់ថា នែឯងប្រយ័ត្នកុំឲ្យភ្លាត់ គ្រាន់តែម្ចាស់ប្រាប់ផុតពីមាត់ វាក៏ឲ្យភ្លាត់ជើងដួលទៅ ហេតុតែវាខ្លាចម្ចាស់ពេកក៏លួចរត់ ម្ចាស់ដេញតាមចាប់បានតែសំពត់ វាស្ទុះរត់ទៅទាំងអាក្រាតកាយ ។ ពួកមនុស្សល្ងង់ឃើញដូច្នោះក៏សំគាល់ថាព្រះអរហន្ត ទើបនាំគ្នាប្រគល់ខ្លួនជាសិស្ស ។ គ្រូនេះជាអ្នកពោលឃាត់ហេតុអាក្រក់ល្អថាគ្មាន ហៅថា អហេតុកវាទ ។ សាមញ្ញផលសុត្តវណ្ណនា ។

ការធ្វើសេចក្ដីទុកបម្រុងគ្នាឬ ធ្វើការប្រទូស្តដល់គ្នានឹងគ្នា ក៏មិនមែនជាបុណ្យមិនមែនជាបាបទេ ដូចគ្នានឹងទឹកភ្លៀងដែលបង្អុរធ្លាក់ចុះមកព្រោះព្រំក្ដាលកាលល្វើលើព្រៃ. ឲ្យរុក្ខលតាសំដុះដាលមានដើមដងផ្លែផ្កាឡើង ឬដូចភ្លើងដែលឆេះដើមឈើឲ្យស្លាប់ ក៏មិនមានបុណ្យមិនមានបាបអ្វីដល់ភ្លៀងទឹងភ្លើងនោះទេ, ការយល់ឃើញបែបនេះហៅថា នត្ថិកទិដ្ឋិ ។

សេចក្ដីដែលបានពណ៌នាមកនេះ សមនឹងពាក្យអដ្ឋកថានៃសាមញ្ញ-ផលសូត្រថា សេចក្ដីយល់ឃើញរបស់គ្រូ ១ នាក់ឈ្មោះអជិតកេស-កម្ពលៈ(១)ថា សត្វទាំងឡាយលុះបែកធ្លាយកនឹងកាយ ស្លាប់ទៅតែងសោះសូន្យលែងឈ្មោះមិនកើតទៀតទេ ព្រមទាំងយល់ឃើញថា

១- នត្ថិ ទិន្នំ(២) ទានដែលបុគ្គលឲ្យហើយមិនបានផល

២- នត្ថិ យិដ្ឋំ ការបូជាធំ គឺទានធំជាវានសាធារណ៍ដល់ជនទាំងពួង មិនមានផល

៣- នត្ថិ ហុតំ គ្រឿងសក្ការៈតូច គឺគ្រឿងសក្ការៈដែលគួរធ្វើដល់ភ្ញៀវ មិនមានផល

---

១ ពាក្យថា " អជិត " ជាឈ្មោះដែលមាតាបិតាសន្មតឲ្យ, ដែលហៅថា " កេសកម្ពលៈ " ព្រោះគ្រូនេះតែងស្លៀកសំពត់កម្ពលដែលធ្វើអំពីសក់មនុស្ស ។ គ្រូនេះជានត្ថិកវាទផងជាឧច្ឆេទវាទផង ព្រោះជាអ្នកពោលឃាត់ផលថាមិនមាន ទាំងឃាត់កំណើតថា សត្វស្លាប់ហើយសូន្យ ។

២ ទាំងពីទី ១ ដល់ទី ១០, ហៅថា វត្ថុមិច្ឆាទិដ្ឋិ ។

៤- នត្ថិ សុកតទុក្កដានំ កម្មានំ ផលំវិបាកោ ផលវិបាកនៃកម្មដែលសត្វធ្វើល្អ ឬធ្វើអាក្រក់ មិនមាន

៥- នត្ថិ អយំ លោកោ លោកនេះ (ដែលសត្វស្ថិតនៅក្នុងលោកខាងមុខ គប្បីបានដោយសារកម្ម) មិនមាន

៦- នត្ថិ បរោ លោកោ លោកខាងមុខ (ដែលសត្វស្ថិតនៅក្នុងលោកនេះ គប្បីបានដោយសារកម្ម) មិនមាន

៧- នត្ថិ មាតា សេចក្តីប្រតិបត្តិល្អឬប្រតិបត្តិអាក្រក់ចំពោះមាតា មិនមានផលបុណ្យ ឬ ផលបាប

៨- នត្ថិ បិតា សេចក្តីប្រតិបត្តិល្អឬប្រតិបត្តិអាក្រក់ចំពោះបិតា មិនមានផលបុណ្យ ឬ ផលបាប

៩- នត្ថិ សត្តា ឱបបាតិកា សត្វដែលច្យុតហើយទៅចាប់កំណើតទៀត មិនមាន

១០- នត្ថិ លោកេ សមណព្រាហ្មណា ពួកសមណៈ ឬព្រាហ្មណ៍ក្នុងលោកនេះ ដែលប្រព្រឹត្តល្អប្រតិបត្តិត្រឹមត្រូវ មិនមាន សេចក្តីយល់ឃើញរបស់ត្រូវនេះហៅថា នត្ថិកទិដ្ឋិ ១ នេះជាសេចក្តីយល់ឃាត់វិបាក គឺបដិសេធផលរបស់អំពើល្អនិងអំពើអាក្រក់ថាគ្មានអំណោយផលជាសុខជាទុក្ខទេ, ខុសពីលទ្ធិពុទ្ធសាសនាដែលប្រកាន់ថា

សេចក្តីសុខទាំងនុ៎ះឯងជាផលដែលផ្លែចេញមកអំពីកម្ម គឺកុសលកម្ម ផ្លែចេញមកជាសេចក្តីសុខកាយ សុខចិត្ត, អកុសលកម្ម ផ្លែចេញមកជាសេចក្តីទុក្ខកាយ ទុក្ខចិត្ត, ផលវិបាកនេះឯងតែងអន្ទោលតាមបុគ្គល ដូចស្រមោលអន្ទោលតាមប្រាណ ។

## មិច្ឆាទិដ្ឋិប្រែប្រួលមកជាពីរវិញ

មិច្ឆាទិដ្ឋិទាំង ៣ ប្រការនេះ បើពោលតាមដំណើរនៃដួងចិត្តមាន ត្រឹមតែ ២ យ៉ាងគឺ:

១- អនិយតមិច្ឆាទិដ្ឋិ ការយល់ខុសមិនទៀង

២- និយតមិច្ឆាទិដ្ឋិ ការយល់ខុសទៀង

អធិប្បាយ :- មិច្ឆាទិដ្ឋិកបុគ្គលឯណា ជាអកិរិយវាទី ជាអហេតុកវាទី ជានត្ថិកវាទី ដែលជាអ្នកឃើញខុសមិនទាន់ទៀងទាត់មិនទាន់ចុះចិត្តជឿស៊ប់ នៅអាចកែប្រែស្ទាក់ស្ទើរក្នុងចិត្ត ជាអ្នកយល់ខុសនៅមានផ្លូវកែឡើងវិញបាន គឺថាបើមានអ្នកប្រាជ្ញស្តីប្រដៅទូន្មាន អ្នកនោះឯងគេចនឹងងាកបែរត្រឡប់មកកាន់ផ្លូវត្រូវវិញ ព្រោះចិត្តរបស់បុគ្គលនោះ មិនទាន់ធ្លាក់ចុះក្នុងដួងចិត្តជាគំរប់ ៧ នៅឡើយ, សេចក្តីយល់ឃើញខុសរបស់បុគ្គលនោះ ហៅថា អនិយតមិច្ឆាទិដ្ឋិ ។

(មានត)

## ព្រះគ្រូមហាបទុម មាឃ – ស៊ុន រៀបរៀង

(តមក)

កិរិយាដែលមិនសុភាពរាបសាពេញបាន គឺអាចធ្វើខ្លួនឲ្យទៅជាអ្នកមានអធ្យាស្រ័យល្អសមគួរនឹងបាននាមថា បរិសញ្ញូ = អ្នកស្គាល់បរិស័ទជាបុគ្គលដែលបណ្ឌិតគប្បីសរសើរ ។ ឯអបចាយនវិធីនោះលោកសំដែងទុកថា មាន ៤ ប្រការគឺ អភិវាទនំ = ការថ្វាយបង្គំឬដំរាបសួរ ១ បច្ចុដ្ឋានំ = ការក្រោកទទួល ១ អាសនទានំ = ការឲ្យអាសនៈ១, មគ្គទានំ = ការប្រាប់ផ្លូវ ១ សក្ការគរុការមានបូជា = ធ្វើសក្ការៈគោរពរាប់អានបូជា ១; អាការទាំង ៤ នេះឯងជាអបចាយនវិធីដែលបុគ្គលគប្បីប្រព្រឹត្តចំពោះវុឌ្ឍបុគ្គលទាំង ៣ នោះ ។ មានសេចក្តីសរសើរថា អបចាយនមយបុណ្យនេះ លោកពណ៌នាថាជាកុសលដ៏ប្រសើរ អាចកំចាត់បង់នូវឧបបីឡកកម្មនិងឧបឃាតកកម្មបាន អំពីនោះនឹងផុតចាកអន្តរាយផ្សេងៗ ហើយឈ្មោះថាធ្វើខ្លួនឲ្យជាបុគ្គលមានសភាពរាបសាគួរឲ្យអ្នកដទៃមានមេត្តាករុណាសង្គ្រោះស្រឡាញ់រាប់អាន ថែមទាំងបានសម្រេចដោយពរ ៤ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ សមដូចពុទ្ធភាសិតថា

អភិវាទនសីលិស្ស និច្ចំ វុឌ្ឍាបចាយិនោ
ចត្តារោ ធម្មា វឌ្ឍន្តិ អាយុ វណ្ណោ សុខំ ពលំ

សេចក្តីថា ធម៌ទាំង ៤ យ៉ាងគឺ អាយុ វណ្ណៈ សុខៈ ពលៈ តែងចំរើនដល់បុគ្គលអ្នកធ្វើសេចក្តីគោរពសំពះអោនលំទោនចំពោះបុគ្គលដែលគួរគោរពគោរពក្រែង ៗ មានសេចក្តីអធិប្បាយថា បុគ្គលអ្នកមានប្រក្រតីប្រព្រឹត្តបន្ទាបបន្ទន់ខ្លួនដោយអភិវាទនកម្មជាដើម រមែងធ្វើខ្លួនឲ្យជាទីស្រឡាញ់ដល់អ្នកធំ គឺការធ្វើចិត្តរបស់លោកឲ្យមានមេត្តាសង្គ្រោះដល់ខ្លួន ហើយក៏នឹងបានបួងប្រថ្នាទូទៅជាទីពេញចិត្ត គឺអាយុយឺនយូរ, សម្បុរល្អ, សេចក្តីសុខងាយសប្បាយចិត្ត នឹងកំឡាំងពលដ៏បរិបូណ៌ ៗ

ន័យម្យ៉ាងទៀត លោកពោលគាថាទុកថា:

យេ វុឌ្ឍំ អបចាយន្តិ នរា ធម្មស្ស កោវិទា
ទិដ្ឋេ ធម្មេ ច បាសំសា សម្បរាយោ ច សុគតិ

សេចក្តីថា នរជនឯណា ឈ្លាសក្នុងធម៌ (ស្គាល់ច្បាប់) បានទន់លំទោនដល់អ្នកដែលគួរគោរព នរជននោះ រមែងបានសេចក្តីសរសើរក្នុងបច្ចុប្បន្នភពនេះ លុះរំលាយខន្ធទៅកាន់បរលោកហើយរមែងបានទៅកើតក្នុងសុគតិភពទៀត ៗ តែបើមិនមានអបចាយនបុគ្គល គឺបុគ្គលដែលសមគួរទទួលទន់លំទោនទេ គប្បីធ្វើសេចក្តីទន់លំទោននឹងសក្ការបូជាចំពោះព្រះធម៌ដូចព្រះបរមគ្រូគ្រប់គ្រាធ្លាប់ទាំងឡាយ ដែលទ្រង់

គោរពក្នុងសព្វពិធកជធម៌ដូច្នោះ  សូម្បីតែព្រះបរមលោកនាថ  ទ្រង់ជាបុគ្គលប្រសើរលើសលុបជាងសាស្តាទាំងពួង  ក៏ទ្រង់តែងធ្វើសក្ការៈគោរពក្នុងព្រះធម៌ជាធម្មតា ។ មានរឿងដំណាលថា ក្នុងសម័យមុនដែលព្រះអង្គត្រាស់ដឹង ទ្រង់ប្រថាប់គង់ក្រោមដើមអជបាលនិគ្រោធជិតមាត់ស្ទឹងនេរញ្ជរាក្នុងឧរុវេលាប្រទេសសេនានិគម  ព្រះអង្គទ្រង់ដំរិះនិចគេនស្មានគួរៈគោរព  ទីពឹងទីកោតរូបបុគ្គលដែលទ្រង់គួរនឹងធ្វើសក្ការៈគោរពបូជានោះ ក៏ឥតប្រទះឃើញសមណព្រាហ្មណ៍ឯណានីមួយ ដែលទ្រទ្រង់នូវគុណធម៌  គឺសីលសមាធិបញ្ញា  និងវិមុត្តិដ៏វិសេសដែលទ្រង់គួរគោរពសោះឡើយ  ទើបទ្រង់សក្ការគោរពចំពោះធម៌ដែលព្រះអង្គទ្រង់បានត្រាស់ដឹងឯងជាជាធំ;  សេចក្តីនេះជាប្រវេណីរបស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយ  សមដូចតម្រាយភាសិតថា:

យេ ច អតីតា សម្ពុទ្ធា យេ ច ពុទ្ធា អនាគតា
យោ ចេតរហិ សម្ពុទ្ធោ ពហុន្នំ សោកនាសនោ
សព្វេ សទ្ធម្មគរុនោ វិហរឹសុ វិហាតិ ច
អថាបិ វិហរិស្សន្តិ ឯសា ពុទ្ធានធម្មតា

សេចក្តីថា ព្រះសម្ពុទ្ធទាំងឡាយអង្គឯណាមានក្នុងអតីតកាលទៅហើយក្តី  ព្រះសម្ពុទ្ធទាំងឡាយអង្គឯណានឹងមានក្នុងអនាគតក្តី  ព្រះសម្ពុទ្ធអង្គឯណាក្នុងបច្ចុប្បន្ននេះក្តី  ទ្រង់ធ្វើសេចក្តីសោករបស់ជនដ៏ច្រើនឲ្យវិនាស,

ព្រះសមុទ្រទាំងអម្បាលនោះ គ្រប់ព្រះអង្គសុទ្ធតែទ្រង់គោរពក្នុងព្រះសទ្ធម្ម ព្រះអង្គបានគង់នៅរួចទៅហើយផង គង់នៅក្នុងកាលឥឡូវនេះផង នឹងគង់នៅតទៅទៀតផង នេះឯងជាធម្មតារបស់ព្រះពុទ្ធទាំងឡាយ ។

តស្មា ហិ អត្តកាមេន មហត្តមភិកង្ខតា
សទ្ធម្មោ គរុកាតព្វោ សរំ ពុទ្ធានសាសនំ

ព្រោះហេតុនោះ អត្តកាមបុគ្គលអ្នកប្រាថ្នានូវសេចក្ដីចំរើន កាលរឭកឃើញនូវពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយហើយ គប្បីធ្វើសេចក្ដីគោរពព្រះសទ្ធម្មគ្រប់ៗពេល ។

អបចាយនមយកុសលមានផលជាវិបាកសម្បត្តិទាំងបច្ចុប្បន្ន ទាំងសម្បរាយិកភព គឺតែមនុស្សឲ្យបានទៅជាអ្នកមានអធ្យាស្រ័យដ៏ល្អ ប្រកបដោយបរិយោសម្មាគារវៈ រក្សានូវអន្តរាយដែលកើតមកអំពីបប-ឡិតកម្មនឹងឲ្យឃាតកកម្មបានហើយ បើកឱកាសឲ្យអ្នកដទៃមានមេត្តាករុណាស្រឡាញ់រាប់អានដល់ខ្លួនបានក្នុងបច្ចុប្បន្ន ទាំងផលក្នុងសម្បរាយិកភពក៏នឹងបានសម្រេចសមកាមប្រាថ្នាពុំខាន ។

## ៣– សណ្ហាវាចា

“ សំដីផ្អែមល្ហែម ”

វាចា ឬសំដីនេះរាប់ថាជារបស់សំខាន់មួយ គឺកាលនឹកដល់សេចក្ដីប្រព្រឹត្តិរបស់មនុស្សគ្រប់រូបនោះ អវយវៈចំណែកខាងក្រៅដែលនឹង

សំដែងឲ្យបុគ្គលដទៃដឹងបានងាយក៏គឺថ្វីកាយនឹងវាចាហ្នឹងឯង ។ ហេតុនេះវាចាទើបជាគ្រឿងសំខាន់បំណែកមួយដែលប្រាប់សេចក្ដីសំគាល់ក្នុងការញ៉ាំងប្រយោជន៍ឲ្យសម្រេចតាមសេចក្ដីត្រូវការរបស់មនុស្សសត្វ ។ ពាក្យពោលល្អ ឬអាក្រក់ក៏សម្រេចមកអំពីវាចាសំដែងចេញទាំងអស់ រមែងជាគ្រឿងបញ្ចេញឲ្យឃើញប្រាកដបានដោយងាយ ដល់ដួងចិត្តរបស់អ្នកពោលថា យ៉ាងនេះយ៉ាងនោះ ព្រោះហេតុនោះ ទើបមានពាក្យពោលទុកថា ហទយស្ស សទិសី វាចា វាចាដូចជាដួងហឫទ័យ មានសេចក្ដីអធិប្បាយថាដួងចិត្តដែលជាធម្មជាតល្អ ឬ អាក្រក់តាំងនៅខាងក្នុង ប៉ុន្តែដោយអាស្រ័យការបំណែកខាងក្រៅគឺវាចានោះឯង ទើបអាចប្រាប់ឲ្យដឹងបាន ព្រោះវាចាដែលលាន់ឮចេញមកខាងក្រៅនោះ អាស្រ័យមកអំពីចិត្តខាងក្នុងបណ្ដាលឲ្យពោល បើចិត្តល្អវាចាដែលសំដែងចេញទាំងអស់ក៏ជាវាចាល្អ បើចិត្តអាក្រក់ហើយវាចាដែលសំដែងចេញមកនោះក៏អាក្រក់ ប្រាកដជាមានពុទ្ធភាសិតក្នុងធម្មបទថា ៖

មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា
មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា
តតោ នំ ទុក្ខមន្វេតិ ចក្កំវ វហតោ បទំ

សេចក្ដីថា ចេតសិកធម៌ទាំងឡាយមានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត សម្រេចមកអំពីចិត្ត បើបុគ្គលមានចិត្តអាក្រក់ ទោះនឹងពោលក្ដី

ក៏តែងពោលសំដីអាក្រក់ ទោះធ្វើក៏តែងធ្វើអំពើអាក្រក់ ទុក្ខរមែងជាប់តាមបុគ្គលនោះ ពីព្រោះតែទុច្ចរិតនោះឯង ដូចជាកង់រទេះដែលវិលទៅតាមស្នាមជើងគោ ។

* មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា
មនសា ចេ បសន្នេន ភាសតិ វា ករោតិ វា
តតោ នំ សុខមន្វេតិ ឆាយាវ អនុបាយិនី ។

សេចក្តីថា ចេតសិកធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត សម្រេចមកអំពីចិត្ត បើបុគ្គលមានចិត្តល្អហើយ ទោះនឹងពោលក្តី ធ្វើក្តី ក៏រមែងពោលតែសំដីល្អធ្វើតែអំពើល្អ សុខរមែងជាប់តាមអ្នកមានចិត្តល្អនោះទៅ ដោយហេតុសុចរិតនោះឯង ដូចជាស្រមោលដែលជាប់តាមខ្លួនដូច្នោះ ។

ពុទ្ធភាសិតទាំងពីរនេះ គ្រាន់តែសំដែងឲ្យឃើញថា កាយល្អឬអាក្រក់ ក៏ព្រោះចិត្តជាធំ ។ ព្រោះកាយជាធម្មជាតសម្រាប់ប្រើក្នុងប្រយោជន៍ដ៏ធំដូច្នេះ ទើបត្រូវចេះលៃលកប្រើកាយក្នុងកិច្ចដែលគួរ ។ កាយនេះជារបស់កណ្តាល ប្រៀបដូចគ្រឿងប្រើខ្លះ ដូចយ៉ាងពន្លាក- ពូថៅជាដើម ជាគ្រឿងប្រកបកិច្ចការជាងឈើ តែបើបុគ្គលមិនដឹងប្រើ នាំយកទៅប្រហារបុគ្គលដទៃ ក៏រមែងឲ្យទោសដល់អ្នកដែលបានប្រើ

(មានត)

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនាៈ ព្រះគ្រូសុវណ្ណញាណ សូរ-ហាយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកអក្សរសាស្ត្រ* ទំព័រ

លោក ហេង-ឃ៉ាន់ — កំពូលស្នេហា (តមក) . . . . . . . . . . . ២២៥

ឃុន សុន្ទរមេធី ញ៉ង-សៀង — ឯកសហស្សរាត្រី ភាគទី១១ . . . . . . . . ២៤០

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម — ព្រះរាជប្រវត្តិ ព្រះបាទសម្តេចព្រះជ័យចេស្តា (ព្រះអង្គសួរ) (តមក) . . . . . . . . . . ២៥៤

*ផ្នែកសាសនា*

ឃុនសុវត្ថិវេទី យូរ-អ៊ុន — មិច្ឆាទិដ្ឋិកថា (តមក) . . . . . . . . . . ២៦៣

ព្រះគ្រូមហាបទុម មាឃ-ស៊ុន — ធម្មវត្តបរិយាយ (តមក) . . . . . . . . . ២៧៦

ឆ្នាំទី ១៨ — លេខ ៥ ខែមេ ១៩៤៦ — ដំឡៃជាវៈ ១ ឆ្នាំ ៣៥ រៀល ។

# លោកហេង-យ៉ាន់ រៀបរៀង

(តមក)

ពេលនោះ ថ្ងៃចេញស្រឡះភ្លឺច្បាស់សព្វទិសទី បក្សាបក្សីម្លូលមីរ ច្រៀលច្ចាត់ ឯអាកាសវេហាស៍ នៅកណ្ដាលទីធ្លា មានដើមដក់ទឹម ក្រហមមួយដើម យោលយោកផ្កាផ្គួនផ្កាយ៉ាងល្អងល្អាយ នាំឲ្យមេអំបៅរែកឃ្មុំបណ្ដែតខ្លួនតាមខ្យល់សំពៅមក ត្រដាងស្លាបលឿងរំលេចពណ៌ឈាមជ្រូកមានរង្វង់ខ្មៅកណ្ដាល សំរាំផងកិរិយាដំកើងចុះជាកំពូលនៃពួកសត្វល្អិតស្អិតកង់សួនច្បារ ចុះទំលើផ្កាយ៉ាងថ្នម ផក់ស្លាបរេរ ៗ យ៉ាងសង្ហា រួចបានទៅស្ទៀមលាប្រមោយជញ្ជាប់ក្រេបយករសលំអងកេសរ ។

នៅលើមែកដើមចម្ប៉ាស្លឹកខ្ចីល្អក់ កូនចាប ១ គូសម្បុរស្រស់ព្រាល លេងជាសុខបៀតគ្នា សំឡេងម៉ើលៗតាមធម្មជាតិដែលមានលំអ ដូចជាទៅស្ពានសួគ៌សម្រាប់សកុណជាតិ ១ គូនោះ ។ ក្រោមម្លប់ផ្ទះឯនាយឯណោះ ព្រាប ១ គូទំសំកុកក្រៀមក្រេវើយ ព្រាប ១ នោះសម្បុរខៀវ កជ្រកក្បាលក្រោមស្លាប ព្រាប ១ ទៀតសម្បុរស ។ ទស្សនភាពនោះគួរឲ្យស្នេហាពន់ពេក ។

សោភ័ក្ត្របានចាកទុកអង្គដួងចិត្តបរារម្មណ៍វាំងនោះហើយ ក៏កើតសេចក្តីត្រេកត្រអាលទើបឃើញថា មេអំបៅមានផ្កាជាទីគាប់ចិត្ត ស្រស់ថ្លាព្រេចផ្គិតទើងគ្រប់ បំណែកសោភ័ក្ត្រក្រោកតែម្នាក់ឯង ឱ! បក្សីហើរបានហើយសម្រែយស្វាបតែ ក្តីទុក្ខបានឃើញច្បាស់ ឯផែនដីមានព្រះអាទិត្យជាទីពឹង នៅក្នុងលោកគេងមានគ្នាផ្កាពីនាក់! សោភ័ក្ត្រត្រេកតែម្នាក់ឯង គ្មានឱ្យអាសូរទេ! រូបធម្មជាតិក៏ផ្សាយនូវសេចក្តីស្នេហាគ្រប់តំបន់..............តែសោភ័ក្ត្រឈរជិតណាំដំនេត្រផលល្អជាប់អស់ពាំងស្រីក្រមុំក្រពេញ ចុះដូចម្តេចក៏នៅតែទទេរបញ្ញ ជូរថ្មីកង់ចិត្តធ្វើអ្វីទៀត ឱកាសនោះហើយដែលគួរធ្វើតែធ្វើឱ្យមានស្រឡាញ់គ្រាន់តែហាមោកនិយាយកេងាងពីរបីម៉ាត់ប៉ុណ្ណោះទេតើ មិនជាការក្រទេតែសោភ័ក្ត្រជាអាត្មកៈមិនទាន់ចុះសម្រួលគន្ធិកប៉ុន្ណោះ ទើបនាំឱ្យរញ្ញាកអល់អែកកន្ទួកចិត្ត មិនគ្មាទីងហា មាត់សាស្រ្តនូវសេចក្តីពិតដល់នាងគ្រាន់តែសំឡឹងមើលមុខនារីហើយផកអើមដំប៉ុណ្ណោះ ។

ចំណែកតណ្ហាដនេត្រក៏ដឹងច្បាស់នូវទឹកចិត្តកំឡោះនោះ ទឹកអៀនថែរមើលតៃទៅ ៗ ទៅ រួចនិយាយសួរសោភ័ក្ត្រឡើងថា "ចុះលោកពូទីងអ្នកមិនជាអ្នកជាការប្រមូលជាអ្នកជំនួញ ?"

"កុំសួរខ្ញុំពីរឿងនេះ ព្រោះហាក់ដូចជានាំទុក្ខមកឱ្យខ្ញុំថែមទៀតយើងជាអ្នកមានទុក្ខទេនាព្រះចន្ទណាស់" ។

រួចក៏ស្ងៀម ព្រោះនឹកឃើញពាក្យពីមុននោះ ក៏សួរនាងឡើងថា "ចុះអ្នកភ្លេចពាក្យដែលខ្ញុំសួរពីមុននោះហើយឬអ្វី បានជាមិនឆ្លើយសោះ?"

"សួរខ្ញុំថាដូចម្ដេច?"

"ខ្ញុំភ្លេចអង្វរអ្នក ឲ្យអាសូរទ្រទ្រង់ខ្ញុំសេចក្ដីមេត្តាដល់ខ្ញុំឲ្យបានយូរអង្វែង តើអ្នកយល់ព្រមដែរឬដូចម្ដេច?"

នាងនៅតែស្ងៀមមិនស្ដី ។

"ដូចម្ដេចក៏អ្នកមិនមានប្រសាសន៍ពាក្យ ១ ម៉ាត់ ឲ្យខ្ញុំបានសុខចិត្តផង" ។

នាងសំឡឹងមើលទៅក្រៅ ឃើញស្លឹកទុំទេសចក់វិលៗ ញញឹមព្រាយ ទើបនាងបែរមកនិយាយថា "បង! បងដឿ ចុះខ្ញុំនេះមិនមានចិត្តការកំដូចបងយល់នោះទេ ខ្ញុំស្មើនឹងល្ហុងថ្ងៃមិញទៅហើយ បើខ្ញុំរកជួយរំដោះទុក្ខបងបានខ្លះនោះ ខ្ញុំធ្វើជូនមួយរំពេចឥតបង្អង់" ។

ឮហៅចេញឈ្មោះថា "បង" ជាគ្រាដំបូង សោកក៏ភ្ញាក់ព្រឺខ្លួន អណ្ដែតអណ្ដូងញ័រជើង ១ រំពេច ស្ទើរតែឈរមិនទាន់ ទើបរំពឹងគិតថា "គួរណាស់តែលន់តួឲ្យនាងបានដឹង តែខ្លាចនាងខឹងទាស់ហេតុលោកផុតក្ដីទៅ ព្រោះឃើញមុខនាងក្រញូវចិញ្ចើម សោកក៏ត្រូវនៅតែក្រង់វិញ សេចក្ដីពិត នេះបានចំជាមហាលាភ" ។

"គ្រាន់តែមានប្រសាសន៍ប៉ុណ្ណេះ ខ្ញុំមានសេចក្ដីត្រេកអរក្រៃលែង ខ្ញុំមិនមានសង្ស័យទៀតថា អ្នកមិនមានមេត្តាផ្សាយអញ្ញាស្រែយដឹងគុណយេ ជួយគ្រេះពាំគោះរូបខ្ញុំ ដែលជាមនុស្សជុំនោះយ៉ាប៉ុន" ។

ពេលនោះ ខ្លួនឲ្យចំពៀកគស្លាប់ណាស់ ស្រាប់តែព្រះសូរ្យ រៀងរះខ្ពស់ឡើង កាយពន្លឺព្រេងព្រាគក្លួសឡោសខ្ទៅថ្វាស្រែឡះបញ្ជាស់ ដាច់ពីថ្ងៃមុនៗ អស់បក្សាបក្សីស្រុះឡើងរៀវខ្វាបចុះឡើងបំពេញពីពេះពាប ត្រៀក ណាក់យោបក់ត្រសៀកលើស្លឹកឈើ ដែលចេញទីនលាស់ថ្មីៗ ស្រោងស្រស់ អស់ព្យុជានានាគពោធិកញ្ញាក់ពាំក្រកចេទ្ធធរលើចង សឹងមានក្លូមកអឹងក្នុងទេហឹងហើរពេលូបនគត្រឹកគត្រេង កណ្ដាលក្ដែន លន្ទ្រង់លេខ្លាចដែលពួកសត្វល្អិតបានប្រត់កងគុម្ពឈើ ឥន់មើលទៅលើ ឃើញមេឃខៀវស្រងាត់ល្អឲ្យជ្រះថ្លាកន្ធិត ។ សត្វចាបទំលើមែក បព្ជា អត់ត្រាំពុំបានក៏បាចំពុះច្រៀងក្រអឹកញាក់កន្ទុយព្រឹតៗ ចាំង ក្នុ បំណែកត្រោចសន្ទឹងព្រាបរះខៀវកើតក្រៀវហើរចាកទេទំពូលលេង គឺបេត្តផ្ទៃជាទីសប្បាយ .. ។

ឯដំរិត្ថា ឮបូក្រសត្រោកក្រោកដឹតៗមក ក៏សូរដើតាពាក្យ ឆ្លើយកដល់ អ្នកតាំងពីកំនូលកន្ទិត ព្រោះមិនបានទៅឃើងដឹតគ្នាឲ្យ យូរគេទៅទៀត នាំគ្នាចេញមកក្រៅទទួលអាហារព្រោះយកក់ពាក់ ។

«ម៉េចទៅលោកគ្រូ បានស្រួលហើយឬ? ស្តាយណាស់មិនបានឯងទៅលេងជាមួយផង ។

«បាទ បានស្រួលហើយ» ក្រោយមក អ្នកណុដនេត្រក៏យកប់ពីខ្លួនទៅកាត់ភោគនៅឲ្យបងស្រីស្លាប់ជាតេសព្វគ្រប់ ដល់ពេលយប់និយាយ លោកគ្រូក៏ក្លែងសួរថា «ម៉េចប្អូន! ប្អូនភ្លេចពាក្យសន្យាហើយឬអ្វី?

«ខ្ញុំមិនភ្លេចទេ មកទៅ» ។

«ទៅក៏ទៅ ឲ្យតែប្រាកដណា តែការបង់ក់យេហើយ» ។

អ្នកទាំងពីរក៏បរលើលាគាមផ្លូវមក លុះដល់មុខផ្ទះណុដនេត្រ កុមារនោះក៏នេះចូលទៅក្នុងឲ្យលោកគ្រូឈរចាំក្រៅរបង ដោយយកពាក្យថាខ្លួនចូលកេចំណាប់ររកោតសិន តែក្លួនៈទៅបាត់លែងចេញមកវិញ លោកគ្រូក៏ញញឹមដើរហួសទៅផ្ទះ ។

ទុក្ខព្រួយសំណាក់ហ្ន៎! បានចួបប្រទះលើនារីរូបបវរ មានទឹកចិត្តត្រជាក់ស្រាយខ្លួនឈាយដូចត្រីសេភា លោកគ្រូក៏សុខចិត្តធ្វើជីវិតនឹងណុដនេត្រ ហើយជាសេចក្តីស្នេហាដែលផុះផុលឡើងជាគ្រាដំបូងបង្អស់ ទើបហួសគិតដល់ក្រមុំព្រហ្មចារិនីដែលបានប្រទះឃើញមកនឹងគេនានណាមួយប្រៀបផ្ទឹមជាមួយនឹងណុដនេត្រផងពុំបាន មានតែណុដនេត្រហើយជាត្រូវជីវិតរបស់គេ ។ «ណុដនេត្រព្រលឹងបងអើយ!

បើបែរជាម៉ែឪសម្ដែងសេចក្ដីប្រាថ្នាទេ សម្របនឹងគត់ពិន្ទុទៅលើរៀងគួរ
ដល់អស់អាយុសង្ខារ ។

សេចក្ដីសង្រ្គើមស្រើបស្រាល ក៏ព្រះតាំងទាំងក្លាក្នុងសន្ដានចិត្ត សោកក្រៃក្រៃលែងគ្មានអ្វីមិនកើត រៀបសំបុត្រចេះតែគាន់ព្រៃទៀប ផ្ទួន ក៏រាយមាយក្លួចបំពេញការណ៍យកចួរទៅក៏សឹងខាន ត្រូវធ្វើពាក្យទោ មនោសព្រួយ ទុកជាសោកក្ដៅអស់សន្ដិ៍ចិត្តយ៉ាងណា ក៏មិនអាច ឃាត់ខាំងសេចក្ដីរើរវាយកុំឲ្យបូលមកត្រឡប់ស្នាក់បានឡើយ ព្រោះពិស ព្រួយបាញ់បុសនៃសរកាមទេពត្រូវត្រង់ចំសព្វសរសៃ រលាយស្ទើរចូល ក្នុងឈាមហើយ ខឹងចប់ចល់ទឹកត្រូវមាំដោយទោសជំងឺសេសសង់ណាបាន សម្ប្រព្រះផ្ទៃដែលជាស្ដេចនៃទេវតា ក៏គង់សោយព្រះភ័ក្ត្រយាំបែរទៅ នាងៗមានភោគវត្តីដែរ បម្រុងជាតិមនុស្សសាមញ្ញ ទឹងអត់ធន់ដួចម្ដេចកើត...។ ក៏ឯបំណាននៃមួយរបស់សោកក្ដៅពេលនោះ គឺបានជួបមុខណាដះនៃនាង នារី បានអង្គុយជិតនាង បាននិយាយរកនាង ។

យប់មួយ មេឃប្រាសចាកមន្ទិលក្ដីស្រទន់ ព្រះចន្ទបែងបញ្ចាស់ ត្រចះត្រចង់ឯអាកាសល័យ ចះក្ងួញស្មើទៀតស្រអាប់លើធម្មជាតិស្រស់ ហ៊ុមព្រង ឯវល្លិ៍លួតលាស់ស្រោងស្រអាប់ដោយស្លឹកទ្រលទ្រប់ព្រាលទៅ ផ្កាយ ផ្កាត្រយោងកែវស្អុះស្អាតយសំយុងចុះដាក់រយោលទោលក្នុងត្រអួបសាយ សត្វពង្រីកលាក់ខ្លួនបំពួនកាយក្រោមដើមស្មៅ ចន្ទីសំឡេងញ័រទ្ទ័រពេង

ស្ងៀម ៗ រត្តិកាលនោះវិសេសមែនៗ ពកាបម្រើងបំពេរល្វេចល្វើយ ណា ខ្យល់រំភើយត្រសៀកត្រជាក់ចិត្ត ។

នៅកណ្ដាលសួននោះ មានបុរសនិងស្ត្រីអង្គុយលេងតែពីរនាក់ ស្ត្រីនោះអង្គុយលើកៅអីវែង បុរសនោះអង្គុយលើកៅអីតូចបៀតជើងនាង មានមុខស្រពោនក្រៀមក្រំជាទុក្ខ ។

“ចុះបងកើតទុក្ខព្រោះអ្វីទៀតហើយ ខកចិត្តណាស់ ធម្មជាតិបំព្រងយ៉ាងនេះ នៅតែមិនសប្បាយទៀត” ។

បុរសនោះមិននិយាយថាដូចម្ដេច ទាញក្រដាសមួយផ្ទាំងពណ៌ខៀវ ពីហោប៉ៅហុចទៅឲ្យនាង នាងទទួលយកមកបើកមើលដឹងសេចក្ដីហើយ ក៏ធ្លាក់ដៃចុះមើលមុខបុរសនោះយ៉ាងព្រួយ ។

“បងអើយ ! ម្ដេចសត្វលោកតែងនឹកសហកគ្នាជាដរាប ! ឱមហាសមុទ្រម្ដេចក៏មកលេបមាតាបិតារបស់បងខ្ញុំដូច្នេះ ឱទេវតាណា មេឃា ម្ដេចមិនមេត្តាដល់សត្វលោកផង” ។

“អូនអើយ ខ្ញុំបងសព្វថ្ងៃនេះ ហាក់ដូចជាកូនសត្វព្រាត់សម្បុក ជាមនុស្សអនាថាឥតគេរាប់ ខ្ញុំអ្នកដ៏មានគុណទាំងពីរ ម្ដេចក៏ចាកចោលកូនទៅដូច្នេះ ឱពុកអើយ ! ឱម្ដាយអើយ ! ម្ដេចបោះបង់កូនឲ្យនៅតែម្នាក់ឯង បើឲ្យកូនបានទាន់ដំណើរទៅសុខ កូនក៏អស់ចិត្តដែរ” ទឹកភ្នែកស្រោចជោកមុខសោកក្រៃ គួរឲ្យអាណិតណាស់ពេក “កូនអើយ ជេណា ហាក់លោក

ហើយ ឡើយណាយទាំងអស់មិនចង់រស់តទៅទៀតទេ កំព្រាជូរចេះ អ្នក...អ្នក...ណាគេនឹងកប់កេងឥតទៅទៀត... មុខ... ជា... ...ល់ផ្ទង់ផ្កាឥដ្ឋិចសត្វស្រែងាបអណ្ដែតគគ្គាលស្ទឹង ខុមហាសមុទ្រ ឡើកកំមិនៈមេត្តាផល់ទ្រង់ខ្ញុំផង........" ។

"ណ្ហាយបង! បងសូមការម្មណ៍ព្រះកុំកើតទុក្ខពេក ធ្មេញបកសនា អ្នកទាំងប៉ិមានតែត្រឹមប៉ុណ្ណេះ ហើយអ្នកទាំងនោះក្មួនទៅកាន់លោកដីណ្ហូរហើយ បើកបអតជួបនឹងបងបាន កំគង់នឹងលួងលោមបងឲ្យរំប្រើងតស៊ូផល់ឧបស័គ្គនៃជីវិត ដោយសេចក្ដីក្លាហាន ។ ថែលជាបងនៅឯងនោះ ពុំមែនទេ ព្រោះណុជនេត្រនៅពិតនេះ...." ។

រូបនាងក៏ទាំមាត់សង្កត់បួលគ្នា នៅស្រៀមសង្កេតមើលកិរិយាសោកក្រៃដែលនើមមុខចេញពីដៃ ហើយក៏ទាប់ដៃសួរបញ្ឈក់ថា "ពំតម្លៃណុជនេត្រសំឡាញ់បង ? ។

នាងក៏ងក់ក្បាលទំនង់ទទួលពាក្យ សោកក្រៃក្រាបក្បាលលើដៃនាង យំយេសទ្ទុះដោយសេចក្ដីសោក បានសន្ទឹមៗ ស្ងប់ពាតអារម្មណ៍ ព្រឿងៗ គ្រប់ពិតដល់សេចក្ដីទុក្ខ គ្រប់បេះក្រប់ថ្ងៃ គ្រប់ប្រាក់ឲ្យទាំងមូល ។

*

* *

## វគ្គទី ៦

# កំឡាំងតណ្ហា

ព្រះអាទិត្យអស្តង្គតទៅហើយ  នៅសល់តែពន្លឺស៊ីជម្ពូលាបប្រាក់ ឯបស្ចិមទិស ហ្វូងក្អែកហើរតម្រង់ទៅទិសស្រុកខ្លួនវិញ សូរបក្សីរត្ត កន្ទ្រាន់ទ្រាំងខ្សឹកខ្សួល ធ្វើឲ្យអាកាសស្ងប់រំភើបក្រៀមក្រំ កើតជាសោក ខ្យល់ខ្សុកខ្សួលល្ងៀនលយងងឹតកាលើយ  គួរឲ្យស្រណោះអាឡោះអាល័យ ហ្ន៎ គួរឲ្យសោកស្តាយពេក! ។ លោកអ្នកយាមកាយបួនញាប់ឡើងៗ កៀន អ្នកស្រុកឲ្យឈប់សម្រាកកាយ ព្រោះងងឹតទឹតហើយ ។ សំឡេងនៅ កន្ទ្រឹមកំលាន់ញាប់ដូចគ្នាដែរ  សូរញញាំរដៃដែកបង្ហើយការ  ទីងសូរ ម៉ាស៊ីនរវិលរ៉ុំកំពង់ជាលើកក្រោយបង្អស់ ។ បន្ទាប់មកបាត់ស្ងាត់ឈឹងស្ងប់ឲ្យ ឯស្ងួនបូរ៉ិកស្ងាត់ដែរ តែខាងវាំងឮលឺយ៉ៃនៅឡើយរួចកំពែងព្នូទៀត ។

កណ្តាលសេចក្តីស្ងប់នោះ ឈរលើកាំជណ្តើរផ្ទះតាចារ្យ សោភ័ក្រ្ត ហុចក្រដាសមួយសន្លឹកឲ្យណុជនេក្រនារី  នាងទទួលយកពីដៃហើយ បើកមើលបានសេចក្តីថា :

"ប្អូន! បងបានសង្កេតឃើញកិរិយាគួរពិរុទ្ធរបស់ប្អូន  ដោយណែន ដើមទ្រូង ទុប្អូនអើយប្អូន នេះប្អូនបងលោសអ្វីទៅនឹងបង? ប្អូនបងមិន សមសក្តិនឹងនិយាយលេងជាមួយ? បានជាឃើញបងមកដល់ហើយបែរ ជាគេចមុខចេញ" ។

មើលព្រៃទៃបុណ្ណាំងមុខនាងឡើងស្លាំង បបូរមាត់ឡើងស្វាយមួយរំពេច ឯក្រដាសដែលនាងកាន់នៅដៃក៏ញ័របន្តិចៗ រួចនាងងើបមុខឡើងដាច់ចាក់យ៉ាងក្រៀមក្រំថា "បងកុំមានប្រសាសន៍បែបហ្នឹងខុសទេ ខ្ញុំមិនចូលចិត្តសោះ" ។

សោភ័ក្ត្រស្រឡាំងកាំងភ្ញាក់ដកសំបុត្រពីដៃនាងមក នាងក៏ចុះទៅនិយាយលេងជាមួយនឹងម្ចាស់ផ្ទះ សោភ័ក្ត្រមិនអស់ចិត្តដើរតាមទៅដែរ ព្រោះនាងមិនដែលធ្វើមុខបែបនេះសោះ ដើរទៅជិតនាងហើយ សោភ័ក្ត្រក៏ថ្លែងសេចក្ដីងឿងឆ្ងល់នោះដល់នាងថា "អូន! បងធ្វើឲ្យអូនខកអន់ចិត្តឬ បានជាអូនមានអាការបែបនេះដល់បង ចូរអូនមេត្តាប្រាប់បងផង បងនឹងកែប្រែគំនិតឲ្យល្អឡើងវិញ" នាងមិនស្ដី សោភ័ក្ត្រអង្វរតទៅទៀត "បើជាបងខុសត្រង់ម្ដេចមា អូនអាណិតសន្ដោសដល់បងម្ដងចុះ ធ្វើម្ដេចកម្មបងត្រូវតែគេស្អប់ខ្ពើមដូច្នេះ តែអូន បងមិនបានគិតឡើយថា អូនប្រែចិត្តរហ័សបែបនេះ អូនចាំទេ តើជីវិតបងប្រព្រឹត្តទៅដល់ពេលនេះ ព្រោះនរណា? ។

នាងនៅតែព្រងើយ ស្រាប់តែក្រោកដើរទៅផ្ទះយ៉ាងរហ័ស រួចតែល្មួចឈឺចិត្តទៅដោយសេចក្ដីទោមនស្ស សោភ័ក្ត្រក៏វិលមកកន្លែងអង្គុយទៀតវិញ ផ្ដើមតាមរាវរកនឹងសាកសួរឲ្យអស់សេចក្ដី ។ អង្គុយស្ងួយស្រពោន់ទើបនឹកឃើញថា កាលពីវេលាម៉ោង៨យប់ មានភ្ញៀវមក

សេនផ្ទះអាចារ្យព្រែនទាក់ ហើយគេបានអង្វរសោភ័ក្រ្តឲ្យលេងភ្លេងឲ្យស្ដាប់ សោភ័ក្រ្តក៏អង្គុយចុះដាក់ដៃលើខ្នងពីយ៉ាណូ ងើបមុខមើលលើប្រវត្តិផល់រឿងកំសត់របស់ខ្លួន ទាំងផល់មាតាបិតាទាំងបងប្រុសដែលបាត់បង់ទៅហើយ រួចបានទុនមុខចុះចាប់លេងភ្លេងឲ្យសមតាមដំណើរចិត្ត ។ សំនៀងស្រាលរួចស្រួចខ្ពស់ឡើងជាលំដាប់ ហើយស្រាកធ្លាក់ចុះមកទាបវិញ . យ៉ាងអាក់អួលហាក់ដូចជាសំដីនៃអ្នកហៀបនឹងស្លាប់ហាក់ជន្លក់នោះឯង រួចបានលន្ទង់លន្ទោចស្រួចឡើងពេញទាំងបន្ទប់សន្សឹមៗចុះមកវិញ ហាក់ដូចជាទំនួញថ្ងូរកុមារកំព្រា ។

ណុជនេត្រនារីឮហើយ បានស្អៀកចិត្តទឹកការណ៍គេខ្លាចផ្សា អត់ទ្រាំយំពុំបាន អ្នកឯទៀតក៏មានទឹកចិត្តដូចនាងគ្រប់គ្នា រំភើបព្រួយដូងហួចយមហិមា ទុកជាសូរស័ព្ទភ្លេងបាត់ស្ងាត់ទៅយូរណាស់ហើយ ក្ដីនោះនៅតែរងំក្នុងត្រចៀកនៅឡើយ ។

ចំណែកសោភ័ក្រ្តក៏ប្រញាប់វិលទៅផ្ទះវិញ ណុជនេត្រឆ្ងៀតសួរថា: "បងមានថ្វីដៃពូកែណាស់ បានរៀនភ្លេងនេះពីណាមក ខ្ញុំមិនដែលបានស្ដាប់សោះ" ។

"បងមានសៀវភៅមួយមានបទគ្រប់មុខ សៀវភៅនោះចៅហ្វាយគាំងបង បានឲ្យបងជាផ្ដាំ ព្រោះបងពូកែពីយ៉ាណូពេក" ។

“បងការណាំគេឲ្យខ្ញុំសូមខ្ចី” ។

“មានតែស្អែកបងយកមកឲ្យ” ។

ពីព្រឹកថ្ងៃនោះ លោកគ្រូបានយកសៀវភៅភ្លេងមកប្រគល់នឹងអាចារ្យ មុខគេ អាចារ្យសួរឡើងថា “ចុះយកសៀវភៅមកធ្វើអ្វីហ្នះ?

យកមកឲ្យណុជនេត្រ ព្រោះនាងសុំខ្ចីពីម្សិលមិញ មុខអាចារ្យទ្រង់ អង់បន្តិច “ទុកនៅនេះចុះ ចាំខ្ញុំឲ្យនាង” ។

លោកគ្រូមិនដឹងគិតធ្វើដូចម្ដេច ក៏ដាក់សៀវភៅលើតុ តែទឹកខាញ់នឹងអាចារ្យពេក ដល់នាងមក អាចារ្យហៅនាងទៅអង្គុយនាយតែពីរនាក់ ដដែកគ្នាសំឡេងទ្រង់គឹងរំនង់ដូចឈ្លោះគ្នា ចំណែកណុជនេត្រឡើងមុខក្រហមគ្រវីក្បាលបដិសេធញយៗ ហើយគ្រវៃដៃមិនឈប់ជាការសារៈនៃសេចក្ដីសន្ទុះសង្ស័យហួសមិនពេញចិត្ត ងាកមើលទៅលោកគ្រូម្ដងៗ ដែលអង្គុយប្រឈមមុខទៅតែដោយសេចក្ដីទំនឹងសេចក្ដីខ្មាស ព្រោះត្រូវនៅតែឯងឥតគេរាប់ ខ្ចីញញ័រសោចទិនអ្នកទាំងពីរនោះ តែមិនដឹងធ្វើដូចម្ដេច ក៏ដើរចុះឡើងពេញបន្ទប់ទទួលភ្ញៀវ រួចវិលមកអង្គុយកន្លែងដដែលវិញ ដល់នាងងាររមើលមកម្ដងទៀត លោកគ្រូញាក់មុខយ៉ាងដូរ នាំឲ្យនាងអត់ញញឹមពុំបាន ។ សម្រេចទៅអាចារ្យមុខក្រហមប្រហែលជាខឹងខ្លាំង ក្រោកក្រសមិននិយាយស្ដីថាអ្វី ដើរចូលទៅក្នុងទៅ ចំណែកណុជនេត្រក៏ក្រៀមមុខវិលទៅផ្ទះវិញ ។

កាលបើហេតុការណ៍អស់នោះច្បាស់ដល់ចិត្តហើយ សោភ័ក្ត្រ បានភ្ញាក់ច្បាស់ដល់សេចក្តីថ្លៃថ្លៃយ៉ាងហួស នៃអាការៈរបស់ណុជនេត្រ នេះច្បាស់ជាអាចារ្យគំរាំងរៃតនោះញុះញង់ហើយបានជានាំស្អប់ខ្ញុំមិនគួរសោះ អាចារ្យមកទ្រុស្តមិត្រដាក់គ្នាឯងដូច្នេះ! មិនយល់ដល់ដើមត្រូវនិងគ្នាផង មិនគួរឡើយ ខ្ញុំជាអាចារ្យមកធ្វើមារដែកសេចក្តីសុខរបស់គ្នាយ៉ាងនេះ ។ . ពិតស្មុគ ៗ ទៅ ចិត្តមនុស្សលោកអាក្រក់ក្រៃមែនហ្ន៎! ... សោភ័ក្ត្រគំគួនផញ្ញើគិតដូច្នោះ ស្រាប់តែអាចារ្យមកដល់ជាមួយនឹងមិត្តម្នាក់ទៀតដែលសោភ័ក្ត្រស្គាល់ជាក់ អ្នកនោះឯងទើបនឹងបានបុណ្យស័ក្តិជាសុភាពបុរស មាឌតូចគន់ស្តើងមុខ ជែនសក់ញែកចំហៀង ក្នុងក្រឡុបក្រឡាប់ជាមនុស្សវិល ច្រមុះធំបុង មាត់ក្របីថ ហែបជាអ្នកគិតច្រើន តោះនិយាយតិច ធ្វើអ្វីក៏មិនឲ្យផ្លូសព្វសហេតុ អ្នកទាំងពីរនាក់ធ្វើការៈដល់គ្នារួចហើយ ក៏អង្គុយចុះតែរៀងខ្លួន សោភ័ក្ត្រគន់មើលមុខអាចារ្យដូចជានៅដៃវិលទឹកថា "គាត់នេះគំនិតជ្រៅណាស់ មើលមិនធ្លុះសោះឡើយ ។ មុខយ៉ាងនេះមិនគួរបើចេះលេងតល់សោះ" ៕

ពន្លឺក្រហមព្រាល ៗ ឯបស្ចិមទិស កាន់តែស្រអាប់ទៅលំដាប់ ៗ សេចក្តីងងឹតសន្សឹម ៗ គ្របដណ្តប់ពិភពលោក ពួកទិសាចររបស់ទៀងទៀនភ្លឺ ៗ បំភ្លឺខ្លួននឹងត្រាច់រកភក្សាហារតាមសេចក្តីសប្បាយ ចំណែក

ពួកចិញ្ចឹមបក្សីណាក់ខ្លួនចំពួនកាយព្រំកើនកំរើក លុះហៅយកំណត់បានសេចក្ដី គំនិតគំនុំនៃនាត្រីវាល ៗ ដូច្នេះគួរឲ្យស្រណោះពេលនោះក្រពក គួរឲ្យសង្វេគដល់ជីវិតសត្វលោក រស្មីព្រះអាទិត្យវែងវែហៀរទិសលិច សាយសូន្យទៅ ជារូបភាពដ៏ពិតនៃជីវិតរបស់សោភ័ក្ត្រ កាលបាន ដឹងដំណឹងអាក្រក់ពីស្រុកមកថា ចាស់ពុកម្ដាយព្រមទាំងបងប្អូនបាត់មិន ឃើញវិលមកផ្ទះវិញ គឺដល់មរណភាពហើយ" សោភ័ក្ត្រកើតសេចក្ដី ទៀយណាស់ពេកលោកជាច្រើន តែបានស្បើយខ្លះព្រោះសន្សំមិត្តបាន ណាជាតែត្រជួយជួរជំនោម ឥឡូវណាជាតែត្រៃវត្តសង្ឃទៀត គួរឲ្យ បន្សៀតបន្ទាល់អង់ចិត្តទេ នុងនុចពីយ៉ាណាត់! ជំនួបដែលសោភ័ក្ត្រធ្លាប់ អង្គុយជាសុខ ជំនួបដែលសូន្យគន្ធរសេចក្ដីសុខកាយសប្បាយចិត្ត ឥឡូវ ដូចម្ដេចក៏សោភ័ក្ត្រលង់យល់ទៀតព្រោះតែជាប្រផ្នូលនៃអតីតរបស់ បុរសនោះ ៗ ពិតហើយ ទីណាដែលយើងជួបប្រទះសេចក្ដីសុខ យើង តែងឃ្លាតចាកទីនោះជាដរាប ៗ សោភ័ក្ត្រនឹកឃើញរឿងត្រូវយំទៀង តិច ៗ ទឹកមុខពេញចិត្តទេឃើញ ។

នៅពេលនោះស្រុកតាបុរសបានផ្ដាំផ្ញើទៀតថា ភាពទាំងដែល [illegible] ។

ភាពតាំងពីពេល "ខ្ញុំមានប្រសាសន៍យ៉ាងហ្នឹង លោក គាត់ពុន កើតទុក្ខ ព្រោះដូចជាប្រាសចាកមេត្តាធម៌ មួយវិញទៀត ត្រូវឲ្យដឹង

អាស្រ័យសោកក្រៀមផង មនុស្សនេះតែព្រួយចិត្តពោយតោសោកខ្លាំងណាស់ មិនស្គាល់ខុសត្រូវ ហើយធម្មតាអ្នកកើតទុក្ខក៏ជួបគាំងអស់ប្រយ័ត្នកើតវិការនឹងគ្នា តែកមិនសប្បាយចិត្ត ហើយខ្លួនក៏ពុំហានលេងដែរ" ។

គាថានេះក៏តែងប្រាប់បញ្ចូលសោកក្រៀមលេងផង ដើម្បីនឹងធ្វើឲ្យបានគេកសេចក្តីទុក្ខ ទើបអ្នកទាំង ៣ នាំគ្នាដើរមួយ ៗ តាមផ្លូវទៅដើរបណ្តើរដៃផ្អែកគ្នាបណ្តើរ ។

អាចារ្យ– លោកព្រះថេរស្រុតសាស្ត្រថា: "កាលណាដែលកុំធ្វើឲ្យខ្ញុំ កាលខ្ញុំកុំធ្វើឲ្យដែល" បានសេចក្តីដូចម្តេច? សុភាពបុរស– "ទេលោកអាចារ្យ ការត្រង់នោះស្រេចនៅលើលោកអាចារ្យហើយ" ។ អាចារ្យ- លោក ពាក្យនេះមានអត្ថន័យខ្លួនណាស់ កាលដែលជួបជាមិត្តភាព គឺការសមាគមនេះមានប្រយោជន៍ច្រើនយ៉ាង ពីព្រោះគល្យាណមិត្តប្រៀបដូចមាសប្រាក់ ទ្រព្យរត្នឯង ដែលជួយឲ្យយើងឆ្លងដើរកាត់លើសមុទ្រជីវិតបានដោយមិនលំបាក បើអ្នកណាមានមិត្តល្អច្រើន អ្នកនោះឯង ផុតពាក់សេចក្តីមើលងាយពីសំណាក់អ្នកដទៃ ហេតុនេះបានជាកុំធ្វើឲ្យខ្ញុំ បើបានគ្នាជាមិត្តភក្តិហើយ គោរពរក្សាមិត្តភាពនោះឲ្យបានខ្ជាប់ខ្ជួនឡើង កុំឲ្យអន្តរាយទៅដោយឃើញប្រយោជន៍ផ្ទាល់ខ្លួនណាទីមួយ ៗ

(មានត)

ឯកសារប្រាក្រិត

# មួយពាន់មួយយប់ (ជារឿងអារ៉ាប់)

ភាគទី ១១

យុះ សុន្ទរមេធី ញ៉ូង - សៀត
ប្រែពីភាសាបារាំងនៃសេចក្ដីខេមរភាសា

## រឿងនាងសូប៉ីត

នាងសូប៉ីត ចាប់ផ្ដើមក្រាបទូលថា បពិត្រព្រះអង្គជានាយកនៃបរស័ទ! រឿងដែលខ្ញុំម្ចាស់នឹងថ្វាយសារស័ព្ទក្រាបទូលឥឡូវនេះ គឺជារឿងចំឡែកយ៉ាងអស្ចារ្យ ដែលគេមិនដែលបានឮអ្នកណាមួយនិយាយឡើយ ។ ឆ្កែញីទាំងពីរហើយនឹងខ្ញុំម្ចាស់ គឺជាបងប្អូនបង្កើតមានមាតាបិតាជាមួយគ្នា, ឯស្ត្រីម្នាក់ ដែលនាំបណ្ដាលរំពាត់ទាំងពីរនាក់ឲ្យក្លាយទៅជាមេឆ្កែនោះ ខ្ញុំម្ចាស់នឹងក្រាបទូលជាខាងក្រោយ ៗ នាងពីរនាក់ដែលនៅផ្ទះជាមួយនឹងខ្ញុំម្ចាស់ គឺដែលគង់ជាមួយនៅចំពោះមុខនេះក៏ត្រូវជាបងប្អូនបង្កើតដែរ ប៉ុន្តែខុសគ្នាមួយម្ដាយទេ ៗ នាងដែលមានស្នែងសំឡាកក្រហមក្រពៅនោះ ឈ្មោះសាមីន, នាងមួយទៀតឈ្មោះសាហ្វី ហើយចំណែកនាងខ្ញុំម្ចាស់ឈ្មោះសូប៉ីត ។

ក្រោយបិតារបស់យើងទទួលអនិច្ចកម្មទៅ យើងទាំងអស់គ្នាក៏បានទទួលចំណែកកេរ្តិ៍មរតកស្មើៗគ្នា; ចំណែកនាងបងប្អូនស្រីពីរនាក់

ខាងក្រោយ (គឺខាងដែលមានឪពុកជាមួយម្ដាយខ្ញុំ) កាលបានទទួលចំណែកមត៌ករបស់ខ្លួនហើយ គេក៏មានប្ដីទាំងពីរនាក់ ហើយគេទៅនៅដាច់ដោយឡែកជាមួយនឹងម្ដាយរបស់គេ ។ បងប្អូនស្រីពីរនាក់ទៀត ហើយនឹងខ្ញុំម្ចាស់ នៅជាមួយនឹងម្ដាយរបស់យើងកាលគាត់នៅរស់នៅឡើយ, លុះដល់គាត់អស់អាយុសង្ខារទៅទៀត គាត់មានប្រាក់ចុងបែកឲ្យយើងបាន ១ ពាន់កហាបណៈម្នាក់ ។

កាលបានទទួលចំណែកមត៌កនេះ ១ ខ្លួនហើយ បងស្រីទាំងពីររបស់ខ្ញុំម្ចាស់ក៏មានប្ដីទៅទៀត ហើយគេបែកទៅនៅជាមួយនឹងត្រកូលខាងប្ដីទៅ ពេលខ្ញុំម្ចាស់នៅត្រមោចតែម្នាក់ឯង ។ លុះចំណេរតមកខាងក្រោយ ប្ដីរបស់នាងដែលជាបងបង្អស់ ក៏តាំងលក់ទ្រព្យសម្បត្តិដែលជាកេរ្តិ៍មត៌កខាងខ្លួន ទំងខាងប្រពន្ធអស់ពេញ ហើយប្រមូលយកតែប្រាក់កាស រួចនាំប្រពន្ធទៅៈទៅរកស៊ីឯស្រុកអញ្ចៀន ។ កាលទៅក្នុងស្រុកនោះ ប្ដីជាអ្នកចាយធំឥតសណ្ដាប់ធ្នាប់ ចេះតែចាយបំផ្លាញខ្ជះខ្ជាយដល់តែវិនាសហិនទ្រព្យសម្បត្តិអស់, លុះចំណេរតទៅ ធ្លាក់ខ្លួនទៅជាអ្នកក្រីក្ររហេមរហាម ប្ដីក៏រកឧបាយកលដើម្បីលែងបង់ស្រីខ្ញុំម្ចាស់ ហើយក៏បណ្ដេញនាងឲ្យចុះចេញពីផ្ទះ ។

បងស្រីខ្ញុំម្ចាស់ វិលត្រឡប់មកឯក្រុងបាតលីបុត្រវិញ, ពេលដែលនាងធ្វើដំណើរចេញពីស្រុកអញ្ចៀកមកក្រុងបាតលីបុត្រនោះ មានសេចក្ដី

លំបាកតាមយ៉ាងលើសលប់ពន់ប្រមាណ ព្រោះដំណើរផ្លូវឆ្ងាយពេក លុះមកដល់ហើយក៏ចូលទៅជ្រកកោនអាស្រ័យនៅនឹងផ្ទះខ្ញុំម្ចាស់ ម្យ៉ាងទៀតរូបរាងរបស់នាងមុខគួរឲ្យអាណិតអាសូរខ្លាំងណាស់ ព្រោះត្រូវសេចក្តីក្រីក្រជះជាន់ ៗ ខ្ញុំម្ចាស់ក៏បានទទួលនាងដោយសេចក្តីស្នេហា ដែលនាងបានផ្តល់ផ្គងសង្ឃឹមទុកចិត្តមកលើខ្ញុំម្ចាស់តាំងពីនាយមក ៗ ខ្ញុំម្ចាស់បានសាកសួរអំពីដើមចម ដែលនាំបណ្តាលឲ្យធ្លាក់ខ្លួនទៅជាមនុស្សរហេមរហាមយ៉ាងនេះ, នាងក៏បានប្រាប់ខ្ញុំម្ចាស់សព្វគ្រប់ អំពីដំណើរប្តីរបស់នាងជាមនុស្សស៊ីផឹកបំផ្លាញទ្រព្យសម្បត្តិ ហើយធ្វើទុកបុកម្នេញបណ្តេញនាងចេញមកនោះ ៗ ខ្ញុំម្ចាស់ឈឺខ្លោចចិត្តណាស់នឹងសេចក្តីទុក្ខលំបាករបស់នាង ហើយក៏តាំងយំសោកជាមួយគ្នា ៗ រួចហើយខ្ញុំម្ចាស់ឲ្យនាងចូលទៅងូតទឹកជំរះញើសក្អែលឲ្យស្អាតបាត ហើយក៏ឲ្យសំលៀកបំពាក់យ៉ាងល្អ ៗ របស់ខ្ញុំម្ចាស់ទៅនាងស្លៀកពាក់ រួចទើបខ្ញុំម្ចាស់និយាយថា "អ្នកបង! អ្នកគឺជាបងស្រីខ្ញុំ, ខ្ញុំត្រូវធ្លាក់អ្នកជួបវាសនាខ្ញុំ, កង់ពេលដែលបែកគ្នាទៅនោះ ហេតុតែគុណបុណ្យព្រះជួយខ្ញុំ ក៏ទ្រព្យសម្បត្តិចិត្តបន្ទប់ដែលត្រូវបានមកជាចំណែកខ្ញុំនោះឯង ខ្ញុំគិតថ្លៃផ្សំផ្គុំធ្វើមធ្យោបាយដើមទុន ចិញ្ចឹមនាងធ្វើស្រែបានផលចំរើនកើនគ្រាន់បើរាប់មក ៗ សូមបងសង្ឃឹមទុកកង់ចិត្តចុះថា ខ្ញុំគ្មានបងណាដទៃក្រៅអំពីបងទេ, យើងនឹងនៅនឹងគ្នាឲ្យបានសុខសប្បាយតទៅ" ៗ

យើងក៏នៅជាមួយគ្នាទាំងពីរនាក់ អស់កាលជាយូរខែដោយមានអធ្យាស្រ័យល្អត្រូវគ្នាមិនដែលទាស់ខ្នងទេឡើយ យើងចេះតែផ្ដើមនិយាយញយៗ អំពីបងស្រីទាំង ៣ របស់យើង ព្រោះតាំងពីបែកគ្នាទៅមិនដែលបានដឹងដំណឹងសុខទុក្ខអ្វីសោះ ថ្ងៃមួយស្រាប់តែលេចមុខនាងទៅដល់ ដោយមានរឿងហេតុអមង្គលដូចជាបងស្រីមុននោះដែរ គឺប្ដីរបស់នាងធ្វើទុក្ខបុកម្នេញបណ្ដេញនាងចេញតាមទំនងដូចគ្នា ; ខ្ញុំម្ចាស់ក៏បានទទួលនាងដោយសេចក្ដីមេត្រីរាប់អានដូចមុនៗ ។

លុះនៅជាមួយគ្នាបានយូរបន្តិចទៅ បងស្រីទាំងពីរនាក់និយាយនឹងខ្ញុំម្ចាស់ថា នាងគិតចង់យកប្ដីម្ដងទៀត ដោយយករឿងដែលនៅក្នុងបន្ទុកជាមួយនឹងខ្ញុំម្ចាស់នោះឯង មកក្ដីគួរជាគ្រឿងការថាខ្វាបក្រែងខ្ញុំម្ចាស់លំបាកចិត្ត ខ្ញុំម្ចាស់ក៏បានតបថា "បើគ្មានហេតុអ្វីដទៃក្រៅអំពីរឿងខ្វាបចិត្តខ្ញុំ ព្រោះតែនៅក្នុងបន្ទុកជាមួយនេះទេ សូមបងកុំព្រួយឲ្យសោះ ត្រូវតែនៅជាមួយនឹងខ្ញុំតទៅទៀតដោយសេចក្ដីក្សេមក្សាន្តចុះ ខ្ញុំឥតមានសេចក្ដីធុញទ្រាន់អ្វីឡើយ ទាំងទ្រព្យសម្បត្តិរបស់ខ្ញុំក៏មានគ្រប់គ្រាន់ល្មមចិញ្ចឹមគាត់ទាំង ៣ នាក់បាន តាមសមគួរដល់ឋានៈរបស់យើង ។ ប៉ុន្តែខ្ញុំជប់ក្រែងមិនមែនរឿងខ្វាបចិត្តខ្ញុំ ព្រោះតែនៅក្នុងបន្ទុកជាមួយគ្នា ក្រែងលោមានតែរឿងម្យ៉ាង គឺត្រង់ចង់បានប្ដីម្ដងទៀតហ្នឹងឯង ហើយបែរជាគេចកែសំនួនយករឿងថា ខ្វាបចិត្តខ្ញុំនោះមកជាគ្រឿងកាន់ទេដឹង? ប្រសិនបើ

ផុតពារនេះ ខ្ញុំក៏គោរពតែគួរណាស់ ។ សូមបងគិតពិចារណាមើល ឲ្យល្អិតល្អន់មែនទែន អំពីសេចក្ដីសប្បាយយ៉ាងណា ខ្វះត្រង់ដែលយកប្ដីក្រុងសៀមពីរទៀតនោះ បើតាមយោបល់ខ្ញុំថា ប្រែងលោកដូចមុនទៀតទេអ៊ីង ព្រោះប្ដីដែលជាមនុស្សស្លូតត្រង់តាមគន្លងធម៌នោះ យើងគេកម្របានណាស់ ណាក៏យសូមបងជឿខ្ញុំចុះ យើងស៊ូនៅចិញ្ចឹមជីវិតជាមួយគ្នាតាមមានតាមបាន ជាជាងក្រានូយ៉ាងនេះទៅវិញល្អជាង" ។

សំដីដែលខ្ញុំម្ចាស់និយាយពន្យល់តាំងអម្បាលម៉ាន ឥតប្រយោជន៍សោះ តែនាងបរៀសចូលយកប្ដីទៀតពាល់តែបាន ។ ប៉ុន្តែព្រះមិនសមព្រហ្មមិនជួយ ទើបតែទងបានពីរ-បីខែ ស្រាប់តែលោកក្បាលក្រឡឹមតាំងពីទាក់ទៅផ្ទះខ្ញុំម្ចាស់ដដែល ព្រោះប្ដីលែងត្រូវទក្បាលចោលដូចមុនទៀត ហើយក៏អង្វរសូមទោសខ្ញុំម្ចាស់ណោះ ជាប្រទេសដង ខ្ញុំចូលខុសពីធំ ព្រោះតែខ្លួនបះបេសខ្ទីរងមិនតាមដំបូន្មានខ្ញុំម្ចាស់ នាងបាននិយាយពន្យល់ខ្ញុំថា "បង! នាងគឺជាប្អូនពៅរបស់យើងក៏ពិតមែន ប៉ុន្តែនាងជាមនុស្សស្របពិតគំនិតប្រែផ្ទះជាងយើង បើនាងគាណកះបត្តាឲ្យយើងទៅដេកកោនជាមួយបម្ដីទៀត សូមនាងទុកយើងតាំងពីនោកក្ដូបណាក្នុងព្រះទៅចុះ យើងហាក់សន្យាថា នឹងស្រួចលែងត្មែមាត់យ៉ាងបែបនេះទៀតហើយ" ។ ខ្ញុំម្ចាស់ក៏តបទៀតថា "ឲ្យបង់សំឡាញ់អើយ! តាំងពីដូចបងបែកពីខ្ញុំទៅក្នុងលោកក្រោយនេះ ប្ដីរបស់

ខ្ញុំឥតប្រែប្រួលផ្លាស់ប្តូរទេ គឺនៅតែស្មោះត្រង់ចំពោះបងទាំងពីរដូចកាល
មុនដដែល សូមបងមកនៅសប្បាយរីករាយជាមួយនឹងខ្ញុំវិញចុះ" ។

និយាយដូច្នេះហើយ ខ្ញុំម្ចាស់ក៏នឹងបងទាំងពីរ រួចហើយបាននៅជាមួយ
គ្នាដូចកាលពីមុនរៀងមក ។

• យើងនៅរួបរួមគ្នាជាសុខសប្បាយ មិនដែលមានឈ្លោះទាស់ទែង
អ្វីឡើយ បានចំនួន ៣ ឆ្នាំ ឃើញថា ព្រះលោកជួយប្រោសប្រណោ
ឲ្យមានទ្រព្យការគួរសម ខ្ញុំម្ចាស់ក៏បានគិតគូរពែលរកនឹងធ្វើដំណើរតាម
សមុទ្រ ដើម្បីធ្វើជំនួញជួញប្រែល្បងមើលម្ដង ។ ដោយអស្រ័យហេតុ
នេះ ទើបខ្ញុំម្ចាស់ទៅឯក្រុង បាល់ស្សូរ ជាមួយនឹងបងស្រីទាំងពីរនាក់ រួច
បានទិញសំពៅមួយមានគ្រឿងប្រដាប់គប់ក្រាន់ទាំងអស់ ហើយយក
មកផ្ទុកទំនិញផ្សេងៗ ដឹកនាំពីក្រុងបាគដាទទៅ ។ ដោយមានខ្យល់ត្រូវ
ទំនងល្អ យើងក៏លើកក្ដោងបើកចេញទៅតាមអំពីឈូងសមុទ្រ ប៉ែរស៊ិក
(Persique) ។ កាលយើងទៅដល់កណ្ដាលសមុទ្រ យើងបានបើកសំពៅ
បត់តាមផ្លូវទៅស្រុកឥណ្ឌា លុះយើងធ្វើដំណើរតាមផលាសយយ៉ាងនេះ
បានចំនួន ២០ ថ្ងៃ ក៏មើលទៅឃើញដីមាត់ច្រាំង គឺជាភ្នំមួយដ៏ខ្ពស់ត្រដូច
ត្រដឹមស្កឹមស្កៃ ហើយនៅខាងជើងភ្នំនោះឯង មើលទៅឃើញទីក្រុងមួយ
ល្អស្រស់ចិញ្ចែងៗ ដោយវេលានោះមានខ្យល់ជានោះត្រជាក់ល្អ យើងក៏បានបើក
សំពៅទៅដល់នៃកំពង់ព្រាម ហើយយើងចុះយុថ្កាចតនៅត្រង់នោះ ។

ខ្ញុំម្ចាស់ឥតបន្ថែមបន្ថយការតាំងឲ្យបងស្រីជូនទៅផងទេ ខ្ញុំម្ចាស់ឡើងពីសំពៅតែម្នាក់ឯង ហើយដើរតម្រង់ទៅរកទ្វារក្រុងនោះតែម្តង ក្បែរទ្វារក្លោងនោះ ខ្ញុំម្ចាស់បានឃើញមនុស្សទ្វារបាលមីរៈជរជាស ខ្លះអង្គុយខ្លះឈរកាន់ដំបងគ្រប់ៗគ្នា ។ ប៉ុន្តែពួកទ្វារបាលទាំងនោះ សុទ្ធតែមានមុខដូចក្រញាំត្មាតឲ្យព្រឺក្បាលខ្លាចស្ញប់ស្ញែងក្រពេក ដល់សង្កេតមើលមែនទែនទៅ ឃើញនៅខ្ចីថ្ពាល់ឥតកំរើកសោះ ទាំងក្មេងក៏ឥតប្រែប្រួលឡើយ ទើបខ្ញុំម្ចាស់បាត់ខ្លាចវិញ ហើយដើរចូលទៅជិតមនុស្សទ្វារបាលទាំងនោះ ក៏បានស្គាល់ច្បាស់ថា គឺជាមនុស្សក្លាយទៅជាថ្មសោះ ។

ខ្ញុំម្ចាស់ចូលទៅខាងក្នុងទីក្រុងហើយ ដើរទៅតាមផ្លូវគ្រប់អន្លើឃើញមនុស្សមានកំពស់កំពគ្រប់បែប (ខ្លះទាប, ខ្លះយ៉ាងកណ្តាល, ខ្លះខ្ពស់) ប៉ុន្តែឥតកំរើកខ្លួនប្រាណសោះ គឺរូបមនុស្សក្លាយទៅជាថ្មទាំងអស់ ។ នៅត្រង់ទីផ្សារឃើញផ្ទះលក់អីវ៉ាន់ខ្លះបិទទ្វារ ហើយផ្ទះខ្លះបើកទ្វារ តែមនុស្សក្នុងផ្ទះនោះ ក្លាយជាថ្មដូចគ្នាដែរ ។ ក្រឡេកមើលទៅចំពង់ក្បឺនលើដំបូលផ្ទះបាយ ឥតឃើញហុយផ្សែងសោះ, រឿងនេះអាចឲ្យខ្ញុំម្ចាស់យល់សេចក្តីបានថា មនុស្សទាំងអស់ដែលនៅក្នុងផ្ទះ ក៏ដូចគ្នានឹងមនុស្សដែលនៅខាងក្រៅផ្ទះដែរ គឺក្លាយទៅជាថ្មដូចៗគ្នា ។

កាលខ្ញុំម្ចាស់ទៅដល់ទីវាល ១ ចំកណ្តាលទីក្រុង ខ្ញុំបានបើកទ្វារធំ១ដែលបេធាពាសពេញសុទ្ធតែដំបារមាស ដោយសន្មតថាទាំង

ពីរផតចាក់សោរទ្រាំតែព្រានទៅបាន   ខាងក្នុងទៀតពីសំពត់ស្រែ បង់បាំងពីខាងមុខ   ហើយមានកំផែងក្រៀមមួយព្រួះនៅខាងលើទ្វារនោះ ផង ៗ លុះបានពិនិត្យមើលក្នុងនោះសព្វគ្រប់ទៅ ខ្ញុំម្ចាស់អាចដឹង ច្បាស់ថា គឺជាព្រះពន្ធនាគាររបស់ជាតិក្រអឹណាមួយ ដែលបាន សោយពលក្ខ័ណ្ឌស្រុកនោះឯង ៗ ប៉ុន្តែគួរឲ្យឆ្ងល់ណាស់ ព្រោះឥត ប្រទះឃើញមនុស្សរស់ដល់ម្នាក់សោះ ខ្ញុំម្ចាស់ក៏ចូលទៅទៀត ដោយ គិតល្បងមើលថាក្រែងលោឃើញអ្នកណាមួយ ៗ ខ្ញុំម្ចាស់តាប់ពើក ស៊ើបកំផែងគន្លងថ្នាក់ល្អងប្រចាំការ ស្រាប់តែភ្ញាក់ព្រើត ព្រោះ ឃើញពួកទាហានក្លាយជាថ្ម ខ្លះឈរ ខ្លះអង្គុយ ខ្លះផ្អែកបាំងដៃ ៗ

ខ្ញុំម្ចាស់ដើរកាត់ទីធ្លាធំដែលមានមនុស្សច្រើនដើរដាស ខ្លះមាន ការសារបាក់ដូចជាណាមដើងដើរទៅ ខ្លះដូចជាដើរមកប្រទាក់គ្នាគ្រាត់ ដៃឡើងឡើង ប៉ុន្តែឥតករគ្រាកខ្លួនប្រាណសោះ ព្រោះសុទ្ធតែជាមនុស្ស ក្លាយទៅជាថ្ម ដូចជាខ្ញុំម្ចាស់បានឃើញពីមុននោះដែរ ៗ ខ្ញុំម្ចាស់ដើរចូល ទៅធ្លាទីពីរហើយទីធ្លាទី ៣ ឥតពុំស្រូបមនុស្សម្នាសោះ គឺជាទីស្ងាត់ស្ងៀម ឈឹងគួរឲ្យព្រឺក្បាល ៗ

កាលចូលទៅដល់ធ្លាទី ៤ បានឃើញប្រាសាទមួយខ្ពស់ច្រាប មាន បន្ទប់បិទបាំងដោយប្រដាប់មាសត្រាន់ ខ្ញុំម្ចាស់វិនិច្ឆ័យថា គឺជាដំណាក់ របស់អគ្គមហេសីស្ដេច ទើបបើកទ្វារចូលទៅ ៗ ក្នុងបន្ទប់ធំជាងមហាសាល

ទៅៗជាច្រើន ដែលក្លាយទៅជាថ្ម ខ្ញុំម្ចាស់ដើរចូលទៅទៀតដល់បន្ទប់ៗ ដែលមានគ្រឿងតាំងល្អដ៏វិចិត្រគួរឲ្យពិតពិល មិលមើល ត្រង់កន្លែងនោះ ឃើញស្រីម្នាក់ក្លាយទៅជាថ្មដែរ ។ ខ្ញុំម្ចាស់ស្គាល់ជាក់ថានេះជាអគ្គមហេសី ស្ដេច ទ្រង់មកុដមាសពាក់លើព្រះសិរ ហើយមានពាក់អង្កាំធ្វើពីកែវមុក្ដា គ្រាប់មូលធំ ៗ លុះដល់ចូលទៅពិនិត្យមើលឲ្យជាក់ច្បាស់ទៅ ឃើញថា គ្រឿងប្រដាប់តែងខ្លួនទាំងនោះក៏គ្មានរបស់ឯណាដែលល្អជាងទៀតទេ ។

ខ្ញុំម្ចាស់ឈរគោតស្ញប់ស្ញែងមួយស្របក់ អំពីទ្រព្យសម្បត្តិផ្សេងៗ ទីតាំងរបស់បន្ទប់នោះឯង ហើយនឹងគ្រែមាស ពូក ខ្នល់ ខ្នើយ ព្រំ ត្រៀមចាំដែលក្រាលជារបៀបរៀបរយសព្វគ្រប់ ព្រមទាំងកៅអីវែងៗ គ្របដោយសំពត់ក្រហម ហើយបង្អួចក្បាច់ដៃធ្វើពីមាសវិចិត្របំពាក់ បញ្ចុះដោយច្បាក់ក្បាច់រចនារូបមុខមនុស្សនិងសត្វផ្សេងៗ មានរបៀប ស្អាតយ៉ាងក្រៃលែង ។

ខ្ញុំម្ចាស់ចេញពីបន្ទប់អគ្គមហេសីក្លាយជាថ្មនោះ ហើយចូលទៅក្នុងវិមានឯទៀតជាច្រើន ដែលមានរបៀបរៀបចំយ៉ាងស្អាតស្រស់បំព្រង រហូតដល់ទៅបន្ទប់ ១ ធំប្លែកខុសពីបន្ទប់ធម្មតា ក្នុងបន្ទប់នោះមានបល្ល័ង្កធ្វើពីមាសគាប់ ហើយមានជាក់ៗ ខ្ពស់បន្តិច បញ្ចុះរំលេចដោយថ្មកែវមរកត ហើយលើបល្ល័ង្កនោះ មានគ្រែសំពត់យ៉ាងមានដម្លៃវិចិត្រ ស្រោះបុំក់យ៉ាងខ្សែយធ្វើពីកែវមុក្ដាមានពន្លឺផ្លេកៗ ។ របស់ដែលនាំ

ឲ្យខ្ញុំម្ចាស់មិនអស្ចារ្យចំពោះកកូនទុំនោះ គឺពន្លឺចិញ្ចាចក្លាំង ចាំងផ្សាយ ចេញមកពីខាងលើគ្រែនោះឯង ។ ខ្ញុំម្ចាស់ទឹកឆ្ងល់ណាស់ ព្រោះមិន ដឹងរបស់អ្វីដែលបញ្ចេញផ្សាយពន្លឺមកនោះ ខ្ញុំម្ចាស់ក៏ឡើងទៅបើក ក្បាលសំឡៀកមើល បានឃើញពេជ្រ ១ ដុំធំប៉ុនពងសត្វ អូទ្រីស ដាក់ដំកល់លើជើងតាំង ១ ដុំពេជ្រនោះគឺជារតនវត្ថុល្អផុតលេខ មានពន្លឺ ភ្លឺផ្លាំងចាំងចិញ្ចែងចិញ្ចាច់ កាលយកមកសំឡឹងមើលឯពន្លឺថ្ងៃ ដុំពេជ្រ នោះចាំងខ្លាំងណាស់ ខ្ញុំម្ចាស់ទ្រាំសំឡឹងមើលពុំមិនបាន ។

នៅក្បាលគ្រែតាំងសងខាងមានទៀនឆេះផុងៗ នាំឲ្យខ្ញុំម្ចាស់រឹត តែសង្ស័យឡើងដោយចង់ដឹងហេតុគេទុកឥតខ្វៃនោះ ប៉ុន្តែរឿងនេះ គាប់ឲ្យខ្ញុំម្ចាស់វិនិច្ឆ័យសេចក្តីបានថា គង់តែមានមនុស្សណាមួយនៅរស់ កណ្តាលដីស្កកស្កុះនេះឯងពុំខាន ព្រោះទៀនដែលឆេះផុងៗនោះមិនមែន ឆេះឯងៗឡើយ ខ្ញុំម្ចាស់ឈប់ឈរគាំងកណ្តាលបន្ទប់នោះ សំឡឹង មើលរបស់ចំឡែកៗឯទៀតជាច្រើន ឯរតនវត្ថុដែលល្អបំផុតកាត់ថ្លៃមិន បាននោះ គឺដុំពេជ្រដែលខ្ញុំម្ចាស់ទើបនឹងនិយាយហើយនោះឯង ។

ដោយហេតុទាំងអស់របស់ស្រស់ៗ ឬគ្រាន់តែប្រាថ្នាទៅក៏អាច ចូលទៅបាន ខ្ញុំម្ចាស់ក៏បេះតែចូលទៅក្នុងកន្លែងឯទៀតៗដែលមានរបស់ ល្អៗ ដូចជាខ្ញុំម្ចាស់បានឃើញកាលពីមុននោះដែរ ។ ខ្ញុំម្ចាស់ចូល ទៅរហូតដល់បន្ទប់គ្រឿងតាំង ដែលពាសពេញទៅដោយទ្រព្យរបស់

ថ្លៃថ្លាផ្សេង ៗ នឹងគណនាត្រាកប់ពុំបានឡើយ ហើយឈរសំឡឹងមើលត្រង់កន្លែងនោះ ទាល់តែភាំងស្មារតីភ្លេចខ្លួន ឥតនឹកនាដល់សំពៅ ហើយនឹងបងស្រីសោះឡើយ គិតតែបំពេញបំណងចំពោះរបស់ថ្លៃ ៗ តែប៉ុណ្ណោះឯង ៗ រវល់តែនឹងមើលរបស់ចំឡែកទាំងនោះ ស្រាប់តែដល់ពេលព្រលប់ជិតយប់ងងឹត ខ្ញុំម្ចាស់ក៏គិតវិលត្រឡប់ទៅឯសំពៅវិញ ខ្ញុំម្ចាស់ចង់ដើរតាមផ្លូវដែលចូលមកកាលដំបូង ប៉ុន្តែរកផ្លូវដើមនោះពុំឃើញ ទៅជាវង្វេងវិលក្បែរត្រឡប់ចុះឡើង ៗ ក្នុងល្វែងដដែល ៗ ទើបគិតសម្រេចក្នុងចិត្តថា នឹងសុំប្រថុយទទួលព្រះករុណាទានដំណេក ១ យប់ក្នុងបន្ទប់ធំដែលមានបល្ល័ង្ក ក្រែ ជុំពេជ្រហើយនឹងទៀនឆេះផ្លុង ៗ នោះឯង ។ ព្រមតែដល់ស្អែកឡើងនឹងក្លាក់ទៅឯសំពៅពីព្រលឹម ៗ ខ្ញុំម្ចាស់ក៏ប្រះខ្លួនទៅលើគ្រែបេះតែរំភើបញាប់ញ័រភ័យផ្អុក ៗ ព្រោះនៅតែម៉ោចឲ្យម្នាក់ឯងក្នុងកន្លែងរហោឋានស្ងាត់ជ្រងំយ៉ាងនេះ ដំណើរតែបេក្ខារម្ភនោះឯងនាំឲ្យខ្ញុំម្ចាស់ទទួលទានដំណេកមិនលក់សោះ ។

ដល់ពេលប្រហែលជាពាក់កណ្តាលអធ្រាត្រ ស្រាប់តែឮថាដមនុស្សស្រែចលក្ខនអាល់កូរ៉ង់ (Alcoran) របៀបស្ទូរសំឡេងនោះដូចជាពេលគ្នាប់ស្ទូត្រគម្ពីរយើងដូច្នោះដែរ ។ រឿងនេះនាំឲ្យខ្ញុំម្ចាស់ភ្ញាក់ខ្លាច ហើយមានសេចក្តីក្តៅក្រហាយយ៉ាងច្រើន ទើបក្រោកឡើងភ្លាមហើយកាន់ទៀន ១ បំភ្លឺ ទោលមើលផ្លូវដើរពីបន្ទប់មួយទៅបន្ទប់មួយ

កាលតែដល់កន្លែងដែលត្រូវសំឡេងនោះ ហើយឈប់ក្បែរទ្វារ ដើម្បីសង្កេតមើលឲ្យជាក់លាក់ ។ ខ្ញុំម្ចាស់ដាក់ចៀនចោលទៅទីងងឹត ហើយសំឡឹងមើលតាមប្រហោងទ្វារ ក៏បានឃើញអាសនៈព្រះមួយ ហើយមានតូបមួយទៀត សម្រាប់ដើរក្រឡឹងប្រទក្សិណ សូត្រធម៌ដូចជារបៀបគន្ធព្រះវិហារយើងដែរ មានចាំងចង្កៀងព្យួរភ្លឺចែង ហើយទីងជើងទៀនទ្រទៀនក្រមួនសធំ ៗ ឆេះភ្លឺដូចគ្នា ។

ខ្ញុំម្ចាស់ បានឃើញក្រោលមួយតូចក្រោលក្នុងទីនោះផង មានសណ្ឋានខ្ទង់ត្រាយដូចជាក្រោលនៅស្រុកយើង ដែលសម្រាប់អង្គុយសូត្រធម៌ដូច្នោះដែរ ។ មានមនុស្សកំឡោះម្នាក់មុខខាត់ស្រស់បំព្រិម អង្គុយលើក្រោលនោះ ដាក់ក្បេនកាលក្បួនពីខាងមុខដំកល់លើជើងអាការ ១ ហើយសូត្រដោយសេចក្ដីប្រយ័ត្នម៉ឺងម៉ាត់ ។ កាលបានឃើញជាក់ហើយ ខ្ញុំម្ចាស់ញ័រនោះភ្លុក ៗ ភ័យអរ ៗ រីតតែសង្ស័យណាស់ទៅទៀត ដោយគិតថាហេតុអ្វីក៏អ្នកកំឡោះនេះមកនៅត្រហោចតែម្នាក់ឯង ក្នុងទីក្រុងដែលមានមនុស្សទាំងអស់ក្លាយទៅជាថ្មយ៉ាងនេះ ហើយខ្ញុំម្ចាស់ស្មានថា គង់នឹងមានហេតុកើតផ្សំខាងអ្វីម្យ៉ាង ៗ ពុំខាន ។

ដោយទ្វារបន្ទប់នោះគ្រាន់តែទាញបង្ខិតទៅបាន ទើបខ្ញុំម្ចាស់បើកចូលទៅហើយឈរពីខាងមុខតូប រួចក៏ធ្វើសព្ទគារយ៉ាបន្ទន់សួរដោយសំឡេងយ៉ាងច្បាស់ ៗ ថា " សូមសរសើរចំពោះព្រះជាម្ចាស់ ដែល

ទ្រង់ប្រោសប្រោណឲ្យខ្ញុំធ្វើដំណើរតាមផលសាគរ មកដល់ទីនេះដោយ
សេចក្តីសុខសប្បាយ! សូមទ្រង់មេត្តាបីបាច់ថែរក្សាការពារខ្ញុំ ឲ្យបានសេចក្តី
សុខសប្បាយដូចគ្នា ដរាបដល់ពេលត្រឡប់ទៅស្រុកទេសរបស់ខ្ញុំវិញ;
បពិត្រព្រះម្ចាស់ថ្លៃ សូមទ្រង់ព្រះសណ្ដាប់ពាក្យបួងសួងរបស់ខ្ញុំនេះ" ។

មនុស្សកំឡោះស្រាប់តែក្រឡេកមើលមកខ្ញុំម្ចាស់ហើយនិយាយថា
"ម្ចាស់ស្រីស្រស់ចំណាប់ ខ្ញុំសូមឲ្យនាងប្រាប់ខ្ញុំតើនាងជាអ្វី ហើយអ្នក
ណានាំនាងចូលមកហូតដល់ទីក្រុងនេះ ហាក់ដ៏បែកបរដោយបាបគ្រោះ
នេះឯង សូមឲ្យតែនាងប្រាប់ខ្ញុំចុះខ្ញុំនឹងជូនភ្ញៀងដល់នាងវិញ គឺខ្ញុំនឹង
ប្រាប់ពន្យល់នាងអំពីរឿងខ្ញុំ ព្រមទាំងដើមហេតុនៃបណ្ដាផល ដែល
ធ្លាក់ខ្លួនទៅក្នុងបាបគ្រោះដូចនាងបានឃើញស្រាប់ ហើយនឹងរឿងការ
ខ្ញុំដែលនៅជាសុខសប្បាយតែម្នាក់ឯង ក្នុងកន្លែងដែលទទួលគ្រោះថ្នាក់
វិនាសអន្តរាយយ៉ាងនេះ" ។

ខ្ញុំម្ចាស់ក៏បានអធិប្បាយប្រាប់មនុស្សកំឡោះនោះ ដោយសេចក្តី
ក្បៀបខ្សេចៗ អំពីរឿងរបស់ខ្លួន តាំងអំពីចេញពីស្រុកហើយធ្វើដំណើរ
ផ្លូវឆ្ងាយត្រាំខ្លួន ២០ ថ្ងៃ ទើបបានមកដល់ផែនេះដោយសេចក្តីសុខ
សប្បាយ ។ រួចហើយខ្ញុំម្ចាស់សូមឲ្យមនុស្សកំឡោះនោះនិយាយរឿង
របស់ខ្លួនប្រាប់ខ្ញុំម្ចាស់វិញតាមពាក្យសន្យាពីខាងដើម, ខ្ញុំម្ចាស់បានប្រាប់
បញ្ជាក់ថា ខ្ញុំម្ចាស់អស្ចារ្យក្នុងចិត្តខ្លាំងណាស់ តាំងពីបានចូលមក

ឃើញរបស់ចំឡែក ៗ គ្រប់គ្រឿងទាំងអស់ ព្រោះមិនដឹងដើមចមហេតុ គេធ្វើយ៉ាងណាសោះ ។

គ្រានោះ អ្នកកំឡោះតបថា "អូនស្រី! សូមនាងនៅចាំមួយស្របក់សិន ។ និយាយប៉ុណ្ណេះហើយ អ្នកកំឡោះក៏បិទត្រាំងពាក់ក្បាល ដាក់ញាត់ក្នុងស្រោមហើយយកទៅទុកក្នុងតូប ៗ ពេលនោះខ្ញុំម្ចាស់ សង្កេតគយគន់មើលអ្នកកំឡោះនោះដោយក្តៅចិត្ត ឃើញថាជាមនុស្ស មានលក្ខណៈសក្តិសមល្អឥតខ្ចោះ បណ្តាលឲ្យខ្ញុំម្ចាស់មានសេចក្តីរំភើប រំជួលជ្រួលច្រើមក្នុងចិត្តយ៉ាងខ្លាំង ដែលតាំងពីកាលមុនរហូតមកដល់ ឥឡូវនេះខ្ញុំម្ចាស់មិនដែលប្រទះសោះ ។ អ្នកកំឡោះនោះបានហៅខ្ញុំម្ចាស់ទៅឲ្យអង្គុយជិត ហើយមុននឹងនិយាយរឿងនេះប្រាប់ខ្ញុំម្ចាស់នោះ ខ្ញុំម្ចាស់បានសំដែងការទឹកមុខស្រស់ស្រាយល្មមឲ្យគេដឹងបានថា ខ្ញុំម្ចាស់មានចិត្តប្រាថ្នាស្មោះស្ម័គ្រចំពោះលើរូបគេនោះពិត ៗ ហើយខ្ញុំម្ចាស់ និយាយដោយសំដីដ៏ទន់ភ្លន់ថា "បពិត្រម្ចាស់ថ្លៃសំឡាញ់ ដែលជាបណ្តាលចិត្តរបស់ខ្ញុំ! ខ្ញុំមានសេចក្តីសង្ស័យព្រោសព្រាលក្នុងចិត្តជាទីបំផុត ព្រោះបានឃើញរបស់ចំឡែក ៗ ច្រើនណាស់ តាំងពីខ្ញុំទើបនឹងឈានជើង ១ ជំហានចូលមកដល់ទីក្រុងនេះម្ល៉េះ ខ្ញុំនឹងទ្រាំបន្តទៅទៀតពុំបានទេ, សូមលោកករុណាពន្យល់ខ្ញុំផង, ដោយមានហេតុ គេធ្វើអស្ចារ្យដូចម្តេច ដែលលោកនៅតែម្នាក់ឯង កណ្តាលចំណោមមនុស្សស្លាប់ក្លាយជាថ្មយ៉ាងនេះ" ។ (មាននៅ)

ព្រះរាជប្រវត្តិ

# ព្រះបាទសម្តេចព្រះជ័យជេដ្ឋា (ព្រះអង្គសូរ)

(តមក)

*លុះដល់ថ្ងៃ ១ កើតខែបុស្សឆ្នាំជូតសំរឹទ្ធិស័ក (ព.ស. ២២១៩ ច.ស. ១០៣៨) ស្តេចលើកចតុរង្គសេនាចេញពីព្រះបរមរាជវាំងឧត្តុង្គឫជ័យ ទ្រង់ទៅកោះស្លាកែត ដែលជាទីប្រជុំបោះទ័ពរបស់សម្តេចព្រះបទុមរាជាមហាឧបយោរាជ*[១] ។ *ពេលទ្រង់ជ្រាបថា សម្តេចព្រះកែវហ្វា*

---

១ សម្តេចព្រះបទុមរាជាមហាឧបយោរាជ (ព្រះអង្គនន្ទ) នេះ ជាព្រះរាជបុត្រាសម្តេចព្រះកែវហ្វា (ព្រះអង្គអឹម) នឹងអ្នកម្នាងជន្ទ័ (ជាពិណារ) ជាព្រះមាតា ។ ទ្រង់ប្រសូតក្នុងឆ្នាំខាល (សក្រាជមិនប្រាកដ) ដល់ព្រះជន្មបាន ១៨ វស្សា ទ្រង់ព្រះនាមព្រះអង្គនន្ទ ។ កាលព្រះជ្រៃជ័យជេដ្ឋាព្រះនាមជា ព្រះបទុមរាជាក្បត់នាំបក្សពួកចូលលុកក្នុងព្រះរាជវាំងឧត្តុង្គឫជ័យ ធ្វើគុតព្រះបាទសម្តេចព្រះបរមរាជា (ព្រះអង្គសូរ) ដែលជាព្រះវររាជបិតា សម្តេចព្រះកែវហ្វា (ព្រះអង្គជី) នឹងព្រះជ័យជេដ្ឋា ដើម្បីនឹងដណ្តើមយករាជសម្បត្តិ នោះសម្តេចព្រះរាមាធិបតីមហាឧបយោរាជ (ព្រះអង្គតន់) ទ្រង់ជ្រាបហេតុ ក៏ស្តេចគេចរត់នាំទាំងព្រះអង្គនន្ទរាជបុត្រាសម្តេចព្រះកែវហ្វា (អង្គអឹម) ត្រូវជាព្រះភាគិនេយ្យរបស់ទ្រង់នេះទៅស្រុកយួន ។ លុះស្តេចនាំកងទ័ពយួននឹងព្រះអង្គនន្ទមក ដើម្បីច្បាំងសងសឹកជំនួសព្រះរៀម (ព្រះបរមរាជាអង្គសូរ) ដល់មកដែនកម្ពុជា ទ្រង់ជ្រាបថា ពួកពាលក្បត់ធ្វើគុតព្រះបទុមរាជារួចហើយ (ស្តេចនេះក្រងរាជ្យបានតែ ៥ ខែទេ) តែឮសម្តេចព្រះកែវហ្វា (ព្រះអង្គជី) ឡើងគ្រងរាជសម្បត្តិ ក៏ទ្រង់សោកព្រះរាជអំណាចណាស់ ក៏ព្រះអង្គលើកកងទ័ពទៀតមក ។ ឯសម្តេចព្រះកែវហ្វា (ព្រះអង្គជី) កាលទ្រង់ជ្រាបថា

ចូន ...

(ព្រះអង្គច័ន្ទ) ទិវង្គតហើយ ទ្រង់មានព្រះអំណាចណាស់ ទ្រង់ប្រើកម្លាំងទ័ព
ទ័ពមាយាចនាំទាំងពួកយួន ។ លោ ខ្លះអ្នកត្រើយខាងលិចបថយកទូកនៈហើយ ។
ស្ដេចលើកទ័ពដេញចិត្តចេញពីកោះស្លាកែត មន្រ្តីសំរេចកំពង់ហ្លួង ហើ
ដល់ស្រុកពញាឮ ក៏ប្រទះនឹងកងទ័ពព្រះជ័យជេដ្ឋា ទើបបាក់ចម្បាំងគ្នានៅទី
នោះឡើង ។ ទ័ពខាងសម្ដេចព្រះបរមរាជាមហាចក្រពត្រាធិរាជ បរាជ័យ
ដកទ័ពត្រឡប់ទៅកោះស្លាកែតវិញ ហើយស្ដេចនាំអ្នកម្នាងនឹងពួកខ្ញុំកំដរ
ចុះទៅក្រុងអណ្ណាម ស្ដេចព្រះរាជដំណើរទៅដល់កុំពែង ដែនស្រុកយួន
នោះអ្នកម្នាងអែមកូនបិនជាព្រះទេពីសម្ដេចព្រះរាជបុត្រាចន្ទ វេលាដែល
សម្ដេចនោះក្នុងកាលជាព័រព្រះរាជធិតា ប្រទាននាមជា ព្រះអង្គអិម
ហើយស្ដេចប្រថាប់នៅប្រទល់ដែននោះឯង ។ (ច្បាប់សាស្ត្រស្ទឹងកែ

---

សម្ដេចព្រះរាមាធិបតីជាព្រះបិតុច្ឆាស្ដេចលើកទ័ពមកផ្ទួញ ក៏ទ្រង់បារម្ភក្រែងព្រះបិតុច្ឆាមក
ផណ្ដើមរាជសម្បត្តិ ទើបទ្រង់ចាត់កេណ្ឌពលឲ្យចេញច្បាំងទប់ទល់ ។ ឯសម្ដេចព្រះរាមា-
ធិបតីទ្រង់ក្រាបក៏ខ្លាំង កើតទៅវាយច្បាំងឡើងតែមិនទាន់ចាញ់ឈ្នះ ស្រាប់តែប្រឈួនជាទម្ងន់
សោយទិវង្គតទៅ ។ ទើបព្រះអង្គឥន្ទទទួលធ្វើចម្បាំងតទល់នឹងកងទ័ពសម្ដេចព្រះកែវហ្វា
ទ្រង់ភាគ្យ ទាល់តែស្រុកខ្មែរទាំងមូលបែកចេញជាពីរភាគ ភាគខាងកើតចំណូលបានព្រះអង្គឥន្ទ
ភាគខាងលិចទៅទៀតបានសម្ដេចព្រះកែវហ្វា ។ ចម្បាំងនេះមិនទាន់ចាញ់ឈ្នះដាច់ស្រេច សម្ដេច
ព្រះកែវហ្វា ក៏សោយព្រះទិវង្គតទៅ ទើបព្រះជ័យជេដ្ឋា (ព្រះអង្គសូរ) ទទួលធ្វើចម្បាំងត
នឹងព្រះអង្គឥន្ទមក ជួបមានរឿងសាស័ក្តក្នុងរាជប្រវត្តិស្រាប់ ។

ពិនិច្ឆ័យទោសតាមជាការសារថា (ព្រះអង្គអឹមសុគតក្នុងឆ្នាំកោបញ្ចស័ក ព. ស. ២២២៦(១)) ។

ចំណែកឯព្រះជ័យជេដ្ឋា កាលទ្រង់មានជ័យជំនះហើយ ក៏ទ្រង់លើកទ័ពត្រឡប់មកក្រុងគន្ធព្វជ័យវិញ ។

## ព្រះជ័យជេដ្ឋាឡើងគ្រងរាជសម្បត្តិ

ឯមេទ័ពមេកងទាំងពួងព្រមទាំងនាហ្មឺនសព្វមុខមន្ត្រី បានជំនុំយល់ព្រមគ្នាថា គួរអញ្ជើញព្រះជ័យជេដ្ឋា ឲ្យឡើងគ្រងរាជសម្បត្តិតទៅ ។

---

១ តាមច្បាប់ពង្សាវតារ "Cao-Men-Ky-Luoc" ថាក្នុងឱកាសដែលព្រះអង្គនន់រត់ទៅរកព្រះនគរទៅនោះ ទ្រង់ទៅបានកូនចិនម្នាក់ជាព្រះជាយា ហើយកើតបានបុត្រ ១ ទ្រង់ប្រទាននាមថា អ្នកអង្គអឹម ។ លុះ ៣ ឆ្នាំតមក, សករាជញ៉ាំ-ថូត (1682) ទ្រង់បាននៅសុំជំនួយ ថាំ-ភូន ជាជាតិចិននៅតំបន់ ឡាំ-ញ៉ែន សំដីធម្មតាហៅថា ជំ-ឡាំ ហើយទ្រង់ឲ្យគេបម្លុលពួកចិនជាកងទ័ពឡើង ។ ទ្រង់បានលើកកងទ័ពក្រោយនេះចូលទៅដែនខ្មែរ ហប់ច្បាំងគ្នានៅខែត្រមាត់ពាម ពួកនោះបានព្រមចុះចាញ់ព្រះអង្គ ទើបទ្រង់លើកទ័ពចូលទៅបន្ទាយ ណក់-យ៉ាង (ក្រុងភ្នំពេញ) ច្បាំងតទល់នឹងកងទ័ព អ៊ូ-ឌុង ណោ-ដី (ឧត្តុង្គឫជ័យ) ។ ព្រះជ័យជេដ្ឋា (ព្រះអង្គសូរ) (យួនហៅថា សា-ស៊ី-ទ្រី-សូរ-ប៉ា-ស្ទូ-រត់ទៅក្រែក ឬ-ណាំ ណាំ-ដី (ទ្រង់ផ្ញើង?) ។ គាត់នោះបត្តិចមក ទ្រង់នាំកងទ័ពចេញទៅច្បាំងតទល់នឹងពួកទ័ពចិន ១ បានជ័យជំនះទៅនៅកោះ បាវ-យៀន ។

មួយឆ្នាំតមក, សករាជ ឆត-ហ៊ូយ (1682) សា-ស៊ី-ទ្រី សូ-ប៉ា-ស្ទូ ស្តេចត្រឡប់មកគង់នៅ អូ-ឌុង-ណោ-ដី វិញ ។ ក្នុងឆ្នាំតមក, សករាជ យ៉ប់-ទី (1683) ព្រះអង្គនន់ ទ័ពទៅនៅខែត្រ ចាគ-ភូ ហើយច្បាំងនឹង សា-សី-ទ្រី-សូ-ថា-ស្ទូ ច្បាំងទប់ទល់ក្នុង ៤ ឆ្នាំមិនចាញ់មិនឈ្នះ ។

ថ្ងៃ ១១ កើតខែផល្គុណ ឆ្នាំថោះសប្តស័ក ព្រះពុទ្ធសករាជ ២២១៩ ចុល្លសករាជ ១០៣៧ (គ. ស. ១៦៧៨) វេលាព្រឹក បានឫក្សរមង្គលល្អ ទើបព្រះជ័យជេដ្ឋា (ព្រះអង្គសូរ) ស្ដេចឡើងគ្រងរាជសម្បត្តិ តពីសម្ដេចព្រះកែវហ្វា (ព្រះអង្គជី) ជាព្រះជេដ្ឋាព្រះវររាជបិតាមួយ ទ្រង់តាំងព្រះអង្គអីក្សត្រី ព្រះអនុជាឡើងជាព្រះរាជទេពី ស្ដេចប្រថាប់នៅក្នុងព្រះបរមរាជវាំងក្រុងឧត្តុង្គមានជ័យ (១) ។

លុះដល់ខែបុស្សឆ្នាំរោងអដ្ឋស័ក (ព. ស. ២២២០) ព្រះបាទសម្ដេចព្រះជ័យជេដ្ឋា ស្ដេចនាំពួកខ្ញុំរាជការទៅកសាងព្រះរាជវាំង គង់នៅទួលឥ ជើងគងរៃ ត្រសំរោងទងស្លាំ ។

ចំណែកឯព្រះទាវក្សត្រីជាព្រះវររាជមាតា ស្ដេចគង់នៅក្នុងព្រះបរមរាជវាំងក្រុងឧត្តុង្គជ័យ ។ លុះដល់ឆ្នាំរកាទោស័ក (ព. ស. ២២២៤) ព្រះអង្គអីក្សត្រីជាព្រះរាជទេពី ប្រសូតព្រះរាជបុត្រ ១ អង្គ ទ្រង់តាំងព្រះនាមព្រះមហាក្សត្រ ។

---

១ តាមច្បាប់ព្រះរាជពង្សាវតារភាសាថៃថា ទ្រង់ឡើងគ្រងរាជ្យនៅស្រុកព្រាំតម្លឹងក្នុងខែត្រសំរោងទង ចំណែកឯក្រុងឧត្តុង្គព្រះអង្គនូវឡើងគ្រងរាជ្យ ស្នងព្រះអង្គសម្ដេចព្រះរាមាធិបតី (ព្រះអង្គតន់) ។ ដល់ឆ្នាំមមែ ព. ស. ២២២២ ច. ស. ១០៤១ ទើបសម្ដេចព្រះជ័យជេដ្ឋាស្ដេចចេញពីស្រុកព្រាំតម្លឹងទៅក្រុងឧត្តុង្គ ។ ឯព្រះអង្គនូវដែលទ្រង់រាជ្យនៅក្រុងឧត្តុង្គ ព្រះជន្ម ២៥ វស្សាស្ដេចដោះរត់ទៅស្រុកយួន ទើបសម្ដេចព្រះជ័យជេដ្ឋាស្ដេចទៅប្រថាប់នៅក្រុងឧត្តុង្គតមក ។

## ព្រះរាជសង្គ្រាមគ្រាទី ២

## ទ័ពព្រះបរមរាជាលុកវាយបានក្រុងឧត្តុង្គឮជ័យ

អំពីកាលឯសម្តេចព្រះបរមរាជាមហាឧបយោរាជ ( ព្រះឥន្ទ្ររាជា ) ដែលស្តេចគង់នៅប្រទល់ដែនយួននោះ ទ្រង់បានចាត់មន្ត្រីខ្ញុំរាជការឲ្យទៅក្រាបទូលស្តេចយួន សុំសេនាទាហានមកថែមទៀត ស្តេចយួនបានចាត់មន្ត្រីខ្ញុំរាជការឲ្យនាំសេនាទាហាន ៥០០០ មកថ្វាយ ។

លុះដល់ឆ្នាំចត្វាស័ក ( ព. ស. ២២២៦ ) សម្តេចព្រះបរមរាជាស្តេចលើកទ័ពយួនដើរទឹក ឡើងមកវាយបានខែត្របាសាក់ព្រះត្រពាំងក្រមួនស វាយបានខែត្រតាមមាត់ទន្លេឡើងរៀងមក ដល់ខែត្រល្វាឯមចូលមកបោះទ័ពធ្វើបន្ទាយនៅជ្រោយចង្វា ។ ឯពួកចៅហ្វាយស្រុក ក៏ធ្វើកត្តហាយថ្វាយឲ្យទ្រង់ជ្រាបតាមដំណើរសព្វគ្រប់ ។

ទើបព្រះបាទសម្តេចព្រះជ័យជេដ្ឋា ស្តេចចាត់សេនាទាហានឲ្យលើកទ័ពទៅបោះនៅភ្នំពេញ បង្ក្រាំគ្នានៅទីនោះតែបរាជ័យចាញ់ទ័ពសម្តេចព្រះបរមរាជា ទើបលើកទ័ពថយមកក្រាបទូលឲ្យទ្រង់ជ្រាបទៅព្រះរាជវាំងទូលថ្វាយវិញ ។

ក្រោយនោះ ទ្រង់ត្រាស់បង្គាប់ឲ្យចាត់ពលដាក់តែយល្បាត រៀងតាមផ្លូវដើរគោកបន្ទាប់ក្រែងយួនលើកតាម និងការពារមាត់ទន្លេដើរទឹកផង ។ តែខាងក្រុងឧត្តុង្គជ័យ ពុំបានដាក់តែយល្បាតដោយធ្វេសប្រហែស ។

ឯសម្តេចព្រះបទុមរាជាកាលទ្រង់ជ្រាបថា សម្តេចព្រះជ័យជេដ្ឋា ទៅចសាងព្រះរាជវាំងគង់នៅទួលផ្ដើង ទុកសម្តេចព្រះមហាក្សត្រីឲ្យគង់នៅព្រះរាជវាំងទុគ្គព្រ័យ ក៏ទ្រង់មានព្រះអំណរណាស់ ទើបទ្រង់ប្រឹក្សានឹងកូនយួនថា វេលានេះត្រូវយើងលើកទ័ពទៅលុករាជវាំងទុគ្គព្រ័យ ចាប់យកសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាព្រះជ័យជេដ្ឋា នាំមកទុកក្នុងទ័ពយើងឲ្យបានសិន បើបានដូចបំណង អ្នកព្រះជ័យជេដ្ឋាគង់នឹងលើករាជសម្បត្តិថ្វាយយើងពុំខាន មេទ័ពយួនក៏យល់ព្រម ។

លុះវេលាយប់ ស្តេចលើកទ័ពដើងទឹកកម្រង់ទៅកំពង់ហ្លួង ហើយលើកឡើងទៅព្រះរាជវាំងទុគ្គពីមុន ត្រាស់បង្គាប់ឲ្យសេនាពាហានបាញ់កាំភ្លើងបន្លើល ។ ពួកមន្ត្រីនឹងបណ្តាក្រសួងនៅក្នុងព្រះរាជវាំង ក៏ភិតភ័យភ្ញាក់ផ្អើលរត់ខ្ចាត់ខ្ចាយ ទ្រង់កៀងបង្ខំឲ្យសេនាពាហានបើកទ្វារបន្ទាយ ចូលក្នុងព្រះរាជវាំងបាន ទ្រង់ត្រាស់បង្គាប់ឲ្យសេនាពាហានចាប់សម្តេចព្រះមហាក្សត្រី ជាព្រះវររាជមាតាព្រះជ័យជេដ្ឋានឹងនាំយកជាសារទៀត ឲ្យកងទ័ពឃុំគ្រង ស្តេចបោះទ័ពក្នុងព្រះរាជវាំង ។

ឯមន្ត្រីខ្លះរាជការខ្លះក៏ភិតភ័យរត់ទៅក្រាបទូល សម្តេចព្រះជ័យជេដ្ឋាឲ្យទ្រង់ជ្រាបរឿងគ្រប់ប្រការ ស្តេចទ្រង់ព្រួយព្រះទ័យណាស់ ត្រាស់ឲ្យប្រជុំសេនាបតីមន្ត្រីមកប្រឹក្សាពីការព្រះរាជសង្គ្រាមថា ថ្វីសក្លាយទាំងនេះ ព្រោះតែយើងធ្វេសប្រហែស រួចត្រាស់ឲ្យប្រមូលសេនាពាហាន

រួចស្រេច ស្តេចឡើងគង់ព្រះទីនាំងគជេន្ទ្រ លើកទ័ពចេញពីព្រះនគរកំពង់ឡួងទ្រង់ទៅក្រុងឧត្តុង្គជ័យ ដាក់ជំរុំមានល័ក្ខណ៍ ត្រាស់បង្គាប់ឲ្យបោះទ័ពនៅទីនោះមួយយប់ ព្រឹកឡើងទ្រង់ចាត់ទ័ពមុខក្រោយ ឆ្ពោះស្តេចលើកទ័ពចូលទៅតាមព្រះនគរឧត្តុង្គជ័យ ។

សម្តេចព្រះបទុមរាជា ក៏ត្រាស់បង្គាប់ឲ្យសេនាទាហានចេញទទួលប្រាំងតាំងឈ្មោះគ្រប់ពួកកងបន្ទាយវិញ ទើបទ្រង់ត្រាស់បង្គាប់ឲ្យនាយទ័ពនាំសម្តេចព្រះរាជត្រ្កីនិងនាងគាំ ចេញទៅមុនតាមផ្លូវបន្ទាយខាងកើត ស្តេចលើកទ័ពចេញទៅតាមក្រោយ ចុះព្រះទីនាំងនាក់នៅកំពង់ហ្លួង ហើយទ្រង់នាំសម្តេចព្រះរាជត្រ្កីឲ្យគង់នៅបន្ទាយស្រាយបង្អួ ចាត់ទ័ពឡើងរក្សាគង់ព្រះទីនាំងនាក់ ។

ឯសម្តេចព្រះជ័យជេដ្ឋាកាលទ្រង់ជ្រាបថា សម្តេចព្រះបទុមរាជាបរាជ័យចេញពីព្រះបរមនគរទៅអស់ហើយ ទើបស្តេចលើកទ័ពវិលត្រឡប់មកព្រះនគរកំពង់ឡួងវិញ ។

## ព្រះជ័យជេដ្ឋាព្រះអង្គបែរព្រះរាជឋាន
## ស្តេចមកគង់នៅព្រះរាជវាំងឧត្តុង្គជ័យ

ព្រះជ័យជេដ្ឋាទ្រង់ចាត់ឲ្យប្រជុំសេនាបតីមន្ត្រីទាំងនាយទ័ពនាយកងទាំងពួង ទ្រង់ប្រឹក្សាថា យើងធ្វើការច្បាំងដោយទាំងនេះ ព្រោះយើងបានបណ្ដេញព្រះបរមនគរឧត្តុង្គមានជ័យ មកនៅព្រះនគរកំពង់ឡួង

ចំនួន ៧ ឆ្នាំ បាល់តែព្រះបទុមរាជាលើកទ័ពមកលុកចាប់យក ព្រះគោន្ទោន
យើងទៅឃុំទុកក្នុងកងទ័ព វេលានោះ ត្រូវយើងត្រឡប់ទៅគង់នៅក្នុង
ព្រះបរមរាជវាំងចតុម្មុខវិញ ។ ឯអស់នាហ៊្មឺនសព្វមុខមន្ត្រីក្រាបបង្គំទូល
យល់ព្រមតាម ។

លុះដល់ខែពិសាខ ឆ្នាំកុរបញ្ចស័ក (ព. ស. ២២២៧) ស្ដេចនាំព្រះ
ទេពីព្រះម្ចាស់ ព្រមទាំងវង្សានុវង្សនាហ៊្មឺនសព្វមុខមន្ត្រីនាយទ័ពនាយកង
ទាំងពួង ព្រះរាជដំណើរទៅគង់នៅព្រះរាជវាំងក្រុងចតុម្មុខពូជ័យវិញ ។

ក្រោយនោះត្រាស់បង្គាប់ ឲ្យលោកនយល្បាតតាមផ្លូវដើរទឹក
ដើរគោក ហើយទ្រង់ចាត់ឲ្យភ្នាក់ងារទៅកេណ្ឌពលពីខេត្តក្រៅមក
បណ្ដាខែត្រទៅត្រើយខាងលិចទន្លេ ។ ដោយដំណើរនេះដល់សម្ដេច
ព្រះបទុមរាជា ទើបទ្រង់ប្រឹក្សានឹងអ្នកយួនទាំងពីរនាក់ថា ឥឡូវព្រះជ័យ
ជេដ្ឋាមកគង់នៅក្រុងចតុម្មុខពូជ័យហើយ ។ កេណ្ឌពលមកច្បាំងនឹងយើង
ដោយខ្លាច់ដែលយើងចាប់ព្រះវររាជមាតាមកឃុំទុកក្នុងកងទ័ព បើដូច្នេះ
ត្រូវយើងលើកទ័ពទៅវាយមុនកុំឲ្យប្រជុំពលទាន់ ។ អ្នកទាំងពីរក៏
យល់ព្រម ។

សម្ដេចព្រះបទុមរាជាទ្រង់ត្រាស់បង្គាប់ ឲ្យអ្នកយួនទាំងពីរលើកទ័ព
ដើរទឹកទៅវាយក្រុងចតុម្មុខ បានទៀងបោះទ័ពនៅស្រុកពញាឮខ្លះនៅកំពង់
ក្រសាំងខ្លះ ដោយបំណងនឹងរោធព័ទ្ធព្រះរាជវាំងចតុម្មុខមានជ័យ ។

ឯព្រះជ័យជេដ្ឋាទ្រង់ត្រាស់ថា ទ័ពយួនខ្លះលើកមកឡើងគោក មិនឆ្ងាយអំពីក្រុងប៉ុណ្ណោះ ទ្រង់ព្រួយព្រះរាជហឫទ័យណាស់ ទើបទ្រង់ប្រឹក្សានឹងសេនាមាត្យនាយទ័ពនាយកងទាំងពួងថា សត្រូវលើកមកពោះទ័ពជិតយើងណាស់ តើយើងត្រូវចេញច្បាំងឬដូចម្ដេច? នាយទ័ពនាយកងក្រាបទូលថា ការធ្វើសង្គ្រាមតែងមានឈ្នះមានចាញ់ តែការដែលមានជ័យជំនះនោះដោយកលឧបាយ ១ ដោយសេនាទាហានមានសតិបញ្ញាច្រើន ១ ដោយសេនាទាហានមានថ្វីដៃ ១ ដោយសេនាទាហានមានច្រើនហើយព្រមព្រៀងគ្នា ១ បើមិនព្រមព្រៀងគ្នាមានច្រើនដូចមានតិច ៗ ១ ទៀតវេលានេះ សេនាទាហានខាងយើងមានតិចណាស់ ដែលត្រាស់ឲ្យទៅកេណ្ឌនោះពុំទាន់មកជួបជុំ ទូលព្រះបង្គំទាំងអស់គ្នាយល់ឃើញថា គួរស្ដេចថយទៅគង់នៅបន្ទាយករណ្ដាលព្រាំតម៉ឹងសិន ដោយធ្វើកលឧបាយបញ្ឆោតកុំឲ្យពួកសត្រូវដឹងថា ស្ដេចថយក្រខ្ញាំង លើកគាម ឲ្យយល់ថាស្ដេចគង់នៅក្នុងព្រះបរមរាជវាំងនេះ ទ្រង់ព្រះសណ្ដាប់ហើយក៏ទ្រង់យល់ព្រម ។-

(មានត)

# មិច្ឆាទិដ្ឋិកថា

## យុគសុវត្ថិវេទី យូរ-អ៊ុន រៀបរៀង

(តមក)

បុគ្គលឯណាមានសេចក្ដីឃើញខុសទៀងទាត់ គឺមានចិត្តជឿស៊ប់តាមយោបល់នោះៗ ហើយលែងវាគវែរតំរិះទៅឯណាទៀត យល់ឃើញយ៉ាងណា ក៏ប្រកាន់ស្អិតយ៉ាងនោះ ទោះបីអ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាដើម ប្រដៅទូន្មានក៏មិនលះបង់លទ្ធិនោះចេញ ព្រោះចិត្តរបស់បុគ្គលនោះធ្លាក់ចុះដល់ជំនឿជាត់រឹង ៗ; ការយល់ឃើញយ៉ាងនេះឯងឈ្មោះថា និយតមិច្ឆាទិដ្ឋិ ។

គម្ពីរអដ្ឋកថានៃសាមញ្ញផលសូត្រនិងអដ្ឋកថានៃទសមសូត្រ ត្រង់តតិយវគ្គនៃគម្ពីរចតុក្កង្គុត្តរ មានពន្យល់ត្រង់រឿងនេះថា: បុគ្គលឯណាប្រកាន់នូវលទ្ធិនៃមិច្ឆាទិដ្ឋិទាំង ៣ នោះ មិច្ឆាទិដ្ឋិណាមួយហើយ អង្គុយស្វាធ្យាយសូត្ររៀនគម្ពីរដែលបង្កើតទិដ្ឋិនោះ ពិចារណានូវសេចក្ដីនៃគម្ពីរនោះទាំងយប់ទាំងថ្ងៃ, មិច្ឆាសតិគឺស្មារតីដ៏គិតខុសរបស់បុគ្គលនោះ ក៏តាំងស៊ប់គង់អារម្មណ៍នៃមិច្ឆាទិដ្ឋិដែលប្រព្រឹត្តទៅដោយន័យថា បុគ្គលកាលធ្វើអំពើអាក្រក់ មិនឈ្មោះថាធ្វើបាប, ហេតុបច្ច័យដែលនឹងធ្វើសត្វឲ្យសៅហ្មង ឬឲ្យបរិសុទ្ធមិនមាន, សត្វកាលស្លាប់ហើយក៏សូន្យ ដូច្នេះជាដើម ចិត្តនៃបុគ្គលនោះឯង រមែងដំកល់នៅនឹងថ្កល់គង់អារម្មណ៍នៃ

មិច្ឆាទិដ្ឋិនោះ ទាំងផ្លូវនេះក៏ស្ទះទៅ ; កាលផ្លូវទី ១ ស្ទះទៅ ឬផ្លូវទី ២ ផ្លូវទី ៣ ផ្លូវទី ៤ ផ្លូវទី ៥ ផ្លូវទី ៦ ស្ទះទៅ បុគ្គលនោះឯងឈ្មោះថា អនិយតមិច្ឆាទិដ្ឋិ ជាសតេកិច្ឆោ គឺជាអ្នកយល់ឃើញខុសប្រែប ដោយការកែព្យាបាន, កាលបើផ្លូវស្ទះទៅជាគំរប់ ៧ បុគ្គលនោះឯងឈ្មោះថា និយតមិច្ឆាទិដ្ឋិ ជាអតេកិច្ឆោ គឺជាអ្នកយល់ខុសមិនងាយអ្នកប្រាជ្ញណាកែឡើងបានវិញ ។ ចំណាំមិច្ឆាទិដ្ឋិទាំង ៣ នោះ បុគ្គលខ្លះមានចិត្តចុះស៊ប់កាន់មិច្ឆាទិដ្ឋិតែមួយ ខ្លះចុះស៊ប់កាន់មិច្ឆាទិដ្ឋិពីរ ខ្លះចុះស៊ប់កាន់មិច្ឆាទិដ្ឋិទាំងបី, បុគ្គលមានចិត្តចុះស៊ប់កាន់មិច្ឆាទិដ្ឋិ ១ ក្តី ២ ក្តីឬចុះស៊ប់កាន់មិច្ឆាទិដ្ឋិទាំង ៣ ក្តីឈ្មោះថា និយតមិច្ឆាទិដ្ឋិ ជាអ្នកមានទោសធ្ងន់ដល់ការឃាត់ផ្លូវសួគ៌និងផ្លូវនិព្វាន គឺជាជាអ្នកមិនអាចនឹងទៅកាន់ស្ថានសួគ៌ឬស្ថាននិព្វានក្នុងអត្តភាពជាលំដាប់នោះបានទេ បុគ្គលនោះឯងលោកហៅថាជាជដ្តកក្នុងសង្សារវដ្ត កើតមកគ្រាន់តែក្សាផែនដីឬឲ្យជូនផែនដីប៉ុណ្ណោះ មិនអាចនឹងរើខ្លួនឲ្យរួចចេញចាកសង្សារវដ្តបាន ព្រោះបុគ្គលបែបនេះ ច្រើនតែមិនងាយនឹងរើខ្លួនឲ្យរួចចាកគតបានឡើយ ។ ចុះបុគ្គលដែលឈ្មោះថា និយតមិច្ឆាទិដ្ឋិនោះ ចំពោះតែក្នុងអត្តភាពមួយនេះទេ ឬក្នុងអត្តភាពដទៃទៀតក៏នៅតែជានិយតមិច្ឆាទិដ្ឋិដែរ ។ ជានិយតមិច្ឆាទិដ្ឋិតែក្នុងអត្តភាពមួយនេះទេ តែបើទៅកើតក្នុងភពដទៃ ១ បានសេពគប់នឹងបុគ្គលជាមិច្ឆាទិដ្ឋិច្រើនទៀត ក៏ត្រឡប់ជាសាបចិត្តនឹងមិច្ឆាទិដ្ឋិនោះ ។

ទៀតវិញ ។ មិច្ឆាទិដ្ឋិ ៣ ប្រការ បំប្រួញមកជា ២ ប្រការវិញ មាន សេចក្ដីអធិប្បាយដោយន័យនេះឯង ។

## ទិដ្ឋិ ហុកសិបពីរ

មិច្ឆាទិដ្ឋិដែលថាមាន ៦២ តើដូចម្ដេចខ្លះ ?

មិច្ឆាទិដ្ឋិមាន ៦២[១] ប្រការនោះ ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់សំដែង ក្នុងគម្ពីរទីឃនិកាយសីលក្ខន្ធវគ្គ ត្រង់ព្រហ្មជាលសូត្រថា ម្នាលភិក្ខុទាំងឡាយ តថាគតធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្ដមដោយខ្លួនឯង ហើយអាចនឹងសំដែងបាននូវធម៌ទាំងឡាយឯណា, ពួកជនកាលនិយាយសរ-សើរនូវគុណរបស់តថាគតតាមសេចក្ដីពិត ដោយធម៌ទាំងឡាយឯណា ធម៌ទាំងឡាយនោះជាធម៌ជ្រាលជ្រៅដទៃអំពីសីលទាំង ៣ គឺ ចូឡសីល, មជ្ឈិមសីល, មហាសីល ជាធម៌ដែលបុគ្គលឃើញបានដោយលំបាក ត្រាស់ដឹងបានដោយក្រ ជាធម៌ស្ងប់រម្ងាប់ ជាធម៌ដ៏ថ្លៃថ្លា មិនជាទីស្ទង់ប្រមើលដោយសេចក្ដីត្រិះរិះ ជាធម៌ដ៏ល្អិត មានតែអ្នកប្រាជ្ញទើបដឹងបាន ។ ម្នាលភិក្ខុទាំងឡាយ ចុះធម៌ទាំងឡាយនោះតើដូចម្ដេចខ្លះ ? ។

ម្នាលភិក្ខុទាំងឡាយ មានសមណព្រាហ្មណ៍ពួក ១ ជាអ្នកប្រកប

---

១ ទិដ្ឋិ ៦២ ប្រការនោះ ចែកជា ២ ពួកគឺៈ បុព្វន្តកប្បទិដ្ឋិ ១ អបរន្តកប្បទិដ្ឋិ ១; រីបុព្វន្តកប្បទិដ្ឋិមានហេតុ ១៨ អបរន្តកប្បទិដ្ឋិមានហេតុ ៤៤, រួមត្រូវជា ៦២ ។ ចូរមើលសេចក្ដីខ្លីៗសំដែងដោយសង្ខេបតទៅនេះ បើចង់ជ្រាបដោយពិស្ដារ សូមមើលក្នុងសុត្តន្តបិដកខ្មែរ ១៤ ត្រង់ព្រហ្មជាលសូត្រចុះ ។

ដោយបុព្វន្តកប្បទិដ្ឋិ គឺជាអ្នកមានសេចក្ដីយល់ឃើញនូវចំណែកនៃខន្ធខាងដើម (ខន្ធកន្លងអតីតកាល) ព្រោះតែនូវចំណែកនៃខន្ធខាងដើម ហើយពោលនូវចំណែកនៃទិដ្ឋិច្រើនប្រការ ដោយហេតុ ១៨ យ៉ាង ។ ក្នុងហេតុទាំង ១៨ យ៉ាងនោះ មានពួកសមណព្រាហ្មណ៍ដែលជាអ្នកបញ្ញត្ត ៤ ពួកគឺ:

ក) ពួកសមណព្រាហ្មណ៍ជាសស្សតវាទ (អ្នកពោលប្រកាន់ថាទៀង) តែងបញ្ញត្តខ្លួននិងលោកថាទៀង ដោយហេតុ ៤ យ៉ាងគឺ

១- ព្រោះអាស្រ័យសេចក្ដីព្យាយាម ហើយបានដល់នូវចេតោសមាធិ កាលបើចិត្តតាំងនៅខ្ជាប់ខ្ជួនហើយ ក៏រឭកជាតិរបស់ខ្លួនឯងបានតាំងអំពី ១ ជាតិ ២ ជាតិ រហូតដល់ ១សែនជាតិ ទើបបញ្ញត្តខ្លួននិងលោកថាទៀង ។

២- ព្រោះអាស្រ័យសេចក្ដីព្យាយាម ហើយបាននូវចេតោសមាធិ កាលបើចិត្តតាំងនៅខ្ជាប់ខ្ជួនហើយ ក៏រឭកជាតិរបស់ខ្លួនឯងបានតាំងអំពី ១ សំវដ្តវិវដ្តកប្ប[១] រហូតដល់ ១០ សំវដ្តវិវដ្តកប្ប ទើបបញ្ញត្តខ្លួននិងលោកថាទៀង ។

៣- ព្រោះអាស្រ័យសេចក្ដីព្យាយាម ហើយបាននូវចេតោសមាធិ កាលបើចិត្តតាំងនៅខ្ជាប់ខ្ជួនហើយ ក៏រឭកជាតិរបស់ខ្លួនឯងបានតាំងអំពី

---

១ សំវដ្តកប្ប ប្រែថា កប្បវិនាស, វិវដ្តកប្ប ប្រែថា កប្បចំរើន ។

១០ សំវដ្តវិវដ្តកប្ប ហេតុផល ៤ៈ សំវដ្តវិវដ្តកប្ប ទើបបញ្ញត្តខ្លួននឹង លោកថាទៀង ។

៤ – ព្រោះអាស្រ័យសេចក្តីត្រិះរិះពិចារណា ស្ទាបស្ទង់មើលដោយប្រាជ្ញារបស់ខ្លួនឯងហើយសំដែងថា ខ្លួននឹងលោកជាសភាវៈទៀង សភាវៈ ផុតពូជ តាំងនៅនឹងថ្កល់ដូចជាកំពូលភ្នំ ឬដូចជាសសរគោល ឯសត្វទាំងនោះតែងអន្ទោលទៅមក តែងច្យុត តែងកើតវិញ ។

ខ) ពួកសមណព្រាហ្មណ៍ ជាអ្នកប្រកបដោយឯកច្ចសស្សតឯកច្ច-អសស្សតទិដ្ឋិ គឺយល់ថាលោកពួកខ្លះទៀង ពួកខ្លះមិនទៀង តែងបញ្ញត្តខ្លួននឹងលោកថាទៀងខ្លះ មិនទៀងខ្លះ ដោយហេតុ ៤ យ៉ាងគឺ:

៥ – ព្រោះរឭកបានត្រឹមតែជាតិ ដែលខ្លួនធ្លាប់កើតជាមហាព្រហ្ម ហើយច្យុតមកកាន់អត្តភាពជាមនុស្សប៉ុណ្ណោះ មិនអាចរឭកនូវជាតិឲ្យហួសអំពីនោះទៅទៀតបាន ទើបបញ្ញត្តខ្លួននឹងលោកថាទៀងខ្លះ មិនទៀងខ្លះ ។

៦ – ព្រោះរឭកបានត្រឹមតែជាតិ ដែលខ្លួនធ្លាប់កើតជាទេវតាឈ្មោះ ខិឌ្ឌាបទោសិកា (អ្នកវិនាសខ្លួនព្រោះល្បែង) គឺទេវតាដែលជាប់ចិត្តតែនឹងល្បែងភ្លេចបរិភោគអាហារ ហើយច្យុតមកកាន់អត្តភាពជាមនុស្សប៉ុណ្ណោះ មិនអាចរឭកនូវជាតិឲ្យហួសអំពីនោះទៅទៀតបាន ទើបបញ្ញត្តខ្លួននឹងលោកថាទៀងខ្លះ មិនទៀងខ្លះ ។

៧- ព្រោះពួកបានត្រឹមតែជាតិដែលខ្លួនធ្លាប់កើតជាទេវតា ឈ្មោះ មនោបទោសិកា[១] (អ្នកវិនាសខ្លួនព្រោះចិត្តប្រទូស្ដ) គឺទេវតាអ្នកធ្វើចិត្តឲ្យប្រទូស្ដដល់គ្នានឹងគ្នាហួសវេលា ហើយច្យុតមកកាន់អត្តភាពជាមនុស្សប៉ុណ្ណោះ មិនអាចនឹងរឭកឲ្យហួសអំពីនោះទៅទៀតបាន ទើបបញ្ញត្តខ្លួននឹងលោកថាទៀងខ្លះ មិនទៀងខ្លះ ។

៨ - ព្រោះតស្រ័យសេចក្ដីត្រិះរិះពិចារណាស្ទាបស្ទង់មើលដោយប្រាជ្ញារបស់ខ្លួនឯងហើយសំដែងថា ធម្មជាតិដែលហៅថា ភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ជាសភាវៈមិនទៀងទាត់មិនស្ថិតស្ថេរ តែងប្រែប្រួលទៅវិញជាធម្មតា ចំណែកខាងធម្មជាតដែលហៅថា ចិត្ត មនោ ឬវិញ្ញាណ នេះជាសភាវៈទៀងទាត់ស្ថិតស្ថេរ មិនប្រែប្រួលទៅវិញជាធម្មតា ។

ខ) ពួកសមណព្រាហ្មណ៍ជាអ្នកប្រកបដោយអន្តានន្តទិដ្ឋិ បញ្ញត្តលោកមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ដោយហេតុ ៤ យ៉ាងគឺ:

១ - ព្រោះតស្រ័យសេចក្ដីព្យាយាម ហើយបាននូវចេតោ-សមាធិ កាលបើចិត្តតាំងនៅខ្ជាប់ខ្ជួនហើយ ក៏មានសេចក្ដីសំគាល់ថាលោកមានទីបំផុត ទើបបញ្ញត្តថាលោកមានទីបំផុត មានខ្សែជុំវិញគឺមូលជុំវិញ ។

---

១ ជនរស់ទេវតានៅជាន់ចាតុម្មហារាជិកៈ ។

១០ - ព្រោះអាស្រ័យសេចក្តីព្យាយាម ហើយបាននូវចេតោស-
មាធិ កាលបើចិត្តតាំងនៅខ្ជាប់ខ្ជួនហើយ ក៏មានសេចក្តីសំគាល់ថា
លោកមិនមានទីបំផុត ទើបបញ្ញត្តថាលោកមិនមានទីបំផុត ។

១១ - ព្រោះអាស្រ័យសេចក្តីព្យាយាម ហើយបាននូវចេតោស-
មាធិ កាលបើចិត្តតាំងនៅខ្ជាប់ខ្ជួនហើយ ក៏មានសេចក្តីសំគាល់ថា
លោកមានទីបំផុតក្នុងទិសខាងលើ និងទិសខាងក្រោម, លោកមិនមាន
ទីបំផុតក្នុងទិសទទឹង គឺទិសតូចៗ ទើបបញ្ញត្តថាលោកមានទីបំផុតខ្លះ
មិនមានទីបំផុតខ្លះ ។

១២ - ព្រោះអាស្រ័យសេចក្តីត្រិះរិះពិចារណាស្ទាបស្ទង់មើលដោយ
ប្រាជ្ញារបស់ខ្លួនឯង ហើយសំដែងថា លោកនេះមានទីបំផុតក៏មិនមែន
មិនមានទីបំផុតក៏មិនមែន ។

ឃ) ពួកសមណព្រាហ្មណ៍ជាអ្នកប្រកបដោយ អមរាវិក្ខេបទិដ្ឋិ គឺ
អ្នកនិយាយបោះសំដីមិនឲ្យស្លាប់ខ្លួន កាលបើមានអ្នកណាមួយសាកសួរ
ប្រស្នាក្នុងកុសលនិងអកុសលនោះៗ ក៏ដល់នូវការបោះពាក្យបោះសំដីមិន
ឲ្យស្លាប់ពាក្យ ដោយហេតុ ៤ យ៉ាងគឺ:

១៣ - ព្រោះខ្លាចមុសាវាទ ខ្ពើមមុសាវាទ កាលបើមានអ្នក
ណាមួយសាកសួរប្រស្នាក្នុងកុសលនិងអកុសលនោះៗ ក៏ដល់នូវការបោះ
ពាក្យបោះសំដីមិនឲ្យស្លាប់ពាក្យថា សេចក្តីយល់ឃើញរបស់ខ្ញុំថាយ៉ាង

នេះក៏មិនមែន ថាយ៉ាងនោះក៏មិនមែន ថាយ៉ាងដទៃក៏មិនមែន ថាមិនមែនក៏ទេ ថាមិនមែនទេក៏មិនមែនដែរ ។

១៤- ព្រោះខ្លាចឧបាទាន ទើបឧបាទាន កាលបើមានអ្នកណាមួយសាកសួរប្រស្នាគឺកុសលនិងអកុសលនោះៗ ក៏ដល់នូវការពោះពាក្យពោះសំដីមិនឲ្យស្ថាប់ពាក្យថា សេចក្ដីយល់ឃើញរបស់ខ្ញុំថាយ៉ាងនេះក៏មិនមែន ថាយ៉ាងនោះក៏មិនមែន ថាយ៉ាងដទៃក៏មិនមែន ថាមិនមែនក៏ទេ ថាមិនមែនទេក៏មិនមែនដែរ ។

១៥- ព្រោះខ្លាចពាក្យសួរដេញដោល ព្រោះធុញថប់នឹងពាក្យសួរដេញដោល កាលបើមានអ្នកណាមួយសាកសួរប្រស្នាគឺកុសលនិងអកុសលនោះៗ ក៏ដល់នូវការពោះពាក្យពោះសំដីមិនឲ្យស្ថាប់ពាក្យថា សេចក្ដីយល់ឃើញរបស់ខ្ញុំថាយ៉ាងនេះក៏មិនមែន ថាយ៉ាងនោះក៏មិនមែន ថាយ៉ាងដទៃក៏មិនមែន ថាមិនមែនក៏ទេ ថាមិនមែនទេក៏មិនមែនដែរ ។

១៦- ព្រោះហេតុតែខ្លួនមានប្រាជ្ញាទន់ ហេតុតែខ្លួនល្ងង់ខ្លៅ កាលបើមានអ្នកណាមួយសាកសួរប្រស្នាគឺកុសលនិងអកុសលនោះៗ ក៏ដល់នូវការពោះពាក្យពោះសំដីមិនឲ្យស្ថាប់ខ្លួនថា សេចក្ដីយល់ឃើញរបស់ខ្ញុំថាយ៉ាងនេះក៏មិនមែន ថាយ៉ាងនោះក៏មិនមែន ថាយ៉ាងដទៃក៏មិនមែន ថាមិនមែនក៏ទេ ថាមិនមែនទេក៏មិនមែនដែរ ។

ង ) ពួកសមណព្រាហ្មណ៍ជាអ្នកប្រកបដោយអធិច្ចសមុប្បន្នទិដ្ឋិ ក៏អ្នកបញ្ញត្តខ្លួននិងលោកថាកើតឡើងដោយឥតហេតុ ដោយហេតុ ២ យ៉ាងគឺ:

១៧- ព្រោះរឭកបានត្រឹមតែជាតិដែលខ្លួនធ្លាប់កើតជាទេវតាឈ្មោះ អសញ្ញីសត្វ គឺសត្វមិនមានសញ្ញា ហើយក៏ច្យុតមកកាន់អត្តភាពជាមនុស្ស ត្រឡប់ជាមានសញ្ញាកើតឡើងវិញ មិនបានរឭកឲ្យហួសអំពីនោះទៅទៀតបានឡើយ ទើបបញ្ញត្តខ្លួននិងលោកថាកើតឡើងដោយឥតហេតុ ។

១៨- ព្រោះអាស្រ័យសេចក្ដីត្រិះរិះពិចារណាស្ទាបស្ទង់មើល ដោយប្រាជ្ញារបស់ខ្លួនឯង ហើយពោលយ៉ាងនេះថា ខ្លួននិងលោកកើតឡើងដោយឥតហេតុ ។

មានសមណព្រាហ្មណ៍ ១ ពួក ជាអ្នកប្រកបដោយអបរន្តកប្បទិដ្ឋិ ជាអ្នកមានសេចក្ដីយល់ឃើញនូវចំណែកនៃខន្ធខាងមុខ គឺខន្ធក្នុងអនាគតកាល ហើយសំដែងនូវចំណែកនៃទិដ្ឋិច្រើនប្រការ ដោយហេតុ ៤៤ ។ ក្នុងហេតុទាំង ៤៤ នោះមានពួកសមណព្រាហ្មណ៍ដែលជាអ្នកបញ្ញត្ត ៥ ពួកគឺ

ក ) ពួកសមណព្រាហ្មណ៍ដែលជាអ្នកប្រកបដោយឧទ្ធមាឃាតនទិដ្ឋិ[១] ជាសញ្ញីវាទ (ប្រកាន់ថាខ្លួនកាលស្លាប់ទៅមានសញ្ញា) បញ្ញត្តនូវខ្លួនថាមានសញ្ញាខាងមុខអំពីសេចក្ដីស្លាប់ ដោយហេតុ ១៦ យ៉ាងគឺ:

---

១ សេចក្ដីយល់ឃើញខាងមុខអំពីសេចក្ដីស្លាប់ ។

១៩ – បញ្ញត្តថា ខ្លួនមានរូប ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញា ។

២០ – បញ្ញត្តថា ខ្លួនមិនមានរូប ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញា ។

២១ – បញ្ញត្តថា ខ្លួនមានរូបខ្លះមិនមានរូបខ្លះ ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញា ។

២២ – បញ្ញត្តថា ខ្លួនមានរូបក៏មិនមែន មិនមានរូបក៏មិនមែន ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញា ។

២៣ – បញ្ញត្តថា ខ្លួនមានទីបំផុត ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញា ។

២៤ – បញ្ញត្តថា ខ្លួនមិនមានទីបំផុត ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញា ។

២៥ – បញ្ញត្តថា ខ្លួនមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញា ។

២៦ – បញ្ញត្តថា ខ្លួនមានទីបំផុតក៏មិនមែន មិនមានទីបំផុតក៏មិនមែន ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញា ។

២៧ – បញ្ញត្តថា ខ្លួនមានសញ្ញាដូចគ្នា ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញា ។

២៨— បញ្ញត្តថា ខ្លួនមានសញ្ញាផ្សេងៗ ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញា ។

២៩— បញ្ញត្តថា ខ្លួនមានសញ្ញាតិច ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញា ។

៣០— បញ្ញត្តថា ខ្លួនមានសញ្ញាច្រើន ឥតប្រមាណមិនបាន ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញា ។

៣១— បញ្ញត្តថា ខ្លួនមានសុខតែម្យ៉ាង ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញា ។

៣២— បញ្ញត្តថា ខ្លួនមានទុក្ខតែម្យ៉ាង ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញា ។

៣៣— បញ្ញត្តថា ខ្លួនមានទាំងសុខទាំងទុក្ខ ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញា ។

៣៤— បញ្ញត្តថា ខ្លួនមិនមានទុក្ខ មិនមានសុខ ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញា ។

១) ពួកសមណព្រាហ្មណ៍ ជាអ្នកប្រកបដោយឧទ្ធមាឃតនទិដ្ឋិ ជាអសញ្ញីវាទ (ប្រកាន់ថាខ្លួនកាលស្លាប់ទៅមិនមានសញ្ញា) បញ្ញត្តខ្លួនថា មិនមានសញ្ញា ខាងមុខអំពីសេចក្តីស្លាប់ ដោយហេតុ ៨ យ៉ាងគឺ:

៣៥ – បញ្ញត្តថា ខ្លួនមានរូប ជាអត្តភាពមិនមានភេទ ស្លាប់ហើយជាសត្វមិនមានសញ្ញា ។

៣៦ – បញ្ញត្តថា ខ្លួនមិនមានរូបជាអត្តភាពមិនមានភេទ ស្លាប់ហើយជាសត្វមិនមានសញ្ញា ។

៣៧ – បញ្ញត្តថា ខ្លួនមានរូបខ្លះ មិនមានរូបខ្លះ ជាអត្តភាពមិនមានភេទ ស្លាប់ហើយជាសត្វមិនមានសញ្ញា ។

៣៨ – បញ្ញត្តថា ខ្លួនមានរូបក៏មិនមែន · មិនមានរូបក៏មិនមែន ជាអត្តភាពមិនមានភេទ ស្លាប់ហើយជាសត្វមិនមានសញ្ញា ។

៣៩ – បញ្ញត្តថា ខ្លួនមានទីបំផុត ជាអត្តភាពមិនមានភេទ ស្លាប់ហើយជាសត្វមិនមានសញ្ញា ។

៤០ – បញ្ញត្តថា ខ្លួនមិនមានទីបំផុតជាអត្តភាពមិនមានភេទ ស្លាប់ហើយជាសត្វមិនមានសញ្ញា ។

៤១ – បញ្ញត្តថា ខ្លួនមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ជាអត្តភាពមិនមានភេទ ស្លាប់ហើយជាសត្វមិនមានសញ្ញា ។

៤២ – បញ្ញត្តថា ខ្លួនមានទីបំផុតក៏មិនមែន មិនមានទីបំផុតក៏មិនមែន ជាអត្តភាពមិនមានភេទ ស្លាប់ហើយជាសត្វមិនមានសញ្ញា ។

គ) ពួកសមណព្រាហ្មណ៍ ជាអ្នកប្រកបដោយទ្ធមាយតនទិដ្ឋិ ជានេវសញ្ញានាសញ្ញាវាទ បញ្ញត្តរូបខ្លួនថាមានសញ្ញាក៏មិនមែន មិនមាន

សញ្ញីក៏មិនមែន (មានសញ្ញាដូចជាគ្មានសញ្ញា គឺមានសញ្ញាដ៏ល្អិត) ខាងមុខអំពីសេចក្តីស្លាប់ ដោយហេតុ ៨ យ៉ាងគឺ:

៤៣— បញ្ញត្តថា ខ្លួនមានរូប ជាអត្តាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញីក៏មិនមែន មិនមានសញ្ញីក៏មិនមែន ។

៤៤— បញ្ញត្តថា ខ្លួនមិនមានរូប ជាអត្តាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញីក៏មិនមែន មិនមានសញ្ញីក៏មិនមែន ។

៤៥— បញ្ញត្តថា ខ្លួនមានរូបខ្លះ មិនមានរូបខ្លះ ជាអត្តាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញីក៏មិនមែន មិនមានសញ្ញីក៏មិនមែន

៤៦— បញ្ញត្តថា ខ្លួនមានរូបក៏មិនមែន មិនមានរូបក៏មិនមែន ជាអត្តាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញីក៏មិនមែន មិនមានសញ្ញីក៏មិនមែន ។

៤៧— បញ្ញត្តថា ខ្លួនមានទីបំផុត ជាអត្តាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញីក៏មិនមែន មិនមានសញ្ញីក៏មិនមែន ។

៤៨— បញ្ញត្តថា ខ្លួនមិនមានទីបំផុត ជាអត្តាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញីក៏មិនមែន មិនមានសញ្ញីក៏មិនមែន ។

៤៩— បញ្ញត្តថា ខ្លួនមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ជាអត្តាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញីក៏មិនមែន មិនមានសញ្ញីក៏មិនមែន ។

(មានត)

## ធម្មបរិយាយ

# ព្រះគ្រូមហាបទុម មាឃ-ស៊ុន រៀបរៀង

(តមក)

បើយកទៅប្រកបកិច្ចការជាងឈើ ឲ្យសមតាមឋានៈក៏តែងហុចសេចក្ដីសុខមកឲ្យ សេចក្ដីនេះមានឧបមាយ៉ាងណា ពាក្យក៏មានឧបមេយ្យដូច្នោះដែរ គឺបើបុគ្គលពោលតែពាក្យដែលល្អ ក៏រមែងបានគុណប្រយោជន៍ សមគួរតាមនាទីរបស់ខ្លួន តែបើបុគ្គលអ្នកមិនដឹងប្រើ គឺយកពាក្យទៅប្រើជេរប្រទេចផ្ដាសាចាក់ដោតឲ្យអ្នកដទៃ បានសេចក្ដីក្ដៅក្រហាយជាដើម ក៏រមែងឲ្យទោសដល់អ្នកប្រើពុំខាន ត្រូវនឹងភាសិតលោកពោលទុកថា "អ្នកឯណាប្រើអណ្ដាតគឺពាក្យរបស់ខ្លួន ឲ្យជាគ្រឿងប្រហារដល់អ្នកដទៃហើយអ្នកនោះ នឹងត្រូវប្រើសីសៈរបស់ខ្លួនឲ្យជាគ្រឿងទទួលផលជំនួសពាក្យដែលខ្លួនពោលចេញទៅ" ដូច្នេះឯង ។ មានបុរាណសុភាសិតម្យ៉ាងទៀតថា "អណ្ដាតជាអាទិ៍កន្លង បានសុខទុក្ខផង ពីព្រោះអណ្ដាត" ។ អ្នកមានពាក្យល្អប្រកបធ្វើកិច្ចរបស់ខ្លួន ទោះបីតិចច្រើនឲ្យសម្រេចបាន ដូចភាសិតមួយឃ្លាទៀតថា "សំដីជាឯក លេខជាទោ" ដូច្នេះ ។

ហេតុនេះទើបលោកប្រៀនប្រដៅឲ្យលះពាក្យអាក្រក់ចេញហើយឲ្យពោលតែពាក្យដែលល្អប្រពៃ ត្រូវនឹងពុទ្ធានុសាសនីថា

តមេវ វាចំ ភាសេយ្យ  យាយត្តានំ ន តាបយេ សេចក្ដីថាបុគ្គលមិនត្រូវពោលវាចាដែលញុាំងខ្លួនឲ្យក្ដៅក្រហាយឡើយ ។ ព្រោះដូច្នោះសាធុជនគួរពោលតែវាចាដែលល្អ គឺវាចាដែលទន់ផ្អែមល្ហែម ព្រោះវាចាដែលពោលល្អហើយរមែងនាំប្រយោជន៍មកឲ្យ ។ វាចាដែលទន់ផ្អែមល្ហែមនោះ បានដល់ពាក្យដែលជាទីស្រឡាញ់ មិនក្រូវនៃស្លួន ដូចចំពាក់ដោតដល់ត្រចៀកអ្នកដទៃដែលបានស្ដាប់ ។

វាចាទន់ផ្អែមល្ហែមនោះ កាលបើចែកចេញជាប្រភេទមាន ៤ យ៉ាង គឺ សច្ចវាចា វាចាដែលពិត ១ អបិសុណវាចា វាចាមិនស៊កសៀត ១ អផរុសវាចា វាចាមិនគំរោះគំរើយ ១ អសម្ផប្បលាបវាចា វាចាដែលមិនឥតប្រយោជន៍ ១ ។

សច្ចវាចា និងអបិសុណវាចា ទាំងនេះ លើកទុកសិនឯងចាំពោលជាខាងក្រោយតទៅតាមលំដាប់បទមាតិកាដែលបានពោលរៀបរៀងទុកមកហើយខាងដើម; ក្នុងទីនេះ នឹងពណ៌នាវាចាល្អពីរប្រភេទ គឺវាចាប្រកបដោយមេត្តាករុណា ១ វាចាទន់ផ្អែមល្ហែម ១, ក្នុងប្រភេទទី ១ វាចាប្រកបដោយមេត្តាករុណា  បានដល់ពាក្យដែលល្អចិត្តក្នុងវេលាដែលឃើញអ្នកដទៃបានទុក្ខ ជួយជាសំនៀងឲ្យគ្រាកចាកសេចក្ដីទុក្ខឲ្យបានទទួលសេចក្ដីសុខវិញ ដូចពេទ្យឬអ្នកព្យាបាលមនុស្សឈឺ សូម្បីមានកាការណាមួយមិនជាទីត្រូវចិត្តរបស់ខ្លួនដែលអ្នកឈឺសំដែងឲ្យប្រាកដឡើង

កំដោយ ក៏អ្នកគ្រូព្យាបាលត្រូវតែតាំងចិត្តឲ្យល្អ ទាំងត្រូវប្រើយោនិ-សោមនសិការៈ អត់សង្កត់សេចក្ដីក្រោធខឹង បង្កើតសេចក្ដីមេត្តាករុណាឲ្យមាំមួន ពោលពាក្យប្រលោមលួមចិត្តឲ្យជាទីត្រេកអរដល់អ្នកឈឺ ដើម្បីលើកទឹកចិត្តឲ្យរីករាយតទៅ ហើយជួយណែនាំឲ្យមនុស្សឈឺ ចំប្រតិបត្តិគ្រប់ខ្លួនឲ្យល្អ, ការគ្រូដោយវិធីដូច្នេះ ឈ្មោះថា ជាពាក្យប្រកបដោយមេត្តាករុណា ។ មួយវិញទៀត ពួកជនដែលនៅរួមគណៈ រួមពួក រួមស្រុក រួមវត្ត មានសេចក្ដីប្រព្រឹត្តលាមកអាក្រក់ផ្លូវកាយវាចា មានការប្រព្រឹត្តអបាយមុខទាំង៤ គឺជាអ្នកលេងស្រី លេងស្រា, លេងល្បែងភ្នាល់ ទាំងអ្នកប្រសព្វនឹងបាបមិត្តដែលជាហេតុនាំខ្លួនឲ្យសាបសូន្យចាកប្រយោជន៍ទាំងពីរប្រការ គឺប្រយោជន៍បច្ចុប្បន្ននឹងប្រយោជន៍បរលោក, អ្នកដែលមានសេចក្ដីប្រព្រឹត្តល្អ គួរតែប្រើសំដីប្រកបដោយមេត្តានិយាយណែនាំប្រៀនប្រដៅ ឲ្យលះសេចក្ដីអាក្រក់នោះចេញ ហើយឲ្យតាំងខ្លួននៅក្នុងសេចក្ដីល្អមាំមួនឡើង យ៉ាងនេះក៏ឈ្មោះថា ជាពាក្យប្រកបដោយមេត្តាករុណា ។ ប្រភេទទី ២: ពាក្យទន់ផ្អែមល្ហែម ចុះដល់ពាក្យដែលពិរោះពិសា មិនគំរោះគំរើយ មិនទ្រគោះចុះបោក មិននាំឲ្យក្ដៅក្រហាយដល់ចិត្តរបស់អ្នកស្ដាប់ ជាពាក្យដែលមិនប្រកបព្រមដោយទិដ្ឋិមានៈ ដែលចាត់ថាជាពាក្យគួរទទួលទុកត្រសោបត្រកងទុកក្នុងចិត្តរបស់អ្នកស្ដាប់ មានការមិនជេរប្រទេចផ្ដាសាជេរស្ដីជាដើម ។ ផលរបស់ពាក្យទាំងពីរនេះ

បែកផ្សេងពីគ្នាដូចជាបានពោលរួចហើយ  គឺពាក្យអាក្រក់រមែងនាំផលអាក្រក់មកឲ្យ  ពាក្យដែលទន់ភ្លន់រមែងនាំផលល្អប្រពៃមកឲ្យ  តាមចំណែកនៃអាក្រក់និងល្អ ។ ព្រោះហេតុនេះ អ្នកត្រូវការនិយាយសេចក្ដីសុភាពទាំងឡាយ  គួរតែពោលពាក្យដែលទន់ភ្លន់ទើបជាការប្រពៃ  សូម្បីតែការប្រៀនប្រដៅកូនចៅរបស់ខ្លួនក៏គួរពោលតែពាក្យដែលពីរោះផ្អែមល្ហែម  ព្រោះការពោលពាក្យទន់ភ្លន់ដែលប្រាសចាកសេចក្ដីក្រោធខឹងនោះ តែងមានអានិសង្សអនេកប្រការដូចបានពោលមកហើយ  ទើបជាកុសលចរិយាដែលគួរតែប្រព្រឹត្តដោយចំណែកមួយ ។

## ៤-- បេសុញ្ញវាចា:

" ការលះបង់នូវសំដីបិតសៀត "

ខគ្រឹនេះបានដល់ការដែលមិនពោលពាក្យញុះញង់  បំបែកសេចក្ដីស្រឡាញ់ ។  ពាក្យនេះជាចំណែកកណ្ដាលមានទាំងគុណនិងទោសដូចបានពោលមកខាងដើមហើយ ។  ឯការពោលសិតសៀតញុះញង់ឲ្យជនអ្នកមានសាមគ្គីបែកបាក់គ្នានោះ  គឺសង្ខំរឿងពីរបស់អ្នកខាងណោះនាំទៅប្រាប់អ្នកខាងនេះ, សង្កៀតពាក្យពោលរបស់អ្នកខាងណោះ យកមកប្រាប់ដល់អ្នកខាងណេះ  ដោយមានបំណងចង់ធ្វើខ្លួនឲ្យបានគាប់ចិត្តជាទីស្រឡាញ់របស់អ្នកទាំងពីរខាងក្ដី  ដោយត្រូវការឲ្យគេថាជាសត្រូវ

បែកបាក់គ្នាស្រុកៗក្ដី ដោយការបន្ថយកម្លាំងសេចក្ដីសាមគ្គីរបស់គេឲ្យអន់ខ្សោយថយចុះទៅក្ដី ទាំងអស់នេះ ចាត់ចូលក្នុងលក្ខណៈដែលហៅថាពាក្យញុះញង់ ។ ម្យ៉ាងទៀត ការដើរសង្កេតយករឿងរ៉ាវរបស់ជនដទៃដែលគេមិនត្រូវការបើកចំហ ទៅបរិយាយអធិប្បាយក្នុងទីស្ថានផ្សេងៗ យ៉ាងនេះជាអំពើពុំប្រពៃឡើយ ឯការពោលពាក្យសើចសៀតញុះញង់បំបែកបំបាក់គេនោះរមែងឲ្យទោសដល់ម្ចាស់ខ្លួន តាមហេតុដែលខ្លួនបានពោលគឺធ្វើមិនឲ្យបានជាទីទុកចិត្តរបស់អ្នកដទៃ ប្រាសចាកសេចក្ដីរាប់អាន ទាំងមិនជាទីប្រាថ្នារបស់ពួកជនអ្នកស្រឡាញ់សាមគ្គីធម៌ បុគ្គលអ្នកប្រើសំដីញុះញង់ឈ្មោះថាជាអ្នកមិនដឹងប្រើនូវពាក្យរបស់ខ្លួន ព្រោះពាក្យនោះអាចធ្វើជនសព្វប្រទេសទាំងជាតិឲ្យទៅជាសត្រូវនឹងគ្នាបាន សូម្បីក្នុងផ្លូវព្រះពុទ្ធ-សាសនាក៏លោកចាត់ថាជាកម្មដ៏ធ្ងន់បំផុត ដូចការញុះញង់ទំលាយពួកសង្ឃ ដែលតាំងនៅក្នុងសេចក្ដីសាមគ្គីឲ្យបែកបាក់គ្នាក៏ត្រូវសង្ឃភេទជាអនន្តរិយកម្ម យ៉ាងធ្ងន់បំផុត តាំងនៅក្នុងឋានៈជាបាបជិតរបស់អ្នកកាន់ព្រះពុទ្ធសាសនា ហេតុនេះ ការពោលពាក្យសើចសៀតបុគ្គលគប្បីលះបង់ចេញហើយ គួរពោលតែពាក្យដែលជាហេតុនាំឲ្យកើតសេចក្ដីសាមគ្គីព្រមព្រៀងគ្នា ។

(អាចក)

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនាៈ ព្រះគ្រូសុវណ្ណញាណ សួរ - ហាយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង


*ផ្នែកអក្សរសាស្ត្រ* — *ទំព័រ*

| | | |
|---|---|---|
| លោក ហេង-យ៉ាន់ | កំពូលស្នេហា (តមក) . . . . . . . . | ២៨១ |
| ឃុនសុន្ទរមេធី ញូង-សឿង | ឯកសហស្សរាត្រី ភាគទី ១១ (តមក) . . | ២៩៣ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម | ព្រះរាជប្រវត្តិ ព្រះបាទសម្ដេចព្រះជ័យចេស្ដា (ព្រះអង្គសួរ) (តមក) . . . . . . . . | ៣០៣ |

*ផ្នែកសាសនា*

| | | |
|---|---|---|
| ឃុនសុវត្ថិវេទី យូរ - អ៊ុន | មិច្ឆាទិដ្ឋិកថា (តមកនិងចប់) . . . . . . | ៣១៣ |
| ព្រះគ្រូមហាបទុម មាឃ-ស៊ុន | ឥន្ទវគ្គបរិយាយ (តមក) . . . . . . . . | ៣៣១ |


ឆ្នាំទី ១៨ – លេខ ៦ ខែមិថុនា ១៩៤៦ – ដំឡៃជាវៈ ១ ឆ្នាំ ៣៨ រៀល ។

## កំពូលស្នេហា

# លោកហេង-យ៉ាន់ រៀបរៀង

(តមក)

សោភ័ក្ត្រ - សេចក្ដីនេះក៏ឃើញថាត្រូវប្រាកដ តែមានមិត្តចំ-ពួកខ្លះ ឃើញគេរបស់ខ្លួនបានសេចក្ដីសុខ តែរំដាច់ផ្ដាញសុខរបស់គេចេញ យ៉ាងហ្នឹង គួរជាមនុស្សបែបណាទៅ ? ។

អាចារ្យ - ត្រង់នេះហើយដែលលោកពោលថា "កាលខ្ញុំធ្វើឲ្យតែ" នរដែលមិត្តប្រព្រឹត្តល្មើសលើយើង ប្ដូរមួយក្បត់ចិត្តយើង បើយើងបេះអត់សង្កត់នោះជាការប្រសើរណាស់ នឹងមិនមានរឿងវែងទៅទៀត សេចក្ដីបង្ហៀរលោកក៏គៀនៅត្រឹមហ្នឹង ម៉េចឯងយល់ហើយឬនៅ ? ។

សោភ័ក្ត្រនៅស្ងៀមមិនមាត់ តែបព្ចាស់ក្នុងចិត្តថា គាត់នេះលេងខ្លួនហើយល្អណាស់ អាចារ្យ ។ ឯងប្រាជ្ញហើយ គំនិតយើងមិនដល់ទេ កាខ្ញុំតែឯងទៅចុះ គ្នាក់ទឹងតែដើមឲ្យងស្លាប់ទៅៈហើយ ។

លុះដើរដល់គៀមចិនលក់បាយ ក៏នាំគ្នាទាំង ៣ នាក់ចូលទៅអង្គុយហូតបាយដោយសប្បាយ គេពីរនាក់គេរួចមុន ទៅសល់តែសោភ័ក្ត្រម្នាក់ឯង ព្រោះមិនបានជាតិតហូតប៉ុន្មាន ដល់គេងើបទៅគេទឹកតតទៅបាន ក្ដាក់ខ្លួនព្រឹកខំបង្ហើយឲ្យអស់ពីចាន នៅរង់ចាំគេក្រឡប់វិលមកវិញ

ប្រាជ្ញាទីក្រោយមកក៏អញអុញមិនដឹងជាទីងគិតយ៉ាងណា ព្រោះខ្លួនមិនបានជាប់លុយមកផង ថ្ងៃនោះក៏ "គជ" រកមួយ:សិនគាន ទើបទឹកចិត្តចូលទីងអាចារ្យសន្ទឹក ក្លែងគិតដល់គុណដល់សេចក្ដីបង្គួរ និយាយទីងមិនឲ្យគិតលុយហើយនិយាយប្រាប់ថា ចាំស្អែកសឹមចេញលុយ ចិនក៏ព្រមព្រោះសោភ័ក្រ្ដជាប់ចេញចូលគៀមនោះ ។

លុះអាចារ្យទឹងសុភាចារបុរសវិលមកវិញ ទើបអាចារ្យលូកយកលុយឲ្យចិន តែសោភ័ក្រ្ដឃាត់មិនព្រមឲ្យចេញព្រោះខ្លួនចេញរួចហើយ តែអាចារ្យចេះតែចេញឲ្យថ្លៃបាយទៅ ដើរដល់ទីស្នាក់ សោភ័ក្រ្ដចាប់ទាញអាវអាចារ្យខ្លាចនិយាយថា "អាចារ្យមិនគួរលក់មុខខ្ញុំបាទ ដូច្នេះសោះ" ។

សុភាចារបុរស· "នែ! សោភ័ក្រ្ដឯងថាហ្នឹងខុសទេ គិតឲ្យជ្រៅទៅចុះ យើងមានគិតលក់មុខឯងពីកាលណា យើងទៅរកទិចចកទេតើ ម្ដេចក៏ប្រកាន់យ៉ាងហ្នឹង" ។

សោភ័ក្រ្ដ· "លោកមិនប្រាប់ទេ អាចារ្យចង់តែបំបាក់មុខខ្ញុំព្រោះឃើញខ្ញុំក្រ បើស្អប់ខ្ញុំណាស់យកកាំបិតមកសំឡាប់ខ្ញុំតែម្ដងទៅ" ។

អាចារ្យតឹងដើមទ្រូងក៏ដកខ្លួនថយពីដៃសោភ័ក្រ្ដយ៉ាងខ្លាំង សោភ័ក្រ្ដស្ទាខជាអាចារ្យកេរយ៉ ក៏ប្រឹងស្ទៀតដាល់អាចារ្យចំបង្កាផ្កាទៅក្រោយ អាចារ្យទ្រេតខ្លួនទៅប៉ះលើជញ្ជាំងផ្ទះឮគ្រាំង សោភ័ក្រ្ដគិតថែមទៀតតែ

អាចារ្យហើយគេបានចំបង់ខ្លួនឲ្យត្រង់ឡើងហើយកបសង្វិញនោះត្រូវឆ្អឹងជំនីរយ៉ាងធ្ងន់ សោភ័ក្ត្រក៏ដួលដល់ផែនដី បានសេចក្ដីឈឺចាប់ជាច្រើន ហើយដឹងខ្លួនច្បាស់ជាចាញ់ប្រៀបអាចារ្យ តែខំប្រឹងក្រោកឡើងចូលប្រយុទ្ធដោយមានះរិតចុះអាចារ្យពីក្រោមបំរុងឲ្យដួលនៅនឹងកន្លែង តែអាចារ្យមុខរឹងនោះ តែរវាស្រង់ដៃសោភ័ក្ត្រទាំងពីរឡើងផុតឡើងលើពោះនៅទទេ សោភ័ក្ត្រនឹកថា ដល់សេចក្ដីមរណៈជាន់នេះហើយក៏ភាវនាជាប់មាត់ធ្មេចភ្នែកហៅឈ្មោះថា "ណុជនេត្រនារី មាសបងអើយ" ។

នៅវេលានោះ រូបភាពដួងហ្ឫទ័យប្រាស់ក្នុងសតិរបស់សោភ័ក្ត្រនាងមានទឹកមុខស្ងួតស្រពោនយំខ្សឹកខ្សួល ទបនោយាំងស្ងួ ពោលពាក្យថា "ឱ! សោភ័ក្ត្របងប្អូន ម្ដេចមកចោលប្អូនឲ្យនៅតែឯងដូច្នេះមិនអាសូរដល់ចិត្តណុជនេត្របងបងទេឬ?" ហើយសោភ័ក្ត្រញញឹមតបទៅវិញ "ប្អូន បងស្លាប់គ្រោះនេះបិទភ្នែកជិត បងស្លាប់ព្រោះប្អូនណា! បងលាហើយ" រូបរូបនិមិត្តក៏អន្តរធានទៅ ឮស្នូរស្រៀង១ក្នុងត្រចៀកថា "ល្មមហើយលើងវិលទៅផ្ទះវិញហើយ" ទើបបើកភ្នែកឡើង ស្រាប់តែឃើញខ្លួនក្រាបលើស្មាអាចារ្យ សោភ័ក្ត្រភ្ញាក់ព្រឺតផើបឡើងយកដៃស្ទាបពោះក៏គ្មានដឹងអ្វីដូចធម្មតា ដូច្នោះឯង នាំឲ្យអាចារ្យនឹងសុភាចារបុរសសើចព្រមគ្នា ទើបអាចារ្យលួងលោមថា ឯងស្មានថាខ្ញុំជាមនុស្សឃោរឃៅ? ចូរដឹងច្បាស់ថា ខ្ញុំជាអាចារ្យពិតមិនមានចិត្តព្រួញញ៉ាំឲ្យគេបែកបាក់គ្នាទេ

ណ្ហើយបាត់ទឹងទៅ   ចាំពាក្យសុភាសិតដែលខ្ញុំបានអធិប្បាយឲ្យស្ដាប់កាលពីមុននោះទុកជាច្បាប់តទៅមុខ" ។

សោកក្រើនខ្លួនខុស   លុតជង្គង់ចុះសំពះសូមទោសអាចារ្យរួចបានលាអ្នកចាំងពីវិលត្រឡប់ទៅសំណាក់អាត្មាវិញ   ទឹកមិនអស់ចិត្តនឹងខ្លួនបានប្រព្រឹត្តឲ្យគួងលើអាចារ្យជាអ្នកមានគុណលើក្បាល   មិនគួរសោះហេតុតែមាត្រាមធ្វើឲ្យវង្វេងងងឹតមុខ   ទឹកបង់ជាក់ទណ្ឌកម្មខ្លួនឲ្យសមពាចកំហុស   ចុងបង្អស់បានហួសគិតដល់ណុជនេត្រូវក៏ដកដង្ហើមធំ ។

"អនិច្ចាហ្ន៎!   អំណាចមាត្រាមអាចនឹងសង្កត់សង្កិនជីវិតរបស់សត្វលោកឲ្យអន្ធការចុះ ជាសភាវៈតែងរកមិននឹងបជួបកង្ហារ   តម្រែននឹងប្រសើនឹងពាក់ឲ្យល្អបាន   ជាសត្រូវចំបងផងសត្វលោក   ជាសភាពបដិកូល ពុំគប្បីសេពគប់ មិនរើងដោយហេតុដ៏កព្វាន់អ្នកបានជាសត្វលោកកល់រួចគាប់ចិត្តនឹងអស់ធម្មជាតិនេះអីម៉្លេះ   មិនគួរបើតាំងស្ដែងភាពជាកំពូលត្រយងជីវិតសោះ   សមតែទុកជាតុក្កតាសំរាប់តាំងរាំលំអតែប៉ុណ្ណោះកន្សែពកៈសាំទៅហើយ ។

ដែលយើងមិនអាចនឹងសន្ទនាបាននោះ   គឺយើងស្មោះត្រង់ដល់គូសំឡាញ់របស់យើង   ដូចសុនខដែលស្មោះជល់ម្ចាស់របស់វាហួតដល់លះបង់ប្រយោជន៍ផ្ទាល់ខ្លួន   កាស្សួរឲ្យតែគាប់ចិត្តយើង   កុំនិយាយចុះអំពីទុក្ខវេទនាដែលយើងបានទ្រាំមកនោះ   មុឺងហើយនៅមិនត្រូវចិត្ត

នាងទៀត នាងនៅធ្វើព្រងើយមិនមេត្តាប្រណីដល់ប៊ុនសាវសែសក់ ថែរ ជាគំចេះតែរើយដំកើងថ្លៃឲ្យថ្លៃជាងយើងដកប មិនតែប៉ុណ្ណោះមានផល់ ទៅទទួលការៈអ្នកដទៃទៅវិញ នាំឲ្យយើងម្នាម្នេញតែម្នាក់ឯង ឃើញ ជាមាតុគ្រាមនេះជាអសិរពិសគួរឲ្យចៀសវាង តែបណ្ដោយឲ្យវាចិតបាន ហើយ គំស្រួលពិសនោះនឹងផ្សព្វផ្សាយជ្រួតជ្រាបពាសពេញតែគ្រាន់ កាយ មិនអាយទឹងកំចាត់ឲ្យឃ្លាតចេញបានឡើយ ។

ឱហ្ន៎ជីវិតមនុស្ស!

វគ្គទី ៧

## អនិច្ចយ៉ាយី

ចុះអំពូមិនទាន់ស្ងាត់សោះយាយនៅឡើយ នៅមើលឃើញព្រិលៗ មិនសូវច្បាស់ តែគេឮសូរសន្ទុះទាត់ស្ពឹកការចេញពីផ្ទះឈើមួយ នៅជើងក្រានភ្លើងចេះសន្ធោសន្ធៅ ចានក្បានទង្គិចគ្នានាំឲ្យដឹងថាអ្នកផ្ទះមានរវល់ធ្វើបុណ្យទានដោយពិត គេកំពុងរៀបចំធ្វើបុណ្យឧទ្ទិះលាភធាន ។ ផ្ទះនោះសង់អំពីឈើលាបពណ៌ខៀវមានយ៉ាំងខាងមុខ ទើបនឹងសង់ចំនួនបីឆ្នាំប៉ុណ្ណោះ ព្រោះក្បឿនៅក្រហមស្អាតនៅឡើយ មុខផ្ទះមានសួនដើមផ្កាដាំជាជួរមានរបៀបរៀបរយ ជាគេហដ្ឋានថ្មីខ្សែស្រួសក្រសួងដែលលោកគ្រូធ្វើការកែសំបុត្រ ។

ឪនោះ ផុះពោះបន្តិចកន្ទាប មុខស្រស់ញញឹម មានពុកមាត់ គាត់ខ្លី ៗ ប្រកបដោយចិត្តអធ្យាស្រ័យ តែជាក់ល្អមិនចេះប្រកាន់ទោសអ្នកដទៃ មានតែពាក្យបក់អានគេកល់គ្នាមិនរើសមុខ ៗ

ឪពុកមាត់ខ្លីមានកូនស្រីមួយ ទើបនឹងចូលក្នុងអាយុ ១៨ឆ្នាំ ហើយគាត់បានពិនិត្យឃើញកិរិយាគំនិតសោភ័ក្ត្រជាអ្នកត្រឹមត្រូវ ទើបចង់ភ្ជាប់ជាសាច់ញាតិ ពេលណាមានកិច្ចរវល់ម្ដង ៗ តែងហៅសោភ័ក្ត្រមកជួយជានិច្ចមិនដែលខាន ៗ

មុននោះមួយថ្ងៃ ឪខ្សែល្អសបានឲ្យបម្រើទៅហៅសោភ័ក្ត្រមកចប្លួនណាយប់នោះសោភ័ក្ត្រអង្គុយលេងនៅមុខផ្ទះម្នាក់ឯង កំពុងតែបែងខ្វល់ក្នុងចិត្តពុំសប្បាយ ដល់គេទៅហៅក៏ទទួលឡើងថា ពេលព្រឹកស្អែកនឹងជួបមុខកូនក្រមុំ នឹងបុត្រអ្នកជាតខាងម្នាក់ទៀតដែលគេប្រមូលទុកឲ្យដែរ ក្លាឲ្យលំបាកចិត្តមិនដឹងនឹងធ្វើកុមុខវៃបណាទីឯយកបិត្តនារីណា បែរទៅខាងណេះ ខ្លាចខាងណោះខឹង តែណ្ហើយតាមកុសលចុះ ៗ

ដល់ព្រឹកឡើង សោភ័ក្ត្រភ្ញាក់ពីព្រលឹមទៅផ្ទះឪខ្សែល្អសបានជួយកុងតែងរៀបចាត់ក្បានជាដើម ហើយបោសប្រាសសំអាតផ្ទះក្រាលកន្ទេលឲ្យស្រួលបួល ដល់ពេលលោករៀបធាន់ សោភ័ក្ត្រក៏លុតជង្គង់ពរចូលទៅជួសបាយដាក់ចាន រួចលើកថាសប្រណាម្យនៅវេលានោះភ្នែកសោភ័ក្ត្រសំឡឹងមើលនារីទាំងពីរនាក់ ក៏ភ្ញាក់ខ្លួនដោយលំអរបស់

ម៉ាងទាំងពីរ ពីបាកចិត្តខឹងរើសដែរ សុទ្ធតែកើតទោមទាំងពីរនាក់ ណា ព្រលក្ដែកដោយពន្លឺត្បូងពេជ្រដេញផ្លេកៗនៅនឹងត្រចៀកនាង ។

តែសោភ័ក្ត្រគាត់ចិត្តធ្វើអភិវន្ទនាការ ចំពោះបុត្រីថៃខ្សែល្អសព្រោះ រូបនាងចំណាប់ណាស់ ហើយកិរិយាមារយាទរបស់នាងក៏សុភាពរៀបរយ ល្អ សាច់គឺមិនដូរឡើងឈាមបំព្រងគួរបេតនា ស្រស់ជាងណុដខេត្រនារីជា ច្រើន មើលចុះក្ដែកក្លីគ្របះស្រឡះដូចពន្លឺព្រះភាព តែនិយាយកាលណា គ្រប់ក្ដែតក្រោមក៏ឡើងជាជួត ក្ដែកនោះល្មមសមនឹងដងកក្ការបស់នាង មិនតូចហួសខ្នាតមិនធំហួសមាត្ន សំដែងប្រាប់ថាជាអ្នកមានបដិភាណ ក្ដៀវក្តា មានពាក្យការគ្រោះក្សាយ ពងនាងតូចស្ដើងល្វាសល្អនមិនពេង ទៅមុខ មិនតែនមកក្រោយ ដំណើររៀបរយសមរម្យមិនលេះលោង ។ សោភ័ក្ត្រស្ទើរតែមិនជឿដល់ក្ដែករបស់ខ្លួន ទឹកស្នានជាយល់សប្ដិ មាន មុខប្រែក្លាយពីទុក្ខសៅហ្មង ទៅជាញញឹមបំព្រងឡើង ។ អ្នកទាំងអស់ គ្នាឃើញអាការកិរិយាសោភ័ក្ត្រដូច្នោះ ក៏ញញឹមអៀនកល់ខ្លួនធ្វើឲ្យក៏ឡោះ ក្រមុំទាំងគូនោះអៀនអន់ដាក់មុខ ។

ដល់ពេលអាហារ សោភ័ក្ត្រត្រូវអង្គុយជិតនាងទាំងពីរ ហៅតែសេន អៀនអស់យ៉ាងហើយ ស្ទើរនឹងលេបបាយមិនចូល ណាចន់មើលនាង ផង ណាទំព្រងកុំឲ្យគ្នាខុសរបៀប ត្រាតែញញើរដែបន្តិចៗ ។

----

ដល់ចំណាប់រូប បន្ទែមក៏ត្រូវលើកមកតាំងនៅមុខ មានសង់ខ្សែរលើប ក្លិនផ្កាឈើយអប់ផ្កាម្លិះផង។ ត្រាប់ខ្សែរលៀងធ្មេញខ្មៅដូចដែលកំពឹតមាស ខៀវ ហើយបន្ទែមត្រជាក់ ក្រោយទឹកតកពីលើ ទឹងផ្លែឈើឯទៀតៗ ជាច្រើន សុទ្ធជាចំណីប្រណីតតាំងអស់ សោភ័ក្ត្រពាមមុខណាក៏ពេញចិត្ត ។ ទើប មានយាយជកម្នាក់និយាយជន្ទូជន្ទេញឡើងថា :

“ម៉េចអ្នកប្អូនតូច បន្ទែមហ្នឹងគួរសមទេ?

“បាទលោកយាយ បន្ទែមអស់នេះមានទុជាសេណាស់ អ្នកដែលធ្វើនោះសមជាគ្រប់លក្ខណ៍ហើយ យ៉ាងហ្នឹងបានចំជាមេផ្ទះយ៉ាងឯក ជាអ្នកស្គាល់ភារៈរបស់ស្ត្រីភាព មិនដូចនារីខ្លះបេះកាសាដង់ស្ទូចស្តេន ទើនមិនចង់ចូលផ្ទះក្រាន គិតតែពីសំអាងឈាយជាត់មេច្រឡាបបបួរមាត់ ក្រហមព្រោះទឹកអប់សព្វសព៌ាងកាយ ដើរលេងហ៊ឺហាមិនប្រព្រឹត្តតាម ច្បាប់ស្រី ខុសឆ្ងាយពីប្រវេណីបុរាណ ព្រោះនារីអស់នោះយល់ឃើញថា “ការប្រព្រឹត្តបែបនោះសំដែងឲ្យដឹងថា នាងមានការព្រមិបរិបូណ៌មិន ដូចកូនស្រីនៅតែកន្ទុះផ្ទះដូចជាជាប់ឃុំ” ។

“ចុះអ្នកប្អូនតូចឯង ជានរណាធ្វើម្ហូបចំណីតាំងនេះលន់ស្មានមើល?

“ជំរាបប្រសាសន៍លោកយាយ, បើជាខ្ញុំបានឃើញនឹងភ្នែកខ្លួន អ្នកនឹងមិនជំរាប តែនេះខ្ញុំបាទដូចខ្ញាក់តាំងសង្ខាន ត្រាន់តែទឹកសរ-សើរ.........” ។

ជីខ្យល្អួសស្ទើយផ្តែតឡើងថា: "ដៃប្អូនឯងធ្វើណាក្មួយ"

សោភ័ក្រ្តបែរមុខមើលនាង ប្រទះភ្នែកគ្នា នាងក៏អៀនឱនមុខចុះ សោភ័ក្រ្តគិតក្នុងចិត្តថា ទុកជាយ៉ាងណាក៏មិនចាញ់ប្រៀបណុជនេត្រនារីដែរ ព្រោះណុជនេត្រតែងថ្ងូរតែរឿយៗ ថានាងមិនសូវប្រសប់ខាងមុខស្ងូតណ្តាំទេ តែដល់ពេលធ្វើបាយច្រើនតែគេចទៅណេះទៅណោះឲ្យផុតកុំឲ្យត្រូវភ្លក់ម្ហូបស៊ីបន្ទោសព្រោះម្ហូបមិនឆ្ងាញ់ឬក៏បាយឆៅប្រាយឬខ្លោច" ។

ជីខ្យល្អួសសំឡេងឃើញអ្នកទាំងពីរមានទឹកចិត្តស្របគ្នាដូច្នោះ ក៏និយាយឡើងទៀតថា:

"មើលក្មួយៗ ឯងមិនទាន់ត្រូវការចង់បានប្រពន្ធកូននៅឡើយទេឬអ្វី? នៅលីវតែឯងមិនគាប់ប្រសើរទេ ព្រោះមិនចេះទុកប្រាក់កាសឲ្យគង់ដោយគ្មានបារម្ភព្រួយនឹងត្រូវសារ តើក្មួយមានបើចាប់ចិត្តលើរូបនារីណាដែរឬ? បើពេញចិត្តត្រង់ណា ក្មួយប្រាប់ពូចុះចាំពូជួយធ្វើជាអ្នកផ្លូវចៅមហាឲ្យ" ។

"ជំរាបប្រសាសន៍លោកពូ ខ្ញុំបាទមិនយល់ទាស់ដល់ការកសាងគ្រួសារទេ តែខ្លួនខ្ញុំបាទសព្វថ្ងៃនេះ ទីទាល់ក្រនឹងរកអ្វីចិញ្ចឹមប្រពន្ធពុំបាន ទើបខ្ចាប់សេចក្តីនេះចេញ" ។

"កុំព្រួយអ្វី ការនេះទុកភារៈឲ្យពូចុះ ចាំពូគិតគូរបែបលក់ឲ្យបាន ស្រួល ព្រោះឯងដូចជាកូនជាមេពូដែរ" ។

សោភ័ក្ត្រផ្ដាសេចក្ដីយល់ច្បាស់ ក៏នៅស្ងៀមទ្រំទ្រង់ស្រពោនមុខបន្តិច រួចគិតក្នុងចិត្តថា "តើទឹងបាត់ចិត្តដូចម្ដេចបាន ឱណុជនេត្រស្និទ្ធជាប់ក្នុងដួងកមលសោភ័ក្ត្រយ៉ាងស្និទ្ធ ដែលជាម្ចាស់ចិត្តរបស់សោភ័ក្ត្រទៅហើយ ឱណុជនេត្រនារីអើយ! ទុកជានាងបែរចិត្តប្រែគំនិតដូចម្ដេច រូបបងនៅតែស្រឡាញ់នាងទៀតលើសដើមយ៉ាងណាមុខជាមិនបានជួបមុខប្អូនទៀតហើយ ឱណុជនេត្របណ្ដូលចិត្តអើយ! បងស៊ូម៉ឺងដែរនៅតែប្អូនមិនមេត្តាទៀត ថ្ងៃនេះយើងឃ្លាតចាកគ្នាដាច់សង្វែង ឆ្ងាយអើយសែនឆ្ងាយគួរឲ្យស្ដាយក្រៃណាទឹងស្ដាយ ធ្វើម្ដេចបានប្អូនដឹងចិត្តបងអេះ មកគ្រានេះបងគោរពតែព្រមទទួលយកកូនបីជាគូគ្រងហើយ តែអាពាហ៍ពិពាហ៍នេះកើតឡើងដោយប្រាសចាកសេចក្ដីស្នេហា ព្រោះបងស្រឡាញ់តែប្អូនមួយប៉ុណ្ណោះ ប្អូនជឿចុះកុំមានសេចក្ដីយល់អក្រក់ពីបងទៅទៀត ព្រោះបងផុតសង្ឃឹមហើយមួយវិញទៀតបីក៏មានគុណនឹងបងជាច្រើន សមគួរបងនឹងសោះសូន្យចាប់ដើមពីពេលនេះទៅ អនិច្ចាអើយ ធ្វើម្ដេចនឹងឲ្យណុជនេត្របានដឹងចិត្តបងអេះ?

កាលបើអ្នកទាំងអស់គ្នា បរិភោគអាហារស្រេចបរិបូណ៌ហើយ សោភ័ក្ត្រក៏ជួយលើកចានក្បានយកទៅលាងទុកដាក់ សោភ័ក្ត្រអ្នកក្រាំទឹង

ពពុះសាប៊ូ ពួកនារីខំលាងសំអាតហើយរៀបជាជង់ ៗ ស្រើគុះ ដល់ពេលរសៀលបានខឹងតែស្ងួតទឹក សោភ័ក្រ្តក៏រើយកកន្ទេលទៅជូត ដើម្បីនឹងរៀបដាក់ទុកកន្លែង តាប់ចូនពេលនោះគ្មាននរណានៅ ៗ តែពីរនាក់នឹងបុត្រីថៅកែស្រួស អ្នកទាំងពីរអង្គុយទល់មុខគ្នាធ្វើការ ។

ពេលនោះស្ងាត់សូន្យឈឹងឥតមានអ្វីកំរើក អ្នកផ្ទះអស់កំឡាំងសំរាកខ្លួនអស់ សោភ័ក្រ្តក៏រំពឹងដល់ក្តីកំសត់របស់ខ្លួនកាន់តែខ្លាំងឡើងៗ ផ្ទប់មុខមិនសប្បាយ លែងរវល់ប្រែស្រើយលេងជាមួយនឹងកុមារីនៅមុខខ្លួន កាលបើនាងឃើញទឹកមុខកំឡោះដូច្នោះ នាងរាប់ចិត្តសួរដោយញញើតឡើងថា

“បងព្រួយពីរឿងអ្វីឬ? ឬមួយពុំស្រួលខ្លួនអញ្ជើញទៅសំរាកចុះ ទុកបានឲ្យខ្ញុំជូតតែម្នាក់ឯងបានហើយ” ។

លុះបានឮសំដីដ៏ពីរោះជាប់ចិត្តដែលខ្លួនខានបានស្តាប់ជាយូរណាស់មកហើយ សោភ័ក្រ្តក៏យល់ឃើញថានាងនោះអាចនឹងលួងលោមឲ្យខ្លួនឃ្លាតចាកទុក្ខបាន ទើបសំដែងសេចក្តីអរគុណចំពោះនាងដោយសំរក់ទឹកភ្នែកពីរបីតក់ តែនាងគាត់មិនយល់ទើបកើតចង្ងល់ក្នុងចិត្តសួរផ្ទួនឡើងជាពីរដង ពីរឿងហេតុដែលនាំឲ្យកំលោះនោះកើតទុក្ខ ។ ដោយអត់ទ្រាំសំងំទុកក្នុងចិត្តមិនបាន ដោយចង់បញ្ចេញសេចក្តីកំបាំងនៃចិត្តរបស់ខ្លួនឲ្យគេដឹង សោភ័ក្រ្តក៏ថ្លែងទុក្ខប្រាប់នាងថា:

“អ្នក! អ្នកមានពិត្តសង្វេគដល់រូបខ្ញុំជាមនុស្សអនាថាឥតទីពឹង នោះ ខ្ញុំបាទអរគុណអ្នកលើសលែង ឯជីវិតខ្ញុំនោះគ្មានខ្លឹមសារសោះ ហើយកាលបើខ្ញុំនឹកដល់អនាគតរបស់ខ្ញុំម្ដងៗ តក់ស្លុតរន្ធត់ចិត្តឥតរកពយ ហាក់ដូចជាមានអ្វីមកគំរាមមិនឲ្យនៅសុខ អ្នកធ្លាប់ឃើញហើយមហាសមុទ្រតើមានសភាពបែបណា ជួនទឹកថ្កល់ ជួនញាប់ញ័រតក្រើតដោយព្យុះព្យាមា កើតរលកធំៗ ប៉ុនភ្នំ អ្នកសន្និដ្ឋានមើលចុះ នាវាតូចមួយដែលអណ្ដែតកណ្ដាលទឹកល្ហល្ហាប កណ្ដាលខ្យល់គាប ខំប្រឹងប្រយុទ្ធនឹងរលកភ័យក្នុងទីងងឹតឈឹងគេមើលទិសតំបន់ពុំឃើញ សង្ឃឹមតែកើនគោមផ្ទុះប៉ុណ្ណោះ ភាពនាវាកណ្ដាលសមុទ្រមានខ្យល់ខ្លាំងយ៉ាងណាមិញ ភាពនៃជីវិតខ្ញុំបាទក៏ដូច្នោះដែរ សព្វថ្ងៃស្មុងរកតែពន្លឺគោមផ្ទុះ តែគ្រានេះឲ្យអ្នកអើយ ពន្លឺនោះលេចដល់ភ្នែកខ្ញុំបាទហើយ...” ។

សោភ័ក្រ្តដកដង្ហើមធំ ចំណែកកុមារីស្ដាប់សេចក្ដីសោភ័ក្រ្តពុំបានហានបិត្តអាណិតអាសូរកុមារគ្រាតែស្រក់ទឹកភ្នែក ។ ដល់ធ្វើការងារសម្រេចហើយ សោភ័ក្រ្តនិយាយលាអ្នកម្ចាស់ផ្ទះវិលមកត្រឹស្ថានអាត្មាវិញ ។

(មានត)

ឯកសារមហាស្រុកត្រី

# មួយពាន់មួយយប់ (ជារឿងអារ៉ាប់)

ភាគទី ១១

## រឿងនាងស្បឺត

(តមក)

អ្នកកំលោះក៏តាំងផ្ដើមនិយាយថា ''អ្នកស្រី! តាមសព្វគ្រប់យ៉ាងដែលនាងមើលនឹងស្បូត្របួសសួនអំពាញមិញនេះ អាចហុបសេចក្ដីឲ្យខ្ញុំយល់បានថា នាងទទួលស្គាល់នៅពេលអានចំពោះព្រះកែមេ្យ៉ាងប៉ុណ្ណោះ ។ នាងនឹងបានត្រូវត្រាំស្លាប់ហេតុផលយ៉ាងសំខាន់ ដែលមានប្រាកដ ព្រោះគេជះបារមីនឹងឬទ្ធិបេស្ដារបស់ទ្រង់ ក្នុងពេលឥឡូវនេះពុំខាន ។ ខ្ញុំសូមសារភាពប្រាប់នាងថា កន្ទេលនេះគឺជាទ្រព្យរបស់ប្រទេសមួយយ៉ាងស្កុសម្ក ដែលផលពីដើមមានព្រះពជាគឺព្រះវរបិតារបស់ខ្ញុំហ៊ីងឯងគ្រប់គ្រងពង្សមានអំណាចពេញបន្ទុក ។ ព្រះពជាអង្គនេះ ព្រមទាំងស្រីស្នំក្រមការ, បណ្ដាជនក្នុងក្រុងទីដបណ្ដាក់ស្ដែបជាទាំងអស់ក្នុងព្រះនគរ សុទ្ធតែបួលចិត្តខាងវេទមន្តផ្សេង ៗ គឺជាអ្នកកាន់លទ្ធិបូជាភ្លើងនឹងកាន់លទ្ធិគោរពចំពោះ ណារ៉ាឌុន ជាស្ដេចជាន់ចាស់របស់ពួកយក្សដែលជាសត្រូវធំនឹងព្រះជាម្ចាស់យើង ។

ព្រះវរមាតាបិតាស្រឡាញ់ខ្ញុំជាទីបំផុត តាំងពីកុមារតូចមក ខ្ញុំមានស៊ីកលៀងយ៉ាងល្អ ១ នាក់ ជាតិជាអ្នកកាន់សាសនាមហាម៉ុត, នាងនោះបានចេះចាំក្បួនអាល់គួរង់ស្ទាត់ចំណាន ហើយចេះសេចក្តីអធិប្បាយពន្យល់យ៉ាងចំណាប់ ។ ស៊ីកលៀងតែងនិយាយនឹងខ្ញុំរឿយ ៗ ថា "ព្រះអយ្យបុត្រ! ក្នុងលោកនេះមានតែព្រះមួយអង្គទេ សូមទ្រង់ប្រយ័ត្ន កុំគាន់ប្រឡូកទៅទទួលស្គាល់ ហើយគោរពមនុស្សឯទៀតៗ ឡើយ" ។ នាងបង្រៀនខ្ញុំឲ្យមើលជាភាសាអារ៉ាប់ ហើយគម្ពីរដែលឲ្យមកខ្ញុំហាត់រៀនមើលនោះ គឺក្បួនអាល់គួរង់ ។ កាលខ្ញុំបានចេះចាំស្ទាត់ហើយ នាងបានអធិប្បាយពន្យល់ខ្ញុំ អំពីគោលទ្យាក់ហ៊ានរបស់ក្បួនដ៏សំខាន់នេះថែមទៀត ។ ឯកិច្ចដែលនាងបង្រៀនខ្ញុំនេះ គឺលបលាក់មិនឲ្យព្រះមាតាបិតានិងអ្នកផងដឹងឡើយ, លុះនាងបង្រៀនខ្ញុំឲ្យបានចេះដឹងពិតប្រាកដហើយ ចិត្តខ្លួនខ្ញុំក៏មានសេចក្តីជឿជាក់ខាងសាសនាមហាម៉ុតមុតមាំ ហើយនាងក៏ធ្វើមរណកាលទៅ ។ តាំងពីនាងក្ស័យជន្មទៅ ខ្ញុំក៏នៅតែចាំក្បួនអាល់គួរង់នោះជិតជាប់នៅក្នុងដួងចិត្តរបស់ខ្ញុំ តាមរបៀបដែលនាងបានបង្រៀនខ្ញុំ, ចំណែកខាង ណាហ្សារ៉ុត ដែលជាព្រះក្លែងក្លាយហើយនិងការបូជាក្លែងនោះខ្ញុំស្អប់ខ្ពើមណាស់ ។

លុះកន្លងទៅបាន ៧ ឆ្នាំពីរ-បីខែ ស្រាប់តែឮសូរសំឡេងទ្រហឹងអឹងកង កក្រើកខ្ទរខ្ទារពាសពេញទាំងទីក្រុង ហើយសំឡេងដែលគេកាប

ស្តាប់ជាតិចាំបាន នោះដូចតទៅនេះ "ឱហ្វូងសត្វបក្សាជនទាំងឡាយ! ចូរអ្នកទាំងអស់គ្នាបោះបង់លទ្ធិព្រះ ណារាយណ៍ និងលទ្ធិបូជាភ្លើងចោលចេញទៅ; ចូរនាំគ្នាគោរពបូជាចំពោះព្រះតែមួយអង្គប៉ុណ្ណោះ ដែលទ្រង់តែងមានសេចក្តីមេត្តាករុណា" ។

សូរសំឡេងថែបនេះឮពាសពេញទាំងទីក្រុង អស់កាលចំនួន ៣ ឆ្នាំតទៅមុខទៀត, ទុកជាដូច្នោះ ក៏ឥតមានអ្នកណាមួយប្រែគំនិតត្រឡប់មកកាន់សាសនាមហាម៉ុតឡើយ ។ ដល់ទៅថ្ងៃក្រោយបង្អស់នៃឆ្នាំទី ៣, ប្រហែលជាម៉ោង ៣ ឬម៉ោង ៤ ព្រឹក ពួកបណ្តាជនទូទៅទាំងអស់ក្នុងទីក្រុង ស្រាប់តែប្រែក្លាយទៅជាថ្មក្នុងពេលតែមួយភ្លែតប៉ុណ្ណោះ, អ្នកដែលកំពុងសំដែងអាការបែបណា ក៏នៅជាបែបនោះត្រង់កន្លែងដែលខ្លួននៅ (គឺអង្គុយក៏នៅជាអង្គុយដដែល យ៉ាងនេះជាដើម) ។ ព្រះវរបិតារបស់ខ្ញុំក៏ត្រូវទទួលគ្រោះថ្នាក់ដូចគ្នា គឺទ្រង់ក្លាយទៅជាថ្មខ្មៅដែលគេឃើញត្រង់កន្លែងមួយក្នុងវាំងនេះ ទាំងព្រះវរមាតាខ្ញុំក៏ធ្លាក់ទៅក្នុងបាបកម្មដូចគ្នាដែរ ។

នៅសល់តែខ្ញុំម្នាក់ឯង ដែលព្រះមិនបានដាក់ទោសផ្តន្ទាជាទំងន់ដូច្នោះ; តាំងពីពេលនោះមក ខ្ញុំរឹតតែមានសទ្ធាជឿជាក់ខ្លាំងបំផុត ហើយចំប្រឹងគោរពព្រះដោយម៉ឺងម៉ាត់ឥតសល់ពេលណាឡើយ ។ នែអ្នកស្រីឆោមឆាយ! ខ្ញុំជឿប្រាកដថា ព្រះអង្គបានបញ្ជូននាងមកក្នុងទីនេះដើម្បីឲ្យខ្ញុំ

បានលំហែកក្សាន្តចាកសេចក្តីទុក្ខ ខ្ញុំសូមអរព្រះគុណចំពោះព្រះអង្គឥត
មានទីបំផុត ព្រោះទីស្ងាត់ផែនដីនេះបណ្តាលឲ្យខ្ញុំអផ្សុកពេកណាស់" ។

រឿងក៏ទាំងអស់នេះ នឹងពាក្យទាំងប៉ុន្មានមាត់ខាងក្រោយនេះ
ធ្វើឲ្យខ្ញុំព្រួសរំភើបរំជួលខ្លាំងណាស់ ទើបខ្ញុំម្ចាស់និយាយថា "ទ្រង់! ពិត
ដូច្នោះមែន ឥតសង្ស័យឡើយ គឺជាគុណបុណ្យព្រះបានដឹកនាំខ្ញុំឲ្យចូល
មកដល់កំពង់ផែរបស់ទ្រង់នេះ ដើម្បីឲ្យបានជួបនឹងទ្រង់ហើយអញ្ជើញ
ឲ្យស្ដេចចេញផុត អំពីទីលំនៅដែលមានគ្រោះថ្នាក់យ៉ាងនេះឯង ។
កាលបើទ្រង់បានទតឃើញសំពៅដែលខ្ញុំជិះធ្វើដំណើរមកនោះ ទ្រង់គង់
នឹងជ្រាបថា ខ្ញុំជាអ្នកស្រុកស្កុកមួយដែរ ក្នុងក្រុងបាតដាវ ហើយខ្ញុំបាន
ទុកទ្រព្យសម្បត្តិឯទៀតៗ ច្រើនក្រាស់ក្រៃលគួរសមនៅទីនោះ ។ សូម
ឲ្យតែទ្រង់ស្ដេចទៅជាមួយនឹងខ្ញុំចុះ ខ្ញុំនឹងហ៊ានធានាថាយកទីសំណាក់ជាក់
ពួនយ៉ាងស្ងាត់ ឲ្យគង់នៅជាសុខសប្បាយ ដរាបទាល់តែទ្រង់បានស្គាល់
ស្ដេចកាលីហ្វ៍មានអំណាចជានាយកៈលើពួកបរិសុទ្ធ ហើយស្ដេចនោះ
នឹងប្រទានកិត្តិយសបណ្ដាស័ក្តិដ៏ខ្ពង់ខ្ពស់ ឲ្យល្មមសមនឹងបុណ្យរបស់
ទ្រង់ ។ ស្ដេចនោះគង់នៅក្នុងក្រុងបាតដាវ ហើយដំណើរដែលយើង
ទៅដល់ដំបូងនោះ យើងមិនមែនឲ្យដំណឹងឲ្យស្ដេចជ្រាបភ្លាមថា ទ្រង់
បានទៅដល់ក្រុងនោះទេ ទាំងមិនបាច់អង្វរគេសូមទីពំនាក់ជើងកោនអ្វី
ឡើយ គឺស្រេចលើខ្ញុំទាំងអស់ ។ ទ្រង់មិនគួរគង់នៅឲ្យយូរគេទៅទៀត

កូនចៅក្រុង ដែលគ្មានរបស់របរគាំពារទុកបំរុងឲ្យគេមើលគ្រាន់យ៉ាងនេះទេ; សំពៅរបស់ខ្ញុំនោះខ្ញុំប្រគល់ថ្វាយឲ្យនៅក្រោមបង្គាប់ទ្រង់ ស្រេចតែទ្រង់ទ្រង់សព្វព្រះទ័យរៀបចំតាក់តែងយ៉ាងណាក៏បាន" ។ ព្រះអង្គម្ចាស់នោះក៏ទទួលយល់ព្រមតាម រួចហើយយើងបានត្រៀមរកវេលាត្រីដែលសល់នៅ គឺពេលដែលមិនទាន់ភ្លឺនៅឡើយនោះ រៀបចំខ្លួនប្រាណនឹងប្រែដាប់ប្រែដាវបំរុងនឹងបុះសំពៅ ។

លុះដល់អរុណរះឡើង យើងក៏បើកអំពីកំពង់បុះសំពៅទៅឯកំពង់ផែ បានបួនទឹងបងស្រីទាំងពីរនាក់, នាយដំណែតសំពៅទីងពួកឈ្មួញទាំង-ឡាយ ដែលមានសេចក្តីព្រួយបារម្ភទទួងមើលផ្លូវ ព្រោះបាត់ខ្ញុំម្ចាស់មួយថ្ងៃមួយយប់ ។ លុះខ្ញុំម្ចាស់បានបង្ហាញឲ្យព្រះអង្គម្ចាស់ស្គាល់បងស្រីទាំងពីរនាក់ហើយ ខ្ញុំម្ចាស់ក៏សារសព្វនោះសារប្រាប់អ្នកទាំងនោះ អំពីដំណើរដែលឃាត់ខាំងខ្ញុំម្ចាស់មិនឲ្យត្រឡប់មកសំពៅពីថ្ងៃម្សិលមិញ ហើយប្រាប់អំពីការបានបួនទឹងស្ដេចកំឡោះនោះ ហើយនឹងរឿងរ៉ាវរបស់ទ្រង់ព្រមទាំងហេតុផលនៃសេចក្តីទុក្ខវេទនារបស់ចៅក្រុងដែលថ្កុំថ្កើងនោះផង ។

ពួកឈ្មួញសំពៅផ្ញើអីវ៉ាន់ដែលខ្ញុំដឹកយកពីស្រុកទៅនោះ យកចេញពីសំពៅមកដាក់លើគោក ហើយជញ្ជូនទ្រព្យសម្បត្តិសុទ្ធតែមានដម្លៃយ៉ាងល្អ ៗ កងកំរ៉ង ដូចយ៉ាងគ្រឿងពេជ្រ, គ្រឿងមាសនឹងគ្រឿង

ប្រាក់គ្រប់បែបនោះ យកមកផ្ទុកក្នុងសំពៅវិញអស់ពេលជាយូរថ្ងៃ ។ យើងបោះគ្រឿងសម្រាប់តុបតែងផ្ទះជាច្រើនយ៉ាង ដូចយ៉ាងតុ ទូ កាំងកៅអីជាដើម ហើយនិងគ្រឿងមាសប្រាក់ឯទៀត ៗ នោះច្រើនណាស់ ព្រោះសំពៅផ្ទុកដល់កំរិតទៅហើយ គ្មានកន្លែងដាក់យកមកឡើយ ក៏ត្រូវតែមានសំពៅជាច្រើនទៀតទើបផ្ទុកដឹករបស់ក្នុងវាំងនោះយកមកឯក្រុងបាតដាវៀអស់បាន ។

លុះយើងបានផ្ទុកទ្រព្យសម្បត្តិដែលយើងត្រូវការតាំងអម្បាលម៉ាននោះក្នុងសំពៅរួចស្រេចហើយ យើងបានយកស្បៀងអាហារនិងទឹកខ្លះដាក់បន្ថែមតាមផ្លូវផង ។ ប៉ុន្តែពោះតែត្រង់ស្បៀងនោះ យើងនៅសល់គ្រឿងគោកដែលបានដាក់សំពៅយកមកពីក្រុងបាល់សូក ដល់ទីបំផុតយើងលើកក្តោងបើកសំពៅចេញពីទីនោះបណ្ដោយតាមទិសខ្យល់, សំពៅលឿនក្រៃតាមជលាស័យសមដូចបំណង ។

ស្ដេចកំឡោះ, បងស្រីនិងខ្ញុំម្ចាស់នៅតែនិយាយលេងសើចដោយរីករាយជាមួយគ្នារាល់ៗ ថ្ងៃ ប៉ុន្តែមិនដឹងជាកម្មក្រាស់អ្វីហ្ន៎! ការសាមគ្គីរបស់យើងនោះមិនបានយូរប៉ុន្មានឡើយ គឺបងស្រីទាំងពីរនាក់បែរទៅជាប្រែប្រច័ណ្ឌស្ដេចកំឡោះហើយនិងខ្ញុំម្ចាស់ លុះតមកក្នុងថ្ងៃមួយជាខាងក្រោយ បងស្រីសួរខ្ញុំម្ចាស់ដោយឧបាយកលថា កាលណាយើងទៅដល់ក្រុងជាតបាទហើយ យើងនឹងទុកដាក់ព្រះអង្គម្ចាស់

ជាអ្វី ៗ ខ្ញុំម្ចាស់ដឹងខ្លួនភ្លាម គឺគេដាក់ប្រស្នាសួរត្រង់ផ្លូវនេះ ដើម្បីបង់ជីវិតគិតខ្ញុំម្ចាស់ឲ្យប្រាស់លាស់កុំណោះឯង ៗ ហេតុនោះខ្ញុំម្ចាស់ធ្វើជានិយាយបំអកបំអន់ដំបូងសើចលេងត្រឡប់ត្រឡិនចុះឡើងដោយពាក្យថា "ខ្ញុំយកព្រះអង្គម្ចាស់នេះទៅធ្វើជាប្តី" រួចខ្ញុំម្ចាស់ក៏ងាកបែរទៅនិយាយនឹងស្តេចនោះថា "ម្ចាស់បង! ខ្ញុំសូមអង្វរឲ្យទ្រង់យល់ព្រមក្នុងរឿងនេះ កាលណាយើងទៅដល់ក្រុងបាតជាទហើយ ខ្ញុំនឹងប្រគល់ខ្លួនប្រាណធ្វើជាទាសីយ៉ាងសុភាពរាបសារបស់ទ្រង់ តាមតែទ្រង់ប្រើប្រាស់ចុះខ្ញុំនឹងទុកទ្រង់ជាចៅហ្វាយនាយដោយដាច់ខាត" ៗ

ព្រះអង្គម្ចាស់ឆ្លើយមកវិញថា "អ្នកស្រី! ខ្ញុំមិនដឹងទេ តាមតែនាងលើកទុកលើកដាក់ចុះ, ប៉ុន្តែចំណែកខ្ញុំវិញ ខ្ញុំសុំប្រាប់នាងដោយប្រាកដប្រជា ចំពោះមុខអ្នកស្រីទាំងពីរនាក់ដែលជាបងរបស់នាងថា លុះដល់ពេលនោះ ខ្ញុំយល់ព្រមទទួលតាមពាក្យអញ្ជើញរបស់នាង ដោយទឹកចិត្តសុចរិតស្មោះត្រង់ពិត ៗ; ខ្ញុំមិនមែនទុកនាងជាទាសីទេ ទោះបីយ៉ាងម៉េចក៏គង់ទុកនាងជាប្រពន្ធ ឬជាមេផ្ទះដែរ ហើយខ្ញុំឥតកក់កាចយកអំណាចអ្វីទេ ស្រេចតែនឹងនាងចុះ" ៗ លុះបានស្តាប់ពាក្យនេះហើយ បងស្រីខ្ញុំម្ចាស់ទាំងពីរនាក់ក៏ប្រែពីមុខភ្លាម ហើយខ្ញុំម្ចាស់បានសំគាល់មើលតាំងពីពេលនោះមកឃើញថា នាងទាំងពីរនាក់មានចិត្តមិនស្មោះត្រង់ចំពោះរូបខ្ញុំម្ចាស់ដូចកាលពីដើមទៀយ ព្រោះបមោហោរបស់គាត់

កក្តាប់បានស៊ីបានចុកមួយលើកពីរលើកម្ដងៗ ទៅហើយ នៅតែបន់

ប្រៀតប្រៀនដណ្ដើមរបស់ផងគេទៀត) ។

លើងទៅដល់ឈូងសមុទ្រពែរ្ស ហើយចូលសំពៅទៅរកក្រុងបាល់សូរ៉ា, ដោយមានខ្យល់ជំនោរត្រូវគ្នានឹងពេញបន្ទុក ខ្ញុំម្ចាស់សង្ឃឹមថាស្រួតនឹងបានដល់ទីក្រុងនោះពុំខាន ។ ប៉ុន្តែលុះដល់ពេលយប់ វេលាដែលខ្ញុំម្ចាស់កំពុងទទួលព្រះកដទានដំណេកលក់ស៊ប់ បងស្រីទាំងពីរនាក់ក្រោកឡើងយកគ្រឿងឈសនោះនាំគ្នាចាប់ខ្ញុំម្ចាស់ទម្លាក់ចោលក្នុងសមុទ្រ ទាំងព្រះអង្គម្ចាស់នោះក៏ចាប់បោះចោលទៅក្នុងសមុទ្រដែរ ។ ខ្ញុំម្ចាស់ជ្រមុជជ្រមាំលិចលង់ឈ្លក់ទឹកនៅនាកណ្ដាលផ្ទៃសមុទ្រធំធេង ណាមួយយប់ងងឹតសូន្យសុង ស្ទើរតែចាក់ក្អកមិនយល់ ប៉ុន្តែដោយសារទឹកដោះម្ដាយថ្លៃណាស់ ទ្រាំដោយភ័ព្វសំណាងយ៉ាងអស្ចារ្យ សូម្បីងងឹតឈឹងយ៉ាងនោះក៏ខ្ញុំម្ចាស់នៅតែមើលឃើញបាន គឺសំឡឹងមើលទៅខាងមុខឃើញទៅៗ ប្រាកដដល់ក្តួតខ្ញុំម្ចាស់ហាក់ដូចជាដី ទើបខំប្រឹងហែលបណ្ដោយខ្លួនសំដៅទៅត្រង់ទីនោះ ។ កាលព្យាយាមហែលយ៉ាងនេះយូរណាស់ក៏បានដល់ទីជម្រាលឆ្នេរសមុទ្រ ; លុះដល់ពេលភ្លឺច្បាស់ឡើង ខ្ញុំម្ចាស់បានស្គាល់កន្លែងនោះពិតប្រាកដថាជាកោះមួយតូចស្ងាត់ផ្ទាល់ឆ្ងាយដាច់សន្ធឹងអំពីក្រុងបាល់សូរ៉ា ។ ខ្ញុំម្ចាស់ដោះសំលៀកបំពាក់សំងួតហាលថ្ងៃក្នុងទីនោះមួយសន្ទុះ រួចហើយដើរសៀរៗតាមទីជម្រាលខាត់សមុទ្រ

បានឃើញផ្លែឈើគ្រប់បែបទំទឹកភង់ជាស្អាត ក៏មានសេចក្តីត្រេកអរដោយ សង្ឃឹមថា ទីនេះអាចនាំការរក្សាជីវិតឲ្យបានរស់នៅតទៅទៀតបាន ។

ខ្ញុំម្ចាស់គង់យសម្រាកកំឡុងក្រោមម្លប់ឈើ ១ ដើម ក្រឡេកទៅឃើញពស់ ១ មានស្លាប ពងអាក់ពះ ហើយបណ្តោយខ្លួនវែងល្វៃ លូនសំដៅមករកខ្ញុំម្ចាស់ធ្វើក្បាលងើងៗ បម្រះប្រឡោតទៅខាងស្តាំម្តង ខាងឆ្វេងម្តង ហើយលៀនអណ្តាតផ្លុមៗ អាការបែបនេះអាចឲ្យខ្ញុំម្ចាស់យល់សេចក្តីបានថា មានសេចក្តីអន្តរាយ ឬ សត្រូវកំណាចអ្វីមួយជៀតជៀនជាដោយពិត ទើបខ្ញុំម្ចាស់ក្រោកឈរឡើង ហើយក្រឡេកមើលបញ្ឆៀតទៅទៀត ក៏បានឃើញពស់ ១ ទៀតធំសម្បើមអស្ចារ្យកំពុងទាំពស់មុននោះត្រឹមត្រូវ ហើយទំប្រឹងលេបដោយកំឡាំងយ៉ាងក្លាហាន ខ្ញុំម្ចាស់មានសេចក្តីភ័យភិតភាសូរពន់ពេក ។ គង់ពេលនោះគួរតែខ្ញុំម្ចាស់ខ្លាចហើយគៀសខ្លួនគេចចេញ ប៉ុន្តែបែរជាមានសេចក្តីអង់អាចហ៊ានប្រឈមទៅវិញ ទើបចាប់រើសបានដុំថ្ម ១ ដុំដែលនៅជិតខ្លួន ហើយគោលពេញទំហឹងសំដៅពស់ធំដែលកំពុងលេប ។ ដៃខ្ញុំម្ចាស់ដូចជាត្រង់គួរសមដែរ ដុំថ្មនោះត្រូវចំក្បាលពស់នោះពួសម៉ក, វាក៏ខ្ជាក់ខ្ជួរពស់តូចនោះចោលទៅ ។ ពស់តូចបានរួចខ្លួនហើយក៏ត្រដាងស្លាបហោះហើរ, ខ្ញុំម្ចាស់តាមសំឡឹងមើលយូរណាស់ វាហោះទៅតាមអាកាសខ្ពស់ប្រែដូចជាផ្កាយសត្វចម្កា, ទាល់តែផុតកន្ទុយភ្នែកទើបខ្ញុំម្ចាស់ទៅ

អង្គុយក្រោមម្លប់ ១ ទៀត ហើយក៏ទទួលព្រះកជទានដំណេកលក់ក្នុងទីនោះទៅ ។

លុះរលឹកឡើង ស្រាប់តែភ្ញាក់ខ្លួនព្រឺត ព្រោះនៅក្បែរខ្លួនខ្ញុំម្ចាស់ឃើញមានស្រីម្នាក់ មុខមាត់ស្រស់បំព្រងមានទាំងដៃមេដៃក្ដពីមានសម្បុរផ្សេងៗ គ្នា ។ ខ្ញុំម្ចាស់ក្រោកអង្គុយឡើងភ្លាមហើយបានសួរស្រីនោះថា នាងជាអ្វី ? នាងឆ្លើយប្រាប់ថា " ខ្លួនខ្ញុំនេះឯងគឺជាពស់ដែលនាងបានជួយឲ្យរួច អំពីកណ្ដាប់ដៃសត្វកំណាចក្នុងពេលមុនបន្តិចនេះ ខ្ញុំបានដឹកលើកដល់ឧបការគុណដែលនាងបានធ្វើដល់ខ្ញុំ ហើយខ្ញុំត្រូវតបគុណដល់នាងវិញ ។ ខ្ញុំបានដឹងទាំងអស់ អំពីសេចក្ដីក្សត់ចិត្តរបស់បងស្រីទាំងពីរនាក់ ហើយដើម្បីសងសឹកជំនួសនាងនោះ គឺកាលដែលខ្ញុំបានរួចអំពីគ្រោះថ្នាក់ដោយសារជំនួយរបស់នាងហើយ ខ្ញុំទៅប្រមូលអស់ទាំងគ្នាដែលជាស្រីទេពអប្សរដូចខ្ញុំដែរ ឲ្យគេទៅជួយជញ្ជូនអីវ៉ាន់ទាំងអស់ក្នុងសំពៅនោះ យកទៅទុកដាក់ក្នុងឃ្លាំងរបស់នាងឯត្រង់បាតដាច រួចហើយយើងបានពន្លិចសំពៅនោះចោលក្នុងសមុទ្រទៅ ។ មេដៃទៅទាំងពីរនេះគឺជាបងស្រីរបស់នាងហើយ, ខ្ញុំបានសង្ស័យធ្វើឲ្យក្លាយគេទៅជាឃ្មាំងនេះឯង ។ សេចក្ដីខ្ញុំប៉ុណ្ណេះមិនទាន់ជួននៅឡើយទេ ខ្ញុំត្រូវតែឲ្យនាងធ្វើបាបថែមទៀត តាមចំនួនដែលខ្ញុំនឹងប្រាប់នាង" ។ (មានត)

# ព្រះរាជប្រវត្តិ

# ព្រះបាទសម្ដេចព្រះជ័យជេដ្ឋា ( ព្រះអង្គស្ងួន )

( តទៅ )

## ព្រះជ័យជេដ្ឋាស្ដេចបយពេញពីព្រះរាជវាំង ឧត្តុង្គឫជ័យទៅប្រថាប់នៅស្រុកកណ្ដាលប្រាំតម្លឹង

ទើបសម្ដេចព្រះជ័យជេដ្ឋាត្រាស់បង្គាប់ឲ្យញ៉ាំតេជោ ចៅហ្វាយស្រុកខែត្រក្រុមការទីង ៗ ញ៉ាំតូសេនា ( សំ ) ឲ្យកាន់សេនាទាហាន ២០០០ នៅក្នុងព្រះបរមរាជវាំង ដល់វេលាយប់ឲ្យដុតភ្លើងជុំវិញបន្ទាយ ឲ្យវាយស្គរជុំវែងឲ្យលាន់ឮរំពងឡើង ដើម្បីឲ្យតងទ័ពយួន · ទ្រយល់ថាស្ដេចឲ្យលើកទ័ពទៅលុក រួចឲ្យនាយទ័ពនាយកងនាំសេនាទាហានហែស្ដេចឆ្វេង-ស្ដាំ បង្ការក្រុងយួនលើកទ័ពមកតាម ស្ដេចឲ្យដុតព្រះរាជទ្រព្យព្រះទេពីព្រះម្ចាស់ ដោយដំរីសេះរទេះឲ្យលើកចេញទៅមុន រួចស្ដេចឡើងគង់ព្រះទីនាំងគជេន្ទ្រ ព្រមដោយសេនានិករ ទៅប្រថាប់នៅស្រុកកណ្ដាលប្រាំតម្លឹង ៗ ទើបត្រាស់ឲ្យធ្វើបន្ទាយនៅកណ្ដាលប្រាំតម្លឹង ១ អន្ទើ នៅព្រៃភ្នំ ១ អន្ទើសម្រាប់ជាទីប្រជុំពល ទ្រង់ចាត់នាយទ័ពឲ្យទៅប្រាប់មន្ត្រីដែលនៅកណ្ដាលស្រុកឲ្យបានដឹងគ្រប់ប្រការ ។

ឯទ័ពយួន លុះយប់បានឃើញភ្លើងភ្លឺស្វរស្គរវែងទ្រហឹង ស្មានថាទ័ពខ្មាំងលើកមកលុកក៏ប្រយ័ត្នរក្សាមិនប្រហែស ដល់ព្រឹកឡើង

ទើបដឹងថា ស្ដេចយាងចេញពីក្រុងឧត្ដុង្គផុតអស់ទៅហើយ ពុំហ៊ាន លើកតាមដោយខ្លាចកលឧបាយ ក៏លើកទ័ពទៅប្រជាយបន្ទំ ល្វាឯម វិញ ។

ឧកញ៉ាធម្មតេជោនិងឧកញ៉ាតេជៈសេនាដឹងថាទ័ពយួនថយចុះទៅអស់ ហើយ ក៏លើកទ័ពតាមស្ដេចទៅជួបជុំនៅបន្ទាយកណ្ដាលព្រៃតម្រីង ។

## ព្រះជ័យជេដ្ឋាទ្រង់ចាត់ចៅពញាភក្ដីសង្គ្រាម (ហុក) ឲ្យទៅទទួលព្រះកន្លោងពីក្នុងបំណែរាមទេព

លុះទ្រង់ជ្រាបថា សេនាទាហានមកជួបជុំហើយ ទើបទ្រង់ប្រឹក្សា ជឹងសេនាបតីថា អ្នកព្រះបទុមរាជាបានជាក្លៀវក្លាណាស់ ដោយបានព្រះ កន្លោងហើងទៅទុកក្នុងកណ្ដាប់ដៃ ខ្ញុំយល់ថា ត្រូវទៅអញ្ជើញសម្ដេច ព្រះកន្លោងមកពីក្នុងទ័ព ព្រះបទុមរាជាឲ្យបានស៊ិន សូមរើសស្រ្គាមគេទៅ ទៀតតែមិនដឹងជាឈ្មោះណា អង់អាចក្លាហានទទួលភាសាទៅអញ្ជើញ មកបាន ។ គ្រានោះ ឧកញ៉ាមន្ត្រីសង្គ្រាម (សួស) ក្រាបបង្គំទូលថា ទូលព្រះបង្គំជាខ្ញុំយល់ឃើញតែចៅពញាភក្ដីសង្គ្រាម ជាប្អូនទូលព្រះបង្គំ មានជ័យ មានសតិបញ្ញា ក្លៀវក្លាតបេះឧបាយកលដឹងធ្ងន់ដឹងស្រាល ។ ទ្រង់ព្រះសណ្ដាប់ទ្រង់មានព្រះអំណរណាស់ ទើបត្រាស់ឲ្យហៅចៅ ពញាភក្ដីសង្គ្រាម (ហុក) ចូលគាល់ មានព្រះរាជឱង្ការថា យើងមិន

ឃើញអ្នកឯណា ទីនទទួលអាសាទៅកញ្ចេញព្រះអង្គទ្រង់ឃើញមកបាននៅ បងអ្នកថា ឃើញតែអ្នកឯងមួយ មានសតិបញ្ញាក្លាហានល្មមទៅធ្វើការនេះបាន តើអ្នកទទួលយកអាសាឃើញបានឬទេ។

ចៅពញាកក្តីសង្គ្រាម (ហុក) ក៏ទទួលយកអាសាដោយស្ម័គ្រ ទ្រង់ត្រាស់ថា បើអ្នកទៅកញ្ចេញសម្តេចព្រះវររាជមាតាមកថ្វាយបាន ដូចបំណងកញ្ញ ទីនព្រះរាជទានស័ក្តិ ១០ ហូពាន់តាមចិត្តស្រឡាញ់ ហើយទ្រង់ប្រគល់ព្រះទម្រង់ ១ វង់ទៅថ្វាយព្រះវររាជមាតាជាបន្ទាល់ ទ្រង់ព្រះបណ្តាំគ្រប់ប្រការ ។ ចៅពញាកក្តីសង្គ្រាមក្រាបទូលថា បើទូលព្រះបង្គំទៅបាន ៦-៧ ថ្ងៃ សូមឲ្យទ្រង់ចាត់កងទ័ពទៅចាំទទួលតាមរយៈផ្លូវដែលត្រឡប់វិញ ។

## ចៅពញាកក្តីសង្គ្រាម (ហុក) ធ្វើពិធីអធិដ្ឋានរូបហែលឆ្លងទៅបន្ទាយជ្រោយចង្វា

ថ្ងៃអាទិត្យ ១១ កើតខែមិគសិរឆ្នាំជូតឆស័ក (ព.ស. ២២២៨) ចៅពញាកក្តីសង្គ្រាម (ហុក) ក្រាបថ្វាយបង្គំលាចេញមកយកខ្ញុំម្នាក់ ជាជំនិតទុកចិត្តឈ្មោះនាយគោនីនទៃ ១ ឈ្មោះតាស្រស់ជាប់តាមទៅផង ។ លុះដល់ភ្លឺចេញចូលសំណាក់នៅវត្តព្រះស្រែការលេញ នៅមាត់ព្រែកតាមផ្ទុង ដើរសុើបដំណឹងបានដឹងថា សម្តេចព្រះវររាជត្រៃយូនយកទៅឃុំទុកក្នុងទូកនៅទីជ្រោយចង្វា ។ ដល់យប់ស្ងាត់ចៅពញាកក្តី

សង្គ្រាម (ហុក) យកទៀនធូបហើយចូលបោសប្រាសសំអាតព្រះ
វិហារ ហើយអុជទៀនធូបបូជាព្រះស្រេកាលេញថ្វាយបង្គំអធិដ្ឋានថា ខ្ញុំ
ព្រះអង្គនេះ មានកតញ្ញូនឹងព្រះបាទកូតជាអម្ចាស់ ស៊ូលះបង់ជីវិតមិនគិត
ស្លាប់ ទទួលរកសាមកអញ្ជើញសម្តេចព្រះពាក្យត្រៃ ជាព្រះវរពជ-
ឆាតាអំពីកណ្តាប់ដៃនៃពកសត្រូវ បើសម្តេចព្រះជ័យជេដ្ឋាជាអម្ចាស់ខ្ញុំ
ស្តេចមានបុណ្យ ស្តេចនឹងបានឡើងសោយរាជ្យក្នុងក្រុងកម្ពុជាធិបតីនេះ
សូមកុំឲ្យទ័ពយួនមើលឃើញស្គាល់ខ្ញុំឡើយ ដោយសេចក្តីកតញ្ញូរបស់
ខ្ញុំសូមកុំបីមានអន្តរាយអ្វីឡើយ សូមទេវតាជួយទំនុកបំរុងឲ្យខ្ញុំទៅអញ្ជើញ
សម្តេចព្រះវរពជមាតាបានដោយងាយ រួចទៅពញាកក្តីសង្គ្រាម (ហុក)
តាំងសែតមន្តផ្លុំសណ្តំបង្ហើរទៅតាមខ្យល់ ឲ្យពួកយួនដេកលក់កុំឲ្យដឹង
ខ្លួន ហើយនាំនាយគោចុះពីព្រះវិហារដើរតែបួសបាន ១ កំណាត់ម្នាក់
ជាក់ក្តែកស្រែតំថា ឲ្យចាំអញនៅមុខព្រះវិហារនេះចុះកាងនិលកុំឈប់
នៃនោះសំទៀនធំចាំមាក់បាន ។ ផលយប់ស្ងាត់ ទៅពញាកក្តីសង្គ្រាម
(ហុក) បកសំពត់ស្បៀកក្រវាត់ខ្ទង់ចេញទៅតែខោស្លាប់ក្តៅ សៀត
កាំបិតស្បៀត នាយគោក៏ធ្វើដូចគ្នា រួចនាំគ្នាចុះទឹកហែលឆ្លងព្រែកទៅ
ព្រៃជាយចង្វា វេលានោះចួនជាមានភ្លៀងមានខ្យល់ផង ពួកពលក្នុងចំព
វៃវៈយួនចូលព្រួតដេកអស់ ទៅពញាកក្តីសង្គ្រាមនឹងនាយគោក៏ឆ្លងទៅ
ដល់ព្រៃជាយចង្វា តាំងយកមេយទ្ធាយស្រែះបន្តអាគមសណ្តំផ្លុំបង្ហើរទៀត

រួចដើររកតាមគន់មើលសម្តេចព្រះតាវក្សត្រី ស្រាប់តែក្រឡេកទៅឃើញគុកមួយ នៅកណ្តាលមានស្ពានជាប់មកដល់ច្រាំង មានគុកឡោមជុំវិញជាច្រើន ហើយដើរគន់មើលក្នុងគុកឃើញស្តេចផ្ទំលក់ ស្គាល់ជាក់ជាសម្តេចព្រះតាវក្សត្រី ក៏នាំនាយគោឡើងលើគុកថ្វាយបង្គំ ទើបក្សង់ទឹកទន្លេប្រោះព្រះលើព្រះអង្គ ទ្រង់ប្រែព្រះអង្គឡើងគង់ទតមកឃើញចៅពញាកក្តីសង្គ្រាមៗ ថ្វាយបង្គំថ្វាយព្រះខ្មែងក្រាបទូលតិចៗ ស្តេចមានព្រះបន្ទូលថា បានអ្នកឯងមកអញអរណាស់ ដូចបានឃើញមុខកូន បើយកតែអញតែម្នាក់ឯងអញមិនទៅទេ ត្រូវយកមីអំទៅផង ទើបអញព្រមទៅ ព្រោះវាកំសត់ណាស់ៗ ចៅពញាកក្តីសង្គ្រាមក្រាបទូលថា សូមកុំព្រួយព្រះរាជហឫទ័យ ទើបសម្តេចព្រះតាវក្សត្រីទ្រង់ដាស់នាងអំឡើងឲ្យរៀបខ្លួនទាំងប្រមូលព្រះរាជទ្រព្យៗ ចៅពញាកក្តីសង្គ្រាមអញ្ជើញសម្តេចឲ្យគង់លើស្មាខ្លួន នាងអំសាទៀតជិះលើស្មានាយគោ ហើយនាំគ្នាហែលទំលុះទឹកម្រែងតាមសម្ងំតែល្អ រួចរបូតពីចំណោមទ័ពយួនខ្មៅ ទៅឡើងនៅកំពង់វត្តព្រះស្រការ លេញជិតមាត់ព្រែកពាមជុំវិញ ឲ្យស្តេចគង់ឲ្យស្រួលហើយ ទើបចៅពញាកក្តីសង្គ្រាមនឹងនាយគោ ផ្លាស់សំពត់ជាប្រញាប់ អញ្ជើញសម្តេចឲ្យគង់លើស្មាខ្លួនដើរកាត់ព្រៃតាំងយប់ នាយគោដើរមុខនាងអំដើរក្រោយផ្លូវហួសផ្លូវផ្លែប៉ត នាយគោសួរថាផ្លូវនេះទៅខាងណា ចៅពញាកក្តី

ឲ្យបែកទៅខាងស្ពានដៃ ក៏នាំគ្នាដើរទៅតាំងយប់រងឹតរំលងផ្លូវ ដល់ភ្លឺព្រាង ៗ ដល់ស្ទឹងព្រែកត្នោតទើបដឹងថាដើរខុសផ្លូវ ។ ចៅពញាភក្ដីសង្គ្រាមនឹងនាយកោះ កាប់មែកឈើធ្វើជាអង្រឹងស្នងបង់ចងសំពត់នាំគ្នាសែងសម្ដេចដើរទៅ ៗ រហូតដល់ថ្ងៃរសៀល ទ្រង់អត់ព្រះក្រយាហារ ទ្រង់ព្រះកន្ទ្រង់ ដល់ទួលផ្ទើង ទ្រង់ប្រើនាយកោះឲ្យឡើងបេះផ្លែផ្ទើងឲ្យទ្រង់សោយ ឯចៅពញាភក្ដីសង្គ្រាមក៏ដើររកសុំអាហារអ្នកស្រុកមកថ្វាយ សោយហើយស្រេចទើបយាងស្ដេចពីទួលផ្ទើង តម្រង់ទៅអង្គព្រះពាយ ឈប់ផ្ទុំនៅទីនោះ ។

រីឯណាកងទ័ពយួន-ខ្មែរនៅព្រៃយេបង្កា ដល់ព្រឹកឡើងទើបដឹងថាបាត់សម្ដេចព្រះចៅក្សត្រ ហើយនាំគ្នាទៅទូលសម្ដេចព្រះបទុមរាជា ៗ ទ្រង់ចាត់អ្នកទ្រៀងគុន ឲ្យនាំសេនាទាហានយួន-ខ្មែរលើកទៅតាមតែពុំទាន់ សេនាទាហានខ្លះត្រឡប់ទៅទូលវិញ ។

## ព្រះជ័យជេដ្ឋាទ្រង់ចាត់ទ័ព ឲ្យទៅចាំទទួលចៅពញាភក្ដីសង្គ្រាម (ហុក)

ឯសម្ដេចព្រះជ័យជេដ្ឋាទ្រង់ចាត់ឲ្យលើកទ័ព ទៅចាំទទួលចៅពញា-ភក្ដីសង្គ្រាម កងទ័ពដែលលើកទៅទទួលនោះ កាលដឹងថាយួនលើកទ័ពតាមមកក៏ថយចូលសំងំពួនក្នុងព្រៃចាំស្ដាប់ដំណឹង លុះដឹងថាចៅពញា-

កក្តិសង្គ្រាម អញ្ជើញសម្តេចព្រះទាវក្សត្រមកដុតហើយ ក៏មិនពុំទ ចេញចម្បាំងនឹងទ័ពយួន ចាំជួបនឹងចៅពញាកក្តិសង្គ្រាមសិន ។

ចៅពញាកក្តិសង្គ្រាមលុះដឹងថា ទ័ពយួន-ខ្មែរលើកទ័ពមកជិតណាស់ ក៏នាំសម្តេចព្រះទាវក្សត្រទៅបំពួនក្នុងព្រៃខាងលិចអន្លុងព្រះ-ពាយ ។ ឯទ័ពយួន-ខ្មែរតាមទៅពុំទាន់ហើយ ក៏ត្រឡប់ទៅបោះទ័ពនៅក្នុងពេញវិញ ។ ឯចៅពញាកក្តិសង្គ្រាមដឹងថាយួនលើកទ័ពត្រឡប់ទៅវិញហើយ ក៏អញ្ជើញសម្តេចព្រះទាវក្សត្រចេញពីព្រៃផលពួននោះតទៅទៀត លុះដល់ទំនប់ព្រះឥន្ទ្រទេព ទើបស្តេចឲ្យឈប់នៅទីនោះ ។ ចៅពញាកក្តិសង្គ្រាមក៏ប្រើនាយគោឲ្យទៅជំរាបចៅពញាកក្តិសង្គ្រាម (សួស) ជាបង ឲ្យនាំសេចក្តីក្រាបបង្គំទូលឲ្យទ្រង់ជ្រាប វេលានោះ ស្តេចព្រះរាជដំណើរមកប្រថាប់នៅព្រៃត្រពាំងគង់ក្នុងខែត្រសំរោងទងស្តាំ ។ កាលទ្រង់ជ្រាបរឿងសព្វគ្រប់ហើយ ទ្រង់មានព្រះអំណរពន់ប្រមាណ ទ្រង់ព្រះរាជបញ្ជាឲ្យបងព្រះទីនាំងគជេន្ទ្រ ស្រេចស្តេចយាងគង់ ពួកមន្ត្រីខ្ញុំរាជការសេនាទាហានហែហមជាយសប៉ែវ ស្តេចព្រះរាជដំណើរចេញពីព្រៃត្រពាំងគងក៏មកដល់ទំពលលំហាច បានជួបនឹងសម្តេចព្រះទាវក្សត្រជាព្រះវររាជមាតានឹងចៅពញាកក្តិសង្គ្រាម (ហុក) ទ្រង់មានព្រះអំណរណាស់ ស្តេចចុះពីព្រះទីនាំងទ្រង់ឱបព្រះបាទព្រះវររាជមាតាទ្រង់ព្រះកន្សែង សម្តេចព្រះវររាជមាតា

ក៏ទ្រង់ព្រះកន្សែង ពណ៌នាពីស្តេចនៅក្នុងកណ្តាប់ដៃរាជសត្រូវសព្វគ្រប់ ៗ សម្តេចព្រះរាជបុត្រទូលថា ទូលព្រះបង្គំជាខ្ញុំពុំហ៊ានលើកកងទ័ពទៅវាយបន្ទាយភ្នំពេញ-ជ្រោយបង្វា ដោយខ្លាចក្រែងគេធ្វើទុក្ខព្រះវររាជមាតា ឥឡូវនេះ ទូលបង្គំជាខ្ញុំនឹងឲ្យសេនាទាហានលើកទ័ពទៅវាយបន្ទាយភ្នំពេញ-ជ្រោយបង្វា របស់ព្រះបទុមរាជាឲ្យបែកបាក់ទៅទាល់តែបាន ហើយអញ្ជើញសម្តេចព្រះវររាជមាតាឲ្យឡើងគង់ព្រះទីនាំងគជេន្ទ្រស្តេចព្រះរាជដំណើរទៅបន្ទាយកណ្តាលក្រាំងតម្ងឹង ៗ

ស្តេចទ្រង់ប្រឹក្សានឹងនាយទ័ពនាយពលទាំងពួងថា ព្រះបទុមរាជាប្រហែលឲ្យលើកទ័ពតាមមកទៀតពុំខាន ត្រូវយើងលើកសេនាទាហានទៅទទួលច្បាំង បើមានទ័ពលើកមកឲ្យមានសំបុត្រផកក្រាបទូលជាប្រញាប់ នាហ្មឺនសព្វមុខមន្ត្រីក៏យល់ព្រម ទើបទ្រង់តាំង ១ ពញាចក្រីដេជះរាជ (សោម) ឲ្យនាំសេនាទាហានទៅបោះទ័ពនៅបុងប៉ឹងក្បែរខាងលិច ៗ

## ព្រះរាជសង្គ្រាមគ្រាទី ៣

## ទ័ពព្រះជ័យជេដ្ឋាវាយបានបន្ទាយភ្នំពេញ - ជ្រោយបង្វា

ឯសម្តេចព្រះបទុមរាជា កាលទ្រង់ជ្រាបថា ទ័ពខ្មែរ-យួនលើកទៅតាមសម្តេចព្រះវរក្សត្រីពុំទាន់ ក៏ទ្រង់ខ្ញាល់ណាស់ ទើបទ្រង់តាំង ១ ពញាស្រីអគ្គរាជ (សួស) ១ ពញាធម្មតេជោស្រី ឲ្យនាំសេនា

ទាហាន ១០,០០០ ជូនទ័ពនៅលើកតាមសម្ដេចព្រះតាក្សិន ២ ផ្លូវ ១ ផ្លូវ ត្រូវស៊ីនឹងទ័ពថៃ ១ ផ្លូវកម្រង់ទៅក្រុងកុក្កពុជ័យ ។

ចំណែកឧកញ៉ាធម្ម័យធិរាជ (សោម) ក៏តាំងព្រោះប្រឹក្សាព្រមព្រៀងគ្នាថា ត្រូវតាំងបះបោរឲ្យទៅក្រាបទូលឲ្យទ្រង់ជ្រាបជាប្រញាប់តាមព្រះរាជបណ្ដាំ ហើយអកម៉ឺនបៃបុនរីក្សពាក់សេនាទាហាន ៤ នាក់ ឲ្យនាំចុតហ្មាយទៅថ្វាយឲ្យទ្រង់ជ្រាប តាមរឿងដែលសម្ដេចព្រះបទុមរាជាលើកទ័ពមកពីផ្លូវគប់ប្រការ ។

ហើយសម្ដេចព្រះជ័យជេដ្ឋា ត្រាស់បង្គាប់ឲ្យចៅពញាកក្ដិសង្គ្រាម (ហុក) នាំសេនាទាហាន ១០,០០០ លើកកម្រង់ទៅក្រុងកុក្កពុជ័យ ទ្រង់បាក់ឲ្យហ្លួងគាំនាំសេនាទាហាន ៨០០០ លើកទៅជួបឧកញ៉ាធម្ម័យធិរាជនៅខែត្រភ្នំពេញ ទ័ពទាំងពីរកងក៏លើកបញ្ចៀវទៅ ទ័ពស្របបានជួបប្រទះគ្នានៅកាលបោ៉ង កងខ្មែរសំរេចនឹងច្រើនបានចាប់ច្បាំងគ្នានៅទីនោះ ។ ចៅពញាកក្ដិសង្គ្រាមបញ្ជាកងទ័ពកុំឲ្យជ្រួលជ្រើម រួបចាត់ទ័ពជាបីកង កងកណ្ដាលឲ្យលើកទៅជួបប្រឈមនឹងទ័ពមុខ ប៉ែកស្ដាំឆ្វេងឲ្យវាយផ្ទប់ទាំងសងខាង ទ័ពទាំង ៣ កងលើកសន្ធឹងគេបាញ់កាំភ្លើងឆ្មាប្ដូលទៅ ទ័ពខ្មែរ-យួនស្លាប់ជាច្រើន ព្រោះពុំបានបកជ័យរត់ទៅវិញ ។ ចំណែកហ្លួងគាំនាំសេនាទាហានទៅដល់ប្រយុទ្ធនឹងទ័ពឧកញ៉ាធម្ម័យធិរាជ ក៏ច្បាំងនឹងទ័ពយួន-ខ្មែរនៅភូមិបែកបាន ឯទ័ពដែល

បកជ័យកើតខ្លាំងក្លាយទ្រង់ទៅបន្ទាយជ្រោយចង្វា ខ្លះទ្រង់ពុំទាន់នោះទៅ.
ពញាកក្តីសង្គ្រាមទីឯកញ៉ាឧទ័យធិកជរួមរួមទ័ពជាមួយគ្នាលើកតាមទៅ
ទាន់តាប់សម្លាប់ពលខ្មែរ-យួនស្លាប់ទីឯតាប់ខ្ទួកបានជាច្រើន រួបរួម
ទាហានទៅកាយបន្ទាយជ្រោយចង្វាទៀត សេនាទាហានខ្មែរ-យួនពុំ
ហ៊ានចេញច្បាំង ទើបអញ្ជើញសម្តេចព្រះបទុមកជា ចុះគង់ព្រះទីនាំង
នាវាបោលបន្ទាយជ្រោយចង្វាទ្រង់ទៅត្រើយល្វាឯម ស្តេចទៅបោះទ័ព
នៅខែត្រស្រីសឈរ ។ ឯចៅពញាកក្តីសង្គ្រាមទីឯកញ៉ាឧទ័យធិកជ
កាលវាយបានបន្ទាយកំពេញនឹងជ្រោយចង្វាហើយ ក៏ចាត់ឲ្យប្រមូល
សេនាទាហាននឹងគ្រឿងសស្ត្រាវុធ កៀរគ្រួមកដាក់ត្រើយកំពេញវិញ
ហើយចាត់អកហ្មឺនហោមវៃចុងក្សៀទនឹងសេនាទាហាន ៦ នាក់ឲ្យនាំសេចក្តី
ក្រាបបង្គំទូលឲ្យទ្រង់ជ្រាបគ្រប់ប្រការ ទ្រង់មានព្រះអំណរណាស់ ស្តេច
ទ្រង់សរសើរចៅពញាកក្តីសង្គ្រាមទីឯកញ៉ាឧទ័យធិកជផ្សេងៗ ហើយ
ទ្រង់ព្រះតម្រាស់ថា ចៅពញាកក្តីសង្គ្រាម (ហុក) ល្មមតាំងឲ្យធ្វើ
ជាសេនាបតីបាន ។

ទើបទ្រង់ត្រាស់ឲ្យអកហ្មឺនហោមវៃចុងក្សៀនាំរបស់មានដំឡៃផ្សេងៗ
ទៅព្រះរាជទានៈមេទ័ពទាំងពីរ ទីឯនាយទ័ពនាយកងទាំងពួងតាមនឿយ
ហត់នឹកជការទ្រង់ព្រះបណ្តាំថាឲ្យបោះទ័ពនៅកំពេញកំចាកជស្រែឲ្យ
មាំមួនកុំបីធ្វេសប្រហែស ។ (មានត)

# អញ្ញាទិដ្ឋិកថា

## ឃុនសុវត្តិវិទី យូរ-អ៊ុន រៀបរៀង

(តមកនិងចប់)

៤០— បញ្ញត្តថា ខ្លួនមានទីបំផុតក៏មិនមែន មិនមានទីបំផុតក៏មិនមែន ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ។

ឃ) ពួកសមណព្រាហ្មណ៍ ជា ៧ ពួក (អ្នកកោលថាដាច់សូន្យ) បញ្ញត្តនូវការដាច់សូន្យ នូវសេចក្តីវិនាស នូវសេចក្តីមិនកើតទៀតនៃសត្វដែលមាននៅ ដោយហេតុ ៧ យ៉ាងគឺ:

៤១— បញ្ញត្តថា ខ្លួនមានរូបប្រកបដោយមហាភូតរូប ៤ កើតមកអំពីមាតាបិតា ស្លាប់ហើយរមែងដាច់សូន្យ មិនកើតទៀត ។

៤២— បញ្ញត្តថា ខ្លួនមានរូបជាទិព្វ ជាកាមាវចរទេវតា (ត្រាច់ទៅក្នុងកាមភព) មានកវឡិង្ការាហារជាចំណី ស្លាប់ហើយរមែងដាច់សូន្យ មិនកើតទៀត ។

៤៣— បញ្ញត្តថា ខ្លួនមានរូបជាទិព្វ កើតដោយឈានចិត្ត មានអវយវៈធំតូចគ្រប់សព្វ មានឥន្ទ្រិយមិនថោកថយ ស្លាប់ហើយរមែងដាច់សូន្យ មិនកើតទៀត ។

៩៤— បញ្ញត្តថា ពួកសត្វដែលចូលទៅកាន់អាកាសានញ្ចាយតនគត ស្លាប់ហើយរមែងដាច់សូន្យ មិនកើតទៀត ។

៩៥— បញ្ញត្តថា ពួកសត្វដែលចូលទៅកាន់វិញ្ញាណញ្ចាយតនគត ស្លាប់ហើយរមែងដាច់សូន្យ មិនកើតទៀត ។

៩៦— បញ្ញត្តថា ពួកសត្វដែលចូលទៅកាន់អាកិញ្ចញ្ញាយតនគត ស្លាប់ហើយរមែងដាច់សូន្យ មិនកើតទៀត ។

៩៧— បញ្ញត្តថា ពួកសត្វដែលចូលទៅកាន់នេវសញ្ញានាសញ្ញាយតនគត ស្លាប់ហើយរមែងដាច់សូន្យមិនកើតទៀត ។

ង) ពួកសមណព្រាហ្មណ៍ ដែលទិដ្ឋធម្មនិព្វានវាទ (ពួកពោលនូវនិព្វានគឺសេចក្តីរលត់ទុក្ខក្នុងបច្ចុប្បន្ន) បញ្ញត្តព្រះនិព្វានក្នុងបច្ចុប្បន្នថា ជាគុណយ៉ាងក្រៃលែងរបស់សត្វដែលមាននៅ ដោយហេតុ ៥ យ៉ាង គឺ:

៩៨— បញ្ញត្តថា ខ្លួនដែលឲ្យគេបំរើផ្គត់ផ្គង់ដោយកាមគុណ ៥ ទើបឈ្មោះថាជាអត្តភាពបានដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្ន ។

៩៩— បញ្ញត្តថា ខ្លួនដែលបានស្ងប់ស្ងាត់ចាកកាម ស្ងប់ស្ងាត់ចាកអកុសលធម៌ ហើយបានដល់បឋមជ្ឈានប្រកបដោយវិតក្កៈ វិចារៈ នាំបីតិនិងសុខៈកើតអំពីសេចក្តីស្ងប់ស្ងាត់ ទើបឈ្មោះថាជាអត្តភាពបានដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្ន ។

២០– បញ្ញត្តថា ខ្លួនដែលបានរម្ងាប់វិតក្កៈ វិចារៈ អស់ហើយ បានដល់នូវទុតិយជ្ឈាន ជាធម្មជាតតម្កល់ប្រាកដក្នុងខ្លួន មានសេចក្តីជ្រះថ្លាគឺសទ្ធា ជាសភាពនៃចិត្តដ៏ខ្ពស់ឯក ជាឈានមិនមានវិតក្កៈ វិចារៈ មានតែបីតិនិងសុខៈកើតអំពីសមាធិ ទើបឈ្មោះថាជាអត្តភាពបានដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្ន ។

២១– បញ្ញត្តថា ខ្លួនដែលប្រកបដោយឧបេក្ខាផង មានស្មារតីដឹងខ្លួនផង បានសោយសុខដោយនាមកាយផង ព្រោះអស់ទៅនៃបីតិក៏បានដល់នូវតតិយជ្ឈាន ជាឈានដែលប្រកបដោយឧបេក្ខានិងសុខៈ ទើបឈ្មោះថាជាអត្តភាពបានដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្ន ។

២២– បញ្ញត្តថា ខ្លួនដែលបានលះបង់សុខៈផង លះបង់ទុក្ខផង មានសោមនស្សនិងទោមនស្សអស់ហើយក្នុងកាលមុន ហើយបានដល់នូវចតុត្ថជ្ឈាន ដែលជាឈានមានអារម្មណ៍មិនមែនទុក្ខ មិនមែនសុខ គឺជាឧបេក្ខា មានសតិដ៏បរិសុទ្ធកើតអំពីឧបេក្ខាវេទនា ទើបឈ្មោះថាជាអត្តភាពបានដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្ន ។

ម្នាលភិក្ខុទាំងឡាយ ពួកសមណព្រាហ្មណ៍ជាអ្នកប្រកបដោយបុព្វន្តកប្បិកទិដ្ឋិ អបរន្តកប្បិកទិដ្ឋិ បុព្វន្តាបរន្តកប្បិកទិដ្ឋិ ជាអ្នកមានសេចក្តីយល់ឃើញនូវខន្ធជាចំណែកខាងដើម គឺខន្ធក្នុងអតីតកាល និងខន្ធជាចំណែកខាងមុខ គឺខន្ធក្នុងអនាគតកាល ព្រោះខន្ធជាចំណែក

ខាងដើម និងខន្ធជាបំណែកខាងមុខ តែងតែសំរេចដោយហេតុទាំង ៦២ ប្រការនេះឬក៏បណ្ដាហេតុទាំង ៦២ ប្រការនោះ ដោយហេតុណាមួយ មិនមានហេតុដទៃក្រៅពីនេះឡើយ ។ ពួកសមណព្រាហ្មណ៍ទាំងនោះសុទ្ធតែជាអ្នកមិនដឹង មិនឃើញ តាមសភាវៈធម៌ដែលពិតទេ តែងសោយនូវអារម្មណ៍ក្នុងទិដ្ឋិនោះ ។ តណ្ហា, ឧបាទាន, ភព, ជាតិ, ជរា, មរណ, សេចក្ដីសោកស្រណោះ, សេចក្ដីខ្សឹកខ្សួល សេចក្ដីមិនស្រួលកាយ, សេចក្ដីតូចចិត្ត, សេចក្ដីចង្អៀតចិត្ត, របស់ពួកសមណព្រាហ្មណ៍នោះឯង តែងកើតមានឡើង ។ ពួកសមណព្រាហ្មណ៍ទាំងនោះដែលប្រកាន់ទិដ្ឋិ ៦២ នេះឯងគ្រប់សព្វហើយ រមែងត្រូវឲ្យជួបប៉ះនៅក្នុងសំណាញ់ អាស្រ័យនៅក្នុងសំណាញ់ កាលងើបឡើងក៏ងើបឡើងក្នុងសំណាញ់ ជាប់នៅក្នុងសំណាញ់ ប្រៀបដូចជាអ្នកនេសាទមច្ឆាជាតិក្ដី អ្នកជំនួយរបស់អ្នកនេសាទមច្ឆាជាតិក្ដី ដែលមិនប្រសប់បង់សំណាញ់ក្នុងអន្លង់ទឹកតូច ដោយគិតថាអញធ្វើសត្វតូចសត្វធំក្នុងអន្លង់ទឹកនេះ ឲ្យនៅក្នុងសំណាញ់ អាស្រ័យនៅក្នុងសំណាញ់ កាលងើបឡើងក៏ងើបឡើងក្នុងសំណាញ់ដូច្នោះឯង ។

ម្នាលភិក្ខុទាំងឡាយ តថាគតដឹងច្បាស់នូវហេតុនៃទិដ្ឋិនោះយ៉ាងនេះថា ហេតុនៃទិដ្ឋិទាំងឡាយនេះ ដែលបុគ្គលកាន់យកយ៉ាងនេះ ប្រកាន់ខុសយ៉ាងនេះ មានគតិយ៉ាងនេះ មានការប្រព្រឹត្តទៅក្នុងខាងមុខ

យ៉ាងនេះ ៗ តថាគតដឹងច្បាស់នូវហេតុនៃទិដ្ឋិនោះផង ដឹងច្បាស់នូវសីល សមាធិ និងសព្វញ្ញុតញ្ញាណ ដែលជាគុណជាតលើសលុបក្រៃលែងជាងនោះទៅទៀតផង, កាលបើដឹងច្បាស់នូវគុណវិសេសនោះហើយ ក៏មិនបានប្រកាន់ខុសឡើយ មួយទៀត កាលបើតថាគត មិនបានប្រកាន់ខុសហើយ ក៏ដឹងនូវព្រះនិព្វានជាគ្រឿងរលត់ទៅ នៃបកខាសពិសេសដោយខ្លួនឯង តាំងដឹងច្បាស់នូវហេតុដែលនាំឲ្យកើតឡើងនៃវេទនាផង នូវសេចក្ដីអស់ទៅនៃវេទនាផង នូវគុណនៃវេទនាផង នូវទោសនៃវេទនាផង នូវកិរិយារលាស់ចោលនូវវេទនាផង ដោយគួរតាមពិត ៗ ម្នាលភិក្ខុទាំងឡាយ តថាគតផុតស្រឡះហើយចាកកិលេស ព្រោះមិនបានប្រកាន់នូវធម៌ណាមួយមានខន្ធជាដើម ៗ ម្នាលភិក្ខុទាំងឡាយ តថាគតធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្ដមដោយខ្លួនឯង ហើយអាចសំដែងនូវធម៌ទាំងឡាយឯណា, ពួកជនកាលពោលសរសើរគុណរបស់តថាគតតាមសេចក្ដីពិតដោយធម៌ទាំងឡាយឯណា, ធម៌ទាំងឡាយនេះឯងហើយដែលជាធម៌ដ៏ជ្រាលជ្រៅ ដែលបុគ្គលកម្រឃើញបាន ត្រាស់ដឹងបានដោយកម្រ ជាធម៌ស្ងប់រម្ងាប់ ជាធម៌ដ៏ថ្លៃថ្លា មិនជាទីស្ទង់ប្រមើលដោយសេចក្ដីត្រិះរិះបាន ជាធម៌ដ៏ល្អិត មានតែអ្នកប្រាជ្ញទើបដឹងបាន ៗ

ចប់ ទិដ្ឋិ ៦២ ប្រការ ។

## អន្តគ្គាហិកទិដ្ឋិ

មិច្ឆាទិដ្ឋិប្រកាន់យកហេតុជាទីបំផុត ហៅថា អន្តគ្គាហិកទិដ្ឋិ[១] មានវត្ថុ ១០ យ៉ាងគឺ:

១- សស្សតោ លោកោ [ប្រកាន់ថាលោកទៀងទ]

២- អសស្សតោ លោកោ [ប្រកាន់ថាលោកមិនទៀងទ]

៣- អន្តវា លោកោ [ប្រកាន់ថាលោកមានទីបំផុត]

៤- អនន្តវា លោកោ [ប្រកាន់ថាលោកមិនមានទីបំផុត]

៥- តំ ជីវំ តំ សរីរំ [ប្រកាន់ថាជីវៈនោះក៏គឺសរីរៈនោះ]

៦- អញ្ញំ ជីវំ អញ្ញំ សរីរំ [ប្រកាន់ថាជីវៈដទៃសរីរៈក៏ដទៃ]

៧- ហោតិ តថាគតោ បរម្មរណា [ប្រកាន់ថាសត្វកើតទៀត] ខាងមុខអំពីសេចក្ដីស្លាប់

៨- ន ហោតិ តថាគតោ បរម្មរណា [ប្រកាន់ថាសត្វមិនកើតទៀត] ខាងមុខអំពីសេចក្ដីស្លាប់

៩- ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណា [ប្រកាន់ថាសត្វកើតទៀតក៏មាន មិនកើតទៀតក៏មាន] ខាងមុខអំពីសេចក្ដីស្លាប់

---

១ ទិដ្ឋិនេះ ឃាត់តែមគ្គ ឧឃាត់សួគ៌ទេ ព្រោះការយល់ខុសបែបនេះ មិនទាន់ធ្លាក់ក្នុងកត្តអំពើកម្ម ។

៦០- នេវ ហោតិ ច ន ហោតិ តថាគតោ បរម្មរណា [ប្រកាន់ថាសត្វកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ខាងមុខអំពីសេចក្ដីស្លាប់ ៗ

## សក្កាយទិដ្ឋិ

សេចក្ដីយល់ឃើញដែលជាហេតុឲ្យប្រកាន់ខ្លួន ហៅថា សក្កាយទិដ្ឋិ[1] មានតែ ២០ យ៉ាងគឺ

### ពួករូបក្ខន្ធ

១- រូបំ អត្តតោ សមនុបស្សតិ ពិចារណាឃើញរូបថាជាខ្លួន

២- រូបវន្តំ អត្តានំ សមនុបស្សតិ ពិចារណាឃើញខ្លួនថាមានរូប

៣- អត្តនិ រូបំ សមនុបស្សតិ ពិចារណាឃើញរូបក្នុងខ្លួន

៤- រូបស្មឹ អត្តានំ សមនុបស្សតិ ពិចារណាឃើញខ្លួនក្នុងរូប

### ពួកវេទនាខន្ធ

៥- វេទនំ អត្តតោ សមនុបស្សតិ ពិចារណាឃើញវេទនាថាជាខ្លួន

៦- វេទនាវន្តំ អត្តានំ សមនុបស្សតិ ពិចារណាឃើញខ្លួនថាមានវេទនា

---

១ ទិដ្ឋិនេះឃាត់តែមគ្គមិនឃាត់សួគ៌ ដូចញ្ញានិងអត្តក្ខាហិកទិដ្ឋិដែរ ។

៧- អត្តនិ វេទនំ សមនុបស្សតិ ពិចារណាឃើញវេទនាក្នុងខ្លួន

៨- វេទនាយ អត្តានំ សមនុបស្សតិ ពិចារណាឃើញខ្លួនក្នុងវេទនា

## ពួកសញ្ញាខន្ធ

៩- សញ្ញំ អត្តតោ សមនុបស្សតិ ពិចារណាឃើញសញ្ញាថាជាខ្លួន

១០- សញ្ញាវន្តំ អត្តានំ សមនុបស្សតិ ពិចារណាឃើញខ្លួនថាមានសញ្ញា

១១- អត្តនិ សញ្ញំ សមនុបស្សតិ ពិចារណាឃើញសញ្ញាក្នុងខ្លួន

១២- សញ្ញាយ អត្តានំ សមនុបស្សតិ ពិចារណាឃើញខ្លួនក្នុងសញ្ញា

## ពួកសង្ខារក្ខន្ធ

១៣- សង្ខារេ អត្តតោ សមនុបស្សតិ ពិចារណាឃើញសង្ខារទាំងឡាយថាជាខ្លួន

១៤- សង្ខារវន្តំ អត្តានំ សមនុបស្សតិ ពិចារណាឃើញខ្លួនថាមានសង្ខារ

១៥- អត្តនិ សង្ខារេ សមនុបស្សតិ ពិចារណាឃើញសង្ខារទាំងឡាយក្នុងខ្លួន

១៦- សង្ខារេសុ អត្តានំ សមនុបស្សតិ ពិចារណាឃើញខ្លួនក្នុងសង្ខារទាំងឡាយ

## ពួកវិញ្ញាណក្ខន្ធ

១៧- វិញ្ញាណំ អត្តតោ សមនុបស្សតិ ពិចារណាឃើញវិញ្ញាណជាខ្លួន

១៨- វិញ្ញាណវន្តំ អត្តានំ សមនុបស្សតិ ពិចារណាឃើញខ្លួនថាមានវិញ្ញាណ

១៩- អត្តនិ វិញ្ញាណំ សមនុបស្សតិ ពិចារណាឃើញវិញ្ញាណក្នុងខ្លួន

២០- វិញ្ញាណស្មឹ អត្តានំ សមនុបស្សតិ ពិចារណាឃើញខ្លួនក្នុងវិញ្ញាណ ។

## ទោសមិច្ឆាទិដ្ឋិ

មិច្ឆាទិដ្ឋិមានទោសយ៉ាងណាខ្លះ ចូរអធិប្បាយមកមើល ?

វត្ថុទាំងឡាយដែលមានទម្ងន់ ដូចយ៉ាងថ្មក្រួស ដុំដីជាដើម ស្ទើរមានទំហំប្រមាណប៉ុនគ្រាប់សណ្តែកបាយ ឬ សណ្តែកពកផ្ទាស

ដែលបុគ្គលចាប់បោះចោលទៅក្នុងទឹក, ថ្ម ឬ ក្រួសជាដើមនោះមិនអាចនឹងអណ្តែតឡើងឡើយ មានតែធ្លាក់លិចចុះទៅក្នុងទឹកសស្រឹម ត្រាតែដល់ផែនដីទើបឈប់, មួយទៀត លាមកវត្ថុដែលមានក្លិនស្អុយ ក៏ជាច្រើនសូម្បីយ៉ាងតិចបំផុត ក៏គង់មានក្លិនអសោចិ៍ដែលគួរឲ្យខ្ពើមរអើមមិនខាន សេចក្តីនេះមានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចមិច្ឆាទិដ្ឋិទាំងឡាយដែលបានពោលមកខាងដើមនោះសុទ្ធតែជាធម៌នាំបណ្តាលឲ្យមានទោសដល់ពួកសត្វនិងនាំសត្វឲ្យទៅកើតក្នុងអបាយទាំង ៤ មាននរកជាដើមដូច្នោះឯង ។ ហេតុនោះ ជនជាបណ្ឌិតគប្បីប្រៀបធៀបថា មិច្ឆាទិដ្ឋិនេះមិនបាននាំសត្វឲ្យទៅកើតក្នុងអបាយដូច្នេះឡើយ, សមដូចពុទ្ធត្រាស់ក្នុងគម្ពីរឯកនិបាតអង្គុត្តរថា: នាហំ ភិក្ខវេ អញ្ញំ ឯកធម្មំបិ សមនុបស្សាមិ, យេនេវំ សត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ, យថយិទំ ភិក្ខវេ មិច្ឆាទិដ្ឋិ; មិច្ឆាទិដ្ឋិយា ភិក្ខវេ សមន្នាគតា សត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ (សេចក្តីថា) ម្នាលភិក្ខុទាំងឡាយ, តថាគតពិនិត្យមើលៈមិនឃើញមានធម៌ដទៃសូម្បីតែធម៌មួយដែល ជាធម៌នាំពួកសត្វដែលបែកធ្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ឲ្យទៅកើតក្នុងអបាយ, ទុគ្គតិ, វិនិបាត, នរក ក្រៅអំពីមិច្ឆាទិដ្ឋិនេះឡើយ; ម្នាលភិក្ខុទាំងឡាយ, ពួកសត្វដែលប្រកបដោយមិច្ឆាទិដ្ឋិហើយ, លុះដល់បែក

ឬះ យកទីកាយទាំងមូលអំពីសេចក្ដីស្លាប់ទៅ ទៀតក៏ទៅកើតក្នុងអបាយ, ទុគ្គតិ, វិនិបាត, នរក (ជាប្រាកដ) ។

ហេតុនោះ សាធុជនដែលមានប្រាជ្ញាល្អ ជាអ្នកប្រាថ្នាសេចក្ដីសុខ សេចក្ដីចំរើន ប្រាថ្នាឲ្យរួចចាកទុក្ខទាំងពួង គួរតែជៀសអំពីទោសមិច្ឆាទិដ្ឋិនោះ ដោយសព្វគ្រប់; កាលបើជាច្បាស់ហើយ ត្រូវកុំធ្វើខ្លួនឲ្យជាមនុស្សមិច្ឆាទិដ្ឋិឡើយ ឬ ពួកជនណា ធ្លាប់ជាអ្នកមិច្ឆាទិដ្ឋិស្រាប់ហើយ ក៏គួរលះបង់មិច្ឆាទិដ្ឋិនោះចេញ ហើយសមាទានកាន់យកសម្មាទិដ្ឋិវិញ ទើបនឹងរួចចាកទុក្ខទាំងពួងផង ឈ្មោះថាជាអ្នកមិនមែនជាចំរូង ឬមិនមែនជាជន្លត់ក្នុងសាសនាផង; ព្រោះថាព្រះពុទ្ធសាសនានៅប្រតិស្ឋានក្នុងទីណា ទីនោះបើមានមនុស្សមិច្ឆាទិដ្ឋិច្រើន ព្រះពុទ្ធសាសនាមិនអាចនឹងប្រតិស្ឋិតទៅបានដោយស្រួលទេ ។

មួយវិញទៀត មនុស្សមិច្ឆាទិដ្ឋិនេះរាប់ថាជាបុគ្គលអន្ធពាលដែលអ្នកប្រាជ្ញតែងតិះដៀលថាជា "មនុស្សទ្រុស្ដលោក" គឺគ្រាន់តែកើតមកជាមនុស្សឲ្យបង្អៀតក្នុងលោកមិនបានធ្វើលោកនេះឲ្យចំរើនរុងរឿងឡើយ ។ ខ្ញុំនឹងអធិប្បាយចំពោះពាក្យថា "មនុស្សទ្រុស្ដលោក" តទៅ:-

ត្រង់ពាក្យថា "លោក" ក្នុងទីនេះ បើពោលដោយព្យញ្ជនៈ បានដល់ទីនៅអាស្រ័យរបស់សត្វទាំងឡាយ, បើពោលដោយអត្ថ បានដល់ពួកសត្វដែលនៅលើផែនដី ។ ពាក្យថា "មនុស្សទ្រុស្ដលោក"

សំដៅយកមនុស្សដែលមានយោបល់យល់ខុសប្រព្រឹត្តធ្វើតែសេចក្តីអា-
ក្រក់ដោយកាយ វាចា ចិត្ត ជាប្រក្រតីនោះឯង ៗ ឯលោកទីដ៏រុងរឿងថ្កុំ
សោភស្ងួននោះ រមែងពណ្ណលម្អតអំពីពួកមនុស្សៈដោយច្រើនក្រៃលែង
ជាងរបស់ឯទៀត ព្រោះថាបើមនុស្សទាំងឡាយជាបណ្ឌិតមានសេចក្តី
យល់ឃើញត្រូវ តាំងនៅក្នុងសីលធម៌ មានហិរិ សេចក្តីខ្មាស, ឱត្តប្ប
សេចក្តីក្រែងខ្លាចចំពោះបាបកម្ម គឺសេចក្តីអាក្រក់ដែលជាប់ជិតស្អិតនៅ
ក្នុងដួងចិត្តហើយ, រមែងមិនប្រាថ្នាដើម្បីកេងរៀងបៀតបៀនគ្នា មិនមាន
សេចក្តីរង្កៀសសង្ស័យដល់គ្នានឹងគ្នារៀងកល់ខ្លួន ប្រកបការចិញ្ចឹមជីវិត
ក៏ដោយផ្លូវសុចរិតយុត្តិធម៌ ព្រមទាំងធ្វើការទំនុកបំរុងដល់គ្នានឹងគ្នាក្នុង
សោមវិបត្តិ ដូចគ្រោះភ័យ អគ្គិភ័យនិងឧទកភ័យជាដើម; កាលបើពួក
មនុស្សប្រព្រឹត្តដូច្នេះ លោកឈ្មោះថាមានសេចក្តីរុងរឿង, ចំណែក
សត្វដែលអាស្រ័យនៅក្នុងលោកនោះ ក៏បានសេចក្តីសុខប្រាសចាកទុក្ខ
ភ័យន្តរាយ ឧបទ្រពគ្រប់យ៉ាង ៗ បើពួកជនច្រើនតែជាមនុស្សពាលមាន
សេចក្តីប្រកាន់ខុសថាជាត្រូវ ប្រព្រឹត្តសេចក្តីអាក្រក់ដោយផ្លូវកាយ,
វាចា, ចិត្ត, ប្រាថ្នាគិតធ្វើការអ្វី បំណងយកតែប្រយោជន៍ផ្ទាល់ខ្លួនម្យ៉ាង
គ្រង់ប្រយោជន៍ដល់ជាតិនិងសាសនាមិនគិតសោះ កាលបើយ៉ាងនេះសត្វ
ក្នុងលោករមែងបានទទួលសេចក្តីក្តៅក្រហាយខាងចិត្ត ព្រោះហើយ
លោកក៏មិនមានដំណើរជឿនលឿនទៅរកសេចក្តីរុងរឿងចាំមួនបាន មាន

តែអ៊ីប្បុនថយចុះដោយលំដាប់ ព្រោះហេតុនោះបានជាបណ្ឌិតតិះដៀល ជនពាលដែលមានសេចក្ដីយល់ខុសថាជា "មនុស្សទ្រស្ដលោក" ។ មួយទៀតមនុស្សពាលជាមិច្ឆាទិដ្ឋិនេះ ប្រៀបដូចជាព្រៃស្បាតដែលកើតមកគ្រាន់តែសុកស្មាញក្នុងទីកន្ទន់ប៉ុណ្ណោះ, ការដែលប្រៀបដូច្នេះ ក៏គ្រាន់តែជាពាក្យឧបមាទេ, បើតាមសេចក្ដីពិត ជនពាលនោះឯង រមែងសុកស្មាញក្រៃលែងជាងព្រៃស្បាតឬក្រៃលែងជាងសត្វតិរច្ឆានទៅទៀត ព្រោះព្រៃស្បាតទោះជាសុកស្មាញយ៉ាងណា ក៏គង់តែមិនចេះបៀតបៀនមនុស្សក្នុងលោកឲ្យសាបសូន្យឡើយ, គង់មានប្រយោជន៍ គេយកទៅធ្វើជារបងសំរាប់ការពារស្រែមានពោតជាដើមបានខ្លះ, ចំណែកសត្វតិរច្ឆានពួកខ្លះ សូម្បីខ្លួនវាស្លាប់ហើយ គេមិនអាចប្រើប្រាស់វាបានក៏មែនហើយ តែស្បែកឆ្អឹងនឹងស្នែងរបស់វា ក៏គង់គេយកទៅធ្វើជាគ្រឿងប្រដាប់សំរាប់ប្រើប្រាស់បានខ្លះ, ឯជនពាលនឹងយកទៅធ្វើដូច្នោះមិនបាន មានតែបណ្ដាលទុក្ខទោសក្ដៅក្រហាយដល់អ្នកដទៃ កើតមកគ្រាន់តែជាព្រៃក្នុងលោកប៉ុណ្ណោះឯង ។

មួយវិញទៀត បុគ្គលពាលជាមិច្ឆាទិដ្ឋិនោះ មិនមែនគ្រាន់តែធ្វើលោកឲ្យដល់នូវសេចក្ដីសាបសូន្យ ឬក៏ដូចជាចំរូងទីនជង្គត់ក្នុងសាសនាប៉ុណ្ណោះទេ តែងធ្វើខ្លួនឯងឲ្យបានទទួលទុក្ខទោសក្នុងបច្ចុប្បន្នទាំងបរលោកថែមទៀតផង ។

ទោសមិច្ឆាទិដ្ឋិដូចសំដែងមកនេះ ជាបរិយាយដោយរួបរួមមិនបានញែកចេញឲ្យឃើញផ្សេងៗពីគ្នាថា មិច្ឆាទិដ្ឋិណាមានទោសយ៉ាងណាៗ ក៏នៅឡើយទេ ។ អំពីនេះនឹងសំដែងអំពីទោសមិច្ឆាទិដ្ឋិ ឲ្យឃើញផ្សេងៗគ្នា តាមសេចក្ដីដែលព្រះសរិមង្គលាចារ្យៈលោកបានដកស្រង់ពីគម្ពីរផ្សេងៗ មករៀបរៀងទុកក្នុងគម្ពីរមង្គលត្ថទីបនី ត្រង់វិនយកថាដូចមានបាឡីជាដើមថា: ឯកច្ចា មិច្ឆាទិដ្ឋិ សគ្គាវរណា ចេវ ហោតិ មគ្គាវរណា ច: ឯកច្ចា មគ្គាវរណាវ ន សគ្គាវរណា (សេចក្ដីថា) មិច្ឆាទិដ្ឋិពួកខ្លះ ឃាត់សួគ៌ផង ឃាត់មគ្គផង, ពួកខ្លះឃាត់តែមគ្គម្យ៉ាង មិនបានឃាត់សួគ៌ទេ ។

មិច្ឆាទិដ្ឋិពួកណា ឃាត់សួគ៌ផង ឃាត់មគ្គផង? មិច្ឆាទិដ្ឋិពួកណា ឃាត់តែមគ្គមិនឃាត់សួគ៌?

បណ្ដាមិច្ឆាទិដ្ឋិទាំងនោះ, អហេតុកទិដ្ឋិ អកិរិយទិដ្ឋិ និង នត្ថិកទិដ្ឋិ ទាំង ៣ នេះ ឃាត់សួគ៌ផង ឃាត់មគ្គផង គឺស្ទះទប់គតិរបស់សត្វមិនឲ្យទៅសោយសម្បត្តិសុខក្នុងស្ថានសួគ៌ ទាំងមិនឲ្យលុះមគ្គផលជាន់ខ្ពស់បានឡើយ; ឯ អនិយតមិច្ឆាទិដ្ឋិ និង និយតមិច្ឆាទិដ្ឋិទាំង ២ នេះ ក៏ឃាត់សួគ៌ និងមគ្គដែរ, ប៉ុន្តែបើនិយាយពីទោសតូចនិងទោសធំ អនិយតមិច្ឆាទិដ្ឋិ មានទោសតូច, និយតមិច្ឆាទិដ្ឋិមានទោសធំ ។ ពិតដូច្នោះមែន ព្រះសរិ-
មង្គលាចារ្យ លោកក៏បានពោលថា: អនន្តរិយកម្មតោបិ និយតមិច្ឆាទិដ្ឋិ

មហាសាវជ្ជតរំ វេទិតព្វំ (សេចក្តីថា) លោកអ្នកប្រាជ្ញមានប្រាជ្ញាគួរជ្រាបថា និយតមិច្ឆាទិដ្ឋិ មានទោសធំជាងអនន្តរិយកម្មទៅទៀត ។ បានជាពោលដូច្នោះ ព្រោះអាងព្រះពុទ្ធដីកាដែលសម្តេចព្រះឈ្នះមារជាម្ចាស់ត្រាស់ទុកក្នុងគម្ពីរឯកនិបាតអង្គុត្តរថា: នាហំ ភិក្ខវេ អញ្ញំ ឯក-ធម្មំបិ សមនុបស្សាមិ យំឯវំ មហាសាវជ្ជំ, យថយិទំ ភិក្ខវេ មិច្ឆាទិដ្ឋិ; មិច្ឆាទិដ្ឋិបរមានិ ភិក្ខវេ វជ្ជានិ (សេចក្តីថា) ម្នាលភិក្ខុទាំងឡាយ, តថា-គតបានពិនិត្យរកមើលមិនឃើញមានធម៌ដទៃឯណា សូម្បីតែធម៌មួយដែលមានទោសធំ ឲ្យដូចជានិយតមិច្ឆាទិដ្ឋិនេះឡើយ; ម្នាលភិក្ខុទាំងឡាយ ទោស (ដែលធំ) បំផុត ស្រេចហើយត្រឹមនិយតមិច្ឆាទិដ្ឋិ ។

ព្រះពុទ្ធភាសិតដែលបានលើកមកសំដែងអាងនេះ គួរមានសេចក្តីសង្ស័យកើតឡើងដល់ពុទ្ធបរិស័ទ ដែលបានមើលឬបានស្តាប់ថា អនន្តរិយកម្ម៥យ៉ាងគឺ: មាតុឃាត= សម្លាប់មាតា១ បិតុឃាត= សម្លាប់បិតា១ អរហន្តឃាត= សម្លាប់ព្រះអរហន្ត១ លោហិតុប្បាទ= ប្រទូស្តបំពោះព្រះសម្ពុទ្ធ ធ្វើឲ្យពុះពង់ចេញព្រះលោហិត១ សង្ឃភេទ= បំបែកសង្ឃ១ កម្មទាំង៥យ៉ាងនេះ ជាអំពើមានទោសធំ, ចុះនិយតមិច្ឆា-ទិដ្ឋិនុ៎ះឯង ដែលទ្រង់សំដែងថាមានទោសធំជាងអនន្តរិយកម្មទៅទៀត តើព្រោះហេតុដូចម្តេច?

ទីនេះវិសជ្ជនាប្រស្នានេះ តាមន័យដែលមានមកក្នុងអដ្ឋកថា និងដីកា នៃឯកនិបាតអង្គុត្តរនោះ ដូចមានសេចក្តីតទៅនេះ :

និយតមិច្ឆាទិដ្ឋិ បានជាព្រះអង្គសំដែងថាមានទោសធំជាងអនន្តរិយកម្ម ព្រោះអនន្តរិយកម្មនោះ ជាអំពើមានទោសអាចកំណត់ទី និងកំណត់ពេល ដែលសត្វទទួលនូវទុក្ខបាន, ចំណែកនិយតមិច្ឆាទិដ្ឋិមិនកំណត់ទីមិនកំ-ណត់ពេលទេ, មែនពិតបណ្តាអនន្តរិយកម្ម ៥ នោះកម្ម ៤ យ៉ាងគឺមាតុឃាត, បិតុឃាត, អរហន្តឃាត លោហិតុប្បាទ សម្តេចព្រះជិនស្រីត្រាស់ថា ជាអំពើនាំសត្វឲ្យទៅកើតក្នុងនរកតែមានកំណត់ តែមុខជានឹងរួចចាកទុក្ខបាន, ចំណែកសង្ឃភេទកម្មញ៉ាំងសត្វឲ្យស្ថិតនៅក្នុងនរកអស់កំណត់ ១ កប្បប៉ុណ្ណោះ ៗ ឯនិយតមិច្ឆាទិដ្ឋិនោះ នឹងរកទីកំណត់ រកទីផុតរួចចាកទុក្ខឲ្យដូចជាអនន្តរិយកម្មមិនមានឡើយ ព្រោះនិយតមិច្ឆាទិដ្ឋិ លោកថាជាឫសគល់នៃសង្សារវដ្ត, ចំណែកសត្វដែលប្រកបដោយនិយតមិច្ឆាទិដ្ឋិនេះ មិនអាចនឹងរួចចេញចាកភពវដ្តសង្សារ ទៅតាំងនៅក្នុងស្ថានព្រះនិព្វានបានទេ តែងអន្ទោលទៅមកយោងយកកំណើតកើតស្លាប់ក្នុងវាលវដ្តសង្សារនូវទុក្ខលំបាករកកំណត់មិនបាន បើអ្នកណាចូលទៅសេពគប់នឹងបុគ្គលជានិយតមិច្ឆាទិដ្ឋិ នោះ នឹងដឹកនាំអ្នកនោះឯងឲ្យប្រតិបត្តិខុសផ្លូវដ៏ប្រពៃ គឺអដ្ឋង្គិកមគ្គ មួយទៀត បុគ្គលប្រកបដោយនិយតមិច្ឆាទិដ្ឋិ រែងនឹងបានទៅកើតក្នុងស្ថានសួគ៌ រែងបានលុះមគ្គផល កាលបើកប្ប

វិនាសដោយភ្លើងនេះ ពួកមហាជននាំគ្នាចំរើនឈាន ហើយបានទៅកើតក្នុងព្រហ្មលោកទាំងអស់គ្នា ចំណែកខាងបុគ្គលជានិយតមិច្ឆាទិដ្ឋិទៅកើតឯបិដ្ឋិចក្កវាឡ គឺចក្កវាឡនានាក្រៅអំពីចក្កវាឡដែលភ្លើងនេះប្រល័យកល្បកាលភ្លើងប្រល័យកល្បនេះរាលទៅដល់បិដ្ឋិចក្កវាឡនោះ សត្វជានិយតមិច្ឆាទិដ្ឋិអណ្តែតទៅនៅក្នុងអាកាសជាទីរលមួយ ហើយនេះដោយអំណាចកំលាំងកម្មរបស់ខ្លួនឯង ។ និយតមិច្ឆាទិដ្ឋិមិនមានទីកំណត់ដែលនឹងនាំសត្វប្រថាគទុក្ខដូចសំដែងមកនេះឯង ទើបព្រះលោកគ្គមហាវីរជាម្ចាស់ត្រាស់ថា និយតមិច្ឆាទិដ្ឋិមានទោសធំបណ្តាប់ ។

សុទកាមបុគ្គល គួរគេចវៀរចៀសអំពីនូវបុគ្គលជាមិច្ឆាទិដ្ឋិឲ្យផុតស្រឡះចេញ ព្រោះជនពួកនេះរមែងធ្វើបុគ្គលដែលបានសេពគប់ឬលបគំនិតផងនោះ ឲ្យមានសេចក្តីអន្តរាយជាច្រើនប្រការ ។ ហេតុនោះបានជាអដ្ឋកថាចារ្យលោកសំដែងដាស់តឿនក្រើនរំឮក ទុកក្នុងអដ្ឋកថានៃសាមញ្ញផលសូត្រថា :

តស្មា អកល្យាណជនំ អាសីវិសមិវោរគំ

អារកា បរិវជ្ជេយ្យ ភូតិកាមោ វិចក្ខណោ

អកល្យាណជនរមែងជាបច្ច័យនៃភាពជាផ្គត់ក្នុងសង្សារ ព្រោះហេតុនោះ អ្នកប្រាជ្ញមានប្រាថ្នានូវសេចក្តីចំរើន (ដោយគុណមានសីល

ជាដើម) គប្បីវៀសវាងកុំឲ្យឆ្ងាយខ្លួនអ្នកលក្ខណៈគុណនោះ ដូចបុគ្គលវាងវៀស អង្គាសដែលមានការសពិសដូច្នោះចឹង ។

មិត្តទុច្ចរិតថា គឺសំដៅដល់អំពើមិច្ឆាទិដ្ឋិ មិនបានពិស្តារគោរស ណាទេ ក៏មនុស្សដាច់ដោយសោវត្ថិសម្ដែងតែប៉ុណ្ណោះ ។

# ព្រះគ្រូមហាបទុម មាឃ-ស៊ុន រៀបរៀង

(តមក)

គឺគួរពោលតែកថា ដែលជាហេតុណានាំជនអ្នកមិនទាន់ព្រមព្រៀងឲ្យព្រមព្រៀងគ្នាឡើង នាំជនអ្នកព្រមព្រៀងស្រាប់ហើយឲ្យរឹតតែជិតស្និទ្ធចំរើនឡើង ព្រោះសេចក្តីសាមគ្គីជាកិច្ចយ៉ាងសំខាន់ អាចញ៉ាំងប្រយោជន៍ទោះបីតិចច្រើនឲ្យសម្រេចបានដោយងាយ; ហេតុនេះការលះបង់សំដីញុះញង់សិកសៀត ហើយពោលតែកថាដែលជាហេតុញ៉ាំងសេចក្តីសាមគ្គីឲ្យកើតក្នុងសន្តាននោះទើបចាត់ជាគុណធម៌ប្រកបរឿយៗ ។

## ៥— មច្ឆេរវិនយេ យុត្តៈ

" សេចក្តីចែកបន្ទុកក្នុងការនាំបង់នូវសេចក្តីកំណាញ់ "

ខ នេះបានដល់ការបរិច្ចាគវត្ថុរបស់ខ្លួនឲ្យទៅជាទានដល់អ្នកដទៃ; ចេតនាដែលជាហេតុលោកឲ្យឈ្មោះថាទានៗពោលដោយអាការមាន ២ គឺ ការឲ្យដោយបូជាគុណ ដូចបុត្តធីតាជូនវត្ថុរបស់ខ្លួនចំពោះមាតាបិតាជាដើម ១ ការឲ្យដោយសេចក្តីសង្គ្រោះសម្រាប់អ្នកមានឋានៈខ្ពស់ គប្បីឲ្យដល់បុគ្គលទាបជាងខ្លួន ឬមានឋានៈស្មើគ្នា ១ ។ ទាននេះកាលបើញែកចេញទៅតាមចំណែកនៃការបរិច្ចាគ មានពីរប្រភេទ គឺសាធារណទាន ១ អសាធារណទាន ១; សាធារណទាន = ការឲ្យនូវទៅមិនបានចំពោះរូប

បានដល់ការបរិច្ចាគទ្រព្យកសាងឬជួសជុលអារាម ដែលជាទីសម្រាប់បំពេញព្រហ្មវិហារធម៌ ទីនេះជាទីសម្រាប់បំពេញបុណ្យកុសលរបស់ជនទូទៅ ឬការបំណាយធនធានសាងរោងព្យាបាល ដែលជាទីបំបាត់រោគាព្យាធិរបស់ពួកជនផ្សេងៗ សាងរោងរៀនសិល្បវិទ្យាសម្រាប់កុលបុត្តទាំងការសាងស្ពានសង់សាលាសំណាក់ លើកថ្នល់ ជីកអណ្តូងទឹកដែលជាការឲ្យសេចក្តីសុខដល់ជនទូទៅមិនចំពោះមុខទាំងអស់នេះ ចាត់ជាសាធារណទានចំណែកមួយ ។

ម្យ៉ាងទៀត ការសាងសៀវភៅគម្ពីរក្បួនខ្នាតផ្សេងៗ ឬសំដែងពាក្យប្រដៅក្នុងផ្លូវព្រះពុទ្ធសាសនា ដែលជាសេចក្តីប្រតិបត្តិដឹកនាំឲ្យតាំងនៅក្នុងសេចក្តីល្អ ចែកដល់ពួកជនទូទៅ ក៏ចាត់ជាសាធារណទានដូចគ្នាដែរ ។

ឯអសាធារណទាននោះ គឺការឲ្យដោយចំពោះ ដូចការឲ្យដោយបូជាគុណដល់បុគ្គលមានមាតាបិតានឹងគ្រូឧបជ្ឈាយាចារ្យជាដើម ឬឲ្យដល់បុគ្គលអ្នកទីទាល់ក្រក្រលំបាកខ្សត់ខ្សោយទ្រព្យសម្បត្តិ ឲ្យបានទទួលសេចក្តីសុខស្រួលបាន ឬឲ្យដល់បុគ្គលអ្នកទុព្វលភាពដែលផុតគ្រឿងចិញ្ចឹមជីវិត; ការដែលឲ្យចំពោះរូបដូច្នេះ ចាត់ជាអសាធារណទាន ។ ការឲ្យនេះ ត្រូវអាស្រ័យទឹកចិត្តរបស់អ្នកបរិច្ចាគជ្រះថ្លាឲ្យគ្រឿងឧបភោគនិងគ្រឿងបរិភោគ ដែលជារបស់គាប់ចិត្តប្រយោជន៍ឲ្យសម្រេច

ផលអ្នកទទួល មិនមែនសំដៅការបរិច្ចាគវត្ថុដែលឲ្យទោសផលអ្នកទទួល មានឲ្យទឹកស្រវឹងជាដើមឡើយ ។ ប្រការមួយទៀត មិនមែនសំដៅយកការបរិច្ចាគ ដើម្បីបំពេញសេចក្ដីលោភដែលខុសសេចក្ដីប្រាថ្នារបស់ការបរិច្ចាគទាន ព្រោះការបរិច្ចាគទានដើម្បីបន្ទោបង់នូវសេចក្ដីកំណាញ់តែប៉ុណ្ណោះមិនមែនបំពេញសេចក្ដីលោភឲ្យចំរើនឡើង ដូចការបរិច្ចាគដោយប្រាថ្នាយកតម្លៃផលអំពីអ្នកទទួល គឺយកទ្រព្យទៅផ្ញើក្នុងធនាគារដើម្បីដកយកតម្លៃដូច្នោះឡើយ ព្រោះការឲ្យបែបនោះឈ្មោះថាមិនបានប្រព្រឹត្តទៅដោយសេចក្ដីសង្គ្រោះដោយពិត ឬ បរិច្ចាគដោយសេចក្ដីប្រាថ្នាចង់មានទ្រព្យសម្បត្តិក្នុងជាតិមុខ ដោយមានជម្រេះថា ជាតិនេះខ្លួនជាអ្នកខ្សត់ខ្សោយសម្បត្តិហើយក៏បរិច្ចាគទៅ, ការបរិច្ចាគដូចពោលមកនេះមែនមិនប្រពៃ កាលបើពោលដល់ផលការបរិច្ចាគហើយ ក៏មែនមាននៅជាធម្មតា តែមិនគួរបរិច្ចាគឲ្យជាការទំនុកបំរុងសេចក្ដីលោភ បើបរិច្ចាគដើម្បីកាត់ ឬ លះបង់នូវកិលេស គឺសេចក្ដីកំណាញ់នោះទើបជាការប្រពៃ ។ ការបរិច្ចាគទានដោយអាការដែលល្អទាំង ២ ប្រការដែលពោលហើយនេះ ទើបឈ្មោះថាជាទានដ៏ល្អ ហៅថាសប្បុរិសទាន ។ សូម្បីពុទ្ធគាថាក៏មានត្រាស់ទុកថា វិចេយ្យ ទានំ សុគតប្បសត្ថំ ការពិចារណាមុនសិនហើយទើបឲ្យ ព្រះសុគតទ្រង់សរសើរ ដូច្នេះឯង, សេចក្ដីនេះសំដែងឲ្យឃើញថាការបរិច្ចាគនោះ

ក៏ត្រូវតែជ្រើសរើសបុគ្គលនិងស្ថានដែលគួរឲ្យ ៗ ទានជាគុណជាតិ មានប្រយោជន៍ក្នុងការទាញទឹកចិត្តអ្នកដទៃឲ្យស្រឡាញ់រាប់អានជាដើម ហេតុនេះសាធុជនគួរប្រកបឲ្យកើតឡើងហើយ ៗ សូម្បីព្រះពុទ្ធសាសនា ដែលបានឋិតនៅរហូតមកដល់សព្វថ្ងៃនេះ ក៏អាស្រ័យមានការបរិច្ចាគ របស់អ្នកមានសទ្ធា ទើបបានជាកំឡាំងជួយឧបត្ថម្ភដល់ជនទូទៅ បើ ពោលដោយសេចក្ដីពិតគឺផលនៃការបរិច្ចាគនេះ រមែងបញ្ចេញផលឲ្យ ឃើញបានទាំងបំណែកខាងក្នុងនិងខាងក្រៅ គឺការបានពិចារណាហើយ ទើបឲ្យ ទឹកចិត្តក៏រមែងកើតសេចក្ដីជ្រះថ្លារីករាយក្នុងការបរិច្ចាគ ព្រោះ ខ្លួនឯងបានស្វែងរកទ្រព្យសម្បត្តិមកដើម្បីទំនុកបំរុងខ្លួនឲ្យបានទទួលសុខ ក្នុងបច្ចុប្បន្នព្រមទាំងបានចែកទ្រព្យសម្បត្តិរបស់ខ្លួននោះឲ្យដល់ជនដទៃ ដើម្បីប្ដូរយកសេចក្ដីសុខទៀត យ៉ាងនេះឈ្មោះថាបានបំពេញប្រយោជន៍ ទាំង ២ គឺអត្តត្ថៈ ប្រយោជន៍ខ្លួន បរត្ថៈ ប្រយោជន៍អ្នកដទៃ ៗ ព្រោះ ហេតុនោះ ការបរិច្ចាគទានរបស់ខ្លួនឲ្យជាប្រយោជន៍ដល់អ្នកដទៃ រមែង ជាផ្លូវកំចាត់បោលនូវមន្ទិល គឺសេចក្ដីកំណាញ់របស់ខ្លួនចេញបាន ទើប ជាកុសលដែលសាធុជនគួរប្រកបឲ្យមានក្នុងខន្ធសន្តាន ៗ

# សច្ចវាចា

"ពាក្យសត្យ ឬ សំដីពិត"

សេចក្ដីជាសំដីពិតនេះ ជាគុណជាតិប្រសើរបរិសុទ្ធប្រាសចាក សេចក្ដីសៅហ្មង ដូចនៃមណីដែលមានពន្លឺស្អាត គាបញ្ញាំងប្រយោជន៍ ខ្លួននិងប្រយោជន៍លោកឲ្យសម្រេចបាន ជាហេតុនៃសេចក្ដីទុកចិត្តរបស់ អ្នកដទៃនិងធ្វើសេចក្ដីរីកយឲ្យកើតដល់ខ្លួន ។ បុគ្គលឯណាមិនពោលនូវ ពាក្យសត្យ រមែងធ្វើខ្លួនឲ្យបានទទួលផលគឺសេចក្ដីវិនាស ព្រោះវាចា ដែលមិនប្រកបដោយសច្ចៈ រមែងជាហេតុនាំឲ្យកើតទោសចំពោះខ្លួន និងនាំឲ្យខានចិត្តរបស់ពួកជនដែលបានស្ដាប់ សូម្បីលាភសក្ការៈដែល បម្រុងនឹងកើតឡើងក៏ត្រឡប់ជាខានបាន តាំងលាភសក្ការៈដែលកើតមាន ស្រាប់ហើយក៏រមែងសាបសូន្យ, រួមសេចក្ដីឲ្យឃើញបានដោយងាយ មក ក៏គឺជាហេតុនាំឲ្យវិនាសចាកសម្បត្តិទាំង ៣ គឺ និព្វានសម្បត្តិ ១ ទេវសម្បត្តិ ១ មនុស្សសម្បត្តិ ១ ព្រោះពាក្យមិនប្រកបដោយសច្ចៈនោះ ជាវាចារបស់ពួកជនពាលប្រកាន់កាន់ ។

ការពោលពាក្យពិតជាអំណោយប្រយោជន៍យ៉ាងសំខាន់ តែសេចក្ដី ពិតនោះសំគាល់យកត្រង់សេចក្ដីពិតក្នុងវត្ថុដែលប្រពៃ សមតាមពុទ្ធ- ភាសិតថា សច្ចេ អត្ថេ ច ធម្មេ ច អាហុ សន្តោ បតិដ្ឋិតា

សេចក្ដីថា "សប្បុរសទាំងឡាយតាំងសឹងហើយ ក្នុងសច្ចៈដែល ជាអត្ថនិងធម៌" ។ ហេតុនេះគប្បីឃើញតួយ៉ាង សច្ចៈដែលប្រកបដោយ អត្ថនិងធម៌ ដូចពាក្យរបស់ឧបតិស្សបរិព្វាជក និងកោលិតបរិព្វាជក ដែល ធ្វើកតិកាប្ដេជ្ញាដល់គ្នានឹងគ្នាថា យើងទាំងពីរនាក់ដែលដើរទៅស្វែងរក មោក្ខធម៌នេះ បើអ្នកណាបានសម្រេចធម៌មុន អ្នកនោះត្រូវត្រឡប់មក ប្រាប់ដល់គ្នានឹងគ្នា ដូច្នេះ; ចំណែកខាងឧបតិស្សបរិព្វាជកបានស្ដាប់ធម៌ ទេសនារបស់ព្រះអស្សជិត្ថេរបានលុះអមតធម៌មុន ក៏បានទៅសំដែង ប្រាប់ដល់កោលិតបរិព្វាជកជាសម្លាញ់តាមសេចក្ដីប្ដេជ្ញា កោលិតបរិព្វា-ជកក៏បានលុះធម៌ដូចគ្នា, នេះឯងគឺសេចក្ដីពិតដែលជាអត្ថនិងដែលជា ធម៌ ។ ម្យ៉ាងទៀត ពាក្យសច្ចៈដែលជាប្រយោជន៍ខ្លួននិងជាប្រយោជន៍ លោកឈ្មោះថាប្រកបដោយអត្ថ ។ គុណគឺសេចក្ដីល្អឈ្មោះថាជាធម៌, ការពោលពាក្យសច្ចៈដែលប្រកបដោយអត្ថនិងធម៌នេះ សាធុជនប្រុស ស្រីគួរខំប្រឹងបណ្ដុះបណ្ដាលឲ្យកើតឡើងក្នុងសន្ដាន គឺកាលបើសច្ចៈធម៌ ដែលមិនទាន់មាន គួរធ្វើឲ្យកើតមានឡើង បើកើតមានស្រាប់ហើយ គួរខំប្រឹងថែរក្សាទុកកុំឲ្យសាបសូន្យខាតខូចទៅឡើយ ព្រោះសេចក្ដី ពិតត្រង់នេះ ជាធម្មជាតគួរជាទីប្រាថ្នារបស់ពួកសប្បុរសទាំងពួង សូម្បី ព្រះដ៏មានព្រះភាគក៏ទ្រង់ត្រាស់សរសើរទុកថា សច្ចំ វេ អមតា វាចា "វាចាពិតជាវាចាមិនស្លាប់ គឺជាវាចាញុំាងប្រយោជន៍ឲ្យសម្រេច" ។

(មាឃក)